# សុត្តន្តបិដក





១៦

# SUTTANTA PITAKA

# ព្រះ

# ត្រៃបិដកបាលី

## និង

# សេចក្តីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក

# ទីឃនិកាយ   តតយវគ្គ

# មហាវគ្គ

# ១៦

*មហាបទានសូត្រ   មហានិទានសូត្រ*
*និង   មហាបរិនិព្វានសូត្រ*



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

# DĪGHANIKĀYA

# TATIYABHĀGA

# MAHĀVAGGA

# 16

## MAHĀPADĀNASUTTA MAHĀNIDĀNASUTTA

## & MAHĀPARINIBBĀNASUTTA

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមវ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammayutt Sangkat Chatumuk Khan Daun Penh P.Penh

# ទំព័រទទេ

# សេចក្តីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ ល គឺជាជើងរបស់ព្យញ្ជនៈ ម ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សង្ខិកាច្បាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## ទីឃនិកាយ  តតិយភាគ

## មហាវគ្គ

## ១៦

## មហាបទានសូត្រ  បហានិទានសូត្រ

## និង  មហាបរិនិព្វានសូត្រ

ព. ស.  ២៥១៤

# សុត្តន្តបិដកេ ទីឃនិកាយស្ស

## តតិយោ ភាគោ

## មហាវគ្គោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## មហាបទានសុត្តំ បឋមំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ ករេរិកុដិកាយំ ។ អថខោ សម្ពហុលានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ ករេរិមណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ បុព្វេនិវាសប្បដិសំយុត្តា ធម្មី កថា ឧទបាទិ ឥតិបិ[១] បុព្វេនិវាសោ ឥតិ-បិ[២] បុព្វេនិវាសោតិ ។ អស្សោសិ ខោ ភគវា

១-២ ឱ. បិសទ្ទោ ន ទិស្សតិ ។

# សុត្តន្តបិដក ទីឃនិកាយ

# តតិយភាគ

# មហាវគ្គ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*
*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

# មហាបទានសូត្រ ទី ១

[១] *ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យ ១ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងករេរិកុដិកា*[១] *ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយ ច្រើនរូប ត្រឡប់មកពីបិណ្ឌបាត (បានធ្វើភត្តកិច្ចស្រេចហើយ) ក្នុងវេលាក្រោយភត្ត ក៏អង្គុយប្រជុំគ្នា ក្នុងសាលាសម្រាប់អង្គុយ ដែលគេធ្វើនៅជិតករេរិមណ្ឌល ហើយក៏កើតជាធម្មីកថា គឺការនិយាយអំពីធម៌ ប្រកបដោយបុព្វេនិវាសថា បុព្វេនិវាស ដូច្នេះខ្លះ បុព្វេនិវាស ដូច្នេះខ្លះ ។ ព្រះមានព្រះភាគ ទ្រង់បានឮពាក្យចរចានេះ របស់ភិក្ខុទាំងនោះ ដោយព្រះ*

---

១ អដ្ឋកថា ពន្យល់ថា "ករេរិ" ប្រែថា ដើមថ្ងាន់ ។ មណ្ឌលដែលគេកំណត់ដោយដើមថ្ងាន់នោះ ឈ្មោះថា ករេរិមណ្ឌល ។ ករេរិមណ្ឌលនេះឯង តាំងនៅទៀបទ្វារកុដិនោះ បានជាហៅថា ករេរិកុដិកា ។ នេះជាកុដិធំ ១ ដ្បិតក្នុងវិហារជេតពនមានកុដិធំៗ បួន គឺ ករេរិកុដិ ១ កោសម្ពកុដិ ១ គន្ធកុដិ ១ សឡលឃរៈ ១ កុដិមួយៗ ធ្វើអស់តម្លៃ ១ សែនកហាបណៈ ។ បណ្តាកុដិទាំងនោះ សឡលឃរៈ ព្រះបាទបសេនទិទ្រង់សាង ។ ក្រៅពីនេះ សុទ្ធតែអនាថបិណ្ឌិកគហបតីសាងទាំងអស់ ។

២



ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ តេសំ ភិក្ខូនំ ឥមំ កថាសល្លាបំ ។ អថខោ ភគវា ឧដ្ឋាយាសនា យេន ករេរិមណ្ឌលមាឡោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឯវំ វុត្តេ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ អម្ហាកំ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តានំ ករេរិមណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ បុព្វេនិវាសប្បដិសំយុត្តា ធម្មី កថា ឧទបាទិ ឥតិបិ បុព្វេនិវាសោ ឥតិបិ បុព្វេនិវាសោតិ អយំ ខោ នោ ភន្តេ អន្តរាកថា វិប្បកតា អថ ភគវា អនុប្បត្តោតិ ។ ឥច្ឆេយ្យាថ នោ តុម្ហេ ភិក្ខវេ បុព្វេនិវាសប្បដិសំយុត្តំ ធម្មឹ កថំ សោតុន្តិ ។ ឯតស្ស ភគវា កាលោ

ទិព្វសោតធាតុដ៏បរិសុទ្ធ កន្លងបង់នូវសោតៈនៃមនុស្សសាមញ្ញ ។ ទើបព្រះមានព្រះភាគ ទ្រង់ក្រោកអំពីអាសនៈ ទ្រង់ចូលសំដៅទៅរោងករេរិ-មណ្ឌល លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់ស៊ប់ហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយប្រជុំគ្នានិយាយពីរឿងអ្វី អន្តរាកថា[១]ដូចម្តេច ដែលអ្នកទាំងឡាយ បញ្ឈប់ទៅវិញ ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយ ត្រឡប់មកពីបិណ្ឌបាត (បានធ្វើភត្តកិច្ចស្រេចហើយ) ក្នុងវេលាក្រោយភត្ត អង្គុយប្រជុំគ្នាក្នុងរោងករេរិមណ្ឌលនេះ ក៏កើតជាធម្មីកថា ប្រកបដោយបុព្វេនិវាសថា បុព្វេនិវាសដូច្នេះខ្លះ បុព្វេនិវាសដូច្នេះខ្លះ បពិត្រព្រះអង្គដ៏ចម្រើន នេះឯងជាអន្តរាកថាដែលខ្ញុំព្រះអង្គទាំងឡាយបញ្ឈប់ ដ្បិតព្រះមានព្រះភាគស្តេចមកដល់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចង់ស្តាប់ធម្មីកថាប្រកបដោយបុព្វេនិវាសដែរឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ កាលនេះជាកាលគួរ ដល់ការធ្វើធម្មីកថានុ៎ះហើយ

---

១ ពាក្យនិយាយពីគុណនិងទោសហើយដាច់ទៅ ។

៣

មហាបទានសុត្តេ បឋមភាណវារំ សត្តសម្មាសម្ពុទ្ធប្បវត្តិ

ឯតស្ស សុគត កាលោយំ ភគវា បុព្វេនិវាសប្បដិសំយុត្តំ ធម្មឹ កថំ ករេយ្យ ភគវតោ វចនំ[១] សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឥតោ សោ ភិក្ខវេ ឯកនវុតោ កប្បោ[២] យំ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ ។ ឥតោ សោ ភិក្ខវេ ឯកត្តឹសោ កប្បោ[៣] យំ សិខី ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ ។ តស្មឹយេវ ខោ ភិក្ខវេ ឯកត្តឹសេ កប្បេ វេស្សភូ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ ។ ឥមស្មឹយេវ ខោ ភិក្ខវេ ភទ្ទកប្បេ កកុសន្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ ។

---

១ ឱ. ម. វចនន្តិ ន ទិស្សតិ ។ ២ ម. ឯកនវុតិកប្បេ ។ ៣ ម. ឯកត្តឹសេ កប្បេ ។

បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ការធ្វើធម្មីកថានុ៎ះហើយ គួរព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ដែលប្រកបដោយបុព្វេនិវាស ភិក្ខុទាំងឡាយស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគហើយ នឹងចងចាំទុក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយចាំស្តាប់ ចូរប្រុងធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោសយ៉ាងហ្នឹងហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីភទ្ទកប្បនេះ (ថយក្រោយទៅ) ៩១ កប្ប ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ រាប់អំពីភទ្ទកប្បនេះទៅ ៣១ កប្ប ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកប្ប ៣១ នោះដែរ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងភទ្ទកប្បនេះឯងព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។

ឥមស្មឹយេវ ខោ ភិក្ខវេ ភទ្ទកប្បេ កោណាគមនោ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ ។ ឥមស្មឹយេវ ខោ ភិក្ខវេ ភទ្ទកប្បេ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ ។ ឥមស្មឹយេវ ខោ ភិក្ខវេ ភទ្ទកប្បេ អហំ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ ។

[២] វិបស្សី ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ ខត្តិយោ ជាតិយា អហោសិ ខត្តិយកុលេ ឧទបាទិ ។ សិខី ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ ខត្តិយោ ជាតិយា អហោសិ ខត្តិយកុលេ ឧទបាទិ ។ វេស្សភូ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ ខត្តិយោ ជាតិយា អហោសិ ខត្តិយកុលេ ឧទបាទិ ។ កកុសន្ធោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ ព្រាហ្មណោ ជាតិយា អហោសិ ព្រាហ្មណកុលេ ឧទបាទិ ។ កោណាគមនោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ ព្រាហ្មណោ ជាតិយា អហោសិ

ម្នាលភិក្ខុទាំងឡាយ ក្នុងភទ្ទកប្បនេះដែរ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ក្នុងភទ្ទកប្បនេះដែរ ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគត អរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោក ក្នុងភទ្ទកប្បនេះដែរ ។

[២] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជាខត្តិយជាតិទ្រង់កើតក្នុងខត្តិយត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាខត្តិយជាតិទ្រង់កើតក្នុងខត្តិយត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាខត្តិយជាតិទ្រង់កើតក្នុងខត្តិយត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណជាតិ ទ្រង់កើតក្នុងព្រាហ្មណៈត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណជាតិទ្រង់កើត

ព្រាហ្មណកុលេ ឧទបាទិ ។ កស្សបោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ ព្រាហ្មណោ ជាតិយា អហោសិ ព្រាហ្មណកុលេ ឧទបាទិ ។ អហំ ភិក្ខវេ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ ខត្តិយោ ជាតិយា អហោសឹ ខត្តិយកុលេ ឧប្បន្នោ ។

[៣] វិបស្សី ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ កោណ្ឌញ្ញោ គោត្តេន អហោសិ ។ សិខី ភិក្ខវេ ភគ-វា អរហំ សម្មាសម្ពុទ្ធោ កោណ្ឌញ្ញោ គោត្តេន អ-ហោសិ ។ វេស្សភូ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ កោណ្ឌញ្ញោ គោត្តេន អហោសិ ។ កកុសន្ធោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ កស្សបោ គោត្តេ-ន អហោសិ ។ កោនាគមនោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ កស្សបោ គោត្តេន អហោសិ ។ កស្សបោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ កស្ស-បោ គោត្តេន អហោសិ ។ អហំ ភិក្ខវេ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ គោតមោ គោត្តេន អហោសឹ[១] ។

១ ឱ. អហោសិន្តិ ន ទិស្សតិ ។

ក្នុងព្រាហ្មណត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណជាតិ ទ្រង់កើតក្នុងព្រាហ្មណត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគត អរហន្តសម្មាសម្ពុទ្ធ ជាខត្តិយ-ជាតិ កើតក្នុងខត្តិយត្រកូល ។

[៣] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មា-សម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកស្សបគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកស្សបគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកស្សបគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគត អរហន្តសម្មាសម្ពុទ្ធ ជាគោតមគោត្រ ។

[៤] វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អសីតិវស្សសហស្សានិ[១] អាយុប្បមាណំ អហោសិ ។ សិខិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សត្តតិវស្សសហស្សានិ អាយុប្បមាណំ អហោសិ ។ វេស្សភុស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សដ្ឋីវស្សសហស្សានិ អាយុប្បមាណំ អហោសិ ។ កក្កុសន្ធស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ចត្តាឡីសវស្សសហស្សានិ[២] អាយុប្បមាណំ អហោសិ ។ កោនាគមនស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស តឹសវស្សសហស្សានិ អាយុប្បមាណំ អហោសិ ។ កស្សបស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស វីសតិវស្សសហស្សានិ[៣] អាយុប្បមាណំ អហោសិ ។ មយ្ហំ ភិក្ខវេ ឯតរហិ អប្បកំ អាយុប្បមាណំ បរិត្តំ លហុកំ យោ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ ។

---

១ ឱ. អសិតឹ វស្សសហស្សានិ ។ ២ ឱ. ចត្តារីសំ វស្សសហស្សានិ ។ ៣ ឱ. វីសតឹ វស្សសហស្សានិ ។

[៤] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ៧ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ៦ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ៤ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ៣ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ២ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ជន្មាយុរបស់តថាគតមានប្រមាណតិច ឆាប់រហ័ស បុគ្គល (ក្នុងសម័យនេះ) ដែលរស់នៅយ៉ាងយូរបានត្រឹម ១០០ ឆ្នាំ និងតិចជាង ១០០ ឆ្នាំ ឬច្រើនជាង ១០០ ឆ្នាំ ក៏មាន (ដោយតិច) ។

៧

មហាបទានសុត្តេ  បឋមភាណវារំ  សត្តសម្មាសម្ពុទ្ធុប្បវត្តិ

[៥] វិបស្សី ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ បាដលិយា មូលេ អភិសម្ពុទ្ធោ ។ សិខី ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ បុណ្ឌរីកស្ស មូលេ អភិសម្ពុទ្ធោ ។ វេស្សភូ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ សាលស្ស មូលេ អភិសម្ពុទ្ធោ ។ កកុសន្ធោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ សិរីសស្ស មូលេ អភិសម្ពុទ្ធោ ។ កោណាគមនោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ ឧទុម្ពរស្ស មូលេ អភិសម្ពុទ្ធោ ។ កស្សបោ ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ និគ្រោធស្ស មូលេ អភិសម្ពុទ្ធោ ។ អហំ ភិក្ខវេ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ អស្សត្ថស្ស មូលេ អភិសម្ពុទ្ធោ ។

[៦] វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ខណ្ឌតិស្សំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ សិខិស្ស ភិក្ខវេ ភគវតោ អរហតោ

មហាបទានសូត្រ ភាណវារៈទី ១ ប្រវត្តិនៃព្រះសម្មាសម្ពុទ្ធ ៧ ព្រះអង្គ

[៥] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមបាដលិព្រឹក្ស (ដើមជ្រនៀង) ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមបុណ្ឌរីកព្រឹក្ស[១] (ដើមស្វាយ-ស) ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមសាលព្រឹក្ស ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមសិរីសព្រឹក្ស (ដើមច្រេស) ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមឧទុម្ពរព្រឹក្ស (ដើមល្វា) ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមនិគ្រោធព្រឹក្ស (ដើមជ្រៃ) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ តថាគត អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមអស្សត្ថព្រឹក្ស (ដើមពោធិ៍បាយ) ។

[៦] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើនឈ្មោះ ខណ្ឌៈ ១ តិស្សៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មា-

---

១ បុណ្ឌរីកសព្ទនេះ បើក្នុងទីឯទៀត ប្រែថា ឈូក-ស ក៏បាន ។ តែក្នុងទីនេះបានជាប្រែថា ស្វាយ-ស ព្រោះអដ្ឋកថា ថា សេតម្ពរុក្ខ នឹងហៅថា សេតម្ពព្រឹក្ស ដូច្នេះវិញក៏បាន ។

៨



សម្មាសម្ពុទ្ធស្ស អភិភូសម្ភវំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ វេស្សភុស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សោណុត្តរំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ កក្កុសន្ធស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស វិធូរសញ្ជីវំ[១] នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ កោនាគមនស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ភិយ្យោសុត្តរំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ កស្សបស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស តិស្សភារទ្វាជំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ មយ្ហំ ភិក្ខវេ ឯតរហិ សារីបុត្តមោគ្គល្លានំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។

---

១ ម. វិធូរសំជីវំ ។

សម្ពុទ្ធ មានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះ អភិភូ ១ សម្ភវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះ សោនៈ ១ ឧត្តរៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះ វិធូរៈ ១ សញ្ជីវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះ ភិយ្យោសៈ ១ ឧត្តរៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះ តិស្សៈ ១ ភារទ្វាជៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ តថាគតមានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះ សារីបុត្ត ១ មោគ្គល្លាន ១ ។

មហាបទានសុត្តេ បឋមភាណវារំ សត្តសម្មាសម្ពុទ្ធប្បវត្តិ

[៧] វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស តយោ សាវកានំ សន្និបាតា អហេសុំ ឯកោ សាវកានំ សន្និបាតោ អហោសិ អដ្ឋសដ្ឋីភិក្ខុសតសហស្សំ ឯកោ សាវកានំ សន្និបាតោ អហោសិ ភិក្ខុសតសហស្សំ ឯកោ សាវកានំ សន្និបាតោ អហោសិ អសីតិភិក្ខុសហស្សានិ ។ វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឥមេ តយោ សាវកានំ សន្និបាតា អហេសុំ សព្វេសំយេវ ខីណាសវានំ ។ សិខិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស តយោ សាវកានំ សន្និបាតា អហេសុំ ឯកោ សាវកានំ សន្និបាតោ អហោសិ ភិក្ខុសតសហស្សំ ឯកោ សាវកានំ សន្និបាតោ អហោសិ អសីតិភិក្ខុសហស្សានិ[១] ឯកោ សាវកានំ សន្និបាតោ អហោសិ សត្តតិភិក្ខុសហស្សានិ ។ សិខិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឥមេ តយោ សាវកានំ សន្និបាតា អហេសុំ សព្វេសំយេវ ខីណាសវានំ ។

---

១ ឱ. អសិតឹ ភិក្ខុសហស្សានិ ។

[៧] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត (ប្រជុំសាវ័ក) ៣ ដង គឺសាវកសន្និបាត មានភិក្ខុចំនួន ៦ លាន ៨ សែនរូបម្តង សាវកសន្និបាត មានភិក្ខុ ១ សែនរូបម្តង សាវកសន្និបាត មានភិក្ខុ ៨ ហ្មឺនរូបម្តង ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទាំង ៣ ដងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត ៣ ដង គឺសាវកសន្និបាត មានភិក្ខុ ១ សែនរូបម្តង សាវកសន្និបាត មានភិក្ខុ ៨ ហ្មឺនរូបម្តង សាវកសន្និបាត មានភិក្ខុ ៧ ហ្មឺនរូបម្តង ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទាំង ៣ ដងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។

១០



វេស្សភុស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
តយោ សាវកានំ សន្និបាតា អហេសុំ ឯកោ សាវ-
កានំ សន្និបាតោ អហោសិ អសីតិភិក្ខុសហស្សានិ
ឯកោ សាវកានំ សន្និបាតោ អហោសិ សត្តតិភិក្ខុ-
សហស្សានិ ឯកោ សាវកានំ សន្និបាតោ អហោសិ
សដ្ឋីភិក្ខុសហស្សានិ ។ វេស្សភុស្ស ភិក្ខវេ ភគវតោ
អរហតោ សម្មាសម្ពុទ្ធស្ស ឥមេ តយោ សាវកានំ
សន្និបាតា អហេសុំ សព្វេសំយេវ ខីណាសវានំ ។
កកុសន្ធស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុ-
ទ្ធស្ស ឯកោ សាវកានំ សន្និបាតោ អហោសិ
ចត្តាឡីសភិក្ខុសហស្សានិ ។ កកុសន្ធស្ស ភិក្ខវេ
ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អយំ ឯកោ
សាវកានំ សន្និបាតោ អហោសិ សព្វេសំយេវ ខីណា-
សវានំ ។ កោណាគមនស្ស ភិក្ខវេ ភគវតោ
អរហតោ សម្មាសម្ពុទ្ធស្ស ឯកោ សាវកានំ

ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មាន សាវកសន្និបាត ៣ ដង គឺសាវកសន្និបាត មានភិក្ខុ ៨ ហ្មឺនរូបម្តង សាវកសន្និបាត មានភិក្ខុ ៧ ហ្មឺនរូបម្តង សាវកសន្និបាត មានភិក្ខុ ៦ ហ្មឺនរូបម្តង ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះវេស្សភូ មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទាំង ៣ ដងនេះ សុទ្ធតែជាខីណាស្រព ទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធ មានសាវកសន្និបាតតែម្តង មានភិក្ខុ ៤ ហ្មឺនរូប ។ ម្នាល ភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះកកុសន្ធៈមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធតែម្តងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុ ទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មាន

សន្និបាតោ អហោសិ តឹសភិក្ខុសហស្សានិ ។ កោណាគមនស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អយំ ឯកោ សាវកានំ សន្និបាតោ អហោសិ សព្វេសំយេវ ខីណាសវានំ ។ កស្សបស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឯកោ សាវកានំ សន្និបាតោ អហោសិ វីសតិភិក្ខុសហស្សានិ ។ កស្សបស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អយំ ឯកោ សាវកានំ សន្និបាតោ អហោសិ សព្វេសំយេវ ខីណាសវានំ ។ មយ្ហំ ភិក្ខវេ ឯតរហិ ឯកោ សាវកានំ សន្និបាតោ អហោសិ អឌ្ឍតេឡសានិ[១] ភិក្ខុសតានិ ។ មយ្ហំ ភិក្ខវេ អយំ ឯកោ សាវកានំ សន្និបាតោ អហោសិ សព្វេសំយេវ ខីណាសវានំ ។

[៨] វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អសោកោ នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ ។ សិខិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ខេមង្ករោ នាម ភិក្ខុ

---

១ ម. អឌ្ឍតេលសានិ ។

សាវកសន្និបាតតែម្តង មានភិក្ខុ ៣ ហ្មឺនរូប ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ តែម្តងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាតតែម្តង មានភិក្ខុ ២ ហ្មឺនរូប ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ តែម្តងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតមានសាវកសន្និបាតតែម្តង មានភិក្ខុ ១ ពាន់ ២ រយ ហាសិបរូប ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាត របស់តថាគត តែម្តងនេះ ក៏សុទ្ធតែជាខីណាស្រពទាំងអស់ ។

[៨] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះអសោកៈ ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំង-ឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះខេមង្ករៈ

ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ ។ វេស្សភុស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឧបសន្តោ[១] នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ ។ កកុសន្ធស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស វុឌ្ឍិជោ[២] នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ ។ កោនាគមនស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សោត្ថិជោ នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ ។ កស្សបស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សព្វមិត្តោ នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ ។ មយ្ហំ ភិក្ខវេ ឯតរហិ អានន្ទោ នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ[៣] អគ្គុបដ្ឋាកោ ។

---

១ ឱ. ឧបសន្នកោ ។ ២ ឱ. ម. ពុទ្ធិជោ ។ ៣ ឱ. អហោសីតិ ន ទិស្សតិ ។

*ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូ មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះឧបសន្តៈ ជាឧបដ្ឋាក អ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះវុឌ្ឍិជៈ ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះសោត្ថិជៈ ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះសព្វមិត្តៈ ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគត មានភិក្ខុឈ្មោះអានន្ទ[១] ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។*

---

១ អដ្ឋកថា ថា ក្នុងបឋមពោធិកាល មិនមានភិក្ខុអ្នកបម្រើព្រះមានព្រះភាគជាប់ជានិច្ចទេ ជួនណាព្រះនាគសមាលត្ថេរ ជួនណាព្រះនាគិតត្ថេរ ជួនណាព្រះឧបវាណត្ថេរ ជួនណាព្រះសុនក្ខត្តត្ថេរ ជួនណាចុន្ទសមណុទ្ទេស ជួនណាព្រះសាគតត្ថេរ ជួនណាព្រះមេឃិយត្ថេរ បម្រើ ។ លុះដល់កាលខាងក្រោយមក ទើបបានព្រះអានន្ទត្ថេរ ចូលមកបម្រើជាប់រហូតដល់ព្រះអង្គចូលព្រះបរមនិព្វាន ។

[៩] វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ពន្ធុមា នាម រាជា បិតា អហោសិ ពន្ធុមតី នាម ទេវី មាតា អហោសិ ជនេត្តី ពន្ធុមស្ស រញ្ញោ ពន្ធុមតី នាម នគរំ រាជធានី អហោសិ ។ សិខិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អរុណោ នាម រាជា បិតា អហោសិ បភាវតី នាម ទេវី មាតា អហោសិ ជនេត្តី អរុណស្ស រញ្ញោ អរុណវតី នាម នគរំ រាជធានី អហោសិ ។ វេស្សភុស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សុប្បតីតោ នាម រាជា បិតា អហោសិ យសវតី នាម ទេវី មាតា អហោសិ ជនេត្តី សុប្បតីតស្ស រញ្ញោ អនោមំ នាម នគរំ រាជធានី អហោសិ ។ កកុសន្ធស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អគ្គិទត្តោ នាម ព្រាហ្មណោ បិតា អហោសិ វិសាខា នាម ព្រាហ្មណី មាតា អហោសិ ជនេត្តី ។ តេន ខោ បន ភិក្ខវេ សមយេន ខេមោ នាម រាជា អហោសិ ខេមស្ស រញ្ញោ ខេមវតី នាម នគរំ រាជធានី អហោសិ ។

[៩] ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជា ទ្រង់ព្រះនាមពន្ធុមៈ ព្រះមាតាព្រះនាមពន្ធុមតីទេវី ជាព្រះជនេត្តី (មាតាបង្កើត) ព្រះនគរឈ្មោះពន្ធុមតី ជារាជធានីនៃព្រះបាទពន្ធុមៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជាទ្រង់ព្រះនាមអរុណៈ ព្រះមាតាព្រះនាមបភាវតីទេវី ជាព្រះជនេត្តី នគរឈ្មោះអរុណវតី ជារាជធានីនៃព្រះបាទអរុណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជាទ្រង់ព្រះនាមសុប្បតីតៈ ព្រះមាតាព្រះនាមយសវតីទេវី ជាព្រះជនេត្តី នគរឈ្មោះអនោមៈ ជារាជធានីនៃព្រះបាទសុប្បតីតៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណ៍នាមអគ្គិទត្ត ព្រះមាតាជាព្រាហ្មណីនាមវិសាខា ជាជនេត្តី ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង មានព្រះរាជាព្រះនាមខេមៈ នគរឈ្មោះខេមវតី ជារាជធានីនៃព្រះបាទខេមៈ ។

កោណាគមនស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស យញ្ញទត្តោ នាម ព្រាហ្មណោ បិតា អហោសិ ឧត្តរា នាម ព្រាហ្មណី មាតា អហោសិ ជនេត្តី ។ តេន ខោ បន ភិក្ខវេ សមយេន សោភោ នាម រាជា អហោសិ សោភស្ស រញ្ញោ សោភវតី នាម នគរំ រាជធានី អហោសិ ។ កស្សបស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ព្រហ្មទត្តោ នាម ព្រាហ្មណោ បិតា អហោសិ ធនវតី នាម ព្រាហ្មណី មាតា អហោសិ ជនេត្តី ។ តេន ខោ បន ភិក្ខវេ សមយេន កិកី[១] នាម រាជា អហោសិ កិកិស្ស រញ្ញោ ពារាណសី នាម នគរំ រាជធានី អហោសិ ។ មយ្ហំ ភិក្ខវេ ឯតរហិ សុទ្ធោទនោ នាម រាជា បិតា អហោសិ មាយា នាម[២] ទេវី មាតា អហោសិ[៣] ជនេត្តី កបិលវត្ថុំ[៤] នាម នគរំ រាជធានី អហោសីតិ[៥] ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។

---

១ ឱ. ម. កិកី ។ ២ ឱ. នាមាតិ ន ទិស្សតិ ។ ៣ ឱ. ម. អហោសីតិ ន ទិស្សតិ ។ ៤ ឱ. ម. កបិលវត្ថុ ។ ៥ ឱ. ម. អហោសីតិ ន ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណ៍នាមយញ្ញទត្ត ព្រះមាតាជាព្រាហ្មណីនាមឧត្តរា ជាព្រះជនេត្តី ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង មានព្រះរាជាព្រះនាមសោភៈ នគរឈ្មោះសោភវតី ជារាជធានីនៃព្រះបាទសោភៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះកស្សបៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណ៍នាមព្រហ្មទត្ត ព្រះមាតាជាព្រាហ្មណីនាមធនវតី ជាព្រះជនេត្តី ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង មានព្រះរាជាព្រះនាមកឹកី នគរឈ្មោះពារាណសី ជារាជធានីនៃព្រះបាទកិកី ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ព្រះបិតារបស់តថាគត ជាព្រះរាជាទ្រង់ព្រះនាមសុទ្ធោទនៈ ព្រះមាតាទ្រង់ព្រះនាមមាយាទេវី ជាព្រះជនេត្តី ព្រះនគរឈ្មោះកបិលវត្ថុ ជារាជធានី ។ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះហើយ លុះព្រះសុគត បានត្រាស់ពាក្យនេះចប់ហើយ ក៏ទ្រង់ក្រោកចាកអាសនៈ ស្តេចចូលទៅកាន់ព្រះវិហារ ។

[១០] អថខោ តេសំ ភិក្ខូនំ អចិរបក្កន្តស្ស ភគវតោ អយមន្តរាកថា ឧទបាទិ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ តថាគតស្ស មហិទ្ធិកតា មហានុភាវ-តា យត្រ ហិ នាម តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ ជាតិតោបិ អនុស្សរិស្សតិ នាមតោបិ អនុស្សរិស្សតិ គោត្តតោបិ អនុស្សរិស្សតិ អាយុប្បមាណតោបិ អ-នុស្សរិស្សតិ សាវកយុគតោបិ អនុស្សរិស្សតិ សាវក-

មហាបទានសូត្រ ភាណវារៈទី ១ ពោលអំពីបុព្វេនិវាសានុស្សតិរបស់ព្រះមានព្រះភាគ

[១០] កាលព្រះមានព្រះភាគ ស្តេចចេញទៅ មិនយូរប៉ុន្មាន ក្នុងលំដាប់នោះ អន្តរាកថានេះ ក៏កើតឡើង ដល់ភិក្ខុទាំងនោះថា ម្នាលលោកមានអាយុទាំងឡាយ អស្ចារ្យណាស់ ម្នាលលោកមានអាយុទាំងឡាយ ហេតុនេះ មិនធ្លាប់ដែលមានឡើយ ព្រះតថាគតព្រះអង្គមានឫទ្ធិច្រើន មានអានុភាពច្រើនណាស់ហ្ន៎ អម្បាលដូចព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិល នូវកិលេសជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ[១] ទ្រង់ផ្តាច់ផ្តិល នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់[២] ទ្រង់គ្របសង្កត់ នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់[៣] ទ្រង់កន្លងបង់នូវទុក្ខទាំងពួង[៤] ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគត រលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង រលឹកឃើញព្រះគោត្រផង រលឹកឃើញប្រមាណនៃព្រះជន្មាយុផង រលឹកឃើញគូនៃសាវ័កផង រលឹក

---

១ អដ្ឋកថា ថា ធម៌ជាគ្រឿងធ្វើដំណើរសត្វដែលត្រាច់រង្គាត់ទៅក្នុងវដ្តសង្សារឲ្យយឺតយូរ ហៅថា បបញ្ចធម៌ សំដៅយកកិលេសទាំង ៣ គឺ តណ្ហា មានៈ ទិដ្ឋិ ។ ២ កម្មជាកុសលនិងអកុសល ហៅថា កុសលាកុសលកម្មវដ្ត ជាគ្រឿងញ៉ាំងសត្វឲ្យវិលកើត វិលស្លាប់នៅក្នុងលោក ។ ៣ ពាក្យថា គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ជាពាក្យផ្លាស់ប្តូរនឹងពាក្យថា ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់នោះដែរ បានសេចក្តីថា គ្របសង្កត់ឬផ្តាច់ផ្តិលនូវកម្មទាំងពួងដែលជាគ្រឿងញ៉ាំងសត្វឲ្យវិលកើត វិលស្លាប់ ។ ៤ បានដល់កន្លងបង់នូវទុក្ខទាំងអស់ដែលជារបស់វដ្តៈ ។

សន្និបាតតោបិ អនុស្សរិស្សតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំនាមា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំគោត្តា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំសីលា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំធម្មា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំបញ្ញា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំវិហារី តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ[១] ។ កឹ នុ ខោ អាវុសោ តថាគតស្សេវ នុ ខោ ឯសា ធម្មធាតុ សុប្បដិវិទ្ធា យស្សា ធម្មធាតុយា សុប្បដិវិទ្ធត្តា តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ ជាតិតោបិ អនុស្សរតិ នាមតោបិ អនុស្សរតិ គោត្តតោបិ អនុស្សរតិ អាយុប្បមាណតោបិ អនុស្សរតិ សាវកយុគតោបិ អនុស្សរតិ

---

១ ឱ. ម. ឯវំនាមា ឯវំគោត្តា ឯវំសីលា ឯវំធម្មា ឯវំបញ្ញា ឯវំវិហារី ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតីតិ ទិស្សតិ ។

ឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្វះ ព្រះមានព្រះភាគទាំងនោះ មានព្រះនាមយ៉ាងនេះខ្វះ ព្រះមានព្រះភាគទាំងនោះ មានព្រះគោត្រយ៉ាងនេះខ្វះ ព្រះមានព្រះភាគទាំងនោះ មានសីលយ៉ាងនេះខ្វះ ព្រះមានព្រះភាគទាំងនោះ មានធម៌យ៉ាងនេះខ្វះ ព្រះមានព្រះភាគទាំងនោះ មានប្រាជ្ញាយ៉ាងនេះខ្វះ ព្រះមានព្រះភាគទាំងនោះ មានវិហារធម៌យ៉ាងនេះខ្វះ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្វះ ។ ម្នាលអាវុសោទាំងឡាយ ធម្មធាតុណា ដែលព្រះតថាគតត្រាស់ដឹងហើយ ធម្មធាតុនុ៎ះ គឺព្រះតថាគតត្រាស់ដឹងមែនឬ បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគត រលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង រលឹកឃើញព្រះគោត្រផង រលឹកឃើញប្រមាណនៃជន្មាយុផង រលឹកឃើញ

មហាបទានសុត្តេ បឋមភាណវារំ ភគវតោ បុព្វេនិវាសានុស្សតិកថា

សាវកយុគតោបិ អនុស្សរតិ សាវកសន្និបាតតោបិ អនុស្សរតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំនាមា ។ ឯវំគោត្តា ។ ឯវំសីលា ។ ឯវំធម្មា ។ ឯវំបញ្ញា ។ ឯវំវិហារី ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ឧទាហុ ទេវតា តថាគតស្ស ឯតមត្ថំ អារោចេសុំ យេន តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ ជាតិតោបិ អនុស្សរតិ នាមតោបិ អនុស្សរតំ គោត្តតោបិ អនុស្សរតិ អាយុប្បមាណតោបិ អនុស្សរតិ សាវកយុគតោបិ អនុស្សរតិ សាវកសន្និបាតតោបិ អនុស្សរតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំនាមា ។ ឯវំគោត្តា ។ ឯវំសីលា ។ ឯវំធម្មា ។ ឯវំបញ្ញា ។ ឯវំវិហារី ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ។ អយញ្ច ហិ តេសំ ភិក្ខូនំ អន្តរាកថា វិប្បកតា ហោតិ ។

គូនៃសាវ័កផង រលឹកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាមយ៉ាងនេះខ្លះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ឬថាទេវតាទាំងឡាយ ក្រាបបង្គំទូលនូវសេចក្តីនុ៎ះ ចំពោះព្រះតថាគតទេដឹង បានជាព្រះអតីតពុទ្ធទាំងឡាយដែលទ្រង់ផ្តាច់ផ្តិល នូវកិលេសជាគ្រឿងញុាំងសត្វឲ្យមានដំណើរយឺតយូរទ្រង់ផ្តាច់ផ្តិល នូវកម្មជាគ្រឿងញុាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញុាំងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគត រលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង រលឹកឃើញព្រះគោត្រផង រលឹកឃើញប្រមាណនៃព្រះជន្មាយុផង រលឹកឃើញគូនៃសាវ័កផង រលឹកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាមយ៉ាងនេះខ្លះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ។ នេះឯង ជាអន្តរាកថា ដែលភិក្ខុទាំងនោះ (និយាយ) ហើយ បញ្ឈប់ទៅ ។

[១១] អថខោ ភគវា សាយណ្ហសមយំ បដិសល្លា-
ណា វុដ្ឋិតោ យេន ករេរិមណ្ឌលមាឡោ តេនុបសង្កមិ
ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ
ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ
កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា
វិប្បកតាតិ ។ ឯវំ វុត្តេ តេ ភិក្ខូ ភគវន្តំ ឯតទ-
វោចុំ ឥធ ភន្តេ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ
អយមន្តរាកថា ឧទបាទិ អច្ឆរិយំ អាវុសោ អព្ភូតំ
អាវុសោ តថាគតស្ស មហិទ្ធិកតា មហានុភាវតា
យត្រ ហិ នាម តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ
ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ
ជាតិតោបិ អនុស្សរិស្សតិ នាមតោបិ អនុស្សរិស្សតិ

[១១] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ស្តេចចូលទៅឯកុដិករេរិមណ្ឌល លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគគង់ស៊ប់ហើយ ទើបត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ប្រជុំគ្នានិយាយអ្វីហ្ន៎ អម្បាញ់មិញនេះ អន្តរាកថាដូចម្តេចដែលអ្នកទាំងឡាយបញ្ឈប់ទៅ ។ កាលបើព្រះមានព្រះភាគ ត្រាស់សួរយ៉ាងនេះហើយ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះមានព្រះភាគ ស្តេចចេញទៅ មិនយូរប៉ុន្មាន អន្តរាកថានេះ ក៏កើតឡើង ដល់ខ្ញុំព្រះអង្គទាំងឡាយក្នុងទីនេះថា ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ហេតុមិនដែលមានក៏ទៅជាមាន ព្រះតថាគតទ្រង់មានឫទ្ធិច្រើន មានអានុភាពច្រើនណាស់ហ្ន៎ អម្បាលដូចព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់ នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងនូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគត រលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង

គោត្តតោបិ អនុស្សរិស្សតិ អាយុប្បមាណតោបិ អនុស្សរិស្សតិ សាវកយុគតោបិ អនុស្សរិស្សតិ សាវកសន្និបាតតោបិ អនុស្សរិស្សតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ។ បេ ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ។ កិំ នុ ខោ អាវុសោ តថាគតស្សេវ នុ ខោ ឯសា ធម្មធាតុ សុប្បដិវិទ្ធា យស្សា ធម្មធាតុយា សុប្បដិវិទ្ធត្តា តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ ជាតិតោបិ អនុស្សរតិ នាមតោបិ អនុស្សរតិ គោត្តតោបិ អនុស្សរតិ អាយុប្បមាណតោបិ អនុស្សរតិ សាវកយុគតោបិ អនុស្សរតិ សាវកសន្និបាតតោបិ អនុស្សរតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំនាមា ។ ឯវំគោត្តា ។ ឯវំសីលា ។ ឯវំធម្មា ។ ឯវំបញ្ញា ។ ឯវំវិហារី ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ឧទាហុ ទេវតា តថាគតស្ស ឯតមត្ថំ អារោចេសុំ

រលឹកឃើញព្រះគោត្រផង រលឹកឃើញប្រមាណនៃព្រះជន្មាយុផង រលឹកឃើញគូនៃសាវ័កផង រលឹកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ ។ បេ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ។ ម្នាលអាវុសោទាំងឡាយ ធម្មធាតុណាដែលព្រះមានព្រះភាគត្រាស់ដឹងហើយដោយល្អ ធម្មធាតុនោះ ព្រះតថាគត ត្រាស់ដឹងដោយល្អមែនឬ បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិល នូវកិលេសជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិល នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគត រលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង រលឹកឃើញព្រះគោត្រផង រលឹកឃើញប្រមាណនៃព្រះជន្មាយុផង រលឹកឃើញគូនៃសាវ័កផង រលឹកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាមយ៉ាងនេះខ្លះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ឬថាទេវតាទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះតថាគតទេដឹង

យេន តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ ជាតិតោបិ អនុស្សរតិ នាមតោបិ ។ បេ ។ សាវកសន្និបាតតោបិ អនុស្សរតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំនាមា ។ បេ ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ អយំ ខោ នោ ភន្តេ អន្តរាកថា វិប្បកតា[១] អថ ភគវា អនុប្បត្តោតិ ។ តថាគតស្សេវេសា ភិក្ខវេ ធម្មធាតុ សុប្បដិវិទ្ធា យស្សា ធម្មធាតុយា សុប្បដិវិទ្ធត្តា តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ ជាតិតោបិ អនុស្សរតិ នាមតោបិ អនុស្សរតិ គោត្តតោបិ អនុស្សរតិ អាយុប្បមាណតោបិ អនុស្សរតិ សាវកយុគតោបិ អនុស្សរតិ សាវកសន្និ-

១ ម. ហោតីតិ ទិស្សតិ ។

បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគត រលឹកឃើញព្រះជាតិផង ទ្រង់រលឹកឃើញព្រះនាមផង ។ បេ ។ រលឹកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្វះ មានព្រះនាមយ៉ាងនេះខ្វះ ។ បេ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្វះ បពិត្រព្រះអង្គដ៏ចម្រើន អន្តរាកថានេះឯង ដែលខ្ញុំព្រះអង្គទាំងឡាយបញ្ឈប់ទៅ ព្រោះព្រះមានព្រះភាគស្តេចមកដល់ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មធាតុណា ដែលព្រះតថាគតត្រាស់ដឹងហើយដោយល្អ ធម្មធាតុនុ៎ះ ព្រះតថាគតត្រាស់ដឹងឯងដោយល្អហើយ បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់ នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏តថាគតរលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង រលឹកឃើញព្រះគោត្រផង រលឹកឃើញប្រមាណនៃព្រះជន្មាយុផង រលឹកឃើញគូនៃ

## ២១

### មហាបទានសុត្តេ បឋមភាណវារំ ភគវតោ បុព្វេនិវាសានុស្សតិកថា

ចាតតោបិ អនុស្សរតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំណាមា ។ បេ ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ទេវតាបិ តថាគតស្ស ឯតមត្ថំ អារោចេសុំ យេន តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្តេ សព្វទុក្ខវីតិវត្តេ ជាតិតោបិ អនុស្សរតិ ណាមតោបិ ។ បេ ។ សាវកសន្និចាតតោបិ អនុស្សរតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំ-ណាមា ។ បេ ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ។ ឥច្ឆេយ្យាថ ជោ តុម្ហេ ភិក្ខវេ ភិយ្យោសោ មត្តាយ បុព្វេនិវាសប្បដិសំយុត្តំ ជម្មឹ កាថំ សោតុន្តិ ។ ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា ភិយ្យោសោ មត្តាយ បុព្វេនិវាសប្បដិ-សំយុត្តំ ជម្មឹ កាថំ ការេយ្យ ភគវតោ សុត្វា ភិក្ខូ

សាវ័កផង រលឹកឃើញ នូវសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្វះ មានព្រះនាមយ៉ាងនេះខ្វះ ។ បេ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្វះ ទាំងពួកទេវតា ក៏បានប្រាប់សេចក្តីនុ៎ះដល់តថាគតដែរ បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិល នូវកិលេសជាគ្រឿងញុំាងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញុំាងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញុំាងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏តថាគត រលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង ។ បេ ។ រលឹកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្វះ មានព្រះនាមយ៉ាងនេះ ។ បេ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្វះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចង់ស្តាប់ធម្មីកថាដ៏ប្រកបដោយបុព្វេនិវាស ឲ្យច្រើនជាងប្រមាណដែរឬទេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ កាលនេះជាកាលគួរ ដើម្បីធ្វើនូវធម្មីកថានុ៎ះហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរ ដើម្បីធ្វើនូវធម្មីកថានុ៎ះហើយ សូមព្រះមានព្រះភាគធ្វើនូវធម្មីកថា ដែលប្រកបដោយបុព្វេនិវាស ឲ្យច្រើនជាងប្រមាណចុះ ភិក្ខុទាំងឡាយបានស្តាប់ធម្មីកថា របស់ព្រះមានព្រះភាគហើយ

ជាវេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឥតោ សោ ភិក្ខវេ ឯកនវុតោ កប្បោ[១] យំ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ ។ វិបស្សី ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ ខត្តិយោ ជាតិយា អហោសិ ខត្តិយកុលេ ឧទបាទិ ។ វិបស្សី ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ កោណ្ឌញ្ញោ គោត្តេន អហោសិ ។ វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អសីតិវស្សសហស្សានិ អាយុប្បមាណំ អហោសិ ។ វិបស្សី ភិក្ខវេ ភគវា អរហំ សម្មាសម្ពុទ្ធោ បាដលិយា មូលេ អភិសម្ពុទ្ធោ ។ វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ខណ្ឌតិស្សំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ វិបស្សិស្ស ភិក្ខវេ

១ ម. ឯកនវុតិកប្បេ ។

ក៏នឹងចាំទុក ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយចាំស្តាប់ចុះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីកប្បនេះ (ថយក្រោយទៅ) ៩១ កប្ប ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាខត្តិយជាតិ ទ្រង់កើតក្នុងខត្តិយៈត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមដើមបាដលិព្រឹក្ស (ដើមជ្រនៀង) ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះខណ្ឌៈ ១ តិស្សៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សី

២៣

មហាបទានសុត្តេ បឋមភាណវារំ ពោធិសត្តស្ស ធម្មតាកថា

ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស តយោ សាវកានំ សន្និបាតា អហេសុំ ឯកោ សាវកានំ សន្និបាតោ អហោសិ អដ្ឋសដ្ឋីភិក្ខុសតសហស្សំ ឯកោ សាវកានំ សន្និបាតោ អហោសិ ភិក្ខុសតសហស្សំ ឯកោ សាវ-កានំ សន្និបាតោ អហោសិ អសីតិភិក្ខុសហស្សានិ ។ វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឥមេ តយោ សាវកានំ សន្និបាតា អហេសុំ សព្វេសំ-យេវ ខីណាសវានំ ។ វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អសោកោ នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ ។ វិបស្សិស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ពន្ធុមា នាម រាជា បិតា អហោសិ ពន្ធុមតី នាម ទេវី មាតា អហោសិ ជនេត្តី ពន្ធុមស្ស រញ្ញោ ពន្ធុមតី នាម នគរំ រាជធានី អហោសិ ។

[១២] អថខោ ភិក្ខវេ វិបស្សី ពោធិសត្តោ តុសិ-តា កាយា ចវិត្វា សតោ សម្បជានោ មាតុ កុច្ឆឹ ឱក្កមិ ។ អយមេត្ថ ធម្មតា ។

មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត ៣ ដង គឺ សាវកសន្និបាត មានភិក្ខុ ៦ លាន ៨ សែនរូបម្តង សាវកសន្និបាត មាន ភិក្ខុ ១ សែនរូបម្តង សាវកសន្និបាត មានភិក្ខុ ៨ ហ្មឺនរូបម្តង ។ ម្នាល ភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះវិបស្សីមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធ ទាំង ៣ ដងនេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មាន ភិក្ខុឈ្មោះអសោកៈ ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជា ទ្រង់ព្រះនាមពន្ធុមៈ ព្រះមាតាព្រះនាមពន្ធុមតី ជាព្រះជនេត្តី នគរឈ្មោះ ពន្ធុមតី ជារាជធានី នៃព្រះបាទពន្ធុមៈ ។

[១២] ម្នាលភិក្ខុទាំងឡាយ កាលព្រះវិបស្សីពោធិសត្វ ច្យុតចាក ឋានតុសិត ទ្រង់មានសតិសម្បជញ្ញៈ ចុះកាន់ផ្ទៃនៃព្រះមាតា ។ នេះជាធម្មតា (របស់ព្រះពោធិសត្វ) ក្នុងវេលាដែលចុះកាន់ផ្ទៃនៃព្រះ មាតានុ៎ះ ។

[១៣] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ តុសិតា កាយា ចវិត្វា មាតុ កុច្ឆឹ ឱក្កមតិ ។ អថ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អប្បមាណោ ឧឡារោ ឱភាសោ លោកេ[១] ចាតុភ-វតិ អតិក្កម្មេវ[២] ទេវានំ ទេវានុភាវំ ។ យាបិ តា លោកន្តរិកា អឃា អសំវុតា អន្ធការតិមិសា យត្ថ-បិមេ ចន្ទិមសុរិយា ឯវំមហិទ្ធិកា ឯវំមហានុភាវា អា-ភាយ នានុភោន្តិ តត្ថបិ អប្បមាណោ ឧឡារោ ឱភាសោ ចាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ ។ យេបិ តត្ថ សត្តា ឧបបន្នា តេបិ តេនោភាសេន អញ្ញមញ្ញំ សញ្ជានន្តិ អញ្ញេបិ កិរ ភោ សន្តិ សត្តា ឥធុបបន្នា-តិ ។ អយញ្ច ទសសហស្សី លោកធាតុ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ[៣] អប្បមាណោ ច ឧឡារោ ឱភាសោ លោកេ ចាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ ។ អយមេត្ថ ធម្មតា ។

---

១ ឱ. ម. លោកេតិ ន ទិស្សតិ ។ ២ ឱ. អតិក្កម្ម ។ ៣ ឱ. ម. សម្បវេធតិ ។

[១៣] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលពោធិសត្វច្យុតចាកស្ថានតុសិត ចុះកាន់ផ្ទៃនៃព្រះមាតា ។ គ្រានោះ ពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន ក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក៏កើតប្រាកដឡើងក្នុងលោកដ៏កន្លងបង់នូវទេវានុភាពនៃទេវតាទាំងឡាយ ។ ឱកាសណាដែលចំហទទេ នៅក្នុងទីបំផុតនៃលោកឥតមានអ្វីបាំងរាំង មានតែអ័ព្ទងងឹត ព្រះចន្ទព្រះអាទិត្យទាំងនេះ សឹងមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក៏ផ្សាយពន្លឺទៅមិនដល់ក្នុងទីណា ពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ក៏កើតប្រាកដឡើងក្នុងទីទាំងនោះ ។ ពួកសត្វណាដែលកើតឡើងក្នុងទីទាំងនោះ សត្វអម្បាលនោះ ក៏ស្គាល់គ្នានិងគ្នាច្បាស់ ដោយសារពន្លឺនោះថា អើហ្ន៎ មានពួកសត្វឯទៀត កើតក្នុងទីនេះដែរ ។ លោកធាតុទាំងមួយហ្មឺននេះ ក៏កញ្រើករំពើកញ្រាប់ញ័រ ទាំងពន្លឺដ៏ភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោក កន្លងទេវានុភាពនៃទេវតាទាំងឡាយ ។ នេះជាធម្មតា (របស់ពោធិសត្វ) ក្នុងវេលាដែលចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

[១៤] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆឹ ឱក្កន្តោ ហោតិ ចត្តារោ[១] ទេវបុត្តា ចាតុទ្ទិសំ រក្ខាយ ឧបគច្ឆន្តិ មា នំ[២] ពោធិសត្តំ វា ពោធិសត្តមាតរំ វា មនុស្សោ វា អមនុស្សោ វា កោចិ វិហេឋេសីតិ ។ អយមេត្ថ ធម្មតា ។

[១៥] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆឹ ឱក្កន្តោ ហោតិ បកតិយា សីលវតី ពោធិសត្តមាតា ហោតិ វិរតា បាណាតិបាតា វិរតា អទិន្នាទានា វិរតា កាមេសុ មិច្ឆាចារា វិរតា មុសាវា-ទា វិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា ។ អយមេត្ថ ធម្មតា ។

---

១ ឱ. ម. ឯត្ថន្តរេ នន្តិ ទិស្សតិ ។ ២ ឱ. តំ ។

[១៤] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃព្រះមាតា មានទេវបុត្រ ៤ អង្គ តែងចូលទៅរក្សាក្នុងទិសទាំង ៤ ដោយគិតថា កុំឲ្យមនុស្សនិងអមនុស្សណានីមួយ បៀត-បៀនព្រះពោធិសត្វ និងព្រះមាតានៃព្រះពោធិសត្វនោះបានឡើយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតាន៎ុះ ។

[១៥] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វ ជាអ្នកមានសីល[១] ដោយប្រក្រតី ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្ប-មាទដ្ឋាន ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតាន៎ុះ ។

---

១ អដ្ឋកថា ថា កាលដែលព្រះពុទ្ធជាម្ចាស់មិនទាន់កើតឡើង មនុស្សទាំងឡាយតែងថ្វាយបង្គំក្នុងសម្នាក់នៃពួកតាបសនិងបរិព្វាជកហើយអង្គុយច្រហោងសមាទានសីល សូម្បីព្រះមាតានៃព្រះពោធិសត្វរបស់យើងទាំងឡាយ ក៏ទ្រង់សមាទានសីលក្នុងសម្នាក់នៃកាលទេវិលឥសីដែរ តែដល់ពោធិសត្វគង់នៅក្នុងផ្ទៃព្រះនាង ៗ មិនគង់ជិតបាទមូលនៃអ្នកដទៃឡើយ ទ្រង់គង់លើអាសនៈដ៏ស្មើ គ្រាន់តែពិចារណាសីលដែលសមាទានហើយប៉ុណ្ណោះ ហេតុដូច្នោះ បានជាលោកថា ព្រះមាតានៃពោធិសត្វទ្រង់កាន់សីលដោយព្រះអង្គឯង ។

[១៦] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆឹ ឱក្កន្តោ ហោតិ ន ពោធិសត្តមាតុ បុរិសេសុ មានសំ ឧប្បជ្ជតិ កាមគុណូបសំហិតំ អនតិក្កមនិយា ច ពោធិសត្តមាតា ហោតិ កេនចិ បុរិសេន រត្តចិត្តេន ។ អយមេត្ថ ធម្មតា ។

[១៧] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆឹ ឱក្កន្តោ ហោតិ លាភិនី ពោធិសត្តមាតា ហោតិ បញ្ចន្នំ កាមគុណានំ ។ សា បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារេតិ ។ អយមេត្ថ ធម្មតា ។

[១៨] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆឹ ឱក្កន្តោ ហោតិ ន ពោធិសត្តមាតុ កោចិទេវ អាពាធោ ឧប្បជ្ជតិ សុខិនី ពោធិសត្តមាតា ហោតិ អកិលន្តកាយា ពោធិសត្តញ្ច ពោធិសត្តមាតា តិរោកុច្ឆិគតំ បស្សតិ សព្វង្គប្បច្ចង្គំ អហីនិន្ទ្រិយំ[១] ។ សេយ្យថាបិ ភិក្ខវេ មណិវេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ

១ ឱ. អភិនិន្ទ្រិយំ ។

[១៦] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វ មិនមានចិត្តប្រកបដោយកាមគុណ ក្នុងបុរសទាំងឡាយ ព្រះមាតានៃព្រះពោធិសត្វ មិនដែលមានបុរសណាមួយ មានចិត្តត្រេកអរប្រព្រឹត្តកន្លងបានឡើយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

[១៧] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វ តែងបានទូវកាមគុណទាំង ៥ ជាប្រក្រតី ។ ព្រះមាតានៃព្រះពោធិសត្វនោះ តែងស្កប់ស្កល់ប្រកបព្រម មានអ្នកផ្គាប់បម្រើដោយកាមគុណទាំង ៥ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

[១៨] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិ-សត្វចុះកាន់ផ្ទៃនៃព្រះមាតា អាពាធណានីមួយ ក៏មិនកើតឡើងដល់ព្រះមាតានៃព្រះពោធិសត្វឡើយ ព្រះមាតានៃព្រះពោធិសត្វ មានតែសេចក្តីសុខជាប្រក្រតី មានកាយមិនបានលំបាក មួយទៀត មាតានៃព្រះពោធិសត្វតែងមើលឃើញព្រះពោធិសត្វ ហាក់ដូចជាឋិតនៅក្រៅផ្ទៃ សព្វអវយវៈទាំងធំទាំងតូច មានឥន្ទ្រិយក៏មិនថោកថយ ។ ម្នាលភិក្ខុទាំងឡាយ កែវមណីពិទូរ្យដ៏ល្អ មានកំណើតដ៏បរិសុទ្ធ មានជ្រុង ៨ ដែលជាងឆ្នៃ

## ២៧

### មហាបទានសុត្តេ បឋមភាណវារំ ពោធិសត្តស្ស ធម្មតាកថា

សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ តត្រស្ស[១] សុត្តំ អាវុតំ នីលំ វា បីតំ វា លោហិតកំ[២] វា ឱទាតំ វា បណ្ឌុសុត្តំ វា តមេនំ ចក្ខុមា បុរិសោ ហត្ថេសុ[៣] ករិត្វា បច្ចវេក្ខេយ្យ អយំ ខោ មណិវេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ តត្រស្ស[៤] សុត្តំ អាវុតំ នីលំ វា បីតំ វា លោហិតកំ វា ឱទាតំ វា បណ្ឌុសុត្តំ វា[៥] ឯវមេវ ខោ ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆឹ ឱក្កន្តោ ហោតិ ន ពោធិសត្តមាតុ កោចិទេវ អាពាធោ ឧប្បជ្ជតិ សុខិនី ពោធិសត្តមាតា ហោតិ អកិលន្តកាយា ពោធិសត្តញ្ច ពោធិសត្តមាតា តិរោកុច្ឆិគតំ បស្សតិ សព្វង្គបច្ចង្គឹ អហីនិន្ទ្រិយំ ។ អយមេត្ថ ធម្មតា ។

---

១ ម. តត្រ យំ ។ ២ ឱ. លោហិតំ ។ ៣ ឱ. ហត្ថេ ។ ៤ ឱ. ម. តត្រិទំ ។ ៥ ឱ. ម. វាតិ ។

ល្អហើយ ដ៏ថ្លាស្អាតប្រាសចាកមន្ទិល សមរម្យដោយអាការគ្រប់យ៉ាង បេសពណ៌ខៀវក្តី ពណ៌លឿងក្តី ពណ៌ក្រហមក្តី ពណ៌សក្តី ពណ៌លឿងទុំក្តី ដែលគេដោតហើយក្នុងកែវនោះ បុរសដែលមានភ្នែក ដាក់កែវនោះលើដៃ ពិចារណាឃើញច្បាស់ថា កែវមណីពិទូរ្យនេះឯង ដ៏ល្អមានកំណើតបរិសុទ្ធមានជ្រុង ៨ ដែលជាងបានច្នៃល្អហើយ ដ៏ថ្លាស្អាតប្រាសចាកមន្ទិល សមរម្យដោយអាការគ្រប់យ៉ាង បេសពណ៌ខៀវក្តី ពណ៌លឿងក្តី ពណ៌ក្រហមក្តី ពណ៌សក្តី ពណ៌លឿងទុំក្តី ដែលគេដោតក្នុងកែវនោះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា អាពាធណានីមួយ មិនដែលកើតឡើងដល់ព្រះមាតាព្រះពោធិសត្វឡើយ ព្រះមាតានៃព្រះពោធិសត្វ ជាអ្នកមានសេចក្តីសុខជាប្រក្រតី មានកាយមិនបានលំបាក មួយទៀត ព្រះមាតានៃព្រះពោធិសត្វ តែងមើលឃើញនូវព្រះពោធិសត្វ ហាក់ដូចជាឋិតនៅក្រៅផ្ទៃ ទាំងអវយវៈធំតូចទាំងអស់ មានឥន្ទ្រិយមិនថោកថយ មានឧបមេយ្យដូច្នោះឯង ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតាន៉ុះ ។

[១៩] ធម្មតា ឯសា ភិក្ខវេ សត្តាហជាតេ ពោធិសត្តេ ពោធិសត្តមាតា កាលំ ករោតិ តុសិតំ កាយំ ឧបបជ្ជតិ ។ អយមេត្ថ ធម្មតា ។

[២០] ធម្មតា ឯសា ភិក្ខវេ យថា អញ្ញា ឥត្ថិកា នវ វា ទស វា មាសេ គព្ភំ កុច្ឆិនា បរិហរិត្វា វិជាយន្តិ ន ហេវំ(១) ពោធិសត្តមាតា វិជាយតិ ។ ទសេវ មាសានិ ពោធិសត្តំ ពោធិសត្តមាតា កុច្ឆិនា បរិហរិត្វា វិជាយតិ ។ អយមេត្ថ ធម្មតា ។

[២១] ធម្មតា ឯសា ភិក្ខវេ យថា អញ្ញា ឥត្ថិកា និសិន្នា វា និបន្នា វា វិជាយន្តិ ន ហេវំ ពោធិសត្តំ ពោធិសត្តមាតា វិជាយតិ ឋិតា ច(២) ពោធិសត្តំ ពោធិសត្តមាតា វិជាយតិ ។ អយមេត្ថ ធម្មតា ។

---

១ ឱ. ម. ឯត្ថន្តរេ ពោធិសត្តន្តិ ទិស្សតិ ។ ២ ឱ. ម. វ ។

[១៩] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលព្រះពោធិសត្វប្រសូតមកបាន ៧ ថ្ងៃ ព្រះមាតានៃព្រះពោធិសត្វ តែងធ្វើមរណកាលទៅកើតនៅស្ថានតុសិត ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[២០] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺស្ត្រីទាំងឡាយដទៃតែងទ្រទ្រង់គភ៌អស់ ៩ ខែខ្លះ ១០ ខែខ្លះ ទើបបានប្រសូតយ៉ាងណា ព្រះមាតានៃព្រះពោធិសត្វ មិនប្រសូតយ៉ាងនោះឡើយ ។ ព្រះមាតានៃពោធិសត្វតែងទ្រង់គភ៌ពោធិសត្វ អស់ ១០ ខែគត់ ទើបបានប្រសូត ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[២១] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺស្ត្រីទាំងឡាយដទៃតែងអង្គុយសម្រាលក៏មាន ដេកសម្រាលក៏មានយ៉ាងណា ព្រះមាតានៃព្រះពោធិសត្វប្រសូតព្រះពោធិសត្វមិនមែនយ៉ាងដូច្នោះទេ ព្រះមាតានៃព្រះពោធិសត្វ រមែងស្ថិត (ឈរ) ប្រសូតព្រះពោធិសត្វ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

មហាបទានសុត្តេ បឋមភាណវារំ ពោធិសត្តស្ស ធម្មតាកថា

[២២] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆិស្មា និក្ខមតិ ទេវា បឋមំ បដិគ្គណ្ហន្តិ បច្ឆា មនុស្សា ។ អយមេត្ថ ធម្មតា ។

[២៣] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆិស្មា និក្ខមតិ អប្បត្តោ ច[១] ពោធិសត្តោ បឋវឹ ហោតិ ចត្តារោ នំ ទេវបុត្តា បដិគ្គហេត្វា មាតុ បុរតោ ឋបេន្តិ អត្តមនា ទេវិ ហោហិ មហេសក្ខោ តេ បុត្តោ ឧប្បន្នោតិ ។ អយមេត្ថ ធម្មតា ។

[២៤] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆិស្មា និក្ខមតិ វិសទោវ និក្ខមតិ អមក្ខិតោ ឧទ្ទេន អមក្ខិតោ សេម្ហេន អមក្ខិតោ រុហិរេន អមក្ខិតោ កេនចិ អសុចិនា សុទ្ធោ វិសុទ្ធោ ។

---
១ ឱ. ម. វ ។

[២២] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា ទេវតា[១] ទាំងឡាយ តែងទទួល (ព្រះពោធិសត្វ) មុន ទើបមនុស្សទាំងឡាយទទួលក្រោយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[២៣] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា ព្រះពោធិសត្វមិនទាន់ចុះដល់ផែនដី មានទេវបុត្រទាំង ៤ ទទួលព្រះអង្គ តម្កល់ក្នុងខាងមុខនៃព្រះមាតាថា បពិត្រព្រះនាងទេវី សូមព្រះនាងមានចិត្តរីករាយចុះ បុត្ររបស់ព្រះនាងជាអ្នកមានស័ក្តិធំ ទ្រង់កើតឡើងហើយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[២៤] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា ដ៏ល្អល្អះ (ស្រស់បស់) ចេញមក មិនប្រឡាក់ដោយទឹក (ភ្លោះ) មិនប្រឡាក់ដោយស្លេស្ម មិនប្រឡាក់ដោយឈាម មិនប្រឡាក់ដោយអសោចិ៍ណានីមួយឡើយ ជាអ្នកស្អាតបរិសុទ្ធ ។

---

១ អដ្ឋកថា ថា ពួកទេវតាដែលមកទទួលពោធិសត្វនោះ គឺពួកព្រហ្មជាខីណាស្រពក្នុងជាន់សុទ្ធាវាស ។

សេយ្យថាបិ ភិក្ខវេ មណិរតនំ កាសិកេ វត្ថេ និក្ខិត្តំ នេវ មណិរតនំ កាសិកំ វត្ថំ មក្ខេតិ នបិ កាសិកំ វត្ថំ មណិរតនំ មក្ខេតិ តំ កិស្ស ហេតុ ឧភិន្នំ សុទ្ធត្តា ឯវមេវ ខោ ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆិស្មា និក្ខមតិ វិសទោ វ និក្ខមតិ អមក្ខិតោ ឧទ្ទេន អមក្ខិតោ សេម្ហេន អមក្ខិតោ រុហិរេន អមក្ខិតោ កេនចិ អសុចិនា សុទ្ធោ វិសុទ្ធោ ។ អយមេត្ថ ធម្មតា ។

[២៥] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆិស្មា និក្ខមតិ ទ្វេ ឧទកស្ស ធារា អន្តលិក្ខា បាតុភវន្តិ ឯកា សីតស្ស ឯកា ឧណ្ហស្ស យេន ពោធិសត្តស្ស ឧទកកិច្ចំ ករោន្តិ មាតុ ច ។ អយមេត្ថ ធម្មតា ។

ម្នាលភិក្ខុទាំងឡាយ កែវមណីដែលបុគ្គលដាក់ចុះលើកាសិកពស្ត្រ កែវមណី (នោះ) មិនប្រឡាក់នូវកាសិកពស្ត្រឡើយ កាសិកពស្ត្រក៏មិនប្រឡាក់នូវកែវមណីដែរ ហេតុអ្វីបានជាថាដូច្នោះ ព្រោះសំពត់និងកែវមណីទាំងពីរជារបស់ស្អាត មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា ដ៏ល្អល្អះចេញមក មិនប្រឡាក់ដោយទឹក (ភ្លោះ) មិនប្រឡាក់ដោយស្លេស្ម មិនប្រឡាក់ដោយឈាម មិនប្រឡាក់ដោយអសោចិ៍ណានីមួយឡើយ ជាអ្នកស្អាតបរិសុទ្ធ មានឧបមេយ្យដូច្នោះឯង ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[២៥] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា មានធារទឹក ២ ហូរចុះមកអំពីអាកាស ធារទឹក ១ ត្រជាក់ ធារទឹក ១ ក្តៅ ធ្វើនូវការលាងជម្រះព្រះពោធិ-សត្វផង ព្រះមាតាផង ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[២៦] ធម្មតា ឯសា ភិក្ខវេ សម្បតិជាតោ ពោធិសត្តោ សមេហិ បាទេហិ បតិដ្ឋហិត្វា ឧត្តរេនាភិមុខោ[១] សត្តបទវីតិហារេន គច្ឆតិ សេតម្ហិ ឆត្តេ អនុធារិយមានេ[២] សព្វា ច ទិសា អនុវិលោកេតិ[៣] អាសភិញ្ច វាចំ ភាសតិ អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា មេ[៤] ជាតិ នត្ថិទានិ បុនព្ភវោតិ ។ អយមេត្ថ ធម្មតា ។

[២៧] ធម្មតា ឯសា ភិក្ខវេ យទា ពោធិសត្តោ មាតុ កុច្ឆិស្មា និក្ខមតិ អថ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អប្បមាណោ ឧឡារោ ឱភាសោ បាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ ។ យាបិ តា លោកន្តរិកា អឃា អសំវុតា អន្ធការតិមិសា យត្ថបិមេ ចន្ទិមសុរិយា

---

១ ឱ. ឧត្តរាភិមុខោ ។ ២ ឱ. អនុហីរមានេ ។ ៣ ឱ. វិលោកេតិ ។ ៤ ឱ. ម. មេតិ ន ទិស្សតិ ។

[២៦] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺកាលដែលព្រះពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋាន (ឈរលើផែនដី) ដោយព្រះបាទជាន់ស៊ប់ ផ្ទោះព្រះភក្រ្តទៅកាន់ទិសឧត្តរ ទ្រង់យាងឈានទៅបាន ៧ ជំហាន កាលដែលមហាជន កំពុងបាំងស្វេត្រឆត្រថ្វាយ ក៏រមិលមើលនូវទិសទាំងពួងផង ទ្រង់ពោលនូវអាសភិវាចា គឺវាចាដ៏ឧត្តមផងថា អញជាបុគ្គលខ្ពង់ខ្ពស់របស់លោក អញជាបុគ្គលធំបំផុតរបស់លោក អញជាបុគ្គលប្រសើរបំផុតរបស់លោក នេះជាកំណើតបំផុតរបស់អញ ឥឡូវនេះភពថ្មីតពីនេះទៅទៀត មិនមានឡើយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[២៧] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា គ្រានោះ ពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន កើតប្រាកដឡើងក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេស កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ ឱកាសណាដែលចំហទទេ នៅក្នុងទីបំផុតនៃលោក ឥតមានអ្វីបាំងរាំង មានតែអ័ព្ទងងឹត ព្រះចន្ទនិងព្រះអាទិត្យមានឫទ្ធយ៉ាងនេះ

ឯវំមហិទ្ធិកា ឯវំមហានុភាវា អាភាយ ជានុភោន្តិ តត្ថបិ អប្បមាណោ ឧឡារោ ឱភាសោ ចាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ ។ យេបិ តត្ថ សត្តា ឧបបន្នា តេបិ តេនោភាសេន អញ្ញមញ្ញំ សញ្ជានន្តិ អញ្ញេបិ កិរ ភោ សន្តិ សត្តា ឥធុបបន្នាតិ ។ អយញ្ច ទសសហស្សី លោកធាតុ សង្កម្បតិ សម្ប-កម្បតិ សម្បវេធតិ អប្បមាណោ ច ឧឡារោ ឱភា-សោ លោកេ ចាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុ-ភាវំ ។ អយមេត្ថ ធម្មតា ។

[២៨] ជាតេ ខោ បន ភិក្ខវេ វិបស្សិម្ហិ កុមារេ ពន្ធុមតោ រញ្ញោ បដិវេទេសុំ បុត្តោ តេ ទេវ[១] ជាតោ តំ ទេវោ បស្សតូតិ ។ អទ្ទសា ខោ ភិក្ខវេ ពន្ធុមា រាជា វិបស្សឹ កុមារំ ទិស្វា នេមិត្តេ ព្រាហ្មណេ អាមន្តាបេត្វា ឯតទវោច បស្សន្តុ ភោន្តោ នេមិត្តា ព្រាហ្មណា កុមារន្តិ ។ អទ្ទសំសុ[២] ខោ ភិក្ខវេ ធំ[៣] នេមិត្តា ព្រាហ្មណា វិបស្សឹ កុមារំ ទិស្វា

១ ម. ទេវ តេ ។ ២ ឱ. អទ្ទសាសុំ ។ ៣ ឱ. នន្តិបទំ នត្ថិ ។

មានអានុភាពច្រើនយ៉ាងនេះ ផ្សាយពន្លឺទៅមិនដល់ក្នុងទីណា ពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងទីទាំងនោះ កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ ពួកសត្វណាដែលកើតក្នុងទីទាំងនោះ សត្វអម្បាលនោះ ក៏ស្គាល់ច្បាស់នូវគ្នានិងគ្នា ដោយសារពន្លឺនោះថា អើហ្ន៎ មានពួកសត្វដទៃកើតក្នុងទីនោះដែរ ។ លោកធាតុ ១ ហ្មឺននេះក៏កក្រើករំពើកញាប់ញ័រ ទាំងពន្លឺភ្លឺស្វាងច្បាស់ក៏រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោក កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[២៨] ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារ ប្រសូតមករួចហើយ រាជបុរសទាំងឡាយ ក៏ក្រាបបង្គំទូលព្រះបាទពន្ធុមៈថា បពិត្រព្រះសម្មតិទេព ព្រះរាជបុត្ររបស់ព្រះអង្គប្រសូតហើយ សូមព្រះអង្គទ្រង់ទតព្រះរាជបុត្រនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបាទពន្ធុមៈទ្រង់ទតឃើញព្រះវិបស្សីកុមារ លុះទ្រង់ឃើញហើយ ក៏ត្រាស់បង្គាប់ឲ្យហៅពួកព្រាហ្មណ៍ជាហោរាមកហើយ មានព្រះរាជឱង្ការដូច្នេះថា ពួកព្រាហ្មណ៍ជាហោរាដ៏ចម្រើន ចូរមើលកុមារ (នេះ) ។ ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ជាហោរាក៏មើលនូវព្រះវិបស្សីកុមារនោះ លុះបានឃើញហើយ

៣៣

### មហាបទានសុត្តេ បឋមភាណវារំ ទ្វត្តឹសមហាបុរិសលក្ខណកថា

ពន្ធុបត្តំ(១) រាជានំ ឯតទវោចុំ អត្តមនោ ទេវ ហោតិ មហេសក្ខោ តេ(២) បុត្តោ ឧប្បន្នោ លាភា តេ មហារាជ សុលទ្ធន្តេ មហារាជ យស្ស តេ កុលេ ឯវរូបោ បុត្តោ ឧប្បន្នោ អយំ ហិ ទេវ កុមារោ ទ្វត្តឹសមហាបុរិសលក្ខណេហិ សមន្នាគតោ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេ វ(៣) គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្តរតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន

---

១ ឱ. ពន្ធុមំ ។ ២ ឱ. តេ ទេវ ។ ៣ ឱ. វសទ្ទោ នត្ថិ ។

ក្រាបបង្គំទូលព្រះបាទពន្ធុមៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គមានព្រះហឫទ័យរីករាយ ព្រះរាជបុត្ររបស់ព្រះអង្គ មានស័ក្តិធំ បានកើតឡើងហើយ បពិត្រមហារាជ ព្រះអង្គមានលាភហើយ បពិត្រមហារាជ ព្រះអង្គបានដោយល្អហើយ ព្រះរាជបុត្រដែលមានសភាពដូច្នេះ កើតឡើងក្នុងត្រកូលព្រះអង្គហើយ បពិត្រព្រះសម្មតិទេព ដ្បិតព្រះរាជកុមារនេះប្រកបដោយមហាបុរិសលក្ខណៈ ៣២ ឯមហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ រមែងមានគតិតែ ២ យ៉ាង មិនមានគតិដទៃទៀតទេ គឺបើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្រជាធម្មរាជ ប្រកបដោយធម៌ ជាក្សត្រិយ៍ឈ្នះសង្រ្គាមមានទីបំផុតទល់នឹងសមុទ្រទាំង ៤ មានជនបទដ៏មាំមួន ប្រកបដោយរតនៈ ៧ ប្រការ ឯរតនៈ ទាំង ៧ ប្រការរបស់ព្រះអង្គ ដូច្នេះគឺ ចក្ករ័តន៍ (ចក្រកែវ) ហត្ថិរ័តន៍ (ដំរីកែវ) អស្សរ័តន៍ (សេះកែវ) មណិរ័តន៍ (កែវមណី) ឥត្ថីរ័តន៍ (ស្ត្រីកែវ) គហបតិរ័តន៍ (គហបតីកែវ) បរិនាយករ័តន៍ (នាយបរិនាយកកែវ) ជាគម្រប់ ៧ ព្រះអង្គមានព្រះរាជបុត្រច្រើនជាងពាន់ ជាអ្នកក្លៀវក្លា មានសភាពជាអ្នកព្យាយាម (ក្លាហាន) អាចញាំញីនូវសេនារបស់ស្តេចដទៃបាន ព្រះអង្គគ្រប់សង្កត់នូវផែនដីនេះ មានសាគរជាទីបំផុត ទ្រង់គ្រប់គ្រងដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើ

អសត្ថេន ធម្មេន អភិវិជយ អជ្ឈាវសតិ សចេ ខោ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ ។ កតមេហិ ចាយំ ទេវ កុមារោ ទ្វត្តឹសមហាបុរិសលក្ខណេហិ សមន្នា-គតោ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេ វ គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្តរតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ។ បេ ។ អភិវិជយ អជ្ឈាវសតិ សចេ ខោ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ ។

[២៩] អយំ ហិ ទេវ កុមារោ សុប្បតិដ្ឋិតបាទោ យំបាយំ ទេវ កុមារោ សុប្បតិដ្ឋិតបាទោ ឥទម្បិស្ស មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ។

សស្រ្តាវុធឡើយ ប្រសិនបើទ្រង់ចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូលគឺកិលេសរបើកហើយ ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ដូចម្តេចខ្វះ មហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ រមែងមានគតិតែ ២ យ៉ាង មិនមែនមានគតិដទៃទៀតឡើយ គឺបើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាក្សត្រិយ៍ទ្រង់ធម៌ ជាក្សត្រិយ៍ឈ្នះសង្គ្រាមមានទីបំផុតទល់នឹងសមុទ្រទាំង ៤ ព្រះអង្គមានជនបទដ៏មាំមួន ប្រកបដោយរតនៈ ៧ ប្រការ ឯរតនៈ ៧ ប្រការរបស់ព្រះអង្គដូច្នេះ គឺចក្ករ័តន៍ ។ បេ ។ ទ្រង់ឈ្នះគ្រប់សង្កត់ ប្រសិនបើព្រះកុមារនេះ ចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស នឹងបានជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូលគឺកិលេសរបើកហើយ ។

[២៩] បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះបាទាប្រតិស្ឋានស៊ប់ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារដែលមានព្រះបាទាប្រតិស្ឋានស៊ប់នេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរសនោះ ។

ឥមស្ស ទេវ កុមារស្ស ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ សហស្សារានិ សនេមិកានិ សនាភិកានិ សព្វាការបរិបូរានិ យំបិ ទេវ ឥមស្ស កុមារស្ស ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ សហស្សារានិ សនេមិកានិ សនាភិកានិ សព្វាការបរិបូរានិ ឥទម្បិស្ស មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ។

អយំ ហិ ទេវ កុមារោ អាយតបណ្ហិ ។

អយំ ហិ ទេវ កុមារោ ទីឃង្គុលី ។

អយំ ហិ ទេវ កុមារោ មុទុតលុនហត្ថបាទោ[១] ។

អយំ ហិ ទេវ កុមារោ ជាលហត្ថបាទោ ។

---

១ មុទុតលុនបាទោតិបិ បាឋោ ។ ឱ. មុទុតលុណហត្ថបាទោ ។

*បពិត្រព្រះសម្មតិទេព ចក្រទាំងឡាយកើតមាន ត្រង់ផ្ទៃព្រះបាទានៃព្រះរាជកុមារនេះ ប្រដាប់ដោយកាំមួយពាន់ ព្រមទាំងខ្នងកង់និងដុំមានចន្លោះស្មើគ្នាគ្រប់អន្លើ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារដែលមានរូបចក្រកើតត្រង់ផ្ទៃនៃព្រះបាទាខាងក្រោម ប្រដាប់ដោយកាំមួយពាន់ ព្រមទាំងខ្នងកង់និងដុំ មានចន្លោះស្មើគ្នាគ្រប់អន្លើនេះ នេះឯងជាមហាបុរិសលក្ខណៈ របស់មហាបុរសនោះ ។*

*បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះមានព្រះបណ្ហិ គឺកែងព្រះបាទវែង[១] ។*

*បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះអង្គុលីគឺម្រាមព្រះហស្តនិងម្រាមព្រះបាទវែង[២] ។*

*បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទទន់ល្វន់ (ដូចជាដុំសំឡីដែលគេថ្លេចអស់មួយរយដង) ។*

*បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទប្រទាក់ដោយក្រឡាដូចជាសំណាញ់ ។*

---

១ បើចែកសរីរប្បទេសត្រង់នោះជា ៤ ភាគ ពីរភាគជាចុងព្រះបាទ មួយភាគ ជាកព្រះបាទ មួយភាគជាព្រះបណ្ហិ ។ ២ ចំណែកខាងព្រះហស្ត ម្រាមទាំង ៤ វែងស្មើគ្នា ព្រះបាទម្រាមទាំង ៥ វែងស្មើគ្នា ម្រាមទាំងអស់មូលត្រសូលរៀវល្អ ដូចជាផង់មនោសិលា ដែលគេលាយប្រេងហើយលញ់ ។

អយំ ហិ ទេវ កុមារោ ឧស្សង្ខបាទោ ។

អយំ ហិ ទេវ កុមារោ ឯណិជង្ឃោ ។

អយំ ហិ ទេវ កុមារោ ឋិតកោ វ អនោនមន្តោ ឧភោហិ បាណិតលេហិ ជន្នុកានិ បរិមសតិ[១] បរិមជ្ជតិ ។

អយំ ហិ ទេវ កុមារោ កោសោហិតវត្ថគុយ្ហោ ។

អយំ ហិ ទេវ កុមារោ សុវណ្ណវណ្ណោ កាញ្ចនសន្និភត្តចោ ។

អយំ ហិ ទេវ កុមារោ សុខុមច្ឆវី សុខុមត្តា ឆវិយា រជោជល្លំ កាយេ ន ឧបលិម្បតិ ។

---

១ ម. បរាមសតិ ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះបាទដូចជាអណ្តែតឡើងខាងលើ (ហាក់ដូចជាមិនជាប់គ្នានឹងខ្នងព្រះបាទ) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះជង្ឃា គឺស្នង (រៀវមូលត្រសូល) ស្រដៀងនឹងស្នងសត្វទ្រាយ (ពុំនោះសោតស្រដៀងនឹងដង្កើមស្រូវ) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ កាលបើទ្រង់ព្រះសណ្ឋិត គឺទ្រង់ឈរ មិនឱនព្រះអង្គចុះ អាចស្ទាបព្រះជាណុ គឺជង្គង់ ដោយផ្ទៃព្រះហស្តទាំង ២ បាន ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះអង្គាវយវៈដែលគប្បីលាក់ ឲ្យកំបាំងដោយសំពត់ បិតនៅក្នុងស្រោម (ប្រហែលដូចជាអង្គជាត នៃដំរីឬគោឈ្មោលជាដើម) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះឆវិវណ្ណ គឺ សម្បុរ (ល្បើងភ្លឺអន្ទង) ដូចជាសម្បុរនៃមាស ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះឆវីគឺសម្បុរល្អិតផូរផង់ រលីងស្រិលរតលធូលី ៗ ធ្លាក់មកត្រូវមិនជាប់ព្រះកាយ ។

មហាបទានសុត្តេ បឋមភាណវារំ ទ្វត្តឹសមហាបុរិសលក្ខណកថា

អយំ ហិ ទេវ កុមារោ ឯកេកលោមោ ឯកេ-
កានិ លោមានិ លោមកូបេសុ ជាតានិ ។

អយំ ហិ ទេវ កុមារោ ឧទ្ធគ្គលោមោ ឧទ្ធគ្គានិ
លោមានិ ជាតានិ នីលានិ អញ្ជនវណ្ណានិ កុណ្ឌា-
លាវត្តានិ ទក្ខិណាវដ្ដជាតានិ[១] ។

អយំ ហិ ទេវ កុមារោ ព្រហ្មុជុគត្តោ ។

អយំ ហិ ទេវ កុមារោ សត្តុស្សទោ ។

អយំ ហិ ទេវ កុមារោ សីហបុព្វឌ្ឍកាយោ ។

---

១ ឱ. កុណ្ឌលវត្តានិ ទក្ខិណាវត្តកជាតានិ ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះលោមាគឺរោម ក្នុងរណ្ដៅមួយ ៗ តែមួយសរសៃ ៗ រាល់រណ្ដៅ ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានចុងព្រះលោមាងឡើងលើ ជាទក្ខិណាវដ្ដវិលវង់ព័ទ្ធពេនទៅខាងស្ដាំ មានពណ៌ខៀវស្រស់ ដូចជាពណ៌នៃផ្កាអញ្ជ័ន ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះកាយត្រង់ដូចជាកាយព្រហ្ម ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះមំសៈគឺសាច់ ៧ អន្លើពេញលេញ (គឺត្រង់ខ្នងព្រះហស្ដទាំង ២ ខ្នងព្រះបាទទាំង ២ ព្រះអង្សកូដគឺចង្កួយស្មាទាំង ២ និងត្រង់ព្រះខន្ធប្បទេសគឺព្រះក សរីរប្រទេសទាំង ៧ អន្លើនេះមានសាច់ពេញលេញល្អ ឥតមានឃើញសរសៃឡើយ) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានចំណែកកន្ទះព្រះកាយ[១] ខាងដើម ស្រដៀងគ្នានឹងចំណែកកន្ទះកាយនៃរាជសីហ៍ ។

---

១ អដ្ឋកថាថា សត្វសីហៈមានកាយពាក់កណ្ដាលទៅលើពេញលេញ កាយខាងក្រោមមិនពេញទេ ចំណែកព្រះមហាបុរស ក៏មានព្រះកាយពាក់កណ្ដាលខាងលើពេញលេញ ដូចកាយសីហៈដែរ ។

អយំ ហិ ទេវ កុមារោ បីតន្តរំសោ[១] ។

អយំ ហិ ទេវ កុមារោ និគ្រោធបរិមណ្ឌលោ យាវតក្វស្ស កាយោ តាវតក្វស្ស ព្យាមោ យាវ-តក្វស្ស ព្យាមោ តាវតក្វស្ស កាយោ ។

អយំ ហិ ទេវ កុមារោ សមវដ្តក្ខន្ធោ ។

អយំ ហិ ទេវ កុមារោ រសគ្គសគ្គី ។

១ ឱ. ម. ចិត្តន្តរំសោ ។

*បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានចង្អូរនៃព្រះបិដ្ឋិប្រទេសពេញបរិបូណ៌ គឺមានខ្នងពេញស្មើ ឥតមានចង្អូរផតខូងត្រង់កណ្ដាលឡើយ ។*

*បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានទ្រង់ទ្រាយព្រះកាយប្រហែលនឹងបរិមណ្ឌលនៃដើមជ្រៃ*[១] *គឺមានកាយនិងព្យាមប្រវែងគ្នា (ដូចជាជ្រៃមានប្រវែងដើម និងមែកមិនលើសមិនខ្វះហួសគ្នាប៉ុន្មាន) ។*

*បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះខន្ធប្បទេស គឺព្រះសុរង មូលសម ។*

*បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះប្រសាទ គឺសរសៃ ល្អិតឆ្មារដ៏លើសលែង សម្រាប់ទទួលរសអាហារ*[២] *។*

---

១ ដើមជ្រៃមានមែកបែកចេញពីដើមមានប្រវែងស្មើគ្នាទោះបី ៥០ ហត្ថ ឬ ១០០ ហត្ថក៏មានប្រមាណត្រូវគ្នាមិនខុស ទាំងបណ្ដោយទាំងទទឹង ចំណែកខាងព្រះកាយរបស់ព្រះមានព្រះភាគ ក៏មានប្រមាណត្រូវគ្នា ទាំងជំហរព្រះកាយទាំងព្យាមដែរ ។ ២ អដ្ឋកថា ថា មានសរសៃយ៉ាងឆ្មារល្អិត ៧ ពាន់ ប្រជុំស្រោបត្រង់ព្រះសុរង (សម្រាប់ទទួលនាំរសអាហារឲ្យជ្រួតជ្រាបផ្សព្វផ្សាយក្នុងព្រះកាយទាំងមូលបាន ឥតមានទើសទាក់) សូម្បីអាហារយ៉ាងតិចប៉ុនគ្រាប់ល្ង ១ ដែលទ្រង់ដាក់ត្រង់ចុងព្រះជិវ្ហា ក៏អាចជ្រួតជ្រាបសព្វសព៌ាង្គកាយបាន ។

មហាបទានសុត្តេ បឋមភាណវារំ ទ្វត្តឹសមហាបុរិសលក្ខណកថា

អយំ ហិ ទេវ កុមារោ សីហហនុ ។

អយំ ហិ ទេវ កុមារោ ចត្តាឡីសទន្តោ ។

អយំ ហិ ទេវ កុមារោ សមទន្តោ ។

អយំ ហិ ទេវ កុមារោ អវិរឡទន្តោ[១] ។

អយំ ហិ ទេវ កុមារោ សុសុក្កទាឋោ ។

អយំ ហិ ទេវ កុមារោ បហូតជិវ្ហោ ។

អយំ ហិ ទេវ កុមារោ ព្រហ្មស្សរោ ករវិក-

ភាណី ។

---

១ ឱ. អវិវរទន្តោ ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះហនុគឺចង្កា សណ្ឋានស្រដៀងនឹងចង្ការាជសីហ៍ (ពេញបរិបូណ៌ប្រហែលដូចព្រះចន្ទត្រង់ថ្ងៃ ១២ កើត) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះទន្តគឺធ្មេញ ៤០ គត់ (ខាងលើ ២០ ខាងក្រោម ២០) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះទន្តរាបស្មើ (មិនប្រជួស ឬប្រពើសខ្ពស់ទាបឡើយ) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានរបៀបនៃព្រះទន្តជិតស្និទ្ធល្អ ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះទាឋាគឺព្រះចង្កូម (ទាំង ៤) សស្អាត (ភ្លឺរុងរឿងដាងពន្លឺផ្កាយព្រឹក) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះជិវ្ហាដ៏ទន់ល្មមល្មៃ ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះសូរសៀងគឺសូរសព្ទសំឡេងក្រាងក្រអៅ ដូចជាសំឡេងនៃមហាព្រហ្មកាលបើបញ្ចេញព្រះវាចាពុតពីរោះដូចជាសំឡេងនៃសត្វករវិក ។

អយំ ហិ ទេវ កុមារោ អភិនីលនេត្តោ ។

អយំ ហិ ទេវ កុមារោ គោបខុមោ ។

ឥមស្ស ទេវ កុមារស្ស ឧណ្ណា ភមុកន្តរេ ជាតា ឱទាតា មុទុ តូលសន្និភា ។ យំបិ ទេវ[1] ឥមស្ស កុមារស្ស ឧណ្ណា ភមុកន្តរេ ជាតា ឱទាតា មុទុ តូលសន្និភា ។

អយំ ហិ ទេវ កុមារោ ឧណ្ហីសសីសោ យំបាយំ ទេវ កុមារោ ឧណ្ហីសសីសោ ឥទម្បិស្ស មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ។

---

១ ម. ទេវាតិបទំ នត្ថិ ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះនេត្រខៀវស្រស់[១] (ក្នុងទីដែលគួរខៀវ) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានដួងព្រះនេត្រស្រដៀងនឹងដួងភ្នែកនៃគោ ( មានដួងព្រះនេត្រទាំង ២ ថ្វាយង់ស្រដៀងនឹងដួងភ្នែកកូនគោសម្បុរក្រហម ដែលទើបនឹងសម្រាល់មួយរំពេច) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះឧណ្ណា-លោម គឺរោមដុះត្រង់ចន្លោះព្រះភមូ (ចិញ្ចើម) មានសម្បុរសក្បុស ទន់ល្វន់ដូចជាសំឡី ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះសិរ្សហាក់ដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ (រុងរឿងដូចជាព្រះមហាក្សត្រិយ៍ដែលទ្រង់នូវក្បាំងព្រះភក្ត្រ) ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ ដែលមានព្រះសិរ្សហាក់ដូចប្រដាប់ដោយក្បាំងស្រេចស្រាប់ ដោយហេតុណា ហេតុនេះឯងជាមហាបុរិសលក្ខណៈ របស់មហាបុរសនោះ ។

---

១ អដ្ឋកថា ថា ត្រង់កន្លែងដែលគួរខៀវក៏ខៀវស្រស់ដូចជាផ្កាត្រកៀត ឬ ផ្កាកណ្ដៀង ត្រង់កន្លែងដែលគួរលឿង ក៏លឿងស្រស់ដូចជាផ្កាកណ្ណិកា... ក្រហមស្រស់ដូចជាផ្កាច្បារ... សថ្លាត្រចះដូចជាផ្កាយព្រឹក... ខ្មៅស្រស់ដូចជាផ្លែផ្គាំ ។

៤១

### មហាបទានសុត្តេ បឋមភាណវារំ វិបស្សិប្បវត្តិកថា

[៣០] ឥមេហិ ខោ អយំ ទេវ កុមារោ ទ្វត្តឹ-
សមហាបុរិសលក្ខណេហិ សមន្នាគតោ យេហិ ស-
មន្នាគតស្ស មហាបុរិសស្ស ទ្វេ វ[១] គតិយោ ភវន្តិ
អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ
ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិ-
យប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្តរតនា-
និ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ
មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ
សត្តមំ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា
វីរង្គរូបា បរសេនប្បមទ្ទនា សោ ឥមំ បឋវឹ សាគរបរិ-
យន្តំ អទណ្ឌេន អសត្ថេន ធម្មេន សមេន អភិវិជិយ
អជ្ឈាវសតិ សចេ ខោ បន អគារស្មា អនគារិយំ
បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវ-
ដច្ឆទោ ហោតិ[២] ។

[៣១] អថខោ ភិក្ខវេ ពន្ធុមា រាជា នេមិត្តេ
ព្រាហ្មណេ អហតេហិ វត្ថេហិ អច្ឆាទេត្វា[៣] សព្វ-
កាមេហិ សន្តប្បេសិ ។ អថខោ ភិក្ខវេ ពន្ធុមា

---
១ ឱ. វសទ្ទោ នត្ថិ ។ ២ ឱ. ម. ហោតីតិ បាឋោ នត្ថិ ។ ៣ ឱ. ម. អច្ឆាទាបេត្វា ។

[៣០] បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនេះឯង មហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ រមែងមានគតិតែ ២ យ៉ាង មិនមានគតិដទៃទៀតឡើយ គឺបើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិប្រកបដោយធម៌ ជាក្សត្រិយ៍ទ្រង់ធម៌ ជាក្សត្រិយ៍ឈ្នះសង្គ្រាម មានទីបំផុតទល់នឹងសមុទ្រទាំង ៤ ព្រះអង្គមានជនបទដ៏មាំមួន ប្រកបដោយរតនៈ ៧ ប្រការ ឯរតនៈ ៧ ប្រការរបស់ព្រះអង្គដូច្នេះ គឺ ចក្រកែវ ដំរីកែវ សេះកែវ កែវមណី ស្ត្រីកែវ គហបតិកែវ នាយបរិនាយកកែវ ជាគម្រប់ ៧ ព្រះអង្គមានព្រះរាជបុត្រច្រើនជាងពាន់ដ៏ក្លៀវក្លា មានសភាព ជាអ្នកមានព្យាយាម អាចញាំញីនូវសេនារបស់ស្តេចដទៃបាន ព្រះអង្គគ្របសង្កត់នូវផែនដីនេះ ដែលមានសាគរជាទីបំផុត ទ្រង់គ្រប់-គ្រងដោយធម៌ដ៏ស្មើ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើសស្ត្រាវុធឡើយ ប្រសិនបើទ្រង់ចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូលគឺកិលេសរបើកហើយ ។

[៣១] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈឲ្យពួកព្រាហ្មណ៍ទាំងឡាយដែលជាហោរា ស្លៀកដណ្តប់សំពត់ថ្មី ៗ ហើយឲ្យឆ្អែតស្កប់ស្កល់ដោយវត្ថុជាទីប្រាថ្នាទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ

រាជា វិបស្សិស្ស កុមារស្ស ជាតិយោ ឧបដ្ឋាបេសិ ។ អញ្ញា ខីរំ[១] ចាយេន្តិ អញ្ញា នហាបេន្តិ អញ្ញា ជា-វេន្តិ អញ្ញា អង្កេន បរិហរន្តិ ។ ជាតស្ស ខោ បន ភិក្ខវេ វិបស្សិស្ស កុមារស្ស សេតច្ឆត្តំ ជារយិត្ថ ទិ-វា ចេវ រត្តឹ ច មា នំ សីតំ វា ឧណ្ហំ វា តិណំ វា រជោ វា ឧស្សាវោ វាតិ[២] ។ ជាតោ ខោ បន ភិក្ខវេ វិបស្សី កុមារោ ពហុនោ ជនស្ស បិយោ អហោសិ មនាបោ ។ សេយ្យថាបិ ភិក្ខវេ ឧប្បលំ វា បទុមំ វា បុណ្ឌរីកំ វា ពហុនោ ជនស្ស បិយំ មនាបំ ឯវមេវ ខោ ភិក្ខវេ វិបស្សី កុមារោ ព-ហុនោ ជនស្ស បិយោ អហោសិ មនាបោ ។ ស្វាស្សុទំ អង្កេនេវ អង្កំ បរិហរិយតិ ។ ជាតោ ខោ បន ភិក្ខវេ វិបស្សី កុមារោ មញ្ជុស្សរោ ច អហោ-សិ វគ្គុស្សរោ ច មធុរស្សរោ ច បេមនីយស្សរោ ច ។ សេយ្យថាបិ ភិក្ខវេ ហិមវន្តេ បព្វតេ ករវិកា នាម សកុណជាតិ មញ្ជុស្សរា ច វគ្គុស្សរា ច មធុរស្សរា ច

១ ឱ. សុទំ ។ ២ ឱ. វា ពាធតិ ។ ម. វា ពាធយិត្ថាតិ ។

លំដាប់នោះ ព្រះបាទពន្ធុមៈទ្រង់ត្រាស់បង្គាប់ឲ្យមេដោះទាំងឡាយបម្រើព្រះវិបស្សីកុមារ ។ ពួកស្ត្រីខ្លះថ្វាយព្រះក្សីររស ស្ត្រីខ្លះថ្វាយព្រះស្នាន (ផ្ងូតទឹក) ស្ត្រីខ្លះថ្នាក់ថ្នម ស្ត្រីខ្លះបីបមថ្នម-ព ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារ ប្រសូតមកហើយ រាជបុរសទាំងឡាយតែងបាំងនូវស្វេត្រច្ឆ័ត្រទាំងថ្ងៃទាំងយប់ ដើម្បីកុំឲ្យត្រជាក់ឬក្តៅ ស្មៅឬធូលី ឬទឹកសន្សើមពាល់ត្រូវបាន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលដែលព្រះវិបស្សីកុមារប្រសូតមកហើយ រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់ជនច្រើនគ្នា ។ ម្នាលភិក្ខុទាំងឡាយ ផ្កាឧប្បលក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី តែងជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើនគ្នា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារ រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើនគ្នា ក៏មានឧបមេយ្យដូច្នោះឯង ។ មានដំណាលថា ព្រះវិបស្សីកុមារនោះ គេតែងដណ្តើមបី-ព ផ្លាស់ប្តូរគ្នា ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារប្រសូតមកហើយ មានសំឡេងស្រទន់ មានសំឡេងក្បោះក្បាយ មានសំឡេងផ្អែមល្ហែម មានសំឡេងគួរឲ្យអ្នកផងស្រឡាញ់ ។ ម្នាលភិក្ខុទាំងឡាយ សកុណជាតិឈ្មោះករវិក ដែលនៅលើភ្នំហេមពាន្ត មានសំឡេងស្រទន់ មានសំឡេងក្បោះក្បាយ មានសំឡេងផ្អែមល្ហែម មានសំឡេង

បេមនីយស្សរា ច ឯវមេវ ខោ ភិក្ខវេ វិបស្សី កុមារោ មញ្ជុស្សរោ ច អហោសិ វគ្គុស្សរោ ច មធុរស្សរោ ច បេមនីយស្សរោ ច ។ ជាតស្ស ខោ បន ភិក្ខវេ វិបស្សិស្ស កុមារស្ស កម្មវិបាកជំ ទិព្វចក្ខុំ បាតុរហោសិ យេន ទូរំ(១) សមន្តា យោជនំ បស្សតិ ទិវា ចេវ រត្តឹ ច ។ ជាតោ ខោ បន ភិក្ខវេ វិបស្សី កុមារោ អនិម្មិស្សន្តោ(២) បេក្ខតិ សេយ្យថាបិ ភិក្ខវេ(៣) ទេវតា(៤) តាវត្តឹសា អនិម្មិស្សន្តា(៥) បេក្ខន្តិ ឯវមេវ ខោ ភិក្ខវេ វិបស្សី កុមារោ អនិម្មិស្សន្តោ បេក្ខតិ(៦) ។ ជាតស្ស(៧) ខោ បន ភិក្ខវេ វិបស្សិស្ស កុមារស្ស វិបស្សីត្វេវ(៨) សមញ្ញា ឧទបាទិ ។ អថខោ ភិក្ខវេ ពន្ធុមា រាជា អត្ថករណោ(៩) និសិន្នោ វិបស្សឹ កុមារំ អង្កេ និសីទាបេត្វា

---

១ ឱ. ម. សុទំ ។ ២ ឱ. អនិមិសន្តោ ។ ម. អនិម្មិសន្តោ ។ ៣ ឱ. ម. ភិក្ខវេតិ ន ទិស្សតិ ។ ៤ ឱ. ម. ទេវា ។ ៥ ឱ. ម. អនិមិសន្តោ ។ ៦ ឱ. ម. ឯវមេវ ខោ ភិក្ខវេ វិបស្សី កុមារោ អនិម្មិស្សន្តោ បេក្ខតីតិ ន ទិស្សន្តិ ។ ៧ ឱ. ជាតស្សាតិ បាឋោ ន ទិស្សតិ ។ ៨ ឱ. ម. វិបស្ស វិបស្សី ត្វេវាតិ អាមេណ្ឌិតំ ទិស្សតិ ។ ៩ ឱ. ម. អត្តករណោ ។

គួរឲ្យអ្នកផងស្រឡាញ់ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារ ក៏មានសំឡេងស្រទន់ មានសំឡេងក្បោះក្បាយ មានសំឡេងផ្អែមល្ហែម មានសំឡេងគួរឲ្យអ្នកផងស្រឡាញ់ ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារប្រសូតមកហើយ មានចក្ខុដូចជាទិព្វ កើតអំពីកម្មវិបាក កើតមានប្រាកដ អាចមើលឃើញនូវទីឆ្ងាយចំនួនមួយយោជន៍ ដោយជុំវិញបាន ទាំងវេលាថ្ងៃទាំងវេលាយប់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារ ដែលប្រសូតមកហើយ តែងសំឡឹងមើលមិនប៉ប្រិច ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយ ដែលឋិតនៅក្នុងឋានត្រៃត្រឹង្ស តែងសំឡឹងមើលមិនប៉ប្រិច យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារ ក៏តែងសំឡឹងមើលមិនប៉ប្រិចយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារប្រសូតមកហើយ ព្រះនាមថា វិបស្សី ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈគង់ក្នុងទីជម្រះក្តី ទ្រង់ញុំាងព្រះវិបស្សីកុមារឲ្យគង់លើព្រះឧរុ

អង្កេ[១] អនុសាសតិ ។ តត្រ សុទំ ភិក្ខវេ វិបស្សី កុមារោ បិតុ អង្កេ និសិន្នោ វិចេយ្យ វិចេយ្យ អត្ថេ បណាយតិ ញាណេន ។ វិចេយ្យ វិចេយ្យ កុមារោ អង្កេ បណាយតិ ញាណេនាតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស កុមារស្ស ភិយ្យោសោ មត្តាយ វិបស្សីត្វេវ សមញ្ញា ឧទបាទិ ។ អថខោ ភិក្ខវេ ពន្ធុមា រាជា វិបស្សិស្ស កុមារស្ស តយោ បាសាទេ ការាបេសិ ឯកំ វស្សិកំ ឯកំ ហេមន្តិកំ ឯកំ គិម្ហិកំ បញ្ច-កាមគុណានិ ឧបដ្ឋាបេសិ ។ តត្រ សុទំ ភិក្ខវេ វិបស្សី កុមារោ វស្សិកេ បាសាទេ ចត្តារោ មាសេ និប្បុ-រិសេហិ តុរិយេហិ បរិចារយមានោ[២] ន ហេដ្ឋា-បាសាទំ[៣] ឱរោហតីតិ ។

បឋមភាណវារំ ។

---

១ ឱ. ម. អត្ថេ ។ ២ ឱ. បរិវារយមានោ ។ ម. បរិចារិយមានោ ។ ៣ ម. ហេដ្ឋាបាសាទា ។

ពិភាក្សាក្ដីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មានដំណាលថា ក្នុងកាលនោះ ព្រះវិបស្សីកុមារគង់នៅនាព្រះឱរុព្រះបិតា ពិចារណាទៅក៏ដឹងច្បាស់ នូវសេចក្ដីទាំងឡាយ ដោយញាណ ។ ព្រះវិបស្សីកុមារពិចារណាទៅហើយ ក៏ដឹងច្បាស់នូវក្ដី ដោយញាណ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះនាមថា វិបស្សី ក៏កើតឡើងដល់ព្រះវិបស្សីកុមារ ដោយសុះសាយទូទៅ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទពន្ធុមៈឲ្យជាងសង់ប្រាសាទ ៣ ខ្នង សម្រាប់ព្រះវិបស្សីកុមារ (គង់) គឺប្រាសាទ ១ សម្រាប់គង់ក្នុងវស្សានរដូវ ប្រាសាទ ១ សម្រាប់គង់ក្នុងហេមន្តរដូវ ប្រាសាទ ១ សម្រាប់គង់ក្នុងគិម្ហរដូវ មានកាមគុណ ៥ ផ្គត់ផ្គង់បម្រុងទុក ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្ដីដំណាលថា ក្នុងកាលនោះ ព្រះវិបស្សីកុមារមានសុទ្ធតែពួក (ស្ត្រី) ឥតមានបុរស បម្រើដោយតន្ត្រីទាំងឡាយ នៅលើប្រាសាទក្នុងវស្សានរដូវអស់ ៤ ខែ មិនដែលចុះមកខាងក្រោមប្រាសាទឡើយ ។

ចប់ ភាណវារៈទី ១ ។

[៣២] អថខោ ភិក្ខវេ វិបស្សី កុមារោ ពហុន្នំ វស្សានំ ពហុន្នំ វស្សសតានំ ពហុន្នំ វស្សសហស្សានំ អច្ចយេន សារថឹ អាមន្តេសិ យោជេហិ សម្ម សារថិ ភទ្ទានិ ភទ្ទានិ យានានិ ឧយ្យានភូមឹ គច្ឆាម សុភូមឹ[១] ទស្សនាយាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សារថិ វិបស្សិស្ស កុមារស្ស បដិស្សុត្វា ភទ្ទានិ ភទ្ទានិ យានានិ យោជេត្វា វិបស្សិកុមារស្ស[២] បដិវេទេតិ យុត្តានិ ខោ តេ ទេវ ភទ្ទានិ ភទ្ទានិ យានានិ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ ភិក្ខវេ វិបស្សី កុមារោ ភទ្រំ[៣] យានំ អភិរុហិត្វា ភទ្ទេហិ ភទ្ទេហិ យានេហិ ឧយ្យានភូមឹ និយ្យាសិ ។ អទ្ទសា ខោ ភិក្ខវេ វិបស្សី កុមារោ ឧយ្យានភូមឹ និយ្យន្តោ បុរិសំ ជិណ្ណំ គោបានសិវង្កំ ភគ្គំ[៤] ទណ្ឌបរាយនំ បវេធមានំ គច្ឆន្តំ អាតុរំ គតយោព្វនំ ទិស្វា សារថឹ អាមន្តេសិ អយំ បន សម្ម សារថិ បុរិសោ

១ ឱ. ភូមឹ ។ ២ ឱ. ម. យោជាបេត្វា វិបស្សិស្ស កុមារស្ស ។ ៣ ឱ. ម. ភទ្ទំ ។ ៤ ឱ. ម. ភោគ្គំ ។

[៣២] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារ លុះកន្លងកាលច្រើនរយ ច្រើនពាន់ឆ្នាំទៅ ក៏ត្រាស់ហៅនាយសារថីមកថា ហៃនាយសារថីជាសំឡាញ់ស្មើចិត្តអើយ ចូរឯងរៀបទឹមនូវយានទាំងឡាយ ដែលល្អ ៗ យើងនឹងទៅកាន់ទីឧទ្យានមើលទីភូមិដ៏ល្អ ។ ម្នាលភិក្ខុទាំងឡាយ ឯនាយសារថី ក៏ទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ទឹមនូវយានទាំងឡាយដែលល្អ ៗ រួចហើយ ក្រាបបង្គំទូលព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព យានទាំងឡាយល្អ ៗ ខ្ញុំព្រះអង្គទឹមរួចហើយ ឥឡូវនេះ សូមព្រះអង្គកំណត់នូវកាលដ៏គួរចុះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីកុមារ ឡើងគង់យានដ៏ល្អចេញទៅកាន់ឧទ្យាន ដោយយានទាំងឡាយដែលល្អ ៗ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារ កាលដែលស្តេចទៅកាន់ឧទ្យាន បានទតទៅឃើញបុរសចាស់ មានឆ្អឹងជំនីរដូចជាបង្កង់ មានខ្នងកោង មានឈើច្រត់ជាគ្រឿងទប់ទល់ កំពុងញាប់ញ័រក្រហល់ក្រហាយ មានវ័យកន្លងហើយ លុះឃើញហើយក៏ត្រាស់ហៅនាយសារថីមកថា ហៃនាយសារថីជាសំឡាញ់ស្មើចិត្តអើយ ចុះបុរសនេះ

កឹកតោ កេសាបិស្ស ន យថា អញ្ញេសំ កាយោ-បិស្ស ន យថា អញ្ញេសន្តិ ។ ឯសោ ខោ ទេវ ជិណ្ណោ នាមាតិ ។ កឹ បនេសោ សម្ម សារថិ ជិណ្ណោ នាមាតិ ។ ឯសោ ខោ ទេវ ជិណ្ណោ នាម ន ទានិ តេន ចិរំ ជីវិតព្វំ ភវិស្សតីតិ ។ កឹ បន សម្ម សារថិ អហំបិ ជរាធម្មោ ជរំ អនតីតោតិ ។ ត្វញ្ច ទេវ មយញ្ចម្ហា សព្វេ ជរាធម្មា ជរំ អនតីតាតិ ។ តេន-ហិ សម្ម សារថិ អលន្ទានជ្ជ ឧយ្យានភូមិយា ឥតោ ច[១] អន្តេបុរំ បច្ចនិយ្យាហីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សារថិ វិបស្សិស្ស កុមារស្ស បដិស្សុត្វា តតោ ច អន្តេបុរំ បច្ចនិយ្យាសិ ។ តត្រ សុទំ ភិក្ខវេ

---

១ ឱ. ម. វ ។

ធ្វើដូចម្ដេច បានជាសក់គាត់មិនដូចជាសក់អ្នកឯទៀត ទាំងកាយគាត់ក៏មិនដូចកាយអ្នកឯទៀតដែរ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព នោះឯងហៅថា បុរសចាស់ ។ ហៃនាយសារថីជាសំឡាញ់ស្មើចិត្តអើយ ចុះដូចម្ដេចបុរសនុ៎ះ បានជាឈ្មោះថា បុរសចាស់ ។ បពិត្រព្រះសម្មតិទេព ឯបុរសនេះ បានជាឈ្មោះថា បុរសចាស់ តពីនេះទៅនុ៎ះ គាត់នឹងមិនរស់នៅយូរប៉ុន្មានទេ ។ ហៃនាយសារថីជាសំឡាញ់ស្មើចិត្តអើយ ទុកជាអាត្មាអញត្រូវមានសេចក្ដីចាស់ជាធម្មតា មិនកន្លងសេចក្ដីចាស់ទៅបានទេ ឬដូចម្ដេច ។ បពិត្រព្រះសម្មតិទេព មនុស្សទាំងអស់គ្នា ទោះព្រះអង្គក្ដី យើងខ្ញុំទាំងឡាយក្ដី សុទ្ធតែមានសេចក្ដីចាស់ជាធម្មតា មិនកន្លងសេចក្ដីចាស់ទៅបានទេ ។ ហៃនាយសារថីជាសំឡាញ់ស្មើចិត្តអើយ បើដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះល្មមប៉ុណ្ណឹងហើយ ឯងចូរត្រឡប់អំពីទីនេះទៅកាន់ខាងក្នុងបុរីវិញចុះ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថី ក៏ទទួលស្ដាប់ព្រះបន្ទូលព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចេញអំពីទីនោះ ត្រឡប់ទៅខាងក្នុងបុរីវិញទៅ ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្ដីដំណាលថា

វិបស្សី កុមារោ អន្តេបុរំ គតោ ទុក្ខី ទុម្មនោ បជ្ឈាយតិ ធិរត្ថុ កិរ ភោ ជាតិ នាម យត្រ ហិ នាម ជាតស្ស ជរា បញ្ញាយិស្សតីតិ ។

[៣៣] អថខោ ភិក្ខវេ ពន្ធុមា រាជា សារថឹ អាមន្តាបេត្វា ឯតទវោច កច្ចិ សម្ម សារថិ កុមារោ ឧយ្យានភូមិយា អភិរមិត្ថ កច្ចិ សម្ម សារថិ កុមារោ ឧយ្យានភូមិយា អត្តមនោ អហោសីតិ ។ ន ខោ ទេវ កុមារោ ឧយ្យានភូមិយា អភិរមិត្ថ ន ខោ ទេវ កុមារោ ឧយ្យានភូមិយា អត្តមនោ អហោសីតិ ។ កឹ បន សម្ម សារថិ អទ្ទស កុមារោ ឧយ្យានភូមឹ និយ្យន្តោតិ ។ អទ្ទសា ខោ ទេវ កុមារោ ឧយ្យានភូមឹ និយ្យន្តោ បុរិសំ ជិណ្ណំ គោបានសិវង្កំ ភគ្គំ ទណ្ឌបរាយណំ បវេធមានំ គច្ឆន្តំ អាតុរំ គតយោព្វនំ ទិស្វា មំ ឯតទវោច អយំ បន សម្ម សារថិ បុរិសោ កឹកតោ

ក្នុងកាលនោះ ព្រះវិបស្សីកុមារ លុះទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីព្រួយ តូចព្រះទ័យ សញ្ជប់សញ្ជឹងដោយព្រះតម្រិះថា ថ្វីយ អើហ្ន៎ សេចក្តីចាស់ តែងមានប្រាកដ ដល់សត្វលោកដែលកើតហើយ ។

[៣៣] ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះបាទពន្ធុមៈត្រាស់បង្គាប់ឲ្យរាជបុរសហៅនាយសារថីមកហើយ ទ្រង់មានព្រះបន្ទូលសួរថា នែនាយសារថី សំឡាញ់ស្មើចិត្តអើយ កុមារមានសេចក្តីត្រេកអរក្នុងឧទ្យានដែរឬ នែនាយសារថី សំឡាញ់ស្មើចិត្តអើយ កុមារមានចិត្តរីករាយក្នុងឧទ្យានដែរឬ ។ នាយសារថី ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារ មិនមានសេចក្តីត្រេកអរក្នុងឧទ្យានទេ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារ មិនមានព្រះទ័យរីករាយក្នុងឧទ្យានទេ ។ នែនាយសារថី សំឡាញ់ស្មើចិត្ត កាលដែលកុមារចេញទៅកាន់ឧទ្យាន បានឃើញអ្វីខ្លះដែរឬ ។ បពិត្រព្រះសម្មតិទេព កាលដែលព្រះរាជកុមារស្តេចទៅកាន់ឧទ្យាន បានទតឃើញបុរសចាស់ មានឆ្អឹងជំនីរដូចបង្កង់ មានខ្នងកោង មានឈើច្រត់ជាគ្រឿងទប់ទល់ កំពុងញ័ររន្ធត់ក្រហល់ក្រហាយ មានវ័យកន្លងហើយ លុះទតឃើញហើយ ក៏មានព្រះបន្ទូលដូច្នេះនឹងខ្ញុំព្រះអង្គថា ហៃនាយសារថី សំឡាញ់ស្មើចិត្ត ចុះបុរសនុ៎ះដូចម្តេច

កោសាបិស្ស ន យថា អញ្ញេសំ កាយោបិស្ស ន យថា អញ្ញេសន្តិ ឯសោ ខោ ទេវ ជិណ្ណោ នាមាតិ កឹ បនេសោ សម្ម សារថិ ជិណ្ណោ នាមាតិ ឯសោ ខោ ទេវ ជិណ្ណោ នាម នទានិ តេន ចិរំ ជីវិតព្វំ ភវិស្សតីតិ កឹ បន សម្ម សារថិ អហំបិ ជរាធម្មោ ជរំ អនតីតោតិ ត្វញ្ច ទេវ មយញ្ចម្ហា សព្វេ ជរាធម្មា ជរំ អនតីតាតិ តេនហិ សម្ម សារថិ អលន្ទានជ្ជ ឧយ្យានភូមិយា ឥតោ ច អន្តេបុរំ បច្ចនិយ្យាហីតិ ឯវំ ទេវាតិ ខោ អហំ ទេវ វិបស្សិស្ស កុមារស្ស បដិស្សុត្វា តតោ ច អន្តេបុរំ បច្ចនិយ្យាសឹ

បានជាសក់គាត់មិនដូចជាសក់អ្នកទាំងឡាយឯទៀត ទាំងកាយរបស់គាត់ ក៏មិនដូចកាយអ្នកទាំងឡាយឯទៀតដែរ ខ្ញុំព្រះអង្គ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព នុ៎ះឯងឈ្មោះថា បុរសចាស់ ព្រះរាជកុមារសួរទៀត ថា នែនាយសារថី សំឡាញ់ស្មើចិត្ត ចុះដូចម្តេចបុរសនុ៎ះ បានជាឈ្មោះ ថា ចាស់ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះ បានជាឈ្មោះថា បុរសចាស់ តពីនេះទៅ គាត់នឹងមិនរស់នៅបានយូរ ប៉ុន្មានទេ ព្រះរាជកុមារសួរទៀតថា ហៃនាយសារថី សំឡាញ់ស្មើ ចិត្ត ទុកជាអាត្មាអញ ក៏មានសេចក្តីចាស់ជាធម្មតា មិនកន្លងនូវសេចក្តី ចាស់ទៅបានទេឬដូចម្តេច ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិ-ទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី ទោះយើងខ្ញុំទាំងឡាយក្តី សុទ្ធតែមានសេចក្តីចាស់ជាធម្មតា មិនកន្លងនូវសេចក្តីចាស់ទៅបានឡើយ ព្រះរាជកុមារ ក៏មានព្រះបន្ទូលថា ហៃនាយសារថី សំឡាញ់ស្មើចិត្ត បើដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះល្មមប៉ុណ្ណឹងហើយ ឯងចូរត្រឡប់អំពី ទីនេះ ទៅកាន់ខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គក៏ទទួល ស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព ព្រះករុណា ថ្លៃវិសេស ហើយក៏ចេញអំពីទីនោះ ត្រឡប់មកខាងក្នុងបុរីវិញ

សោ ខោ នេវ កុមារោ អន្ធេបុរំ គតោ ទុក្ខី ទុម្មនោ បជ្ឈាយតិ ធិរត្ថុ កិរ ភោ ជាតិ ជាម យត្រ ហិ ជាម ជាតស្ស ជរា បញ្ញាយិស្សតីតិ ។ អថខោ ភិក្ខវេ ពន្ធុមស្ស រញ្ញោ ឯតទហោសិ មា ហេវ ខោ វិបស្សី កុមារោ ន រជ្ជំ ការេសិ មា ហេវ វិបស្សី កុមារោ អគារស្មា អនគារិយំ បព្វជិ មា ហេវ នេមិត្តានំ ព្រាហ្មណានំ សច្ចំ អស្ស វចនន្តិ ។ អថខោ ភិក្ខវេ ពន្ធុមា រាជា វិបស្សិស្ស កុមារស្ស ភិយ្យោសោ មត្តាយ បញ្ចកាមគុណានិ ឧបដ្ឋាបេសិ យថា វិ-បស្សី កុមារោ រជ្ជំ ការេយ្យ យថា វិបស្សី កុ-មារោ ន អគារស្មា អនគារិយំ បព្វជេយ្យ យថា នេមិត្តានំ ព្រាហ្មណានំ មិច្ឆា អស្ស វចនំ ។ តត្រ សុទំ ភិក្ខវេ វិបស្សី កុមារោ បញ្ចហិ កាមគុណេ-ហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ ។

[៣៤] អថខោ ភិក្ខវេ វិបស្សី កុមារោ ពហុន្នំ វស្សានំ ។ បេ ។ អទ្ទសា ខោ ភិក្ខវេ វិបស្សី កុមារោ ឧយ្យានភូមឹ និយ្យន្តោ បុរិសំ អាពាធិកំ

បពិត្រព្រះសម្មតិទេព ឯព្រះកុមារនោះ លុះទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខ តូចព្រះទ័យ សញ្ជប់សញ្ជឹងថា ថ្វីយ អើហ្ន៎ សេចក្តីចាស់ តែងមានប្រាកដ ដល់សត្វលោកដែលកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈទ្រង់មានព្រះតម្រិះដូច្នេះថា កុំឲ្យវិបស្សីកុមារខានសោយរាជ្យឡើយ កុំឲ្យវិបស្សីកុមារចេញចាកគេហដ្ឋានទៅបួសឡើយ កុំឲ្យពាក្យនៃពួកព្រាហ្មណ៍ជាហោរាទៀងឡើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទពន្ធុមៈទ្រង់ផ្គត់ផ្គង់បម្រុងកាមគុណ ៥ ឲ្យច្រើនឡើងទៀត ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារ បានសោយរាជ្យសម្បត្តិ ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារខានចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួស ធ្វើយ៉ាងណា ឲ្យតែពាក្យនៃពួកព្រាហ្មណ៍ជាហោរាខុសទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ ឮថាក្នុងកាលនោះ ព្រះវិបស្សីកុមារឆ្អែតស្កប់ស្កល់ មានគ្រប់ព្រម ដោយកាមគុណទាំង ៥ ។

[៣៤] ម្នាលភិក្ខុទាំងឡាយ លំដាប់តមក ព្រះវិបស្សីកុមារ (លុះកន្លងកាល) ច្រើនឆ្នាំទៅ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារស្តេចទៅកាន់ឧទ្យាន បានទតឃើញបុរសមានអាពាធ

ទុក្ខិតំ ពាឡ្ហគិលានំ សកេ មុត្តករីសេ បលិបន្នំ សយមានំ[១] អញ្ញេហិ វុដ្ឋាបិយមានំ អញ្ញេហិ សំវេសិយមានំ ទិស្វា សារថឹ អាមន្តេសិ អយំ បន សម្ម សារថិ បុរិសោ កឹកតោ អក្ខីនិបិស្ស ន យថា អញ្ញេសំ សិរោបិស្ស ន យថា អញ្ញេសន្តិ ។ ឯសោ ខោ ទេវ ព្យាធិកោ[២] នាមាតិ ។ កឹ បនេសោ សម្ម សារថិ ព្យាធិកោ នាមាតិ ។ ឯសោ ខោ ទេវ ព្យាធិកោ នាម អប្បេវនាម តម្ហា អាពាធា វុដ្ឋហេយ្យាតិ ។ កឹ បន សម្ម សារថិ អហំបិ ព្យាធិធម្មោ ព្យាធឹ អនតីតោ ។ ត្វញ្ច ទេវ មយញ្ចម្ហា សព្វេ ព្យាធិធម្មា ព្យាធឹ អនតីតាតិ ។ តេនហិ សម្ម សារថិ

១ ឱ. សេមានំ ។ ២ ឱ. វ្យាធិតោ ។ ម. ព្យាធិតោ ។

ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ ដេកត្រាំក្នុងទឹកមូត្រនិងលាមករបស់ខ្លួន មានជនទាំងឡាយដទៃលើកឲ្យក្រោកឡើង មានជនទាំងឡាយដទៃ ផ្តេកឲ្យដេក លុះទតឃើញហើយ ត្រាស់សួរនាយសារថីថា ហែនាយសារថី សំឡាញ់ស្មើចិត្ត ចុះបុរសនេះធ្វើដូចម្តេច បានជាភ្នែករបស់គាត់មិនដូចភ្នែកពួកជនដទៃ ទាំងក្បាលរបស់គាត់ ក៏មិនដូចក្បាល នៃពួកជនដទៃ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះឈ្មោះថា បុរសឈឺ ។ ហែនាយសារថី សំឡាញ់ស្មើចិត្ត ចុះបុរសនុ៎ះព្រោះហេតុដូចម្តេច បានជាឈ្មោះថា បុរសឈឺ ។ បពិត្រព្រះសម្មតិទេព បុរសនុ៎ះធ្វើដូចម្តេច នឹងឲ្យរួចចាកជំងឺនោះបាន (ព្រោះហេតុនោះ) បានជាឈ្មោះថា បុរសឈឺ ។ ហែនាយសារថី សំឡាញ់ស្មើចិត្ត ចុះចំណែកអាត្មាអញមានជំងឺជាធម្មតា មិនកន្លងសេចក្តីឈឺចាប់ទៅបានទេ ឬដូចម្តេច ។ បពិត្រព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី ទោះយើងខ្ញុំទាំងឡាយក្តី សុទ្ធតែជាអ្នកមានជំងឺជាធម្មតា មិនកន្លងសេចក្តីឈឺចាប់ទៅបានឡើយ ។ នែនាយសារថី សំឡាញ់ស្មើចិត្ត បើដូច្នោះ

អលង្ការេន្តុ ឧយ្យានភូមិយា ឥតោ ច អន្តេបុរំ បច្ចនិយ្យាហីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សារថិ វិបស្សិស្ស កុមារស្ស បដិស្សុត្វា តតោ ច អន្តេបុរំ បច្ចនិយ្យាសិ ។ តត្រ សុទំ ភិក្ខវេ វិបស្សី កុមារោ អន្តេបុរំ គតោ ទុក្ខី ទុម្មនោ បជ្ឈាយតិ ធិរត្ថុ កិរ ភោ ជាតិ នាម យត្រ ហិ នាម ជាតស្ស ជរា បញ្ញាយិស្សតិ ព្យាធិ បញ្ញាយិស្សតីតិ ។

[៣៥] អថខោ ភិក្ខវេ ពន្ធុមា រាជា សារថឹ អាមន្តាបេត្វា ឯតទវោច កច្ចិ សម្ម សារថិ កុមារោ ឧយ្យានភូមិយា អភិរមិត្ថ កច្ចិ សម្ម សារថិ កុមារោ ឧយ្យានភូមិយា អត្តមនោ អហោសីតិ ។ ន ខោ ទេវ កុមារោ ឧយ្យានភូមិយា អភិរមិត្ថ ន ខោ ទេវ កុមារោ ឧយ្យានភូមិយា អត្តមនោ អហោសីតិ ។ កឹ បន សម្ម សារថិ អទ្ទស កុមារោ ឧយ្យានភូមឹ និយ្យន្តោតិ ។ អទ្ទសា ខោ ទេវ កុមារោ

ការទៅឧទ្យានក្នុងថ្ងៃនេះ ល្មមប៉ុណ្ណឹងហើយ ឯងចូរប្រញាប់ចេញអំពីទីនេះត្រឡប់ទៅកាន់ខាងក្នុងបុរីវិញ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះសម្មតិ-ទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចេញអំពីឧទ្យាននោះត្រឡប់មកកាន់ខាងក្នុងបុរីវិញ ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីដំណាលថាក្នុងកាលនោះ ព្រះវិបស្សីកុមារ លុះទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខ តូចព្រះទ័យ សញ្ជប់សញ្ជឹងថា ថ្វីយ អើហ្ន៎ ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដ ដល់សត្វលោកដែលកើតហើយ ។

[៣៥] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទពន្ធុមៈ ទ្រង់មានព្រះបន្ទូលឲ្យហៅនាយសារថីមកហើយ ត្រាស់សួរដូច្នេះថា នែនាយសារថី សំឡាញ់ស្មើចិត្ត កុមារមានសេចក្តីត្រេកអរ ក្នុងឧទ្យានដែរឬ នែនាយសារថី សំឡាញ់ស្មើចិត្ត កុមារមានចិត្តរីករាយ ក្នុងឧទ្យានដែរឬ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រះរាជ-កុមារ មិនបានត្រេកអរក្នុងឧទ្យានទេ បពិត្រព្រះសម្មតិទេព ព្រះរាជ-កុមារមិនមានព្រះទ័យរីករាយ ក្នុងឧទ្យានទេ ។ នែនាយសារថី សំឡាញ់ស្មើចិត្ត ចុះកាលដែលកុមារ ទៅកាន់ឧទ្យាន បានឃើញអ្វីខ្លះ ។ បពិត្រព្រះសម្មតិទេព កាលដែលព្រះរាជកុមារ ស្តេចទៅកាន់

ឧយ្យានភូមឹ និយ្យន្តោ បុរិសំ អាពាធិកំ ទុក្ខិតំ ពាឡ្ហគិលានំ សកេ មុត្តករីសេ បលិបន្នំ សយមានំ អញ្ញេហិ វុដ្ឋាបិយមានំ អញ្ញេហិ សំវេសិយមានំ ទិស្វា មំ ឯតទវោច អយំ បន សម្ម សារថិ បុរិសោ កឹ-កតោ អក្ខីនិបិស្ស ន យថា អញ្ញេសំ សិរោបិស្ស ន យថា អញ្ញេសន្តិ ឯសោ ខោ ទេវ ព្យាធិកោ ឆាមាតិ កឹ បនេសោ សម្ម សារថិ ព្យាធិកោ ឆា-មាតិ ឯសោ ខោ ទេវ ព្យាធិកោ ឆាម អប្បេវឆាម តម្ហា អាពាធា វុដ្ឋហេយ្យាតិ កឹ បន សម្ម សារថិ អហំបិ ព្យាធិធម្មោ ព្យាធឹ អនតីតោតិ ត្វញ្ច ទេវ មយញ្ចម្ហា សព្វេ ព្យាធិធម្មា ព្យាធឹ អនតីតាតិ

ឧទ្យាន បានឃើញបុរស មានអាពាធ ឈឺធ្ងន់ ដល់នូវសេចក្ដីទុក្ខ ដេកនៅក្នុងទឹកមូត្រនិងលាមករបស់ខ្លួន ដែលជនទាំងឡាយដទៃកំពុងលើកឲ្យក្រោក ជនទាំងឡាយដទៃ កំពុងផ្ដេកឲ្យដេក លុះទតឃើញហើយ ក៏ទ្រង់ត្រាស់សួរខ្ញុំព្រះអង្គដូច្នេះថា ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត ចុះបុរសនេះធ្វើដូចម្ដេច បានជាភ្នែករបស់គាត់មិនដូចភ្នែកពួកជនដទៃ ទាំងក្បាលរបស់គាត់ ក៏មិនដូចក្បាលពួកជនដទៃដែរ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ឯបុរសនុ៎ះឈ្មោះថាបុរសឈឺ ទើបព្រះរាជកុមារសួរទៀតថា នៃនាយសារថី សំឡាញ់ស្មើចិត្ត ចុះបុរសនុ៎ះ ហេតុម្ដេចបានជាឈ្មោះថា បុរសឈឺ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះធ្វើដូចម្ដេច នឹងឲ្យរួចចាកជំងឺនោះបាន (ព្រោះហេតុនោះ) បានជាឈ្មោះថា បុរសឈឺ ទើបព្រះរាជកុមារសួរទៀតថា នៃនាយសារថីជាសំឡាញ់ស្មើចិត្ត ចុះចំណែកអាត្មាអញមានជំងឺជាធម្មតា មិនកន្លងសេចក្ដីឈឺចាប់ទៅបានទេឬ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្ដី ទោះយើងខ្ញុំទាំងឡាយក្ដី សុទ្ធតែមានជំងឺជាធម្មតា មិនកន្លងសេចក្ដីឈឺចាប់

៥៣



តេនហិ សម្ម សារថិ អលន្ទានជ្ជ ឧយ្យានភូមិយា ឥ-តោ ច អន្តេបុរំ បច្ចនិយ្យាហីតិ ឯវំ ទេវាតិ ខោ អហំ ទេវ វិបស្សិស្ស កុមារស្ស បដិស្សុត្វា តតោ ច អន្តេបុរំ បច្ចនិយ្យាសឹ ឯសោ ខោ ទេវ កុមា-រោ អន្តេបុរំ គតោ ទុក្ខី ទុម្មនោ បជ្ឈាយតិ ធិរត្ថុ កិរ ភោ ជាតិ នាម យត្រ ហិ នាម ជាតស្ស ជរា បញ្ញាយិស្សតិ ព្យាធិ បញ្ញាយិស្សតីតិ ។ អថខោ ភិក្ខវេ ពន្ធុមស្ស រញ្ញោ ឯតទហោសិ មា ហេវ ខោ វិបស្សី កុមារោ ន រជ្ជំ ការេសិ មា ហេវ វិបស្សី កុមារោ អគារស្មា អនគារិយំ បព្វជិ មា ហេវ នេមិត្តានំ ព្រាហ្មណានំ សច្ចំ អស្ស វច-នន្តិ ។ អថខោ ភិក្ខវេ ពន្ធុមា រាជា វិបស្សិស្ស កុមារស្ស ភិយ្យោសោ មត្តាយ បញ្ចកាមគុណានិ ឧបដ្ឋាបេសិ យថា វិបស្សី កុមារោ រជ្ជំ ការេយ្យ យថា វិបស្សី កុមារោ ន អគារស្មា អនគារិយំ បព្វជេយ្យ យថា នេមិត្តានំ ព្រាហ្មណានំ មិច្ឆា អស្ស វចនំ ។

ទៅបានឡើយ ឯព្រះរាជកុមារ ក៏មានព្រះបន្ទូលថា នៃនាយសារថីសំឡាញ់ស្មើចិត្ត បើដូច្នោះ ការទៅក្នុងឧទ្យានក្នុងថ្ងៃនេះល្មមប៉ុណ្ណឹងហើយ ឯងចូរចេញអំពីទីនេះត្រឡប់ទៅកាន់ខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គ ទទួលស្តាប់ព្រះបន្ទូល នៃព្រះវិបស្សីកុមារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចេញអំពីឧទ្យាននោះ ត្រឡប់មកខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព លុះព្រះរាជកុមារទ្រង់ទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខ តូចព្រះទ័យ សញ្ជប់សញ្ជឹងថា ថ្វីយ អើហ្ន៎ ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដដល់សត្វលោកដែលកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទពន្ធុមៈមានព្រះតម្រិះដូច្នេះថា កុំឲ្យវិបស្សីកុមារខានសោយរាជ្យឡើយ កុំឲ្យវិបស្សីកុមារ បានចេញចាកគេហដ្ឋានទៅបួសឡើយ កុំឲ្យពាក្យនៃពួកព្រាហ្មណ៍ជាហោរាទៀងឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈផ្គត់ផ្គង់បម្រុងកាមគុណទាំង ៥ ច្រើនឡើងទៀត ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារ នៅសោយរាជសម្បត្តិបាន ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារ ខានចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស ធ្វើយ៉ាងណាឲ្យតែពាក្យនៃពួកព្រាហ្មណ៍ជាហោរាខុសទៅវិញ ។

តត្រ សុទំ ភិក្ខវេ វិបស្សី កុមារោ បញ្ចកាមគុ-ណេហិ សមប្បិតោ សមង្គិភូតោ បរិចារេតិ ។ បេ ។

[៣៦] អទ្ទសា ខោ ភិក្ខវេ វិបស្សី កុមារោ ឧយ្យានភូមឹ និយ្យន្តោ មហាជនកាយំ សន្និបតិតំ នានារត្តានញ្ច ទុស្សានំ វិលាតំ ករិយមានំ ទិស្វា សារថឹ អាមន្តេសិ កិំ នុ ខោ សោ សម្ម សា-រថី មហាជនកាយោ សន្និបតិតោ នានារត្តានញ្ច ទុស្សានំ វិលាតំ ករិយតីតិ ។ ឯសោ ខោ ទេវ កាលកតោ នាមាតិ ។ តេនហិ សម្ម សារថិ យេន សោ កាលកតោ តេន រថំ បេសេហីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សារថិ វិបស្សិស្ស កុមារស្ស បដិស្សុត្វា យេន សោ កាលកតោ តេន រថំ បេ-សេហិ ។ អទ្ទសា ខោ ភិក្ខវេ វិបស្សី កុមារោ

ម្នាលភិក្ខុទាំងឡាយ មានសេចក្ដីដំណាលថា ក្នុងកាលនោះ ព្រះវិបស្សីកុមារទ្រង់ឆ្អែតស្កប់ស្កល់ ប្រកបព្រមដោយកាមគុណទាំង ៥ ។ បេ ។

[៣៦] ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារចេញទៅកាន់ឧទ្យាន បានទតឃើញពពួកមហាជន កំពុងប្រជុំគ្នាធ្វើគ្រឿងសែង ដោយសំពត់មានពណ៌ក្រហមផ្សេងៗទាំងឡាយ លុះឃើញហើយ ក៏ត្រាស់សួរនាយសារថីថា ហៃនាយសារថី សំឡាញ់ស្មើចិត្ត ចុះពពួកមហាជននោះ ប្រជុំគ្នាធ្វើគ្រឿងសែង ដោយសំពត់មានពណ៌ក្រហមផ្សេងៗទាំងឡាយ ដើម្បីអ្វី ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះឈ្មោះថា ធ្វើមរណកាលហើយ ។ ហៃនាយសារថី សំឡាញ់ស្មើចិត្ត បើដូច្នោះ ឯងចូរបររថទៅត្រង់ទីដែលបុរសធ្វើមរណកាលនោះ (បិតនៅ) ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្ដាប់ព្រះបន្ទូលព្រះវិបស្សីកុមារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏បររថសំដៅទៅត្រង់ទី ដែលបុរសធ្វើមរណកាលនោះ (បិតនៅ) ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារបានទតទៅឃើញ

៤៤

មហាបទានសុត្តេ ទុតិយភាណវារំ តតិយទេវទូតទស្សនកថា

បេតំ កាលកតំ ទិស្វា សារថឹ អាមន្តេសិ កឹបនាយំ សម្ម សារថិ កាលកតោ នាមាតិ ។ ឯសោ ខោ ទេវ កាលកតោ នាម នទានិ តំ ទក្ខន្តិ មាតា វា បិតា វា អញ្ញេ វា ញាតិសាលោហិតា សោបិ ន ទក្ខិស្សតិ មាតរំ វា បិតរំ វា អញ្ញេ វា ញា-តិសាលោហិតេតិ ។ កឹ បន សម្ម សារថិ អហំបិ មរណធម្មោ មរណំ អនតីតោ មំបិ ន ទក្ខន្តិ ទេវោ វា ទេវី វា អញ្ញេ វា ញាតិសាលោហិតា អហំបិ ន ទក្ខិស្សាមិ ទេវំ វា ទេវឹ វា អញ្ញេ វា ញាតិសាលោហិតេតិ ។ ត្វញ្ច ទេវ មយញ្ចម្ហា សព្វេ មរណធម្មា មរណំ អនតីតា តំបិ ន ទក្ខន្តិ ទេវោ វា ទេវី វា អញ្ញេ វា ញាតិសាលោហិតា ត្វំបិ

បុរសដែលធ្វើមរណកាលទៅកាន់បរលោកហើយ លុះទតឃើញហើយ ក៏ត្រាស់សួរនាយសារថីថា ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត ចុះបុរសនុ៎ះដូចម្ដេច បានជាហៅថា ធ្វើមរណកាល ។ នាយសារថី ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះឯង បានជាឈ្មោះថា ធ្វើមរណកាល (ព្រោះថា) ក្នុងកាលឥឡូវនេះ មាតាក្ដី បិតាក្ដី ញាតិសាលោហិតទាំងឡាយដទៃក្ដី លែងឃើញបុរសនោះហើយ ទាំងបុរសនោះសោតក៏លែងឃើញមាតាបិតានិងញាតិសាលោហិតទាំងឡាយដទៃដែរ ។ ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត ចុះចំណែកអាត្មាអញមានសេចក្ដីស្លាប់ជាធម្មតា មិនកន្លងសេចក្ដីស្លាប់ទៅបាន ទោះព្រះបរមបពិត្រ (ជាព្រះវរបិតា) ក្ដី ព្រះនាងទេវី (ជាព្រះវរមាតា) ក្ដី ព្រះញាតិសាលោហិតទាំងឡាយដទៃក្ដី លែងបានឃើញនូវអាត្មាអញ ទាំងអាត្មាអញក៏លែងបានឃើញនូវព្រះបរមបពិត្រ ព្រះនាងទេវីនិងព្រះញាតិសាលោហិតទាំងឡាយដទៃដែរឬដូចម្ដេច ។ នាយសារថី ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិ-ទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្ដី យើងខ្ញុំទាំងឡាយក្ដី សុទ្ធតែមានសេចក្ដីស្លាប់ជាធម្មតា មិនកន្លងសេចក្ដីស្លាប់ទៅបានឡើយ ទាំងព្រះបរមបពិត្រក្ដី ព្រះនាងទេវីក្ដី ព្រះញាតិសាលោហិតទាំងឡាយដទៃក្ដី ក៏លែងបានឃើញព្រះអង្គ ទាំងព្រះអង្គសោត ក៏លែងបាន

ន ទក្ខិស្សសិ ទេវំ វា ទេវឹ វា អញ្ញេ វា ញា-តិសាលោហិតេតិ ។ តេនហិ សម្ម សារថិ អ-លន្ទានជ្ជ ឧយ្យានភូមិយា ឥតោ ច អន្តេបុរំ បច្ច-និយ្យាហីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សារថិ វិបស្សិស្ស កុមារស្ស បដិស្សុត្វា តតោ ច អន្តេបុរំ បច្ចនិយ្យាសិ ។ តត្រ សុទំ ភិក្ខវេ វិបស្សី កុមា-រោ អន្តេបុរំ គតោ ទុក្ខី ទុម្មនោ បជ្ឈាយតិ ធិរត្ថុ កិរ ភោ ជាតិ នាម យត្រ ហិ នាម ជាតស្ស ជរា បញ្ញាយិស្សតិ ព្យាធិ បញ្ញាយិស្សតិ មរណំ បញ្ញាយិស្សតីតិ ។

[៣៧] អថខោ ភិក្ខវេ ពន្ធុមា រាជា សារថឹ អា-មន្តាបេត្វា ឯតទវោច កច្ចិ សម្ម សារថិ កុមារោ ឧយ្យានភូមិយា អភិរមិត្ថ កច្ចិ សម្ម សារថិ កុមារោ ឧយ្យានភូមិយា អត្តមនោ អហោសីតិ ។ ន ខោ ទេវ កុមារោ ឧយ្យានភូមិយា អភិរមិត្ថ ន ខោ ទេវ កុមារោ ឧយ្យានភូមិយា អត្តមនោ អហោសីតិ ។

ឃើញព្រះបរមបពិត្រ ព្រះនាងទេវី និងព្រះញាតិសាលោហិតទាំងឡាយ ដទៃដែរ ។ ហៃនាយសារថី ជាសំឡាញ់ស្មើចិត្ត បើដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះ ល្មមប៉ុណ្ណឹងហើយ ឯងចូរចេញអំពីទីនេះ ត្រឡប់ទៅកាន់ខាងក្នុងបុរីវិញចុះ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចេញអំពីទីនោះ ត្រឡប់មកខាងក្នុងនៃបុរីវិញ ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីដំណាលថា ក្នុងកាលនោះព្រះវិបស្សីកុមារ លុះស្តេចទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខ តូចព្រះទ័យ សញ្ជប់សញ្ជឹងថា ថ្វីយ អើហ្ន៎ ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដ មរណៈតែងមានប្រាកដ ដល់សត្វលោកដែលកើតហើយ ។

[៣៧] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈទ្រង់ត្រាស់បង្គាប់ឲ្យរាជបុរសហៅនាយសារថីមក ហើយទ្រង់មានព្រះបន្ទូលសួរដូច្នេះថា នៃនាយសារថី ជាសំឡាញ់ស្មើចិត្ត កុមារមានសេចក្តីត្រេកអរចំពោះឧទ្យានដែរឬ នៃនាយសារថី ជាសំឡាញ់ស្មើចិត្ត កុមារមានចិត្តរីករាយក្នុងឧទ្យានដែរឬ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារមិនបានត្រេកអរចំពោះឧទ្យានទេ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារមិនមានព្រះទ័យរីករាយ ក្នុងឧទ្យានទេ ។

៤៧



កឹ បន សម្ម សារថិ អទ្ទស កុមារោ ឧយ្យានភូមឹ និយ្យន្តោតិ ។ អទ្ទសា ខោ ទេវ កុមារោ ឧយ្យានភូមឹ និយ្យន្តោ មហាជនកាយំ សន្និបតិតំ នានារត្តានញ្ច ទុស្សានំ វិលាតំ កយិរមានំ ទិស្វា មំ ឯតទវោច កឹ នុ ខោ សោ សម្ម សារថិ មហាជនកាយោ សន្និបតិតោ នានារត្តានញ្ច ទុស្សានំ វិលាតំ កយិរតីតិ ឯសោ ខោ ទេវ កាលកតោ នាមាតិ តេនហិ សម្ម សារថិ យេន សោ កាលកតោ តេន រថំ បេសេហីតិ ឯវំ ទេវាតិ ខោ អហំ ទេវ វិបស្សិស្ស កុមារស្ស បដិស្សុត្វា យេន សោ កាលកតោ តេន រថំ បេសេសឹ អទ្ទសា ខោ ទេវ កុមារោ បុរិសំ[១] បេតំ កាលកតំ ទិស្វា មំ ឯតទវោច កឹ បនាយំ សម្ម សារថិ កាលកតោ

១ ឱ. ម. បុរិសន្តិ បាឋោ ន ទិស្សតិ ។

នៃនាយសារថី ជាសំឡាញ់ស្មើចិត្ត ចុះកាលដែលកុមារចេញទៅកាន់ឧទ្យានបានឃើញអ្វីខ្លះ ។ នាយសារថី ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព កាលដែលព្រះរាជកុមារស្តេចទៅកាន់ឧទ្យាន បានទតពពួកមហាជនកំពុងប្រជុំគ្នាធ្វើគ្រឿងសែងដោយសំពត់ទាំងឡាយ មានពណ៌ក្រហមផ្សេង ៗ លុះទតឃើញហើយ ទ្រង់មានព្រះបន្ទូលដូច្នេះនឹងខ្ញុំព្រះអង្គថា នៃនាយសារថីជាសំឡាញ់ស្មើចិត្ត ពពួកមហាជននោះប្រជុំគ្នាធ្វើគ្រឿងសែងដោយសំពត់ទាំងឡាយ មានពណ៌ក្រហមផ្សេង ៗ ដើម្បីអ្វី ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះឯងឈ្មោះថា ធ្វើមរណកាលហើយ ទើបព្រះរាជកុមារ បង្គាប់ខ្ញុំព្រះអង្គថា ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត បើដូច្នោះ បុរសនោះធ្វើមរណកាលក្នុងទីណា ចូរបររថទៅក្នុងទីនោះ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គក៏ទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយក៏បររថសំដៅទៅទីដែលបុរសធ្វើមរណកាលនោះ (បិតនៅ) បពិត្រព្រះសម្មតិទេព ព្រះរាជកុមារក៏បានទតឃើញបុរសដែលធ្វើមរណកាល ទៅកាន់លោកខាងមុខ លុះទតឃើញហើយ ទ្រង់មានព្រះបន្ទូលដូច្នេះនឹងខ្ញុំព្រះអង្គថា ហៃនាយសារថី ជាសំឡាញ់ស្មើចិត្ត ចុះបុរសនុ៎ះ ហេតុដូចម្តេច បានជាឈ្មោះថា ធ្វើមរណកាល

ជាមាតិ ឯសោ ខោ ទេវ កាលកតោ ជាម ជនាជិ តំ ឧក្ខន្តិ មាតា វា បិតា វា អញ្ញេ វា ញាតិសាលោហិតា សោបិ ន ឧក្ខិស្សតិ មាតរំ វា បិតរំ វា អញ្ញេ វា ញាតិសាលោហិតេតិ កឹ បន សម្ម សារថិ អហំបិ មរណធម្មោ មរណំ អនតីតោ មំបិ ន ឧក្ខន្តិ ទេវោ វា ទេវី វា អញ្ញេ វា ញាតិសាលោហិតា អហំបិ ន ឧក្ខិស្សាមិ ទេវំ វា ទេវឹ វា អញ្ញេ វ ញាតិសាលោហិតេតិ ត្វញ្ច ទេវ មយញ្ចម្ហា សព្វេ មរណធម្មា មរណំ អនតីតា តំបិ ន ឧក្ខន្តិ ទេវោ វា ទេវី វា អញ្ញេ វា ញាតិសាលោហិតា ត្វំបិ ន ឧក្ខិស្សសិ ទេវំ វា ទេវឹ វា អញ្ញេ វា ញាតិសាលោហិតេតិ តេនហិ សម្ម

ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ឯបុរសនុ៎ះ បានជា ឈ្មោះថា ធ្វើមរណកាល (ព្រោះថា) ក្នុងកាលឥឡូវនេះ មាតាក្តី បិតាក្តី ញាតិសាលោហិតទាំងឡាយដទៃក្តី លែងបានឃើញបុរសនុ៎ះហើយ ទាំង បុរសនោះសោត ក៏លែងបានឃើញមាតាបិតានិងញាតិសាលោហិតទាំង- ឡាយដទៃដែរ ទើបព្រះរាជកុមារត្រាស់សួរទៀតថា ហៃនាយសារថីជា សំឡាញ់ស្មើចិត្ត ចុះចំណែកអាត្មាអញ មានសេចក្តីស្លាប់ជាធម្មតា មិន កន្លងសេចក្តីស្លាប់ទៅបាន ទោះព្រះបរមបពិត្រក្តី ព្រះនាងទេវីក្តី ព្រះញាតិ សាលោហិតទាំងឡាយដទៃក្តី លែងបានឃើញអាត្មាអញហើយ ទាំង អាត្មាអញសោត ក៏លែងបានឃើញព្រះបរមបពិត្រ ព្រះនាងទេវីនិងញាតិ- សាលោហិតទាំងឡាយដទៃដែរឬ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះ សម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី យើងខ្ញុំទាំងឡាយក្តី សុទ្ធតែមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន ទាំង ព្រះបរមបពិត្រក្តី ព្រះនាងទេវីក្តី ព្រះញាតិសាលោហិតទាំងឡាយដទៃក្តី នឹងលែងបានឃើញព្រះអង្គ ទាំងព្រះអង្គសោត ក៏នឹងលែងបានឃើញ ព្រះបរមបពិត្រ ព្រះនាងទេវី ព្រះញាតិសាលោហិតទាំងឡាយដទៃដែរ

៤៩

មហាបទានសុត្តេ ទុតិយភាណវារំ ពន្ធុមបរិវិតក្កកថា

សារថិ អលង្ទានជ្ជ ឧយ្យានភូមិយា ឥតោ ច អន្តេបុរំ បច្ចនិយ្យាហីតិ ឯវំ ទេវាតិ ខោ អហំ ទេវ វិបស្សិស្ស កុមារស្ស បដិស្សុត្វា តតោ ច អន្តេបុរំ បច្ចនិយ្យាសឹ សោ ខោ ទេវ កុមារោ អន្តេបុរំ គតោ ទុក្ខី ទុម្មនោ បជ្ឈាយតិ ធិរត្ថុ កិរ ភោ ជាតិ នាម យត្រ ហិ នាម ជាតស្ស ជរា បញ្ញាយិស្សតិ ព្យាធិ បញ្ញាយិស្សតិ មរណំ បញ្ញាយិស្សតីតិ ។ អថខោ ភិក្ខវេ ពន្ធុមស្ស រញ្ញោ ឯតទហោសិ មា ហេវ ខោ វិបស្សី កុមារោ ន រជ្ជំ ការេសិ មា ហេវ ខោ វិបស្សី កុមារោ អគារស្មា អនគារិយំ បព្វជិ មា ហេវ ខោ នេមិត្តានំ ព្រាហ្មណានំ សច្ចំ អស្ស វចនន្តិ ។ អថខោ ភិក្ខវេ ពន្ធុមា រាជា វិបស្សិស្ស កុមារស្ស ភិយ្យោសោ មត្តាយ បញ្ចកាមគុណានិ ឧបដ្ឋាបេសិ យថា វិបស្សី កុមារោ រជ្ជំ ការេយ្យ យថាបិ វិបស្សី កុមារោ ន អគារស្មា អនគារិយំ បព្វជេយ្យ យថាបិ

ទើបព្រះរាជកុមារមានព្រះបន្ទូលថា ហៃនាយសារថី ជាសំឡាញ់ស្មើចិត្ត បើដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះ ល្មមប៉ុណ្ណឹងហើយ ចូរចេញអំពីទីនេះ ត្រឡប់ទៅខាងក្នុងបុរីវិញចុះ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារ ដោយពាក្យថា បពិត្រព្រះអង្គព្រះករុណាវិសេស ហើយក៏ចេញអំពីទីនោះ ត្រឡប់មកខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព ឯព្រះរាជកុមារនោះ លុះស្តេចទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខ តូចព្រះទ័យ សញ្ជប់សញ្ជឹងថា ថ្វីយ អើហ្ន៎ ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដ មរណៈតែងមានប្រាកដ ដល់សត្វលោកដែលកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទពន្ធុមៈទ្រង់មានព្រះតម្រិះដូច្នេះថា កុំឲ្យវិបស្សីកុមារខានសោយ-រាជ្យឡើយ កុំឲ្យវិបស្សីកុមារ បានចេញចាកគេហដ្ឋានទៅបួសឡើយ កុំឲ្យពាក្យរបស់ពួកព្រាហ្មណ៍ជាហោរាពិតឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈទ្រង់ផ្គត់ផ្គង់កាមគុណទាំង ៥ ច្រើនឡើងទៀត ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារសោយរាជសម្បត្តិបាន ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារខានចេញចាកគេហដ្ឋានទៅបួស ធ្វើយ៉ាងណា

នេមិត្តានំ ព្រាហ្មណានំ មិច្ឆា អស្ស វចនំ ។ តត្រ សុទំ ភិក្ខវេ វិបស្សី កុមារោ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ ។

[៣៨] អថខោ ភិក្ខវេ វិបស្សី កុមារោពហុន្នំ វស្សានំ ពហុន្នំ វស្សសតានំ ពហុន្នំ វស្សសហស្សានំ អច្ចយេន សារថឹ អាមន្តេសិ យោជេហិ សម្ម សារថិ ភទ្រានិ ភទ្រានិ យានានិ ឧយ្យានភូមឹ គច្ឆាម សុភូមឹ ទស្សនាយាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សារថិ វិ-បស្សិស្ស កុមារស្ស បដិស្សុត្វា ភទ្រានិ ភទ្រានិ យានានិ យោជេត្វា[១] វិបស្សិស្ស កុមារស្ស បដិវេទេសិ យុត្តានិ ខោ តេ ភទ្រានិ ភទ្រានិ យានានិ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ ភិក្ខវេ វិបស្សី កុមារោ ភទ្រំ យានំ អភិរុហិត្វា ភទ្រេហិ ភទ្រេហិ យានេហិ ឧយ្យាន-ភូមឹ និយ្យាសិ ។ អទ្ទសា ខោ ភិក្ខវេ វិបស្សី កុ-មារោ ឧយ្យានភូមឹ និយ្យន្តោ បុរិសំ ជិណ្ណំ គោបានសិវង្កំ

---

១ ឱ. យោជាបេត្វា ។

ឲ្យតែពាក្យរបស់ពួកព្រាហ្មណ៍ជាហោរាទៅជាពាក្យខុស ។ ម្នាលភិក្ខុទាំង-ឡាយ មានសេចក្តីដំណាលថា ក្នុងកាលនោះ ព្រះវិបស្សីកុមារទ្រង់ឆ្អែតស្កប់ស្កល់ ប្រកបព្រមដោយកាមគុណទាំង ៥ ។

[៣៨] ម្នាលភិក្ខុទាំងឡាយ លំដាប់តមក ព្រះវិបស្សីកុមារ លុះកន្លងឆ្នាំច្រើនរយ ច្រើនពាន់ទៅ ទ្រង់ហៅនាយសារថីមកថា ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត ចូរឯងទឹមយានទាំងឡាយដែលល្អ ៗ យើងនឹងទៅកាន់ឧទ្យានដើម្បីមើលនូវទីល្អ ៗ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារ ដោយពាក្យថា បពិត្រព្រះអង្គ ព្រះករុណាវិសេស ហើយក៏ទឹមយានទាំងឡាយដែលល្អ ៗ រួចក្រាបបង្គំទូលដល់ព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព យានទាំងឡាយដែលល្អ ៗ ខ្ញុំព្រះអង្គបានទឹមស្រេចហើយ ឥឡូវនេះ សូមទ្រង់ជ្រាបនូវកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សី-កុមារទ្រង់ឡើងកាន់យានដ៏ល្អ ហើយស្តេចទៅកាន់ឧទ្យាន ដោយយានទាំងឡាយដ៏ល្អៗ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះវិបស្សីកុមារស្តេចទៅកាន់ឧទ្យាន ក៏បានទតឃើញបុរសមានសីសៈរលីង ជាអ្នកបួស

៦១



កាសាយវសនំ ទិស្វា សារថឹ អាមន្តេសិ អយំ បន សម្ម សារថិ បុរិសោ កឹកតោ សីសំបិស្ស ន យថា អញ្ញេសំ វត្ថានិបិស្ស ន យថា អញ្ញេសន្តិ ។ ឯសោ ខោ ទេវ បព្វជិតោ នាមាតិ ។ កឹ បនេសោ សម្ម សារថិ បព្វជិតោ នាមាតិ ។ ឯសោ ខោ ទេវ បព្វជិ-តោ នាម សាធុ ធម្មចរិយា សាធុ សមចរិយា សាធុ កុសលចរិយា[១] សាធុ បុញ្ញកិរិយា សាធុ អវិហឹសា សាធុ ភូតានុកម្បាតិ ។ សាធុ ខោ សោ សម្ម សារ-ថិ បព្វជិតោ នាម សាធុ[២] ធម្មចរិយា សាធុ សម-ចរិយា សាធុ កុសលចរិយា សាធុ បុញ្ញកិរិយា សាធុ អវិហឹសា សាធុ ភូតានុកម្បា[៣] តេនហិ សម្ម សារថិ យេន សោ បព្វជិតោ តេន រថំ បេសេហីតិ ។

---

១ ឱ. ម. កុសលកិរិយា ។ ២ ឱ. ម. ឯត្ថន្តរេ ហិ សម្ម សារថីតិ បទត្តយំ ទិស្សតិ ។ ៣ ម. ភូតានុកម្បាតិ ។

ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ លុះឃើញហើយ ទ្រង់សួរនាយសារថីថា ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត ចុះបុរសនុ៎ះធ្វើដូចម្តេច បានជាក្បាលរបស់គាត់ មិនដូចជាក្បាលពួកជនដទៃ ទាំងសំពត់របស់គាត់ ក៏មិនដូចជាសំពត់ពួកជនដទៃដូច្នេះ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះឯងឈ្មោះថា អ្នកបួស ។ ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត ចុះបុរសនោះហេតុដូចម្តេច បានជាឈ្មោះថា អ្នកបួស ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះបានជាឈ្មោះថា អ្នកបួស ព្រោះប្រព្រឹត្តធម៌ដោយប្រពៃ ព្រោះប្រព្រឹត្តនូវធម៌ដ៏ស្មើដោយប្រពៃ ព្រោះប្រព្រឹត្តកុសលដោយប្រពៃ ព្រោះធ្វើអំពើបុណ្យដោយប្រពៃ ព្រោះមិនបានបៀតបៀនដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វដោយប្រពៃ ។ ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត បុរសនោះឈ្មោះថា អ្នកបួស ព្រោះប្រព្រឹត្តធម៌ដោយប្រពៃ ព្រោះប្រព្រឹត្តធម៌ដ៏ស្មើដោយប្រពៃ ព្រោះប្រព្រឹត្តកុសលដោយប្រពៃ ព្រោះធ្វើអំពើបុណ្យដោយប្រពៃ ព្រោះមិនបានបៀតបៀនដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វដោយប្រពៃ ជាការស្រួលពិត ហៃនាយសារថីជាសំឡាញ់ស្មើចិត្ត បើដូច្នោះ ចូរអ្នកបររថទៅត្រង់ទីដែលអ្នកបួសនោះឋិតនៅចុះ ។

ឯវំ ទេវាតិ ខោ ភិក្ខវេ សារថិ វិបស្សិស្ស កុមារស្ស បដិស្សុត្វា យេន សោ បព្វជិតោ តេន រថំ បេសេសិ ។ អថខោ ភិក្ខវេ វិបស្សី កុមារោ តំ បព្វជិតំ ឯតទវោច ត្វំ បន សម្ម កឹកតោ សីសំបិ តេ ន យថា អញ្ញេសំ វត្ថានិបិ តេ ច យថា អញ្ញេសន្តិ ។ អហំ ខោ ទេវ បព្វជិតោ នាមាតិ ។ កឹ បន ត្វំ សម្ម បព្វជិតោ នាមាតិ ។ អហំ ខោ ទេវ បព្វជិតោ នាម សាធុ ធម្មចរិយា សាធុ សមចរិយា សាធុ កុសលចរិយា សាធុ បុញ្ញកិរិយា សាធុ អវិហឹសា សាធុ ភូតានុកម្បាតិ ។ សាធុ ខោ ត្វំ សម្ម បព្វជិតោ នាម សាធុ[១] ធម្មចរិយា សាធុ សមចរិយា សាធុ កុសលចរិយា សាធុ បុញ្ញកិរិយា សាធុ អវិហឹសា សាធុ ភូតានុកម្បាតិ ។

---

១ ឱ. ឯត្តន្តរេ ហិ សម្ម សារថីតិ ទិស្សន្តិ ។

ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារ ដោយពាក្យថា បពិត្រព្រះអង្គ ព្រះករុណាវិសេស ហើយក៏បររថទៅត្រង់អ្នកបួសនោះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីកុមារទ្រង់មានព្រះបន្ទូលសួរដូច្នេះនឹងអ្នកបួសនោះថា នែអ្នកជាសំឡាញ់ស្មើចិត្ត ចុះអ្នកធ្វើដូចម្តេច បានជាក្បាលរបស់អ្នកមិនដូចជាក្បាលពួកជនដទៃ ទាំងសំពត់របស់អ្នក ក៏មិនដូចជាសំពត់ពួកជនដទៃដូច្នេះ ។ អ្នកបួសថ្វាយព្រះពរថា បពិត្រព្រះសម្មតិទេព អាត្មាភាពហ្នឹងហើយ ដែលហៅថា អ្នកបួស ។ នែអ្នកជាសំឡាញ់ស្មើចិត្ត ព្រោះហេតុដូចម្តេច បានជាអ្នកឈ្មោះថា អ្នកបួស ។ បពិត្រព្រះសម្មតិទេព អាត្មាភាពហ្នឹងឯងបានជាឈ្មោះថា អ្នកបួស ព្រោះប្រព្រឹត្តធម៌ ដោយប្រពៃ ព្រោះប្រព្រឹត្តធម៌ដ៏ស្មើ ដោយប្រពៃ ព្រោះប្រព្រឹត្តកុសល ដោយប្រពៃ ព្រោះធ្វើអំពើបុណ្យ ដោយប្រពៃ ព្រោះមិនបានបៀតបៀន ដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វ ដោយប្រពៃ ។ ព្រះវិបស្សីកុមារមានព្រះរាជឱង្ការថា នែអ្នកជាសំឡាញ់ស្មើចិត្ត អ្នកឈ្មោះថា អ្នកបួស ព្រោះប្រព្រឹត្តធម៌ ដោយប្រពៃ ព្រោះប្រព្រឹត្តធម៌ដ៏ស្មើ ដោយប្រពៃ ព្រោះប្រព្រឹត្តកុសល ដោយប្រពៃ ព្រោះធ្វើអំពើបុណ្យ ដោយប្រពៃ ព្រោះមិនបានបៀតបៀន ដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វដោយប្រពៃ ជាការល្អណាស់ ។

អថខោ ភិក្ខវេ វិបស្សី កុមារោ សារថឹ អាមន្តេសិ តេនហិ សម្ម សារថិ រថំ អាទាយ ឥតោ វ អន្តេបុរំ បច្ចានិយ្យាហិ អហំ បន ឥធេវ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សាមីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ[១] សារថិ វិបស្សិស្ស កុមារស្ស បដិស្សុត្វា រថំ អាទាយ តតោ ច អន្តេបុរំ បច្ចានិយ្យាសិ ។ វិបស្សី បន កុមារោ តត្ថេវ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិ ។ អស្សោសិ ខោ ភិក្ខវេ ពន្ធុមតិយា រាជធានិយា មហាជនកាយោ ចតុរាសី-តិចាណសហស្សានិ វិបស្សី កិរ កុមារោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោតិ ។ សុត្វាន នេសំ ឯតទហោសិ

១ ឱ. ភិក្ខវេតិ ន ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះវិបស្សីកុមារ ទ្រង់មានព្រះរាជឱង្ការនឹងនាយសារថីថា ហៃនាយសារថី ជាសំឡាញ់ស្មើចិត្ត បើដូច្នោះ ចូរឯងនាំយករថចេញ អំពីទីនេះត្រឡប់ទៅខាងក្នុងបុរីវិញចុះ ចំណែកអញនឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ លះគេហដ្ឋានបួសក្នុងទីនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារ ដោយពាក្យថា បពិត្រព្រះអង្គ ព្រះករុណាវិសេស ហើយក៏នាំយករថចេញអំពីទីនោះ ត្រឡប់ទៅខាងក្នុងបុរីវិញ ។ ព្រះវិបស្សីកុមារ ទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ ទ្រង់កាសាវពស្ត្រទាំងឡាយ លះគេហដ្ឋានទ្រង់ព្រះផ្នួសក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ឯពពួកមហាជនក្នុងពន្ធុមតីរាជធានី ប្រមាណ ៨ ហ្មឺន ៤ ពាន់នាក់ បានឮដំណឹងថា ព្រះវិបស្សីកុមារ ទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ ទ្រង់កាសាវពស្ត្រទាំងឡាយ លះគេហដ្ឋានទ្រង់ព្រះផ្នួសហើយ ។ លុះពពួកមហាជនទាំងនោះបានឮដំណឹងហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា

ន ហិ ឥទំ ឱរកោ ធម្មវិនយោ ន សា ឱរកា បព្វជ្ជា យត្ថ វិបស្សី កុមារោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ វិបស្សី ហិ[១] នាម កុមារោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សតិ កិមង្គំ បន ន[២] មយន្តិ ។ អថខោ ភិក្ខវេ មហាជនកាយោ[៣] ចតុរាសីតិបាណ-សហស្សានិ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា វិបស្សឹ ពោធិសត្តំ អគារស្មា អន-គារិយំ បព្វជិតំ អនុបព្វជឹសុ ។ តាយ សុទំ ភិក្ខវេ បរិសាយ បរិវុតោ វិបស្សី ពោធិសត្តោ គាមនិគមជ-នបទរាជធានីសុ ចារិកំ ចរតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស រហោគតស្ស បដិសល្លីនស្ស

---

១ ឱ. បិ ។ ២ ម. ន សទ្ធោ ន ទិស្សតិ ។ ៣ ឱ. សោ ភិក្ខវេ មហាជនកាយោ ។ ម. មហាជនកាយោ ។

ព្រះវិបស្សីកុមារ ទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ ទ្រង់កាសាវពស្ត្រទាំង-ឡាយ លះគេហដ្ឋានទៅទ្រង់ព្រះផ្នួស ចំពោះធម្មវិន័យនិងបព្វជ្ជាណា ធម្មវិន័យនិងបព្វជ្ជានោះ មិនថោកទាបឡើយ អម្បាលព្រះវិបស្សីកុមារ ម្ដេចទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ ទ្រង់កាសាវពស្ត្រទាំងឡាយ លះគេហដ្ឋានទ្រង់ព្រះផ្នួសទៅហើយ ចុះយើងរាល់គ្នា ម្ដេចក៏មិនបួស ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ពពួកមហាជនទាំង ៨ ហ្មឺន ៤ ពាន់នាក់ ក៏កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈទាំងឡាយ ហើយបួសតាមព្រះវិបស្សីពោធិសត្វ ដែលចេញចាកព្រះរាជនិវេសន៍ទ្រង់ព្រះផ្នួសក្នុងកាលនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្ដីដំណាលថា ព្រះវិបស្សីពោធិសត្វ មានពួកបរិសទ្យទាំងនោះ ហែហមស្ដេចទៅកាន់ចារិកក្នុងស្រុកនិគមជនបទរាជធានីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ ទៅគង់ក្នុងទីស្ងាត់ទ្រង់ពួនសម្ងំនៅ

ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ន ខោ បនេតំ បតិរូបំ យោហំ អាកិណ្ណោ វិហរាមិ យន្នូនាហំ ឯកោ គណម្ហា វូបកដ្ឋោ វិហរេយ្យន្តិ ។ អថខោ ភិក្ខវេ វិបស្សី ពោធិសត្តោ អបរេន សមយេន ឯកោ គណម្ហា វូបកដ្ឋោ វិហាសិ ។ អញ្ញានេវ តានិ ចតុរាសីតិបព្វជិតសហស្សានិ អគមំសុ ។ អញ្ញេន វិបស្សី ពោធិសត្តោ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស វាសុបគតស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កិច្ឆំ វតាយំ លោកោ អាបន្នោ ជាយតិ ច ជីយតិ ច មីយតិ ច ចវតិ ច ឧបបជ្ជតិ ច អថ ច បនិមស្ស ទុក្ខស្ស និស្សរណំ នប្បជានាតិ ជរាមរណស្ស កុ-ទុស្សុ[១] នាម ឥមស្ស ទុក្ខស្ស និស្សរណំ បញ្ញា-យិស្សតិ ជរាមរណស្សាតិ ។

---

១ ឱ. ម. កុទាស្សុ ។

ក៏មានសេចក្តីត្រិះរិះ ក្នុងព្រះទ័យដូច្នេះថា អាត្មាអញដែលនៅច្របូកច្របល់នេះ ជាការមិនសមគួរឡើយ គួរតែអាត្មាអញ ចេញចាកពួកទៅនៅតែម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ លុះសម័យជាខាងក្រោយមក ព្រះវិបស្សីពោធិសត្វ ចេញចាកពួក ទៅគង់តែមួយព្រះអង្គ ។ ឯពួកបព្វជិតទាំង ៨ ហ្មឺន ៤ ពាន់រូបនោះ ក៏បានទៅនៅដោយឡែកផ្សេង ។ ព្រះវិបស្សីពោធិសត្វ ក៏ចេញទៅនៅដោយឡែកផ្សេង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីពោធិសត្វ ចូលទៅគង់សម្ងំនៅក្នុងទីស្ងាត់ មានសេចក្តីត្រិះរិះ ក្នុងព្រះទ័យយ៉ាងនេះថា ឱសត្វលោកនេះ ដល់នូវសេចក្តីលំបាកណាស់តើ រមែងកើតហើយចាស់ ៗ ហើយស្លាប់ ៗ ហើយច្យុត ៗ ហើយកើតឡើងទៀត ប៉ុន្តែមិនដឹងច្បាស់នូវធម៌ជាគ្រឿងរលាស់ខ្លួនចេញចាកទុក្ខនេះឡើយ បើមិនដឹងច្បាស់នូវធម៌ជាគ្រឿងរលាស់ចេញចាកទុក្ខ គឺជរានិងមរណៈនេះហើយ កាលណាឡើយនឹងធ្វើនូវការរលាស់ចេញចាកទុក្ខ គឺជរានិងមរណៈឲ្យប្រាកដឡើងបាន ។

[៣៩] អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ជរាមរណំ ហោតិ កឹបច្ចយា ជរាមរណន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ជាតិយា ខោ សតិ ជរាមរណំ ហោតិ ជាតិប្បច្ចយា ជរាមរណន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ជាតិ ហោតិ កឹបច្ចយា ជាតីតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ភវេ ខោ សតិ ជាតិ ហោតិ ភវប្បច្ចយា ជាតីតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ភវោ ហោតិ កឹបច្ចយា ភវោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ឧបាទានេ ខោ សតិ ភវោ ហោតិ

[៣៩] ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីហ្ន៎មានឡើង ទើបមានជរា និងមរណៈ ជរានិងមរណៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលបើជាតិមានហើយ ទើបមានជរានិងមរណៈ ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះទៀតថា កាលធម្មជាតអ្វីមានហ្ន៎ ទើបកើតមានជាតិ ជាតិកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សី-ពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលភពមាន ជាតិក៏មាន ជាតិកើតមាន ព្រោះភពជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិ-សត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ ភពទើបកើតមាន ភពកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលឧបាទានកើតមាន ភពក៏កើតមាន

ឧបាទានប្បច្ចយា ភវោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ឧបាទានំ ហោតិ កឹបច្ចយា ឧបាទានន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិ-ការា អហុ បញ្ញាយ អភិសមយោ តណ្ហាយ ខោ សតិ ឧបាទានំ ហោតិ តណ្ហាបច្ចយា ឧបាទានន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ តណ្ហា ហោតិ កឹបច្ចយា តណ្ហា-តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ វេទនាយ ខោ សតិ តណ្ហា ហោតិ វេទនាបច្ចយា តណ្ហាតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ វេទនា ហោតិ កឹបច្ចយា វេទនាតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ផស្សេ ខោ សតិ វេទនា ហោតិ

ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ ទើបឧបាទានកើតមាន ឧបាទានកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលតណ្ហាកើតមាន ឧបាទានទើបកើតមាន ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ តណ្ហាទើបកើតមាន តណ្ហាកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះទ័យ ដោយព្រះយោបល់ ក៏ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលវេទនាកើតមាន តណ្ហាទើបកើតមាន តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សី-ពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ វេទនាទើបកើតមាន វេទនាកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យ ដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលផស្សៈកើតមាន វេទនាទើប

ផស្សប្បច្ចយា វេទនាតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ ផស្សោ ហោតិ កឹបច្ចយា ផស្សោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ សឡាយតនេ ខោ សតិ ផស្សោ ហោតិ សឡាយតនប្បច្ចយា ផស្សោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ សឡាយតនំ ហោតិ កឹបច្ចយា សឡាយតនន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ នាមរូបេ ខោ សតិ សឡាយតនំ ហោតិ នាមរូបប្បច្ចយា សឡាយតនន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ នាមរូបំ ហោតិ កឹបច្ចយា នាមរូបន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ វិញ្ញាណេ ខោ សតិ

កើតមាន វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ ផស្សៈទើបកើតមាន ផស្សៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យ ដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលសឡាយតនៈកើតមាន ផស្សៈទើបកើតមាន ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ សឡាយតនៈទើបកើតមាន សឡាយតនៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះទ័យ ដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលនាមរូបកើតមាន សឡាយតនៈទើបកើតមាន សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ នាមរូបទើបកើតមាន នាមរូបកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលវិញ្ញាណកើតមាន

៦៩



នាមរូបំ ហោតិ វិញ្ញាណប្បច្ចយា នាមរូបន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ សតិ វិញ្ញាណំ ហោតិ កឹបច្ចយា វិញ្ញា-ណន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ នាមរូបេ ខោ សតិ វិញ្ញាណំ ហោតិ នាមរូបប្បច្ចយា វិញ្ញាណន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ បច្ចុទាវត្តតិ ខោ ឥទំ វិញ្ញាណំ នាម-រូបម្ហា នាបរំ គច្ឆតិ ឯត្តាវតា ជាយេថ វា ជីយេថ វា មីយេថ វា ចវេថ វា ឧបបជ្ជេថ វា យទិទំ នាម រូបប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាម-រូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ

នាមរូបទើបកើតមាន នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ វិញ្ញាណទើបកើតមាន វិញ្ញាណកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលនាមរូបកើតមាន វិញ្ញាណទើបកើតមាន វិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា វិញ្ញាណនេះ តែងត្រឡប់ទៅត្រឡប់មក មិនទៅហួសខាងនាយអំពីនាមរូបឡើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ បានជាសត្វកើតហើយចាស់ ៗ ហើយស្លាប់ ៗ ហើយច្យុត ៗ ហើយកើតឡើងទៀត វិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ

ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ សមុទយោ សមុទយោតិ ខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

[៤០] អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ ជរាមរណំ ន ហោតិ កិស្ស និរោធា ជរាមរណនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ជាតិយា ខោ អសតិ ជរាមរណំ ន ហោតិ ជាតិនិរោធា ជរាមរណនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទ-

វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមានព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សោកៈ បរិទេវៈ (សេចក្ដីខ្សឹកខ្សួល) ទុក្ខ ទោមនស្ស និងឧបាយាសៈ (ទង្គឹះក្នុងចិត្ត) ក៏កើតមានព្រម ការកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានដោយអាការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុ ញាណ បញ្ញា វិជ្ជា ពន្លឺ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុន កើតឡើងដល់ព្រះវិបស្សីពោធិសត្វថា កើតឡើង កើតឡើងហ្ន៎ ។

[៤០] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីពោធិសត្វ មានសេចក្ដីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបជរានិងមរណៈមិនមាន ជរានិងមរណៈរលត់ទៅ ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្ដីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលជាតិមិនមាន ជរានិងមរណៈក៏មិនមាន ការរលត់ទៅនៃជរានិងមរណៈព្រោះរលត់ជាតិដូច្នេះ ក៏កើតមានឡើងដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះព្រះវិបស្សីពោធិសត្វ មានសេចក្ដីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិន

៧១



ហោសិ កិម្ហិ នុ ខោ អសតិ ជាតិ ន ហោតិ កិស្ស និរោធា ជាតិនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ ភវេ ខោ អសតិ ជាតិ ន ហោតិ ភវនិ-
រោធា ជាតិនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ ភវោ ន ហោតិ កិស្ស និរោធា ភវនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិកា-
រា អហុ បញ្ញាយ អភិសមយោ ឧបាទានេ ខោ អសតិ ភវោ ន ហោតិ ឧបាទាននិរោធា ភវនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ ឧបាទានំ ន ហោតិ កិស្ស និរោធា ឧបាទាននិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ តណ្ហាយ ខោ អសតិ ឧបា-
ទានំ ន ហោតិ តណ្ហានិរោធា ឧបាទាននិរោធោ-
តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស

មានហ្ន៎ ទើបជាតិមិនមាន ការរលត់ទៅនៃជាតិ ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលបើភពមិនមាន ជាតិក៏មិនមាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភពដូច្នេះ កើតមានឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបភពមិនមាន ការរលត់ទៅនៃភព ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលឧបាទានមិនមាន ភពក៏មិនមាន ការរលត់ទៅនៃភព ព្រោះរលត់ឧបាទានដូច្នេះ ក៏កើតមានឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបឧបាទានមិនមាន ការរលត់ទៅនៃឧបាទាន ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលតណ្ហាមិនមាន ឧបាទានក៏មិនមាន ការរលត់ទៅនៃឧបាទាន ព្រោះរលត់តណ្ហាដូច្នេះ ក៏កើតមានឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ

ឯតទហោសិ កិម្ហិ នុ ខោ អសតិ តណ្ហា ន ហោតិ កិស្ស និរោធា តណ្ហានិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អ-ហុ បញ្ញាយ អភិសមយោ វេទនាយ ខោ អសតិ តណ្ហា ន ហោតិ វេទនានិរោធា តណ្ហានិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោ-សិ កិម្ហិ នុ ខោ អសតិ វេទនា ន ហោតិ កិស្ស និរោធា វេទនានិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិ-ស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញា-យ អភិសមយោ ផស្សេ ខោ អសតិ វេទនា ន ហោតិ ផស្សនិរោធា វេទនានិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ ផស្សោ ន ហោតិ កិស្ស និរោធា ផស្សនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ សឡាយតនេ ខោ អសតិ ផស្សោ ន ហោតិ សឡាយតននិរោធា ផស្សនិរោធោតិ ។

មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបតណ្ហាមិនមាន ការរលត់ទៅនៃតណ្ហា ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលវេទនាមិនមាន តណ្ហាក៏មិនមាន ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនាដូច្នេះ ក៏កើតមានឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបវេទនាមិនមាន ការរលត់ទៅនៃវេទនា ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលផស្សៈមិនមាន វេទនាក៏មិនមាន ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈដូច្នេះ ក៏កើតឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបផស្សៈមិនមាន ការរលត់ទៅនៃផស្សៈ ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលសឡាយតនៈមិនមាន ផស្សៈក៏មិនមាន ការរលត់ទៅនៃផស្សៈ ព្រោះរលត់សឡាយតនៈដូច្នេះ ក៏កើតឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណា ដោយព្រះយោបល់ ។

អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ សឡាយតនំ ន ហោតិ កិស្ស និរោធា សឡាយតននិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ នាមរូបេ ខោ អសតិ ស-ឡាយតនំ ន ហោតិ នាមរូបនិរោធា សឡាយត-ននិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិ-សត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ នាមរូបំ ន ហោតិ កិស្ស និរោធា នាមរូបនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិ-សោមនសិការា អហុ បញ្ញាយ អភិសមយោ វិញ្ញា-ណេ ខោ អសតិ នាមរូបំ ន ហោតិ វិញ្ញាណនិរោធា នាមរូបនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ កិម្ហិ នុ ខោ អសតិ វិញ្ញាណំ ន ហោតិ កិស្ស និរោធា វិញ្ញាណនិរោធោតិ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្ដីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបសឡាយតនៈមិនមាន ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្ដីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលនាមរូបមិនមាន សឡាយតនៈ ក៏មិនមាន ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់នាមរូបដូច្នេះ ក៏កើតមានឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្ដីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វី មិនមានហ្ន៎ ទើបនាមរូបមិនមាន ការរលត់ទៅនៃនាមរូប ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្ដីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលវិញ្ញាណមិនមាន នាមរូបក៏មិនមាន ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណដូច្នេះ ក៏កើតឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្ដីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វី មិនមានហ្ន៎ ទើបវិញ្ញាណមិនមាន ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ធម្មជាតអ្វី ។

អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស យោនិសោមនសិការា អហុ បញ្ញាយ អភិសមយោ នាមរូបេ ខោ អសតិ វិញ្ញាណំ ន ហោតិ នាមរូបនិរោធា វិញ្ញាណនិរោធោតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស ឯតទហោសិ អធិគតោ ខោ ម្យាយំ មគ្គោ[១] ពោធាយ[២] យទិទំ នាមរូបនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុ-

១ ឱ. វិបស្សនាមគ្គោ ។ ២ ម. សម្ពោធាយ ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលនាមរូបមិនមាន វិញ្ញាណក៏មិនមាន ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់នាមរូបដូច្នេះ ក៏កើតឡើង ដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា វិបស្សនាមគ្គនេះ អាត្មាអញ បានត្រាស់ដឹងហើយ ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់នាមរូប ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណ ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ទៅនៃផស្សៈ ព្រោះរលត់សឡាយតនៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈ ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនា ការរលត់ទៅនៃឧបាទាន ព្រោះរលត់តណ្ហា ការរលត់ទៅនៃភព ព្រោះរលត់ទៅនៃឧបាទាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភព ជរានិងមរណៈរលត់ ព្រោះរលត់ជាតិ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈនិង

ចាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ និរោធោ និរោធោតិ ខោ ភិក្ខវេ វិបស្សិស្ស ពោធិសត្តស្ស បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

[៤១] អថខោ ភិក្ខវេ វិបស្សី ពោធិសត្តោ អបរេន សមយេន បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហាសិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ តស្ស បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សិនោ វិហរតោ នចិរស្សេវ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចីតិ ។

ទុតិយភាណវារំ ។

*ឧបាយាសៈក៏រលត់ទៅ ការរលត់ទៅនៃកងទុក្ខទាំងអស់នេះ រមែងមានដោយអាការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុ ញាណ បញ្ញា វិជ្ជា ពន្លឺ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុន ក៏កើតឡើង ដល់ព្រះវិបស្សីពោធិសត្វថា រលត់ រលត់ហ្ន៎ ។*

[៤១] *ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ លុះសម័យជាខាងក្រោយមក ព្រះវិបស្សីពោធិសត្វ ទ្រង់ពិចារណានូវការកើត និងការរលត់ទៅក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបយ៉ាងនេះ ការកើតឡើងនៃរូបយ៉ាងនេះ ការរលត់ទៅនៃរូបយ៉ាងនេះ វេទនាយ៉ាងនេះ ការកើតឡើងនៃវេទនាយ៉ាងនេះ ការរលត់ទៅនៃវេទនាយ៉ាងនេះ សញ្ញាយ៉ាងនេះ ការកើតឡើងនៃសញ្ញាយ៉ាងនេះ ការរលត់ទៅនៃសញ្ញាយ៉ាងនេះ សង្ខារទាំងឡាយយ៉ាងនេះ ការកើតឡើងនៃសង្ខារទាំងឡាយ យ៉ាងនេះ ការរលត់ទៅនៃសង្ខារទាំងឡាយយ៉ាងនេះ វិញ្ញាណយ៉ាងនេះ ការកើតឡើងនៃវិញ្ញាណយ៉ាងនេះ ការរលត់ទៅនៃវិញ្ញាណយ៉ាងនេះ ។ កាលដែលព្រះវិបស្សីពោធិសត្វ ទ្រង់ពិចារណានូវកិរិយាកើតឡើង និងការរលត់ទៅក្នុងឧបាទានក្ខន្ធទាំង ៥ មិនយូរប៉ុន្មាន ព្រះទ័យនៃព្រះអង្គ ក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានឧបាទាន ។*

ចប់ ទុតិយភាណវារៈ ។

[៤២] អថខោ ភិក្ខវេ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឯតទហោសិ យន្នូនាហំ ធម្មំ ទេសេយ្យន្តិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឯតទហោសិ អធិគតោ ខោ មេ អយំ[១] ធម្មោ គម្ភីរោ ទុទ្ទសោ ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ និបុណោ បណ្ឌិតវេទនីយោ អាលយរាមា ខោ បនាយំ បជា អាលយរតា អាលយសម្មុទិតា អាលយរាមាយ ខោ បន បជាយ អាលយរតាយ អាលយសម្មុទិតាយ ទុទ្ទសំ ឥទំ ឋានំ យទិទំ ឥទប្បច្ចយតា បដិច្ចសមុប្បាទោ ឥទម្បិ ខោ ឋានំ ទុទ្ទសំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ អហញ្ចេវ ខោ បន ធម្មំ ទេសេយ្យំ បរេ ច មេ ន អាជានេយ្យុំ សោ មមស្ស កិលមថោ សា មមស្ស វិហេសាតិ ។

---
១ ម. ម្យាយំ ។

[៤២] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា គួរតែ តថាគត សម្តែងធម៌ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា ធម៌ដែលតថាគត ត្រាស់ដឹងហើយនេះ ជាធម៌ជ្រាលជ្រៅ បុគ្គលឃើញបានដោយក្រ ត្រាស់ដឹងតាមបានដោយក្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ថ្លៃថ្លា ជាធម៌ដែល បុគ្គលត្រិះរិះយកឯងមិនបាន ជាធម៌ល្អិត មានតែបណ្ឌិត ទើបដឹងបាន ក៏ពួកសត្វនេះមានអាល័យ គឺកាមគុណ ជាទីត្រេកអរ ត្រេកអរក្នុងកាម-គុណ រីករាយក្នុងកាមគុណ បដិច្ចសមុប្បាទ ដែលមានកាមគុណនេះ ជា បច្ច័យ បដិច្ចសមុប្បាទនេះ ជាឋានៈ ដែលពួកសត្វមានកាមគុណជាទីត្រេក-អរ ត្រេកអរក្នុងកាមគុណ រីករាយក្នុងកាមគុណ ឃើញបានដោយក្រ ធម៌ដែលជាគ្រឿងរម្ងាប់នូវសង្ខារទាំងពួង លះបង់នូវឧបធិក្កិលេសទាំងពួង អស់ទៅនៃតណ្ហា ប្រាសចាករាគៈ រលត់ (នូវកងទុក្ខ) និងព្រះនិព្វាន នេះ ឯងក៏ជាឋានៈ ដែលពួកសត្វឃើញបានដោយក្រ បើទុកជាតថាគតសម្តែង ធម៌ ពួកសត្វដទៃ ក៏មិនគប្បីដឹងច្បាស់បាន សេចក្តីលំបាកកាយនោះ នឹង មានដល់តថាគត ការបៀតបៀនកាយនោះ នឹងមានដល់តថាគត ។

## ៧៧



អបិស្សុទំ[១] ភិក្ខវេ វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឥមា អនច្ឆរិយា គាថា បដិភំសុ បុព្វេ អស្សុតបុព្វា ។

កិច្ឆេន មេ អធិគតំ
ហលន្ទានិ បកាសិតុំ
រាគទោសបរេតេហិ
នាយំ ធម្មោ សុសម្ពុធោ ។
បដិសោតគាមឹ និបុណំ
គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ
តមោក្ខន្ធេន អាវុតាតិ ។

[៤៣] ឥតិហ ភិក្ខវេ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស បដិសញ្ចិក្ខតោ អប្បោស្សុក្កតាយ ចិត្តំ នមិ នោ ធម្មទេសនាយ ។

---

១ ឱ. អបិស្សុ ។ អដ្ឋកថាយម្បិ ឯវមេវ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ មិនតែប៉ុណ្ណោះ មានសេចក្តីដំណាលថា គាថាទាំងឡាយនេះ ដ៏ចម្លែក ដែលព្រះពុទ្ធវិបស្សី ទ្រង់មិនធ្លាប់បានឮក្នុងកាលមុន ក៏ច្បាស់ប្រាកដ ដល់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មា-សម្ពុទ្ធថា

ឥឡូវនេះ តថាគត គួរនឹងសម្តែងធម៌ ដែលតថាគតបានត្រាស់ដឹងដោយកម្រ សត្វទាំងឡាយ ដែលរាគៈទោសៈគ្របសង្កត់ ក៏មិនងាយនឹងត្រាស់ដឹងធម៌នេះបានឡើយ ។ សត្វទាំងឡាយ អ្នកត្រេកត្រអាល ដោយរាគៈ ដែលគំនរនៃងងឹតគឺអវិជ្ជា កំពុងចាក់ស្រេះ មុខជានឹងមិនឃើញធម៌ ដែលនាំសត្វឲ្យដល់នូវព្រះនិព្វាន ជាធម៌ល្អិតសុខុមជ្រាលជ្រៅ ដែលសត្វឃើញដោយកម្រ ។

[៤៣] ម្នាលភិក្ខុទាំងឡាយ កាលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ពិចារណាឃើញ ដោយសេចក្តីត្រិះរិះដូច្នេះហើយ ព្រះហឫទ័យ ឱនទៅរកសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅរកការសម្តែងធម៌ឡើយ ។

[៤៤] អថខោ ភិក្ខវេ អញ្ញតរស្ស មហាព្រហ្មុនោ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ ឯតទហោសិ ជស្សតិ វត ភោ លោកោ វិនស្សតិ វត ភោ លោកោ យត្រ ហិ នាម វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អប្បោស្សុក្កតាយ ចិត្តំ នមិ[១] នោ ធម្មទេសនាយាតិ ។ អថខោ សោ ភិក្ខវេ មហាព្រហ្មា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស បុរតោ ចាតុរហោសិ ។ អថខោ[២] ភិក្ខវេ មហាព្រហ្មា ឯកំសំ ឧត្តរាសង្គំ ករិត្វា ទក្ខិណជានុមណ្ឌលំ បឋវិយំ និទហិត្វា[៣] យេន វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ តេនញ្ជលឹ បណាមេត្វា វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច ទេសេតុ ភន្តេ

---

១ ឱ. នមតិ ។ ២ ឱ. ម. អថ សោ ។ ៣ ឱ. ម. និហន្ត្វា ។

[៤៤] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្ម ១ រូប បាន ដឹងនូវបរិវិតក្កៈក្នុងព្រះហឫទ័យ នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មា-សម្ពុទ្ធ ដោយចិត្តរបស់ខ្លួនហើយ ទើបគិតរំពឹងដូច្នេះថា ឱសត្វលោក វិនាសតើ ឱសត្វលោកវិនាសតើ ព្រោះព្រះវិបស្សីមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធ មានព្រះហឫទ័យឱនទៅរកសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅ រកការសម្តែងធម៌ឡើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្ម នោះ ក៏បាត់អំពីព្រហ្មលោកមកប្រតិស្ឋាន ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះ វិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ប្រៀបដូចបុរសមានកម្លាំងលា ចេញនូវកំភួនដៃ ដែលបត់ចូល ឬបត់ចូលនូវកំភួនដៃ ដែលលាចេញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្មធ្វើនូវសំពត់បង់-ក ឆៀងស្មា ម្ខាង លុតចុះនូវមណ្ឌលនៃជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលី ចំពោះព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ក៏ក្រាបបង្គំទូលព្រះ វិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន

៧៩

មហាបទានសុត្តេ តតិយភាណវារំ មហាព្រហ្មយាចនកថា

ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ សន្តីធ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោតិ ។ ឯវំ វុត្តេ ភិក្ខវេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ តំ មហាព្រហ្មានំ ឯតទវោច មយ្ហំបិ ខោ ព្រហ្មេ ឯតទហោសិ យន្នូនាហំ ធម្មំ ទេសេយ្យន្តិ ។ តស្ស មយ្ហំ ព្រហ្មេ ឯតទហោសិ អធិគតោ ខោ មេ អយំ ធម្មោ គម្ភីរោ ទុទ្ទសោ ទុរនុ-ពោធោ សន្តោ បណីតោ អតក្កាវចរោ និបុណោ បណ្ឌិតវេទនីយោ អាលយរាមា ខោ បនាយំ បជា អាលយរតា អាលយសម្មុទិតា អាលយរាមាយ ខោ បន បជាយ អាលយរតាយ អាលយសម្មុទិតាយ ទុទ្ទសំ ឥទំ ឋានំ យទិទំ ឥទប្បច្ចយតា បដិច្ចស-មុប្បាទោ ឥទម្បិ ខោ ឋានំ ទុទ្ទសំ យទិទំ សព្វ-សង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ

សូមព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ សូមព្រះសុគត ទ្រង់សម្ដែងធម៌ (ដ្បិត) សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលីគឺរាគាទិក្កិលេស ក្នុងចក្ខុស្រាលស្តើងក៏មាន តែមិនបានស្ដាប់ធម៌ មុខជានឹងសាបសូន្យមិនខាន ពួកសត្វដែលបម្រុងនឹងត្រាស់ដឹងធម៌ ក៏គង់មានដែរ ។ ម្នាលភិក្ខុទាំង-ឡាយ កាលមហាព្រហ្មក្រាបបង្គំទូល យ៉ាងនេះហើយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ក៏ត្រាស់ដូច្នេះនឹងមហាព្រហ្មនោះថា ម្នាលព្រហ្ម តថាគតមានសេចក្តីត្រិះរិះថា គួរតែតថាគតសម្ដែងធម៌ដូច្នេះដែរ ។ ម្នាលព្រហ្ម តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ធម៌ដែលតថាគតត្រាស់ដឹងហើយនេះ ជាធម៌ជ្រាលជ្រៅ សត្វឃើញបានដោយក្រ ត្រាស់ដឹងបានដោយក្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ថ្លៃថ្លា ជាធម៌ដែលបុគ្គលត្រិះរិះយកឯងមិនបាន ជាធម៌ល្អិត មានតែបណ្ឌិតទើបដឹងបាន ពួកសត្វនេះ មានអាល័យគឺកាមគុណជាទីត្រេកអរ ត្រេកអរក្នុងកាមគុណ រីករាយក្នុងកាម-គុណ បដិច្ចសមុប្បាទ ដែលមានកាមគុណនេះជាបច្ច័យ បដិច្ចសមុប្បាទនេះជាឋានៈដែលពួកសត្វ មានកាមគុណជាទីត្រេកអរ ត្រេកអរក្នុងកាម-គុណ រីករាយក្នុងកាមគុណ ឃើញបានដោយក្រ ធម៌ដែលជាគ្រឿងរម្ងាប់នូវសង្ខារទាំងពួង លះបង់នូវឧបធិក្កិលេសទាំងពួង អស់ទៅនៃតណ្ហា

វិរាគោ និរោធោ និព្វានំ អហញ្ចេវ ខោ បន ធម្មំ ទេសេយ្យំ បរេ ច មេ ន អាជានេយ្យុំ សោ មមស្ស កិលមថោ សា មមស្ស វិហេសាតិ ។ អបិស្សុធំ ព្រហ្មេ ឥមា អនច្ឆរិយា គាថា បដិភំសុ បុព្វេ មេ[១] អស្សុតបុព្វា

កិច្ឆេន មេ អធិគតំ

ហលន្ទានិ បកាសិតុំ

។ បេ ។ អាវុតាតិ ។

ឥតិហ មេ ព្រហ្មេ បដិសញ្ចិក្ខតោ អប្បោស្សុក្កតាយ ចិត្តំ នមិ នោ ធម្មទេសនាយាតិ ។ ទុតិយម្បិ ខោ ភិក្ខវេ សោ មហាព្រហ្មា ។ បេ ។ តតិយម្បិ ខោ ភិក្ខវេ សោ មហាព្រហ្មា វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច ទេសេតុ ភន្តេ ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ សន្តីធ[២] សត្តា អប្បរជក្ខជាតិកា

---

១ ឱ. ម. មេតិ បទំ ន ទិស្សតិ ។ ២ ឱ. ម. សន្តិ ។

ប្រាសចាករាគៈ រំលត់ (នូវកងទុក្ខ) និងព្រះនិព្វាន នេះឯងជាឋានៈដែល ពួកសត្វឃើញបានដោយក្រ បើទុកជាតថាគតសម្តែងធម៌ ពួកសត្វដទៃ មិនគប្បីអាចដឹងច្បាស់បាន សេចក្តីលំបាកកាយនោះ នឹងមានដល់តថាគត ការបៀតបៀននោះ នឹងមានដល់តថាគត ។ ម្នាលព្រហ្ម មិនតែប៉ុណ្ណោះ មានសេចក្តីដំណាលថា គាថាទាំងឡាយនេះ ចម្លែកដែរ ដែលតថាគតមិនធ្លាប់បានឮក្នុងកាលមុន ក៏ច្បាស់ប្រាកដដល់តថាគត ថា

ឥឡូវនេះ តថាគតគួរសម្តែងធម៌ ដែលតថាគតបានត្រាស់
ដឹងហើយ ដោយកម្រ ។ បេ ។ កំពុងចាក់ស្រែះ

ម្នាលព្រហ្ម កាលតថាគតពិចារណាឃើញដូច្នេះហើយ ចិត្តតថាគតក៏ឱនទៅរកសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅរកការសម្តែងធម៌ឡើយ ។ ម្នាលភិក្ខុទាំងឡាយ មហាព្រហ្មនោះ ក្រាបបង្គំទូលអស់វារៈជាគម្រប់ ២ ដងផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មហាព្រហ្មនោះ ក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ដូច្នេះអស់វារៈជាគម្រប់ ៣ ដងផងថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ សូមព្រះសុគតសម្តែងធម៌ (ដ្បិត) សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលី

អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោតិ ។ អថខោ ភិក្ខវេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ ព្រហ្មុនោ[១] អជ្ឈេសនំ វិទិត្វា សត្តេសុ ការុញ្ញតំ បដិច្ច ពុទ្ធចក្ខុនា លោកំ វោលោកេសិ ។ អទ្ទសា ខោ ភិក្ខវេ វិបស្សី ភគវា អរហំ សម្មា-សម្ពុទ្ធោ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ[២] សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វេ អភព្វេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហ-រន្តេ ។ សេយ្យថាបិ នាម ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមា-និ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍា-និ[៣] ឧទកានុគ្គតានិ អន្តោនិមុគ្គបោសីនិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ សមោទកឋិតានិ[៤] អប្បេ-កច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា

១ ឱ. ឯត្ថន្តរេ ចសទ្ទោ ទិស្សតិ ។ ២ ម. ទ្វាការេតិ ន ទិស្សតិ ។ ៣ សំពទ្ធានីតិបិ បាឋោ ។ ៤ ឱ. សមោទកំ ឋិតានិ ។

គឺកិលេសស្រាលស្តើងក្នុងចក្ខុ តែមិនបានស្តាប់ធម៌ មុខជានឹងសាបសូន្យមិនខាន ពួកសត្វដែលបម្រុងនឹងត្រាស់ដឹងធម៌ក៏មានដែរ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ទទួលអារាធនានៃមហាព្រហ្មហើយ ក៏ប្រមើលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ព្រោះអាស្រ័យនូវសេចក្តីករុណាទៅរកសត្វទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ប្រមើលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ បានឃើញនូវសត្វទាំងឡាយពួកខ្លះមានធូលីគឺរាគាទិក្កិលេស ស្រាលស្តើងក្នុងចក្ខុ ខ្លះមានធូលីគឺរាគទិក្កិលេសក្រាស់ក្នុងចក្ខុ ខ្លះមានឥន្ទ្រិយក្លៀវក្លា ខ្លះមានឥន្ទ្រិយទន់ ខ្លះមានអាការល្អ ខ្លះមានអាការអាក្រក់ ខ្លះពន្យល់បានដោយងាយ ខ្លះពន្យល់បានដោយក្រ ខ្លះមានភ័ព្វ ខ្លះឥតភ័ព្វ ខ្លះជាអ្នកឃើញនូវទោស ក្នុងបរលោកជាសភាវៈគួរខ្លាច ។ ផ្កាជលជាតពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី ដែលដុះក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់តាមទឹក លិចនៅក្នុងទឹកនៅឡើយ ផ្កាជលជាតពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ដែលដុះក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក ផ្កាជលជាតពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី

ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកា អច្ចុគ្គម្ម តិដ្ឋន្តិ[១] អនុបលិត្តានិ ឧទកេន ឯវមេវ ខោ ភិក្ខវេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វេ អភព្វេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ អថខោ ភិក្ខវេ មហាព្រហ្មា វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ គាថាហិ អជ្ឈភាសិ

[៤៩] សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ

---

១ ឱ. ឋន្តិ ។

ដែលដុះក្នុងទឹក ចម្រើនក្នុងទឹក ដុះខ្ពស់ឡើងផុតទឹក មិនជាប់ប្រឡាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ប្រមើលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ក៏ទ្រង់ឃើញនូវសត្វទាំងឡាយ ពួកខ្លះមានធូលីគឺរាគាទិក្កិលេសតិចក្នុងចក្ខុ ខ្លះមានធូលីគឺរាគាទិក្កិលេសច្រើនក្នុងចក្ខុ ខ្លះមានឥន្ទ្រិយក្លៀវក្លា ខ្លះមានឥន្ទ្រិយទន់ ខ្លះមានអាការល្អ ខ្លះមានអាការអាក្រក់ ខ្លះពន្យល់បានដោយងាយ ខ្លះពន្យល់បានដោយក្រ ខ្លះមានភ័ព្វ ខ្លះឥតភ័ព្វ ខ្លះជាអ្នកឃើញនូវទោសក្នុងបរលោក ជាសភាវៈគួរខ្លាច ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មហាព្រហ្ម បានដឹងបរិវិតក្កៈ ក្នុងហឫទ័យ របស់ព្រះវិបស្សី មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ដោយចិត្តរបស់ខ្លួនហើយ ក៏ក្រាបបង្គំទូលព្រះវិបស្សី មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ដោយគាថាទាំងឡាយ ថា

[៤៥] បុរសមានចក្ខុ ឈរលើកំពូលភ្នំថ្មសុទ្ធ មើលឃើញប្រជុំជន ដោយជុំវិញ មានឧបមាយ៉ាងណាមិញ បពិត្រ

តថូបមំ ធម្មមយំ សុមេធសោ(១)
ចាសាទមារុយ្ហ សមន្តចក្ខុ
សោកាវកិណ្ណំ ជនតមបេតសោកោ(២)
អវេក្ខស្សុ ជាតិជរាភិភូតំ ។
ឧដ្ឋេហិ វីរ វិជិតសង្គាម
សត្ថវាហ អនណ វិចរ(៣) លោកេ
ទេសេតុ ភគវា ធម្មំ អញ្ញាតារោ ភវិស្សន្តីតិ ។

[៤៦] ឯវំ វុត្តេ(៤) ភិក្ខវេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ តំ មហាព្រហ្មានំ គាថាយ អជ្ឈភាសិ(៥)

អបារុតា តេ(៦) អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។

---

១ ឱ. ម. សុមេធ ។ ២ ឱ. សោកាវតិណ្ណំ ជនតំ អបេតសោកោ ។ ៣ វិវរាតិបិ បាឋោ ។ ៤ ម. អថខោ ។ ៥ ឱ. បច្ចភាសិ ។ ៦ ឱ. ម. តេសំ ។

ព្រះអង្គអ្នកមានប្រាជ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គជាអ្នកមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ស្តេច ឡើងកាន់ប្រាសាទគឺព្រះធម៌ ប្រមើលមើលនូវប្រជុំជនអ្នកច្រប្រូកច្របល់ដោយសេចក្តីសោក ដែលជាតិជរា កំពុងគ្របសង្កត់ មានឧបមេយ្យយ៉ាងនោះ ។ បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាម អ្នកដឹកនាំពួកវេនេយ្យសត្វ អ្នកឥតបំណុល សូមព្រះអង្គក្រោកឡើង ត្រាច់ទៅក្នុងលោក សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ សត្វទាំងឡាយដែលបម្រុងនឹងត្រាស់ដឹងធម៌ ក៏មានដែរ ។

[៤៦] ម្នាលភិក្ខុទាំងឡាយ កាលមហាព្រហ្មក្រាបបង្គំទូល យ៉ាងនេះហើយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់នឹងមហាព្រហ្មនោះ ដោយព្រះគាថា ដូច្នេះថា

ទ្វារនៃព្រះនិព្វាន គឺអរិយមគ្គបើកដល់អ្នកហើយ សត្វទាំង-ឡាយណា មានសោតបសាទ សត្វទាំងនោះ ចូរបញ្ចេញនូវសទ្ធាមកចុះ ម្នាលព្រហ្ម តថាគតសម្គាល់នូវសេចក្តីនឿយលំបាក បានជាមិនទាន់សម្តែងធម៌ដ៏ឧត្តម ដែលតថាគតស្ទាត់ហើយ ក្នុងសម្នាក់មនុស្សទាំងឡាយ ។

[៤៧] អថខោ ភិក្ខវេ មហាព្រហ្មា តត្ថេវន្តរធាយិ ។ ខោម្ហិ វិបស្សិនា ភគវតា អរហតា សម្មាសម្ពុទ្ធេន ធម្មទេសនាយាតិ វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវ អន្តរធាយិ ។

[៤៨] អថខោ ភិក្ខវេ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឯតទហោសិ កស្ស នុ ខោ អហំ បឋមំ ធម្មំ ទេសេយ្យំ កោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។ អថខោ ភិក្ខវេ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឯតទហោសិ អយំ ខោ ខណ្ឌោ ច រាជបុត្តោ តិស្សោ ច បុរោហិតបុត្តោ ពន្ធុមតិយា រាជធានិយា បដិវសន្តិ បណ្ឌិតា វិយត្តា មេធាវិនោ ទីឃរត្តំ អប្បរជក្ខជាតិកា យន្នូនាហំ ខណ្ឌស្ស ច រាជបុត្តស្ស តិស្សស្ស ច បុរោហិតបុត្តស្ស បឋមំ ធម្មំ ទេសេយ្យំ តេ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សន្តីតិ ។ អថខោ ភិក្ខវេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ

[៤៧] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្ម ជ្រាបថា អាត្មាអញ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ បានប្រទានឱកាស ដើម្បីនឹងសម្ដែងធម៌ដូច្នេះហើយ ក៏ថ្វាយបង្គំលាព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់មានសេចក្ដីត្រិះរិះដូច្នេះថា តថាគតគួរសម្ដែងធម៌ដល់អ្នកណាមុនហ្ន៎ អ្នកណាអាចដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់មានសេចក្ដីត្រិះរិះដូច្នេះថា ព្រះរាជបុត្តព្រះនាមខណ្ឌៈ និងកូនបុរោហិតឈ្មោះ តិស្សៈនេះ ជាបណ្ឌិត ជាអ្នកឈ្លាសវៃ ជាអ្នកមានប្រាជ្ញា មានធូលីគឺរាគាទិក្កិលេសតិចក្នុងចក្ខុ អាស្រ័យនៅក្នុងរាជធានីឈ្មោះពន្ធុមតីជាយូរអង្វែងហើយ បើដូច្នោះ គួរតែតថាគតសម្ដែងធម៌ ដល់រាជបុត្តព្រះនាម ខណ្ឌៈ និងកូនបុរោហិតឈ្មោះ តិស្សៈ ជាមុនចុះ ជនទាំងនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់បាត់អំពីទីជិតនៃពោធិ-

សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ[១] ពោធិរុក្ខមូលេ អន្តរហិតោ ពន្ធុមតិយា រាជធានិយា ខេមេ មិគទាយេ បាតុរហោសិ ។ អថខោ ភិក្ខវេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ ទាយបាលំ[២] អាមន្តេសិ ឯហិ ត្វំ សម្ម ទាយបាល ពន្ធុមតឹ រាជធានឹ បវិសិត្វា ខណ្ឌញ្ច រាជបុត្តំ តិស្សញ្ច បុរោហិតបុត្តំ ឯវំ វទេហិ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ ពន្ធុមតឹ រាជធានឹ អនុប្បត្តោ ខេមេ មិគទាយេ វិហរតិ សោ តុម្ហាកំ ទស្សនកាមោតិ ។ ឯវំ ភន្តេតិ ខោ ភិក្ខវេ ទាយបាលោ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស បដិស្សុត្វា ពន្ធុមតឹ រាជធានឹ បវិសិត្វា ខណ្ឌញ្ច រាជបុត្តំ តិស្សញ្ច បុរោហិតបុត្តំ ឯតទវោច វិបស្សី[៣] ភគវា អរហំ សម្មាសម្ពុទ្ធោ ពន្ធុមតឹ រាជធានឹ អនុប្បត្តោ ខេមេ មិគទាយេ វិហរតិ សោ តុម្ហាកំ ទស្សនកាមោតិ ។ អថខោ ភិក្ខវេ

---

១ ឱ. ឯវមេវ ខោ ។ ២ មិគទាយបាលន្តិបិ បាឋោ ។ ឯវំ សព្វត្ថ ។ ៣ ឱ. ម. ភន្តេតិ ទិស្សតិ ។

ព្រឹក្ស ទៅប្រាកដឯខេមមិគទាយវ័ន[១] ក្នុងនគរពន្ធុមតីរាជធានី មានឧបមាដូចជាបុរសមានកម្លាំង លានូវកំភួនដៃដែលបត់ចូល ឬបត់ចូលនូវកំភួនដៃដែលលាដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ហៅទាយបាលមកថា ម្នាលសំឡាញ់ទាយបាល អ្នកចូរមកណេះ អ្នកចូរទៅកាន់ពន្ធុមតីរាជធានី ហើយនិយាយយ៉ាងនេះនឹងរាជបុត្តនាម ខណ្ឌៈ និងកូនបុរោហិតឈ្មោះ តិស្សៈ ថា ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្តេចមកដល់នគរពន្ធុមតីរាជធានីហើយ ឥឡូវទ្រង់គង់នៅក្នុងខេមមិគទាយវ័ន ព្រះអង្គចង់ជួបនឹងអ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯទាយបាល បានទទួលព្រះពុទ្ធតម្រាស់ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះករុណា ដូច្នេះហើយ ក៏ចូលទៅកាន់ពន្ធុមតីរាជធានី បាននិយាយនឹងព្រះខណ្ឌរាជបុត្រនិងតិស្សបុរោហិតបុត្រ ដូច្នេះថា ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្តេចមកដល់នគរពន្ធុមតីរាជធានីហើយ ឥឡូវទ្រង់គង់នៅក្នុងខេមមិគទាយវ័ន ព្រះអង្គចង់ជួបនឹងអ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ខណ្ឌរាជបុត្រ

១ ឥសិបតនមិគទាយវ័ន កាលគ្រានោះ ហៅថា ខេមមិគទាយវ័ន ។

ខណ្ឌោ ច រាជបុត្តោ តិស្សោ ច បុរោហិតបុត្តោ ភទ្ទានិ ភទ្ទានិ យានានិ យោជាបេត្វា ភទ្ទំ ភទ្ទំ យានំ អភិរុហិត្វា ភទ្ទេហិ ភទ្ទេហិ យានេហិ ពន្ធុមតិយា រាជធានិយា និយឹសុ យេន ខេមោ មិគទាយោ តេន ធាយឹសុ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកា[១] យេន វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ តេសំ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ អនុបុព្វីកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា តេ ភគវា អញ្ញាសិ កល្លចិត្តេ មុទុចិត្តេ វិនីវរណចិត្តេ ឧទគ្គចិត្តេ បសន្នចិត្តេ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។

១ ឱ. ម. ឯត្តន្តរេ វសេន្តោ ទិស្សតិ ។

និងតិស្សបុរោហិតបុត្រ ក៏បង្គាប់ឲ្យទឹមយានល្អ ៗ ហើយឡើងកាន់យានល្អ ៗ ចេញចាកពន្ធុមតីរាជធានី ដោយយានល្អ ៗ បរសំដៅទៅរកខេមមិគទាយវ័ន រហូតដល់កន្លែងសម្រាប់ដាក់យាន លុះដល់ហើយ ក៏ចុះអំពីយាន ដើរទៅដោយជើងទទេ ចូលសំដៅទៅរកព្រះវិបស្សី មានព្រះភាគអរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់សម្តែងអនុបុព្វីកថា ដល់ជនទាំង ២ នាក់នោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសនៃកាមទាំងឡាយ ដ៏លាមកសៅហ្មង ១ អានិសង្សក្នុងការចេញបួស ១ ។ លុះព្រះមានព្រះភាគ បានជ្រាបថា ជនទាំងពីរនាក់នោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះអង្គទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលណោះ ។

៨៧

សេយ្យថាបិ នាម សុទ្ធវត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ ខណ្ឌស្ស ច រាជបុត្តស្ស តិស្សស្ស ច បុរោហិតបុត្តស្ស តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ តេ ទិដ្ឋធម្មា បត្តធម្មា វិទិតធម្មា បរិយោគាឡ្ហធម្មា តិណ្ណវិចិកិច្ឆា វិគតកថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោចុំ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច លភេយ្យាម មយំ ភន្តេ ភគវតោ

ធម្មតាសំពត់ស្អាតប្រាសចាកពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ ដោយប្រពៃ មានឧបមាដូចម្ដេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើង ដល់ខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្រ ក្នុងទីអង្គុយនោះថា ធម្មជាតណាមួយ មានកិរិយាកើតឡើង ជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ ជនទាំងពីរនោះ បានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានត្រាស់ដឹងអរិយសច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ ឆ្លងផុតសេចក្ដីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាវៈជាបុគ្គលក្លាហាន មិនបាច់ជឿស្ដាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះបរមសាស្ដា ទើបក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធវិញ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្ដែងហើយ ដោយអនេកបរិយាយដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬ ដូចជាបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាប្រាប់ផ្លូវ ដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សមានភ្នែកភ្លឺ នឹងមើលឃើញនូវរូបទាំង-ឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន

សង្ឃិកោ បព្វជ្ជំ លភេយ្យាម ឧបសម្បទន្តិ ។ អលត្ថុំ ខោ ភិក្ខវេ ខណ្ឌោ ច រាជបុត្តោ តិស្សោ ច បុរោហិត-បុត្តោ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិកេ បព្វជ្ជំ អលត្ថុំ ឧបសម្បទំ ។ តេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ ធម្មិយា កថាយ សន្ទ-ស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ សង្ខារានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិ-សំសំ បកាសេសិ ។ តេសំ វិបស្សិនា ភគវតា អរ-ហតា សម្មាសម្ពុទ្ធេន ធម្មិយា កថាយ សន្ទស្សិយ-មានានំ សមាទបិយមានានំ សមុត្តេជិយមានានំ ស-ម្បហំសិយមានានំ នចិរស្សេវ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសុ ។

[៤៩] អស្សោសិ ខោ ភិក្ខវេ ពន្ធុមតិយា រាជធា-និយា មហាជនកាយោ ចតុរាសីតិបាណសហស្សានិ វិបស្សី កិរ ភគវា អរហំ សម្មាសម្ពុទ្ធោ ពន្ធុមតឹ រាជធានឹ អនុប្បត្តោ ខេមេ មិគទាយេ វិហរតិ ខណ្ឌោ ច កិរ រាជបុត្តោ តិស្សោ ច បុរោហិតបុត្តោ

យើងខ្ញុំព្រះអង្គ សូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទា ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ ម្នាលភិក្ខុទាំងឡាយ ខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្រ ក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសម្នាក់នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយប្រកាសទោសនៃសង្ខារទាំងឡាយ ដ៏លាមកសៅហ្មង និងអានិសង្សក្នុងបព្វជ្ជា ។ កាលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ណែនាំពន្យល់ជនទាំង ២ នោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ មិនយូរប៉ុន្មាន ចិត្ត (របស់ជនទាំងពីរនោះ) ក៏រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

[៤៩] ម្នាលភិក្ខុទាំងឡាយ ពួកមហាជនក្នុងនគរពន្ធុមតីរាជធានី ចំនួន ៨ ហ្មឺន ៤ ពាន់នាក់ បានឮដំណឹងថា ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្តេចមកដល់ពន្ធុមតីរាជធានីហើយ ឥឡូវទ្រង់គង់នៅនាខេមមិគទាយវ័ន បានឮថាព្រះខណ្ឌរាជបុត្ត និងតិស្សបុរោហិតបុត្ត

វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិកេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតាតិ ។ សុត្វាន នេសំ ឯតទហោសិ ន ហិ នូន សោ ឱរកោ ធម្មវិនយោ ន សា ឱរិកា បព្វជ្ជា យត្ថ ខណ្ឌោ ច រាជបុត្តោ តិស្សោ ច បុរោហិតបុត្តោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតា ខណ្ឌោ ច ហិ នាម[១] រាជបុត្តោ តិស្សោ ច បុរោហិតបុត្តោ[២] កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សន្តិ កិមង្គំ បន មយន្តិ ។ អថខោ សោ ភិក្ខវេ មហាជនកាយោ ចតុរាសីតិបាណសហស្សានិ ពន្ធុមតិយា រាជធានិយា និក្ខមិត្វា យេន ខេមោ មិគទាយោ យេន វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា

១ ម. ហិ នាមាតិ ន ទិស្សតិ ។ ២ ឱ. ឥតោ បរំ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិកេតិ បាឋោ ទិស្សន្តិ ។

បានដាក់កេសានិងមស្សុ ហើយស្លៀកណ្តប់សំពត់កាសាយៈ ចេញចាក ផ្ទះ ទៅបួសក្នុងសម្នាក់នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ លុះពួកមហាជនទាំងនោះ បានឮហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ធម្មវិន័យនិងបព្វជ្ជា ដែលព្រះខណ្ឌរាជបុត្ត និងតិស្សបុរោហិតបុត្ត ដាក់ កេសានិងមស្សុ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកគេហដ្ឋានទៅ បួសនោះ ប្រាកដជាមិនមែនថោកទាបទេ ប៉ុនអម្បាលព្រះខណ្ឌរាជបុត្តនិង តិស្សបុរោហិតបុត្ត ម្តេចដាក់កេសានិងមស្សុ ហើយស្លៀកដណ្តប់សំពត់ កាសាយៈ ចេញចាកគេហដ្ឋានទៅបួស ចុះពួកយើងនៅចាំអ្វីទៀត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងវេលានោះ ពួកមហាជនចំនួន ៨ ហ្មឺន ៤ ពាន់ នោះ ចេញចាកពន្ធុមតីរាជធានី នាំគ្នាដើរសំដៅទៅរកខេមមិគទាយវ័ន ជាទីដែលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធគង់នៅ លុះទៅ ដល់ហើយ ក៏ថ្វាយបង្គំព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ រួច

ឯកមន្តំ និសីទឹសុ ។ តេសំ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ អនុបុព្វិកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា តេ ភគវា អញ្ញាសិ កល្លចិត្តេ មុទុចិត្តេ វិនីវរណចិត្តេ ឧទគ្គចិត្តេ បសន្នចិត្តេ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ តេសំ ចតុរាសីតិបាណសហស្សានំ តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ តេ ទិដ្ឋធម្មា បត្តធម្មា វិទិតធម្មា បរិយោគាឡ្ហធម្មា តិណ្ណវិចិកិច្ឆា វិគតកថំកថា

អង្គុយក្នុងទីដ៏សមគួរ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់សម្តែងអនុបុព្វីកថា ដល់ពួកមហាជននោះ អនុបុព្វីកថានោះ គឺទ្រង់ប្រកាស ទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសនៃកាមទាំង-ឡាយ ដ៏លាមកសៅហ្មង ១ អានិសង្សក្នុងបព្វជ្ជា ១ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ពួកមហាជនទាំងនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែង ដោយព្រះអង្គឯង គឺទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលណោះ ។ ធម្មតា សំពត់-សស្អាត ដែលប្រាសចាកពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ ដោយប្រពៃ មានឧបមាដូចម្តេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើង ដល់ពួកមហាជនទាំង ៨ ហ្មឺន ៤ ពាន់នាក់នោះ ក្នុងទីអង្គុយនោះឯងថា ធម្មជាតណានីមួយ មានកិរិយាកើតឡើង ជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ ឯពួកមហាជនទាំងនោះ បានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានត្រាស់ដឹងអរិយសច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវ

វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោចុំ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុ-ជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេ-យ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាម មយំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យាម ឧបសម្ប-ទន្តិ ។ អលត្ថុំ ខោ ភិក្ខវេ តានិ ចតុរាសីតិបាណស-ហស្សានិ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធ-ស្ស សន្តិកេ បព្វជ្ជំ អលត្ថុំ ឧបសម្បទំ ។ តេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ ធម្មិយា កថាយ សន្ទ-ស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ សង្ខារានំ អាទីនវំ ឱការំ សង្កិលេសំ និព្វានេ[១] អា-និសំសំ បកាសេសិ ។ តេសំ វិបស្សិនា ភគវតា

១ នេក្ខម្មេតិ បាឋេន ភវិតព្វំ ។

ភាវៈជាបុគ្គលក្លាហាន មិនបាច់ជឿពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះបរមសាស្តា ទើបក្រាបទូលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយដោយអនេកបរិយាយ ដូចជាគេផ្ងារ របស់ដែលផ្កាប់ ឬដូចជាបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោតដូចជាកាន់ប្រទីបទ្រោលបំភ្លឺ ក្នុងទីងងឹតដោយគិតថា មនុស្សដែលមានភ្នែកភ្លឺនឹងមើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះ សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំ សូមបាននូវបព្វជ្ជានិងឧបសម្បទា ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ ម្នាលភិក្ខុទាំងឡាយ ពួកមហាជនទាំង ៨ ហ្មឺន ៤ ពាន់នាក់នោះ ក៏បានបព្វជ្ជានិងឧបសម្បទា ក្នុងសម្នាក់នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ជនទាំងនោះ ឲ្យឃើញជាក់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយប្រកាសទោសរបស់សង្ខារដ៏លាមកសៅហ្មង និងអានិសង្សក្នុងព្រះនិព្វាន ។ កាលដែលព្រះវិបស្សីមានព្រះភាគ

អរហតា សម្មាសម្ពុទ្ធេន ធម្មិយា កថាយ សន្ទស្សិយ-មានានំ សមាទបិយមានានំ សមុត្តេជិយមានានំ សម្ប-ហំសិយមានានំ នចិរស្សេវ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសុ ។

[៤០] អស្សោសុំ ខោ ភិក្ខវេ តានិ ចតុរាសីតិ-បព្វជិតសហស្សានិ[១] វិបស្សី កិរ ភគវា អរហំ សម្មា-សម្ពុទ្ធោ ពន្ធុមតឹ រាជធានឹ អនុប្បត្តោ ខេមេ មិ-គទាយេ វិហរតិ ធម្មញ្ច កិរ ទេសេតីតិ ។ អថខោ ភិក្ខវេ តានិ ចតុរាសីតិបព្វជិតសហស្សានិ យេន ពន្ធុមតី រាជធានី យេន ខេមោ មិគទាយោ យេន វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ តេសំ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ អនុបុព្វឹកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កា-មានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិ-

១ ឱ. តានិ បុរិមានិ ចតុរាសីតិ បព្វជិតសហស្សានិ ។ ម. តានិ បុរិមានិ ។

អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ពួកមហាជនទាំងនោះ ឲ្យឃើញជាក់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយមិនយូរប៉ុន្មាន ចិត្ត (របស់មហាជនទាំងនោះ) ក៏រួចស្រឡះចាកអាសវធម៌ទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

[៩០] ម្នាលភិក្ខុទាំងឡាយ បព្វជិតទាំង ៨ ហ្មឺន ៤ ពាន់រូបនោះ បានឮដំណឹងថា ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ស្ដេចមកដល់ពន្ធុមតីរាជធានី ហើយទ្រង់គង់នៅ ក្នុងខេមមិគទាយវ័ន ទ្រង់សម្ដែងធម៌ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ បព្វជិតទាំង ៨ ហ្មឺន ៤ ពាន់រូបនោះ ក៏នាំគ្នាទៅកាន់ក្រុងពន្ធុមតីរាជធានី រួចហើយក៏ដើរសំដៅទៅរកខេមមិគទាយវ័ន ត្រង់កន្លែង ដែលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ គង់នៅ លុះទៅដល់ហើយ ក៏ថ្វាយបង្គំព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់អនុបុព្វីកថា ដល់ពួកបព្វជិតទាំងនោះ អនុបុព្វីកថានោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង ១

៩៣



សំសំ បកាសេសិ ។ យទា តេ ភគវា អញ្ញាសិ
កល្លចិត្តេ មុទុចិត្តេ វិនីវរណចិត្តេ ឧទគ្គចិត្តេ ប-
សន្នចិត្តេ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្ម-
ទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ
មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ
សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ តេសំ ចតុរា-
សីតិបព្វជិតសហស្សានំ តស្មឹយេវ អាសនេ វិរជំ
វីតមលំ ធម្មចក្ខុំ ឧទបាទិ យំកិញ្ចិ សមុទយធម្មំ
សព្វន្តំ និរោធធម្មន្តិ ។ តេ ទិដ្ឋធម្មា បត្តធម្មា
វិទិតធម្មា បរិយោគាឡ្ហធម្មា តិណ្ណវិចិកិច្ឆា វិគតក-
ថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ
វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោចុំ

អានិសង្សក្នុងនេក្ខម្មៈ ១ ។ លុះព្រះមានព្រះភាគទ្រង់ជ្រាបថា បព្វជិតទាំងនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ក៏ទ្រង់ប្រកាសធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្ដែង ដោយព្រះអង្គឯង គឺ ទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលណោះ ។ ធម្មតា សំពត់-សស្អាត ដែលប្រាសចាកពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ ដោយប្រពៃ មានឧបមាដូចម្ដេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើង ដល់ពួកបព្វជិតទាំង ៨ ហ្មឺន ៤ ពាន់នោះ ក្នុងទីអង្គុយនោះថា ធម្មជាតណានីមួយ មានកិរិយាកើតឡើង ជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញ ជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ ពួកបព្វជិតទាំងនោះ បានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានត្រាស់ដឹងអរិយសច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ ឆ្លងផុតចាកសេចក្ដីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាវៈជាបុគ្គលក្លាហាន មិនបាច់ជឿពាក្យបុគ្គលដទៃក្នុងសាសនា របស់ព្រះបរមសាស្ដា ទើបក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគ

អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ[១] ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាម មយំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យាម ឧបសម្បទន្តិ ។ អលត្ថុំ ខោ ភិក្ខវេ តានិ ចតុរាសីតិបព្វជិតសហស្សានិ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិកេ បព្វជ្ជំ អលត្ថុំ ឧបសម្បទំ ។ តេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ សង្ខារានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ[២] អានិសំសំ បកាសេសិ ។ តេសំ វិបស្សិនា ភគវតា អរហតា សម្មាសម្ពុទ្ធេន ធម្មិយា កថាយ សន្ទស្សិយមានានំ

---

១ សេយ្យថាបិ នាមាតិបិ ។ ២ ឱ. ម. និព្វានេ ។

អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយអនេកបរិយាយ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចជាប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចគេកាន់ប្រទីបទ្រោលបំភ្លឺ ក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែកភ្លឺ មើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំសូមបាន នូវបព្វជ្ជា និងឧបសម្បទា ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតទាំង ៨ ហ្មឺន ៤ ពាន់នោះ ក៏បាននូវបព្វជ្ជា និងឧបសម្បទា ក្នុងសម្នាក់នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់បព្វជិតទាំងនោះ ឲ្យឃើញជាក់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយប្រកាសទោស របស់សង្ខារដ៏លាមក សៅហ្មងនិងអានិសង្សក្នុងនេក្ខម្មៈ ។ កាលដែលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ពួកបព្វជិតទាំងនោះ ឲ្យឃើញជាក់

សមានបិយមានានំ សមុត្តេជិយមានានំ សម្បហំសិយមានានំ ឧចិរស្សេវ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសុ ។

[៤១] តេន ខោ បន[១] សមយេន ពន្ធុមតិយា រាជធានិយា មហាភិក្ខុសង្ឃោ បដិវសតិ អដ្ឋសដ្ឋីភិក្ខុសតសហស្សំ ។ អថខោ ភិក្ខវេ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ មហា ខោ ឯតរហិ ភិក្ខុសង្ឃោ ពន្ធុមតិយា រាជធានិយា បដិវសតិ អដ្ឋសដ្ឋីភិក្ខុសតសហស្សំ យន្នូនាហំ ភិក្ខូ អនុជានេយ្យំ ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិ ច សត្តា

១ ឱ. តេន ខោ បន ភិក្ខវេ ។

ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ មិនយូរប៉ុន្មាន ចិត្ត (របស់បព្វជិតទាំងនោះ) ក៏បានរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

[៩១] សម័យនោះឯង មានភិក្ខុសង្ឃច្រើនចំនួន ៦ លាន ៨ សែនរូប នៅអាស្រ័យ ក្នុងពន្ធុមតីរាជធានី ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់ក្នុងទីស្ងាត់ សម្ងំក្នុងព្រះកម្មដ្ឋាន មានព្រះតម្រិះក្នុងព្រះហឫទ័យកើតឡើងយ៉ាងនេះថា ឥឡូវនេះ ពួកភិក្ខុដែលនៅអាស្រ័យ ក្នុងពន្ធុមតីរាជធានី ច្រើនដល់ទៅ ៦ លាន ៨ សែនរូប បើដូច្នោះ គួរតែ តថាគតអនុញ្ញាតភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយ ចូរកុំទៅពីររូប តាមផ្លូវ ១ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសម្ដែងធម៌ ឲ្យមានលម្អបទដើម បទកណ្ដាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយ ក្នុងលោកនេះ ដែលមាន

អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ អបិច ឆន្នំ ឆន្នំ វស្សានំ អច្ចយេន ពន្ធុមតី រាជធានី ឧបសង្កមិតព្វា ចាតិមោក្ខុទ្ទេសាយាតិ ។ អថខោ ភិក្ខវេ អញ្ញតរោ មហាព្រហ្មា វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុ-ទ្ធស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសា-រិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរ-ហិតោ វិបស្សិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស បុរតោ ចាតុរហោសិ ។ អថខោ សោ[១] ភិក្ខវេ មហាព្រហ្មា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ តេនញ្ជលិម្បណាមេត្វា វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច ឯវមេ-តំ ភគវា ឯវមេតំ សុគត មហា ខោ ភន្តេ ឯតរហិ ភិក្ខុសង្ឃោ ពន្ធុមតិយា រាជធានិយា បដិវសតិ អដ្ឋ-សដ្ឋីភិក្ខុសតសហស្សំ អនុជានាតុ ភន្តេ ភគវា ភិក្ខូ

១ ឱ. សោសទ្ទោ ន ទិស្សតិ ។

ធូលី គឺរាគាទិកិលេសតិច ក្នុងភ្នែកក៏មាន សត្វទាំងនោះ តែខានស្តាប់ធម៌ ហើយនឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុងត្រាស់ដឹងធម៌ ក៏មាន មួយទៀត កាលបើវេលាកន្លងទៅបាន ៦ ឆ្នាំ ៗ ហើយ អ្នកទាំងឡាយត្រូវចូលមកកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្ម ១ អង្គ ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះហឫទ័យ របស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដោយចិត្តរបស់ខ្លួនហើយ ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ប្រៀបដូចបុរសមានកម្លាំង លានូវកំភួនដៃ ដែលបត់ចូល ឬបត់ចូលនូវកំភួនដៃដែលលាចេញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្មនោះ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាងប្រណម្យអញ្ជលី ថ្វាយបង្គំព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ហើយក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ភិក្ខុសង្ឃដែលនៅអាស្រ័យក្នុងពន្ធុមតីរាជធានីច្រើនណាស់ ចំនួន ៦ លាន ៨ សែនរូប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អនុញ្ញាតភិក្ខុទាំងឡាយថា

៩៧

មហាបទានសុត្តេ តតិយភាណវារំ សាវកានំ ចារិកចរណកថា

ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិច សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ អបិច ភន្តេ មយំ តថា ការិស្សាម យថា ភិក្ខូ ឆន្នំ ឆន្នំ វស្សានំ អច្ចយេន ពន្ធុមតឹ រាជធានឹ ឧបសង្កមិស្សន្តិ ចាតុមោក្ខុទ្ទេសាយាតិ ។ ឥទមវោច ភិក្ខវេ សោ មហាព្រហ្មា ឥទំ វត្វា វិបស្សឹ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវ អន្តរធាយិ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយ ចូរកុំទៅពីររូបតាមផ្លូវ ១ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសម្ដែងធម៌ឲ្យមានលម្អបទដើម បទកណ្ដាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលីគឺរាគាទិក្កិលេសតិច ក្នុងភ្នែកក៏មាន សត្វទាំងនោះ តែខានស្ដាប់ធម៌នឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វ ដែលបម្រុងត្រាស់ដឹងធម៌គង់មាន បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត កាលបើវេលាកន្លងទៅបាន ៦ ឆ្នាំ ៗ ហើយ ភិក្ខុទាំងឡាយនឹងចូលមកកាន់ពន្ធុមតីរាជធានី ដើម្បីសម្ដែងបាតិមោក្ខយ៉ាងណា យើងខ្ញុំក៏នឹងធ្វើយ៉ាងនោះ ។ ម្នាលភិក្ខុទាំងឡាយ មហាព្រហ្មនោះ បានពោលនូវពាក្យនេះ លុះពោលពាក្យនេះរួចហើយ ក៏ថ្វាយបង្គំលាព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។

[៥២] អថខោ ភិក្ខវេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ សាយណ្ហសមយេ បដិសល្លានា វុដ្ឋិតោ ភិក្ខូ អាមន្តេសិ ឥធ មយ្ហំ ភិក្ខវេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ មហា ខោ ឯតរហិ ភិក្ខុសង្ឃោ ពន្ធុមតិយា រាជធានិយា បដិវសតិ អដ្ឋសដ្ឋីភិក្ខុសតសហស្សំ យន្នូនាហំ ភិក្ខូ អនុជានេយ្យំ ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ អបិច ឆន្នំ ឆន្នំ វស្សានំ

[៥២] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ចេញអំពីទីសម្រាក នៅវេលាសាយណ្ហសម័យ ហើយត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតចូលទៅនៅក្នុងរហោស្ថាន ជាទីសម្រាក មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើង យ៉ាងនេះថា ឥឡូវនេះ ភិក្ខុសង្ឃដែលនៅអាស្រ័យ ក្នុងពន្ធុមតីរាជធានីច្រើនណាស់ ចំនួន ៦ លាន ៨ សែនរូប បើដូច្នោះ គួរតែតថាគតអនុញ្ញាតដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូលទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយ ចូរកុំទៅពីររូបតាមផ្លូវ ១ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសម្តែងធម៌ឲ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ឲ្យបរិសុទ្ធ ប្រកបដោយអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលីគឺរាគាទិក្កិលេសតិចក្នុងចក្ខុក៏មាន សត្វទាំងនោះ តែមិនបានស្តាប់ធម៌ នឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុងត្រាស់ដឹងធម៌គង់មាន មួយទៀត កាលបើវេលាកន្លងទៅបាន ៦ ឆ្នាំ ៗ ហើយ

៩៩

## មហាបទានសុត្តេ តតិយភាណវារំ សាវកានំ ចារិកចរណកថា

អច្ចយេន ពន្ធុមតី រាជធានី ឧបសង្កមិតព្វា បាតិមោ-
ក្ខុទ្ទេសាយាតិ អថខោ ភិក្ខវេ អញ្ញតរោ មហាព្រហ្មា
មម ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម
ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ
បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ
អន្តរហិតោ មម បុរតោ បាតុរហោសិ អថខោ សោ
ភិក្ខវេ មហាព្រហ្មា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេ-
នាហំ តេនញ្ជលិម្បណាមេត្វា មំ ឯតទវោច ឯវមេតំ
ភគវា ឯវមេតំ សុគត មហា ខោ ភន្តេ ឯតរហិ ភិក្ខុ-
សង្ឃោ ពន្ធុមតិយា រាជធានិយា បដិវសតិ អដ្ឋសដ្ឋី-
ភិក្ខុសតសហស្សំ អនុជានាតុ ភន្តេ ភគវា ភិក្ខូ
ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុ-
ខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ
ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ

អ្នកទាំងឡាយ ត្រូវចូលមកកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មានមហាព្រហ្ម ១ អង្គ ដឹងនូវសេចក្តីត្រិះរិះ ក្នុងចិត្តនៃតថាគត ដោយចិត្តរបស់ខ្លួនហើយ ក៏បាត់អំពីព្រហ្មលោកមកប្រាកដ ក្នុងទីចំពោះមុខតថាគត ប្រៀបដូចបុរសអ្នកមានកម្លាំង លាចេញនូវកំភួនដៃ ដែលបត់ចូល ឬបត់ចូលនូវកំភួនដៃ ដែលលាចេញ ម្នាលភិក្ខុទាំងឡាយ ក្នុងវេលានោះ មហាព្រហ្មនោះ ធ្វើសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ថ្វាយបង្គំចំពោះតថាគត ហើយពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ភិក្ខុសង្ឃដែលនៅអាស្រ័យ ក្នុងពន្ធុមតីរាជធានីច្រើនណាស់ ចំនួន ៦ លាន ៨ សែនរូប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អនុញ្ញាតភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយ ចូរកុំទៅពីររូបតាមផ្លូវ ១ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសម្តែង

ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោ-
សានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ
បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិ សត្តា
អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ
ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ អបិច ភន្តេ មយំ តថា
ករិស្សាម យថា ភិក្ខុ ឆន្នំ ឆន្នំ វស្សានំ អច្ចយេន
ពន្ធុមតី រាជធានី ឧបសង្កមិស្សន្តិ ចាតិមោក្ខុទ្ទេសា-
យាតិ ឥទមវោច ភិក្ខវេ សោ[១] មហាព្រហ្មា ឥទំ
វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវ អន្តរ-
ធាយិ ។ អនុជានាមិ ភិក្ខវេ ចរថ ចារិកំ ពហុជន-
ហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ
ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ
ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ
បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិ-
បុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិ សត្តា

១ ឱ. សោ ភិក្ខវេ ។

ធម៌ឲ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយ-ធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលីគឺរាគាទិក្កិលេសតិចក្នុងចក្ខុក៏មាន សត្វទាំងនោះ តែមិនបានស្តាប់ធម៌នឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុងនឹងត្រាស់ដឹងធម៌ គង់មាន បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត កាលបើវេលាកន្លងទៅបាន ៦ ឆ្នាំ ៗ ហើយ ភិក្ខុទាំងឡាយនឹងចូលមកកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខយ៉ាងណា យើងខ្ញុំក៏នឹងធ្វើយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ មហាព្រហ្មនោះ បានពោលពាក្យនេះ លុះពោលពាក្យនេះរួច ក៏ថ្វាយបង្គំលាតថាគត ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។ ព្រះវិបស្សីទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយ ចូរកុំទៅពីររូបតាមផ្លូវ ១ ឡើយ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ ចូរសម្តែងធម៌ ឲ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ ពួកសត្វក្នុងលោកនេះ ដែលមាន

អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ អបិច ភិក្ខវេ ឆដ្ឋំ ឆដ្ឋំ វស្សានំ អច្ចយេន ពន្ធុមតី រាជធានី ឧបសង្កមិតព្វា បាតិមោក្ខុទ្ទេសាយាតិ ។ អថខោ ភិក្ខវេ ភិក្ខូ យេភុយ្យេន ឯកាហេនេវ ជនបទចារិកំ បក្កមឹសុ ។

[៨៣] តេន ខោ បន សមយេន ជម្ពុទីបេ ចតុ-រាសីតិអាវាសសហស្សានិ ហោន្តិ ។ ឯកម្ហិ វស្សេ និក្ខន្តេ ទេវតា សទ្ទមនុស្សាវេសុំ និក្ខន្តំ ខោ មារិសា ឯកវស្សំ បញ្ចិទានិ វស្សានិ សេសានិ បញ្ចន្នំ វស្សានំ អច្ចយេន ពន្ធុមតី រាជធានី ឧបសង្កមិតព្វា បាតិមោក្ខុ-ទ្ទេសាយាតិ ។ ទ្វីសុ វស្សេសុ និក្ខន្តេសុ ទេវតា សទ្ទមនុស្សាវេសុំ និក្ខន្តានិ ខោ មារិសា ទ្វេ វស្សានិ ចត្តារីទានិ វស្សានិ សេសានិ ចតុន្នំ វស្សានំ អច្ចយេន ពន្ធុមតី រាជធានី ឧបសង្កមិតព្វា បាតិមោក្ខុទ្ទេសា-យាតិ ។ តីសុ វស្សេសុ និក្ខន្តេសុ ទេវតា សទ្ទម-នុស្សាវេសុំ និក្ខន្តានិ ខោ មារិសា តីណិ វស្សានិ តីណីទានិ វស្សានិ សេសានិ តិណ្ណំ វស្សានំ អច្ចយេន

ធូលីគឺរាគាទិក្កិលេសតិច ក្នុងចក្ខុក៏មាន សត្វទាំងនោះ តែមិនបានស្តាប់ធម៌នឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុងត្រាស់ដឹងធម៌ គង់មាន ម្នាលភិក្ខុទាំងឡាយ តែថា កាលបើកន្លងទៅបាន ៦ ឆ្នាំ ៗ ហើយ អ្នកទាំងឡាយ ត្រូវមកកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ពួកភិក្ខុច្រើនតែចេញទៅកាន់ចារិក ក្នុងជនបទតែមួយថ្ងៃប៉ុណ្ណោះ ។

[៥៣] សម័យនោះឯង ក្នុងជម្ពូទ្វីបមានអាវាសច្រើន ចំនួន ៨ ហ្មឺន ៤ ពាន់ ។ ដល់កន្លងទៅបាន ១ ឆ្នាំ ពួកទេវតាក៏បន្លឺសូរស័ព្ទថា បពិត្រលោកអ្នកនិទ៌ុក្ខទាំងឡាយ កាលកន្លងទៅបាន ១ ឆ្នាំហើយ ឥឡូវនៅសល់តែ ៥ ឆ្នាំទៀតទេ លុះអំណើះទៅ ៥ ឆ្នាំទៀត លោកទាំងឡាយត្រូវចូលទៅកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកន្លងទៅបាន ២ ឆ្នាំ ពួកទេវតាបន្លឺសូរស័ព្ទថា បពិត្រលោកអ្នកនិទ៌ុក្ខទាំងឡាយ កាលកន្លងទៅបាន ២ ឆ្នាំហើយ ឥឡូវនៅសល់តែ ៤ ឆ្នាំទៀតទេ លុះអំណើះទៅ ៤ ឆ្នាំទៀត លោកទាំងឡាយ ត្រូវចូលទៅកាន់ពន្ធុមតីរាជ-ធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកាលកន្លងទៅបាន ៣ ឆ្នាំ ពួកទេវតាបន្លឺសូរស័ព្ទថា បពិត្រលោកអ្នកនិទ៌ុក្ខទាំងឡាយ កាលកន្លងទៅបាន ៣ ឆ្នាំហើយ ឥឡូវនៅសល់តែ ៣ ឆ្នាំទៀតទេ លុះអំណើះទៅ ៣ ឆ្នាំ

ពន្ធុមតី រាជធានី ឧបសង្កមិតព្វា ចាតិមោក្ខុទ្ទេសា-យាតិ ។ ចតូសុ វស្សេសុ និក្ខន្តេសុ ទេវតា សទ្ទម-នុស្សាវេសុំ និក្ខន្តានិ ខោ មារិសា ចត្តារិ វស្សានិ ទ្វេធានិ វស្សានិ សេសានិ ទ្វិន្នំ វស្សានំ អច្ចយេន ពន្ធុមតី រាជធានី ឧបសង្កមិតព្វា ចាតិមោក្ខុទ្ទេសា-យាតិ ។ បញ្ចសុ វស្សេសុ និក្ខន្តេសុ ទេវតា សទ្ទម-នុស្សាវេសុំ និក្ខន្តានិ ខោ មារិសា បញ្ច វស្សានិ ឯ-កំធានិ វស្សំ សេសំ ឯកស្ស វស្សស្ស អច្ចយេន ពន្ធុមតី រាជធានី ឧបសង្កមិតព្វា ចាតិមោក្ខុទ្ទេសា-យាតិ ។ ឆសុ វស្សេសុ និក្ខន្តេសុ ទេវតា សទ្ទម-នុស្សាវេសុំ និក្ខន្តានិ ខោ មារិសា ឆព្វស្សានិ សម-យោធានិ ពន្ធុមតី រាជធានី ឧបសង្កមិតព្វា(១) ចាតិ-មោក្ខុទ្ទេសាយាតិ ។ អថខោ តេ ភិក្ខវេ ភិក្ខូ អប្បេកាច្ចេ សកេន(២) ឥទ្ធានុភាវេន អប្បេកាច្ចេ ទេវ-តានំ ឥទ្ធានុភាវេន ឯកាហេនេវ ពន្ធុមតឹ រាជធានឹ ឧបសង្កមឹសុ ចាតិមោក្ខុទ្ទេសាយាតិ ។

១ ឱ. ម. ពន្ធុមតី រាជធានី ឧបសង្កមិតុំ ។ ២ ឱ. សកេនេវ ។

ទៀត លោកទាំងឡាយ ត្រូវចូលទៅកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកន្លងទៅបាន ៤ ឆ្នាំ ពួកទេវតាបន្លឺសូរស័ព្ទថា បពិត្រលោកអ្នកនិទ៌ុក្ខទាំងឡាយ កាលកន្លងទៅបាន ៤ ឆ្នាំហើយ ឥឡូវនៅសល់តែ ២ ឆ្នាំទៀតទេ លុះអំណើះទៅ ២ ឆ្នាំទៀត លោកទាំងឡាយត្រូវចូលទៅកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកន្លងទៅបាន ៥ ឆ្នាំ ពួកទេវតាបន្លឺសូរស័ព្ទថា បពិត្រលោកអ្នកនិទ៌ុក្ខទាំងឡាយ កាលកន្លងទៅបាន ៥ ឆ្នាំហើយ ឥឡូវនៅសល់តែ ១ ឆ្នាំទៀតទេ លុះអំណើះទៅ ១ ឆ្នាំទៀត លោកទាំងឡាយត្រូវចូលទៅកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកន្លងទៅបាន ៦ ឆ្នាំ ពួកទេវតាបន្លឺសូរ-ស័ព្ទថា បពិត្រលោកអ្នកនិទ៌ុក្ខទាំងឡាយ កាលកន្លងទៅបាន ៦ ឆ្នាំហើយ ឥឡូវដល់វេលាត្រូវលោកទាំងឡាយ ចូលទៅកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះភិក្ខុទាំងនោះ មានពួកភិក្ខុខ្លះ ចូលទៅកាន់ពន្ធុមតីរាជធានី ដោយអានុ-ភាពនៃឫទ្ធិរបស់ខ្លួន ពួកខ្លះចូលទៅកាន់ពន្ធុមតីរាជធានី ដោយអានុភាពនៃឫទ្ធិទេវតាទាំងឡាយ តែមួយថ្ងៃ ដើម្បីនឹងសម្តែងបាតិមោក្ខ ។

១០៣

មហាបទានសុត្តេ តតិយភាណវារំ បាតិមោក្ខុទ្ទិសនំ

[៤៤] តត្រ សុទំ ភិក្ខវេ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ ភិក្ខុសង្ឃេ ឯវំ ចាតិមោក្ខំ ឧទ្ទិសតិ

ខន្តិ បរមំ តចោ តីតិក្ខា

និព្វានំ បរមំ វទន្តិ ពុទ្ធា

ន ហិ បព្វជិតោ បរូបឃាតី

សមណោ ហោតិ បរំ វិហេឋយន្តោ ។

សព្វចាបស្ស អករណំ កុសលស្សូបសម្បទា

សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ ។

អនូបវាទោ អនូបឃាតោ ចាតិមោក្ខេ ច សំវរោ

មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ

អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនន្តិ ។

មហាបទានសូត្រ ភាណវារៈទី ៣ ការទ្រង់សម្ដែងបាតិមោក្ខ

[៩៤] ម្នាលភិក្ខុទាំងឡាយ មានសេចក្ដីដំណាលថា ក្នុងសម័យនោះ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់សម្ដែងបាតិមោក្ខ ក្នុងជំនុំសង្ឃ យ៉ាងនេះថា

អធិវាសនក្ខន្តី ពោលគឺសេចក្ដីអត់ធន់ ជាតបធម៌ ដ៏ឧត្ដម ព្រះពុទ្ធទាំងឡាយ តែងត្រាស់ថា ព្រះនិព្វាន ជាធម្មជាតឧត្ដម បព្វជិតអ្នកសម្លាប់សត្វដទៃ បៀតបៀនសត្វដទៃ មិនឈ្មោះថា សមណៈឡើយ ។

ការមិនធ្វើអំពើបាបទាំងពួង ការបំពេញកុសល ការញុំាង ចិត្តរបស់ខ្លួនឲ្យផូរផង់ ទាំង ៣ នេះ ជាពាក្យប្រដៅរបស់ ព្រះពុទ្ធទាំងឡាយ ។

ការមិនពោលតិះដៀល ការមិនបៀតបៀន ការសង្រួមក្នុង បាតិមោក្ខ ភាវៈជាអ្នកដឹងប្រមាណក្នុងភត្ត ទីដេកទីអង្គុយដ៏ ស្ងាត់ ការបំពេញព្យាយាម ក្នុងអធិចិត្តទាំង ៦ នេះ ជា ពាក្យប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។

[៥៥] ឯកមិទាហំ ភិក្ខវេ សមយំ ឧក្កដ្ឋាយំ វិហរាមិ សុភវនេ[១] សាលរាជមូលេ ។ តស្ស មយ្ហំ ភិក្ខវេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ន ខោ សោ សុលភរូបោ យោ មយា អនាវុត្ថបុព្វោ[២] ឥមិនា ទីឃេន អទ្ធុនា អញ្ញត្រ សុទ្ធាវាសេហិ ទេវេហិ យត្ថាហំ យេន សុទ្ធាវាសា ទេវា តេន ឧបសង្ក-មេយ្យន្តិ ។ អថខ្វាហំ ភិក្ខវេ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ឧក្កដ្ឋាយំ សុភវនេ សាលរាជមូលេ អន្តរហិតោ អវិហេសុ ទេវេសុ បាតុរហោសឹ ។ តស្មឹយេវ ខោ[៣] ភិក្ខវេ ទេវនិកាយេ អនេកានិ ទេវតាសតានិ[៤] អនេកានិ ទេវតាសហស្សានិ យេនាហំ តេនុបសង្កមឹសុ ឧប-សង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។

១ ឱ. ម. សុភគវនេ ។ ២ ម. អនជ្ឈាវុត្ថបុព្វោ ។ ៣ ឱ. ម. ឯវ ខោតិ សទ្ទទ្វយំ ន ទិស្សតិ ។ ៤ ឱ. ម. អនេកានិ ទេវតាសតានីតិ ន ទិស្សន្តិ ។

[៥៥] ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យមួយ តថាគតនៅទៀបដើមសាលរាជ[១] ក្នុងសុភវ័ន ជិតក្រុងឧក្កដ្ឋា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះយ៉ាងនេះ កើតឡើងក្នុងចិត្ត របស់តថាគត ដែលនៅក្នុងទីស្ងាត់ជាទីសម្រាកនោះថា ជាន់សុទ្ធាវាសណា ដែលតថាគត មិនធ្លាប់នៅអាស្រ័យ ជាន់សុទ្ធាវាសនោះ បុគ្គលមិនងាយនឹងបាន លើកលែងតែពួកទេវតា ដែលនៅក្នុងជាន់សុទ្ធាវាស ជាយូរអង្វែងមកហើយនេះចេញ បើដូច្នោះ គួរតែតថាគត ទៅរកពួកទេវតា ដែលនៅក្នុងជាន់សុទ្ធាវាសនោះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគតចៀសចេញអំពីដើមសាលរាជ ក្នុងសុភវ័នជិតក្រុងឧក្កដ្ឋា ទៅប្រាកដក្នុងទេវលោកឈ្មោះអវិហា ប្រៀបដូចបុរសមានកម្លាំង លាចេញនូវកំភួនដៃ ដែលបត់ចូល ឬបត់ចូលនូវកំភួនដៃ ដែលលាចេញ ។ ម្នាលភិក្ខុទាំងឡាយ ពពួកទេវតាទាំងនោះ មានពួកទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។

---

១ ឈើដែលជាធំជាងគេក្នុងព្រៃ ។

ឯកមន្តំ ឋិតា ខោ ភិក្ខវេ តា ទេវតា មំ ឯតទវោចុំ ឥតោ សោ មារិស ឯកនវុតោ កប្បោ[១] យំ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ វិបស្សី មារិស ភគវា អរហំ សម្មាសម្ពុទ្ធោ ខត្តិយោ ជាតិយា អហោសិ ខត្តិយកុលេ ឧទបាទិ វិបស្សី មារិស ភគវា អរហំ សម្មាសម្ពុទ្ធោ កោណ្ឌញ្ញោ គោត្តេន អហោសិ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អសីតិវស្សសហស្សានិ អាយុប្បមាណំ អហោសិ វិបស្សី មារិស ភគវា អរហំ សម្មាសម្ពុទ្ធោ បាដលិយា មូលេ អភិសម្ពុទ្ធោ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ខណ្ឌតិស្សំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស តយោ សាវកានំ សន្និបាតា អហេសុំ ឯកោ សាវកានំ សន្និបាតោ អហោសិ អដ្ឋសដ្ឋីភិក្ខុសតសហស្សំ ឯកោ

១ ឱ. ឯកនវុតេ កប្បេ ។ ម. ឯកនវុតិកប្បេ ។

ម្នាលភិក្ខុទាំងឡាយ លុះទេវតាទាំងនោះ ឈរក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងតថាគត ថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ រាប់អំពីកប្បនេះ (ថយក្រោយទៅ) ៩១ កប្ប ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជាខត្តិយជាតិ ទ្រង់ព្រះសម្ភព ក្នុងខត្តិយត្រកូល បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជាកោណ្ឌញ្ញគោត្រ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមដើមបាដលិព្រឹក្ស (ដើមប្រនៀង) បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះខណ្ឌៈ ១ តិស្សៈ ១ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានសាវកសន្និបាត ៣ ដងគឺ សាវកសន្និបាតម្តង មានភិក្ខុ ៦ លាន ៨ សែនរូប

សាវកានំ សន្និបាតោ អហោសិ ភិក្ខុសតសហស្សំ ឯកោ សាវកានំ សន្និបាតោ អហោសិ អសីតិភិក្ខុសហស្សានិ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឥមេ តយោ សាវកានំ សន្និបាតា អហេសុំ សព្វេសំយេវ ខីណាសវានំ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អសោកោ នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ពន្ធុមា នាម រាជា បិតា អហោសិ ពន្ធុមតី នាម ទេវី មាតា អហោសិ ជនេត្តី ពន្ធុមស្ស រញ្ញោ ពន្ធុមតី នាម នគរំ រាជធានំ អហោសិ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឯវំ អភិនិក្ខមនំ អហោសិ ឯវំ បព្វជ្ជា ឯវំ បធានំ ឯវំ អភិសម្ពោធិ ឯវំ ធម្មចក្កប្បវត្តនំ តេ មយំ មារិស វិបស្សិម្ហិ ភគវតិ ព្រហ្មចរិយំ ចរិត្វា កាមេសុ កាមច្ឆន្ទំ វិរាជេត្វា ឥធុបបន្នាតិ ។ តស្មិំយេវ ខោ ភិក្ខវេ ទេវនិកាយេ អនេកានិ ទេវតាសតានិ អនេកានិ ទេវតាសហស្សានិ

សាវកសន្និបាតម្តង មានភិក្ខុ ១ សែនរូប សាវកសន្និបាតម្តងមានភិក្ខុ ៨ ហ្មឺនរូប បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានសាវកសន្និបាតទាំង ៣ ដងនេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះអសោកៈ ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះបិតារបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជាទ្រង់ព្រះនាមពន្ធុមៈ ព្រះមាតាព្រះនាម ពន្ធុមតីទេវី ជាព្រះមាតាបង្កើត ព្រះនគរនៃព្រះបាទពន្ធុមៈឈ្មោះ ពន្ធុមតី ជារាជធានី បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ចេញទៅទ្រង់ព្រះផ្នួសយ៉ាងនេះ បព្វជ្ជាយ៉ាងនេះ ការព្យាយាមយ៉ាងនេះ ការបានត្រាស់យ៉ាងនេះ មានព្រះធម្មចក្កប្បវត្តនៈយ៉ាងនេះ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ យើងខ្ញុំទាំងនោះ ប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងសម្នាក់នៃព្រះវិបស្សីមានព្រះភាគ ហើយនឿយណាយចាកសេចក្តីពេញចិត្តនឹងកាមក្នុងកាមទាំងឡាយ ទើបបានមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ មានទេវតាច្រើនរយ ច្រើនពាន់

យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ តា ទេវតា មំ ឯតទវោចុំ ឥតោ សោ មារិស ឯកត្តឹសោ កប្បោ យំ សិខី ភគវា ។ បេ ។ តេ មយំ មារិស សិខិម្ហិ ភគវតិ ។ បេ ។ តស្មឹយេវ ខោ មារិស ឯកត្តឹសេ កប្បេ វេស្សភូ ភគវា ។ បេ ។ តេ មយំ មារិស វេស្សភុម្ហិ ភគវតិ ។ បេ ។ ឥមស្មឹយេវ ខោ មារិស ភទ្ទកប្បេ កក្កុសន្ធោ ។ កោនាគមនោ ។ កស្សបោ ភគវា ។ បេ ។ តេ មយំ មារិស កក្កុ-សន្ធម្ហិ ។ កោនាគមនម្ហិ ។ កស្សបម្ហិ ភគវតិ ព្រហ្មចរិយំ ចរិត្វា កាមេសុ កាមច្ឆន្ទំ វិរាជេត្វា ឥធុបបន្នាតិ ។ តស្មឹយេវ ខោ ភិក្ខវេ ទេវនិកាយេ អនេកានិ ទេវតាសតានិ អនេកានិ ទេវតា-

ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះឈរក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ រាប់អំពីកប្បនេះឡើងទៅ ៣១ កប្ប ព្រះសិខីមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ពួកខ្ញុំព្រះអង្គទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះសិខីមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ក្នុង ៣១ កប្បនោះឯង ព្រះវេស្សភូមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះវេស្សភូមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ក្នុងភទ្ទកប្បនេះ ព្រះកកុសន្ធៈ ។ ព្រះកោនាគមនៈ ។ ព្រះកស្សបៈមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ពួកខ្ញុំព្រះអង្គទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះកកុសន្ធៈ ។ ក្នុងសម្នាក់នៃព្រះកោនាគមនៈ ។ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់នៃព្រះកស្សបៈមានព្រះភាគ ហើយនឿយណាយចាកសេចក្ដីពេញចិត្តនឹងកាមក្នុងកាមទាំងឡាយ ទើបបានមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ មានទេវតាច្រើនរយ ច្រើនពាន់

សហស្សានិ យេនាហំ តេនុបសង្កមឹសុ ឧបសង្ក-មិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ តា ទេវតា មំ ឯតទវោចុំ ឥ-មស្មឹយេវ ខោ មារិស ភទ្ទកប្បេ ភគវា ឯតរហិ អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ ភគវា មារិស ខត្តិយោ ជាតិយា ខត្តិយកុលេ ឧប្បន្នោ ភគវា មារិស គោតមោ គោត្តេន ភគវតោ មារិស អប្បកំ អាយុប្បមាណំ បរិត្តំ លហុកំ យោ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ ភគវា មារិស អស្សត្ថស្ស មូលេ អភិសម្ពុទ្ធោ ភគវតោ មារិស សារីបុត្តមោគ្គល្លានំ[១] នាម សាវកយុគំ អហោសិ[២] អគ្គំ ភទ្ទយុគំ ភគវតោ មារិស ឯសោ[៣] សាវកានំ សន្និបាតោ អហោសិ អឌ្ឍតេឡសានិ ភិក្ខុសតានិ ភគវតោ មារិស អយំ ឯកោ សាវកានំ សន្និបាតោ អហោសិ សព្វេសំយេវ ខីណាសវានំ ភគវតោ មារិស

---

១ ឱ. សារីបុត្តមោគ្គល្លានា ។ ២ ឱ. អហោសីតិ ន ទិស្សតិ ។ ៣ ឱ. ម. ឯកោ ។

ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះឈរក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ឥឡូវនេះ ក្នុងភទ្ទកប្បនេះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងហើយ ក្នុងលោក បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ ជាខត្តិយជាតិ ទ្រង់ព្រះសម្ភព ក្នុងខត្តិយត្រកូល បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ ជាគោតមគោត្រ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ មានព្រះជន្មាយុតិចតួចស្តួចស្តើងណាស់ បុគ្គល (ក្នុងសម័យនេះ) ដែលរស់នៅយ៉ាងយូរ បានត្រឹម ១០០ ឆ្នាំ នឹងតិចជាង ១០០ ឆ្នាំ ឬលើសពី ១០០ ឆ្នាំក៏មានខ្លះដែរ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ ត្រាស់ក្រោមដើមអស្សត្ថព្រឹក្ស[១] បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ មានគូនៃសាវកជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះព្រះសារីបុត្ត ១ ព្រះមោគ្គល្លាន ១ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ ព្រះអង្គមានសាវកសន្និបាតតែម្តង មានភិក្ខុ ១ ពាន់ ២ រយ ៥០ អង្គ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ មានសាវកសន្និបាតតែម្តងនេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ

១ ដើមពោធិ៍បាយ ។

អានន្ទោ នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ ភគវតោ មារិស សុទ្ធោទនោ នាម រាជា បិតា មាយា នាម ទេវី មាតា ជនេត្តី កបិលវត្ថុនគរំ រាជធានី អហោសិ ភគវតោ មារិស ឯវំ អភិនិក្ខមនំ អហោសិ ឯវំ បព្ពជ្ជា ឯវំ បធានំ ឯវំ អភិសម្ពោធិ ឯវំ ធម្មចក្កប្បវត្តនំ តេ មយំ មារិស ភគវតិ ព្រហ្មចរិយំ ចរិត្វា កាមេសុ កាមច្ឆន្ទំ វិរាជេត្វា ឥធុបបន្នាតិ ។ អថខោហំ ភិក្ខវេ អបរេហិ ទេវេហិ សទ្ធឹ យេន អតប្បា ទេវា តេនុបសង្កមឹ ។ អថខោហំ[1] ភិក្ខវេ អបរេហិ ច ទេវេហិ អតប្បេហិ ច ទេវេហិ សទ្ធឹ យេន សុទស្សា ទេវា តេនុបសង្កមឹ ។ អថខោហំ ភិក្ខវេ អបរេហិ ច ទេវេហិ អតប្បេហិ ច ទេវេហិ សុទស្សេហិ ច ទេវេហិ សទ្ធឹ យេន សុទស្សី ទេវា តេនុបសង្កមឹ ។ អថខោហំ ភិក្ខវេ

១ ឱ. ម. អថខ្វាហំ ។

មានភិក្ខុឈ្មោះអានន្ទ ជាអ្នកបម្រើ ជាអ្នកបម្រើដ៏ប្រសើរ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះបិតារបស់ព្រះមានព្រះភាគ ជាព្រះរាជា ព្រះនាមសុទ្ធោទនៈ ព្រះមាតាព្រះនាម មាយាទេវី ជាព្រះមាតាបង្កើត មានព្រះនគរកបិលវត្ថុ ជាព្រះរាជធានី បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគមានអភិនិស្រ្កមណ៍យ៉ាងនេះ មានបព្វជ្ជាយ៉ាងនេះ មានព្យាយាមយ៉ាងនេះ មានការត្រាស់ដឹងយ៉ាងនេះ មានព្រះធម្មចក្កប្បវត្តនៈយ៉ាងនេះ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់នៃព្រះមានព្រះភាគ ហើយនឿយណាយចាកសេចក្តីពេញចិត្តនឹងកាមក្នុងកាមទាំងឡាយ ទើបមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគតចូលទៅរកពួកទេវតា ក្នុងជាន់អតប្បា ព្រមទាំងពួកទេវតាក្នុងជាន់អវិហា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគតចូលទៅរកពួកទេវតា ក្នុងជាន់សុទស្សា ព្រមទាំងទេវតាក្នុងជាន់អវិហា និងពួកទេវតា ក្នុងជាន់អតប្បា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគតចូលទៅរកពួកទេវតា ក្នុងជាន់សុទស្សី ព្រមទាំងពួកទេវតា ក្នុងជាន់អវិហា និងពួកទេវតា ក្នុងជាន់អតប្បា និងពួកទេវតាក្នុងជាន់សុទស្សា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគត

អរិហេហិ ច ទេវេហិ អតប្បេហិ ច ទេវេហិ សុទស្សេហិ ច ទេវេហិ សុទស្សីហិ ច ទេវេហិ សទ្ធឹ យេន អកនិដ្ឋា ទេវា តេនុបសង្កមឹ ។ តស្មឹយេវ ខោ ភិក្ខវេ ទេវនិកាយេ អនេកានិ ទេវតាសតានិ អនេកានិ ទេវតាសហស្សានិ យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ តា ទេវតា មំ ឯតទវោចុំ ឥតោ សោ មារិស ឯកនវុតោ កប្បោ យំ វិបស្សី ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧទបាទិ ។ វិបស្សី មារិស ភគវា អរហំ សម្មាសម្ពុទ្ធោ ខត្តិយោ ជាតិយា អហោសិ ខត្តិយកុលេ ឧទបាទិ វិបស្សី មារិស ភគវា អរហំ សម្មាសម្ពុទ្ធោ កោណ្ឌញ្ញោ គោត្តេន អហោសិ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អសីតិវស្សសហស្សានិ អាយុប្បមាណំ អហោសិ វិបស្សី មារិស ភគវា អរហំ សម្មាសម្ពុទ្ធោ បាដលិយា មូលេ អភិសម្ពុទ្ធោ វិបស្សិស្ស មារិស

ចូលទៅរកពួកទេវតា ក្នុងជាន់អកនិដ្ឋា ព្រមទាំងពួកទេវតា ក្នុងជាន់អវិហា និងពួកទេវតា ក្នុងជាន់អតប្បា និងពួកទេវតា ក្នុងជាន់សុទស្សា និងពួកទេវតាក្នុងជាន់សុទស្សី ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ មានពួកទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះ ឈរនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ រាប់អំពីកប្បនេះឡើងទៅ ៩១ កប្បនោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មា-សម្ពុទ្ធ ទ្រង់កើតហើយក្នុងលោក ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជាខត្តិយជាតិ ទ្រង់ព្រះសម្ភពក្នុងខត្តិយត្រកូល បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិ-បស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដឹងក្រោមដើមបាដលិព្រឹក្ស បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សី

១១១

## មហាបទានសុត្តំ តតិយភាណវារំ ទេវតាបដិនិវេទនកថា

ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ខណ្ឌតិស្សំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស តយោ សាវកានំ សន្និបាតា អហេសុំ ឯកោ សាវកានំ សន្និបាតោ អហោសិ អដ្ឋសដ្ឋីភិក្ខុសតសហស្សំ ឯកោ សាវកានំ សន្និបាតោ អហោសិ ភិក្ខុសតសហស្សំ ឯកោ សាវកានំ សន្និបាតោ អហោសិ អសីតិភិក្ខុសហស្សានិ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឥមេ តយោ សាវកានំ សន្និបាតា អហេសុំ សព្វេសំយេវ ខីណាសវានំ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អសោកោ នាម ភិក្ខុ ឧបដ្ឋាកោ អហោសិ អគ្គុបដ្ឋាកោ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ពន្ធុមា នាម រាជា បិតា អហោសិ ពន្ធុមតី នាម ទេវី មាតា អហោសិ ជនេត្តី ពន្ធុមស្ស រញ្ញោ ពន្ធុមតី នាម នគរំ រាជធានី អហោសិ វិបស្សិស្ស មារិស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឯវំ

មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវ័ក ជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះខណ្ឌៈ ១ តិស្សៈ ១ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត ៣ ដង គឺសាវកសន្និបាតម្តងមានភិក្ខុ ៦ លាន ៨ សែនរូប សាវកសន្និបាតម្តង មានភិក្ខុ ១ សែនរូប សាវកសន្និបាតម្តង មានភិក្ខុប្រាំបីហ្មឺនរូប បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត ៣ ដងនេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះអសោកៈ ជាឧបដ្ឋាក ជាអ្នកបម្រើដ៏ប្រសើរ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះបិតារបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជាទ្រង់ព្រះនាមពន្ធុមៈ ព្រះមាតាព្រះនាមពន្ធុមតីទេវីជាព្រះមាតាបង្កើត នគរនៃព្រះបាទពន្ធុមៈ ឈ្មោះពន្ធុមតីរាជ-ធានី បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ

អភិនិក្ខមនំ អហោសិ ឯវំ បព្វជ្ជា ឯវំ បធានំ ឯវំ អភិសម្ពោធិ ឯវំ ធម្មចក្កប្បវត្តនំ តេ មយំ មារិស វិបស្សិម្ហិ ភគវតិ ព្រហ្មចរិយំ ចរិត្វា កាមេសុ កាមច្ឆន្ទំ វិរាជេត្វា ឥធុបបន្នាតិ ។ តស្មឹយេវ ខោ ភិក្ខវេ ទេវនិកាយេ អនេកានិ ទេវតាសតានិ អនេកានិ ទេវតាសហស្សានិ យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ តា ទេវតា មំ ឯតទវោចុំ ឥតោ សោ មារិស ឯកត្តឹសោ កប្បោ យំ សិខី ភគវា ។ បេ ។ តេ មយំ មារិស សិខិម្ហិ ភគវតិ ។ បេ ។ តស្មឹយេវ ខោ មារិស ឯកត្តឹសេ កប្បេ វេស្សភូ ភគវា ។ បេ ។ តេ មយំ មារិស វេស្សភុម្ហិ ភគវតិ ។ បេ ។ ឥមស្មឹយេវ ខោ មារិស ភទ្ទកប្បេ កកុសន្ធោ ។ កោនាគមនោ ។ កស្សបោ ភគវា

មានអភិនិក្រមណ៍យ៉ាងនេះ មានបព្វជ្ជាយ៉ាងនេះ មានព្យាយាមយ៉ាងនេះ មានការត្រាស់ដឹងយ៉ាងនេះ មានព្រះធម្មចក្កប្បវត្តនៈយ៉ាងនេះ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះវិបស្សីមានព្រះភាគ នឿយណាយចាកសេចក្តីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ ទើបមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ មានពួកទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះ ឈរក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ រាប់ពីភទ្ទកប្បនេះឡើងទៅ ៣១ កប្បនោះ ព្រះសិខីមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះសិខីមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ក្នុង ៣១ កប្បនោះឯង ព្រះវេស្សភូមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះវេស្សភូមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ក្នុងភទ្ទកប្បនេះឯង ព្រះកកុសន្ធៈ ។ ព្រះកោនាគមនៈ ។ ព្រះកស្សបៈមានព្រះភាគ

។ បេ ។ តេ មយំ មារិស កក្កុសន្ធម្ហិ ។ កោណាគមនម្ហិ ។ កស្សបម្ហិ ភគវតិ ព្រហ្មចរិយំ ចរិត្វា កាមេសុ កាមច្ឆន្ទំ វិរាជេត្វា ឥធុបបន្នាតិ ។ តស្មិំយេវ ខោ ភិក្ខវេ ទេវនិកាយេ អនេកានិ ទេវតាសតានិ អនេកានិ ទេវតាសហស្សានិ យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ តា ទេវតា មំ ឯតទវោចុំ ឥមស្មិំយេវ ខោ មារិស ភទ្ទកប្បេ ភគវា ឯតរហិ អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ ភគវា មារិស ខត្តិយោ ជាតិយា ខត្តិយកុលេ ឧប្បន្នោ ភគវា មារិស គោតមោ គោត្តេន ភគវតោ មារិស អប្បកំ អាយុប្បមាណំ បរិត្តំ លហុកំ យោ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ ភគវា មារិស អស្សត្ថស្ស មូលេ អភិសម្ពុទ្ធោ ភគវតោ មារិស

។ បេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះកក្កុសន្ធៈ ។ ក្នុងសម្នាក់ព្រះកោនាគមនៈ ។ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះកស្សបៈមានព្រះភាគ នឿយណាយចាកសេចក្តីពេញចិត្ត នឹងកាមក្នុងកាមទាំងឡាយ ទើបមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ ពួកទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះឈរក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ឥឡូវនេះឯង ក្នុងភទ្ទកប្បនេះ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតក្នុងលោក បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ ជាខត្តិយជាតិ ទ្រង់ព្រះសម្ភពក្នុងខត្តិយត្រកូល បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ ជាគោតមគោត្រ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ មានព្រះជន្មាយុតិចតួចស្តួចស្តើងណាស់ បុគ្គលដែលរស់នៅយ៉ាងយូរបានត្រឹម ១០០ ឆ្នាំ និងថយចុះពី ១០០ ឆ្នាំ ឬ លើសពី ១០០ ឆ្នាំក៏មានខ្លះដែរ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគត្រាស់ក្រោមដើមអស្សត្ថព្រឹក្ស បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ

សារីបុត្តមោគ្គល្លានំ នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ភគវតោ មារិស ឯកោ សាវកានំ សន្និបាតោ អហោសិ អឌ្ឍតេឡសានិ ភិក្ខុសតានិ ភគវតោ មារិស អយំ ឯកោ សាវកានំ សន្និបាតោ អហោសិ សព្វេ-សំយេវ ខីណាសវានំ ភគវតោ មារិស អានន្ទោ នាម ភិក្ខុ ឧបដ្ឋាកោ អគ្គុបដ្ឋាកោ ភគវតោ មារិស សុទ្ធោ-ទនោ នាម រាជា បិតា មាយា នាម ទេវី មាតា ជនេត្តី កបិលវត្ថុនគរំ រាជធានី ភគវតោ មារិស ឯវំ អភិនិក្ខមនំ អហោសិ ឯវំ បព្វជ្ជា ឯវំ បធានំ ឯវំ អភិសម្ពោធិ ឯវំ ធម្មចក្កប្បវត្តនំ តេ មយំ មារិស ភគវតិ ព្រហ្មចរិយំ ចរិត្វា កាមេសុ កាមច្ឆន្ទំ វិរាជេត្វា ឥធុបបន្នាតិ ។

មានគូនៃសាវ័ក ជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះព្រះសារីបុត្ត ១ ព្រះមោគ្គល្លាន ១ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ មានសាវកសន្និបាតតែម្តង មានភិក្ខុ ១ ពាន់ ២ រយ ៥០ រូប បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ មានសាវកសន្និបាតតែម្តងប៉ុណ្ណោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ មានភិក្ខុឈ្មោះអានន្ទ ជាឧបដ្ឋាក ជាអ្នកបម្រើដ៏ប្រសើរ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះបិតារបស់ព្រះមានព្រះភាគ ជាព្រះរាជាព្រះនាមសុទ្ធោទនៈ ព្រះមាតាព្រះនាមមាយាទេវី ជាព្រះមាតាបង្កើត មាននគរកបិលវត្ថុ ជាព្រះរាជធានី បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ ព្រះអង្គមានអភិនិស្ក្រមណ៍យ៉ាងនេះ មានបព្វជ្ជាយ៉ាងនេះ មានព្យាយាមយ៉ាងនេះ មានការត្រាស់ដឹងយ៉ាងនេះ មានព្រះធម្មចក្កប្បវត្តនៈយ៉ាងនេះ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ នឿយណាយចាកសេចក្តីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ ទើបមកកើតក្នុងទីនេះ ។

[៤៦] ឥតិ ខោ ភិក្ខវេ តថាគតស្សេវេសា ធម្មធាតុ សុប្បដិវិទ្ធា យស្សា ធម្មធាតុយា សុប្បដិវិទ្ធត្តា តថាគតោ អតីតេ ពុទ្ធេ បរិនិព្ពុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្តេ សព្វទុក្ខវីតិវត្តេ ជាតិតោបិ អនុស្សរតិ នាមតោបិ អនុស្សរតិ គោត្តតោបិ អនុស្សរតិ អាយុប្បមាណតោបិ អនុស្សរតិ សាវកយុគតោបិ អនុស្សរតិ សាវកសន្និបាតតោបិ អនុស្សរតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំនាមា ។ ឯវំគោត្តា ។ ឯវំសីលា ។ ឯវំធម្មា ។ ឯវំបញ្ញា ។ ឯវំវិហារី ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ។ ទេវតាបិ តថាគតស្ស ឯតមត្ថំ អារោចេសុំ យេន តថាគតោ អតីតេ ពុទ្ធេ បរិនិព្ពុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្តេ សព្វទុក្ខវីតិវត្តេ

[៩៦] ម្នាលភិក្ខុទាំងឡាយ ធម្មធាតុនុ៎ះ តថាគតដឹងដោយប្រការដូច្នេះ ព្រោះតែតថាគត ដឹងច្បាស់នូវធម្មធាតុ បានជាព្រះអតីតពុទ្ធទាំងឡាយ ទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញ៉ាំងសត្វ ឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏តថាគតរលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង រលឹកឃើញព្រះគោត្រផង រលឹកឃើញប្រមាណ នៃព្រះជន្មាយុផង រលឹកឃើញគូនៃសាវ័កផង រលឹកឃើញសាវកសន្និបាតផង ថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះ មានព្រះនាមយ៉ាងនេះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះដូច្នេះផង ។ ទាំងពួកទេវតាក៏បានប្រាប់សេចក្តីនេះចំពោះតថាគត ព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញ៉ាំងសត្វ ឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ

ជាតិតោបិ អនុស្សរតិ នាមតោបិ អនុស្សរតិ គោត្ត-
តោបិ អនុស្សរតិ អាយុប្បមាណតោបិ អនុស្សរតិ
សាវកយុគតោបិ អនុស្សរតិ សាវកសន្និបាតតោបិ
អនុស្សរតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំ-
នាមា ។ ឯវំគោត្តា ។ ឯវំសីលា ។ ឯវំធម្មា ។ ឯវំ-
បញ្ញា ។ ឯវំវិហារី ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ
ឥតិបីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ
ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាបទានសុត្តំ បឋមំ និដ្ឋិតំ ។

តថាគតក៏រលឹកឃើញព្រះជាតិផង រលឹកឃើញព្រះនាមផង រលឹកឃើញព្រះគោត្រផង រលឹកឃើញប្រមាណនៃជន្មាយុផង រលឹកឃើញគូនៃសាវ័កផង រលឹកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំង-ឡាយនោះ ព្រះអង្គមានព្រះជាតិយ៉ាងនេះ មានព្រះនាមយ៉ាងនេះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះដូច្នេះផង ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់នូវព្រះសូត្រនេះ (ចប់) ហើយ ភិក្ខុទាំងនោះ មានចិត្តរីករាយត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មហាបទានសូត្រទី ១ ។

# មហានិទានសុត្តំ ទុតិយំ

[៨៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ[១] នាម កុរូនំ និគមោ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវគម្ភីរោ ចាយំ ភន្តេ បដិច្ចសមុប្បាទោ គម្ភីរាវភាសោ ច អថ ច បន មេ ឧត្តានកុត្តានកោ វិយ ខាយតីតិ ។ មាហេវំ អានន្ទ អវច មាហេវំ អានន្ទ អវច គម្ភីរោ ចាយំ បដិច្ចសមុប្បាទោ គម្ភីរាវភាសោ ច ។ ឯតស្ស អានន្ទ ធម្មស្ស អននុពោធា

១ កម្មាសធម្មន្តិបិ បាឋោ ។

# មហានិទានសូត្រ ទី ២

[៩៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រថាប់នៅក្នុងកម្មាសទម្មនិគម របស់អ្នកកុរុ ក្នុងកុរុជនបទ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះបដិច្ចសមុប្បាទនេះជ្រៅហួសប្រមាណផង ប្រាកដជាជ្រៅផង ទោះបីមានជម្រៅប៉ុណ្ណោះ ក៏គង់តែប្រាកដដល់ខ្ញុំព្រះអង្គ ថាហាក់ដូចជារាក់ក្រៃពេក ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ បដិច្ចសមុប្បាទនេះជ្រៅផង ប្រាកដជាជ្រៅផង ។ ម្នាលអានន្ទ ព្រោះមិនបានត្រាស់ដឹង

អប្បដិវេធា ឯវមយំ បជា តន្តាកុលកជាតា គុណគណ្ឋិកជាតា[1] មុញ្ជបព្វជភូតា អបាយំ ទុគ្គតឹ វិនិបាតំ សំសារំ នាតិវត្តតិ ។ អត្ថិ ឥទប្បច្ចយា ជរាមរណន្តិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ ។ កឹបច្ចយា ជរាមរណន្តិ ឥតិ ចេ វទេយ្យ ជាតិប្បច្ចយា ជរាមរណន្តិ ឥច្ចស្ស វចនីយំ ។ អត្ថិ ឥទប្បច្ចយា ជាតីតិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ ។ កឹបច្ចយា ជាតីតិ ឥតិ ចេ វទេយ្យ ភវប្បច្ចយា ជាតីតិ ឥច្ចស្ស វចនីយំ ។ អត្ថិ ឥទប្បច្ចយា ភវោតិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ ។ កឹបច្ចយា ភវោតិ ឥតិ ចេ វទេយ្យ ឧបាទានប្បច្ចយា ភវោតិ ឥច្ចស្ស វចនីយំ ។ អត្ថិ ឥទប្បច្ចយា ឧបាទានន្តិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ ។ កឹបច្ចយា ឧបាទានន្តិ

---

១ ឱ. គុណគុណ្ឋិកជាតា ។ ម. កុលកណ្ឋិកជាតា ។

ព្រោះមិនបានចាក់ធ្លុះនូវធម៌នុ៎ះឯង ទើបពួកសត្វនេះ កើតទៅជាស្មុគស្មាញ ដូចជាតម្បាញ (ដែលកណ្ដុរកាត់) ដូចជាអំបោះត្រូវទឹកបាយរបស់ជាងតម្បាញ ឬដូចជាសំបុកសត្វស្វាប ដូចជាស្មៅយាប្លងនិងស្មៅដំណេកទន្សាយ ដែលជំពាក់គ្នាយ៉ាងនេះ ទើបមិនកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបាន ។ ម្នាលអានន្ទ កាលបើមានគេសួរថា ជរានិងមរណៈកើតមាន ព្រោះធម៌នេះជាបច្ច័យមានដែរឬ គប្បីឆ្លើយតបថា មាន ។ បើគេសួរទៀតថា ជរានិងមរណៈកើតមាន ព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា ជរានិងមរណៈកើតមានព្រោះជាតិជាបច្ច័យ ។ ម្នាលអានន្ទ កាលបើមានគេសួរថា ជាតិកើតមានព្រោះធម៌នេះជាបច្ច័យមានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា ជាតិកើតមានព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា ជាតិកើតមានព្រោះភពជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា ភពកើតមានព្រោះធម៌នេះជាបច្ច័យមានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា ភពកើតមានព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា ភពកើតមានព្រោះឧបាទានជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា ឧបាទានកើតមានព្រោះធម៌នេះជាបច្ច័យមានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា ឧបាទាន

១១៩



ឥតិ ចេ វទេយ្យ តណ្ហាបច្ចយា ឧបាទានន្តិ ឥច្ចស្ស វចនីយំ ។ អត្ថិ ឥទប្បច្ចយា តណ្ហាតិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ ។ កឹបច្ចយា តណ្ហាតិ ឥតិ ចេ វទេយ្យ វេទនាបច្ចយា តណ្ហាតិ ឥច្ចស្ស វចនីយំ ។ អត្ថិ ឥទប្បច្ចយា វេទនាតិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ ។ កឹបច្ចយា វេទនាតិ ឥតិ ចេ វទេយ្យ ផស្សប្បច្ចយា វេទនាតិ ឥច្ចស្ស វចនីយំ ។ អត្ថិ ឥទប្បច្ចយា ផស្សោតិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ ។ កឹបច្ចយា ផស្សោតិ ឥតិ ចេ វទេយ្យ នាមរូបប្បច្ចយា ផស្សោតិ ឥច្ចស្ស វចនីយំ ។ អត្ថិ ឥទប្បច្ចយា នាមរូបន្តិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថី-តិស្ស វចនីយំ ។ កឹបច្ចយា នាមរូបន្តិ ឥតិ ចេ វទេយ្យ វិញ្ញាណប្បច្ចយា នាមរូបន្តិ ឥច្ចស្ស វចនីយំ ។ អត្ថិ ឥទប្បច្ចយា វិញ្ញាណន្តិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថី-តិស្ស វចនីយំ ។ កឹបច្ចយា វិញ្ញាណន្តិ ឥតិ ចេ វទេយ្យ

កើតមានព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា តណ្ហាកើតមានព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា តណ្ហាកើតមានព្រោះអ្វីជាបច្ច័យ គប្បីប្រាប់ថា តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា វេទនាកើតមានព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា វេទនាកើតមាន ព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា វេទនាកើតមានព្រោះផស្សៈជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា ផស្សៈកើតមានព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា ផស្សៈកើតមានព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា ផស្សៈកើតមានព្រោះនាមរូបជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា នាមរូបកើតមាន ព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា នាមរូបកើតមានព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា វិញ្ញាណកើតមាន ព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា វិញ្ញាណកើតមាន ព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា

នាមរូបប្បច្ចយា វិញ្ញាណន្តិ ឥច្ចស្ស វចនីយំ ។ ឥតិ ខោ អានន្ទ នាមរូបប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ[១] សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៤៨] ជាតិប្បច្ចយា ជរាមរណន្តិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា ជាតិប្បច្ចយា ជរាមរណំ ។ ជាតិ ច[២] ហិ អានន្ទ

១ ឱ. ឯត្ថន្តរេ ជរាមរណប្បច្ចយាតិ បាឋោ ទិស្សតិ អតិរេកបាឋេន ភវិតព្វំ មញ្ញេ ។

២ ឱ. វ ។

វិញ្ញាណកើតមានព្រោះនាមរូបជាបច្ច័យ ។ ម្នាលអានន្ទ វិញ្ញាណកើតមានព្រោះនាមរូបជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈកើតមាន ព្រោះនាមរូបជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតមានព្រម ដោយប្រការដូច្នេះឯង ។ កងទុក្ខទាំងអស់នេះ រមែងកើតឡើងយ៉ាងនេះ ។

[៥៨] ពាក្យថា ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យនេះ ពិតជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះឯង ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតត្រូវដឹងតាមទំនង ដែលជរាមរណៈកើតមានព្រោះជាតិជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើជាតិ

១២១

មហានិទានសុត្តេ ពុទ្ធភាណវារំ បដិច្ចសមុប្បាទកថា

នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិ-
ចិ សេយ្យថីទំ ទេវានំ វា ទេវត្តាយ គន្ធព្វានំ វា គន្ធ-
ព្វត្តាយ យក្ខានំ វា យក្ខត្តាយ ភូតានំ វា ភូតត្តាយ
មនុស្សានំ វា មនុស្សត្តាយ ចតុប្បទានំ វា ចតុប្ប-
ទត្តាយ បក្ខីនំ វា បក្ខិត្តាយ[1] សិរីសបានំ វា សិរីស-
បត្តាយ ។ តេសំ តេសញ្ច ហិ អានន្ទ សត្តានំ ត-
ទត្តាយ ជាតិ នាភវិស្ស ។ សព្វសោ ជាតិយា អសតិ
ជាតិនិរោធា អបិ នុ ខោ ជរាមរណំ បញ្ញាយេថាតិ ។
នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ

១ ឱ. ម. បក្ខត្តាយ ។

មិនមានដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង[១]ហើយ គឺថា ជាតិមិនមាន ដល់ពួកទេវតា ដើម្បីភាវៈជាទេវតាក្តី ដល់ពួកគន្ធព្វ ដើម្បីភាវៈជាគន្ធព្វក្តី ដល់ពួកយក្ស ដើម្បីភាវៈជាយក្សក្តី ដល់ពួកភូត ដើម្បីភាវៈជាភូតក្តី ដល់ពួកមនុស្ស ដើម្បីភាវៈជាមនុស្សក្តី ដល់ពួកសត្វជើងបួន ដើម្បីភាវៈជាសត្វជើងបួនក្តី ដល់ពួកសត្វស្លាប ដើម្បីភាវៈជាសត្វស្លាបក្តី ដល់ពួកសត្វលូនវារ ដើម្បីភាវៈជាសត្វលូនវារក្តី ។ ម្នាលអានន្ទ ជាតិមិនមានដល់សត្វនោះ ៗ ដោយប្រការដូច្នោះឯង ។ កាលបើជាតិមិនមានដោយប្រការទាំងពួង ព្រោះជាតិរលត់ហើយ បើដូច្នេះ តើជរាមរណៈ គប្បីមានប្រាកដដែរឬ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ជាតិនេះ ទើបជាហេតុ

---

១ សេចក្តីនេះត្រូវចូលចិត្តថា សត្វទាំងអស់ក្នុងភពទាំងអស់ កាលបើមានជាតិហើយ ជរាមរណៈក៏មានដែរ ។

និទានំ ឯស សមុទយោ ឯស បច្ចយោ ជរាមរណស្ស យទិទំ ជាតិ ។ ភវប្បច្ចយា ជាតីតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា ភវប្បច្ចយា ជាតិ ។ ភវោ ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ សេយ្យថីទំ កាមភវោ វា[១] រូបភវោ វា[២] អរូបភវោ វា ។ សព្វសោ ភវេ អសតិ ភវនិរោធា អបិ នុ ខោ ជាតិ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ ជាតិយា យទិទំ ភវោ ។ ឧបាទានប្បច្ចយា ភវោតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា ឧបាទានប្បច្ចយា ភវោ ។ ឧបាទានញ្ច[៣] ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ សេយ្យថីទំ កាមុបាទានំ វា ទិដ្ឋុបាទានំ វា សីលព្វតុបាទានំ វា អត្តវាទុបាទានំ វា ។ សព្វសោ ឧបាទានេ អសតិ

---

១-២ ឱ. វាសទ្ទោ ន ទិស្សតិ ។ ៣ ឱ. ឧបាទានំ វ ។

ជានិទាន ជាសមុទ័យ ជាបច្ច័យ នៃជរាមរណៈ ។ ពាក្យថា ជាតិកើតមាន ព្រោះភពជាបច្ច័យនេះ ប្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតត្រូវដឹងតាមទំនង ដែលជាតិកើតមាន ព្រោះភពជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើភពមិនមានហើយដល់សត្វណាមួយក្នុងភពណា ៗ ដោយអាការៈទាំងពួង ដោយសភាវៈទាំងពួង គឺ កាមភព ១ រូបភាព ១ អរូបភព ១ ។ កាលបើភពមិនមានដោយប្រការទាំងពួង ព្រោះភពរលត់ហើយ បើដូច្នេះ តើជាតិគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ភពនេះទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃជាតិ ។ ពាក្យថា ភពកើតមានព្រោះឧបាទានជាបច្ច័យ នេះប្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតត្រូវដឹងតាមទំនងដែលភពកើតមាន ព្រោះឧបាទានជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើឧបាទាន មិនមានហើយ ដល់សត្វណាមួយក្នុងភពណា ៗ ដោយអាការៈទាំងពួង ដោយសភាវៈទាំងពួង គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ កាលបើឧបាទាន មិនមានដោយប្រការទាំងពួង

១២៣

ឧបាទាននិរោធា អបិ នុ ខោ ភវោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ ភវស្ស យទិទំ ឧបាទានំ ។ តណ្ហាបច្ចយា ឧបាទានន្តិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា តណ្ហាបច្ចយា ឧបាទានំ ។ តណ្ហា ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ សេយ្យថីទំ រូបតណ្ហា[១] សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ សព្វសោ តណ្ហាយ អសតិ តណ្ហានិរោធា អបិ នុ ខោ ឧបាទានំ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ ឧបាទានស្ស យទិទំ តណ្ហា ។ វេទនាបច្ចយា តណ្ហាតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា វេទនាបច្ចយា តណ្ហា ។

១ រូបត្តណ្ហាតិបិ ។ ឯវមញ្ញេសុបិ ។

ព្រោះឧបាទានរលត់ហើយ បើដូច្នេះ តើភពគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ឧបាទាននេះទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃភព ។ ពាក្យថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតត្រូវដឹងតាមទំនងដែលឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើតណ្ហាមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង គឺរូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ ។ កាលបើតណ្ហាមិនមានដោយប្រការទាំងពួង ព្រោះតណ្ហារលត់ហើយ បើដូច្នេះ តើឧបាទាន គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង តណ្ហានេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃឧបាទាន ។ ពាក្យថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ នេះប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតត្រូវដឹងតាមទំនងដែលតណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យនេះចុះ ។

វេទនា ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វ-ថា សព្វំ កស្សចិ កិម្හិចិ សេយ្យថីទំ ចក្ខុសម្ផស្ស-ជា វេទនា សោតសម្ផស្សជា វេទនា ឃានសម្ផស្សជា វេទនា ជិវ្හាសម្ផស្សជា វេទនា កាយសម្ផស្សជា វេទ-នា មនោសម្ផស្សជា វេទនា ។ សព្វសោ វេទនាយ អសតិ វេទនានិរោធា អបិ នុ ខោ តណ្ហា បញ្ញាយេ-ថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ តណ្ហាយ យទិទំ វេទនា ។

[៥៩] ឥតិ ខោ បនេតំ[១] អានន្ទ វេទនំ បដិច្ច តណ្ហា តណ្ហំ បដិច្ច បរិយេសនា បរិយេសនំ បដិច្ច លាភោ លាភំ បដិច្ច វិនិច្ឆយោ វិនិច្ឆយំ បដិច្ច ឆន្ទរាគោ ឆន្ទរាគំ បដិច្ច អជ្ឈោសានំ អជ្ឈោ-សានំ បដិច្ច បរិគ្គហោ បរិគ្គហំ បដិច្ច មច្ឆរិយំ

១ ឱ. បនេតន្តិ ន ទិស្សតិ ។

ម្នាលអានន្ទ សេចក្តីពិតថា បើវេទនាមិនមានហើយ ដល់សត្វណាមួយក្នុងភពណា ៗ ដោយអាការៈទាំងពួង ដោយសភាវៈទាំងពួង គឺវេទនាកើតអំពីចក្ខុសម្ផស្ស ១ វេទនាកើតអំពីសោតសម្ផស្ស ១ វេទនាកើតអំពីឃានសម្ផស្ស ១ វេទនាកើតអំពីជិវ្ហាសម្ផស្ស ១ វេទនាកើតអំពីកាយសម្ផស្ស ១ វេទនាកើតអំពីមនោសម្ផស្ស ១ ។ កាលបើវេទនាមិនមានដោយប្រការទាំងពួង ព្រោះវេទនារលត់ហើយ បើដូច្នេះ តើតណ្ហាគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង វេទនានេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃតណ្ហា ។

[៩៩] ម្នាលអានន្ទ តណ្ហាកើតមាន ព្រោះអាស្រ័យវេទនា ការស្វែងរកកើតមាន ព្រោះអាស្រ័យតណ្ហា លាភកើតមានព្រោះអាស្រ័យការស្វែងរក វិនិច្ឆ័យគឺសេចក្តីត្រិះរិះកើតមាន ព្រោះអាស្រ័យលាភ ឆន្ទរាគគឺសេចក្តីប្រាថ្នានិងតម្រេកកើតមាន ព្រោះអាស្រ័យវិនិច្ឆ័យ សេចក្តីចូលចិត្តមាំកើតមានព្រោះអាស្រ័យឆន្ទរាគ សេចក្តីហួងហែងកើតមាន ព្រោះអាស្រ័យសេចក្តីប្រកាន់មាំ សេចក្តីកំណាញ់កើតមានព្រោះអាស្រ័យសេចក្តី

មច្ឆរិយំ បដិច្ច អារក្ខោ អារក្ខំ បដិច្ច[១] អារក្ខាធិករណំ ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុវំតុវំបេសុញ្ញមុសាវាទា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តីតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា អារក្ខាធិករណំ ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុវំតុវំបេសុញ្ញមុសាវាទា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ ។ អារក្ខោ ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ ។ សព្វសោ អារក្ខេ អសតិ អារក្ខនិរោធា អបិ នុ ខោ ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុវំតុវំបេសុញ្ញមុសាវាទា អនេកេ បាបកា អកុសលា ធម្មា សម្ភវេយ្យុន្តិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ

---

១ ឱ. ម. អារក្ខំ បដិច្ចាតិ ន ទិស្សតិ ។

ហួងហែង ការរក្សាមាំកើតមាន ព្រោះអាស្រ័យសេចក្តីកំណាញ់ អកុ-សលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ការឈ្លោះទាស់ទែងវិវាទ ពាក្យថា ឯងមឹង ពាក្យញុះញង់ ពាក្យកុហក កើតមានព្រោះអាស្រ័យការរក្សាមាំ គឺថា មានការរក្សាមាំ ជាហេតុ ពាក្យនេះប្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនង ដែលអកុសលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ការឈ្លោះទាស់ទែងវិវាទ ពាក្យថា ឯងមឹង ពាក្យញុះញង់ ពាក្យកុហក រមែងកើតមាន ព្រោះការរក្សាមាំជាហេតុនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើការរក្សាមាំមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួងដោយសភាវៈទាំងពួង ។ កាលបើការរក្សាមាំ មិនមានដោយប្រការទាំងពួង ព្រោះការរក្សាមាំរលត់ហើយ បើដូច្នេះ តើអកុសលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ការឈ្លោះ ទាស់ទែងវិវាទ ពាក្យថា ឯងមឹង ពាក្យញុះញង់ ពាក្យកុហក គប្បីកើតមានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុ

ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុវំតុវំ-បេសុញ្ញមុសាវាទានំ អនេកេសំ បាបកានំ អកុ-សលានំ ធម្មានំ សម្ភវាយ យទិទំ អារក្ខោ ។ មច្ឆរិយំ បដិច្ច អារក្ខោតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា មច្ឆរិយំ បដិច្ច អារក្ខោ ។ មច្ឆរិយញ្ច[១] ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ ។ សព្វសោ មច្ឆរិយេ អសតិ មច្ឆរិយនិរោធា អបិ នុ ខោ អារក្ខោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ

១ ឱ. មច្ឆរិយំ វ ។

ដូច្នោះ ការរក្សាមាំនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យ នៃកិរិយាកើតមាន នៃអកុសលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ការឈ្លោះ ទាស់ទែង វិវាទ ពាក្យថា ឯងមឹង ពាក្យញុះញង់ ពាក្យកុហក ។ ពាក្យថា ការរក្សាមាំ កើតមានព្រោះអាស្រ័យសេចក្តីកំណាញ់ នេះប្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតគួរដឹងតាមទំនងដែលការរក្សាមាំ កើតមាន ព្រោះអាស្រ័យសេចក្តីកំណាញ់នេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើសេចក្តីកំណាញ់មិនមានហើយ ដល់សត្វណាមួយក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើសេចក្តីកំណាញ់ មិនមានដោយប្រការទាំងពួង ព្រោះសេចក្តីកំណាញ់រលត់ហើយ បើដូច្នេះ តើការរក្សាមាំ គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង សេចក្តីកំណាញ់នេះ ទើបជាហេតុ ជានិទាន

១២៧

មហានិទានសុត្តេ ពុទ្ធភាណវារំ អកុសលធម្មានំ ហេតុប្បច្ចយកថា

ឯស សមុទយោ ឯស បច្ចយោ អារក្ខស្ស យទិទំ មច្ឆរិយំ ។ បរិគ្គហំ បដិច្ច មច្ឆរិយន្តិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា បរិគ្គហំ បដិច្ច មច្ឆរិយំ ។ បរិគ្គហោ ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ ។ សព្វសោ បរិគ្គហេ អសតិ បរិគ្គហនិរោធា អបិ នុ ខោ មច្ឆរិយំ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ មច្ឆរិយស្ស យទិទំ បរិគ្គហោ ។ អជ្ឈោសានំ បដិច្ច បរិគ្គហោតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា អជ្ឈោសានំ បដិច្ច បរិគ្គហោ ។ អជ្ឈោសានញ្ច[១] ហិ អានន្ទ នាភវិស្ស

១ ឱ. អជ្ឈោសានំ វ ។

ជាសមុទ័យ ជាបច្ច័យនៃការរក្សាមាំ ។ ពាក្យថា សេចក្តីកំណាញ់កើតមាន ព្រោះអាស្រ័យការហួងហែង នេះប្រាកដជា តថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនង ដែលសេចក្តីកំណាញ់កើតមាន ព្រោះអាស្រ័យការហួងហែងនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើការហួងហែងមិនមានហើយដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួងទេ ។ កាលបើការហួងហែងមិនមាន ដោយប្រការទាំងពួង ព្រោះការហួងហែងរលត់ហើយ បើដូច្នេះ តើសេចក្តីកំណាញ់គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ការហួងហែងនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃសេចក្តីកំណាញ់ ។ ពាក្យថា សេចក្តីហួងហែងកើតមាន ព្រោះអាស្រ័យសេចក្តីប្រកាន់មាំនេះ ប្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលការហួងហែងកើតមាន ព្រោះអាស្រ័យសេចក្តីប្រ-កាន់មាំនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើសេចក្តីប្រកាន់មាំមិនមាន

សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ ។ សព្វសោ អជ្ឈោសានេ អសតិ អជ្ឈោសាននិរោធា អបិ នុ ខោ បរិគ្គហោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ បរិគ្គហស្ស យទិទំ អជ្ឈោសានំ ។ ឆន្ទរាគំ បដិច្ច អជ្ឈោសានន្តិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា ឆន្ទរាគំ បដិច្ច អជ្ឈោសានំ ។ ឆន្ទរាគោ ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ ។ សព្វសោ ឆន្ទរាគេ អសតិ ឆន្ទរាគនិរោធា អបិ នុ ខោ អជ្ឈោសានំ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ អជ្ឈោសានស្ស យទិទំ ឆន្ទរាគោ ។ វិនិច្ឆយំ បដិច្ច ឆន្ទរាគោតិ

ហើយដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើសេចក្តីប្រកាន់មាំមិនមានដោយប្រការទាំងពួង ព្រោះសេចក្តីប្រកាន់មាំរលត់ហើយ បើដូច្នេះ តើការហួងហែងគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង សេចក្តីប្រកាន់មាំនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃការហួងហែង ។ ពាក្យថា សេចក្តីប្រកាន់មាំកើតមាន ព្រោះអាស្រ័យឆន្ទរាគនេះ ប្រាកដជា តថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនង ដែលសេចក្តីប្រកាន់មាំកើតមាន ព្រោះអាស្រ័យឆន្ទរាគនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើឆន្ទរាគមិនមានហើយដល់សត្វណាមួយក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើឆន្ទរាគ មិនមានដោយប្រការទាំងពួង ព្រោះឆន្ទរាគរលត់ហើយ បើដូច្នេះ តើសេចក្តីប្រកាន់មាំគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ឆន្ទរាគនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃសេចក្តីប្រកាន់មាំ ។ ពាក្យថា ឆន្ទរាគៈកើតមាន ព្រោះអាស្រ័យការវិនិច្ឆ័យ

១២៩



ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា វិនិច្ឆយំ បដិច្ច ឆន្ទរាគោ ។ វិនិច្ឆយោ ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ ។ សព្វសោ វិនិច្ឆយេ អសតិ វិនិច្ឆយនិរោធា អបិ នុ ខោ ឆន្ទរាគោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ ឆន្ទរាគស្ស យទិទំ វិនិច្ឆយោ ។ លាភំ បដិច្ច វិនិច្ឆយោតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា លាភំ បដិច្ច វិនិច្ឆយោ ។ លាភោ ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ ។ សព្វសោ លាភេ អសតិ លាភនិរោធា អបិ នុ ខោ វិនិច្ឆយោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ

នេះប្រាកដជា តថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតត្រូវដឹងតាមទំនង ដែលឆន្ទរាគកើតមាន ព្រោះអាស្រ័យការវិនិច្ឆ័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើការវិនិច្ឆ័យមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើការវិនិច្ឆ័យមិនមានដោយប្រការទាំងពួង ព្រោះការវិនិច្ឆ័យរលត់ហើយ បើដូច្នេះ តើឆន្ទរាគ គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ការវិនិច្ឆ័យនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃឆន្ទរាគ ។ ពាក្យថា ការវិនិច្ឆ័យកើតមាន ព្រោះអាស្រ័យលាភ នេះប្រាកដជា តថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតគួរដឹងតាមទំនងដែលការវិនិច្ឆ័យកើតមាន ព្រោះលាភនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើលាភមិនមានហើយដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើលាភមិនមាន ដោយប្រការទាំងពួង ព្រោះលាភរលត់ហើយ បើដូច្នេះ តើការវិនិច្ឆ័យ គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង លាភនេះ

ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ វិនិច្ឆយស្ស យទិទំ លាភោ ។ បរិយេសនំ បដិច្ច លាភោតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា បរិយេសនំ បដិច្ច លាភោ ។ បរិយេសនា ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ ។ សព្វសោ បរិយេសនាយ អសតិ បរិយេសនានិរោធា អបិ នុ ខោ លាភោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ លាភស្ស យទិទំ បរិយេសនា ។ តណ្ហំ បដិច្ច បរិយេសនាតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា តណ្ហំ បដិច្ច បរិយេសនា ។ តណ្ហា ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ សព្វសោ តណ្ហាយ អសតិ

ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃការវិនិច្ឆ័យ ។ ពាក្យថា លាភកើតមាន ព្រោះអាស្រ័យការស្វែងរកនេះ ប្រាកដជាតថាគតសម្តែង ហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលលាភកើតមាន ព្រោះអាស្រ័យការស្វែងរកនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើការស្វែងរកមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើការស្វែងរក មិនមានដោយប្រការទាំងពួង ព្រោះការស្វែងរករលត់ហើយ បើដូច្នេះ តើលាភគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ការស្វែងរកនោះទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃលាភ ។ ពាក្យថា ការស្វែងរកកើតមាន ព្រោះអាស្រ័យតណ្ហានេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតគួរដឹងតាមទំនងដែលការស្វែងរកកើតមាន ព្រោះអាស្រ័យតណ្ហានេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើតណ្ហាមិនមានហើយដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង តណ្ហានោះ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ កាលបើតណ្ហាមិនមានដោយប្រការទាំងពួង ព្រោះតណ្ហា

តណ្ហានិរោធា អបិ នុ ខោ បរិយេសនា បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ បរិយេសនាយ យទិទំ តណ្ហា ។

[៦០] ឥតិ ខោ អានន្ទ ឥមេ ទ្វេ ធម្មា ទ្វយេន វេទនាយ ឯកសមោសរណា ភវន្តិ ។ ផស្សប្បច្ចយា វេទនាតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា ផស្សប្បច្ចយា វេទនា ។ ផស្សោ ច ហិ អានន្ទ នាភវិស្ស សព្វេន សព្វំ សព្វថា សព្វំ កស្សចិ កិម្ហិចិ សេយ្យថីទំ ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហាសម្ផស្សោ កាយសម្ផស្សោ មនោសម្ផស្សោ ។ សព្វសោ ផស្សេ អសតិ ផស្សនិរោធា អបិ នុ ខោ វេទនា បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ វេទនាយ យទិទំ ផស្សោ ។

រលត់ហើយ បើដូច្នេះ តើការស្វែងរកគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមាន ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង តណ្ហានេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃការស្វែងរក ។

[៦០] ម្នាលអានន្ទ ធម៌ ២ យ៉ាង (វដ្តមូលតណ្ហា ១ សមុទាចារតណ្ហា ១) នេះ ទុកជាមានចំណែក ២ ដូច្នោះ មានទីប្រជុំដោយបច្ច័យតែ ១ ដោយវេទនាជាបច្ច័យ ដោយប្រការដូច្នេះឯង ។ ពាក្យថា វេទនាកើតមានព្រោះផស្សៈជាបច្ច័យ នេះប្រាកដជា តថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលវេទនាកើតមាន ព្រោះផស្សៈជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើផស្សៈមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណា ៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ផស្សៈនោះ គឺចក្ខុសម្ផស្ស ១ សោតសម្ផស្ស ១ ឃានសម្ផស្ស ១ ជិវ្ហាសម្ផស្ស ១ កាយសម្ផស្ស ១ មនោសម្ផស្ស ១ ។ កាលបើផស្សៈមិនមានដោយប្រការទាំងពួង ព្រោះផស្សៈរលត់ហើយ បើដូច្នេះ តើវេទនាគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ផស្សៈនេះទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃវេទនា ។

នាមរូបប្បច្ចយា ផស្សោតិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា នាមរូបប្បច្ចយា ផស្សោ ។ យេហិ អានន្ទ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ យេហិ ឧទ្ទេសេហិ នាមកាយស្ស បញ្ញត្តិ ហោតិ តេសុ អាការេសុ តេសុ លិង្គេសុ តេសុ និមិត្តេសុ តេសុ ឧទ្ទេសេសុ អសតិ អបិ នុ ខោ រូបកាយេ អធិវចនសម្ផស្សោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ យេហិ អានន្ទ អាការេហិ យេហិ លិង្គេហិ យេហិ និ-មិត្តេហិ យេហិ ឧទ្ទេសេហិ រូបកាយស្ស បញ្ញត្តិ ហោតិ តេសុ អាការេសុ តេសុ លិង្គេសុ តេសុ និមិត្តេសុ តេសុ ឧទ្ទេសេសុ អសតិ អបិ នុ ខោ នាមកាយេ បដិឃសម្ផស្សោ បញ្ញាយេថាតិ ។

ពាក្យថា ផស្សៈកើតមាន ព្រោះនាមរូបជាបច្ច័យ នេះប្រាកដជា តថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនង ដែលផស្សៈកើតមាន ព្រោះនាមរូប ជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ បញ្ញត្តិនៃនាមកាយ[១]កើតឡើង ដោយអាការណា ដោយលិង្គណា ដោយនិមិត្តណា ដោយឧទ្ទេសណា កាលបើអាការនោះ លិង្គនោះ និមិត្តនោះ ឧទ្ទេសនោះ មិនមានហើយ បើដូច្នេះ តើអធិវចនសម្ផស្ស គឺមនោសម្ផស្ស គប្បីមានប្រាកដក្នុងរូបកាយ[២]ដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ បញ្ញត្តិនៃរូបកាយ តែងកើតឡើងដោយអាការណា ដោយលិង្គណា ដោយនិមិត្តណា ដោយឧទ្ទេសណា កាលបើអាការនោះ លិង្គនោះ និមិត្តនោះ ឧទ្ទេសនោះ មិនមានហើយ បើដូច្នេះ តើបដិឃ-សម្ផស្ស គឺសម្ផស្សដែលកើតឡើង ព្រោះធ្វើរូបក្ខន្ធដែលប្រកបដោយសេចក្តីថ្នាំងថ្នាក់ ឲ្យជាទីនៅក្នុងនាមកាយ គប្បីមានប្រាកដដែរឬ ។

---

១ បានដល់វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។ ២ បានដល់រូបក្ខន្ធ ។

នោ ហេតំ ភន្តេ ។ យេហិ អានន្ទ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ យេហិ ឧទ្ទេសេហិ នាមកាយស្ស ច រូបកាយស្ស ច បញ្ញត្តិ ហោតិ តេសុ អាការេសុ តេសុ លិង្គេសុ តេសុ និមិត្តេសុ តេសុ ឧទ្ទេសេសុ អសតិ អបិ នុ ខោ អធិវចនសម្ផស្សោ វា បដិឃសម្ផស្សោ វា បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ យេហិ អានន្ទ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ យេហិ ឧទ្ទេសេហិ នាមរូបស្ស បញ្ញត្តិ ហោតិ តេសុ អាការេសុ តេសុ លិង្គេសុ តេសុ និមិត្តេសុ តេសុ ឧទ្ទេសេសុ អសតិ អបិ នុ ខោ ផស្សោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ ផស្សស្ស យទិទំ នាមរូបំ ។ វិញ្ញាណប្បច្ចយា នាមរូបន្តិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយាយេន វេទិតព្វំ យថា វិញ្ញាណប្បច្ចយា នាមរូបំ ។ វិញ្ញាណញ្ច[១] ហិ អានន្ទ មាតុ កុច្ឆិស្មឹ[២] ន ឱក្កមិស្សថ អបិ នុ ខោ

១ ឱ. វិញ្ញាណំ វ ។ ២ ឱ. កុច្ឆឹ ។

បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ បញ្ញត្តិនៃនាមកាយនិងរូបកាយ តែងមានដោយអាការណា ដោយលិង្គណា ដោយនិមិត្តណា ដោយឧទ្ទេសណា កាលបើអាការនោះ លិង្គនោះ និមិត្តនោះ ឧទ្ទេសនោះ មិនមានហើយ បើដូច្នេះ តើអធិវចនសម្ផស្ស ឬបដិឃ-សម្ផស្ស គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ បញ្ញត្តិនៃនាមរូប តែងមានដោយអាការណា ដោយលិង្គណា ដោយនិមិត្តណា ដោយឧទ្ទេសណា កាលបើអាការនោះ លិង្គនោះ និមិត្តនោះ ឧទ្ទេសនោះ មិនមានហើយ បើដូច្នេះ តើផស្សៈគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង នាមរូបនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃផស្សៈ ។ ពាក្យថា នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ នេះប្រាកដជាតថាគតសម្ដែងហើយដោយអាការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនង ដែលនាមរូបកើតមាន ព្រោះវិញ្ញាណ ជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្ដីពិតថា បើវិញ្ញាណនឹងមិនចុះស៊ប់ គឺមិនប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ក្នុងផ្ទៃនៃមាតាហើយ បើដូច្នេះតើ

១៣៤



នាមរូបំ មាតុ កុច្ឆិស្មឹ សមុច្ឆិជ្ជិស្សថាតិ[១] ។ នោ ហេតំ ភន្តេ ។ វិញ្ញាណញ្ច ហិ អានន្ទ មាតុ កុច្ឆិស្មឹ ឱក្កមិត្វា វោក្កមិស្សថ អបិ នុ ខោ នាមរូបំ ឥត្ថត្តាយ អភិនិព្វត្តិស្សថាតិ ។ នោ ហេតំ ភន្តេ ។ វិញ្ញាណញ្ច ហិ អានន្ទ ទហរស្សេវ សតោ វោច្ឆិជ្ជិស្សថ កុមារកស្ស វា កុមារិកាយ វា អបិ នុ ខោ នាមរូបំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ នាម-រូបស្ស យទិទំ វិញ្ញាណំ ។ នាមរូបប្បច្ចយា វិញ្ញាណន្តិ ឥតិ ខោ បនេតំ វុត្តំ ។ តទានន្ទ ឥមិនាបេតំ បរិយា-យេន វេទិតព្វំ យថា នាមរូបប្បច្ចយា វិញ្ញាណំ ។ វិញ្ញាណញ្ច ហិ អានន្ទ នាមរូបេ បតិដ្ឋំ នាលភិស្សថ អបិ នុ ខោ អាយតឹ ជាតិជរាមរណទុក្ខសមុទ-យសម្ភវោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។

---

១ ឱ. សមុច្ឆិស្សថាតិ ។ ម. សមុច្ចិស្សថាតិ ។

នាមរូបនឹងដាច់សូន្យទៅក្នុងផ្ទៃនៃមាតាបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ចុះបើវិញ្ញាណចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាហើយរលត់ទៅវិញ នាមរូបនឹងកើតចំពោះ ក្នុងភាវៈនៃបញ្ចក្ខន្ធដែលបរិបូណ៌នេះ បានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ចុះបើវិញ្ញាណរបស់មនុស្សក្មេង គឺក្មេងប្រុស ឬក្មេងស្រីរលត់ទៅដោយអំណាចចុតិ នាមរូបនឹងដល់នូវសេចក្តីចម្រើន ដុះដាលធំធាត់ដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុនោះ វិញ្ញាណនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃនាមរូប ។ ពាក្យថា វិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតគួរដឹងតាមទំនងដែលវិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ ចុះបើវិញ្ញាណមិនបានទីតម្កល់ក្នុងនាមរូបហើយ កិរិយាកើតឡើងនៃគំនររបស់ទុក្ខ គឺជាតិជរានិងមរណៈគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។

តស្មាតិហានន្ទ ឯសេវ ហេតុ ឯតំ និទានំ ឯស សមុទយោ ឯស បច្ចយោ វិញ្ញាណស្ស យទិទំ នាមរូបំ ។ ឯត្តាវតា ខោ អានន្ទ ជាយេថ វា ជីយេថ វា មីយេថ វា ចវេថ វា ឧបបជ្ជេថ វា ។ ឯត្តាវតា ខោ អធិវចនបថោ ឯត្តាវតា និរុត្តិបថោ ឯត្តាវតា បញ្ញត្តិបថោ ឯត្តាវតា បញ្ញាវចរំ ឯត្តាវតា វដ្ដំ វត្តតិ ។ ឥត្ថត្តំ បញ្ញាបនាយ យទិទំ នាមរូបំ សហ វិញ្ញាណេន ។

[៦១] កិត្តាវតា ច អានន្ទ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ[១] ។ រូបឹ វា ហិ អានន្ទ បរិត្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ រូបី មេ បរិត្តោ អត្តាតិ ។ រូបឹ វា ហិ អានន្ទ អនន្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ រូបី មេ អនន្តោ អត្តាតិ ។ អរូបឹ វា ហិ អានន្ទ បរិត្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ អរូបី មេ បរិត្តោ

១ បញ្ញាបេន្តោ បញ្ញាបេតីតិបិ បាឋោ ។

ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នាមរូបនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃវិញ្ញាណ ។ ម្នាលអានន្ទ នាមរូបគប្បីកើតចាស់ស្លាប់ ឬច្យុត ឬចាប់បដិសន្ធិ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ គន្លងនៃឈ្មោះក្តី គន្លងនៃភាសាក្តី គន្លងនៃបញ្ញត្តិក្តី ខន្ធបញ្ចកៈដែលគួរដឹងដោយបញ្ញាក្តី វដ្តៈក្តី រមែងប្រព្រឹត្តទៅ ដោយហេតុមានប្រមាណប៉ុណ្ណោះ ៗ ឯង ។ ខន្ធបញ្ចកៈ រមែងប្រាកដដោយការបញ្ញត្តនូវឈ្មោះ (មានវេទនានិងសញ្ញាជាដើម) នាមរូបនេះ រមែងប្រព្រឹត្តទៅជាមួយនឹងវិញ្ញាណ ។

[៦១] ម្នាលអានន្ទ ចុះបុគ្គល កាលបញ្ញត្តខ្លួន តែងបញ្ញត្តដោយហេតុមានប៉ុន្មានប្រការ ។ ម្នាលអានន្ទ ក៏បុគ្គល កាលបញ្ញត្តខ្លួន ដែលមានរូបនិងមានប្រមាណតិចថា ខ្លួនរបស់អញមានរូប និងមានប្រមាណតិច[១]ក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គល កាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមានរូបនិងមិនមានទីបំផុតថា ខ្លួនរបស់អញមានរូប និងមិនមានទីបំផុត[២]ក៏មាន ។ ម្នាលអានន្ទ ក៏បុគ្គលកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូបនិងមានប្រមាណតិចថា ខ្លួនរបស់អញ មិនមានរូបនិងមាន

---

១ អដ្ឋកថា ថា បុគ្គលណាកាន់យកនូវកសិណនិមិត្ត ដែលមិនចម្រើន គឺថោកថយ ថាជាខ្លួន ដូច្នេះ បុគ្គលនោះ តែងបញ្ញត្តខ្លួនដែលមានរូប និងមានប្រមាណតិច ។ ពាក្យថា រូប សំដៅយកកសិណនិមិត្ត ពាក្យថា មានប្រមាណតិច សំដៅយកកសិណនិមិត្តដែលថោកថយ ។ ២ បុគ្គលណាកាន់យកនូវកសិណនិមិត្តដែលចម្រើន ថាជាខ្លួនខ្ពង់ខ្ពស់ដូច្នេះ បុគ្គលនោះ តែងបញ្ញត្តខ្លួនថា មានរូបនិងមិនមានទីបំផុត ពាក្យថា រូប សំដៅយកកសិណនិមិត្ត ពាក្យថា មិនមានទីបំផុត សំដៅយកកសិណនិមិត្ត ដែលខ្ពង់ខ្ពស់ថ្លៃថ្លា ។

អត្តាតិ ។ អរូបឹ វា ហិ អានន្ទ អនន្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ អរូបី មេ អនន្តោ អត្តាតិ ។ តត្រានន្ទ យោ សោ រូបឹ បរិត្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ ឯតរហិ វា សោ រូបឹ បរិត្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ តថាភាវឹ[១] វា សោ រូបឹ បរិត្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ អតថំ វា[២] បន សន្តំ តថត្តាយ ឧបកប្បេស្សាមីតិ ឥតិ វា បនស្ស ហោតិ ។ ឯវំ សន្តំ ខោ អានន្ទ រូបឹ បរិត្តត្តានុទិដ្ឋិ

១ ឱ. តត្ថ ភាវី ។ ២ ឱ. វ ។

១៣៦

*ប្រមាណតិច[១]ក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គលកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូបនិងមិនមានទីបំផុតថា ខ្លួនរបស់អញមិនមានរូប និងមិនមានទីបំផុត[២]ក៏មាន ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៤ ពួកនោះ បុគ្គលណាកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមានរូប និងមានប្រមាណតិច បុគ្គលនោះ កាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមានរូប និងមានប្រមាណតិច ក្នុងកាលឥឡូវនេះក្តី[៣] បុគ្គលនោះ កាលនឹងបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមានរូបនិងមានប្រមាណតិច ដែលកើតនៅក្នុងលោកដូច្នោះក្តី[៤] ឬក៏បុគ្គលនោះ មានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិតអាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈដែលពិតទៅវិញក្តី[៥] ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមានរូបថា[៦] មានបរិត្តត្តានុទិដ្ឋិ (សេចក្តីយល់ឃើញថា ខ្លួនមានប្រមាណតិច)*

---

១ បុគ្គលដែលបានសម្រេចនូវរូបជ្ឈានដែលថោកថយ ហើយចម្រើនរូបជ្ឈាននោះ ឆ្លងទៅកាន់អរូបជ្ឈានដែលថោកថយដែរ ក៏កាន់យកនូវអរូបជ្ឈាននោះ ថាជាខ្លួនដូច្នេះ បុគ្គលនោះតែងបញ្ញត្តខ្លួនថា មិនមានរូបនិងមានប្រមាណតិច ដោយអរូបជ្ឈានដែលថោកថយនោះឯង ។ ២ បុគ្គលដែលបានសម្រេចនូវរូបជ្ឈានដែលខ្ពង់ខ្ពស់ថ្លៃថ្លា ហើយចម្រើននូវរូបជ្ឈាននោះ ឆ្លងទៅកាន់អរូបជ្ឈានដែលខ្ពង់ខ្ពស់ថ្លៃថ្លាដែរ ក៏កាន់យកនូវអរូបជ្ឈាននោះ ថាជាខ្លួនដូច្នេះ បុគ្គលនោះតែងបញ្ញត្តខ្លួនថា មិនមានរូបនិងមិនមានទីបំផុត ដោយអរូបជ្ឈានដែលខ្ពង់ខ្ពស់ថ្លៃថ្លានោះឯង ។ ៣ ពាក្យនេះ ព្រះមានព្រះភាគទ្រង់សម្តែងដោយអំណាចឧច្ឆេទទិដ្ឋិ ។ ៤ ដោយអំណាចសស្សតទិដ្ឋិ ។ ៥ បុគ្គលជាឧច្ឆេទវាទី មានប្រាថ្នានឹងបំបែរនូវបុគ្គលជាសស្សតវាទី ឲ្យចូលមកក្នុងទិដ្ឋិរបស់ខ្លួន ចំណែកបុគ្គលដែលជាសស្សតវាទីវិញ ក៏គិតបំបែរបុគ្គលជាឧច្ឆេទវាទី ឲ្យចូលមកក្នុងទិដ្ឋិរបស់ខ្លួនវិញដែរ ។ ៦ សំដៅយកបុគ្គលដែលបានរូបកសិណ ។

១៣៧



អនុសេតីតិ ឥច្ចាលំ[១] វេចនាយ ។ តត្រានន្ទ យោ សោ រូបី អនន្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ ឯតរហិ វា សោ រូបី អនន្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ តថាភាវី វា សោ រូបី អនន្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ អតថំ វា បន សន្តំ តថត្តាយ ឧបកប្បេស្សាមីតិ ឥតិ វា បនស្ស ហោតិ ។ ឯវំ សន្តំ ខោ អានន្ទ រូបឹ អនន្ត-ត្តានុទិដ្ឋិ អនុសេតីតិ ឥច្ចាលំ វេចនាយ ។ តត្រានន្ទ យោ សោ អរូបី បរិត្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ ឯតរហិ វា សោ អរូបី បរិត្តំ អត្តានំ បញ្ញបេន្តោ បញ្ញ-បេតិ តថាភាវី វា សោ អរូបី បរិត្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ អតថំ វា បន សន្តំ តថត្តាយ ឧបកប្បេ-ស្សាមីតិ ឥតិ វា បនស្ស ហោតិ ។ ឯវំ សន្តំ ខោ អានន្ទ

១ ឱ. ឥច្ចលំ ។

ដេកនៅមិនដាច់ ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៤ នោះ បុគ្គលណា កាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមានរូបនិងមិនមានទីបំផុត បុគ្គលនោះ កាលបញ្ញតខ្លួន តែងបញ្ញត្តខ្លួនដែលមានរូបនិងមិនមានទីបំផុត ក្នុងកាលឥឡូវនេះក្តី បុគ្គលនោះកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមានរូបនិងមិនមានទីបំផុត ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិតថា អាត្មាអញនឹងសម្រេច ឬបំ-បែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះ មានហើយ គួរនឹងពោលនូវបុគ្គលដែលមានរូបថា មានអនន្តត្តានុទិដ្ឋិ (សេចក្តីយល់ឃើញថា ខ្លួនមិនមានទីបំផុត) ដេកនៅមិនដាច់ ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៤ ពួកនោះ បុគ្គលណា កាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូបនិងមានប្រមាណតិច បុគ្គលនោះ កាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូបនិងមានប្រមាណតិច ក្នុងកាលឥឡូវនេះក្តី បុគ្គលនោះ កាលបញ្ញត្តខ្លួនតែងបញ្ញត្តខ្លួន ដែលមិនមានរូបនិងមានប្រមាណតិច ដែលកើតក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ

អរូបឹ បរិត្តត្តានុទិដ្ឋិ អនុសេតីតិ ឥច្ចាលំ វចនាយ ។ តត្រានន្ទ យោ សោ អរូបឹ អនន្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ ឯតរហិ វា សោ អរូបឹ អនន្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ តថាភាវឹ វា សោ អរូបឹ អនន្តំ អត្តានំ បញ្ញបេន្តោ បញ្ញបេតិ អតថំ វា បន សន្តំ តថត្តាយ ឧបកប្បេស្សាមីតិ ឥតិ វា បនស្ស ហោតិ ។ ឯវំ សន្តំ ខោ អានន្ទ អរូបឹ អនន្តត្តានុទិដ្ឋិ អនុសេតីតិ ឥច្ចាលំ វចនាយ ។ ឯត្តាវតា ខោ អានន្ទ អត្តានំ បញ្ញបេន្តោ បញ្ញបេតីតិ ។

[៦២] កិត្តាវតា ច[១] អានន្ទ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ ។ រូបឹ វា ហិ អានន្ទ បរិត្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ រូបី មេ បរិត្តោ អត្តាតិ ។ រូបឹ វា ហិ អានន្ទ

១ ម. ចសទ្ទោ នត្ថិ ។

គួរនឹងពោលនូវបុគ្គលដែលមិនមានរូបថា មានបរិត្តត្តានុទិដ្ឋិ ដេកនៅមិនដាច់ ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៤ ពួកនោះ បុគ្គលណា កាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូបនិងមិនមានទីបំផុត បុគ្គលនោះ កាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូបនិងមិនមានទីបំផុតក្នុងកាលឥឡូវនេះក្តី បុគ្គលនោះ កាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូបនិងមិនមានទីបំផុត ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេចឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមិនមានរូបថា មានអនន្តត្តានុទិដ្ឋិ ដេកនៅមិនដាច់ ។ ម្នាលអានន្ទ បុគ្គលកាលបញ្ញត្តខ្លួន តែងបញ្ញត្តដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

[៦២] ម្នាលអានន្ទ ចុះបុគ្គលកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តដោយហេតុមានប៉ុន្មានប្រការ ។ ម្នាលអានន្ទ បុគ្គល កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមានរូបនិងមានប្រមាណតិចថា ខ្លួនរបស់អញមានរូបនិងមានប្រមាណតិចក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គល

អនន្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ រូបី មេ អនន្តោ អត្តាតិ ។ អរូបឹ វា ហិ អានន្ទ បរិត្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ អរូបី មេ បរិត្តោ អត្តាតិ ។ អរូបឹ វា ហិ អានន្ទ អនន្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ អរូបី មេ អនន្តោ អត្តាតិ ។ តត្រានន្ទ យោ សោ រូបឹ បរិត្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញ-បេតិ ឯតរហិ វា សោ រូបឹ បរិត្តំ អត្តានំ ន បញ្ញ-បេន្តោ ន បញ្ញបេតិ តថាភាវឹ[១] វា សោ រូបឹ បរិត្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ អតថំ វា បន សន្តំ តថត្តាយ ឧបកប្បេស្សាមីតិ ឥតិ វា បនស្ស ន ហោតិ ។ ឯវំ សន្តំ ខោ អានន្ទ រូបឹ បរិត្តត្តានុទិដ្ឋិ នានុសេតីតិ ឥច្ចាលំ[២] វចនាយ ។ តត្រានន្ទ យោ សោ រូបឹ អនន្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ

១ ឱ. ម. តត្ថ ភាវឹ ។ ២ ឱ. ឥច្ចលំ ។

កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមានរូបនិងមិនមានទីបំផុតថា ខ្លួនរបស់អញ មានរូបនិងមិនមានទីបំផុតក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គលកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមិនមានរូបនិងមានប្រមាណតិចថា ខ្លួនរបស់អញ មិនមានរូបនិងមានប្រមាណតិចក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គលកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួនដែលមិនមានរូបនិងមិនមានទីបំផុតថា ខ្លួនរបស់អញមិនមានរូបនិងមិនមានទីបំផុតក៏មាន ។ ម្នាលអា-នន្ទ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមានរូបនិងមានប្រមាណតិច បុគ្គលនោះ កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមានរូបនិងមានប្រមាណតិច ក្នុងកាលឥឡូវនេះក្តី បុគ្គលនោះ កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមានរូបនិងមានប្រមាណតិច ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មិនមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមានរូបថា បរិត្តត្តានុទិដ្ឋិមិនដេកនៅរឿយ ៗ ទេ ។ ម្នាលអានន្ទ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួនដែលមានរូបនិងមិនមានទីបំផុត

ឯតរហិ វា សោ រូបឹ អនន្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ តថាភាវឹ វា សោ រូបឹ អនន្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ អតថំ វា បន សន្តំ តថត្តាយ ឧបកប្បេស្សាមីតិ ឥតិ វា បនស្ស ន ហោតិ ។ ឯវំ សន្តំ ខោ អានន្ទ រូបឹ អនន្តត្តានុទិដ្ឋិ ណានុសេតីតិ ឥច្ចាលំ វចណាយ ។ តត្រានន្ទ យោ សោ អរូបឹ បរិត្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ ឯតរហិ វា សោ អរូបឹ បរិត្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ តថាភាវឹ វា សោ អរូបឹ បរិត្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ អតថំ វា បន សន្តំ តថត្តាយ ឧបកប្បេស្សាមីតិ ឥតិ វា បនស្ស ន ហោតិ ។ ឯវំ សន្តំ ខោ អានន្ទ អរូបឹ បរិត្តត្តានុទិដ្ឋិ ណានុសេតីតិ ឥច្ចាលំ វចណាយ ។ តត្រានន្ទ យោ

បុគ្គលនោះ កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមានរូបនិងមិនមានទីបំផុតក្នុងកាលឥឡូវនេះក្តី ឬបុគ្គលនោះ កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួនដែលមានរូបនិងមិនមានទីបំផុត ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មិនមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិតអាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមានរូបថា អនន្តត្តានុទិដ្ឋិមិនដេកនៅរឿយ ៗ ទេ ។ ម្នាលអានន្ទ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួនដែលមិនមានរូបនិងមានប្រមាណតិច បុគ្គលនោះកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួនដែលមិនមានរូបនិងមានប្រមាណតិច ក្នុងកាលឥឡូវនេះក្តី ឬបុគ្គលនោះ កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមិនមានរូបនិងមានប្រមាណតិច ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មិនមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះ មានហើយ គួរនឹងពោលនូវបុគ្គលដែលមិនមានរូបថា បរិត្តត្តានុទិដ្ឋិមិនដេកនៅរឿយ ៗ ទេ ។ ម្នាលអានន្ទ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា

សោ អរូបី អនន្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ ឯតរហិ វា សោ អរូបី អនន្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ តថាភាវឹ វា សោ អរូបី អនន្តំ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតិ អតថំ វា បន សន្តំ តថត្តាយ ឧបកប្បេស្សាមីតិ ឥតិ វា បនស្ស ន ហោ-តិ ។ ឯវំ សន្តំ ខោ អានន្ទ អរូបី អនន្តត្តានុទិដ្ឋិ នានុសេតីតិ ឥច្ចាលំ វចនាយ ។ ឯត្តាវតា ខោ អានន្ទ អត្តានំ ន បញ្ញបេន្តោ ន បញ្ញបេតីតិ ។

[៦៣] កិត្តាវតា ច អានន្ទ អត្តានំ សម-នុបស្សមានោ សមនុបស្សតិ ។ វេទនំ វា ហិ អានន្ទ អត្តានំ សមនុបស្សមានោ សមនុបស្សតិ វេទនា មេ អត្តាតិ ន ហេវ ខោ មេ វេទនា អត្តា អប្បដិសំវេទនោ មេ អត្តាតិ(១) ។ ន ហេវ ខោ មេ វេទនា អត្តា នោបិ អប្បដិសំវេទនោ មេ អត្តា អត្តា មេ វេទយតិ វេទនាធម្មោ ហិ មេ អត្តាតិ ឥតិ វា ហិ អានន្ទ អត្តានំ សមនុបស្សមានោ សមនុបស្សតិ ។ តត្រានន្ទ

១ ឱ. ម. ឥតោ បរំ ឥតិ វា ហិ អានន្ទ អត្តានំ សមនុបស្សមានា សមនុបស្សតីតិ ឥមេ បាឋា ភវន្តិ ។

ការមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមិនមានរូបនិងមិនមានទីបំផុត បុគ្គលនោះ កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញតខ្លួនដែលមិនមានរូបនិងមិនមានទីបំផុត ក្នុងកាលឥឡូវនេះក្តី ឬបុគ្គលនោះ កាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តខ្លួន ដែលមិនមានរូបនិងមិនមានទីបំផុត ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មិនមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គល ដែលមិនមានរូបថា អនន្តត្តានុទិដ្ឋិមិនដេកនៅរឿយ ៗ ទេ ។ ម្នាលអានន្ទ បុគ្គលកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

[៦៣] ម្នាលអានន្ទ បុគ្គលកាលពិចារណានូវខ្លួន តែងពិចារណាដោយហេតុមានប៉ុន្មានប្រការ ។ ម្នាលអានន្ទ បុគ្គលកាលពិចារណានូវខ្លួន តែងពិចារណាខ្លួនដែលមានវេទនាថា វេទនាជាខ្លួនរបស់អញក៏មាន ថា វេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថា ខ្លួនរបស់អញ មិនបានទទួលអារម្មណ៍ក៏មាន ។ ថាវេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថា ខ្លួនរបស់អញមិនបានទទួលអារម្មណ៍ ខ្លួនរបស់អញតែងទទួលវេទនា វេទនាធម៌ជាខ្លួនរបស់អញពិតក៏មាន ម្នាលអានន្ទ បុគ្គលកាលពិចារណានូវខ្លួន តែងពិចារណាដោយប្រការដូច្នេះឯង ។ ម្នាលអានន្ទ បណ្តាបុគ្គល

យោ សោ ឯវមាហ វេទនា មេ អត្តាតិ សោ ឯវមស្ស វចនីយោ តិស្សោ ខោ ឥមា អាវុសោ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមាសំ ខោ ត្វំ តិស្សន្នំ វេទនានំ កតមំ អត្តតោ សមនុបស្សសីតិ ។ យស្មឹ អានន្ទ សមយេ សុខំ វេទនំ វេទេតិ នេវ តស្មឹ សមយេ ទុក្ខំ វេទនំ វេទេតិ ន អទុក្ខមសុខំ វេទនំ វេទេតិ សុខំយេវ[១] តស្មឹ សមយេ វេទនំ វេទេតិ ។ យស្មឹ អានន្ទ សមយេ ទុក្ខំ វេទនំ វេទេតិ នេវ តស្មឹ សមយេ សុខំ វេទនំ វេទេតិ ន អទុក្ខមសុខំ វេទនំ វេទេតិ ទុក្ខំយេវ តស្មឹ សមយេ វេទនំ វេទេ-តិ ។ យស្មឹ អានន្ទ សមយេ អទុក្ខមសុខំ វេទនំ វេទេតិ នេវ តស្មឹ សមយេ សុខំ វេទនំ វេទេតិ ន ទុក្ខំ វេទនំ វេទេតិ អទុក្ខមសុខំយេវ តស្មឹ សមយេ វេទនំ វេទេតិ ។ សុខាបិ ខោ អានន្ទ វេទនា អនិច្ចា

---

១ ម. សុខញ្ញេវ ។

ដែលលុះក្នុងទិដ្ឋិទាំង ៣ ពួកនោះ បុគ្គលណាពោលយ៉ាងនេះថា វេទនាជាខ្លួនរបស់បុគ្គលនោះ អ្នកគប្បីពោលតបយ៉ាងនេះថា ម្នាលអាវុសោ វេទនានេះមាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ បណ្តាវេទនាទាំង ៣ នេះ អ្នកពិចារណាឃើញច្បាស់នូវវេទនាណាថា ជាខ្លួន ។ ម្នាលអានន្ទ សម័យណា បុគ្គលទទួលសុខវេទនា សម័យនោះ មិនទទួលទុក្ខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ សម័យនោះ រមែងទទួលតែសុខវេទនាមួយយ៉ាង ។ ម្នាលអានន្ទ សម័យណា បុគ្គលទទួលទុក្ខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ សម័យនោះ រមែងទទួលតែទុក្ខវេទនាមួយយ៉ាង ។ ម្នាលអានន្ទ សម័យណា បុគ្គលទទួលអទុក្ខមសុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះ រមែងទទួលតែអទុក្ខមសុខវេទនា មួយយ៉ាង ។ ម្នាលអានន្ទ សុខវេទនាក្តី ជាធម្មជាតិមិនទៀង ជាធម្មជាតិ

១៤៣



សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា ។ ទុក្ខាបិ ខោ អានន្ទ វេទនា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា ។ អទុក្ខមសុខាបិ ខោ អានន្ទ វេទនា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា ។ តស្ស សុខំ វេទនំ វេទយមានស្ស ឯសោ មេ អត្តាតិ ហោតិ តស្សាយេវ សុខាយ វេទនាយ និរោធា ព្យគា[១] មេ អត្តាតិ ហោតិ ។ ទុក្ខំ វេទនំ វេទយមានស្ស ឯសោ មេ អត្តាតិ ហោតិ តស្សាយេវ ទុក្ខាយ វេទនាយ និរោធា ព្យគា មេ អត្តាតិ ហោតិ ។ អទុក្ខមសុខំ វេទនំ វេទយមានស្ស ឯសោ មេ អត្តាតិ ហោតិ តស្សាយេវ អទុក្ខមសុខាយ វេទនាយ និរោធា ព្យគា មេ អត្តាតិ ហោតិ ។

១ ឱ. វ្យគា ។ ម. ព្យគ្គា ។

ដែលបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យ (នឹងបច្ច័យនោះ ៗ) មានកិរិយាអស់ទៅ វិនាសទៅ សាបរលាបទៅ រលត់ទៅជាធម្មតា ។ ម្នាលអានន្ទ ទុក្ខវេទនាក្តី ជាធម្មជាតិមិនទៀង ជាធម្មជាតិដែលបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យ (នឹងបច្ច័យនោះ ៗ) មានកិរិយាអស់ទៅ វិនាសទៅ សាបរលាបទៅ រលត់ទៅជាធម្មតា ។ ម្នាលអានន្ទ អទុក្ខមសុខវេទនាក្តី ជាធម្មជាតិមិនទៀង ជាធម្មជាតិដែលបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យ (នឹងបច្ច័យនោះ ៗ) មានកិរិយាអស់ទៅ វិនាសទៅ សាបរលាបទៅ រលត់ទៅជាធម្មតា ។ កាលបុគ្គលនោះ ទទួលសុខវេទនា រមែងដឹងច្បាស់ថា នេះខ្លួនរបស់អញ កាលបើសុខវេទនានោះ រលត់ទៅហើយក៏ដឹងច្បាស់ថា ខ្លួនរបស់អញរលត់ទៅហើយ ។ កាលបុគ្គលនោះទទួលទុក្ខវេទនា រមែងដឹងច្បាស់ថា នេះខ្លួនរបស់អញ កាលបើទុក្ខវេទនានោះរលត់ទៅហើយ ក៏ដឹងច្បាស់ថា ខ្លួនរបស់អញរលត់ទៅហើយ ។ កាលបុគ្គលនោះ ទទួលអទុក្ខមសុខ-វេទនា រមែងដឹងច្បាស់ថា នេះខ្លួនរបស់អញ កាលបើអទុក្ខមសុខវេទនានោះរលត់ទៅហើយ ក៏ដឹងច្បាស់ថា ខ្លួនរបស់អញរលត់ទៅហើយ ។

ឥតិ សោ ទិដ្ឋេ វ ធម្មេ អនិច្ចំ សុខទុក្ខវោកិណ្ណំ ឧប្បាទវយធម្មំ អត្តានំ សមនុបស្សមានោ សមនុបស្សតិ យោ សោ ឯវមាហ វេទនា មេ អត្តាតិ ។ តស្មាតិហានន្ទ ឯតេនបេតំ នក្ខមតិ វេទនា មេ អត្តាតិ សមនុបស្សិតុំ ។ តត្រានន្ទ យោ សោ ឯវមាហ ន ហេវ ខោ មេ វេទនា អត្តា អប្បដិសំវេទនោ មេ អត្តាតិ សោ ឯវមស្ស វចនីយោ យត្ថ បនាវុសោ សព្វសោ វេទយិតំ អត្ថិ អបិ នុ ខោ តត្ថ អស្មីតិ សិយាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯតេនបេតំ នក្ខមតិ ន ហេវ ខោ មេ វេទនា អត្តា អប្បដិសំវេទនោ មេ អត្តាតិ សមនុបស្សិតុំ ។ តត្រានន្ទ

បុគ្គលណា ពោលយ៉ាងនេះថា វេទនាជាខ្លួនរបស់អញ បុគ្គលនោះ កាលពិចារណានូវខ្លួន តែងពិចារណាខ្លួនដែលមិនទៀង លាយច្រឡំដោយសុខនិងទុក្ខ មានកិរិយាកើតឡើងនិងវិនាសទៅជាធម្មតា ក្នុងបច្ចុប្បន្ន ដូចសេចក្តីដែលបានសម្តែងមកនេះឯង ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះ បុគ្គលក្នុងលោកនេះ មិនគួរនឹងពិចារណានូវខ្លួននេះថា វេទ-នាជាខ្លួនរបស់អញ ដោយឧបាយនេះឡើយ ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៣ ពួកនោះ បុគ្គលណា ពោលយ៉ាងនេះថា វេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថាខ្លួនរបស់អញ មិនបានទទួលអារម្មណ៍ បុគ្គលនោះ អ្នកគប្បីពោលតបយ៉ាងនេះថា ម្នាលអាវុ-សោ ការទទួលអារម្មណ៍ ដោយប្រការទាំងពួង រមែងមានក្នុងសុទ្ធរូប-ក្ខន្ធ[១]ណា សេចក្តីដឹងខ្លួនថា អាត្មាអញមាន គប្បីមានក្នុងសុទ្ធរូបក្ខន្ធនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះ បុគ្គលក្នុងលោកនេះ មិនគួរនឹងពិចារណានូវខ្លួននេះថា វេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថា ខ្លួនរបស់អញមិនទទួលអារម្មណ៍ដោយឧបាយនេះឡើយ ។ ម្នាលអានន្ទ បណ្តាបុគ្គល

១ បានដល់រូបក្ខន្ធដែលប្រាសចាកវេទនា មានផាងត្នោតនិងបង្អួចជាដើម ។

យោ សោ ឯវមាហ ន ហេវ ខោ មេ វេទនា អត្តា នោបិ អប្បដិសំវេទនោ[១] អត្តា អត្តា មេ វេទយតិ[២] វេទនាធម្មោ ហិ មេ អត្តាតិ ។ សោ ឯវមស្ស វចនីយោ វេទនា ច[៣] ហិ អាវុសោ សព្វេន សព្វំ សព្វថា សព្វំ អបរិសេសា និរុជ្ឈេយ្យុំ សព្វសោ វេទនាយ អសតិ វេទនានិរោធា អបិ នុ ខោ តត្ថ អហមស្មីតិ សិយាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឯតេនបេតំ នក្ខមតិ ន ហេវ ខោ មេ វេទនា អត្តា នោបិ អប្បដិសំវេទនោ អត្តា អត្តា មេ វេទយតិ វេទនាធម្មោ ហិ មេ អត្តាតិ សមនុបស្សិតុំ ។

[៦៤] យតោ ខោ អានន្ទ ភិក្ខុ នេវ វេទនំ អត្តានំ សមនុបស្សតិ នោបិ អប្បដិសំវេទនំ អត្តានំ សមនុបស្សតិ នោបិ អត្តា[៤] វេទយតិ វេទនាធម្មោ ហិ មេ អត្តាតិ សមនុបស្សតិ ។ សោ ឯវំ សមនុបស្សន្តោ ន កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយញ្ច[៥] ន បរិតស្សតិ

---

១ ឱ. ម. ឯត្តន្តរេ មេតិ បទំ ទិស្សតិ ។ ២ ឱ. ម. វេទិយតិ ។ ៣ ឱ. វ ។ ៤ ឱ. ម. អត្តា មេ ។ ៥ ឱ. អនុបាទិយំ ។

ដែលលុះក្នុងទិដ្ឋិទាំង ៣ ពួកនោះ បុគ្គលណាពោលយ៉ាងនេះថា វេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថា ខ្លួនរបស់អញ មិនបានទទួលអារម្មណ៍ទេ ខ្លួនរបស់អញ រមែងទទួលវេទនា ឯវេទនាធម៌ជាខ្លួនរបស់អញ ។ បុគ្គលនោះ អ្នកគប្បីពោលយ៉ាងនេះថា ម្នាលអាវុសោ វេទនាទាំងឡាយគប្បីរលត់មិនសេសសល់ ដោយអាការៈទាំងពួង ដោយសភាវៈទាំងពួង កាលបើវេទនាមិនមាន ដោយប្រការទាំងពួង ព្រោះវេទនារលត់ហើយ សេចក្តីដឹងខ្លួនថា អាត្មាអញមានដូច្នេះ គប្បីមានក្នុងរូបក្ខន្ធនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះ បុគ្គលក្នុងលោកនេះ មិនគួរនឹងពិចារណានូវខ្លួននេះថា វេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថា ខ្លួនរបស់អញ មិនបានទទួលអារម្មណ៍ទេ ខ្លួនរបស់អញ រមែងទទួលវេទនា ឯវេទនាធម៌ ជាខ្លួនរបស់អញពិត ដោយឧបាយនេះឡើយ ។

[៦៤] ម្នាលអានន្ទ កាលបើភិក្ខុ មិនបានពិចារណានូវវេទនាថាជាខ្លួន ក៏មិនបានពិចារណានូវខ្លួនថា មិនបានទទួលអារម្មណ៍ ក៏មិនបានពិចារណាថា ខ្លួនទទួលវេទនា វេទនាធម៌ជាខ្លួនរបស់អញដូច្នេះឡើយ ។ ភិក្ខុនោះ កាលពិចារណាយ៉ាងនេះ រមែងមិនប្រកាន់នូវធម្មជាតនីមួយ ក្នុងលោក (មានខន្ធលោកជាដើម) កាលបើមិនប្រកាន់ហើយ ក៏រមែងមិនតក់ស្លុត

១៤៦



អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជា- នាតិ ។ ឯវំ វិមុត្តំ[១] ខោ អានន្ទ ភិក្ខុំ យោ ឯវំ វទេយ្យ ហោតិ តថាគតោ បរម្មរណា ឥតិសា ទិដ្ឋីតិ[២] តទកល្លំ ។ ន ហោតិ តថាគតោ បរម្មរណា ឥតិសា ទិដ្ឋីតិ[៣] តទកល្លំ ។ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ឥតិសា ទិដ្ឋីតិ[៤] តទកល្លំ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥតិ- សា ទិដ្ឋីតិ[៥] តទកល្លំ ។ តំ កិស្ស ហេតុ ។ យាវតានន្ទ អធិវចនំ យាវតា អធិវចនបថោ យាវតា និរុត្តិ យាវតា និរុត្តិបថោ យាវតា បញ្ញត្តិ យាវតា បញ្ញត្តិបថោ យាវតា បញ្ញាបនំ[៦] យាវតា បញ្ញាវចរំ យាវតា វដ្ដំ វត្តតិ[៧]

---

១ ឱ. វិមុត្តំ ចិត្តំ ។ ២-៣-៤-៥ បរម្មរណាតិ ឥតិស្ស ទិដ្ឋីតិបិ បាឋោ ។ ៦ ឱ. ម. បញ្ញា ។ ៧ ឱ. ម. វត្តតីតិ ន ទិស្សតិ ។

កាលបើមិនតក់ស្លុតហើយ រមែងបរិនិព្វានចំពោះខ្លួនឯង តែងដឹងច្បាស់ថា កំណើតរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលអានន្ទ ភិក្ខុដែលរួចស្រឡះ (ចាកអាសវៈ) យ៉ាងនេះហើយ បើបុគ្គលណា និយាយយ៉ាងនេះថា ទិដ្ឋិរបស់ភិក្ខុនោះថា សត្វខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងកើតទៀត ពាក្យនោះរបស់បុគ្គលនោះ មិនគួរទេ ។ ថាទិដ្ឋិរបស់ភិក្ខុនោះថា សត្វខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងមិនកើតទៀត ពាក្យនោះរបស់បុគ្គលនោះ មិនគួរទេ ។ ថាទិដ្ឋិរបស់ភិក្ខុនោះថា សត្វខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងកើតទៀតក៏មាន មិនកើតទៀតក៏មាន ពាក្យនោះរបស់បុគ្គលនោះ ក៏មិនគួរ ។ ថាទិដ្ឋិរបស់ភិក្ខុនោះថា សត្វខាងមុខអំពីសេចក្ដីស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនោះរបស់បុគ្គលនោះ ក៏មិនគួរ ។ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ។ ម្នាលអានន្ទ ឈ្មោះនិងគន្លងនៃឈ្មោះក្ដី ភាសានិងគន្លងនៃភាសាក្ដី បញ្ញត្តិនិងគន្លងនៃបញ្ញត្តិក្ដី បញ្ញានិងខន្ធបញ្ចកៈ ដែលគួរដឹងដោយបញ្ញាក្ដី វដ្ដៈក្ដី តែងប្រព្រឹត្តទៅ ដោយកំណត់ត្រឹមណា ៗ

តាវតា[១] វដ្ដំ វត្តតិ តទភិញ្ញា វិមុត្តោ ភិក្ខុ តទភិញ្ញា វិមុត្តំ ភិក្ខុំ[២] ន ជានាតិ ន បស្សតិ ឥតិសា ទិដ្ឋីតិ តទកល្លំ ។

[៦៤] សត្ត ខោ ឥមា អានន្ទ វិញ្ញាណដ្ឋិតិយោ ទ្វេ[៣] អាយតនានិ ។ កតមា សត្ត ។ សន្តានន្ទ សត្តា នានត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមា វិញ្ញាណដ្ឋិតិ ។ សន្តានន្ទ សត្តា នានត្ត-កាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា ព្រហ្មកា-យិកា បឋមាភិនិព្វត្តា ចតុអបាយិកា សត្តា ច[៤] អយំ ទុតិយា វិញ្ញាណដ្ឋិតិ ។ សន្តានន្ទ សត្តា ឯកត្ត-កាយា នានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា

១ ឱ. យាវតា ។ ២ ឱ. វិមុត្តោ ភិក្ខុ ។ ៣ ឱ. ទ្វេ ច ។ ៤ ឱ. ម. ចតុអបាយិកា សត្តា ចាតិ បាឋោ ន ទិស្សន្តិ ។

វដ្តៈក៏ប្រព្រឹត្តទៅ ដោយកំណត់ត្រឹមណោះ ។ ដែរ ភិក្ខុរួចស្រឡះហើយ ព្រោះដឹងនូវសភាវៈ មានឈ្មោះជាដើមនោះ បើបុគ្គលណា ពោលនូវភិក្ខុ ដែលរួចស្រឡះហើយ ព្រោះដឹងនូវសភាវៈ មានឈ្មោះជាដើមនោះថា ភិក្ខុនោះ មិនដឹង មិនឃើញ ទិដ្ឋិរបស់ភិក្ខុនោះដូច្នេះ ពាក្យនោះរបស់ បុគ្គលនោះ មិនគួរទេ ។

[៦៥] ម្នាលអានន្ទ វិញ្ញាណដ្ឋិតិ (ទីតម្កល់នៃវិញ្ញាណ) នេះមាន ៧ អាយតនៈមាន ២ ។ វិញ្ញាណដ្ឋិតិទាំង ៧ នោះ តើដូចម្តេច ។ ម្នាលអានន្ទ ពួកសត្វដែលមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្ស ទេវតាពួកខ្លះ និងសត្វវិនិបាតិកៈ[១]ពួកខ្លះ នេះជាវិញ្ញាណដ្ឋិតិទី ១ ។ ម្នាលអានន្ទ ពួកសត្វដែលមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម ដែលកើតដោយបឋមជ្ឈាន និងពួកសត្វដែលកើតក្នុងអបាយភូមិទាំង ៤ នេះជាវិញ្ញាណដ្ឋិតិទី ២ ។ ម្នាលអានន្ទ ពួកសត្វដែលមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាដែលនៅក្នុងអាភស្សរភព

---

១ បានដល់វេមានិកប្រេត ក្រៅអំពីអបាយទាំង ៤ ។

អយំ តតិយា វិញ្ញាណដ្ឋិតិ ។ សន្តានន្ទ សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា សុភកិណ្ហា[១] អយំ ចតុត្ថា វិញ្ញាណដ្ឋិតិ ។ សន្តានន្ទ សត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនុបគា អយំ បញ្ចមា វិញ្ញាណដ្ឋិតិ ។ សន្តានន្ទ សត្តា សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនុបគា អយំ ឆដ្ឋា វិញ្ញាណដ្ឋិតិ ។ សន្តានន្ទ សត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនុបគា អយំ សត្តមា វិញ្ញាណដ្ឋិតិ ។ អសញ្ញិសត្តាយតនំ[២] នេវសញ្ញានាសញ្ញាយតនមេវ ទុតិយំ ។

១ ឱ. សុភកិណ្ណា ។ ២ អសញ្ញសត្តាយតនន្តិបិ បាឋោ ។

នេះជាវិញ្ញាណដ្ឋិតិទី ៣ ។ ម្នាលអានន្ទ ពួកសត្វដែលមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតា ដែលនៅក្នុងសុភកិណ្ហកព នេះជាវិញ្ញាណដ្ឋិតិទី ៤ ។ ម្នាលអានន្ទ ពួកសត្វដែលកន្លងនូវរូបសញ្ញា[១] ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា[២] នឹងមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា[៣] ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកាសានញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិញ្ញាណដ្ឋិតិទី ៥ ។ ម្នាលអានន្ទ ពួកសត្វដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិញ្ញាណដ្ឋិតិទី ៦ ។ ម្នាលអានន្ទ ពួកសត្វដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិញ្ញាណដ្ឋិតិទី ៧ ។ ឯអាយតនៈទាំងពីរ គឺអសញ្ញិសត្តាយតនៈ (ជាទី ១) នេវសញ្ញានាសញ្ញាយតនៈជាទី ២ ។

---

១ សេចក្តីសម្គាល់ក្នុងរូបាវចរជ្ឈាននិងអារម្មណ៍របស់ឈាននោះ ។ ២ សេចក្តីសម្គាល់ដែលកើតឡើងដោយវត្ថុមានចក្ខុជាដើម ប៉ះពាល់គ្នានឹងអារម្មណ៍មានរូបជាដើម ។ ៣ សញ្ញាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងគ្នា ឬសញ្ញាដែលផ្សេងគ្នា (វិសុទ្ធិមគ្គ) ។

មហានិទានសុត្តេ ពុទ្ធភាណវារំ សត្តវិញ្ញាណដ្ឋិតិកថា

តត្រានន្ទ យាយំ បឋមា វិញ្ញាណដ្ឋិតិ នានត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា យោ នុ ខោ អានន្ទ តញ្ច បជានាតិ តស្សា ច សមុទយំ បជានាតិ តស្សា ច អត្ថង្គមំ បជានាតិ តស្សា ច អស្សាទំ បជានាតិ តស្សា ច អាទីនវំ បជានាតិ តស្សា ច និស្សរណំ បជានាតិ កល្លំ នុ តេន តទភិនន្ទិតុន្តិ ។ នោ ហេតំ ភន្តេ ។ បេ ។ តត្រានន្ទ យាយំ សត្តមា វិញ្ញាណដ្ឋិតិ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគា យោ នុ ខោ អានន្ទ តញ្ច បជានាតិ តស្សា ច សមុទយំ បជានាតិ តស្សា ច អត្ថង្គមំ បជានាតិ តស្សា ច អស្សាទំ បជានាតិ តស្សា ច អាទីនវំ បជានាតិ តស្សា ច និស្សរណំ បជានាតិ កល្លំ នុ តេន តទភិនន្ទិតុន្តិ ។

មហានិទានសូត្រ ពុទ្ធភាណវារៈ ពោលអំពីវិញ្ញាណដ្ឋិតិទាំង ៧

ម្នាលអានន្ទ បណ្ដាវិញ្ញាណដ្ឋិតិទាំង ៧ នោះ វិញ្ញាណដ្ឋិតិទី ១ ណា ដែលថា ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សទេវតាពួកខ្លះ និងសត្វវិនិបាតិកៈពួកខ្លះ ម្នាលអានន្ទ ភិក្ខុណា ដឹងច្បាស់នូវវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវហេតុ ជាទីកើតនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវសេចក្ដីរលត់នៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវអានិសង្សនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវទោសនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវកិរិយារលាស់ចោលនូវវិញ្ញាណដ្ឋិតិនោះផង ភិក្ខុនោះ គួរត្រេកអរនឹងវិញ្ញាណដ្ឋិតិនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនគួរទេ ។ បេ ។ ម្នាលអានន្ទ បណ្ដាវិញ្ញាណដ្ឋិតិទាំង ៧ នោះ វិញ្ញាណដ្ឋិតិទី ៧ ណា ដែលថា ពួកសត្វកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួច ក៏មិនមានដូច្នេះ ម្នាលអានន្ទ ភិក្ខុណា ដឹងច្បាស់នូវវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវហេតុជាទីកើតនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវសេចក្ដីរលត់ នៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវអានិសង្ស នៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវទោស នៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវកិរិយារលាស់ចោលនូវវិញ្ញាណដ្ឋិតិនោះផង ភិក្ខុនោះគួរត្រេកអរនឹងវិញ្ញាណដ្ឋិតិនោះដែរឬ ។

ជោ ហោតំ ភន្តេ ។ តត្រានន្ទ យមិទំ អសញ្ញិសត្តាយតនំ យោ នុ ខោ អានន្ទ តញ្ច បជានាតិ តស្សា ច សមុទយំ បជានាតិ តស្សា ច អត្ថង្គមំ បជានាតិ តស្សា ច អស្សាទំ បជានាតិ តស្សា ច អាទីនវំ បជានាតិ តស្សា ច និស្សរណំ បជានាតិ កាល្លំ នុ តេន តទភិនន្ទិតុន្តិ ។ នោ ហេតំ ភន្តេ ។ តត្រានន្ទ យមិទំ នេវសញ្ញានាសញ្ញាយតនំ យោ នុ ខោ អានន្ទ តញ្ច បជានាតិ តស្សា ច សមុទយំ បជានាតិ តស្សា ច អត្ថង្គមំ បជានាតិ តស្សា ច អស្សាទំ បជានាតិ តស្សា ច អាទីនវំ បជានាតិ តស្សា ច និស្សរណំ បជានាតិ កាល្លំ នុ តេន តទភិនន្ទិតុន្តិ ។ នោ ហេតំ ភន្តេ ។

បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនគួរទេ ។ ម្នាលអានន្ទ បណ្តាអាយតនៈទាំង ២ នោះ អសញ្ញិសត្តាយតនៈណា ម្នាលអានន្ទ ភិក្ខុណា ដឹងច្បាស់នូវអាយតនៈនោះផង ដឹងច្បាស់នូវហេតុជាទីកើត នៃអាយតនៈនោះផង ដឹងច្បាស់នូវសេចក្តីរលត់នៃអាយតនៈនោះផង ដឹងច្បាស់នូវអានិសង្សនៃអាយតនៈនោះផង ដឹងច្បាស់នូវទោសនៃអាយតនៈនោះផង ដឹងច្បាស់នូវកិរិយារលាស់ចោលនូវអាយតនៈនោះផង ភិក្ខុនោះគួរត្រេកអរនឹងអាយតនៈនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនគួរទេ ។ ម្នាលអានន្ទ បណ្តាអាយតនៈទាំង ២ នោះ នេវ-សញ្ញានាសញ្ញាយតនៈណា ម្នាលអានន្ទ ភិក្ខុណា ដឹងច្បាស់នូវអាយ-តនៈនោះផង ដឹងច្បាស់នូវហេតុជាទីកើត នៃអាយតនៈនោះផង ដឹងច្បាស់នូវសេចក្តីរលត់ នៃអាយតនៈនោះផង ដឹងច្បាស់នូវអានិសង្ស នៃអាយតនៈនោះផង ដឹងច្បាស់នូវទោសនៃអាយតនៈនោះផង ដឹងច្បាស់នូវកិរិយារលាស់ចោល នូវអាយតនៈនោះផង ភិក្ខុនោះ គួរត្រេកអរនឹងអាយតនៈនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនគួរទេ ។

យតោ ខោ អានន្ទ ភិក្ខុ ឥមាសញ្ច សត្តន្នំ វិញ្ញាណដ្ឋិតីនំ ឥមេសញ្ច ទ្វិន្នំ អាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទា វិមុត្តោ ហោតិ អយំ វុច្ចតានន្ទ[១] ភិក្ខុ បញ្ញាវិមុត្តោ ។

[៦៦] អដ្ឋ ខោ ឥមេ អានន្ទ វិមោក្ខា ។ កតមេ អដ្ឋ ។ រូបី រូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ ។ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អយំ ទុតិយោ វិមោក្ខោ ។ សុភន្តេវ អធិមុត្តោ ហោតិ អយំ តតិយោ វិមោក្ខោ ។ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ

១ ឱ. វុច្ចតិ អានន្ទ ។

*ម្នាលអានន្ទ កាលណាបើភិក្ខុដឹងច្បាស់នូវហេតុជាទីកើតផង នូវសេចក្តីរលត់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នូវវិញ្ញាណដ្ឋិតិទាំង ៧ និងអាយតនៈទាំង ២ នេះ តាមសេចក្តីពិតមែន ឈ្មោះថា រួចស្រឡះព្រោះមិនប្រកាន់ ម្នាលអានន្ទ ភិក្ខុនេះឯង តថាគតហៅថា បញ្ញាវិមុត្តបុគ្គល ។*

*[៦៦] ម្នាលអានន្ទ វិមោក្ខនេះមាន ៨ យ៉ាង ។ វិមោក្ខទាំង ៨ នោះ តើដូចម្តេច ។ គឺបុគ្គលមានរូបជ្ឈាន[១] តែងឃើញរូប គឺកសិណទាំងឡាយមាននីលកសិណជាដើម នេះជាវិមោក្ខទី ១ ។ បុគ្គលមិនមានសេចក្តីសម្គាល់ក្នុងរូបខាងក្នុងមានសក់ជាដើមរបស់ខ្លួន[២] តែងឃើញរូបខាងក្រៅ គឺកសិណមាននីលកសិណជាដើម នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់កាន់ឈានក្នុងវណ្ណកសិណដែលបរិសុទ្ធ[៣] នេះជាវិមោក្ខទី ៣ ។ បុគ្គលដែលកន្លងនូវរូបសញ្ញា ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា ទាំងមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយចូលទៅ*

---

១ បុគ្គលនោះ បានរូបាវចរជ្ឈានទាំង ៤ ព្រោះអាស្រ័យកសិណជាវត្ថុខាងក្នុងមានសក់ជាដើមរបស់ខ្លួន ។ ២ បុគ្គលដែលបានរូបាវចរជ្ឈានមិនអាស្រ័យនឹងអាការៈមានសក់ជាដើមរបស់ខ្លួន ។ ៣ បុគ្គលដែលបានឈានព្រោះអាស្រ័យវណ្ណកសិណមាននីលកសិណជាដើមដែលបរិសុទ្ធថ្លៃថ្លាជាងបុគ្គលទី ១ ទី ២ ។

អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ ។ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ ។ សព្វសោ អាកិញ្ចញ្ចាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ ។ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតំ និរោធំ[១] ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមោ វិមោក្ខោ ។ ឥមេ ខោ អានន្ទ អដ្ឋ វិមោក្ខា ។ យតោ ខោ អានន្ទ ភិក្ខុ ឥមេ អដ្ឋ វិមោក្ខេ អនុលោមំបិ សមាបជ្ជតិ បដិលោមំបិ សមាបជ្ជតិ អនុលោមប្បដិលោមំបិ សមាបជ្ជតិ យត្ថិច្ឆកំ យទិច្ឆកំ យាវតិច្ឆកំ[២] សមាបជ្ជតិបិ វុដ្ឋាតិបិ អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា

១ ឱ. ម. សញ្ញាវេទយិតនិរោធំ ។ ២ ឱ. យាវទិច្ឆកំ ។

កាន់អាកាសានញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ បុគ្គលដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ បុគ្គលដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ បុគ្គលដែលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។ បុគ្គលដែលកន្លង នូវនេវសញ្ញានាសញ្ញាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលទៅកាន់សញ្ញាវេទយិតនិរោធ (សេចក្ដីរលត់នៃសញ្ញានិងវេទនា) នេះជាវិមោក្ខទី ៨ ។ ម្នាលអានន្ទ វិមោក្ខមាន ៨ ប្រការនេះឯង ។ ម្នាលអានន្ទ កាលណាបើភិក្ខុចូលកាន់វិមោក្ខទាំង ៨ នេះ ជាអនុលោមខ្លះ បដិលោមខ្លះ ទាំងអនុលោម បដិលោមខ្លះ ចូលបាន ចេញបាន តាមសេចក្ដីប្រាថ្នា ក្នុងឱកាសណា តាមសេចក្ដីប្រាថ្នានូវសមាបត្តិណា តាមសេចក្ដីប្រាថ្នានូវកំណត់ប៉ុន្មាន ក៏រមែងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ចំពោះចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមាន

១៨៣



ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតានន្ទ ភិក្ខុ ឧភតោភាគវិមុត្តោ ។ ឥមាយ ច អានន្ទ ឧភតោភាគវិមុត្តិយា អញ្ញា ឧភតោភាគវិមុត្តិ ឧត្តរិតរា វា បណីតតរា នត្ថីតិ ។ ឥទមវោច ភគវា ។ អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មហានិទានសុត្តំ ទុតិយំ និដ្ឋិតំ ។

អាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលអានន្ទ ភិក្ខុនេះ តថាគតហៅថា ឧភតោ-ភាគវិមុត្តបុគ្គល គឺបុគ្គលដែលរួចដោយចំណែកពីរ[១] ។ ម្នាលអានន្ទ ឧភតោភាគវិមុត្តិដទៃ ដែលលើសលុបជាង ឬថ្លៃថ្លាជាងឧភតោភាគវិមុត្តិនេះ មិនមានឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ ។ ព្រះអានន្ទមានអាយុ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគជាម្ចាស់ ។

ចប់ មហានិទានសូត្រទី ២ ។

---

១ បុគ្គលនោះ រួចចាករូបកាយដោយអរូបសមាបត្តិផង រួចចាកនាមកាយដោយមគ្គផង ។

# មហាបរិនិព្វានសុត្តំ តតិយំ

[៦៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ(១) វជ្ជី(២) អភិយាតុកាមោ ហោតិ ។ សោ ឯវមាហ អហំ ហិមេ វជ្ជី ឯវំមហិទ្ធិកេ ឯវំមហានុភាវេ ឧច្ឆេជ្ជាមិ វជ្ជី វិនាសេស្សាមិ វជ្ជី(៣) អនយព្យសនំ អាបាទេស្សាមិ វជ្ជិន្តិ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ វស្សការំ ព្រាហ្មណំ មគធមហាមត្តំ អាមន្តេសិ ឯហិ ត្វំ ព្រាហ្មណ យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ រាជា ភន្តេ មាគធោ អជាតសត្តុ

១ វេទេហិបុត្តោតិបិ ។ ២ ឱ. ម. វជ្ជី ។ ៣ ឯត្ថន្តរេ អភិយាតុកាមោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

# មហាបរិនិព្វានសូត្រទី ៣

[៦៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ[១] ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះរាជាជាធំក្នុងដែនមគធៈ ព្រះនាមអជាតសត្តុវេទេហីបុត្រ[២] មានព្រះបំណងនឹងយាត្រាទៅញាំញីដែនវជ្ជី ។ ព្រះអង្គមានព្រះបន្ទូលយ៉ាងនេះថា អញនឹងផ្តិលផ្តាច់អ្នកដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ អញ (មានបំណងនឹងយាត្រាទៅជិះជាន់)ដែនវជ្ជី នឹងបំផ្លាញដែនវជ្ជី នឹងធ្វើដែនវជ្ជីឲ្យដល់នូវសេចក្តីវិនាស ។ គ្រានោះ ព្រះបាទអជាតសត្តុវេទេហីបុត្តមាគធរាជ ត្រាស់ហៅវស្សការព្រាហ្មណ៍ ដែលជាមហាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ ចូរអ្នកមកនេះ ចូរអ្នកទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះមានព្រះភាគដោយត្បូងតាមពាក្យខ្ញុំ រួចទូលសួរអំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័ស កម្លាំងកាយ និងការនៅសប្បាយគ្រប់ឥរិយាបថ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទអជាតសត្តុ-

១ ហ្វូងត្មាតតែងនៅលើកំពូលភ្នំនោះ ឬភ្នំនោះមានកំពូលស្រដៀងត្មាត បានជាហៅថាគិជ្ឈកូដ ។ ២ ជាព្រះឱរសរបស់ព្រះនាងទេវី ព្រះនាមវេទេហី ។

វេទេហីបុត្តោ ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ រាជា ភន្តេ មាគធោ អជាតសត្តុ វេទេហីបុត្តោ វជ្ជី អភិយាតុកាមោ សោ ឯវមាហ អហំ ហិមេ វជ្ជី ឯវំមហិទ្ធិកេ ឯវំមហានុភាវេ ឧច្ឆេច្ឆាមិ វជ្ជី វិនាសេស្សាមិ វជ្ជី អនយព្យសនំ អាបាទេស្សាមិ វជ្ជីន្តិ យថា ច តេ ភគវា ព្យាករោតិ តំ សាធុកំ ឧគ្គហេត្វា មម[១] អារោចេយ្យាសិ ន ហិ តថាគតា វិតថំ ភណន្តីតិ ។ ឯវំ ភោតិ ខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហីបុត្តស្ស បដិស្សុត្វា ភទ្ទានិ ភទ្ទានិ យានានិ យោជេត្វា[២] ភទ្ទំ ភទ្ទំ យានំ អភិរុហិត្វា ភទ្ទេហិ ភទ្ទេហិ យានេហិ រាជគហម្ហា និយ្យាសិ យេន

១ ឱ. មមំ ។ ២ ឱ. យោជាបេត្វា ។

វេទេហិបុត្តមាគធរាជ ថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគ ដោយព្រះសិរ្ស ហើយផ្តាំមកក្រាបបង្គំទូលសួរ អំពីអាការៈមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័ស ព្រះកាយពលនិងការគង់នៅស្រួល គ្រប់ឥរិយាបថ មួយទៀត ចូរក្រាបទូលយ៉ាងនេះតទៅទៀតថា បពិត្រព្រះ-អង្គដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហិបុត្តមាគធរាជ មានព្រះបំណង នឹងយាត្រាទៅញាំញីដែនវជ្ជី ព្រះអង្គមានបន្ទូលយ៉ាងនេះថា អញនឹងផ្តិល-ផ្តាច់អ្នកដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ អញ (មានបំណងនឹងយាត្រាទៅជិះជាន់) ដែនវជ្ជី នឹងបំផ្លាញដែនវជ្ជី នឹងធ្វើដែនវជ្ជីឲ្យដល់នូវសេចក្តីវិនាស ប៉ុន្តែបើព្រះមានព្រះភាគ ទ្រង់ព្យាករដល់អ្នកយ៉ាងណា ត្រូវអ្នកត្រាប់ត្រងរងព្រះពុទ្ធដីកានោះ ឲ្យជាក់ច្បាស់ ហើយមកប្រាប់ខ្ញុំវិញ ព្រោះព្រះតថាគតទាំងឡាយ មិនដែលមានបន្ទូលខុសទេ ។ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ទទួលព្រះរាជ-ឱង្ការព្រះបាទអជាតសត្តុវេទេហិបុត្រមាគធរាជ ដោយពាក្យថា ព្រះករុ-ណាថ្លៃវិសេស ហើយទើបឲ្យរៀបចំយានទាំងឡាយដែលល្អ ៗ ហើយឡើងជិះយានដែលល្អ ៗ បរចេញអំពីក្រុងរាជគ្រឹះ ទៅដោយយានដែលល្អ ៗ

គិជ្ឈកូដោ បព្វតោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោ- ហិត្វា បត្តិកោវ យេន ភគវា តេនុបសង្កមិ ឧ- បសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវន្តំ ឯតទវោច រាជា ភោ គោតម មាគធោ អជាតសត្តុ វេទេហិបុត្តោ ភោតោ គោ- តមស្ស បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ រាជា ភោ គោ- តម មាគធោ អជាតសត្តុ វេទេហិបុត្តោ វជ្ជី អភិ- យាតុកាមោ សោ ឯវមាហ អហំ ហិមេ វជ្ជី ឯ- វំមហិទ្ធិកេ ឯវំមហានុភាវេ ឧច្ឆេច្ឆាមិ វជ្ជី វិនាសេស្សាមិ វជ្ជី អនយព្យសនំ អាបាទេស្សាមិ វជ្ជិន្តិ ។

បរសំដៅទៅកាន់ភ្នំគិជ្ឈកូដ ទៅដោយយាន កំណត់ត្រឹមទីដែលបរយាន ទៅបាន រួចចុះអំពីយានដើរទៅ ដោយជើងទទេ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហិបុត្តមាគធរាជ ថ្វាយបង្គំព្រះបាទានៃព្រះគោតមដ៏ចម្រើន ដោយព្រះសិរ្ស៍ ហើយផ្ដាំឲ្យទូលសួរអំពីអាការៈ មិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស ព្រះកាយពល និងការគង់នៅស្រួលគ្រប់ឥរិយាបថ បពិត្រព្រះគោតមដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហិបុត្តមាគធរាជ មានព្រះបំណងនឹងស្ដេចទៅញាំញីដែនវជ្ជី ព្រះអង្គមានបន្ទូលយ៉ាងនេះថា អញនឹងផ្ដិលផ្ដាច់អ្នកដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ អញ (មានបំណងនឹងយាត្រាទៅជិះជាន់) ដែនវជ្ជី នឹងបំផ្លាញដែនវជ្ជី នឹងធ្វើដែនវជ្ជីឲ្យដល់នូវសេចក្ដីវិនាស ។

[៦៨] តេន ខោ បន សមយេន អាយស្មា អា-
នន្ទោ ភគវតោ បិដ្ឋិតោ ឋិតោ ហោតិ ភគវន្តំ វីជយ-
មានោ[១] ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អា-
មន្តេសិ កិន្តិ តេ អានន្ទ សុតំ វជ្ជី អភិណ្ហសន្និបា-
តា[២] សន្និបាតពហុលាតិ ។ សុតំ មេតំ ភន្តេ វជ្ជី
អភិណ្ហសន្និបាតា សន្និបាតពហុលាតិ ។ យាវកីវញ្ច
អានន្ទ វជ្ជី អភិណ្ហសន្និបាតា សន្និបាតពហុលា ភ-
វិស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហា-
និ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជី សមគ្គា សន្និបតន្តិ
សមគ្គា វុដ្ឋហន្តិ សមគ្គា វជ្ជិករណីយានិ ករោន្តី-
តិ ។ សុតំ មេតំ ភន្តេ វជ្ជី សមគ្គា សន្និបតន្តិ ស-
មគ្គា វុដ្ឋហន្តិ សមគ្គា វជ្ជិករណីយានិ ករោន្តីតិ ។
យាវកីវញ្ច អានន្ទ វជ្ជី សមគ្គា សន្និបតិស្សន្តិ ស-
មគ្គា វុដ្ឋហិស្សន្តិ សមគ្គា វជ្ជិករណីយានិ ករិស្សន្តិ

---

១ ឱ. វិជមានោ ។ ម. ពីជមានោ ។ ២ ឱ. ម. អភិណ្ហំ សន្និបាតា ។

[៦៨] សម័យនោះឯង ព្រះអានន្ទមានអាយុ ឋិតនៅអំពីខាង ក្រោយព្រះមានព្រះភាគ កំពុងពាត់ (បក់) ថ្វាយព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទ មានអាយុថា ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី មានការប្រជុំគ្នា រឿយ ៗ មានការប្រជុំគ្នាដោយច្រើន ដូច្នេះដែរឬ ។ ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកស្តេចក្នុងដែនវជ្ជី មានការប្រជុំគ្នារឿយ ៗ មានការប្រជុំគ្នាដោយ ច្រើន ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងមានការ ប្រជុំគ្នារឿយ ៗ មានការប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាល អានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តី សាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នក បានឮថា ពួកវជ្ជីក្សត្រិយ៍ ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែង ប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជី ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍ព្រមព្រៀងគ្នាប្រជុំ ព្រម ព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជីដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍នឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នា លើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជី អស់កាលត្រឹមណា

១៤៨



វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជី អប្បញ្ញត្តំ ន បញ្ញបេន្តិ បញ្ញត្តំ ន សមុច្ឆិន្ទន្តិ យថាបញ្ញត្តេ បោរាណេ វជ្ជិធម្មេ សមាទាយ វត្តន្តីតិ ។ សុតំ មេតំ ភន្តេ វជ្ជី អប្បញ្ញត្តំ ន បញ្ញបេន្តិ បញ្ញត្តំ ន សមុច្ឆិន្ទន្តិ យថាបញ្ញត្តេ បោរាណេ វជ្ជិធម្មេ សមាទាយ វត្តន្តីតិ ។ យាវកីវញ្ច អានន្ទ វជ្ជី អប្បញ្ញត្តំ ន បញ្ញបេស្សន្តិ បញ្ញត្តំ ន សមុច្ឆិន្ទិស្សន្តិ យថាបញ្ញត្តេ បោរាណេ វជ្ជិធម្មេ សមាទាយ វត្តិស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជី យេ តេ វជ្ជីនំ វជ្ជិមហល្លកា តេ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ តេសញ្ច សោតព្វំ មញ្ញន្តីតិ ។ សុតំ មេតំ ភន្តេ

ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជីក្សត្រិយ៍មិនបញ្ញត្តច្បាប់ (ដែលពួកស្តេចពីដើម) មិនបានបញ្ញត្ត មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាមប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជីអំពីបូរាណ ដែលបានបញ្ញត្តរួចហើយយ៉ាងណា ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍មិនបញ្ញត្តច្បាប់ (ដែលពួកស្តេចពីដើម) មិនបានបញ្ញត្ត មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាមប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជី អំពីបូរាណដែលបានបញ្ញត្តរួចហើយយ៉ាងណា ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍នឹងមិនបញ្ញត្តច្បាប់ ដែលស្តេចពីដើមមិនបានបញ្ញត្តហើយ មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាមប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជីអំពីបូរាណដែលបានបញ្ញត្តរួចហើយ យ៉ាងណា អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជីក្សត្រិយ៍ ធ្វើសក្ការៈ គោរព រាប់អាន បូជាពួកវជ្ជីក្សត្រិយ៍ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ដែលគួរស្តាប់ របស់ពួកក្សត្រិយ៍ដែលមានព្រះជន្មច្រើនទាំងនោះដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន

វជ្ជី យេ តេ វជ្ជីនំ វជ្ជិមហល្លកា តេ សក្ករោន្តិ គរុ-
ករោន្តិ មានេន្តិ បូជេន្តិ តេសញ្ច សោតព្វំ មញ្ញន្តីតិ ។
យាវកីវញ្ច អានន្ទ វជ្ជី យេ តេ វជ្ជីនំ វជ្ជិមហល្លកា
តេ សក្ករិស្សន្តិ គរុករិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ
តេសញ្ច សោតព្វំ មញ្ញិស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ
បាដិកង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ
វជ្ជី យា តា កុលិត្ថិយោ កុលកុមារិយោ តា ន
ឱក្កស្ស បសយ្ហ វាសេន្តីតិ ។ សុតំ មេតំ ភន្តេ
វជ្ជី យា តា កុលិត្ថិយោ កុលកុមារិយោ តា ន
ឱក្កស្ស បសយ្ហ វាសេន្តីតិ ។ យាវកីវញ្ច អានន្ទ វជ្ជី
យា តា កុលិត្ថិយោ កុលកុមារិយោ តា ន ឱក្កស្ស
បសយ្ហ វាសេស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិ-
កង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ

ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍តែងធ្វើសក្ការៈ គោរព រាប់-អាន បូជា ពួកវជ្ជីក្សត្រិយ៍ដែលមានព្រះជន្មច្រើន ជាងវជ្ជីក្សត្រិយ៍ទាំង-ឡាយ ទាំងជឿពាក្យដែលគួរស្តាប់ របស់ពួកក្សត្រិយ៍ដែលមានព្រះជន្មច្រើនទាំងនោះថា ជាពាក្យគួរស្តាប់ ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជី-ក្សត្រិយ៍នឹងធ្វើសក្ការៈ គោរព រាប់អាន បូជា ពួកវជ្ជីក្សត្រិយ៍ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ទាំងជឿពាក្យគួរស្តាប់ របស់ពួកក្សត្រិយ៍ដែលមានព្រះជន្មច្រើនទាំងនោះ អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជី-ក្សត្រិយ៍ មិនកំហែងបង្ខំពួកស្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូលឲ្យនៅរួមដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍មិនកំហែងបង្ខំពួកស្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូលឲ្យនៅរួមដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍នឹងមិនកំហែងបង្ខំពួកស្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូលឲ្យនៅរួមអស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា

វជ្ជី យានិ តានិ វជ្ជីនំ វជ្ជិចេតិយានិ អព្ភន្តរានិ ចេវ ពាហិរានិ ច តានិ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ តេសញ្ច ទិន្នបុព្វំ កតបុព្វំ ធម្មិកំ ពលឹ នោ បរិហាបេន្តីតិ ។ សុតំ មេតំ ភន្តេ វជ្ជី យានិ តានិ វជ្ជីនំ វជ្ជិចេតិយានិ អព្ភន្តរានិ ចេវ ពាហិរានិ ច តានិ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ តេសញ្ច ទិន្នបុព្វំ កតបុព្វំ ធម្មិកំ ពលឹ នោ បរិហាបេន្តីតិ ។ យាវកីវញ្ច អានន្ទ វជ្ជី យានិ តានិ វជ្ជីនំ វជ្ជិចេតិយានិ អព្ភន្តរានិ ចេវ ពាហិរានិ ច តានិ សក្ករិស្សន្តិ គរុករិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ តេសញ្ច ទិន្នបុព្វំ កតបុព្វំ ធម្មិកំ ពលឹ នោ បរិហាបេស្សន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។ កិន្តិ តេ អានន្ទ សុតំ វជ្ជីនំ អរហន្តេសុ ធម្មិការក្ខាវរណគុត្តិ សុសំវិហិតា កិន្តិ

ពួកវជ្ជីក្សត្រិយ៍ តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយ[១] ក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរក្តី ខាងក្រៅនគរក្តី នឹងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យទៅ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរក្តី ខាងក្រៅនគរក្តី នឹងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យទៅដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍ នឹងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរក្តី ខាងក្រៅនគរក្តី នឹងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យទៅ អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើន តែងមានប្រាកដ ដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជីក្សត្រិយ៍ បានចាត់ចែងត្រឹមត្រូវនូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងអរហន្តទាំងឡាយដោយបំណងថា

---

១ ទីកន្លែងទេវតា ដែលគេធ្លាប់គោរព (អដ្ឋកថា) ។

១៦១



អនាគតា ច អរហន្តោ វិជិតំ អាគច្ឆេយ្យុំ អាគតា ច អរហន្តោ វិជិតេ ផាសុំ វិហរេយ្យុន្តិ ។ សុតំ មេតំ ភន្តេ វជ្ជីនំ អរហន្តេសុ ធម្មិការក្ខាវរណគុត្តិ សុសំវិហិតា កិន្តិ អនាគតា ច អរហន្តោ វិជិតំ អាគច្ឆេយ្យុំ អាគតា ច អរហន្តោ វិជិតេ ផាសុំ វិហរេយ្យុន្តិ ។ យាវកីវញ្ច អានន្ទ វជ្ជីនំ អរហន្តេសុ ធម្មិការក្ខាវរណគុត្តិ សុសំវិហិតា ភវិស្សតិ កិន្តិ អនាគតា ច អរហន្តោ វិជិតំ អាគច្ឆេយ្យុំ អាគតា ច អរហន្តោ វិជិតេ ផាសុំ វិហរេយ្យុន្តិ វុឌ្ឍិយេវ អានន្ទ វជ្ជីនំ ចាដិ-កង្ខា នោ បរិហានីតិ ។

ធ្វើម្ដេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខ ក្នុងដែនរបស់យើងដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍ បានចាត់ចែងដោយត្រឹមត្រូវនូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងព្រះអរ-ហន្តទាំងឡាយ ដោយបំណងថា ធ្វើម្ដេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខ ក្នុងដែនរបស់យើងដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍ នឹងចាត់ចែងដោយត្រឹមត្រូវនូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងព្រះអរហន្តទាំងឡាយ ដោយបំណងថា ធ្វើម្ដេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខ ក្នុងដែនរបស់យើង អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្ដីចម្រើន តែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

[៦៩] អថខោ ភគវា វស្សការំ ព្រាហ្មណំ មគធមហាមត្តំ អាមន្តេសិ ឯកមិទាហំ ព្រាហ្មណ សមយំ វេសាលិយំ វិហរាមិ សារន្ទទេ(១) ចេតិយេ តត្រាហំ វជ្ជីនំ ឥមេ សត្ត អបរិហានិយេ ធម្មេ ទេសេសឹ យាវកីវញ្ច ព្រាហ្មណ ឥមេ សត្ត អបរិហានិយា ធម្មា វជ្ជីសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ វជ្ជី សន្ទិស្សិស្សន្តិ(២) វុឌ្ឍិយេវ ព្រាហ្មណ វជ្ជីនំ បាដិកង្ខា នោ បរិហានីតិ ។ ឯវំ វុត្តេ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវន្តំ ឯតទវោច ឯកមេកេនបិ ភោ គោតម អបរិហានិយេន ធម្មេន សមន្នាគតានំ វជ្ជីនំ វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ កោ បន វាទោ សត្តហិ អបរិហានិយេហិ ធម្មេហិ អករណីយា ច(៣) ភោ គោតម វជ្ជី រញ្ញា មាគធេន អជាតសត្តុនា វេទេហិបុត្តេន យទិទំ យុទ្ធស្ស

---

១ អដ្ឋកថាយម្បិ អយមេវ បាឋោ ។ ម. សានន្ទរេ ។ ២ ឱ. សន្ទិស្សន្តិ ។ ៣ ឱ. វ ។

[៦៩] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ សម័យមួយ តថាគតនៅក្នុងសារន្ទទចេតិយ ទៀបក្រុងវេសាលី តថាគតបានសម្តែងអបរិហានិយធម៌ទាំង ៧ នេះ របស់ពួកវជ្ជីក្សត្រិយ៍ ក្នុងសារន្ទទចេតិយនោះឯង ម្នាលព្រាហ្មណ៍ អបរិហានិយធម៌ទាំង ៧ នេះ តាំងនៅក្នុងពួកវជ្ជីក្សត្រិយ៍ ឬថាពួកវជ្ជីក្សត្រិយ៍នឹងប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលព្រាហ្មណ៍ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ កាលបើព្រះមានព្រះភាគ មានព្រះបន្ទូលយ៉ាងនេះហើយ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីចម្រើន តែងមានប្រាកដ សេចក្តីសាបសូន្យ មិនមានដល់ពួកវជ្ជីក្សត្រិយ៍ ដែលប្រកបដោយអបរិហានិយធម៌ សូម្បីតែមួយ ។ ចាំបាច់និយាយទៅថ្វី ដល់ទៅគ្រប់អបរិហានិយធម៌ទាំង ៧ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត ព្រះបាទអជាតសត្តុវេទេហីបុត្រមាគធរាជ មិនគប្បីចាប់ពួកវជ្ជីក្សត្រិយ៍ដោយការច្បាំងបានទេ

អញ្ញត្រ ឧបលាបនាយ អញ្ញត្រ មិថុភេទាយ ហន្ទ ចទានិ មយំ ភោ គោតម គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ ព្រាហ្មណ កាលំ មញ្ញសីតិ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។

[៧០] អថខោ ភគវា អចិរប្បក្កន្តេ វស្សការេ ព្រាហ្មណេ មគធមហាមត្តេ អាយស្មន្តំ អានន្ទំ អាមន្តេសិ គច្ឆ ត្វំ អានន្ទ យាវតិកា ភិក្ខូ រាជគហំ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា យាវតិកា ភិក្ខូ រាជគហំ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ អាយស្មា អានន្ទោ

វៀរលែងតែការលួងលោមយកចិត្ត ឬការធ្វើឲ្យបែកគ្នា បពិត្រព្រះគោតមដ៏ចម្រើន ណ្ហើយចុះ ខ្ញុំព្រះអង្គសូមលាទៅឥឡូវនេះ ខ្ញុំព្រះអង្គមានកិច្ចច្រើន មានការងារច្រើន ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកចូរសម្គាល់នូវកាលគួរនឹងទៅ ក្នុងវេលានេះចុះ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ត្រេកអររីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈចេញទៅ ។

[៧០] កាលដែលវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ចេញទៅមិនយូរប៉ុន្មាន ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅឲ្យភិក្ខុទាំងអស់ ដែលនៅអាស្រ័យក្នុងក្រុងរាជគ្រឹះប្រជុំគ្នា ក្នុងឧបដ្ឋានសាលា[១] ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយប្រជុំភិក្ខុសង្ឃទាំងអស់ ដែលនៅអាស្រ័យក្នុងក្រុងរាជគ្រឹះ ក្នុងឧបដ្ឋានសាលា ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីសមគួរ ។ ព្រះអានន្ទដ៏មានអាយុ លុះឋិតនៅក្នុងទីដ៏សមគួរហើយ

១ រោងឆាន់ ឬរោងសម្រាប់ប្រើប្រាស់ ។

ភគវន្តំ ឯតទវោច សន្និបតិតោ ភន្តេ ភិក្ខុសង្ឃោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។ អថខោ ភគវា ឧដ្ឋាយាសនា យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ សត្ត វោ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច យាវកីវញ្ច ភិក្ខវេ ភិក្ខូ អភិណ្ហសន្និចាតា សន្និចាតពហុលា ភវិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ ចាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ សមគ្គា សន្និបតិស្សន្តិ សមគ្គា វុដ្ឋហិស្សន្តិ សមគ្គា សង្ឃករណីយានិ ករិស្សន្តិ

បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្គាល់នូវកាលគួរនឹងស្ដេចទៅក្នុងកាលឥឡូវនេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ក្រោកអំពីអាសនៈហើយ ស្ដេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលគេក្រាលទុក ។ លុះព្រះមានព្រះភាគ គង់នៅហើយ ក៏ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងអបរិហានិយធម៌ ៧ ប្រការ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្ដាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្ដែងប្រាប់ ។ ភិក្ខុទាំងឡាយនោះ ក៏ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ បើពួកភិក្ខុនឹងប្រជុំគ្នារឿយ ៗ ប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកទីប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចរបស់សង្ឃ អស់កាលត្រឹមណា

វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ អប្បញ្ញត្តំ ន បញ្ញបេស្សន្តិ បញ្ញត្តំ ន សមុច្ឆិន្ទិស្សន្តិ យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរប្បព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ សក្ករិស្សន្តិ គរុករិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ តេសញ្ច សោតព្វំ មញ្ញិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ឧប្បន្នាយ តណ្ហាយ ពោនោព្ភវិកាយ ន វសំ គច្ឆិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំង-ឡាយ បើពួកភិក្ខុនឹងមិនបញ្ញត្តសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ មិនដកសិក្ខាបទដែលតថាគតបញ្ញត្តហើយ កាន់តាម ប្រព្រឹត្តតាមសិក្ខាបទ ដែលតថាគតបញ្ញត្តហើយយ៉ាងណា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំង-ឡាយ បើពួកភិក្ខុនឹងធ្វើសក្ការៈ គោរព រាប់អាន បូជាពួកភិក្ខុជាថេរៈអ្នកដឹងរាត្រី (ច្រើន) បួសយូរ ជាបិតានៃសង្ឃ ជាបរិនាយក របស់សង្ឃ (ជាអ្នកណែនាំសង្ឃ) ទាំងរាប់អានជឿពាក្យដែលគួរស្តាប់ របស់ភិក្ខុជាថេរៈទាំងនោះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនលុះក្នុងអំណាចតណ្ហា ជាធម្មជាតិនាំសត្វទៅក្នុងភពថ្មីទៀត ដែលកើតឡើងហើយ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

១៦៦



យាវកីវញ្ច ភិក្ខវេ ភិក្ខូ អារញ្ញកេសុ សេនាសនេសុ សាបេក្ខា ភវិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ បច្ចត្តញ្ញេវ សតឹ ឧបដ្ឋបេស្សន្តិ កិន្តិ អនាគតា ច បេសលា សព្រហ្មចារី អាគច្ឆេយ្យុំ អាគតា ច បេសលា សព្រហ្មចារី ផាសុំ វិហរេយ្យុន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិ-កង្ខា នោ បរិហានិ ។

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមានសេចក្ដីប្រាថ្នាក្នុងសេនាសនៈទាំង-ឡាយ ដែលតាំងនៅក្នុងព្រៃ[១] អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រុងស្មារតីក្នុងខ្លួនថា ធ្វើម្ដេចហ្ន៎ ពួកសព្រហ្មចារី[២] មានសីលធម៌ជាទីស្រឡាញ់ ដែលមិនទាន់មកដល់ ក៏សូមឲ្យនិមន្តមក ពួកសព្រហ្មចារីមានសីលធម៌ជាទីស្រឡាញ់ ដែលមកដល់ហើយ សូមឲ្យនៅជាសុខដូច្នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងភិក្ខុទាំងឡាយ ឬថាភិក្ខុទាំងឡាយនឹងប្រតិបត្តិ ក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

---

១ អដ្ឋកថា ថា ប្រទេសដែលនៅឆ្ងាយពីស្រុកកំណត់ ៥០០ ធ្នូរធ្នូឡើងទៅ ។ ២ ភិក្ខុមានព្រហ្មចារ្យស្មើគ្នា ។

មហាបរិនិព្វានសុត្តេ ភិក្ខុភាណវារំ ភិក្ខូនំ សត្តអបរិហានិយធម្មា

[៧១] អបរេបិ វោ[១] ភិក្ខវេ សត្ត អបរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន កម្មារាមា ភវិស្សន្តិ ន កម្មរតា ន កម្មារាមតំ អនុយុត្តា វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន ភស្សារាមា ភវិស្សន្តិ ន ភស្សរតា ន ភស្សារាមតំ អនុយុត្តា វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន និទ្ទារាមា

១ ឱ. ខោ ។

មហាបរិនិព្វានសូត្រ ភិក្ខុភាណវារៈ អបរិហានិយធម៌ ៧ របស់ពួកភិក្ខុ

[៧១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ៧ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុមិនជាអ្នកមានការងារ ជាទីត្រេកអរ[១] មិនត្រេកអរក្នុងការងារ មិនប្រកបរឿយ ៗ នូវភាវៈជាអ្នកមានការងារជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនជាអ្នកមានការនិយាយ (តិរច្ឆានកថា) ជាទីត្រេកអរ មិនត្រេកអរក្នុងការនិយាយ (តិរច្ឆានកថា) មិនប្រកបរឿយ ៗ នូវភាវៈជាអ្នកមានការនិយាយ (តិរច្ឆានកថា) ជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនជាអ្នកមានសេចក្តីដេកលក់ ជាទីត្រេកអរ

---

១ សំដៅយកកិច្ចរបស់ភិក្ខុមានដេរចីវរជាដើម បើភិក្ខុណាធ្វើកិច្ចនោះអស់ ១ ថ្ងៃទាំងមូល មិនមានពេលរៀនសូត្រសោះ ភិក្ខុនោះទើបឈ្មោះថា ត្រេកអរនឹងការងារ បើភិក្ខុដែលធ្វើការងារខ្លះ ប្រកបការរៀនសូត្រខ្លះក្នុង ១ ថ្ងៃ ។ ភិក្ខុនោះមិនឈ្មោះថាត្រេកអរនឹងការងារឡើយ ។

ភវិស្សន្តិ ន និទ្ទារតា ន និទ្ទារាមតំ អនុយុត្តា វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន សង្គណិការាមា ភវិស្សន្តិ ន សង្គ-ណិការតា ន សង្គណិការាមតំ អនុយុត្តា វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន បាបិច្ឆា ភវិស្សន្តិ ន បាបិកានំ ឥច្ឆានំ វសំ គតា វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន បាបមិត្តា ភវិស្សន្តិ ន បាបសហាយា ន បាបសម្បវង្កា[១] វុឌ្ឍិ-យេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ ន ឱរមត្តកេន វិសេសាធិគ-មេន អន្តរា វោសានំ អាបជ្ជិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ

---

១ ឱ. បាបសម្បវង្កា ។ ម. បាបសម្បវង្កតា ។

មិនត្រេកអរ ក្នុងសេចក្តីដេកលក់ មិនប្រកបរឿយ ៗ នូវភាវៈជាអ្នកមានសេចក្តីដេកលក់ជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនជាអ្នកមានគ្នីគ្នាជាទីត្រេកអរ មិនត្រេកអរក្នុងការមានគ្នីគ្នា មិនប្រកបរឿយ ៗ នូវភាវៈជាអ្នកមានគ្នីគ្នាជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនមានសេចក្តីប្រាថ្នាអាក្រក់ មិនលុះក្នុងអំណាចសេចក្តីប្រាថ្នាអាក្រក់ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនមានមិត្រអាក្រក់ មិនមានសំឡាញ់អាក្រក់ មិនជាអ្នកងាកទៅរកបុគ្គលអាក្រក់ អស់កាលត្រឹមណា ម្នាលភិក្ខុទាំង-ឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនដល់នូវសេចក្តីបន្ធូរបន្ថយព្យាយាមក្នុងចន្លោះ ដោយការត្រាស់ដឹងនូវគុណវិសេសត្រឹមតែជាន់ក្រោម អស់កាលត្រឹមណា ម្នាលភិក្ខុទាំង-

ភិក្ខូជំ ចាដិកង្ខា ដោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ជម្មា ភិក្ខូសុ បស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ជម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ ចាដិ-កង្ខា ដោ បរិហានិ ។

[៧២] អបរេបិ វោ ភិក្ខវេ សត្ត អបរិហានិយេ ជម្មេ ដេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច យាវកីវញ្ច ភិក្ខវេ ភិក្ខូ សទ្ធា ភវិស្សន្តិ ។ បេ ។ ហិរិមនា ភវិស្សន្តិ ។ ឱត្តប្បី ភវិស្សន្តិ ។ ពហុស្សុតា ភវិស្សន្តិ ។ អារទ្ធវីរិយា ភវិស្សន្តិ ។ ឧបដ្ឋិតស្សតី ភវិស្សន្តិ ។ បញ្ញវន្តោ ភវិ-ស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ ចាដិកង្ខា ដោ បរិហា-និ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា

ឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិ-ហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។

[៧២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ៧ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្ត ដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមានសេចក្តីជឿ ។ បេ ។ មានចិត្តប្រកបដោយសេចក្តីខ្មាសខ្ពើមបាប ។ មានសេចក្តីខ្លាចបាប ។ ជាពហុស្សូត ។ ប្រារព្ធសេចក្តីព្យាយាម ។ ជាអ្នកមានស្មារតីខ្ជាប់ខ្ជួន ។ ជាអ្នកមានប្រាជ្ញាអស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិត

ធម្មា ភិក្ខូសុ បស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិ-
យេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ
ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។

[៧៣] អបរេបិ វោ ភិក្ខវេ សត្ត អបរិហានិយេ
ធម្មេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិ-
ករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ
ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច
យាវកីវញ្ច ភិក្ខវេ ភិក្ខូ សតិសម្ពោជ្ឈង្គំ ភាវេស្ស-
ន្តិ ។ បេ ។ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេស្សន្តិ ។
វីរិយសម្ពោជ្ឈង្គំ ភាវេស្សន្តិ ។ បីតិសម្ពោជ្ឈង្គំ ភា-
វេស្សន្តិ ។ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេស្សន្តិ ។ សមាធិ-
សម្ពោជ្ឈង្គំ ភាវេស្សន្តិ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេស្សន្តិ

នៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។

[៧៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ៧ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងចម្រើនសតិសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសេចក្តីរលឹក) ។ បេ ។ ចម្រើនធម្មវិចយសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺបញ្ញាជាគ្រឿងពិចារណា) ។ ចម្រើនវីរិយសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺព្យាយាម) ។ ចម្រើនបីតិសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសេចក្តីឆ្អែតស្កប់ក្នុងធម៌) ។ ចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ (ហេតុ-នៃធម៌ជាគ្រឿងត្រាស់ដឹង គឺសេចក្តីស្ងប់រម្ងាប់) ។ ចម្រើនសមាធិសម្ពោ-ជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសេចក្តីតម្កល់ចិត្តមាំ) ។ ចម្រើនឧបេក្ខាសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសេចក្តីព្រងើយ

វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។

[៧៤] អបរេបិ វោ ភិក្ខវេ សត្ត អបរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច យាវកីវញ្ច ភិក្ខវេ ភិក្ខូ អនិច្ចសញ្ញំ ភាវេស្សន្តិ ។ បេ ។ អនត្តសញ្ញំ ភាវេស្សន្តិ ។ អសុភសញ្ញំ ភាវេស្សន្តិ ។ អាទីនវសញ្ញំ ភាវេស្សន្តិ ។ បហានសញ្ញំ ភា-

ក្នុងសុខនិងទុក្ខ) អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។

[៧៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ៧ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្ត ដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងចម្រើនអនិច្ចសញ្ញា (សេចក្តីសម្គាល់ដែលកើតជាមួយនឹងអនិច្ចានុបស្សនា) ។ បេ ។ ចម្រើនអនត្តសញ្ញា (សេចក្តីសម្គាល់ដែលកើតជាមួយនឹងអនត្តានុបស្សនា) ។ ចម្រើនអសុភសញ្ញា (សេចក្តីសម្គាល់នូវអាការ ៣២ ថា មិនស្អាត) ។ ចម្រើនអាទីនវសញ្ញា (សេចក្តីសម្គាល់នូវកាយថា មានទោស) ។ ចម្រើនបហានសញ្ញា សេចក្តីសម្គាល់

វេស្សន្តិ ។ វិរាគសញ្ញំ ភាវេស្សន្តិ ។ និរោធសញ្ញំ ភាវេស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ សត្ត អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច សត្តសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។

[៧៩] អបរេបិ វោ ភិក្ខវេ[១] ឆ[២] អបរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច យាវកីវញ្ច ភិក្ខវេ ភិក្ខូ មេត្តំ កាយកម្មំ បច្ចុបដ្ឋបេស្សន្តិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិ-

---

១ ឱ. ម. អបរេបិ វោ ភិក្ខវេតិ បាឋោ ន ទិស្សន្តិ ។ ២ ឱ. ម. ភិក្ខវេតិ ទិស្សតិ ។

ក្នុងការលះនូវអកុសលវិតក្កៈ) ។ ចម្រើនវិរាគសញ្ញា (សេចក្តីសម្គាល់ក្នុងព្រះនិព្វានដែលប្រាសចាកតម្រេក) ។ ចម្រើននិរោធសញ្ញា (សេចក្តីសម្គាល់ក្នុងព្រះនិព្វានជាគ្រឿងរលត់ទុក្ខ) អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។

[៧៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ៦ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រុងតម្កល់កាយកម្ម ប្រកបដោយមេត្តា ក្នុងសព្រហ្មចារីទាំងឡាយ ទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តី

១៧៣



ហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ មេត្តំ វចីកម្មំ បច្ចុបដ្ឋបេស្សន្តិ[១] ។ បេ ។ មេត្តំ មនោកម្មំ បច្ចុបដ្ឋបេស្សន្តិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ យេ តេ លាភា ធម្មិកា ធម្មលទ្ធា អន្តមសោ បត្តបរិយាបន្នមត្តំបិ តថារូបេហិ លាភេហិ ន[២] អប្បដិវិភត្តភោគី ភវិស្សន្តិ សីលវន្តេហិ សព្រហ្មចារីហិ សាធារណភោគី វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ យានិ តានិ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុបសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ

១ បច្ចុបដ្ឋាបេស្សន្តីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ម. នសទ្ទោ នត្ថិ ។

សាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំង-ឡាយ បើពួកភិក្ខុនឹងប្រុងតម្កល់វចីកម្មប្រកបដោយមេត្តា ។ បេ ។ ប្រុងតម្កល់មនោកម្មប្រកបដោយមេត្តា ក្នុងសព្រហ្មចារីទាំងឡាយ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំង-ឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើលាភទាំងឡាយណា ដែលប្រកបដោយធម៌ ដែលបានមកដោយធម៌ ដោយហោចទៅ សូម្បីវត្ថុដែលគេដាក់ចុះក្នុងបាត្រ ពួកភិក្ខុមិនមានការបរិភោគដោយមិនបាច់ចែករំលែកដោយលាភទាំងឡាយ មានសភាពយ៉ាងនោះ គឺជាអ្នកមានការបរិភោគ ជាសាធារណៈ ជាមួយនឹងសព្រហ្មចារីទាំង-ឡាយ ដែលមានសីល អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ សីលទាំងឡាយណា មិនដាច់ មិនធ្លុះ មិនពព្រុះ មិនពពាល ជាសីលរបស់មនុស្សអ្នកជា (មិនជាខ្ញុំតណ្ហា) អ្នកប្រាជ្ញតែងសរសើរ ជាសីលមិនបានជ្រោកជ្រាកដោយតណ្ហានិងទិដ្ឋិ ជាសីលញ៉ាំងសមាធិឲ្យប្រព្រឹត្តទៅបាន

តថារូបេសុ សីលេសុ សីលសាមញ្ញគតា វិហរិស្សន្តិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ភិក្ខូ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា ទិដ្ឋិសាមញ្ញគតា វិហរិស្សន្តិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ។ យាវកីវញ្ច ភិក្ខវេ ឥមេ ឆ អបរិហានិយា ធម្មា ភិក្ខូសុ ឋស្សន្តិ ឥមេសុ ច ឆសុ អបរិហានិយេសុ ធម្មេសុ ភិក្ខូ សន្ទិស្សិស្សន្តិ វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានីតិ ។ តត្របិ សុទំ ភគវា រាជគហេ វិហរន្តោ គិជ្ឈកូដេ បព្វតេ ឯតទេវ ពហុលំ ភិក្ខូនំ ធម្មិំ កថំ ករោតិ ឥតិ សីលំ ឥតិ សមាធិ

ពួកភិក្ខុជាអ្នកមានសីលស្មើគ្នា ដោយសព្រហ្មចារីទាំងឡាយ ក្នុងសីលទាំងឡាយ មានសភាពយ៉ាងនោះ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិណាដែលឥតទោស ជាទីស្រោចស្រង់សត្វប្រព្រឹត្តទៅ ដើម្បីអស់សេចក្តីទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ពួកភិក្ខុជាអ្នកមានទិដ្ឋិស្មើគ្នា ដោយសព្រហ្មចារីទាំងឡាយ ក្នុងទិដ្ឋិមានសភាពយ៉ាងនោះ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៦ នេះ នឹងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិ ក្នុងអបរិហានិយធម៌ទាំង ៦ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ) ។ កាលដែលព្រះមានព្រះភាគគង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះនោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់ភិក្ខុទាំងឡាយ យ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ

ឥតិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា(១) អវិជ្ជាសវាតិ ។

[៧៦] អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន អម្ពលដ្ឋិកា តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន អម្ពលដ្ឋិកា តទវសរិ ។ តត្រ សុទំ ភគវា អម្ពលដ្ឋិកាយំ វិហរតិ រាជាគារកេ ។ តត្របិ សុទំ ភគវា អម្ពលដ្ឋិកាយំ វិហរន្តោ រាជាគារកេ ឯតទេវ ពហុលំ ភិក្ខូនំ ធម្មឹ កថំ ករោតិ ឥតិបិ សីលំ ឥតិបិ សមាធិ ឥតិបិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា

១ ឥតោ បរំ យេភុយ្យេន ទិដ្ឋាសវាតិ ទិស្សតិ សុត្តន្តនយេន បន តយោ អាសវា ញាតព្វា ។

បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីល រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្ត[១]ដែលអប់រំដោយបញ្ញា រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃពិត គឺកាមាសវៈ (ធម៌ជាគ្រឿងត្រាំ គឺកាម) ភវាសវៈ (ធម៌ជាគ្រឿងត្រាំ គឺភព) អវិជ្ជាសវៈ (ធម៌ជាគ្រឿងត្រាំ គឺអវិជ្ជា) ។

[៧៦] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទ មានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ឧទ្យានឈ្មោះ អម្ពលដ្ឋិកា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់អម្ពលដ្ឋិកាឧទ្យាន មួយអន្លើដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងរាជាគារកៈ (ព្រះរាជដំណាក់) នៅនាអម្ពលដ្ឋិកា-ឧទ្យាននោះ ។ កាលព្រះមានព្រះភាគ ទ្រង់គង់ក្នុងរាជាគារកៈ ក្នុងអម្ពលដ្ឋិកា-ឧទ្យាននោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីល រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិ

១ សំដៅយកមគ្គចិត្តនិងផលចិត្ត ។

មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

[៧៧] អថខោ ភគវា អម្ពលដ្ឋិកាយំ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន នាឡន្ទា តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន នាឡន្ទា តទវសរិ ។ តត្រ សុទំ ភគវា នាឡន្ទាយំ វិហរតិ ចាវាទិកម្ពវនេ[១] ។ អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឯវំ បសន្នោ អហំ ភន្តេ ភគវតិ ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយន្តិ ។

១ ឱ. ម. បាវារិកម្ពវនេ ។

រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញា រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃពិត គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[៧៧] លុះព្រះមានព្រះភាគ ទ្រង់គង់ក្នុងអម្ពលដ្ឋិកាឧទ្យាន តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ស្រុកនាឡន្ទា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្ដេចទៅដល់ស្រុកនាឡន្ទា មួយអន្លើដោយភិក្ខុសង្ឃជាច្រើន ។ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងបាវារិកម្ពវ័ន ទៀបក្រុងនាឡន្ទានោះ ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះសារីបុត្តមានអាយុ លុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាំនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រះមានព្រះភាគ ដោយហេតុយ៉ាំងនេះថា សមណៈឬព្រាហ្មណ៍ដទៃ ជាអ្នកត្រាស់ដឹងក្រៃលែងជាងព្រះមានព្រះភាគ ក្នុងសម្ពោធិញ្ញាណ មិនមានក្នុងអតីតកាល មិនមានក្នុងអនាគតកាល ឬមិនមានក្នុងបច្ចុប្បន្នកាលនេះទេ ។

**១៧៧**

មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ ពុទ្ធគុណានុយោគកថា

ឧឡារា ខោ តេ អយំ សារីបុត្ត អាសភិវាចា ភាសិតា ឯកំសោ គហិតោ សីហនាទោ នទិតោ ឯវំ បសន្នោ អហំ ភន្តេ ភគវតិ ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយន្តិ កឹ នុ សារីបុត្ត យេ តេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ ចេតសា ចេតោ បរិច្ច វិទិតា ឯវំសីលា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំធម្មា ។ ឯវំបញ្ញា ។ ឯវំវិហារី ។ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ។ នោ ហេតំ ភន្តេតិ[១] ។

---

១ ឱ. ម. ឥតិសទ្ទោ នត្ថិ ។

ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលថា ម្នាលសារីបុត្ត អាសភិវាចា[១] ដែលអ្នកនិយាយនេះលើសលុបពេក សីហនាទ ដែលអ្នកប្រកាន់ហើយ បន្លឺឡើងហើយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លា ក្នុងព្រះមានព្រះភាគដោយហេតុយ៉ាងនេះថា សមណៈឬព្រាហ្មណ៍ដទៃ ជាអ្នកត្រាស់ដឹងក្រៃលែងជាងព្រះមានព្រះភាគ ក្នុងសម្ពោធិញ្ញាណ មិនមានក្នុងអតីតកាល មិនមានក្នុងអនាគតកាល ឬមិនមានក្នុងបច្ចុប្បន្នកាលនេះទេ ដូច្នេះជាសំដីដោយឡែក ម្នាលសារីបុត្ត ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលមានក្នុងអតីតកាល ព្រះមានព្រះភាគទាំងអស់នោះ អ្នកបានកំណត់ដឹងច្បាស់នូវចិត្ត ដោយចិត្តរបស់ខ្លួនថា ព្រះមានព្រះភាគទាំងនោះ មានសីលយ៉ាងនេះដូច្នេះផង មានធម៌យ៉ាងនេះ ។ មានបញ្ញាយ៉ាងនេះ ។ មានធម៌ជាគ្រឿងនៅ[២] យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានចិត្តរួចស្រឡះហើយចាកអាសវៈយ៉ាងនេះ ដូច្នេះដែរឬ ។ ព្រះសារីបុត្តមានអាយុ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ ខ្ញុំព្រះអង្គកំណត់ដឹងមិនបានទេ ។

---

១ សំដីអង់អាច ឥតខ្លាចញញើត ។ ២ ធម៌ជាគ្រឿងនៅ មាន ៩ គឺរូបសមាបត្តិ ៤ អរូបសមាបត្តិ ៤ និងសញ្ញាវេទយិតនិរោធ ១ ធម៌ទាំង ៩ នេះ នឹងហៅអនុបុព្វវិហារធម៌ដូច្នេះវិញក៏បាន ។

កឹ បន សារីបុត្ត យេ តេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ ចេតសា ចេតោ បរិច្ច វិទិតា ឯវំសីលា តេ ភគវន្តោ ភវិស្សន្តិ ឥតិបិ ឯវំធម្មា ។ ឯវំបញ្ញា ។ ឯវំវិហារី ។ ឯវំវិមុត្តា តេ ភគវន្តោ ភវិស្សន្តិ ឥតិបីតិ ។ នោ ហេតំ ភន្តេតិ ។ កឹ បន សារីបុត្ត តេ អហំ[១] ឯតរហិ អរហំ សម្មាសម្ពុទ្ធោ ចេតសា ចេតោ បរិច្ច វិទិតោ ឯវំសីលោ ភគវា ឥតិបិ ឯវំធម្មោ ។ ឯវំបញ្ញោ ។ ឯវំវិហារី ។ ឯវំវិមុត្តោ ភគវា ឥតិបីតិ ។ នោ ហេតំ ភន្តេតិ ។ ឯត្ថ ច ហិ[២] តេ សារីបុត្ត អតីតានាគតប្បច្ចុប្បន្នេសុ អរហន្តេសុ សម្មាសម្ពុទ្ធេសុ ចេតោបរិញ្ញាយ[៣] ញាណំ នត្ថិ អថ កិញ្ចេតរហិ តេ អយំ សារីបុត្ត ឧឡារា អាសភិវាចា ភាសិតា ឯកំសោ គហិតោ សីហនាទោ

---

១ ឱ. អហំ តេ ។ ២ ឱ. ឯត្ថេវ ហិ ។ ម. ឯតរហិ ។ ៣ ឱ. ចេតោបរិញ្ញាណំ ។ ម. ចេតសា ចេតោបរិយាយ ញាណំ ។

ម្នាលសារីបុត្ត ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលនឹងមានក្នុងអនាគតកាល ព្រះមានព្រះភាគទាំងអស់នោះ អ្នកបាន កំណត់ដឹងច្បាស់នូវចិត្តដោយចិត្តរបស់ខ្លួនថា ព្រះមានព្រះភាគទាំងនោះ នឹងមានសីលយ៉ាងនេះដូច្នេះផង នឹងមានធម៌យ៉ាងនេះ ។ នឹងមានបញ្ញា យ៉ាងនេះ ។ នឹងមានធម៌ជាគ្រឿងនៅយ៉ាងនេះ ។ ព្រះមានព្រះភាគ ទាំងនោះ នឹងមានចិត្តរួចស្រឡះចាកអាសវៈយ៉ាងនេះ ដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ ខ្ញុំព្រះអង្គកំណត់ដឹងមិនបានទេ ។ ម្នាល សារីបុត្ត តថាគតជាអរហន្តសម្មាសម្ពុទ្ធក្នុងកាលឥឡូវនេះ អ្នកបានកំណត់ ដឹងច្បាស់នូវចិត្តដោយចិត្តរបស់ខ្លួនថា ព្រះមានព្រះភាគមានសីលយ៉ាងនេះ ដូច្នេះផង មានធម៌យ៉ាងនេះ ។ មានបញ្ញាយ៉ាងនេះ ។ មានធម៌ជាគ្រឿងនៅ យ៉ាងនេះ ។ ព្រះមានព្រះភាគ មានចិត្តរួចស្រឡះហើយចាកអាសវៈយ៉ាង នេះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ ខ្ញុំព្រះអង្គកំណត់ដឹងមិន បានទេ ។ ម្នាលសារីបុត្ត បើអ្នកគ្មានញាណជាគ្រឿងកំណត់ដឹងចិត្តរបស់ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលមានក្នុងអតីតកាល អនាគតកាល បច្ចុប្បន្នកាលទាំងនុ៎ះទេ ម្នាលសារីបុត្ត ម្តេចឡើយ ក៏អ្នកពោលអាសភិវាចា ដ៏លើសលុបនេះក្នុងកាលឥឡូវនេះ អ្នកប្រកាន់បន្ទឺឡើងហើយនូវសីហនាទ

១៧៩



នទិតោ ឯវំ បសន្នោ អហំ ភន្តេ ភគវតិ ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយន្តិ ។ ន ខោ មេ ភន្តេ អតីតានាគតប្បច្ចុប្បន្នេសុ អរហន្តេសុ សម្មាសម្ពុទ្ធេសុ ចេតោបរិញ្ញាយ ញាណំ អត្ថិ អបិច ធម្មន្វយោ វិទិតោ សេយ្យថាបិ ភន្តេ រញ្ញោ បច្ចន្តិមំ នគរំ ទឡ្ហុទ្ទាបំ[1] ទឡ្ហបាការតោរណំ ឯកទ្វារំ តត្រស្ស ទោវារិកោ បណ្ឌិតោ វិយត្តោ មេធាវី អញ្ញាតានំ និវារេតា ញាតានំ បវេសេតា សោ តស្ស នគរស្ស សមន្តា អនុចរិយាយ[2] បថំ អនុក្កមមានោ ន បស្សេយ្យ បាការសន្ធិំ វា បាការវិវរំ វា អន្តមសោ ពិឡារនិក្ខមនមត្តំបិ[3] ន បស្សេយ្យ[4] តស្ស ឯវមស្ស យេ ខោ កេចិ ឱឡារិកា បាណា ឥមំ នគរំ បវិសន្តិ វា និក្ខមន្តិ វា សព្វេ តេ ឥមិនា[5] ទ្វារេន បវិសន្តិ វា និក្ខមន្តិ វាតិ

---

១ ឱ. ទឡ្ហុទ្ទាយំ ។ ២ ឱ. ម. អនុបរិយាយ ។ ៣ ឱ. ពិឡារនិស្សក្កនមត្តម្បិ ។ ៤ ឱ. ម. ន បស្សេយ្យាតិ បាឋោ ន ទិស្សតិ ។ ៥ ឱ. ម. ឥមិនា វ ។

ដោយមាំមួនថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រះមានព្រះភាគដោយហេតុយ៉ាងនេះថា សមណៈឬព្រាហ្មណ៍ដទៃ ជាអ្នកត្រាស់ដឹងក្រៃលែង ជាងព្រះមានព្រះភាគ ក្នុងសម្ពោធិញ្ញាណ មិនមានក្នុងអតីតកាល មិនមានក្នុងអនាគតកាល ឬមិនមានក្នុងបច្ចុប្បន្នកាលនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្មានញាណ ជាគ្រឿងកំណត់ដឹងនូវចិត្តរបស់ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលមានក្នុងអតីតកាល អនាគត-កាល និងបច្ចុប្បន្នកាលទេ តែថាខ្ញុំព្រះអង្គដឹងច្បាស់តាមទំនងធម៌ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចទីក្រុង ដែលតាំងនៅក្នុងទីបំផុតដែនរបស់ស្តេច ដែលមានទ្វារមាំ មានកំផែងនិងខ្លោងទ្វារដ៏មាំមួន មានទ្វារតែមួយ ក្នុងទីក្រុងនោះ មានអ្នកចាំយាមទ្វារ ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា ឃាត់ហាមពួកមនុស្សដែលមិនស្គាល់ ឲ្យតែពួកមនុស្សដែលស្គាល់ ចូលទៅ នាយទ្វារនោះ ក៏ដើរទៅតាមផ្លូវ ដើម្បីពិនិត្យមើលជុំវិញទីក្រុងនោះ ក៏មិនឃើញនូវទីកំផែង ឬចន្លោះកំផែង ដោយហោចទៅ សូម្បីតែប្រហោងល្មមសត្វឆ្មាចេញបាន ក៏មិនឃើញឡើយ នាយទ្វារនោះ ក៏មានសេចក្តីយល់យ៉ាងនេះថា ពួកសត្វណានីមួយ ដែលមានកាយធំ ចូលមកកាន់ទីក្រុងនេះក្តី ចេញទៅក្តី ពួកសត្វទាំងអស់នោះ គង់ចូលឬចេញតាមទ្វារនេះ

ឯវមេវ ខោ មេ ភន្តេ ធម្មន្វយោ វិទិតោ យេ តេ ភន្តេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិ-លេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិបដ្ឋានេសុ សុប្បតិដ្ឋិតចិត្តា សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈឹសុ យេបិ តេ ភន្តេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិ-លេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិប្បដ្ឋា-នេសុ សុប្បតិដ្ឋិតចិត្តា សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈិស្សន្តិ ភគ-វាបិ ភន្តេ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ បញ្ច នីវរ-ណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វ-លីករណេ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តោ

យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់តាមទំនងធម៌ ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលមានក្នុងអតីតកាល ព្រះមានព្រះភាគទាំងអស់នោះ បានលះនីវរណធម៌ទាំង ៥ ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម៌ធ្វើប្រាជ្ញាឲ្យថយកម្លាំង ទ្រង់មានព្រះហឫទ័យតម្កល់មាំល្អ ក្នុងសតិប្បដ្ឋានទាំង ៤ ចម្រើនពោជ្ឈង្គទាំង ៧ ដោយពិត ទ្រង់ត្រាស់ដឹងហើយ នូវអនុត្តរសម្មាសម្ពោធិញ្ញាណ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលនឹងមានក្នុងអនាគតកាល ព្រះមានព្រះភាគទាំងអស់នោះ នឹងលះនូវនីវរណធម៌ទាំង ៥ ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម៌ធ្វើប្រាជ្ញាឲ្យថយកម្លាំង មានព្រះហឫទ័យតម្កល់មាំល្អ ក្នុងសតិប្បដ្ឋានទាំង ៤ ចម្រើនពោជ្ឈង្គទាំង ៧ ដោយពិត ហើយនឹងបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងបច្ចុប្បន្នកាលនេះ ក៏លះនីវរណធម៌ទាំង ៥ ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម៌ធ្វើប្រាជ្ញាឲ្យថយកម្លាំង ទ្រង់មានព្រះហឫទ័យតម្កល់មាំល្អ ក្នុងសតិប្បដ្ឋានទាំង ៤ ចម្រើន

សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ។ តត្របិ សុទំ ភគវា នាឡន្ទាយំ វិហរន្តោ ចាវាជិកម្ពវនេ(១) ឯតទេវ ពហុលំ ភិក្ខូនំ ធម្មឹ កថំ ករោតិ ឥតិបិ សីលំ ឥតិបិ សមាធិ ឥតិបិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

[៧៨] អថខោ ភគវា នាឡន្ទាយំ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន ចាដលិក្កាមោ តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

១ ឱ. ម. បាវារិកម្ពវនេ ។

ពោជ្ឈង្គទាំង ៧ ដោយពិត ហើយត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ។ ព្រះមានព្រះភាគគង់ក្នុងបាវារិកម្ពវ័ន ទៀបស្រុកនាឡន្ទានោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ តែងរួចស្រឡះចាកអាសវៈទាំងឡាយដោយពិត គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[៧៨] គ្រាដែលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងស្រុកនាឡន្ទា តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់បាដលិគ្រាម ។ ព្រះអានន្ទមានអាយុទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ។

អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន បាដលិគ្គាមោ តទវសរិ ។ អស្សោសុំ ខោ បាដលិគ្គាមិយា ឧបាសកា ភគវា កិរ បាដលិគ្គាមំ អនុប្បត្តោតិ ។ អថខោ បាដលិគ្គាមិយា ឧបាសកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ បាដលិគ្គាមិយា ឧបាសកា ភគវន្តំ ឯតទវោចុំ អធិវាសេតុ នោ ភន្តេ ភគវា អាវសថាគារន្តិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ បាដលិគ្គាមិយា ឧបាសកា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន អាវសថាគារំ តេនុបសង្កមឹសុ ឧបសង្កមិត្វា សព្វសន្ថរិតំ[១] សន្ថតំ[២] អាវសថាគារំ សន្ថរិត្វា អាសនានិ បញ្ញបេត្វា ឧទកមណិកំ[៣] បតិដ្ឋាបេត្វា តេលប្បទីបំ អារោបេត្វា យេន ភគវា តេនុបសង្កមឹសុ

១ ឱ. សព្វសន្ថរំ ។ ២ ឱ. ម. សន្ថតន្តិ បាឋោ ន ទិស្សតិ ។ ៣ ឱ. ឧទកមណឹ ។

ទើបព្រះមានព្រះភាគស្តេចទៅដល់បាដលិគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ ពួកឧបាសកនៅក្នុងបាដលិគ្រាម បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់បាដលិគ្រាមហើយ ។ ទើបពួកឧបាសកនៅក្នុងបាដលិគ្រាម នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ពួកឧបាសកនៅក្នុងបាដលិគ្រាម លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទទួលផ្ទះសម្នាក់របស់យើងខ្ញុំព្រះអង្គទាំងឡាយ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ ឯពួកឧបាសកនៅក្នុងបាដលិគ្រាមបានដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចូលទៅកាន់ផ្ទះសម្នាក់ លុះចូលទៅដល់ហើយ ក៏ក្រាលផ្ទះសម្នាក់ ឲ្យមានកម្រាលក្រាលសព្វកន្លែង ហើយតាក់តែងអាសនៈ តម្កល់ក្អមទឹក រៀបចំប្រទីបប្រេង រួចចូលទៅគាល់ព្រះមានព្រះភាគ

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ បាដលិគាមិយា ឧបាសកា ភគវន្តំ ឯតទវោចុំ សព្វសន្ថរិតំ សន្ថតំ ភន្តេ អាវសថាគារំ អាសនានិ បញ្ញត្តានិ ឧទកមណិកោ បតិដ្ឋាបិតោ តេលប្បទីបោ អារោបិតោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។ អថខោ ភគវា បុព្វណ្ហសមយំ[១] និវាសេត្វា បត្តចីវរំ អាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន អាវសថាគារំ តេនុបសង្កមិ ឧបសង្កមិត្វា បាទេ បក្ខាលេត្វា អាវសថាគារំ បវិសិត្វា មជ្ឈិមំ ថម្ភំ និស្សាយ បុរត្ថាភិមុខោ និសីទិ ។ ភិក្ខុសង្ឃោបិ ខោ បាទេ បក្ខាលេត្វា អាវសថាគារំ បវិសិត្វា បច្ឆិមភិត្តឹ និស្សាយ បុរត្ថាភិមុខោ និសីទិ ភគវន្តញ្ញេវ បុរក្ខត្វា ។ បាដលិគាមិយាបិ ខោ ឧបាសកា បាទេ បក្ខាលេត្វា អាវសថាគារំ បវិសិត្វា បុរត្ថិមភិត្តឹ និស្សាយ បច្ឆិមាភិមុខា និសីទឹសុ ភគវន្តញ្ញេវ បុរក្ខត្វា ។

---

១ ឱ. បុព្វណ្ហសមយន្តិ បាឋោ ន ទិស្សតិ ។ ម. សាយណ្ហសមយំ ។

លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏ឋិតនៅក្នុងទីដ៏សមគួរ ។ ពួកឧបាសកនៅក្នុងបាដលិគ្រាម លុះឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ផ្ទះសម្នាក់ យើងខ្ញុំព្រះអង្គ បានក្រាលកម្រាលសព្វកន្លែងហើយ អាសនៈទាំងឡាយ យើងខ្ញុំព្រះអង្គបានតាក់តែងហើយ ក្អមទឹក យើងខ្ញុំព្រះអង្គបានតម្កល់ទុកហើយ ប្រទីបប្រេង យើងខ្ញុំព្រះអង្គបានរៀបចំហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្គាល់នូវកាលគួរក្នុងកាលឥឡូវនេះ ។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ស្បង់និងបាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់ស្ដេចចូលទៅកាន់ផ្ទះសម្នាក់ព្រមដោយភិក្ខុសង្ឃ លុះស្ដេចទៅដល់ហើយ ទ្រង់ជម្រះព្រះបាទា ហើយស្ដេចចូលទៅកាន់ផ្ទះសម្នាក់ ទ្រង់គង់បែរព្រះភក្ត្រទៅទិសខាងកើត ផ្អែកនឹងសសរកណ្ដាល ។ ឯភិក្ខុសង្ឃ ក៏លាងបាទារួចចូលទៅកាន់ផ្ទះសម្នាក់ ហើយអង្គុយបែរមុខទៅទិសខាងកើត អែបនឹងជញ្ជាំងខាងលិច គាល់ព្រះមានព្រះភាគ ។ ពួកឧបាសកនៅក្នុងបាដ-លិគ្រាម បានលាងជើងរួចហើយ ចូលទៅកាន់ផ្ទះសម្នាក់អង្គុយបែរមុខទៅទិសខាងលិច អែបនឹងជញ្ជាំងខាងកើត គាល់ព្រះមានព្រះភាគដែរ ។

[៧៩] អថខោ ភគវា ចាដលិគ្គាមិយេ ឧចាសកេ អាមន្តេសិ បញ្ចិមេ គហបតយោ អាទីនវា ទុស្សីលស្ស សីលវិបត្តិយា ។ កតមេ បញ្ច ។ ឥធ គហបតយោ ទុស្សីលោ សីលវិបន្នោ បមាទាធិករណំ មហតឹ ភោគជានឹ និគច្ឆតិ អយំ បឋមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលស្ស សីលវិបន្នស្ស ចាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ទុតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិបន្នោ យញ្ញទេវ[1] បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ អវិសារទោ ឧបសង្កមតិ មង្កុភូតោ អយំ តតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិបន្នោ សម្មូឡ្ហោ កាលំ ករោតិ អយំ ចតុត្ថោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិបន្នោ

---

១ ឱ. ម. មយំ យទេវ ។

[៧៩] លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់នឹងពួកឧបាសក អ្នកបាដលិគ្រាមថា ម្នាលគហបតីទាំងឡាយ ទោសនៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិនេះមាន ៥ ប្រការ ។ ទោសទាំង ៥ ប្រការនោះ តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ក្នុងលោកនេះ តែងដល់នៅសេចក្តីវិនាសនៃភោគៈដ៏ធំ មានសេចក្តីប្រមាទជាហេតុ នេះជាទោសទី ១ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ មួយទៀត កិត្តិសព្ទដ៏អាក្រក់នៃបុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងផ្សាយទៅសព្វទិស នេះជាទោសទី ២ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ទោះចូលទៅរកបរិសទ្យណា ៗ គឺខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណ-បរិសទ្យក្តី ជាអ្នកមិនក្លៀវក្លា ចូលទៅទាំងអៀនអន់ នេះជាទោសទី ៣ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ជាបុគ្គលវង្វេងធ្វើមរណកាល នេះជាទោសទី ៤ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល

កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ អយំ បញ្ចមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ ឥមេ ខោ គហបតយោ បញ្ច អា-ទីនវា ទុស្សីលស្ស សីលវិបត្តិយា ។

[៨០] បញ្ចិមេ គហបតយោ អានិសំសា សីលវ-តោ សីលសម្បទាយ ។ កតមេ បញ្ច ។ ឥធ គហ-បតយោ សីលវា សីលសម្បន្នោ អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ អយំ បឋមោ អានិសំ-សោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហ-បតយោ សីលវតោ សីលសម្បន្នស្ស កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ទុតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហបត-យោ សីលវា សីលសម្បន្នោ យញ្ញទេវ បរិសំ ឧប-សង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ

លុះបែកធ្លាយរាងកាយទៅ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក នេះជាទោសទី ៥ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ ទោសនៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ មាន ៥ ប្រការនេះឯង ។

[៨០] ម្នាលគហបតីទាំងឡាយ អានិសង្សនៃបុគ្គល មានសីលនៃសីលសម្បទានេះ មាន ៥ ប្រការ ។ អានិសង្ស ៥ ប្រការនោះ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលមានសីល ដល់ព្រមដោយសីល ក្នុងលោកនេះ រមែងបានគំនរទ្រព្យដ៏ធំ ដែលមានសេចក្តីមិនប្រមាទជាហេតុ នេះជាអានិសង្សទី ១ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីទាំងឡាយ មួយទៀត កិត្តិសព្ទដ៏ពីរោះរបស់បុគ្គលមានសីលដល់ព្រមដោយសីល តែងផ្សាយទៅសព្វទិស នេះជាអានិសង្សទី ២ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល ទោះចូលទៅរកបរិសទ្យណា ៗ គឺ ខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ជាបុគ្គលមានសេចក្តីក្លៀវក្លា

ឧបសង្កមតិ អមង្កុភូតោ អយំ តតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហបតយោ សីលវា សីលសម្បន្នោ អសម្មូឡ្ហោ កាលំ ករោតិ អយំ ចតុត្ថោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហបតយោ សីលវា សីលសម្បន្នោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ អយំ បញ្ចមោ អានិសំសោ សីលវតោ សីលសម្បទាយ ។ ឥមេ ខោ គហបតយោ បញ្ច អានិសំសា សីលវតោ សីលសម្បទាយាតិ ។

[៨១] អថខោ ភគវា បាដលិគាមិយេ ឧបាសកេ ពហុទេវ រត្តឹ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧយ្យោជេសិ អភិក្កន្តា ខោ គហបតយោ រត្តិ យស្សទានិ តុម្ហេ[១] កាលំ មញ្ញថាតិ ។ ឯវំ ភន្តេតិ ខោ បាដលិគាមិយា ឧបាសកា ភគវតោ បដិស្សុត្វា

១ ឱ. តុម្ហេតិ បាឋោ ន ទិស្សតិ ។

ចូលទៅដោយការមិនអៀនអន់ នេះជាអានិសង្សទី ៣ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល ជាបុគ្គលមិនវង្វេងធ្វើមរណកាល នេះជាអានិសង្សទី ៤ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងកើតក្នុងលោកគឺមនុស្ស សុគតិ និងឋានសួគ៌ នេះជាអានិសង្សទី ៥ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីទាំងឡាយ អានិសង្សនៃបុគ្គលមានសីល នៃសីលសម្បទា មាន ៥ ប្រការនេះឯង ។

[៨១] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ញុំាងពួកឧបាសកអ្នកបាដលិគ្រាម ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យក្លៀវក្លា ឲ្យរីករាយដោយធម្មីកថា អស់រាត្រីជាច្រើន ហើយទ្រង់បញ្ជូនទៅដោយព្រះពុទ្ធដីកាថា ម្នាលគហបតីទាំងឡាយ រាត្រីអស់ហើយ ចូរអ្នកទាំងឡាយសម្គាល់នូវកាលដ៏សមគួរ ក្នុងកាលឥឡូវនេះចុះ ។ ពួកឧបាសកអ្នកបាដលិគ្រាមទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ

ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។ អថខោ ភគវា អចិរបក្កន្តេសុ បាដលិគ្គាមិយេសុ ឧបាសកេសុ សុញ្ញាគារំ បាវិសិ ។

[៨២] តេន ខោ[១] បន សមយេន សុនីធវស្សការា មគធមហាមត្តា បាដលិគ្គាមេ នគរំ មាបេន្តិ វជ្ជីនំ បដិពាហាយ ។ តេន ខោ បន សមយេន សម្ពហុលា ទេវតាយោ សហស្សេវ[២] បាដលិគ្គាមេ វត្ថូនិ បរិគ្គណ្ហន្តិ ។ យស្មឹ បទេសេ មហេសក្ខា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មហេសក្ខានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យម្ហិ[៣] បទេសេ មជ្ឈិមា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មជ្ឈិមានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យម្ហិ បទេសេ នីចា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ នីចានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ អទ្ទសា

១ ម. ខោសទ្ទោ នត្ថិ ។ ២ ឱ. សហស្សស្សេវ ។ ៣ ឱ. ម. យស្មឹ ។

ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចេញទៅ ។ កាលដែលពួកឧបាសកអ្នកបាដលិគ្រាម ចេញទៅមិនយូរប៉ុន្មាន ព្រះមានព្រះភាគ ក៏ទ្រង់ស្តេចចូលទៅកាន់ផ្ទះស្ងាត់ ។

[៨២] សម័យនោះឯង សុនីធៈ និងវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេចក្នុងដែនវជ្ជី ។ សម័យនោះឯង ទេវតាច្រើនពួក ចំនួនមួយពាន់ ៗ គន់មើលទីដីសង់ផ្ទះ ក្នុងបាដលិគ្រាម ។ ពួកទេវតាដែលមានស័ក្តិធំ គន់មើលទីដីសង់ផ្ទះ ក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យទាំងឡាយ ដែលមានស័ក្តិធំ ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ពួកទេវតាដែលមានស័ក្តិយ៉ាងកណ្តាល គន់មើលទីដីសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យទាំងឡាយ ដែលមានស័ក្តិយ៉ាងកណ្តាល ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះ ពួកទេវតាដែលមានស័ក្តិទាប គន់មើលទីដីសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យទាំងឡាយ ដែលមានស័ក្តិទាប ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ។ ព្រះមានព្រះភាគ

ខោ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន តា ទេវតាយោ សហស្សេវ បាដលិគ្គាមេ វត្ថូនិ បរិគ្គណ្ហន្តិយោ ។ អថខោ ភគវា រត្តិយា បច្ចូសសមយេ បច្ចុដ្ឋាយ អាយស្មន្តំ អានន្ទំ អាមន្តេសិ កោ នុ ខោ អានន្ទ បាដលិគ្គាមេ នគរំ មាបេតីតិ ។ សុនីធវស្សការា ភន្តេ មគធមហាមត្តា បាដលិគ្គាមេ នគរំ មាបេន្តិ វជ្ជីនំ បដិពាហាយាតិ ។ សេយ្យថាបិ អានន្ទ ទេវេហិ តាវត្តឹសេហិ សទ្ធឹ សក្កោ មន្តេត្វា ឯវមេវ ខោ អានន្ទ សុនីធវស្សការា មគធមហាមត្តា បាដលិគ្គាមេ នគរំ មាបេន្តិ វជ្ជីនំ បដិពាហាយ ឥធាហំ អានន្ទ អទ្ទសំ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សម្ពហុលា ទេវតាយោ សហស្សេវ បាដលិគ្គាមេ វត្ថូនិ បរិគ្គណ្ហន្តិយោ យស្មឹ បទេសេ មហេសក្ខា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មហេសក្ខានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យស្មឹ បទេសេ មជ្ឈិមា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ

បានទតឃើញពួកទេវតាទាំងនោះ ចំនួនមួយពាន់ ៗ កំពុងគន់មើលទីដីសង់ផ្ទះ ក្នុងបាដលិគ្រាម ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សសាមញ្ញ ។ ទើបព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាលអានន្ទ អ្នកណាហ្ន៎ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ។ ព្រះអានន្ទមានអាយុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សុនីធៈនិងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេចវជ្ជី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សក្កទេវរាជបានប្រឹក្សាជាមួយនឹងពួកទេវតា ដែលឋិតនៅក្នុងឋានតាវត្តិង្ស យ៉ាងណាមិញ ម្នាលអានន្ទ សុនីធៈនិងវស្សការព្រាហ្មណ៍ជាមហាមាត្យ ក្នុងដែនមគធៈ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេចវជ្ជី ក៏ដូច្នោះដែរ ម្នាលអានន្ទ ក្នុងទីនេះ តថាគតបានឃើញពួកទេវតាជាច្រើន ទាំងពាន់ ៗ កំពុងគន់មើលទីដីសង់ផ្ទះ ក្នុងបាដលិគ្រាម ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សសាមញ្ញ ពួកទេវតាដែលមានស័ក្តិធំ គន់មើលទីដីសង់ផ្ទះ ក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យទាំងឡាយ ដែលមានស័ក្តិធំ ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ពួកទេវតាដែលមានស័ក្តិយ៉ាងកណ្តាល គន់

មជ្ឈិមានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យម្ហិ បទេសេ នីចា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ នីចានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ យាវតា អានន្ទ អរិយំ អាយតនំ យាវតា វណិប្បថោ ឥទំ អគ្គនគរំ ភវិស្សតិ បាដលិបុត្តំ បុដភេទនំ បាដលិបុត្តស្ស ខោ អានន្ទ តយោ អន្តរាយា ភវិស្សន្តិ អគ្គិតោ វា ឧទកតោ វា មិថុភេទា វាតិ ។

[៨៣] អថខោ សុនីធវស្សការា មគធមហាមត្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ សុ-នីធវស្សការា មគធមហាមត្តា ភគវន្តំ ឯតទវោចុំ អធិវា-

មើលទីដីសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យទាំង-ឡាយ ដែលមានស័ក្តិយ៉ាងកណ្តាល ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះ ពួកទេវតាដែលមានស័ក្តិទាប គន់មើលទីដីសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យទាំងឡាយ ដែលមានស័ក្តិទាប ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះ ម្នាលអានន្ទ ទីប្រជុំនៃមនុស្សជាអរិយៈ មាននៅកំណត់ត្រឹមណា ផ្លូវឈ្មួញមាននៅកំណត់ត្រឹមណា នគរនេះ នឹងបានជានគរច្បុំច្បើង មានឈ្មោះថា ក្រុងបាដលិបុត្រ ហាក់ជាកន្ទេងសម្រាប់ស្រាយបង្វេចទ្រព្យ កំណត់ត្រឹមណោះ ម្នាលអានន្ទ តែក្រុងបាដលិបុត្រ នឹងមានសេចក្តីអន្តរាយ ៣ យ៉ាង គឺអន្តរាយដោយភ្លើង ១ ដោយទឹក ១ ដោយការបែកគ្នា ១ ។

[៨៣] គ្រានោះ សុនីធៈនិងវស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏បានឋិតនៅក្នុងទីដ៏សមគួរ ។ សុនីធៈនិងវស្សការព្រាហ្មណ៍ជាមហាមាត្យ ក្នុងដែនមគធៈ លុះឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ

សេតុ នោ ភន្តេ[១] ភវំ គោតមោ អជ្ជតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សុនីធវស្សការា មគធមហាមត្តា ភគវតោ អធិវាសនំ វិទិត្វា យេន សកោ អាវសថោ តេនុបសង្កមឹសុ ឧបសង្កមិត្វា សកេ អាវសថេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសុំ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន សុនីធវស្សការានំ មគធមហាមត្តានំ អាវសថោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សុនីធវស្សការា មគធមហាមត្តា ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសុំ សម្បវារេសុំ ។ អថខោ សុនីធវស្សការា មគធមហាមត្តា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ

---

១ ឱ. ភន្តេសទ្ទោ នត្ថិ ។

ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះគោតមដ៏ចម្រើន ព្រមដោយភិក្ខុសង្ឃ ទទួលភត្តរបស់យើងខ្ញុំទាំងឡាយ ដើម្បីឆាន់ក្នុងថ្ងៃនេះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ លុះសុនីធៈនិងវស្សការ-ព្រាហ្មណ៍ជាមហាមាត្យ ក្នុងដែនមគធៈដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួន លុះចូលទៅដល់ហើយ បានតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ក្នុងលំនៅរបស់ខ្លួន រួចហើយទើបឲ្យគេក្រាបទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ ប្រដាប់ដោយបាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យហើយ ស្តេចចូលទៅកាន់លំនៅរបស់សុនីធៈ និងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលបម្រុង ។ ទើបសុនីធៈនិងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ត្រាតែភិក្ខុសង្ឃហាមឃាត់ ។ លំដាប់នោះ សុនីធៈនិងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ (កំណត់ដឹងថា) ព្រះមានព្រះភាគទ្រង់សោយស្រេចហើយ ដាក់ព្រះហស្តចុះអំពីបាត្រហើយ ក៏កាន់យកអាសនៈទាប

១៩១

មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ អនុមោទនគាថា

គហេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ សុនីធវស្សការេ មគធមហាមត្តេ ភគវា ឥមាហិ គាថាហិ អនុមោទិ

[៨៤] យស្មឹ បទេសេ កប្បេតិ
វាសំ បណ្ឌិតជាតិយោ[១]
សីលវន្តេត្ថ ភោជេត្វា
សញ្ញតេ ព្រហ្មចារិនោ[២] ។
យា តត្ថ ទេវតា អាសុំ[៣]
តាសំ ទក្ខិណមាទិសេ
តា បូជិតា បូជយន្តិ[៤]
មានិតា មានយន្តិ នំ ។
តតោ នំ អនុកម្បន្តិ
មាតា បុត្តំវ ឱរសំ
ទេវតានុកម្បិតោ បោសោ
សទា ភទ្រានិ បស្សតីតិ ។

១ ឱ. បណ្ឌិតជាតិកោ ។ ២ ឱ. ព្រហ្មចារយោ ។ ម. ព្រហ្មចរិយេ ។ ៣ ឱ. អាសុ ។ ៤ ម. បូជិតា បូជយន្តិ នំ ។

មួយ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសុនីធៈនិងវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគក៏ទ្រង់អនុមោទនា ដោយគាថាទាំងឡាយនេះថា

[៨៤] បុគ្គលជាបណ្ឌិតសម្រេចទីនៅក្នុងប្រទេសណា បានញុំាងបុគ្គលអ្នកមានសីលទាំងឡាយ អ្នកសង្រួម អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ឲ្យបរិភោគភោជនាហារក្នុងប្រទេសនុ៎ះ ។ បានឧទ្ទិសទក្ខិណាទាន ដល់ពួកទេវតាដែលឋិតនៅក្នុងប្រទេសនោះ ពួកទេវតាទាំងនោះ ដែលបណ្ឌិតបានបូជាហើយ ក៏តែងបូជាតបវិញ ដែលបណ្ឌិតរាប់អានហើយ ក៏តែងរាប់អានបណ្ឌិតនោះវិញ ។ តែងអនុគ្រោះបណ្ឌិតនោះ ព្រោះទក្ខិណានុប្បទាននោះ ដូចជាមាតាអនុគ្រោះកូន ដែលកើតអំពីទ្រូង បុរសដែលទេវតាអនុគ្រោះហើយ រមែងជួបប្រទះនូវសេចក្ដីចម្រើនសព្វកាល ។

[៨៤] អថខោ ភគវា សុនីធវស្សការេ មគធមហាមត្តេ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ តេន ខោ បន សមយេន សុនីធវស្សការា មគធមហាមត្តា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា ហោន្តិ យេនជ្ជ សមណោ គោតមោ ទ្វារេន និក្ខមិស្សតិ តំ គោតមទ្វារំ នាម ភវិស្សតិ យេន តិត្ថេន គង្គានទី[១] តរិស្សតិ តំ គោតមតិត្ថំ នាម ភវិស្សតីតិ ។ អថខោ ភគវា យេន ទ្វារេន និក្ខមិ តំ គោតមទ្វារំ នាម អហោសិ ។ អថខោ ភគវា យេន គង្គានទី តេនុបសង្កមិ ។ តេន ខោ បន សមយេន គង្គានទី បូរា ហោតិ សមតិត្តិកា កាកបេយ្យា ។ អប្បេកច្ចេ មនុស្សា នាវំ បរិយេសន្តិ អប្បេកច្ចេ ឧឡុម្បំ បរិយេសន្តិ អប្បេកច្ចេ កុល្លំ ពន្ធន្តិ ចារាចារំ[២] គន្តុកាមា ។ អថខោ ភគវា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ គង្គាយ នទិយា ឱរិមេ តីរេ អន្តរហិតោ ចារិមេ តីរេ បច្ចុដ្ឋាសិ សទ្ធឹ ភិក្ខុសង្ឃេន ។

---

១ ឱ. គង្គំ នទឹ ។ ២ ឱ. អបរាបរំ ។

[៨៥] លុះព្រះមានព្រះភាគ ទ្រង់អនុមោទនា ដោយគាថាទាំងនេះ ដល់សុនីធៈនិងវស្សការព្រាហ្មណ៍ ដែលជាមហាមាត្យក្នុងដែនមគធៈ ហើយ ទ្រង់ក្រោកអំពីអាសនៈចេញទៅ ។ សម័យនោះឯង សុនីធៈនិងវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ បានដើរតាមព្រះមានព្រះភាគអំពីខាងក្រោយ ៗ ដោយតាំងចិត្តថា ថ្ងៃនេះ ព្រះសមណ-គោតម ទ្រង់ស្ដេចចេញតាមទ្វារណា ទ្វារនោះនឹងបានឈ្មោះថា គោតមទ្វារ ទ្រង់ស្ដេចឆ្លងទន្លេគង្គា ត្រង់កំពង់ណា កំពង់នោះនឹងបានឈ្មោះថា គោតមតិត្ថៈ ។ ព្រះមានព្រះភាគ ទ្រង់ស្ដេចចេញតាមទ្វារណា ទ្វារនោះក៏បានឈ្មោះថា គោតមទ្វារ ចាប់ដើមតាំងអំពីនោះមក ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្ដេចចូលទៅត្រង់ទន្លេគង្គានោះ ។ សម័យនោះឯង ទន្លេគង្គាកំពុងពេញប្រៀប ល្មមសត្វក្អែកទំលើមាត់ច្រាំងឱនផឹកទឹកបាន ។ មនុស្សទាំងឡាយ ដែលប្រាថ្នានឹងឆ្លងអំពីត្រើយម្ខាង ទៅកាន់ត្រើយម្ខាង ពួកខ្លះ ក៏ស្វែងរកទូក ពួកខ្លះក៏ស្វែងរកផែ ពួកខ្លះក៏ចងក្បូន ។ លំដាប់នោះ ព្រះមានព្រះភាគ ស្រាប់តែបាត់ព្រះអង្គអំពីត្រើយទន្លេគង្គាខាងអាយ ទៅប្រាកដព្រះអង្គក្នុងត្រើយខាងនាយ ព្រមទាំងភិក្ខុសង្ឃ ដូចជាបុរសដែលមានកម្លាំង លាកំភួនដៃដែលបត់ហើយ ឬបត់កំភួនដៃដែលលាហើយ ។

អទ្ធសា ខោ ភគវា មនុស្សេ អប្បេកច្ចេ នាវំ បរិយេសន្តេ អប្បេកច្ចេ ឧឡុម្បំ បរិយេសន្តេ អប្បេកច្ចេ កុល្លំ ពន្ធន្តេ ចារា បារំ គន្តុកាមេ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យេ តរន្តិ អណ្ណវំ សរំ
សេតុំ កត្វាន វិសជ្ជ បល្លលានិ
កុល្លំ ជនោ ច ពន្ធតិ[១]
តិណ្ណា មេធាវិនោ ជនាតិ ។

ពុទ្ធភាណវារំ បឋមំ ។

[៨៦] អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន កោដិគ្គាមោ តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន កោដិគ្គាមោ តទវសរិ ។ តត្រ សុទំ ភគវា កោដិគ្គាមេ វិហរតិ ។ តត្រ ខោ ភគវា

---

១ ឱ. ម. កុល្លំ ហិ ជនោ បពន្ធតិ ។

ព្រះមានព្រះភាគ ទ្រង់ទតឃើញមនុស្សទាំងនោះ ពួកខ្លះកំពុងស្វែងរកទូក ពួកខ្លះកំពុងស្វែងរកផែ ពួកខ្លះកំពុងចងក្បូន បំណងនឹងឆ្លងអំពីត្រើយម្ខាង ទៅត្រើយម្ខាង ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវហេតុនុ៎ះហើយ ក៏ទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ជនទាំងឡាយណា ឆ្លងទន្លេនិងស្ទឹង គឺតណ្ហា ដែលជ្រាលជ្រៅធំទូលាយបាន ជនទាំងឡាយនោះ រមែងធ្វើស្ពានគឺអរិយមគ្គ លះបង់ទីទំនាបដែលពេញដោយទឹក ឆ្លងផុតទៅបាន ចំណែកជនជម្ពូតា លុះតែចងក្បូន ទើបឆ្លងទៅបាន ឯពួកជនជាអ្នកប្រាជ្ញ (មិនបាច់ក្បូន) ក៏ឆ្លងទៅបាន ។

ចប់ ពុទ្ធភាណវារៈទី ១ ។

[៨៦] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់កោដិគ្រាម ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់កោដិគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងកោដិគ្រាមនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ

ភិក្ខូ អាមន្តេសិ ចតុន្នំ ភិក្ខវេ អរិយសច្ចានំ អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស ភិក្ខវេ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ ទុក្ខសមុទយស្ស ភិក្ខវេ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ ទុក្ខនិរោធស្ស ភិក្ខវេ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ ទុក្ខនិរោធគាមិនិយា បដិបទាយ ភិក្ខវេ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។

ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងសង្សារវដ្ត) អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសច្ចទាំង ៤ ។ អរិយសច្ចទាំង ៤ នោះ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខសមុទយអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខនិរោធអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

តយិទំ ភិក្ខវេ ទុក្ខំ អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខ-សមុទយោ អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខនិរោធោ អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ឧច្ឆិន្នា ភវតណ្ហា ខីណា ភវនេត្តិ នត្ថិទានិ បុនព្ភវោតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[៨៧] ចតុន្នំ អរិយសច្ចានំ
យថាភូតំ អទស្សនា
សំសរិតំ[១] ទីឃមទ្ធានំ
តាសុ តាស្វេវ[២] ជាតិសុ ។
តានិ ឯតានិ ទិដ្ឋានិ
ភវនេត្តិ សមូហតា
ឧច្ឆិន្នំ មូលំ ទុក្ខស្ស
នត្ថិទានិ បុនព្ភវោតិ ។

---

១ ឱ. សំសិតំ ។ ២ ឱ. តាសេវ ។

ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចនោះឯង ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខសមុទយអរិយសច្ច ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធអរិយសច្ច ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា គឺសេចក្តីប្រាថ្នាក្នុងភពក៏សូន្យទៅ ខ្សែគឺតណ្ហាដែលអាចនាំសត្វអំពីភពមួយទៅភពមួយ ក៏អស់ទៅ ភពថ្មីក្នុងកាលឥឡូវនេះ ក៏មិនមានឡើយ ។ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះហើយ ព្រះសុគតលុះត្រាស់ពាក្យនេះហើយ ព្រះសាស្តាទ្រង់ត្រាស់ពាក្យដូច្នេះដទៃ អំពីពាក្យនោះថា

[៨៧] ការត្រាច់រង្គាត់ទៅអស់កាលជាអង្វែង ក្នុងជាតិនោះ ៗ
ឯង ក៏ព្រោះតែមិនបានឃើញនូវអរិយសច្ចទាំង ៤ តាមពិត ។
ឯអរិយសច្ចទាំង ៤ នោះ បើបុគ្គលបានឃើញហើយ ខ្សែ
គឺតណ្ហា ដែលអាចនាំសត្វអំពីភពមួយទៅភពមួយ ក៏ដាច់
ហើយ ឫសគល់របស់ទុក្ខក៏ពុករលួយហើយ ភពថ្មីទៀតក្នុង
កាលឥឡូវនេះ មិនមានឡើយ ។

[៨៨] តត្របិ សុទំ ភគវា កោដិគ្គាមេ វិហរន្តោ ឯតទេវ ពហុលំ ភិក្ខូនំ ធម្មឹ កថំ ករោតិ ឥតិ សីលំ ឥតិ សមាធិ ឥតិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

[៨៩] អថខោ ភគវា កោដិគ្គាមេ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន នាទិកា[១] តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន នាទិកា តទវសរិ ។ តត្រ[២] សុទំ ភគវា នាទិកេ វិហរតិ គិញ្ជកាវសថេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ

---

១ ម. នាតិកា ។ ២ ម. តត្របិ ។

[៨៨] បានឮថា កាលព្រះមានព្រះភាគ គង់នៅក្នុងកោដិគ្រាម នោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ចំពោះភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃ គឺ កាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[៨៩] លុះព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកោដិគ្រាម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុ មកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់នាទិកគ្រាម ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់នាទិកគ្រាមនោះ ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងផ្ទះសម្នាក់ដែលធ្វើដោយឥដ្ឋ ក្នុងនាទិកគ្រាមនោះ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

១៩៧



អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សាឡ្ហោ ណាម ភន្តេ ភិក្ខុ ណាតិកេ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោ នន្ទា ណាម ភន្តេ ភិក្ខុនី ណាតិកេ កាលកតា តស្សា កា គតិ កោ អភិសម្បរាយោ សុទត្តោ ណាម ភន្តេ ឧបាសកោ ណាតិកេ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោ សុជាតា ណាម ភន្តេ ឧបាសិកា ណាតិកេ កាលកតា តស្សា កា គតិ កោ អភិសម្បរាយោ កកុធោ ណាម ភន្តេ ឧបាសកោ ណាតិកេ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោ ការឡិម្ភោ[១] ណាម ភន្តេ ឧបាសកោ ។ បេ ។ និកដោ ណាម ភន្តេ ឧបាសកោ ។ បេ ។ កដិស្សហោ[២] ណាម ភន្តេ ឧបាសកោ ។ បេ ។ តុដ្ឋោ ណាម ភន្តេ ឧបាសកោ ។ បេ ។ សន្តុដ្ឋោ ណាម ភន្តេ ឧបាសកោ ។ បេ ។

១ ឱ. កាលិង្គោ ។ ម. កាឡិម្ពោ ។ ២ ឱ. កដិស្សកោ ។

ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះអានន្ទមានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះសាឡ្ហៈធ្វើមរណៈកាលក្នុងនាទិកគ្រាម គតិរបស់សាឡ្ហភិក្ខុនោះ ដូចម្តេច បរលោក ដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីឈ្មោះនន្ទា ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ភិក្ខុនីនោះ ដូចម្តេច បរលោក ដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះសុទត្ត ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសកនោះ ដូចម្តេច បរលោក ដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាឈ្មោះសុជាតា ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសិកានោះ ដូចម្តេច បរលោក ដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះកកុធៈ ធ្វើមរណៈកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសកនោះ ដូចម្តេច បរលោក ដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះការឡិម្ភៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះនិកដៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះកដិស្សហៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះតុដ្ឋៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះសន្តុដ្ឋៈ ។ បេ ។

ភដោ[១] នាម ភន្តេ ឧបាសកោ ។ បេ ។ សុភដោ[២] នាម ភន្តេ ឧបាសកោ នាតិកេ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។ សាឡ្ហោ អានន្ទ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ នន្ទា អានន្ទ ភិក្ខុនី បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនី អនាវត្តិធម្មា តស្មា លោកា សុទត្តោ អានន្ទ ឧបាសកោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សតិ សុជាតា អានន្ទ ឧបាសិកា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនា កកុធោ អានន្ទ ឧបាសកោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា

---

១ ឱ. ភទ្ទោ ។ ២ សុភទ្ទោ ។

បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះភជៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះសុភជៈ ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសកនោះ ដូចម្តេច បរលោក ដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ សាឡ្ហភិក្ខុបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ក្នុងបច្ចុប្បន្ន ម្នាលអានន្ទ នន្ទាភិក្ខុនីជាឱបបាតិកសត្វ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម (អនាគាមី) ម្នាលអានន្ទ សុទត្តឧបាសក ជាសកទាគាមី ត្រឡប់មកកាន់លោកនេះម្តងទៀត នឹងធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ដោយមានរាគៈ ទោសៈ មោហៈ ស្រាលស្តើង ម្នាលអានន្ទ សុជាតាឧបាសិកា ជាសោតាបន្នបុគ្គល ជាបុគ្គលលែងធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងទៅខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ម្នាលអានន្ទ កកុធៈឧបាសក ជាឱបបាតិកសត្វ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម

ការឡិម្ភោ អានន្ទ ឧបាសកោ ។ បេ ។ និកដោ អានន្ទ ឧបាសកោ ។ កដិស្សហោ អានន្ទ ឧបាសកោ ។ តុដ្ឋោ អានន្ទ ឧបាសកោ ។ សន្តុដ្ឋោ អានន្ទ ឧបាសកោ ។ ភដោ អានន្ទ ឧបាសកោ ។ សុភដោ អានន្ទ ឧបាសកោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា បរោបញ្ញាស[១] អានន្ទ នាទិកេ ឧបាសកា កាលកតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា នាតិកា[២] នវុតិ អានន្ទ នាទិកេ ឧបាសកា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ ឆសាតិរេកានិ[៣] អានន្ទ បញ្ចសតានិ នាទិកេ ឧបាសកា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា

---

១ ម. បរោបញ្ញាសំ ។ ២ ឱ. ម សាធិកា ។ ៣ ឱ. ម. សាតិរេកានិ ។

ម្នាលអានន្ទ ការឡិម្ពឧបាសក ។ បេ ។ ម្នាលអានន្ទ និកដឧបាសក ។ ម្នាលអានន្ទ កដិស្សហឧបាសក ។ ម្នាលអានន្ទ តុដ្ឋឧបាសក ។ ម្នាលអានន្ទ សន្តុដ្ឋឧបាសក ម្នាលអានន្ទ ភដឧបាសក ។ ម្នាលអានន្ទ សុភដឧបាសក ជាឱបបាតិកសត្វ បរិនិព្វាន ក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម ម្នាលអានន្ទ ពួកឧបាសកជាង ៥០ នាក់ ដែលធ្វើមរណកាលក្នុងនាទិក-គ្រាម សុទ្ធតែជាឱបបាតិកសត្វ បរិនិព្វាន ក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម ម្នាលអានន្ទ ពួកឧបាសក ៩៦ នាក់ ដែលធ្វើមរណកាល ក្នុងនាទិកគ្រាម សុទ្ធតែជាសកទាគាមី ត្រឡប់មកកាន់លោកនេះម្តងទៀត នឹងធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ មានរាគៈ ទោសៈ មោហៈ ស្រាលស្តើង ម្នាលអានន្ទ ពួកឧបាសក ៥១០ នាក់ ដែលធ្វើមរណកាល ក្នុងនាទិក-គ្រាម សុទ្ធតែជាសោតាបន្នបុគ្គល ជាបុគ្គលលែងធ្លាក់ទៅ ក្នុងអបាយ

និយតា សម្ពោធិបរាយណា អនច្ឆរិយំ ខោ បនេតំ អានន្ទ យំ មនុស្សភូតោ កាលំ ករេយ្យ តស្មិំ តស្មិំ ខោ[១] កាលកតេ តថាគតំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆិស្សថ វិហេសា វេសា អានន្ទ តថាគតស្ស តស្មាតិហានន្ទ ធម្មាទាសំ នាម ធម្មបរិយាយំ ទេសេស្សាមិ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិ[២] ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ កតមោ ច សោ អានន្ទ ធម្មាទាសោ ធម្មបរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ឥធានន្ទ អរិយសាវកោ

១ ឱ. ចេ ។ ម. យេវ ។ ២ ឱ. ខិណតិរច្ឆានយោនិយោ ។

ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ម្នាលអានន្ទ សត្វដែលជាមនុស្ស ធ្វើមរណកាលដោយហេតុណា ហេតុនោះ មិនជាអស្ចារ្យទេ ព្រោះកាលបើមនុស្សនោះ ៗ ធ្វើមរណកាលហើយ អ្នកទាំងឡាយមុខជានឹងមករកតថាគត ហើយសួរនូវដំណើរនុ៎ះ ម្នាលអានន្ទ នេះជាសេចក្តីលំបាកដល់តថាគតណាស់ ម្នាលអានន្ទ ព្រោះហេតុនោះ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើប្រាថ្នានឹងព្យាករ ក៏គប្បីព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិសយហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅក្នុងខាងមុខដូច្នេះ តថាគតនឹងសម្តែងធម្មបរិយាយនោះ ឈ្មោះធម្មាទាសៈ (ធម៌ដូចកញ្ចក់ឆ្លុះ) ម្នាលអានន្ទ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើត្រូវការនឹងព្យាករ ក៏គប្បីព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅក្នុងខាងមុខដូច្នេះ ចុះធម្មបរិយាយឈ្មោះធម្មាទាសៈនោះ តើដូចម្តេច ម្នាលអានន្ទ អរិយសាវ័ក

ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ

ក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគនោះ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់ដល់នូវសុន្ទរស្ថាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំង-ឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀតដូច្នេះ អរិយសាវ័កប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយប្រពៃ ជាធម៌ដែលអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរនឹងហៅថា អ្នកចូរចូលមកមើលដូច្នេះបាន ជាធម៌ដែលអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងដោយជាក់ច្បាស់ក្នុងចិត្តនៃខ្លួនដូច្នេះ អរិយសាវ័កប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះសង្ឃថា ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយប្រពៃ ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយត្រង់ ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយសមគួរ ព្រះសង្ឃទាំងអស់នោះ

ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុប្បសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ អយំ ខោ[១] អានន្ទ ធម្មាទាសោ ធម្មបរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ តត្របិ[២] សុទំ ភគវា ញាតិកេ វិហរន្តោ គិញ្ជកាវសថេ ឯតទេវ ពហុលំ ភិក្ខូនំ ធម្មឹ កថំ ករោតិ ឥតិ សីលំ ឥតិ សមាធិ ឥតិ បញ្ញា

១ ឱ. ម. ខោ សោ ។ ២ ឱ. តត្រ ។

បើរាប់ជាគូនៃបុរសមាន ៤ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ពួកសាវ័ក របស់ព្រះមានព្រះភាគនុ៎ះ លោកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា លោកគួរទទួលនូវអាគន្តុកទាន លោកគួរទទួលនូវទក្ខិណាទាន ជាបុគ្គលដែលសត្វលោកគប្បីធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកដូច្នេះ អរិយសាវ័កប្រកបហើយដោយសីល ជាទីគាប់ចិត្តរបស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ ជាសីលរបស់មនុស្សអ្នកជា ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលមិនជ្រោកជ្រាកដោយតណ្ហានិងទិដ្ឋិ ជាសីលញុំាំងសមាធិឲ្យប្រព្រឹត្តទៅបាន ម្នាលអានន្ទ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើត្រូវការនឹងព្យាករ ក៏គប្បីព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខដូច្នេះ ធម្ម-បរិយាយនេះឯង ហៅថា ធម្មាទាសៈ ។ បានឮថា ព្រះមានព្រះភាគគង់ក្នុងផ្ទះសម្នាក់ ធ្វើដោយឥដ្ឋក្នុងនាទិកគ្រាមនោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើនដល់ពួកភិក្ខុយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ

សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

[៩០] អថខោ ភគវា នាទិកេ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន វេសាលី តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន វេសាលី តទវសរិ ។ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ អម្ពបាលិវនេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ សតោ ភិក្ខវេ ភិក្ខុ វិហរេយ្យ សម្បជានោ អយំ តេ[១] អម្ហាកំ អនុសាសនី ។ កថញ្ច ភិក្ខវេ ភិក្ខុ សតោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី

---

១ ឱ. ម. វោ ។

សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[៩០] លុះព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនាទិកគ្រាម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ក្រុងវេសាលី ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់ក្រុងវេសាលី ព្រមដោយភិក្ខុសង្ឃជាច្រើនរូប ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់ក្នុងអម្ពបាលិវ័នទៀបក្រុងវេសាលីនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវមានសតិនិងសម្បជញ្ញៈ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុមានសតិនោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាកាយក្នុងកាយជាប្រក្រតី ជា

វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សតោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។ សតោ ភិក្ខវេ ភិក្ខុ វិហរេយ្យ សម្បជានោ អយំ វោ អម្ហាកំ អនុសាសនីតិ ។

អ្នកមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដឹងខ្លួន មានសតិ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក គឺកាយ ឬឧបាទានក្ខន្ធ ។ ក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្ត ។ ភិក្ខុពិចារណាធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ដឹងខ្លួន មានសតិ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាអ្នកមានសតិយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសម្បជញ្ញៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាឈានទៅមុខ និងការឈានថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាក្រឡេកមើលទៅមុខ និងក្រឡេកមើលទៅខាង ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាអង្គុយ និងកិរិយាលាតលាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាទ្រទ្រង់សង្ឃាដីនិងបាត្រចីវរ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាស៊ី ផឹក ទំពា ក្រេបជញ្ជក់ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាបន្ទោបង់ឧច្ចារៈនិងបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់និយាយនិងការស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសម្បជញ្ញៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវមានសតិនិងសម្បជញ្ញៈ នេះជាពាក្យប្រៀនប្រដៅរបស់តថាគតចំពោះអ្នកទាំងឡាយ ។

[៩១] អស្សោសិ ខោ អម្ពបាលី គណិកា ភគវា កិរ វេសាលឹ អនុប្បត្តោ វេសាលិយំ វិហរតិ មយ្ហំ អម្ពវនេតិ ។ អថខោ អម្ពបាលី គណិកា ភទ្ទានិ ភទ្ទានិ យានានិ យោជាបេត្វា ភទ្ទំ ភទ្ទំ យានំ អភិរុហិត្វា ភទ្ទេហិ ភទ្ទេហិ យានេហិ វេសាលិយា និយ្យាសិ យេន សកោ អារាមោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អម្ពបាលឹ គណិកំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ អម្ពបាលី គណិកា ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ

[៩១] ស្រីផ្កាមាសឈ្មោះ អម្ពបាលី បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់ក្រុងវេសាលីហើយ ទ្រង់គង់នៅក្នុងអម្ពវ័នរបស់អាត្មាអញ ទៀបក្រុងវេសាលី ។ ទើបស្រីផ្កាមាសឈ្មោះ អម្ពបាលី ឲ្យគេរៀបចំយានទាំងឡាយដ៏ថ្លៃថ្លា ហើយឡើងជិះលើយានដ៏ថ្លៃថ្លា ចេញអំពីក្រុងវេសាលី ដោយយានដ៏ថ្លៃថ្លា បរសំដៅទៅកាន់អារាមរបស់ខ្លួន ទៅដោយយានកំណត់ត្រឹមទីដែលបរយានទៅបាន រួចចុះអំពីយានដើរទៅដោយជើងទទេ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះស្រីផ្កាមាសឈ្មោះ អម្ពបាលី អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ ស្រីផ្កាមាសឈ្មោះ អម្ពបាលី លុះព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃទទួលភត្តខ្ញុំម្ចាស់ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ នាងអម្ពបាលីជាស្រីផ្កាមាស

ភគវា តុណ្ហីភាវេន ។ អថខោ អម្ពបាលី គណិកា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[៩២] អស្សោសុំ ខោ វេសាលិកា លិច្ឆវី ភគវា កិរ វេសាលឹ អនុប្បត្តោ វេសាលិយំ វិហរតិ អម្ពបាលិវនេតិ ។ អថខោ តេ លិច្ឆវី ភទ្ទានិ ភទ្ទានិ យានានិ យោជាបេត្វា ភទ្ទំ ភទ្ទំ យានំ អភិរុហិត្វា ភទ្ទេហិ ភទ្ទេហិ យានេហិ វេសាលិយា និយ្យឹសុ ។ តត្រ ឯកច្ចេ លិច្ឆវី នីលា ហោន្តិ នីលវណ្ណា នីលវត្ថា នីលាលង្ការា ឯកច្ចេ លិច្ឆវី បីតា ហោន្តិ បីតវណ្ណា បីតវត្ថា បីតាលង្ការា ឯកច្ចេ លិច្ឆវី លោហិតកា ហោន្តិ លោហិតកវណ្ណា លោហិតកវត្ថា លោហិតកាលង្ការា ឯកច្ចេ លិច្ឆវី ឱទាតា ហោន្តិ ឱទាតវណ្ណា ឱទាតវត្ថា ឱទាតាលង្ការា ។ អថខោ អម្ពបាលី គណិកា ទហរានំ ទហរានំ លិច្ឆវីនំ អក្ខេន អក្ខំ ចក្កេន ចក្កំ យុគេន យុគំ បដិវដ្ដេសិ ។

ដឹងថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។

[៩២] ពួកស្តេចលិច្ឆវី អ្នកនៅក្នុងក្រុងវេសាលីបានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់ក្រុងវេសាលីហើយ ទ្រង់គង់នៅក្នុងអម្ពបាលិវ័ន ទៀបក្រុងវេសាលី ។ ទើបស្តេចលិច្ឆវីទាំងនោះ ឲ្យគេរៀបចំយានទាំងឡាយដ៏ថ្លៃថ្លា ហើយឡើងគង់លើយានដ៏ថ្លៃថ្លា ចេញអំពីក្រុងវេសាលី ដោយយានដ៏ថ្លៃថ្លា ។ បណ្តាស្តេចលិច្ឆវីទាំងនោះ ស្តេចលិច្ឆវីពួកខ្លះ ជាពួកខៀវ មានសម្បុរខៀវ មានសំពត់ខៀវ មានគ្រឿងប្រដាប់ក៏ខៀវ ស្តេចលិច្ឆវីពួកខ្លះ ជាពួកលឿង មានសម្បុរលឿង មានសំពត់លឿង មានគ្រឿងប្រដាប់ក៏លឿង ស្តេចលិច្ឆវីពួកខ្លះ ជាពួកក្រហម មានសម្បុរក្រហម មានសំពត់ក្រហម មានគ្រឿងប្រដាប់ក៏ក្រហម ស្តេចលិច្ឆវីពួកខ្លះ ជាពួក-ស មានសម្បុរ-ស មានសំពត់-ស មានគ្រឿងប្រដាប់ក៏ស ។ លំដាប់នោះ នាងអម្ពបាលីផ្កាមាស បំប៉ះភ្លៅដោយភ្លៅ បំប៉ះកង់ដោយកង់ បំប៉ះនឹមដោយនឹម (នៃយាន) របស់ពួកស្តេចលិច្ឆវីកំលោះ ៗ ។

២០៧



អថខោ តេ(១) លិច្ឆវី អម្ពបាលឹ គណិកំ ឯតទវោចុំ កឹ ជេ អម្ពបាលិ(២) ទហរានំ ទហរានំ លិច្ឆវីនំ អក្ខេន អក្ខំ ចក្កេន ចក្កំ យុគេន យុគំ បដិវដ្ដេសីតិ ។ តថា ហិ បន មេ អយ្យបុត្តា ភគវា និមន្តិតោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ ទេហិ ជេ អម្ពបាលិ ឯតំ ភត្តំ សតសហស្សេនាតិ ។ សចេ ហិ មេ អយ្យបុត្តា វេសាលឹ សាហារំ ទស្សថ ឯវំបិ(៣) មហន្តំ ភត្តំ ន ទស្សាមីតិ ។ អថខោ តេ លិច្ឆវី អង្គុលី បោឋេសុំ(៤) ជិតម្ហា វត ភោ អម្ពបាលិកាយ(៥) វញ្ចិតម្ហា វត ភោ អម្ពបាលិកា-យាតិ(៦) ។ អថខោ តេ លិច្ឆវី យេន អម្ពបាលិវនំ តេន បាយឹសុ ។ អទ្ទសា ខោ ភគវា តេ លិច្ឆវី ទូរតោ វ អាគច្ឆន្តេ ទិស្វាន(៧) ភិក្ខូ អាមន្តេសិ យេសំ ភិក្ខវេ

១ ឱ. តេតិ បទំ នត្ថិ ។ ២ ឯត្ថន្តរេ ភេសជ្ជក្ខន្ធកបាលិយំ អម្ពាកន្តិ បទំ ទិស្សតិ ។ ៣ ឱ. ឯវំ ។ ៤ ផោដេសុន្តិបិ ។ ៥-៦ ឱ. ម. អម្ពកាយាតិ ។ ៧ ឱ. ម. ទិស្វា ។

ឯស្តេចលិច្ឆវីទាំងនោះ មានបន្ទូលនឹងនាងអម្ពបាលីផ្កាមាស យ៉ាងនេះថា ម្នាលមេអម្ពបាលី ហេតុអ្វីក៏នាងបំប៉ះភ្លៅដោយភ្លៅ បំប៉ះកង់ដោយកង់ បំប៉ះនឹមដោយនឹម (នៃយាន) របស់ពួកស្តេចលិច្ឆវីកំលោះ ៗ ។ នាងអម្ពបាលីឆ្លើយថា បពិត្រព្រះអយ្យបុត្រទាំងឡាយ បានជាខ្ញុំម្ចាស់ធ្វើយ៉ាងនោះ ព្រោះខ្ញុំម្ចាស់ បាននិមន្តព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ដើម្បីឆាន់កត្តក្នុងថ្ងៃស្អែក ។ ពួកស្តេចលិច្ឆវីមានបន្ទូលថា ម្នាលមេអម្ពបាលី នាងចូរឲ្យកត្តនេះ មកយើងដោយតម្លៃចំនួន ១ សែនកហាបណៈចុះ ។ នាងអម្ពបាលីឆ្លើយថា បពិត្រព្រះអយ្យបុត្រទាំងឡាយ ទុកជាព្រះអង្គប្រទានក្រុងវេសាលីព្រមទាំងជនបទដល់ខ្ញុំម្ចាស់ ក៏ខ្ញុំម្ចាស់មិនព្រមថ្វាយនូវកត្តដ៏ប្រសើរយ៉ាងនេះឡើយ ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ផ្ទាត់ម្រាមព្រះហស្តហើយពោលថា ម្នាលគ្នាយើង ពួកយើង នាងអម្ពបាលីឈ្នះបានហើយតើហ្ន៎ ម្នាលគ្នាយើង ពួកយើងត្រូវនាងអម្ពបាលីបញ្ឆោតបានហើយហ្ន៎ ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ក៏បរយានទៅកាន់អម្ពបាលិវ័ន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញស្តេចលិច្ឆវីទាំងនោះមកអំពីចម្ងាយ លុះទតឃើញហើយ ក៏ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ

ភិក្ខូនំ ទេវា តាវត្តឹសា អទិដ្ឋបុព្វា ឱលោកេថ ភិក្ខវេ លិច្ឆវិបរិសំ អវលោកេថ ភិក្ខវេ លិច្ឆវិបរិសំ ឧបសំហ-រថ ភិក្ខវេ លិច្ឆវិបរិសំ តាវត្តឹសសទិសន្តិ ។ អថខោ តេ លិច្ឆវី យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកាវ យេន ភគវា តេនុ-បសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ លិច្ឆវី ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេ-ជេសិ សម្បហំសេសិ ។ អថខោ តេ លិច្ឆវី ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិ-តា សម្បហំសិតា ភគវន្តំ ឯតទវោចុំ អធិវាសេតុ នោ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេ-នាតិ ។ អធិវាសិតំ[១] ខោ មេ លិច្ឆវី ស្វាតនាយ អម្ពបាលិគណិកាយ ភត្តន្តិ ។ អថខោ តេ លិច្ឆវី អង្គុលី ផោថេសុំ ជិតម្ហា វត ភោ អម្ពបាលិកាយ

១ ឱ. ម. អធិវុត្ថំ ។

ពួកភិក្ខុណា មិនដែលឃើញពួកទេវតា នៅក្នុងឋានតាវត្តិង្ស ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ចូរមើលលិច្ឆវិបរិស័ទ ចូរសង្កេតមើលលិច្ឆវិ-បរិស័ទ ពិនិត្យមើលលិច្ឆវិបរិស័ទ ដែលប្រហែលគ្នានឹងទេវតា នៅក្នុងឋានតាវត្តិង្ស ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ក៏ទៅដោយយានកំណត់ត្រឹមទីដែលបរយានទៅបាន ហើយចុះអំពីយាន ស្តេចទៅដោយព្រះបាទាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះស្តេចលិច្ឆវីទាំងនោះគង់ក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ ស្តេចលិច្ឆវីទាំងនោះ លុះព្រះមានព្រះភាគ ទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគព្រមទាំងព្រះភិក្ខុសង្ឃ ទទួលភត្តរបស់យើងខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលលិច្ឆវីទាំងឡាយ តថាគតបានទទួលភត្ត របស់នាងអម្ពបាលីផ្កាមាស ដើម្បីឆាន់ក្នុងថ្ងៃស្អែករួចទៅហើយ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះ ផ្ទាត់ម្រាមព្រះហស្តហើយពោលថា ម្នាលគ្នាយើង ពួកយើងឲ្យនាងអម្ពបាលីឈ្នះបានហើយតើហ្ន៎

វញ្ចិតម្ហា វត ភោ អម្ពបាលិកាយាតិ ។ អថខោ តេ លិច្ឆវី ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។ អថខោ អម្ពបាលី គណិកា តស្សា រត្តិយា អច្ចយេន សកេ អារាមេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរំ អាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន អម្ពបាលិគណិកាយ បរិវេសនំ[១] តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ អម្ពបាលី គណិកា ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ អម្ពបាលី គណិកា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ អម្ពបាលី គណិកា ភគវន្តំ ឯតទវោច

១ ឱ. បរិវេសនា ។ ម. និវេសនំ ។

ម្នាលគ្នាយើង ពួកយើងឲ្យនាងអម្ពបាលីបញ្ឆោតបានហើយហ្ន៎ ។ លំដាប់នោះ ស្ដេចលិច្ឆវីទាំងនោះ ត្រេកអររីករាយនឹងភាសិត របស់ព្រះមានព្រះភាគហើយ ក៏ក្រោកអំពីអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ នាងអម្ពបាលីផ្កាមាស តាក់តែងខាទនីយភោជនីយាហារដ៏ថ្លៃថ្លា ក្នុងអារាមរបស់ខ្លួន ហើយឲ្យបម្រើទៅក្រាបទូលកត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់និងបាត្រចីវរអំពីព្រលឹម ស្ដេចសំដៅទៅកាន់ទីអង្គាសចង្ហាន់របស់នាងអម្ពបាលីផ្កាមាស ព្រមដោយភិក្ខុសង្ឃ លុះស្ដេចទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ គ្រានោះ នាងអម្ពបាលីផ្កាមាស បានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពីសា ដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែហាមឃាត់ ។ លំដាប់នោះ នាងអម្ពបាលីផ្កាមាសកំណត់ដឹងថា ព្រះមានព្រះភាគទ្រង់សោយស្រេចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកអាសនៈទាបមួយ អង្គុយក្នុងទីដ៏សមគួរ ។ នាងអម្ពបាលីផ្កាមាស លុះអង្គុយ ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលចំពោះព្រះមានព្រះភាគថា

ឥមាហំ ភន្តេ អារាមំ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស ទម្មីតិ ។ បដិគ្គហេសិ ភគវា អារាមំ ។ អថខោ ភគវា អម្ពបាលី គណិកំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ តត្រ[១] សុទំ ភគវា វេសាលិយំ វិហរន្តោ អម្ពបាលិវនេ ឯតទេវ ពហុលំ ភិក្ខូនំ ធម្មីកថំ ករោតិ ឥតិ សីលំ ឥតិ សមាធិ ឥតិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

[៩៣] អថខោ ភគវា អម្ពបាលិវនេ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន វេឡុវគាមកោ[២] តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន វេឡុវគាមកោ តទវសរិ ។ តត្រ សុទំ ភគវា

១ ឱ. តត្របិ ។ ២ ឱ. ពេឡុវគ្គាមកោ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយអារាមនេះ ដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលនូវអារាម ។ លំ-ដាប់នោះ ព្រះមានព្រះភាគ ទ្រង់ញុំាងនាងអម្ពបាលីផ្កាមាស ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈស្តេចចេញទៅ ។ បានឮថា ព្រះមានព្រះភាគដែលទ្រង់គង់ក្នុងអម្ពបាលិវ័ន ទៀបក្រុងវេសាលីនោះ ទ្រង់ធ្វើធម្មីកថាជាច្រើនដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះចាកអាសវៈទាំងឡាយដោយប្រពៃ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[៩៣] លុះព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពបាលិវ័ន តាមសមគួរ ដល់ពុទ្ធអធ្យាស្រ័យហើយ បានត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងចូលទៅ កាន់វេឡុវគ្រាម ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់វេឡុវគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា

វេឡុវគាមកេ វិហរតិ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ឯថ តុម្ហេ ភិក្ខវេ សមន្តា វេសាលី យថាមិត្តំ យថាសន្ទិដ្ឋំ យថាសម្ភត្តំ វស្សំ ឧបគច្ឆថ[១] អហំ បន ឥធេវ វេឡុវគាមកេ វស្សំ ឧបគច្ឆាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុណិត្វា[២] សមន្តា វេសាលឹ យថាមិត្តំ យថាសន្ទិដ្ឋំ យថាសម្ភត្តំ វស្សំ ឧបគច្ឆុំ[៣] ។ ភគវា បន តត្ថេវ វេឡុវគាមកេ វស្សំ ឧបគច្ឆិ ។ អថខោ ភគវតោ វស្សូបគតស្ស ខរោ អាពាធោ ឧប្បជ្ជិ ពាឡ្ហា វេទនា វត្តន្តិ មារណន្តិកា ។ តត្រ សុទំ ភគវា សតោ សម្បជានោ អធិវាសេសិ[៤] អវិហញ្ញមានោ ។ អថខោ ភគវតោ ឯតទហោសិ ន ខោ មេ តំ បដិរូបំ យោហំ[៥] អនាមន្តេត្វា ឧបដ្ឋាកេ អនបលោកេត្វា ភិក្ខុសង្ឃំ បរិនិព្វាយេយ្យំ

---

១ ឱ. ម. ឧបេថ ។ ២ ឱ. ម. បដិស្សុត្វា ។ ៣ ឱ. ឧបគញ្ចុំ ។ ម. ឧបគច្ឆឹសុ ។ ៤ ឱ. អធិវាសេតិ ។ ៥ ម. ស្វាហំ ។

ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថ ក្នុងវេឡុវគ្រាមនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមក ចូរអ្នកទាំងឡាយ ទៅចាំវស្សាក្នុងទីជិត ៗ ក្រុងវេសាលី តាមបុគ្គលដែលជាមិត្ត តាមបុគ្គលដែលស្គាល់គ្នា តាមបុគ្គលដែលស្និទ្ធស្នាលនឹងគ្នាចុះ ចំណែកតថាគតនឹងនៅចាំវស្សា ក្នុងវេឡុវគ្រាមនេះឯង ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏នាំគ្នាទៅចាំវស្សាក្នុងទីជិត ៗ ក្រុងវេសាលី តាមបុគ្គលដែលជាមិត្ត តាមបុគ្គលដែលស្គាល់គ្នា តាមបុគ្គលដែលស្និទ្ធស្នាលនឹងគ្នា ។ ចំណែកខាងព្រះមានព្រះភាគ ទ្រង់ចាំវស្សាក្នុងវេឡុវគ្រាមនោះឯង ។ កាលព្រះមានព្រះភាគ ទ្រង់គង់ចាំព្រះវស្សា ក៏មានព្រះអាពាធខ្លាំងក្លាកើតឡើង វេទនាដ៏មានកម្លាំងស្មើរនឹងដល់មរណៈក៏ប្រព្រឹត្តទៅ ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់មានសតិនិងសម្បជញ្ញៈ មិនឲ្យទុក្ខវេទនាបៀតបៀនបាន ទ្រង់អត់សង្កត់ (ដោយអធិវាសនខន្តី) ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតមិនបានប្រាប់ពួកភិក្ខុអ្នកបម្រើ និងមិនបានប្រាប់ភិក្ខុសង្ឃហើយបរិនិព្វាន ដោយហេតុណា ហេតុនោះមិនសមគួរ

យន្នូនាហំ ឥមំ អាពាធំ វីរិយេន បដិប្បណាមេត្វា ជីវិតសង្ខារំ អធិដ្ឋាយ វិហរេយ្យន្តិ ។ អថខោ ភគវា តំ អាពាធំ វីរិយេន បដិប្បណាមេត្វា ជីវិតសង្ខារំ អធិដ្ឋាយ វិហាសិ ។ អថខោ ភគវតោ សោ អាពាធោ បដិប្បស្សម្ភិ ។ អថខោ ភគវា គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា វិហារា និក្ខម្ម វិហារប្បច្ឆាយាយំ បញ្ញត្តេ អាសនេ និសីទិ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ទិដ្ឋា[១] ភន្តេ ភគវតោ ផាសុ ទិដ្ឋំ[២] ភន្តេ ភគវតោ ខមនីយំ អបិច[៣] មេ ភន្តេ មធុរកជាតោ វិយ កាយោ ទិសាបិ មេ ន បក្ខាយន្តិ ធម្មាបិ មំ ន បដិភន្តិ

១ ឱ. ទិដ្ឋា មេ ។ ម. ទិដ្ឋោ មេ ។ ២ ឱ. ទិដ្ឋំ មេ ។ ៣ ឱ. អបិ ហិ ។

ដល់តថាគតឡើយ បើដូច្នោះ គួរតែតថាគតគ្របសង្កត់អាពាធនេះ ដោយសេចក្តីព្យាយាម ហើយអធិដ្ឋានជីវិតសង្ខារ សម្រេចឥរិយាបថសិនចុះ ។ ទើបព្រះមានព្រះភាគ ទ្រង់គ្របសង្កត់អាពាធនោះ ដោយសេចក្តីព្យាយាម ហើយទ្រង់អធិដ្ឋាននូវជីវិតសង្ខារ ។ អាពាធនៃព្រះមានព្រះភាគនោះ ក៏រម្ងាប់ទៅក្នុងកាលនោះឯង ។ លុះព្រះមានព្រះភាគ សះស្បើយចាកព្រះអាពាធហើយ ទើបនឹងស្បើយចាកអាពាធមិនយូរប៉ុន្មាន ទ្រង់ស្តេចចេញអំពីវិហារ ទៅគង់លើអាសនៈ ដែលគេបានក្រាលទុកត្រង់ម្លប់វិហារ ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានឃើញព្រះមានព្រះភាគ ទ្រង់បានសេចក្តីសប្បាយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានឃើញព្រះមានព្រះភាគអត់ធន់បាន បពិត្រព្រះអង្គដ៏ចម្រើន ក៏កាយរបស់ខ្ញុំព្រះអង្គហាក់ដូចជាស្រយុតស្រយង់ពេកណាស់ សូម្បីទិសទាំងឡាយ ក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ សូម្បីធម៌ទាំងឡាយក៏មិនច្បាស់លាស់ ដល់ខ្ញុំព្រះអង្គ

២១៣



ភគវតោ គេលញ្ញេន អបិច មេ ភន្តេ អហោសិ កាចិទេវ អស្សាសមត្តា ន តាវ ភគវា បរិនិព្វាយិស្សតិ ន យាវ ភគវា ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរតីតិ ។ កឹ បនានន្ទ ភិក្ខុសង្ឃោ មយិ បច្ចាសីសតិ ទេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ ករិត្វា នត្ថានន្ទ[១] តថាគតស្ស ធម្មេសុ អាចរិយមុដ្ឋិ យស្ស នូន អានន្ទ ឯវមស្ស អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ វា មមុទ្ទេសិកោ ភិក្ខុសង្ឃោតិ វា សោ នូន អានន្ទ ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរេយ្យ ។ តថាគតស្ស ខោ អានន្ទ ន ឯវំ ហោតិ អហំ ខោ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ វា មមុទ្ទេសិកោ ភិក្ខុសង្ឃោតិ វា ។ សកឹ[២] អានន្ទ តថាគតោ ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរិស្សតិ ។ អហំ ខោ បនានន្ទ ឯតរហិ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោ អនុប្បត្តោ អសីតិកោ មេ វយោ វត្តតិ ។

ព្រោះហេតុដែលព្រះមានព្រះភាគទ្រង់ព្រះអាពាធ បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្តែខ្ញុំព្រះអង្គមានសេចក្តីសង្ឃឹមខ្លះថា ព្រះមានព្រះភាគ មិនទាន់សម្តែងធម៌នីមួយដ៏ប្លែក ប្រារព្ធនឹងភិក្ខុសង្ឃដរាបណាទេ ព្រះមានព្រះភាគនឹងមិនទាន់បរិនិព្វានដរាបនោះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ភិក្ខុសង្ឃនៅនឹកប៉ុនប៉ងអ្វីក្នុងតថាគតទៀត ម្នាលអានន្ទ ធម៌ដែលតថា-គតសម្តែងហើយ ធ្វើមិនឲ្យមានខាងក្នុងខាងក្រៅ ម្នាលអានន្ទ កណ្តាប់ដៃនៃអាចារ្យ មិនមានក្នុងធម៌ទាំងឡាយ របស់តថាគតទេ ម្នាលអានន្ទ អ្នកណា មានគំនិតយ៉ាងនេះថា អាត្មាអញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះក្តី ថា ភិក្ខុសង្ឃជាអ្នកអាងនូវអាត្មាអញដូច្នេះក្តី ម្នាលអានន្ទ អ្នកនោះ សមជាពោលពាក្យណាមួយ ប្រារព្ធនឹងភិក្ខុសង្ឃ មិនខាន ។ ម្នាលអានន្ទ តថាគតមិនមានគំនិតយ៉ាងនេះថា អាត្មាអញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះ ឬថាភិក្ខុសង្ឃជាអ្នកអាង នូវអាត្មាអញដូច្នេះសោះឡើយ ។ ម្នាលអានន្ទ ព្រះតថាគតនឹងពោលពាក្យណាមួយ ប្រារព្ធនឹងភិក្ខុសង្ឃ ធ្វើអ្វីទៀត ។ ម្នាលអានន្ទ ឥឡូវនេះ តថាគតគ្រាំគ្រាហើយ ចម្រើនហើយ ចាស់ហើយ កន្លងអាយុកាលដល់បច្ឆិមវ័យហើយ វ័យតថាគតបាន ៨០ ឆ្នាំហើយ ។

សេយ្យថាបិ អានន្ទ ជរសកដំ វេឡុមិស្សកេន[១] យាបេតិ ឯវមេវ ខោ អានន្ទ វេឡុមិស្សកេន មញ្ញេ តថាគតស្ស កាយោ យាបេតិ ។ យស្មឹ អានន្ទ សមយេ តថាគតោ សព្វនិមិត្តានំ អមនសិការា ឯ-កច្ចានំ វេទនានំ និរោធា អនិមិត្តំ ចេតោសមាធឹ ឧ-បសម្បជ្ជ វិហរតិ ផាសុតរោ[២] អានន្ទ តស្មឹ សមយេ តថាគតស្ស កាយោ ហោតិ ។ តស្មាតិហានន្ទ អត្ត-ទីបា វិហរថ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។ កថញ្ច អានន្ទ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្ម-ទីបោ ធម្មសរណោ អនញ្ញសរណោ ។ ឥធានន្ទ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ អានន្ទ ភិក្ខុ

១ ម. ជជ្ជរសកដំ វេធមិស្សកេន ។ ឱ. វេឃមិស្សកេន ។ ២ ឱ. ផាសុកពោ ។

ម្នាលអានន្ទ រទេះចាស់ដែលបរទៅបាន ព្រោះការអបដោយឫស្សីយ៉ាង ណាមិញ ម្នាលអានន្ទ កាយរបស់តថាគតនឹងប្រព្រឹត្តទៅបានដូចជារទេះ អបដោយឫស្សីយ៉ាងនោះឯង ។ ម្នាលអានន្ទ សម័យណា ដែលព្រះតថា-គតចូលចេតោសមាធិ (សេចក្តីតាំងចិត្តមាំ) ដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង ព្រោះរំលត់វេទនាពួកខ្លះ ម្នាលអានន្ទ សម័យនោះ កាយនៃតថាគត ក៏បានសេចក្តីសប្បាយគ្រាន់បើ ។ ម្នាល អានន្ទ ព្រោះហេតុនោះ អ្នកទាំងឡាយចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក កុំយករបស់ដទៃជាទីរលឹក ចូរយកធម៌ជាទីពឹង យកធម៌ជាទីរលឹក កុំយករបស់ដទៃជាទីរលឹកឡើយ ។ ម្នាលអានន្ទ ភិក្ខុយកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក មិនយករបស់ដទៃជាទីរលឹក យកធម៌ជាទីពឹង យកធម៌ជាទីរលឹក មិនយករបស់ដទៃជាទីរលឹកនោះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមដុតកម្តៅកិលេស មានសម្បជញ្ញៈ មានសតិ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក គឺកាយ ឬឧបាទានក្ខន្ធចេញ ។ ក្នុងវេទនាទាំង-ឡាយ ។ ក្នុងចិត្ត ។ ភិក្ខុពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ មានព្យាយាមដុតកម្តៅកិលេស មានសម្បជញ្ញៈ មានសតិ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។ ម្នាលអានន្ទ យ៉ាងនេះឯង ភិក្ខុ

អត្តទីបា វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។ យេ ហិ កេចិ អានន្ទ ឯតរហិ វា មម វា អច្ចយេន អត្តទីបា វិហរិស្សន្តិ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា តមតគ្គេ មេ តេ អានន្ទ ភិក្ខូ ភវិស្សន្តិ យេ កេចិ សិក្ខាកាមាតិ ។

មហាបរិនិព្វានេ គាមកណ្ឌំ សមត្តំ[១] ។

ពុទ្ធភាណវារំ ទុតិយំ ។

[៩៤] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ គណ្ហាហិ អានន្ទ និសីទនំ យេន ចាបាលំ ចេតិយំ[២] តេនុបសង្កមិស្សាម ទិវាវិហារាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា និសីទនំ អាទាយ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ អថខោ ភគវា យេន

១ ឱ. ម. មហាបរិនិព្វានេ គាមកណ្ឌំ សមត្តន្តិ ឥមេ បាឋា ន ទិស្សន្តិ ។ ២ ឱ. ចាបាលំ ចេតិយំ ។ ម. ចាបាលចេតិយំ ។

ឈ្មោះថា យកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក មិនយករបស់ដទៃជាទីរលឹក យកធម៌ជាទីពឹង យកធម៌ជាទីរលឹក មិនយករបស់ដទៃជាទីរលឹក ។ ម្នាលអានន្ទ ក្នុងកាលឥឡូវនេះក្តី អំណើះតតពីតថាគតទៅក្តី ភិក្ខុណាមួយ យកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក មិនយករបស់ដទៃជាទីរលឹក យកធម៌ជាទីពឹង យកធម៌ជាទីរលឹក មិនយករបស់ដទៃជាទីរលឹកឡើយ ម្នាលអានន្ទ មួយទៀត ភិក្ខុណាមួយ ជាអ្នកប្រាថ្នានូវសិក្ខា ភិក្ខុទាំងនោះ នឹងតាំងនៅក្នុងគុណដ៏ប្រសើរបំផុត របស់តថាគតដែរ ។

ចប់ គាមកណ្ឌ ក្នុងមហាបរិនិព្វានសូត្រ ។

ចប់ ពុទ្ធភាណវារៈទី ២ ។

[៩៤] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅទ្រង់បិណ្ឌបាត ក្នុងក្រុងវេសាលី លុះទ្រង់ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងវេសាលីហើយ ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តហើយ ទ្រង់ត្រាស់ នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកកាន់យកនិសីទនៈ[១]ទៅ យើងនឹងចូលទៅសម្រាក ក្នុងវេលាថ្ងៃ ឯបាវាលចេតិយ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏កាន់និសីទនៈទៅតាម ៗ ខាងក្រោយព្រះមានព្រះភាគ ។ គ្រានោះ ព្រះមាន

---

១ អដ្ឋកថាថា និសីទនៈក្នុងទីនេះគឺចម្មខណ្ឌ ។

ចាបាលំ ចេតិយំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អាយស្មាបិ ខោ អានន្ទោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេតិយំ រមណីយំ គោតមកំ ចេតិយំ រមណីយំ សត្តម្ពំ[១] ចេតិយំ រមណីយំ ពហុបុត្តំ ចេតិយំ រមណីយំ សារន្ទទំ ចេតិយំ រមណីយំ ចាបាលំ ចេតិយំ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ[២] កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ

---

១ ឱ. សត្តម្ពកំ ។ ២ ឱ. អានន្ទាតិ បទំ នត្ថិ ។

ព្រះភាគស្តេចចូលទៅកាន់បាវាលចេតិយ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ ។ ចំណែកខាងព្រះអានន្ទមានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលអានន្ទ ក្រុងវេសាលីជាទីគួរត្រេកអរ ឧ-ទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិ-យជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ ធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បុគ្គលនោះបើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប[១] ឬលើសជាង ១ អាយុកប្បក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ ព្រះតថាគតបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹង

---

១ កំណត់អាយុរបស់មនុស្សដែលពេញគ្រប់គ្រាន់តាមកាលតាមសម័យ ហៅថា អាយុកប្ប ដូចក្នុងសម័យព្រះពុទ្ធជាម្ចាស់យើងនេះ អាយុកប្បកំណត់ ១ រយឆ្នាំ ។

២១៧



តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។ ឯវំបិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថា តំ មារេន បរិ-យុដ្ឋិតចិត្តោ ។ ទុតិយម្បិ ខោ ភគវា ។ បេ ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេ-តិយំ រមណីយំ គោតមកំ ចេតិយំ រមណីយំ សត្តម្ពំ ចេតិយំ រមណីយំ ពហុបុត្តំ ចេតិយំ រមណីយំ សា-រន្ទទំ ចេតិយំ រមណីយំ ចាបាលំ ចេតិយំ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលី-កតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា

ឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្ប ក៏បាន ។ ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱភាសជាឱឡារិក យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏មិនអាចនឹងយល់សេចក្ដីច្បាស់លាស់បាន មិនបានអារាធនា ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគត ឋិតនៅអស់ ១ អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ពួកទេវតានិងមនុស្សដូច្នេះសោះ ព្រោះមារចូលមកជ្រែកគំនិត ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលជាគម្រប់ ២ ដងផង ។ បេ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះអានន្ទមានអាយុជាគម្រប់ ៣ ដងផងថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ

សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវ-សេសំ វាតិ ។ ឯវំបិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគ-វន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវ-មនុស្សានន្តិ យថា តំ មារេន បរិយុដ្ឋិតចិត្តោ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ គច្ឆ ត្វំ អានន្ទ យស្សទានិ កាលំ មញ្ញសីតិ ។

បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទ ៤ ព្រះតថាគតបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ។ ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱកាសជាឱឡារិក យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏នៅតែមិនអាចនឹងយល់សេចក្ដីច្បាស់លាស់បានឡើយ ហើយមិនបានអារាធនា ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះឡើយ ព្រោះមារចូលមកជ្រែកគំនិត ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទ មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅចុះ អ្នកចូរដឹងនូវកាលដែលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។

ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។

[៩៥] អថខោ មារោ បាបិមា អចិរប្បក្កន្តេ អាយស្មន្តេ អានន្ទេ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ មារោ បាបិមា ភគវន្តំ ឯតទវោច បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខូ ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា

ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយអង្គុយទៀបគល់ឈើមួយ ក្នុងទីមិនឆ្ងាយ ។

[៩៥] កាលបើព្រះអានន្ទមានអាយុ ចេញទៅហើយមិនយូរប៉ុន្មាន គ្រានោះ ក្រុងមារមានចិត្តបាប ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីដ៏សមគួរ ។ លុះក្រុងមារមានចិត្តបាប ឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ បរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ

២២០

សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ឯតរហិ ខោ បន ភន្តេ ភិក្ខូ ភគវតោ សាវកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្ប-ដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខុនិយោ ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសា-រទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សា-មីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ

ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគតនឹងមិន ទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុ ជាសាវ័ករបស់ព្រះមានព្រះភាគ បានឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាម ធម៌ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនបរប្បវាទ ដែល កើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់សង្កិនដោយល្អ តាមពាក្យដែល សមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រ ព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះ សុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹង បរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះ មានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកភិក្ខុនី ជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្ត តាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈ នៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន

២២១



ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ឯតរហិ ខោ បន ភន្តេ ភិក្ខុនិយោ ភគវតោ សាវិកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឧបាសកា ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ

ទាំងមិនទាន់សង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្ដែងធម៌ប្រកបដោយបាដិហារ្យដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងកាលឥឡូវនេះ ពួកភិក្ខុនីជាសាវិការបស់ព្រះមានព្រះភាគ បានឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ហើយ ទាំងបានរៀនន្ទូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្ដែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនន្ទូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិន ដោយល្អតាមពាក្យសមហេតុ ហើយសម្ដែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកឧបាសកជាសាវ័ករបស់តថាគត ដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀនន្ទូវវាទៈ

សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ឯតរហិ ខោ បន ភន្តេ ឧបាសកា ភគវតោ សាវកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ

នៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយ ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យដរាបណាទេ តថាគតក៏នឹងមិនទាន់បរិ-និព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ ពួកឧបាសកជាសាវ័ករបស់ព្រះមានព្រះភាគ ឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូតទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ហើយ ទាំងបានរៀននូវវាទៈ នៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ

ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឧបាសិកា ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ឯតរហិ ខោ បន ភន្តេ ឧបាសិកា ភគវតោ សាវិកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ

បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកឧបាសិកា ជាសាវិកា របស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មានទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគតក៏នឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ ពួកឧបាសិកា ជាសាវិកា របស់ព្រះមានព្រះភាគបានឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ហើយ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ

សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតន្តិ ឯតរហិ ខោ បន ភន្តេ ភគវតោ ឥទំ ព្រហ្មចរិយំ ឥទ្ធញ្ចេវ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោតិ ។ ឯវំ វុត្តេ ភគវា មារំ បាបិមន្តំ ឯតទវោច អប្បោស្សុក្កោ ត្វំ បាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ

សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ព្រហ្មចារ្យ[១]របស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា និងមិនទាន់ពេញបរិបូណ៌ ដរាបណា មួយទៀត ពួកទេវតានិងមនុស្សមិនទាន់ចេះសម្តែងបានដោយប្រពៃ ដរាបណា តថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះមានព្រះភាគនេះ ខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតានិងមនុស្សចេះសម្តែងបានដោយល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ ។ កាលបើក្រុងមារ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏បានត្រាស់ភាសិតនេះទៅនឹងក្រុងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ

១ សំដៅយកសាសនាទាំងមូលដែលសង្គ្រោះដោយត្រៃសិក្ខា ។

ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ ។ អថខោ ភគវា ចាបាលេ ចេតិយេ សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ ។ ឱស្សដ្ឋេ ច ភគវតា អាយុសង្ខារេ មហា ភូមិចាលោ អហោសិ ភឹសនកោ លោមហំសោ ទេវទុន្ទុភិយោ[១] ច ផលឹសុ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

[៩៦] តុលមតុលញ្ច សម្ភវំ
ភវសង្ខារមវស្សជ្ជិ មុនិ
អជ្ឈត្តរតោ សមាហិតោ
អភិន្ទិ កវចមិវត្តសម្ភវន្តិ ។

[៩៧] អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ មហា វតាយំ ភូមិចាលោ សុមហា វតាយំ ភូមិចាលោ

១ ឱ. លោមហំសនោ ទេវទ្ធន្ទុភិយោ ។ ម. សលោមហំសោ ទេវទុទ្រភិយោ ។

កន្ទង់ ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារឰដ៏បាវាលចេតិយ ។ លុះព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ ក៏កក្រើកផែនដីយ៉ាងធំ គួរឲ្យក្ដុកក្ដឹក ព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវដំណើរនោះហើយ ក៏បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

[៩៦] ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វានដែលមានគុណថ្លឹងមិនបានផង នូវភពផង ទ្រង់លះបង់នូវសង្ខារដែលនាំសត្វទៅកាន់ភពផង ទ្រង់ត្រេកអរនូវអារម្មណ៍ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះហឫទ័យតាំងមាំហើយ (ដោយអំណាចសមថៈ) ផង ទ្រង់បានទម្លាយនូវបណ្ដាញ គឺ កិលេសដែលកើតមាននៅ ក្នុងខ្លួនដូចជាក្រោះ ។

[៩៧] លំដាប់នោះ ព្រះអានន្ទមានអាយុ មានសេចក្ដីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ហេតុជាអស្ចារ្យពេកណាស់ អើហ្ន៎ ហេតុចំឡែកពេកណាស់ ការកក្រើកផែនដីនេះជាយ៉ាងធំ ការកក្រើកផែនដីនេះធំណាស់តើ

ភីសនកោ លោមហំសោ ទេវទុន្ទុភិយោ ច ផលឹសុ កោ នុ ខោ ហេតុ កោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយាតិ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ មហា វតាយំ ភន្តេ ភូមិចាលោ សុមហា វតាយំ ភន្តេ ភូមិចាលោ ភីសនកោ លោមហំសោ ទេវទុន្ទុភិយោ ច ផលឹសុ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយាតិ ។

[៩៨] អដ្ឋ ខោ ឥមេ អានន្ទ ហេតូ អដ្ឋ បច្ចយា មហតោ ភូមិចាលស្ស ចាតុភាវាយ ។ កតមេ អដ្ឋ ។ អយំ អានន្ទ មហាបឋវី ឧទកេ បតិដ្ឋិតា ឧទកំ

គួរឲ្យភ្ញាក់ភ្ញើក ឲ្យព្រឺព្រួចរោម ទាំងស្គរក៏លាន់ឮឡើង មានហេតុដូចម្តេច មានបច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំម៉្លេះ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានហេតុជាអស្ចារ្យ បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដ៏ប្លែក បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះជាយ៉ាងធំ បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះធំពេកណាស់ គួរឲ្យភ្ញាក់ភ្ញើក ឲ្យព្រឺព្រួចរោម ទាំងស្គរក៏លាន់ឮឡើង បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យកក្រើកផែនដីយ៉ាងធំម៉្លេះ ។

[៩៨] ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ឯហេតុបច្ច័យដែលនាំឲ្យកក្រើកផែនដីនេះមាន ៨ យ៉ាង ។ ហេតុបច្ច័យទាំង ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ មហាប្រឹថពីនេះ ប្រតិស្ឋាននៅលើទឹក ឯទឹក

វាតេ បតិដ្ឋិតំ វាតោ អាកាសដ្ឋោ ហោតិ សោ ខោ អានន្ទ សមយោ យំ មហាវាតា វាយន្តិ មហាវាតា វាយន្តា ឧទកំ កម្បេន្តិ ឧទកំ កម្បិតំ បឋវឹ កម្បេតិ អយំ បឋមោ ហេតុ បឋមោ បច្ចយោ មហតោ ភូមិចាលស្ស បាតុភាវាយ ។ បុន ចបរំ អានន្ទ សមណោ វា ហោតិ ព្រាហ្មណោ វា ឥទ្ធិមា ចេតោវសិប្បត្តោ ទេវោ វា មហិទ្ធិកោ មហានុភាវោ តស្ស[១] បរិត្តា បឋវីសញ្ញា ភាវិតា ហោតិ អប្បមាណា អាបោសញ្ញា សោ ឥមំ បឋវឹ កម្បេតិ សង្កម្បេតិ សម្បកម្បេតិ សម្បវេធេតិ អយំ ទុតិយោ ហេតុ ទុតិយោ បច្ចយោ មហតោ ភូមិចាលស្ស បាតុភាវាយ ។ បុន ចបរំ អានន្ទ យទា ពោធិសត្តោ តុសិតា កាយា ចវិត្វា សតោ សម្បជានោ មាតុ កុច្ឆឹ ឱក្កមតិ តទាយំ បឋវី កម្បតិ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ អយំ តតិយោ ហេតុ តតិយោ បច្ចយោ

១ ឱ. ទេវតា វា មហិទ្ធិកា មហានុភាវា យស្ស ។

ប្រតិស្ឋាននៅលើខ្យល់ ខ្យល់ប្រតិស្ឋាននៅលើអាកាស ម្នាលអានន្ទ សម័យ ដែលមានខ្យល់ធំបក់ ខ្យល់ធំដែលបក់នោះ រមែងធ្វើទឹកឲ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដីឲ្យកក្រើកដែរ នេះជាហេតុជាបច្ច័យទី ១ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ សមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញក្នុងចិត្ត ឬទេវតាដែលមានឫទ្ធិធំ មានអានុភាពធំ បុគ្គលនោះ បានចម្រើនបឋវីសញ្ញាឲ្យមានកម្លាំងតិច ចម្រើនអាបោសញ្ញាឲ្យមានកម្លាំងច្រើន បុគ្គលនោះ រមែងធ្វើផែនដីនេះ ឲ្យកក្រើករំពើករំភើបញាប់ញ័របាន នេះជាហេតុជាបច្ច័យទី ២ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វច្យុតចាកពួកទេវតា ដែលឋិតនៅក្នុងឋានតុសិត មានសតិនិងសម្បជញ្ញៈ យាងចុះកាន់ព្រះមាតុឧទរ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ នេះជាហេតុជាបច្ច័យទី ៣

មហតោ ភូមិចាលស្ស ចាតុភាវាយ ។ បុន ចបរំ អានន្ទ យទា ពោធិសត្តោ សតោ សម្បជានោ មាតុ កុច្ឆិម្ហា និក្ខមតិ តទាយំ បឋវី កម្បតិ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ អយំ ចតុត្ថោ ហេតុ ចតុត្ថោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយ ។ បុន ចបរំ អានន្ទ យទា តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ តទាយំ បឋវី កម្បតិ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ អយំ បញ្ចមោ ហេតុ បញ្ចមោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយ ។ បុន ចបរំ អានន្ទ យទា តថាគតោ អនុត្តរំ ធម្មចក្កំ បវត្តេសិ[1] តទាយំ បឋវី កម្បតិ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ អយំ ឆដ្ឋោ ហេតុ ឆដ្ឋោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយ ។ បុន ចបរំ អានន្ទ យទា តថាគតោ សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជតិ តទាយំ បឋវី កម្បតិ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ អយំ សត្តមោ ហេតុ សត្តមោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយ ។

---

១ ឱ. ម. បវត្តេតិ ។

ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វ មានសតិនិងសម្បជញ្ញៈ ទ្រង់ប្រសូតចាកព្រះមាតុឧទរ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុជាបច្ច័យទី ៤ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុជាបច្ច័យទី ៥ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគតញ៉ាំងអនុត្តរធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុជាបច្ច័យទី ៦ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត មានសតិនិងសម្បជញ្ញៈ ដាក់ចុះនូវអាយុសង្ខារ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុជាបច្ច័យទី ៧ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

បុន ចបរំ អានន្ទ យទា តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយតិ តទាយំ បឋវី កម្បតិ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ អយំ អដ្ឋមោ ហេតុ អដ្ឋមោ បច្ចយោ មហតោ ភូមិចាលស្ស បាតុ-ភាវាយ ។ ឥមេ ខោ អានន្ទ អដ្ឋ ហេតូ អដ្ឋ បច្ចយា មហតោ ភូមិចាលស្ស បាតុភាវាយាតិ ។

[៩៩] អដ្ឋ ខោ ឥមា អានន្ទ បរិសា ។ កតមា អដ្ឋ ។ ខត្តិយបរិសា ព្រាហ្មណបរិសា គហបតិបរិសា សមណបរិសា ចាតុម្មហារាជិកបរិសា តាវតឹសបរិសា មារបរិសា ព្រហ្មបរិសា ។ អភិជានាមិ ខោ បនាហំ អានន្ទ អនេកសតំ ខត្តិយបរិសំ ឧបសង្កមិត្វា(១) ។ តត្របិ មយា សន្និសិន្នបុព្វញ្ចេវ សល្លបិតបុព្វញ្ច សា-កច្ឆា ច សមាបជ្ជិតបុព្វា ។ តត្ថ យាទិស កា តេសំ វណ្ណោ ហោតិ តាទិសកោ មយ្ហំ វណ្ណោ ហោតិ យាទិសកោ តេសំ សរោ ហោតិ តាទិសកោ មយ្ហំ សរោ ហោតិ ។ ធម្មិយា ច កថាយ សន្ទស្សេមិ សមាទបេមិ សមុត្តេជេមិ សម្បហំសេមិ ភាសមានញ្ច

១ ឧបសង្កមិតាតិបិ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុជាបច្ច័យទី ៨ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ ហេតុបច្ច័យដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំមាន ៨ យ៉ាងនេះឯង ។

[៩៩] ម្នាលអានន្ទ បរិស័ទនេះមាន ៨ ពួក ។ បរិស័ទទាំង ៨ ពួក តើដូចម្តេច ។ គឺ ខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហ-បតិបរិស័ទ សមណបរិស័ទ ចាតុម្មហារាជិកបរិស័ទ តាវត្តិង្សបរិស័ទ មារបរិស័ទ ព្រហ្មបរិស័ទ ។ ម្នាលអានន្ទ ចំណែកតថាគតចូលទៅកាន់ខត្តិយបរិស័ទជាច្រើនរយ រមែងស្គាល់ច្បាស់ ។ ក្នុងខត្តិយបរិស័ទនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ចូលទៅសាកច្ឆាជាមួយផង ។ សម្បុររបស់ជនទាំងនោះ ក្នុងពួកបរិស័ទនោះយ៉ាងណា សម្បុររបស់តថាគត យ៉ាងនោះដែរ សំឡេងរបស់ជនទាំងនោះយ៉ាងណា សំឡេងរបស់តថាគតយ៉ាងនោះដែរ ។ មួយទៀត តថាគតបានញុំាងជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា កាលដែលតថាគត កំពុងនិយាយ

មំ ន ជានន្តិ កោ នុ ខោ អយំ ភាសតិ ទេវោ វា មនុស្សោ វាតិ ។ ធម្មិយា ច កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា អន្តរធាយាមិ អន្តរហិតញ្ច មំ ន ជានន្តិ កោ នុ ខោ អយំ អន្តរហិតោ ទេវោ វា មនុស្សោ វាតិ ។ អភិជានាមិ ខោ បនាហំ អានន្ទ អនេកសតំ ព្រាហ្មណបរិសំ ។ បេ ។ គហបតិបរិសំ ។ បេ ។ សមណបរិសំ ។ បេ ។ ចាតុម្មហារាជិកបរិសំ ។ បេ ។ តាវត្តឹសបរិសំ ។ បេ ។ មារបរិសំ ។ បេ ។ ព្រហ្មបរិសំ ឧបសង្កមិត្វា ។ តត្របិ មយា សន្និសិន្នបុព្វញ្ចេវ សល្លបិតបុព្វញ្ច សាកច្ឆា ច សមាបជ្ជិតបុព្វា ។ តត្ថ យាទិសកោ តេសំ វណ្ណោ ហោតិ តាទិសកោ មយ្ហំ វណ្ណោ ហោតិ យាទិសកោ តេសំ សរោ ហោតិ តាទិសកោ មយ្ហំ សរោ ហោតិ ។ ធម្មិយា ច កថាយ សន្ទស្សេមិ សមាទបេមិ សមុត្តេជេមិ សម្បហំសេមិ ភាសមានញ្ច មំ ន ជានន្តិ កោ នុ ខោ អយំ ភាសតិ ទេវោ វា មនុស្សោ វាតិ ។

ជនទាំងនោះ មិនស្គាល់តថាគតថា ជនដែលកំពុងនិយាយនេះ តើជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ តថាគត លុះញុំាងជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បាត់រូបទៅ កាលដែលតថាគតបាត់រូបទៅហើយ ឯជនទាំងនោះ នៅតែមិនស្គាល់តថាគតថា ជនដែលបាត់ទៅហើយនេះ តើជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ ម្នាលអានន្ទ តថាគតចូលទៅកាន់ព្រាហ្មណបរិស័ទជាច្រើនរយ រមែងស្គាល់ច្បាស់ ។ បេ ។ គហបតិបរិស័ទ ។ បេ ។ សមណបរិស័ទ ។ បេ ។ ចាតុម្មហារាជិកបរិស័ទ ។ បេ ។ តាវត្តិង្សបរិស័ទ ។ បេ ។ មារបរិស័ទ ។ បេ ។ ព្រហ្មបរិស័ទ ។ ក្នុងព្រហ្មបរិស័ទនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ចូលទៅសាកច្ឆាជាមួយផង ។ សម្បុររបស់ព្រហ្មទាំងនោះ ក្នុងព្រហ្មបរិស័ទនោះយ៉ាងណា សម្បុររបស់តថាគតក៏យ៉ាងនោះដែរ សំឡេងរបស់ព្រហ្មទាំងនោះយ៉ាងណា សំឡេងរបស់តថាគតក៏យ៉ាងនោះដែរ ។ មួយទៀត តថាគតបានញុំាងព្រហ្មទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ចំណែកខាងព្រហ្មទាំងនោះ មិនស្គាល់តថាគតថា ជនដែលកំពុងនិយាយនេះជាអ្វីហ្ន៎ ជាទេវតាឬជាមនុស្សដូច្នេះឡើយ ។

ធម្មិយា ច កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា អន្តរធាយាមិ អន្តរហិ-តញ្ច មំ ន ជានន្តិ កោ នុ ខោ អយំ អន្តរហិតោ ទេវោ វា មនុស្សោ វាតិ ។ ឥមា ខោ អានន្ទ អដ្ឋ បរិសា ។

[១០០] អដ្ឋ ខោ ឥមានិ អានន្ទ អភិភាយត-នានិ ។ កតមានិ អដ្ឋ ។ អជ្ឈត្តំរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ

លុះតថាគតញុំាងព្រហ្មទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បាត់រូបទៅ កាលដែលតថាគតបាត់រូបទៅហើយ ចំណោកព្រហ្មទាំងនោះ នៅតែមិនស្គាល់តថាគតថាជនដែលបាត់ទៅហើយនេះ តើជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ ម្នាលអានន្ទ បរិស័ទមាន ៨ ពួកនេះឯង ។

[១០០] ម្នាលអានន្ទ អភិភាយតនៈ (ហេតុជាគ្រឿងគ្របសង្កត់នូវបច្ចនិកធម៌) នេះមាន ៨ ប្រការ ។ អភិភាយតនៈ ៨ ប្រការ តើដូចម្តេច ។ បុគ្គលពួក ១ មានសេចក្តីសម្គាល់នូវរូបខាងក្នុង[១] ហើយឃើញនូវរូបខាងក្រៅ[២] មានប្រមាណតិច[៣] មានពណ៌ល្អ ឬមានពណ៌អាក្រក់[៤]

១ ដែលថា សម្គាល់នូវរូបខាងក្នុងនោះគឺបុគ្គលយកអាការៈក្នុងខ្លួនមានសក់ជាដើម មកធ្វើបរិកម្ម ។ ២ ដែលថា ឃើញនូវរូបខាងក្រៅ គឺឃើញនូវនិមិត្តខាងក្រៅដែលខ្លួនយកអាការៈខាងក្នុងមកបរិកម្ម ហើយកើតនិមិត្តឡើងខាងក្រៅនោះឯង ។ ៣ ដែលថា មានប្រមាណតិចនោះ សំដៅយកនិមិត្តរបស់បុគ្គលដែលជាវិតក្កចរិត និមិត្តនោះ មានប្រមាណតិច ។ ៤ ដែលថា មានពណ៌ល្អនោះ សំដៅយកនិមិត្តរបស់បុគ្គលដែលជាទោសចរិត ។ ដែលថា មានពណ៌អាក្រក់នោះ សំដៅយកនិមិត្តរបស់បុគ្គលដែលជារាគចរិត ។

តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បឋមំ អភិភាយតនំ ។ អជ្ឈត្តំរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ទុតិយំ អភិភាយតនំ ។ អជ្ឈត្តំ-អរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សា-មីតិ ឯវំសញ្ញី ហោតិ ឥទំ តតិយំ អភិភាយត-នំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ

គ្របសង្កត់នូវរូប[១] ទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន[២] មានពណ៌ល្អ ឬមានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង[៣] ហើយឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានពណ៌ល្អ ឬមានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានពណ៌ល្អ ឬមានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ

---

១ ដែលថា គ្របសង្កត់នូវរូបទាំងនោះ គឺបុគ្គលបានឃើញនូវនិមិត្តខាងក្រៅ ហើយកន្លងបង់នូវនិមិត្តនោះចេញ ទើបចូលទៅកាន់អប្បនាគឺបឋមជ្ឈាន ។ ២ ដែលថា មានប្រមាណច្រើននោះ សំដៅយកនិមិត្តរបស់បុគ្គលដែលជាមោហចរិត ។ ៣ បុគ្គលនោះ មិនយកអាការៈខាងក្នុងមកធ្វើបរិកម្ម យកវត្ថុខាងក្រៅមកធ្វើបរិកម្មវិញ ។

ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ចតុត្ថំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធា-រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្ស-នានិ នីលនិភាសានិ សេយ្យថាបិ នាម ឧម្មាបុប្ផំ នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ សេយ្យថា វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ នីលា-និ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បញ្ចមំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិ-ទ្ធារូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ

*ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ដែលជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ ប្រៀបដូចផ្កាកប្បាសខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ ពុំនោះសោត រូបនោះ ប្រៀបដូចសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់ខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៥ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង*

បីតនិភាសានិ សេយ្យថាបិ ណាម កណ្ណិការបុប្ផំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ សេយ្យថា វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ឆដ្ឋំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ សេយ្យថាបិ ណាម ពន្ធុជីវកំ បុប្ផំ លោហិតកំ លោហិតកវណ្ណំ លោហិតកនិទស្សនំ លោហិតកនិភាសំ សេយ្យថា វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ លោហិតកំ លោហិតកវណ្ណំ

មានពន្លឺលឿង ប្រៀបដូចផ្កាកណ្ណិការលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង ពុំនោះសោត រូបនោះ ប្រៀបដូចសំពត់ កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់លឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ប្រៀបដូចជាផ្កាចម្បារក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោត រូបនោះ ប្រៀបដូចសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់ក្រហម មានពណ៌ក្រហម

លោហិតកនិទស្សនំ លោហិតកនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ សត្តមំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ សេយ្យថាបិ នាម ឱសធិតារកា ឱទាតា ឱទាតវណ្ណា ឱទាតនិទស្សនា ឱទាតនិភាសា សេយ្យថា វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ ឱទាតំ ឱទាតវណ្ណំ ឱទាតនិទស្សនំ ឱទាតនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ អដ្ឋមំ អភិភាយតនំ ។ ឥមានិ ខោ អានន្ទ អដ្ឋ អភិភាយតនានិ ។

ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៧ ។ បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅជារូប-ស មានពណ៌-ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌-ស មានពន្លឺស ប្រៀបដូចផ្កាយព្រឹកដែល-ស មានពណ៌-ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌-ស មានពន្លឺ-ស ពុំនោះសោត រូបនោះប្រៀបដូចសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថាសំពត់-ស មានពណ៌-ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌-ស មានពន្លឺ-ស យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូប-ស មានពណ៌-ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌-ស មានពន្លឺ-ស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៨ ។ ម្នាលអានន្ទ អភិភាយតនៈ មាន ៨ ប្រការនេះឯង ។

[១០១] អដ្ឋ ខោ ឥមេ អានន្ទ វិមោក្ខា ។ កតមេ អដ្ឋ ។ រូបី រូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ ។ អជ្ឈត្តំអរូបសញ្ញី ពហិទ្ធារូបានិ បស្សតិ អយំ ទុតិយោ វិមោក្ខោ ។ សុភន្តេវ អធិមុត្តោ ហោតិ អយំ តតិយោ វិមោក្ខោ ។ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិ-ឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា

[១០១] ម្នាលអានន្ទ វិមោក្ខ (ធម៌ជាគ្រឿងរួចចាកអាសវៈ) នេះមាន ៨ ប្រការ ។ វិមោក្ខ ៨ ប្រការ តើដូចម្តេច ។ បុគ្គលបាននូវរូបជ្ឈាន[១] រមែងឃើញនូវរូបគឺកសិណទាំងឡាយ មាននីលកសិណជាដើម នេះជាវិមោក្ខទី ១ ។ បុគ្គលមិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង រមែងឃើញនូវរូបខាងក្រៅទាំងឡាយ គឺកសិណមាននីលកសិណជាដើម នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់កាន់ឈានក្នុងវណ្ណកសិណដែលបរិសុទ្ធ[២] នេះជាវិមោក្ខទី ៣ ។ បុគ្គល ដែលកន្លងនូវរូបសញ្ញា[៣] ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា[៤] មិនបានធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា[៥] ដោយប្រការទាំងពួង ហើយ

---

១ រូបាវចរជ្ឈានដែលកើតអំពីកសិណមាននីលកសិណជាដើម ក្នុងអាការៈទាំង ៣២ មានសក់ជាដើមដែលសន្មតថាជាវត្ថុខាងក្នុង ។ ២ បុគ្គលដែលបានឈានព្រោះអាស្រ័យវណ្ណកសិណមាននីលកសិណជាដើម ដែលបរិសុទ្ធថ្លៃថ្លាជាងបុគ្គលទី ១ ទី ២ ។ ៣ សេចក្តីសម្គាល់ក្នុងរូបាវចរជ្ឈាននិងអារម្មណ៍របស់ឈាននោះ ។ ៤ សេចក្តីសម្គាល់ដែលកើតឡើងដោយវត្ថុមានចក្ខុជាដើម ប៉ះពាល់នឹងអារម្មណ៍មានរូបជាដើម ។ ៥ សញ្ញា ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងគ្នា ឬសញ្ញាដែលផ្សេងគ្នា ។

អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ ។ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ ។ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមោ វិមោក្ខោ ។ ឥមេ ខោ អានន្ទ អដ្ឋ វិមោក្ខា ។

[១០២] ឯកមិទាហំ អានន្ទ សមយំ ឧរុវេលាយំ វិហរាមិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ អថខោ អានន្ទ មារោ បាបិមា

បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ បុគ្គលដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ បុគ្គលដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា អ្វីតិចតួច ក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ បុគ្គលដែលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។ បុគ្គលដែលកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវសញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានិងវេទនា) នេះជាវិមោក្ខទី ៨ ។ ម្នាលអានន្ទ វិមោក្ខមាន ៨ ប្រការនេះឯង ។

[១០២] ម្នាលអានន្ទ សម័យមួយ តថាគតបានត្រាស់ជាដំបូងបានគង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឱរុវេលាប្រទេសឯណោះ ។ ម្នាលអានន្ទ គ្រានោះឯង ក្រុងមារមានចិត្តបាបចូល

យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ អានន្ទ មារោ បាបិមា មំ ឯតទវោច បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោតិ ឯវំ វុត្តេ អហំ អានន្ទ មារំ បាបិមន្តំ[១] ឯតទវោចំ ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខូ ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តិ ។ ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខុនិយោ ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា

---

១ ឱ. បាបិមំ ។

ទៅរកតថាគត លុះចូលដល់ហើយបានឋិតនៅ ក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះក្រុងមារមានចិត្តបាបឋិតនៅក្នុងទីដ៏សមគួរហើយ បាននិយាយយ៉ាងនេះ នឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ ម្នាលអានន្ទ កាលបើក្រុងមារ បាននិយាយយ៉ាងនេះហើយ តថាគត ក៏បានពោលពាក្យនេះទៅក្រុងមារ មានចិត្តបាបថា ម្នាលមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគតដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើកបែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគត ក៏មិនបានបរិនិព្វានដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកភិក្ខុនី ជាសាវិកា របស់តថាគតដែលឈ្លាស វាងវៃ ក្លៀវក្លា ជា

២៣៩



ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តិ ។ ន តាវាហំ ចាបិម បរិនិព្វាយិស្សាមិ យាវ មេ ឧចាសកា ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តិ ។ ន តាវាហំ ចាបិម បរិនិព្វាយិស្សាមិ យាវ មេ ឧចាសិកា ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា

ពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់បានរៀន នូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើកបែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិន នូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគត មិនទាន់បរិនិព្វាន ដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកឧបាសក ជាសាវ័ករបស់តថាគតដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់បានរៀន នូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើកបែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិន នូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគត មិនទាន់បរិនិព្វានដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកឧបាសិកា ជាសាវិកា របស់តថាគតដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត

ជម្មជរា ជម្មានុជម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុ-
ជម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អា-
ចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ
វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ
សហជម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ
ជម្មំ ទេសេស្សន្តិ ។ ន តាវាហំ ចាបិម បរិនិព្វាយិស្សា-
មិ យាវ មេ ឥជំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ
ជីតញ្ច វិត្ថារិកំ ពហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ
សុប្បកាសិតន្តិ ។ ឥជានេវ ខោ អានន្ទ អជ្ជ ចាបាលេ
ចេតិយេ មារោ ចាបិមា យេជាហំ តេនុបសង្កមិ ឧបសង្ក-
មិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ អានន្ទ
មារោ ចាបិមា មំ ឯតជវោច បរិនិព្វាតុជានិ ភន្តេ ភគវា

ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិន នូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគត ក៏មិនទាន់បរិនិព្វាន ដរាបនោះ ។ ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិសគេមិនទាន់ដឹងច្រើនគ្នា ទាំងមិនទាន់ពេញបរិបូណ៌ ដរាបណា មួយទៀតពួកទេវតានិងមនុស្សមិនទាន់ចេះសម្តែងបាន ដោយប្រពៃ ដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វាន ដរាបនោះ ។ ម្នាលអានន្ទ ថ្ងៃនេះក្រុងមារមានចិត្តបាប បានចូលមករកតថាគត ក្នុងបាវាលចេតិយ អម្បាញ់មិញនេះឯង បានឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះមារមានចិត្តបាប បានឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះសូមព្រះមានព្រះភាគ បរិនិព្វានទៅ

បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ ចាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខូ ន សាវកា ភវិស្សន្តិ ។ យាវ មេ ភិក្ខុនិយោ ន សាវិកា ភវិស្សន្តិ ។ យាវ មេ ឧបាសកា ន សាវ-កា ភវិស្សន្តិ ។ យាវ មេ ឧបាសិកា ន សាវិកា ភវិស្សន្តិ ។ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតន្តិ ។ ឯតរហិ ខោ បន ភន្តេ ភគវតោ ព្រហ្មចរិយំ ឥទ្ធញ្ចេវ ផីតញ្ច វិត្ថារិកំ ពហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិ-តំ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ

សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរ នឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះមានព្រះភាគ បានត្រាស់ព្រះវាចានេះថា ម្នាលមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគតនៅមិនទាន់មាន ដរាបណាទេតថាគត ក៏មិនទាន់បរិនិព្វានដរាបនោះ ។ ពួកភិក្ខុនីជាសាវិការបស់តថាគតនៅមិនទាន់មាន ដរាបណា ។ ពួកឧបាសក ជាសាវ័ករបស់តថាគតនៅមិនទាន់មានដរាបណា ។ ពួកឧបាសិកា ជាសាវិការបស់តថាគតនៅមិនទាន់មាន ដរាបណា ។ ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់-ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នាទាំងមិនទាន់ពេញបរិបូណ៌ ដរាបណា មួយទៀត ពួកទេវតានិងមនុស្សមិនទាន់ចេះសម្ដែងបានដោយប្រពៃ ដរាបណា (តថាគត ក៏មិនទាន់បរិ-និព្វានដរាបនោះ) ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះមានព្រះភាគ បានខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតានិងមនុស្ស ចេះសម្ដែងបានដោយល្អហើយ ។ បពិត្រព្រះអង្គដ៏ចម្រើនឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ

បរិនិព្វានកាលោទានិ ភន្តេ ភគវតោតិ ។ ឯវំ វុត្តេ អហំ អានន្ទ មារំ បាបិមន្តំ ឯតទវោចំ អប្បោស្សុក្កោ ត្វំ បាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ ឥទានេវ ខោ អានន្ទ អជ្ជ ចាបាលេ ចេតិយេ តថាគតេន សតេន សម្បជានេន អាយុសង្ខារោ ឱស្សដ្ឋោតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ អលំទានិ អានន្ទ មា តថាគតំ យាចិ អកាលោទានិ អានន្ទ តថាគតំ យាចនាយាតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ ។ បេ ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ ។ ម្នាលអានន្ទ កាលបើក្រុងមារ បាននិយាយយ៉ាងនេះហើយ តថាគត ក៏បានពោលពាក្យនេះ ទៅនឹងក្រុងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ម្នាលអានន្ទ ក្នុងថ្ងៃនេះ តថាគតមានសតិសម្បជញ្ញៈ បានដាក់អាយុសង្ខារ ក្នុងបាវាលចេតិយអម្បាញ់មិញនេះឯង ។ កាលបើព្រះមានព្រះភាគ មានពុទ្ធតម្រាស់ យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏បានក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំង-ឡាយ ។ ម្នាលអានន្ទ ឥឡូវនេះ កុំឡើយ អ្នកកុំអង្វរតថាគតឡើយ ម្នាលអានន្ទ ឥឡូវនេះ មិនមែនជាកាលគួរ ដើម្បីអារាធនាតថាគតទេ ។ ព្រះអានន្ទមានអាយុ បានក្រាបបង្គំទូលជាគម្រប់ពីរដងផង ។ បេ ។

តតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ សទ្ទ-ហសិ ត្វំ អានន្ទ តថាគតស្ស ពោធិន្តិ ។ ឯវំ ភន្តេតិ ។ អថ កិញ្ចរហិ ត្វំ អានន្ទ តថាគតំ យាវតតិយកំ អភិនិប្បីឡេសីតិ ។ សម្មុខា មេ តំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខ-មានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា

ព្រះអានន្ទមានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់បីដង ផងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ អ្នកជឿពោធិញ្ញាណរបស់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។ ម្នាលអានន្ទ កាលបើអ្នកជឿដែរ ហេតុអ្វី ក៏អ្នកនៅតែទទូចតថាគតដល់ទៅ ៣ ដង ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកានេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានត្រងរងក្នុងទីចំពោះព្រះភក្ត្រថា ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្ប ក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ

យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។ សទ្ទហាសិ ត្វំ អានន្ទាតិ ។ ឯវំ ភន្តេតិ ។ តស្មាតិហានន្ទ តុយ្ហេវេតំ ទុក្កដំ តុយ្ហេវេតំ អបរទ្ធំ យំ ត្វំ តថាគតេន ឯវំ ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន តថាគតំ យាចិ តិដ្ឋតុ ភគវា[១] កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ សចេ ត្វំ អានន្ទ តថាគតំ យាចេយ្យាសិ ទ្វេវ តេ វាចា តថាគតោ បដិក្ខិបេយ្យ អថ តតិយកំ អធិវាសេយ្យ តស្មាតិហានន្ទ តុយ្ហេវេតំ ទុក្កដំ តុយ្ហេវេតំ អបរទ្ធំ ។

១ ម. ភន្តេ ភគវា ។

បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគត ប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។ ម្នាលអានន្ទ អ្នកជឿឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។ ម្នាលអានន្ទ ហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ព្រោះតថាគតបានធ្វើនិមិត្តជាឱឡារិក បានធ្វើឱភាស ជាឱឡារិកយ៉ាងនេះហើយ អ្នកនៅតែមិនយល់សេចក្តីច្បាស់លាស់បាន មិនអារាធនាតថាគតថា សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអារាធនាតថាគត តថាគតគប្បីឃាត់វាចារបស់អ្នកត្រឹមតែពីរលើក តែដល់ទៅបីលើក តថាគតគប្បីទទួល ម្នាលអានន្ទ ព្រោះហេតុនោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

[១០៣] ឯកមិទាហំ អានន្ទ សមយំ រាជគហេ វិហរាមិ គិជ្ឈកូដេ បព្វតេ ។ តត្រាបិ ខោ តាហំ អានន្ទ អាមន្តេសឹ រមណីយំ អានន្ទ រាជគហំ រមណីយោ គិជ្ឈកូដោ បព្វតោ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា បរិចិតា សុសមារទ្ធា សោ[១] អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ឯវម្បិ ខោ ត្វំ អានន្ទ តថាគតេន ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន តថាគតំ យាចិ តិដ្ឋតុ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជន-

---

១ ឱ. សោតិ បទំ ន ទិស្សតិ ។

[១០៣] ម្នាលអានន្ទ សម័យមួយ តថាគតគង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះឯណោះ ម្នាលអានន្ទ ក្នុងទីនោះឯង តថាគតបានពោលនឹងអ្នកថា ម្នាលអានន្ទ ក្រុងរាជគ្រឹះជាទីគួរត្រេកអរ ភ្នំគិជ្ឈកូដជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ កាលបើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្ប ក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ កាលបើតថាគត ប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្ប ក៏បាន ម្នាលអានន្ទ កាលបើតថាគតបានធ្វើនិមិត្តជាឱឡារិក ធ្វើឱភាសជាឱឡារិក យ៉ាងនេះហើយ អ្នកនៅតែមិនយល់សេចក្តីច្បាស់លាស់បាន មិនអារាធនាតថាគតថា សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជន

សុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ សចេ ត្វំ អានន្ទ តថា-គតំ យាចេយ្យាសិ ទ្វេ វ តេ វាចា តថាគតោ បដិក្ខិបេយ្យ អថ តតិយកំ អធិវាសេយ្យ តស្មា-តិហានន្ទ តុយ្ហេវេតំ ទុក្កដំ តុយ្ហេវេតំ អបរទ្ធំ ។

[១០៤] ឯកមិទាហំ អានន្ទ សមយំ តត្ថេវ រាជ-គហេ វិហរាមិ គោតមនិគ្រោធេ[១] ។ បេ ។ តត្ថេវ រា-ជគហេ វិហរាមិ ចោរប្បបាតេ[២] ។ តត្ថេវ រាជគហេ វិហរាមិ វេភារបស្សេ សត្តបណ្ណគុហាយំ[៣] ។ តត្ថេវ រាជគហេ វិហរាមិ ឥសិគិលិបស្សេ កាឡសិលាយំ ។ តត្ថេវ រាជគហេ វិហរាមិ សីតវនេ សប្បសោណ្ឌិក-បព្ភារេ ។ តត្ថេវ រាជគហេ វិហរាមិ តបោទារាមេ ។ តត្ថេវ រាជគហេ វិហរាមិ វេឡុវនេ កលន្ទកនិ-វាបេ ។ តត្ថេវ រាជគហេ វិហរាមិ ជីវកម្ពវនេ ។ តត្ថេវ រាជគហេ វិហរាមិ មទ្ទកុច្ឆិស្មឹ មិគទាយេ ។

១ ឱ. និគ្រោធារាមេ ។ ២ ឱ. ។ បេ ។ ៣ ឱ. ម. សត្តបណ្ណិគុហាយំ ។

ច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលអានន្ទ បើអ្នកអារាធនាតថាគត ៗ គប្បីឃាត់វាចារបស់អ្នកត្រឹមតែពីរលើក តែដល់បីលើក តថាគត គប្បីទទួល ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

[១០៤] ម្នាលអានន្ទ សម័យមួយ តថាគតនៅក្នុងគោតមនិគ្រោធ ជិតក្រុងរាជគ្រឹះនោះឯង ។ បេ ។ តថាគតនៅជិតជ្រោះជាទីទម្លាក់នូវចោរ ទៀបក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងសត្តបណ្ណគុហា (គុហាដែលសន្ធតដោយដើមសត្តបណ្ណព្រឹក្ស) ខាងភ្នំវេភារៈជិតក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងកាឡសិលា (ថ្មខ្មៅ) ខាងភ្នំឥសិគិលិ ទៀបក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងសប្បសោណ្ឌិកបព្ភារៈ (ញកមានត្រពាំងទឹកជាទីនៅនៃពស់) ក្នុងសីតវ័ន (ព្រៃត្រជាក់) ទៀបក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងតបោទារាម (អារាមជិតស្ទឹងឈ្មោះតបោទា) ជិតក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងវេឡុវនកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងជីវកម្ពវ័ន ជិតក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងមទ្ទកុច្ឆិមិគទាយវ័ន ជិតក្រុងរាជគ្រឹះនោះឯង ។

តត្រាបិ ខោ តាហំ អានន្ទ អាមន្តេសឹ រមណីយំ អានន្ទ រាជគហំ រមណីយោ គិជ្ឈកូដោ បព្វតោ រមណីយោ គោតមនិគ្រោធោ រមណីយោ ចោរប្បបាតោ រមណីយា វេភារបស្សេ សត្តបណ្ណិគុហា រមណីយា ឥសិគិលិបស្សេ កាឡសិលា រមណីយោ សីតវនេ សប្បសោណ្ឌិកបព្ភារោ រមណីយោ តបោទារាមោ រមណីយោ វេឡុវនេ កលន្ទកនិវាបោ រមណីយំ ជីវកម្ពវនំ រមណីយោ មទ្ទកុច្ឆិមិគទាយោ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ[១] អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ឯវម្បិ ខោ ត្វំ អានន្ទ តថាគតេន ឱឡារិកេ និមិត្តេ កយិរមានេ

១ ឱ. សោតិ បទំ នត្ថិ ។

ម្នាលអានន្ទ តថាគតនៅក្នុងទីអម្បាលនោះ បានប្រាប់អ្នកថា ម្នាលអានន្ទ ក្រុងរាជគ្រឹះ ជាទីគួរត្រេកអរ ភ្នំគិជ្ឈកូដ ជាទីគួរត្រេកអរ គោតម-និគ្រោធ ជាទីគួរត្រេកអរ ជ្រោះសម្រាប់ទម្លាក់នូវចោរ ជាទីគួរត្រេកអរ សត្តបណ្ណគុហា ខាងភ្នំវេភារៈ ជាទីគួរត្រេកអរ កាឡសិលាខាងភ្នំឥសិគិលិ ជាទីគួរត្រេកអរ សប្បសោណ្ឌិកបព្ភារៈ ក្នុងសីតវ័ន ជាទីគួរត្រេកអរ តបោទារាម ជាទីគួរត្រេកអរ វេឡុវ័នកលន្ទកនិវាបស្ថាន ជាទីគួរត្រេកអរ ជីវកម្ពវ័ន ជាទីគួរត្រេកអរ មទ្ទកុច្ឆិមិគទាយវ័ន ជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតទៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគត ធ្វើនិមិត្តជាឱឡារិក

ឱឡារិកេ ឱភាសេ កយិរមានេ ជាសក្ខិ បដិវិជ្ឈិតុំ ន តថាគតំ យាចិ តិដ្ឋតុ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកា-នុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ សចេ ត្វំ អានន្ទ តថាគតំ យាចេយ្យាសិ ទ្វេ វ តេ វាចា តថាគតោ បដិក្ខិបេយ្យ អថ តតិយកំ អធិវា-សេយ្យ តស្មាតិហានន្ទ តុយ្ហេវេតំ ទុក្កដំ តុយ្ហេវេតំ អបរទ្ធំ ។

[១០៥] ឯកមិទាហំ អានន្ទ សមយំ ឥធេវ វេ-សាលិយំ វិហរាមិ ឧទេនេ ចេតិយេ ។ តត្រាបិ ខោ តាហំ អានន្ទ អាមន្តេសឹ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេតិយំ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អា-កង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។

ធ្វើឱភាសជាឱឡារិកយ៉ាងនេះហើយ អ្នកនៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនអារាធនាតថាគតថា សូមព្រះមានព្រះភាគ ទ្រង់ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ទ្រង់ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអារាធនាតថាគត ៗ គប្បីឃាត់ពាក្យអ្នកត្រឹមតែ ២ ដងប៉ុណ្ណោះ គង់នឹងទទួលអារាធនាក្នុងវារៈជាគម្រប់ ៣ ដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

[១០៥] ម្នាលអានន្ទ សម័យមួយ តថាគតនៅក្នុងឧទេនចេតិយទៀបក្រុងវេសាលីនេះឯង ។ កាលតថាគតនៅក្នុងឧទេនចេតិយ បានប្រាប់អ្នកថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅគប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។

តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ឯវម្បិ ខោ ត្វំ អានន្ទ តថាគតេន ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន តថាគតំ យាចិ តិដ្ឋតុ ភគវា កប្បំ តិដ្ឋតុ សុគ-តោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកា-នុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ សចេ ត្វំ អានន្ទ តថាគតំ យាចេយ្យាសិ ទ្វេ វ តេ វាចា តថាគតោ បដិក្ខិបេយ្យ អថ តតិយកំ អធិ-វាសេយ្យ តស្មាតិហានន្ទ តុយ្ហេវេតំ ទុក្កដំ តុយ្ហេវេតំ អបរទ្ធំ ។

ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្ប ក៏បាន ម្នាលអានន្ទ កាលបើតថាគតធ្វើនិមិត្តជាឱឡារិក ធ្វើឱភាសជាឱឡារិក យ៉ាងនេះហើយ អ្នកនៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បានឡើយ មិនអារាធនាតថាគតថា សូមព្រះមានព្រះភាគ ទ្រង់ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ទ្រង់ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអារាធនាតថាគត ៗ គប្បីឃាត់ពាក្យអ្នកត្រឹមតែ ២ ដងប៉ុណ្ណោះ គង់នឹងទទួលអារាធនាក្នុងវារៈជាគម្រប់ ៣ ដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

[១០៦] ឯកមិទាហំ អានន្ទ សមយំ ឥធេវ វេសាលិយំ វិហរាមិ គោតមកេ ចេតិយេ ។ បេ ។ ឥធេវ វេសាលិយំ វិហរាមិ សត្តម្ពេ ចេតិយេ ។ ឥធេវ វេសាលិយំ វិហរាមិ ពហុបុត្តេ ចេតិយេ ។ ឥធេវ វេសាលិយំ វិហរាមិ សារន្ទទេ[១] ចេតិយេ ។ ឥទានេវ ខោ តាហំ អានន្ទ អជ្ជ ចាបាលេ ចេតិយេ អាមន្តេសឹ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេតិយំ រមណីយំ គោតមកំ ចេតិយំ រមណីយំ សត្តម្ពំ ចេតិយំ រមណីយំ ពហុបុត្តំ ចេតិយំ រមណីយំ សារន្ទទំ ចេតិយំ រមណីយំ ចាបាលំ ចេតិយំ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា

១ ម. សានន្ទរេ ។

[១០៦] ម្នាលអានន្ទ សម័យមួយ តថាគតនៅក្នុងគោតមកចេតិយ ជិតក្រុងវេសាលីនេះឯង ។ បេ ។ តថាគតនៅក្នុងសត្តម្ពចេតិយ ជិតក្រុងវេសាលីនេះឯង ។ តថាគតនៅក្នុងពហុបុត្តចេតិយ ជិតក្រុងវេសាលីនេះឯង ។ តថាគតនៅក្នុងសារន្ទទចេតិយ ជិតក្រុងវេសាលីនេះឯង ។ ម្នាលអានន្ទ ក្នុងកាលឥឡូវនេះ តថាគតនៅក្នុងបាវាលចេតិយ ក្នុងថ្ងៃនេះ បានប្រាប់អ្នកថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយ ជាទីគួរត្រេកអរ គោតមកចេតិយ ជាទីគួរត្រេកអរ សត្តម្ពចេតិយ ជាទីគួរត្រេកអរ ពហុបុត្តចេតិយ ជាទីគួរត្រេកអរ សារន្ទទចេតិយ ជាទីគួរត្រេកអរ បាវាលចេតិយ ជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្ប ក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ

អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ឯវម្បិ ខោ ត្វំ អានន្ទ តថាគតេន ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន តថាគតំ យាចិ តិដ្ឋតុ ភគ-វា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតា-យ សុខាយ ទេវមនុស្សានន្តិ សចេ ត្វំ អានន្ទ តថាគតំ យាចេយ្យាសិ ទ្វេ វ តេ វាចា តថាគតោ បដិក្ខិបេយ្យ អថ តតិយកំ អធិវាសេយ្យ តស្មាតិ-ហានន្ទ តុយ្ហេវេតំ ទុក្កដំ តុយ្ហេវេតំ អបរទ្ធំ ននុ ឯវំ អានន្ទ មយា បដិកច្ចេវ អក្ខាតំ សព្វេហេវ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថា-ភាវោ តំ កុតេត្ថ អានន្ទ លព្ភា យន្តំ ជាតំ

បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគតធ្វើនិមិត្តជាឱឡារិក ធ្វើឱកាសជាឱឡារិក យ៉ាងនេះហើយ ក៏អ្នកនៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនអារាធនាតថាគតថា សូមព្រះមានព្រះភាគ ទ្រង់ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ទ្រង់ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំង-ឡាយដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអារាធនាតថាគត ៗ គប្បីឃាត់ពាក្យអ្នកត្រឹមតែ ២ ដងប៉ុណ្ណោះ គង់នឹងទទួលអារាធនាក្នុងវារៈជាគម្រប់ ៣ ដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ម្នាលអានន្ទ ក្រែងតថាគតប្រាប់អ្នកជាមុនហើយយ៉ាងនេះថា សេចក្តីព្រាត់ប្រាស សេចក្តីវិនាស សេចក្តីប្រែប្រួលចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអានន្ទ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ មិនព្រាត់ប្រាសក្នុងខន្ធប្រវត្តិនេះ អំពីទីណា ធម្មជាតណា កើតឡើងហើយ

ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតិ ។ យំ ខោ បនេតំ អានន្ទ តថាគតេន ចត្តំ វន្តំ មុត្តំ បហីនំ បដិនិស្សដ្ឋំ ឱស្សដ្ឋោ អាយុសង្ខារោ ឯកំសេន វាចា ភាសិតា ន ចិរំ តថាគតស្ស ប-រិនិព្វានំ ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ តញ្ច[១] តថាគតោ ជីវិតហេតុ បុន បច្ចាគមិស្សតីតិ នេតំ ឋានំ វិជ្ជតិ អាយាមានន្ទ យេន មហាវនំ យេន[២] កូដាគារសា-លា តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា អាយស្មតា អានន្ទេន សទ្ធឹ យេន មហាវនំ យេន[៣] កូដាគារសាលា តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ គច្ឆ ត្វំ អានន្ទ យាវ-តិកា ភិក្ខូ វេសាលឹ ឧបនិស្សាយ វិហរន្តិ តេ សព្វេ

---

១ ឱ. តំ វចនំ ។ ២-៣ ឱ. ម. យេនាតិ បទំ នត្ថិ ។

មានហើយ សង្ខារតាក់តែងហើយ តែងមានសេចក្ដីវិនាសទៅជាធម្មតា ធម្មជាតនោះឯង បុគ្គលនឹងពោលឃាត់ថា កុំវិនាសដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះ មិនមានឡើយ ។ ម្នាលអានន្ទ មួយទៀត ធម្មជាតណា ដែលតថាគតទាត់ចោលហើយ ខ្ជាក់ចោលហើយ ជម្រុះចោលហើយ លះបង់ចោលហើយ បន្សាត់ចោលហើយ អាយុសង្ខារតថាគតដាក់ចុះហើយ វាចាតថាគតពោលដោយពិតថា បរិនិព្វាន នៃតថាគតមិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ តថាគត នឹងត្រឡប់មកកាន់ធម្មជាតនោះវិញទៀត ព្រោះហេតុនៃជីវិតប៉ុណ្ណោះ (ដោយហេតុណា) ហេតុនុ៎ះ មិនមានឡើយ ម្នាលអានន្ទ មកយើងនឹងទៅកាន់កូដាគារសាលា នាមហាវ័ន ។ ព្រះអានន្ទ មានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ក៏ស្ដេចចូលទៅកាន់កូដាគារសាលា នាមហាវ័ន មួយអន្លើដោយព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ អ្នកចូរទៅឲ្យពួកភិក្ខុទាំងប៉ុន្មាន ដែលអាស្រ័យនៅ ក្នុងក្រុងវេសាលី ទាំងអស់នោះ

ឧបដ្ឋានសាលាយំ សន្និបាតេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា[១] យាវ-តិកា ភិក្ខូ វេសាលឹ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេត្វា យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សន្និបតិតោ ភន្តេ ភិក្ខុសង្ឃោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។

[១០៧] អថខោ ភគវា យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និ-សីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ

១ ឱ. ម. បដិស្សុត្វា ។

មកជួបជុំក្នុងឧបដ្ឋានសាលា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ឲ្យពួកភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅ ក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ទ្រង់ជ្រាបនូវកាលគួរ ក្នុងកាលឥឡូវនេះ ។

[១០៧] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅ កាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ បាន

តស្មាតិហ ភិក្ខវេ យេ តេ[១] មយា ធម្មា អភិញ្ញា[២] ទេសិតា តេ វោ សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ[៣] អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិ-តាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ ច តេ ភិក្ខវេ ធម្មា មយា អភិញ្ញា ទេសិតា យេ តេ[៤] សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុ-ជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ សេយ្យថីទំ ។ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា

១ ឱ. វោ ។ ២ ឱ. អភិញ្ញាយ ។ ៣ អទ្ធនីយន្តិបិ ។ ៤ ម. តេ វោ ។

ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយ ដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំង-ឡាយ គប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយ ៗ ដោយប្រការដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថា-គតសម្តែងហើយ ដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយ គប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឲ្យរឿយ ៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះតើដូចម្តេច ។ អ្វីខ្លះ ។ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤

បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥមេ ខោ តេ[១] ភិក្ខវេ ធម្មា មយា អភិញ្ញា ទេសិតា យេ តេ[២] សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា[៣]

---

១ ឱ. តេតិ បទំ នត្ថិ ។ ម. វោ ។ ២ ឱ. ម. តេ វោ ។ ៣ ឥតោ បរំ ឱរោបិយបោត្ថកេ បរិបក្កោ វយោ មយ្ហំ..... ទុក្ខស្សន្តំ ករិស្សតីតិ ទិស្សន្តិ ។

ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយ ដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយ គប្បីរៀនដោយប្រពៃ ហើយសេពចម្រើន ធ្វើឲ្យរឿយ ៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿន អ្នកទាំងឡាយ សង្ខារទាំងឡាយ មានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយ ចូរញុំាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគតមិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់មានព្រះបន្ទូលដូច្នេះ តទៅទៀតថា

[១០៨] ទហរាបិ ច យេ វុឌ្ឍា
យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច
សព្វេ មច្ចុបរាយនា ។
យថាបិ កុម្ភការស្ស
កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច
យញ្ច បក្កំ យញ្ច អាមកំ
សព្វំ ភេទបរិយន្តំ
ឯវំ មច្ចាន ជីវិតំ ។
អថាបរំ ឯតទវោច សត្ថា
បរិបក្កោ វយោ មយ្ហំ
បរិត្តំ មម ជីវិតំ
បហាយ វោ គមិស្សាមិ
កតំ មេ សរណមត្តនោ ។

[១០៨] ពួកជនណា ៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។ ភាជន៍ដី ដែលស្មូនផ្ទាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

ព្រះសាស្តា ទ្រង់មានព្រះបន្ទូល ដូច្នេះ តទៅទៀតថា

វ័យរបស់តថាគត ចាស់ហើយ ជីវិតរបស់តថាគត មានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅ ឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។

អប្បមត្តា សតីមន្តោ
សុសីលា ហោថ ភិក្ខវោ
សុសមាហិតសង្កប្បា
សចិត្តមនុរក្ខថ ។
យោ ឥមស្មឹ ធម្មវិនយេ
អប្បមត្តោ វិហរិស្សតិ[១]
បហាយ ជាតិសំសារំ
ទុក្ខស្សន្តំ ករិស្សតីតិ ។

ពុទ្ធភាណវារំ តតិយំ[២] ។

[១០៩] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ នាគាវលោកិតំ[៣] វេសាលឹ អបលោកេត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥទំ បច្ឆិមកំ អានន្ទ តថាគតស្ស វេសាលិយា ទស្សនំ ភវិស្សតិ អាយាមានន្ទ យេន ភណ្ឌគាមោ តេនុបសង្កមិស្សាមាតិ ។

១ ឱ. វិហេស្សតិ ។ ម. វិហេស្សតិ ។ ២ ឱ. តតិយភាណវារំ និដ្ឋិតំ ។ ម. ភាណវារំ តតិយំ ។ ៣ ឱ. ម. នាគាបលោកិតំ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួនឲ្យរឿយ ៗ ចុះ ។ ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ (ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខាន ។

ចប់ ពុទ្ធភាណវារៈទី ៣ ។

[១០៩] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរចូលទៅបិណ្ឌបាត ក្នុងក្រុងវេសាលី លុះស្តេចទៅបិណ្ឌបាត ក្នុងក្រុងវេសាលីហើយ ទ្រង់ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ទ្រង់ងាកក្រឡេកមើលនូវក្រុងវេសាលី ដូចជាដំរីដែលក្រឡេកបែរមើល (នូវទីខាងក្រោយ) ហើយត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ តថាគត ឃើញក្រុងវេសាលីម្តងនេះ ជាបច្ឆិមទស្សនៈ (ការឃើញទីបំផុត) ម្នាលអានន្ទ មក យើងនឹងទៅកាន់ភណ្ឌគ្រាម ។

ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោ-
សិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ
យេន ភណ្ឌគ្គាមោ តទវសរិ ។ តត្រ សុទំ ភគវា ភណ្ឌ-
គ្គាមេ វិហរតិ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ
ចតុន្នំ ភិក្ខវេ ធម្មានំ អននុពោធា អប្បដិវេធា ឯវមិទំ
ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។
កតមេសំ ចតុន្នំ ។ អរិយស្ស ភិក្ខវេ សីលស្ស
អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ
សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ អរិយស្ស ភិក្ខវេ
សមាធិស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃ-
មទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។

ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់ភណ្ឌគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងភណ្ឌគ្រាមនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងសង្សារវដ្ត) អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវធម៌ទាំង ៤ យ៉ាង ។ ធម៌ទាំង ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសីល ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសមាធិ ។

អរិយាយ ភិក្ខវេ បញ្ញាយ អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ អរិយាយ ភិក្ខវេ វិមុត្តិយា អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ តយិទំ ភិក្ខវេ អរិយំ សីលំ អនុពុទ្ធំ បដិវិទ្ធំ អរិយោ សមាធិ អនុពុទ្ធោ បដិវិទ្ធោ អរិយា បញ្ញា អនុពុទ្ធា បដិវិទ្ធា អរិយា វិមុត្តិ អនុពុទ្ធា បដិវិទ្ធា ឧច្ឆិន្នា ភវតណ្ហា ខីណា ភវនេត្តិ នត្ថិទានិ បុនព្ភវោតិ ។ ឥទមវោច ភគវា ឥទំ វត្វាន[១] សុគតោ អថាបរំ ឯតទវោច សត្ថា

---

១ ឱ. វត្វា ។

ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយ-វិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ អរិយសីលនោះឯង ។ ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយសមាធិដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយបញ្ញាដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយវិមុត្តិ ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា គឺសេចក្តីប្រាថ្នាក្នុងភព ក៏សូន្យទៅ ខ្សែគឺតណ្ហា ដែលអាចនាំសត្វអំពីភពមួយទៅភពមួយក៏អស់ទៅ ភពថ្មីទៀត ក៏មិនមានក្នុងកាលឥឡូវនេះឡើយ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់ត្រាស់ដូច្នេះតទៅទៀតថា

[១១០] សីលំ សមាធិ បញ្ញា ច
វិមុត្តិ ច អនុត្តរា
អនុពុទ្ធា ឥមេ ធម្មា
គោតមេន យសស្សិនា
ឥតិ ពុទ្ធោ អភិញ្ញាយ
ធម្មមក្ខាតិ[១] ភិក្ខុនំ
ទុក្ខស្សន្តង្ករោ[២] សត្ថា
ចក្ខុមា បរិនិព្វុតោតិ ។

[១១១] តត្រាបិ សុទំ ភគវា ភណ្ឌគាមេ វិហរន្តោ ឯតទេវ ពហុលំ ភិក្ខូនំ ធម្មឹ កថំ ករោតិ ឥតិ សីលំ ឥតិ សមាធិ ឥតិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

---

១ ឱ. ម. ធម្មមក្ខាសិ ។ ២ ឱ. ម. ទុក្ខស្សន្តករោ ។

[១១០] ធម៌ទាំងនេះ គឺសីល សមាធិ បញ្ញា និងវិមុត្តិដ៏ប្រសើរ ព្រះគោតមព្រះអង្គមានយស បានត្រាស់ដឹងហើយ ព្រះពុទ្ធទ្រង់ត្រាស់ដឹង យ៉ាងនេះហើយ ទើបសម្ដែងធម៌ប្រាប់ចំពោះភិក្ខុទាំងឡាយ ព្រះសាស្ដាមានចក្ខុ ទ្រង់ធ្វើនូវព្រះនិព្វានជាទីបំផុត នៃកងទុក្ខ ទ្រង់បរិនិព្វានហើយ ។

[១១១] បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកណ្ឌគ្រាមនោះ ទ្រង់ធ្វើធម្មីកថាជាច្រើន ចំពោះភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំ ដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំ ដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំ ដោយបញ្ញាហើយ រមែងរួចស្រឡះដោយប្រពៃ ចាកអាសវៈទាំង-ឡាយ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[១១២] អថខោ ភគវា ភណ្ឌគ្គាមេ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន ហត្ថិគ្គាមោ អម្ពគ្គាមោ ជម្ពុគ្គាមោ យេន(១) ភោគនគរំ តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ភោគនគរំ តទវសរិ ។ តត្រ សុទំ ភគវា ភោគនគរេ វិហរតិ អានន្ទេ ចេតិយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ចត្តារោមេ ភិក្ខវេ មហាបទេសេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច

---

១ ឱ. ហត្ថិគាមោ ។ បេ ។ អម្ពគាមោ... ជម្ពុគាមោ... យេន ។ ម. ហត្ថិគាមោ យេន អម្ពគាមោ យេន ជម្ពុគាមោ យេន ។

[១១២] គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភណ្ឌគ្រាម តាមសមគួរ ដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ហត្ថិគ្រាម អម្ពគ្រាម ជម្ពុគ្រាម និងភោគនគរ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់ភោគនគរ ព្រមដោយភិក្ខុសង្ឃជាច្រើនអង្គ ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអានន្ទចេតិយ ជិតភោគនគរនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងមហាបទេសទាំង ៤ នេះ អ្នកទាំងឡាយ ចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា

[១១៣] ឥធ ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុ សាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ ។ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱសារេតព្វានិ[១] វិនយេ សន្ទស្សេតព្វានិ ។ តានិ ចេ សុត្តេ ឱសារិយមានានិ វិនយេ សន្ទស្សិយមានានិ ន ចេវ សុត្តេ ឱសរន្តិ[២] ន ច វិនយេ[៣] សន្ទិស្សន្តិ ។ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ ន ចេវ តស្ស ភគវតោ វចនំ ឥមស្ស ច ភិក្ខុនោ ទុគ្គហិតន្តិ ឥតិ ហេតំ ភិក្ខវេ ឆឌ្ឌេយ្យាថ ។ តានិ ចេ សុត្តេ ឱសារិយមានានិ[៤] វិនយេ សន្ទស្សិយមានានិ សុត្តេ ចេ[៥] ឱសរន្តិ វិនយេ ចេ សន្ទិស្សន្តិ ។

---

១ អ. ឱតារេតព្វានិ ។ ២ អ. ឱ. ឱតរន្តិ ។ ៣ ឱ. ន វិនយេ ។ ៤ ឱ. ឱតារិយមានានិ ។ ៥ ឱ. ម. ចេវ ។

[១១៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ខ្ញុំបានស្តាប់ បានទទួលចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ហើយ ត្រូវរៀនន្ទូវបទនិងព្យញ្ជនៈទាំងនោះ ឲ្យចាំល្អ ហើយស្ទាបស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទាបស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ មិនប្រជុំចុះ គឺមិនមានក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិន័យផងទេ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះទេ ជាពាក្យដែលភិក្ខុនេះរៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ត្រូវចោលពាក្យនុ៎ះចេញ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទាបស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ ក៏ប្រជុំចុះក្នុងព្រះសូត្រផង ប្រាកដក្នុងព្រះវិន័យផង ។

និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ តស្ស ភគវតោ វចនំ ឥមស្ស ច ភិក្ខុនោ សុគ្គហិតន្តិ ឥទំ ភិក្ខវេ បឋមំ មហាបទេសំ ធារេយ្យាថ ។

[១១៤] ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អមុកស្មឹ នាម អាវាសេ សង្ឃោ វិហរតិ សត្ថេរោ សបាមោក្ខោ តស្ស មេ សង្ឃស្ស សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុ សាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ ។ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱសារេតព្វានិ វិនយេ សន្ទស្សេតព្វានិ ។ តានិចេ សុត្តេ ឱសារិយមានានិ វិនយេ សន្ទស្សិយមានានិ ន ចេវ សុត្តេ ឱសរន្តិ ន ច វិនយេ សន្ទិស្សន្តិ ។ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ ន ចេវ តស្ស ភគវតោ វចនំ តស្ស ច ភិក្ខុសង្ឃស្ស[១] ទុគ្គហិតន្តិ ឥតិ ហេតំ ភិក្ខវេ

១ ឱ. ម. សង្ឃស្ស ។

អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះ ដែលភិក្ខុនេះរៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាបឋមនេះចុះ ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃនៅក្នុងអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មានទាំងភិក្ខុជាប្រធាន ខ្ញុំបានស្តាប់បានទទួលចំពោះមុខព្រះសង្ឃនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យបៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់នូវភាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ហើយ ត្រូវរៀននូវបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ មិនប្រជុំចុះក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិន័យផងទេ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគទេ ជាពាក្យដែលភិក្ខុសង្ឃនោះរៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ

ឆឌ្ឌេយ្យាថ ។ តានិ ចេ សុត្តេ ឱសារិយមានានិ វិន-
យេ សន្ទស្សិយមានានិ សុត្តេ ចេ ឱសរន្តិ វិនយេ ចេ
សន្ទិស្សន្តិ ។ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ តស្ស ភគវ-
តោ វចនំ តស្ស ច សង្ឃស្ស សុគហិតន្តិ ឥទំ ភិក្ខវេ
ទុតិយំ មហាបទេសំ ធារេយ្យាថ ។

[១១៩] ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អមុ-
កស្មឹ នាម អាវាសេ សម្ពហុលា ថេរា ភិក្ខូ វិហរន្តិ
ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកា-
ធរា តេសំ មេ ថេរានំ សម្មុខា សុតំ សម្មុខា បដិគ្គហិ-
តំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុ សាសនន្តិ
តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ ។ បេ ។
ន វិនយេ សន្ទិស្សន្តិ ។ និដ្ឋមេត្ថ គន្តព្វំ អទ្ធា
ឥទំ ន ចេវ តស្ស ភគវតោ វចនំ តេសញ្ច ថេរានំ
ទុគ្គហិតន្តិ ឥតិ ហេតំ ភិក្ខវេ ឆឌ្ឌេយ្យាថ ។ តានិ ចេ

គប្បីចោលពាក្យនុ៎ះចេញ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំង-ឡាយ ស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ ក៏ប្រជុំចុះក្នុងព្រះសូត្រផង ប្រាកដក្នុងព្រះវិន័យផង ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះ ដែលព្រះសង្ឃនោះរៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាគម្រប់ពីរនេះចុះ ។

[១១៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈច្រើនអង្គ នៅក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រ-ទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈទាំងនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរនឹងភាសិត របស់ភិក្ខុនោះឡើយ ។ បេ ។ បទនិងព្យញ្ជនៈ មិនប្រាកដក្នុងព្រះវិន័យ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះទេ ជាពាក្យដែលព្រះថេរៈទាំងនោះ រៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីចោលពាក្យនុ៎ះចេញ ។ បទនិងព្យញ្ជនៈទាំងនោះ

សុត្តេ ឱសារិយមានានិ ។ បេ ។ វិនយេ សន្ទិស្សន្តិ ។ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ តស្ស ភគវតោ វចនំ តេ-សញ្ច ថេរានំ សុគហិតន្តិ ឥទំ ភិក្ខវេ តតិយំ មហា-បទេសំ ធារេយ្យាថ ។

[១១៦] ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អ-មុកស្មឹ នាម អាវាសេ ថេរោ ភិក្ខុ វិហរតិ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ តស្ស មេ ថេរស្ស សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុ សាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្ប-ដិក្កោសិតព្វំ ។ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱសារេតព្វានិ វិនយេ សន្ទស្សេតព្វានិ ។ តានិ ចេ សុត្តេ ឱសារិយមានានិ វិនយេ សន្ទស្សិយមានានិ ន ចេវ សុត្តេ ឱសរន្តិ ន ច វិនយេ សន្ទិស្សន្តិ ។

កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងព្រះសូត្រ ។ បេ ។ ប្រាកដក្នុងព្រះវិន័យ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះ ដែលព្រះថេរៈទាំងនោះ រៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាគម្រប់ ៣ នេះចុះ ។

[១១៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈនៅក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់បានទទួលចំពោះមុខព្រះថេរៈអង្គនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ កុំអាលត្រេកអរ កុំអាលឃាត់នូវភាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ហើយ គប្បីរៀននូវបទនិងព្យញ្ជនៈទាំងនោះ ឲ្យចាំល្អ ហើយស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ មិនប្រជុំចុះក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិន័យផងទេ ។

និដ្ឋមេត្ថ គន្តព្វំ ។ បេ ។ អទ្ធា ឥទំ តស្ស ភគវតោ វចនំ តស្ស ច ថេរស្ស សុគហិតន្តិ ឥទំ ភិក្ខវេ ចតុត្ថំ មហាបទេសំ ធារេយ្យាថ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ មហាបទេសេ ធារេយ្យថាតិ ។ តត្របិ សុទំ ភគវា ភោគនគរេ វិហរតិ[១] អានន្ទេ ចេតិយេ ឯតទេវ ពហុលំ ភិក្ខូនំ ធម្មឹ កថំ ករោតិ ឥតិ សីលំ ឥតិ សមាធិ ឥតិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

[១១៧] អថខោ ភគវា ភោគនគរេ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន បាវា តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

១ ឱ. វិហរន្តោ ។

អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះ ។ បេ ។ ថា នេះ ជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះ ដែលព្រះថេរៈនោះ រៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំង-ឡាយ គប្បីចាំទុកនូវមហាបទេសជាគម្រប់ ៤ នេះចុះ ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសទាំង ៤ នេះឯង ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអានន្ទចេតិយ ជិតភោគនគរនោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំ ដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះដោយប្រពៃ ចាកអាសវៈទាំងឡាយ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[១១៧] គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភោគនគរ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយត្រាស់ហៅ ព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ក្រុងបាវា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

២៦៧

## មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ ចុន្ទកម្មារបុត្តវត្ថុ

អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ចាវា តទវសរិ ។ តត្រ សុទំ ភគវា ចាវាយំ វិហរតិ ចុន្ទស្ស កម្មារបុត្តស្ស អម្ពវនេ ។ អស្សោសិ ខោ ចុន្ទោ កម្មារបុត្តោ ភគវា កិរ ចាវំ អនុប្បត្តោ ចាវាយំ វិហរតិ មយ្ហំ អម្ពវនេតិ ។ អថខោ ចុន្ទោ កម្មារបុត្តោ យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចុន្ទំ កម្មារបុត្តំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ ចុន្ទោ កម្មារបុត្តោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទ-បិតោ សមុត្តេជិតោ សម្បហំសិតោ ភគវន្តំ ឯត-ទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា

ទើបព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់ក្រុងបាវា ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពវ័ន (ព្រៃស្វាយ) របស់នាយចុន្ទកម្មារបុត្ត (កូនជាងមាស) ទៀបក្រុងបាវានោះ ។ នាយចុន្ទកម្មារបុត្ត បានឮដំណឹងថា ព្រះមានព្រះភាគ ស្តេចមកដល់ក្រុងបាវា ឥឡូវនេះ ទ្រង់គង់នៅក្នុងអម្ពវ័នរបស់អាត្មាអញ ទៀបក្រុងបាវា ។ គ្រានោះ នាយចុន្ទកម្មារបុត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះនាយចុន្ទកម្មារបុត្ត អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ នាយចុន្ទកម្មារបុត្ត កាលដែលព្រះមានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួល

២៦៨



តុណ្ហីភាវេន ។ អថខោ ចុន្ទោ កម្មារបុត្តោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ចុន្ទោ កម្មារបុត្តោ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា បហូតញ្ច សូករមទ្ទវំ ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន ចុន្ទស្ស កម្មារបុត្តស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ចុន្ទំ កម្មារបុត្តំ អាមន្តេសិ យន្តេ ចុន្ទ សូករមទ្ទវំ បដិយត្តំ តេន មំ បរិវិស យំ បនញ្ញំ ខាទនីយំ ភោជនីយំ បដិយត្តំ ភិក្ខុសង្ឃំ បរិវិសាតិ ។

និមន្តដោយតុណ្ហីភាព ។ លុះនាយចុន្ទកម្មារបុត្ត បានដឹងច្បាស់ថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ ទើបនាយចុន្ទកម្មារបុត្ត ក៏ឲ្យគេចាត់ចែងខាទនីយភោជនីយាហារមានរសដ៏ពិសា ព្រមទាំងសូករមទ្ទវៈ[១]ដ៏ច្រើន ក្នុងផ្ទះរបស់ខ្លួនហើយ ឲ្យគេទៅក្រាបទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់លំនៅរបស់នាយចុន្ទកម្មារបុត្ត ជាមួយនឹងភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់រួចហើយ ក៏ត្រាស់នឹងនាយចុន្ទកម្មារបុត្តថា ម្នាលនាយចុន្ទ សូករមទ្ទវៈណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសតថាគត ដោយសូករមទ្ទវៈនោះចុះ ឯខាទនីយភោជនីយាហារដទៃណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសភិក្ខុសង្ឃ ដោយខាទនីយភោជនីយាហារនោះចុះ ។

---

១ ពាក្យថា សូករមទ្ទវៈ បានដល់សាច់ជ្រូកដែលគេចិញ្ច្រាំឲ្យល្អិតទន់ហើយចម្អិនដោយល្អ ។ មួយទៀត សូករមទ្ទវៈនេះ ជាឈ្មោះភោជនដែលតាក់តែងត្រូវតាមតម្រានៃម្ហូបមានរសឆ្ងាញ់ ។ អដ្ឋកថា ។

២៦៩



ឯវំ ភន្តេតិ ខោ ចុន្ទោ កម្មារបុត្តោ ភគវតោ បដិស្សុត្វា យំ អហោសិ សូករមទ្ទវំ បដិយត្តំ តេន ភគវន្តំ បរិវិសិ យំ បនញ្ញំ ខាទនីយំ ភោជនីយំ បដិយត្តំ តេន ភិក្ខុសង្ឃំ បរិវិសិ ។ អថខោ ភគវា ចុន្ទំ កម្មារ-បុត្តំ អាមន្តេសិ យន្តេ ចុន្ទ សូករមទ្ទវំ អវសិដ្ឋំ តំ សោព្ភេ និខណាហិ នាហន្តំ ចុន្ទ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្ម-ណិយា បជាយ សទេវមនុស្សាយ យស្ស តំ បរិភុត្តំ សម្មា បរិណាមំ គច្ឆេយ្យ អញ្ញត្រ តថាគតស្សាតិ ។ ឯវំ ភន្តេតិ ខោ ចុន្ទោ កម្មារបុត្តោ ភគវតោ បដិស្សុត្វា យំ អហោសិ សូករមទ្ទវំ អវសិដ្ឋំ តំ សោព្ភេ និខណិត្វា

នាយចុន្ទកម្មារបុត្ត ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏អង្គាសព្រះមានព្រះភាគ ដោយសូករមទ្ទវៈ ដែលខ្លួនតាក់តែងហើយ អង្គាសភិក្ខុសង្ឃ ដោយខាទនីយភោជនីយាហារ ដទៃ ដែលខ្លួនតាក់តែងហើយ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងនាយចុន្ទកម្មារបុត្តថា ម្នាលនាយចុន្ទ សូករមទ្ទវៈណារបស់អ្នក ដែលនៅសល់ អ្នកចូរកប់នូវសូករមទ្ទវៈនោះ ក្នុងរណ្តៅទៅ ម្នាលនាយចុន្ទ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញបុគ្គលណាមួយ ដែលបរិភោគនូវសូករមទ្ទវៈនោះ ហើយ សូករមទ្ទវៈនោះ គប្បីដល់នូវកិរិយារលួយទៅដោយល្អឡើយ វៀរលែងតែ តថាគតចេញ ។ នាយចុន្ទកម្មារបុត្ត ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កប់សូករមទ្ទវៈដែលនៅសល់នោះ ក្នុងរណ្តៅ

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចុន្ទំ កម្មារបុត្តំ ភគវា ធម្មិយា កថាយ សន្ទ-ស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ភគវតោ ចុន្ទស្ស កម្មារបុត្តស្ស ភត្តំ ភុត្តាវិស្ស ខរោ អាពាធោ ឧបជ្ជិ លោហិតបក្ខន្ទិកា សព្វាឡ្ហា វេទនា វត្តន្តិ មរណន្តិ-កា ។ តាបិ[១] សុទំ ភគវា សតោ សម្បជានោ អធិ-វាសេសិ អវិហញ្ញមានោ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន កុសិនារា តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

១ ឱ. ម. តា ។

ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះនាយចុន្ទកម្មារបុត្ត អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយក៏ក្រោកចាកអាសនៈ ស្ដេចចេញទៅ ។ លុះព្រះមានព្រះភាគ ទ្រង់ឆាន់កត្តរបស់នាយចុន្ទកម្មារបុត្តរួចហើយ ព្រះអាពាធដ៏ខ្លាំង ក៏កើតឡើង វេទនាដ៏ក្លៀវក្លា កើតអំពីលោហិតប្បក្ខន្ទិកាពាធ (អាពាធចុះព្រះលោហិត) ជិតនឹងដល់នូវមរណៈ ក៏ប្រព្រឹត្តទៅ ។ បានឮថា ព្រះមានព្រះភាគ មានព្រះសតិនិងសម្បជញ្ញៈមិនបានលំបាក ទ្រង់អត់សង្កត់នូវវេទនានោះបាន ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ក្រុងកុសិនារា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូល នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[១១៨] ចុន្ទស្ស ភត្តំ ភុញ្ជិត្វា
កម្មារស្សាតិ មេ សុតំ
អាពាធំ សម្ផុសិ[១] ធីរោ
បពាឡ្ហំ មារណន្តិកំ ។
ភុត្តស្ស ច[២] សូករមទ្ទវេន
ព្យាធិ បពាឡ្ហោ[៣] ឧទបាទិ សត្ថុ[៤]
វិរេចមានោ ភគវា អវោច
គច្ឆាមហំ កុសិនារំ នគរន្តិ ។

(ឥមា គាថាយោ សង្គីតិកាលេ សង្គីតិការកេហិ វុត្តា[៥])

[១១៩] អថខោ ភគវា មគ្គា ឱក្កម្ម យេន អញ្ញតរំ[៦] រុក្ខមូលំ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ ចតុគ្គុណំ សង្ឃាដឹ បញ្ញបេហិ កិលន្តោស្មិ អានន្ទ

១ ឱ. សម្ផុសី ។ ម. សំផុសិ ។ ២ ឱ. ម. ច ។ ៣ ឱ. វ្យាធិប្បពាឡ្ហា ។ ម. បពាឡ្ហោ ។ ៤ ឱ. ម. សត្ថុនោ ។ ៥ ឱ. ម. បោត្ថកេសុ ឥមា គាថាយោ វុត្តាតិ ន ទិស្សន្តិ ។ ៦ ឱ. យេនញ្ញតរំ ។

[១១៨] ខ្ញុំបានឮថា ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់សោយភត្ត របស់នាយចុន្ទកម្មារបុត្ត ហើយមានព្រះអាពាធជាទម្ងន់ ជិតនឹងមរណៈ ។ ព្យាធិដ៏ក្លាកើតដល់ព្រះសាស្តា ដែលសោយភត្ត ដោយសូករមទ្ទវៈ ព្រះមានព្រះភាគ ទ្រង់មានអាពាធចុះព្រះលោហិតរឿយ ៗ ទើបមានព្រះពុទ្ធតម្រាស់ថា តថាគតនឹងទៅកាន់ក្រុងកុសិនារា ។

(គាថាទាំងនេះ ព្រះសង្គីតិកាចារ្យទាំងឡាយ សម្តែងហើយក្នុងកាលធ្វើសង្គីតិ) ។

[១១៩] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចៀសចេញ អំពីផ្លូវ ហើយទ្រង់ចូលទៅកាន់ម្លប់ឈើ ១ ដើម លុះចូលដល់ហើយ ទ្រង់ត្រាស់ នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកក្រាលសង្ឃាដីមានជាន់ ៤ ឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតល្ហិតល្ហៃណាស់

និសីទិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា ចតុគ្គុណំ សង្ឃាដឹ បញ្ញបេសិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ ចាតីយំ អាហរ បិបាសិតោស្មិ អានន្ទ បិវិស្សាមីតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥទានិ ភន្តេ បញ្ចមត្តានិ សកដសតានិ អភិក្កន្តានិ[១] តំ ចក្កច្ឆិន្នំ ឧទកំ បរិត្តំ លុឡិតំ អាវិលំ សន្ទតិ អយំ ភន្តេ កកុធនទី[២] អវិទូរេ អច្ឆោទកា សាតោទកា សីតោទកា សេតោទកា សុបតិត្ថា រមណីយា ឯត្ថ ភគវា ចាតីយញ្ច បិវិស្សតិ គត្តានិ ច សីតីករិស្សតីតិ[៣] ។ ទុតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ។ ឥង្ឃ មេ ត្វំ អានន្ទ ចាតីយំ អាហរ បិបាសិតោស្មិ

១ ឱ. ម. អតិក្កន្តានិ ។ ២ ឱ. កកុត្ថា នទី ។ ម. កកុធា នទី ។ ៣ ឱ. ម. សីតំ ករិស្សតីតិ ។

តថាគតអង្គុយសិន ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូល នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយក៏ក្រាលសង្ឃាដី មានជាន់ ៤ ថ្នាយ ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់រួចហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទ មានអាយុថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគត ស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ រទេះចំនួន ៥០០ គេបរឆ្លងទៅហើយ ទឹកនោះតិច កង់រទេះក៏កិន ល្អក់រឹករវ ហូរមក បពិត្រព្រះអង្គដ៏ចម្រើន ស្ទឹងកកុធៈជិតនៅនេះ មានទឹកថ្លា មានទឹកមានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករង មានកំពង់ក៏ស្រួល ជាទីគួរត្រេកអរ ក្នុងស្ទឹងនុ៎ះ ព្រះមានព្រះភាគនឹងសោយទឹកក៏បាន នឹងស្រង់ព្រះកាយ ឲ្យត្រជាក់ស្រួលក៏បាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុ ជាគម្រប់ពីរដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់

អានន្ទ បិវិស្សាមីតិ ។ ទុតិយម្បិ ខោ អាយស្មា
អានន្ទោ ភគវន្តំ ឯតទវោច ឥទានិ ភន្តេ បញ្ច-
មត្តានិ សកដសតានិ អតិក្កន្តានិ តំ ចក្កច្ឆិន្នំ
ឧទកំ បរិត្តំ លុឡិតំ អាវិលំ សន្ទតិ អយំ ភន្តេ ក-
កុធនទី អវិទូរេ អច្ឆោទកា សាតោទកា សីតោទកា
សេតោទកា សុបតិត្ថា រមណីយា ឯត្ថ ភគវា បានី-
យញ្ច បិវិស្សតិ គត្តានិបិ សីតីករិស្សតីតិ ។ តតិ-
យម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ
មេ ត្វំ អានន្ទ បានីយំ អាហរ បិបាសិតោស្មិ អានន្ទ
បិវិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ
ភគវតោ បដិស្សុត្វា បត្តំ គហេត្វា យេន សា នទិកា
តេនុបសង្កមិ ។ អថខោ សា នទិកា ចក្កច្ឆិន្នា ប-
រិត្តា លុឡិតា អាវិលា សន្ទមានា អាយស្មន្តេ អានន្ទេ
ឧបសង្កមន្តេ អច្ឆា វិប្បសន្នា អនាវិលា សន្ទ-
តិ[១] អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ

---

១ ឱ. ម. សន្ទិត្ថ ។

តថាគតនឹងឆាន់ទឹកបន្តិច ។ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់-មិញនេះ រទេះចំនួន ៥០០ គេបរឆ្លងទៅហើយ ទឹកនោះតិច កង់រទេះក៏កិន ល្អក់រីករវ ហូរមក បពិត្រព្រះអង្គដ៏ចម្រើន ស្ទឹងកកុធៈជិតនៅនេះ មានទឹកថ្លា មានទឹកមានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករង មានកំពង់ក៏ស្រួល ជាទីគួរត្រេកអរ ក្នុងស្ទឹងនុ៎ះ ព្រះមានព្រះភាគ នឹងសោយទឹកក៏បាន នឹងស្រង់ព្រះកាយ ឲ្យត្រជាក់ស្រួលក៏បាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុ ជាគម្រប់បីដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមក ឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច ។ ព្រះអានន្ទមានអាយុ ក៏ទទួលព្រះបន្ទូល នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កាន់បាត្រដើរតម្រង់ទៅស្ទឹងនោះ ។ លំដាប់នោះ ស្ទឹងតូចដែលកង់កិន ល្អក់រីករវ ហូរមកនោះ កាលដែលព្រះអានន្ទមានអាយុ ចូលទៅដល់ហើយ ក៏ត្រឡប់ទៅជារងថ្លា មិនល្អក់ហូរមកវិញ ។ ទើបព្រះអានន្ទមានអាយុ មានសេចក្ដីត្រិះរិះដូច្នេះថា

អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ តថាគតស្ស មហិទ្ធិកតា មហានុភាវតា អយំ ហិ សា នទិកា ចក្កច្ឆិន្នា បរិត្តា លុឡិតា អាវិលា សន្ទមានា មយិ ឧបសង្កមន្តេ អច្ឆា វិប្បសន្នា អនាវិលា សន្ទតីតិ ។ បត្តេន ចានីយំ អា-ទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគ-វន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ តថាគតស្ស មហិទ្ធិកតា មហានុភាវតា ឥទានិ សា ភន្តេ នទិកា ចក្កច្ឆិន្នា បរិត្តា លុឡិតា អាវិលា សន្ទមានា មយិ ឧបសង្កមន្តេ អច្ឆា វិប្បសន្នា អនាវិលា សន្ទិត្ថ បិវតុ ភគវា ចានីយំ បិវតុ សុគតោ ចានីយន្តិ ។ អថខោ ភគវា ចានីយំ អបាយិ ។

[១២០] តេន ខោ បន សមយេន បុក្កុ-សោ មល្លបុត្តោ អាឡារស្ស កាលាមស្ស សាវកោ កុសិនារាយ ចាវំ អទ្ធានមគ្គប្បដិបន្នោ ហោតិ ។

ឱហ្ន៎ ហេតុនេះ ជាអស្ចារ្យពេកណាស់ ឱហ្ន៎ ហេតុនេះ ចម្លែកពេកណាស់ ស្ទឹងតូចនេះឯង ដែលកង់កិនល្អក់រីករហូរមក កាលបើអាត្មាអញ ចូលមកដល់ ក៏ត្រឡប់ទៅជាទឹករថ្លាស្អាត មិនល្អក់ហូរមកវិញ ព្រោះព្រះតថាគតមានឫទ្ធិធំ មានអានុភាពធំ ។ ព្រះអានន្ទ ក៏ដងទឹកដោយបាត្រ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ជាអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ស្ទឹងតូចដែលកង់កិនល្អក់រីករកំពុងហូរមកនោះ កាលដែលខ្ញុំព្រះអង្គចូលទៅដល់ហើយ ក៏ត្រឡប់ទៅជាទឹករថ្លាស្អាត មិនល្អក់ហូរមកវិញ ព្រោះព្រះអង្គមានឫទ្ធិធំ មានអានុភាពធំ សូមព្រះមានព្រះភាគ ទ្រង់សោយព្រះសុទ្ធរស សូមព្រះសុគត ទ្រង់សោយព្រះសុទ្ធរស ។ លំដាប់នោះ ព្រះមានព្រះភាគ ក៏ទ្រង់សោយព្រះសុទ្ធរស ។

[១២០] សម័យនោះឯង មល្លបុត្ត (ព្រះរាជបុត្រនៃមល្លក្សត្រិយ៍) ព្រះនាមបុក្កុសៈ ជាសាវ័ករបស់អាឡារតាបស កាលាមគោត្ត ចេញអំពីក្រុងកុសិនារា ដើរទៅតាមផ្លូវឆ្ងាយ សំដៅទៅកាន់ក្រុងបាវា ។

អទ្ទសា ខោ បុក្កុសោ មល្លបុត្តោ ភគវន្តំ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នំ ទិស្វាន[១] យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បុក្កុសោ មល្លបុត្តោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ សន្តេន វត ភន្តេ បព្វជិតា វិហារេន វិហរន្តិ ភូតបុព្វំ ភន្តេ អាឡារោ កាលាមោ អទ្ធានមគ្គប្បដិបន្នោ មគ្គា ឱក្កម្ម អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ អថខោ ភន្តេ បញ្ចមត្តានិ សកដសតានិ អាឡារំ កាលាមំ និស្សាយ និស្សាយ អតិក្កមឹសុ អថខោ ភន្តេ អញ្ញតរោ បុរិសោ តស្ស សកដសត្ថស្ស បិដ្ឋិតោ បិដ្ឋិតោ អាគច្ឆន្តោ យេន អាឡារោ កាលាមោ តេនុបសង្កមិ

១ ឱ. ម. ទិស្វា ។

បុក្កុសមល្លបុត្ត បានឃើញព្រះមានព្រះភាគ គង់ក្រោមម្លប់ឈើ ១ ដើម លុះឃើញហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ បុក្កុសមល្លបុត្ត លុះគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ អស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតតែងនៅដោយវិហារធម៌ ដ៏ស្ងប់រម្ងាប់ បពិត្រព្រះអង្គដ៏ចម្រើន មានរឿងពីដើមថា អាឡារតាបស កាលាមគោត្ត ដើរទៅកាន់ផ្លូវឆ្ងាយ ហើយចេញអំពីផ្លូវ ចូលទៅអង្គុយសម្រាក នៅក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើ ១ ដើម នៅជិតផ្លូវ បពិត្រព្រះអង្គដ៏ចម្រើន កាលនោះ មានរទេះចំនួន ៥០០ កន្លងហួសទៅក្បែរ ៗ នឹងអាឡារតាបស កាលាមគោត្ត បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ មានបុរសម្នាក់ដើរមកតាមក្រោយពួករទេះនោះ ចូលសំដៅទៅរកអាឡារតាបស កាលាមគោត្ត

ឧបសង្កមិត្វា អានន្ទំ ឯតទវោច អបិ ភន្តេ បញ្ចមត្តានិ សកដសតានិ អតិក្កន្តានិ អទ្ទសាតិ ន ខោ អហំ អាវុសោ អទ្ទសន្តិ កឹ បន ភន្តេ សទ្ទំ អស្សោសីតិ ន ខោ អហំ អាវុសោ សទ្ទំ អស្សោសិន្តិ កឹ បន ភន្តេ សុត្តោ អហោសីតិ ន ខោ អហំ អាវុសោ សុត្តោ អហោសិន្តិ កឹ បន ភន្តេ សញ្ញី អហោសីតិ ឯវមាវុសោតិ សោ ត្វំ ភន្តេ សញ្ញី សមានោ ជាគរោ បញ្ចមត្តានិ សកដសតានិ និស្សាយ និស្សាយ អតិក្កន្តានិ នេវ អទ្ទស ន បន សទ្ទំ អស្សោសិ អបិ ហិ តេ ភន្តេ សង្ឃាដិ រជេន ឱកិណ្ណាតិ ឯវមាវុសោតិ អថខោ ភន្តេ តស្ស បុរិសស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សន្តេន វត ភោ បព្វជិតា វិហារេន វិហរន្តិ យត្រ ហិ នាម សញ្ញី សមានោ ជាគរោ បញ្ចមត្តានិ សកដសតានិ និស្សាយ និស្សាយ អតិក្កន្តានិ នេវ ទក្ខតិ

លុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងអាឡារតាបស កាលាម-គោត្តថា បពិត្រតាបសដ៏ចម្រើន លោកម្ចាស់បានឃើញរទេះចំនួន ៥០០ កន្ទង់ហួសទៅហើយដែរឬ (អាឡារតាបសឆ្លើយថា) ម្នាលអាវុសោ យើងមិនបានឃើញទេ (បុរសនោះសួរទៀតថា) បពិត្រតាបសដ៏ចម្រើន ចុះលោកម្ចាស់បានឮសូរសម្លេងដែរឬ ម្នាលអាវុសោ យើងមិនបានឮសូរសម្លេងទេ បពិត្រតាបសដ៏ចម្រើន ចុះលោកម្ចាស់ សិងលក់ឬអ្វី ម្នាលអាវុសោ យើងមិនបានដេកលក់ទេ បពិត្រតាបសដ៏ចម្រើន ចុះលោកម្ចាស់មានសញ្ញាដែរឬ ម្នាលអាវុសោ អើ យើងមានសញ្ញាដែរ បពិត្រតាបសដ៏ចម្រើន លោកម្ចាស់មានសញ្ញានៅភ្ញាក់រលឹក មិនបានឃើញរទេះចំនួន ៥០០ កន្ទង់ហួសទៅក្បែរ ៗ ខ្លួន ទាំងមិនបានឮសូរ បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះសង្ឃាដីរបស់លោកម្ចាស់ ប្រឡាក់ដោយធូលីដែរឬ ម្នាលអាវុសោ ប្រឡាក់ដែរ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ បុរសនោះ មានសេចក្តីត្រិះរិះ ដូច្នេះថា ឱហ្ន៎ ហេតុនេះ អស្ចារ្យពេកណាស់ ឱហ្ន៎ ហេតុនេះ ចម្លែកពេកណាស់ ពួកបព្វជិតតែងនៅដោយវិហារធម៌ដ៏ស្ងប់រម្ងាប់ ព្រោះថា តាបសមានសញ្ញានៅភ្ញាក់រលឹក តែមិនបានឃើញរទេះចំនួន ៥០០ កន្ទង់ហួសទៅក្បែរ ៗ ខ្លួន ។

ន បន សក្កំ សោស្សតីតិ អាឡារ កាលាម ឧឡារំ បសាទំ បវេទេត្វា បក្កាមីតិ ។ តំ កឹ មញ្ញសិ បុក្កុស កតមំ នុ ខោ ទុក្ករតរំ វា ទុរភិសម្ភវតរំ វា យោ វា[1] សញ្ញី សមានោ ជាគរោ បញ្ចមត្តានិ សកដសតានិ និស្សាយ និស្សាយ អតិក្កន្តានិ នេវ បស្សេយ្យ ន បន សទ្ទំ សុណេយ្យ យោ វា សញ្ញី សមានោ ជាគរោ ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ វិជ្ជុតាសុ និច្ឆរន្តីសុ អ-សនិយា ផលន្តិយា នេវ បស្សេយ្យ ន បន សទ្ទំ សុ-ណេយ្យាតិ ។ កឹ ហិ ភន្តេ ករិស្សន្តិ បញ្ច វា សកដស-តានិ ឆ វា សកដសតានិ សត្ត វា សកដសតានិ

១ ឱ. វាសទ្ទោ នត្ថិ ។

ទាំងមិនបានឮសូរ ហើយបុរសនោះ ក៏កើតសេចក្តីជ្រះថ្លាក្រៃលែង ក្នុងអាឡារតាបស កាលាមគោត្ត ហើយចៀសចេញទៅ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលបុក្កុសៈ អ្នកសម្គាល់ហេតុនោះដូចម្តេច បុគ្គលណាមួយ មានសញ្ញានៅភ្ញាក់រលឹក មិនបានឃើញរទេះចំនួន ៥០០ ដែលកន្លងហួសទៅក្បែរ ៗ ខ្លួន ទាំងមិនបានឮសូរ បុគ្គលណាមួយមានសញ្ញានៅភ្ញាក់រលឹក កាលដែលភ្លៀងកំពុងបង្អុរចុះ កាលដែលភ្លៀងកំពុងធ្វើសំឡេងឈូឆរ កាលដែលផ្លេកបន្ទោរកំពុងភ្លឺច្រវាត់ កាលដែលរន្ទះ[១]កំពុងបាញ់ ក៏មិនបានឃើញ ទាំងមិនបានឮសូរ (បណ្តាហេតុរបស់បុគ្គលទាំងពីរនោះ) ហេតុណាហ្ន៎ ដែលធ្វើបានដោយកម្រ ឬដែលមានដោយកម្រជាងគេ ។ បុក្កុសមល្លបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន រទេះ ៥០០ ក្តី រទេះ ៦០០ ក្តី រទេះ ៧០០ ក្តី

---

១ រន្ទះមាន ៩ យ៉ាង គឺ អសញ្ញា រន្ទះធ្វើសត្វដែលត្រូវសំឡេងរន្ទះនោះគ្របសង្កត់ឲ្យបាត់សញ្ញា ១ វិចក្កា រន្ទះដែលមានសណ្ឋានមូលដូចជាកង់រទេះ ១ សតេរា រន្ទះដែលមានសណ្ឋានដូចជាស្លាបក្តោងទូក ១ គគ្គរា រន្ទះដែលធ្វើសំឡេងគ្រឹកគ្រេង ១ កបិសីលា រន្ទះដែលមានអាការៈដូចជាស្វាញាក់ចិញ្ចើម ១ មច្ឆវិលោលិកា រន្ទះដែលមានអាការៈដូចត្រីភ្លៀក ១ កុក្កុដកា រន្ទះដែលមានអាការៈដូចមាន់ទទះស្លាប ១ ទណ្ឌមណិក រន្ទះដែលមានអាការៈដូចផ្ទៀងនង្គ័ល ១ សុក្ខាសនី រន្ទះស្ងួតធ្វើកន្លែងដែលធ្លាក់ចុះឲ្យរបើកចេញទៅ ១ (អដ្ឋកថាព្រមទាំងដីកា) ។

អដ្ឋ វា សកដសតានិ នវ វា សកដសតានិ ទស វា សកដសតានិ ។ បេ ។ សហស្សំ វា សកដសតានិ អថខោ ឯតនេវ ឧក្ការតរញ្ចេវ ទុរភិសម្ភវតរញ្ច យោ សញ្ញី សមានោ ជាគរោ ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ វិជ្ជុតាសុ[1] និច្ឆរន្តីសុ អសនិយា ផលន្តិយា នេវ បស្សេយ្យ ន បន សទ្ទំ សុណេយ្យាតិ ។

[១២១] ឯកមិទាហំ បុក្កុស សមយំ អាតុមាយំ វិហរាមិ ភុសាគារេ ។ តេន ខោ បន សមយេន ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ វិជ្ជុតាសុ និច្ឆរន្តីសុ អសនិយា ផលន្តិយា អវិទូរេ[2] ភុសាគារស្ស ទ្វេ កស្សកា ភាតរោ ហតា ចត្តារោ ច ពលិពទ្ទា ។ អថខោ បុក្កុស អាតុមាយំ មហាជនកាយោ និក្ខមិត្វា យេន តេ ទ្វេ កស្សកា ភាតរោ ហតា ចត្តារោ ច ពលិពទ្ទា តេនុបសង្កមិ ។ តេន ខោ បនាហំ បុក្កុស សមយេន

---

១ ម. វិជ្ជុលតាសុ ។ ២ ឱ. អវិទូរេតិ ន ទិស្សតិ ។

រទេះ ៨០០ ក្តី រទេះ ៩០០ ក្តី រទេះ ១០០០ ។ បេ ។ រទេះ ១ សែនក្តី នឹងធ្វើប្រយោជន៍ដូចម្តេច បុគ្គលណាមួយ មានសញ្ញានៅភ្ញាក់រលឹក កាលដែលភ្លៀង កំពុងបង្អុរចុះ កាលដែលភ្លៀងកំពុងធ្វើសំឡេងឈូឆរ កាលដែលផ្លេកបន្ទោរកំពុងភ្លឺប្រវាត់ កាលដែលរន្ទះកំពុងបាញ់ ក៏មិនបានឃើញ ទាំងមិនបានឮសូរ ហេតុនេះឯងរបស់បុគ្គលនោះ ជាហេតុដែលធ្វើបានដោយកម្រផង ដែលមានដោយកម្រផង ដោយពិត ។

[១២១] ម្នាលបុក្កុសៈ សម័យមួយ តថាគតនៅក្នុងរោងលានស្រូវ ទៀបស្រុកអាតុមាឯណោះ ។ ក៏សម័យនោះឯង ភ្លៀងកំពុងបង្អុរចុះ ភ្លៀងកំពុងធ្វើសំឡេងឈូឆរ ផ្លេកបន្ទោរកំពុងភ្លឺប្រវាត់ រន្ទះកំពុងបាញ់ មានអ្នកស្រែជាបងប្អូននឹងគ្នាពីរនាក់ និងគោ ៤ ត្រូវរន្ទះបាញ់ស្លាប់ ជិតរោងលានស្រូវ ។ ម្នាលបុក្កុសៈ កាលនោះឯង ពួកមហាជនចេញអំពីស្រុកអាតុមាចូលទៅកាន់ទី នៃបុរសអ្នកស្រែពីរនាក់បងប្អូន និងគោទាំង ៤ ដែលរន្ទះបាញ់ស្លាប់នោះ ។ ម្នាលបុក្កុសៈ សម័យនោះឯង តថាគត

ភុសាគារា និក្ខមិត្វា ភុសាគារទ្វារេ អព្ភោកាសេ ចង្កមាមិ ។ អថខោ បុក្កុស អញ្ញតរោ បុរិសោ តម្ហា មហាជនកាយា យេនាហំ តេនុបសង្កមិ ឧប-សង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ អហំ បុក្កុស តំ បុរិសំ ឯតទវោចំ កិន្នុ ខោ សោ អាវុសោ មហាជនកាយោ សន្និបតិ-តោតិ ។ ឥទានិ ភន្តេ ទេវេ វស្សន្តេ ទេវេ គឡគឡា-យន្តេ វិជ្ជុតាសុ និច្ឆរន្តីសុ អសនិយា ផលន្តិយា ទ្វេ កស្សកា ភាតរោ ហតា ចត្តារោ ច ពលិពទ្ទា ឯត្ថ សោ(១) មហាជនកាយោ សន្និបតិតោ ត្វំ បន ភន្តេ ក្វ អហោសីតិ ។ ឥធេវ ខោ អហំ អាវុសោ អ-ហោសិន្តិ ។ កឹ បន ភន្តេ អទ្ទសាតិ ។ ន ខោ អហំ(២) អាវុសោ អទ្ទសន្តិ ។ កឹ បន ភន្តេ សទ្ទំ អស្សោសីតិ ។ ន ខោ អហំ អាវុសោ សទ្ទំ អស្សោ-សិន្តិ ។ កឹ បន ភន្តេ សុត្តោ អហោសីតិ ។ ន ខោ អហំ អាវុសោ សុត្តោ អហោសិន្តិ ។

---

២ ឱ. ម. ឯត្តេសោ ។ ២ ឱ. អយំ បាឋោ ន ហោតិ ។

ចេញអំពីលានស្រូវ ដើរចង្ក្រមទៅក្នុងទីវាល ជិតទ្វារពេងលានស្រូវ ។ ម្នាលបុក្កុសៈ កាលនោះ មានបុរសម្នាក់ ចេញអំពីពួកមហាជននោះ ចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលបុក្កុសៈ លុះបុរសនោះ ឋិតនៅក្នុងទីដ៏សមគួរហើយ តថាគត ក៏និយាយដូច្នេះថា ម្នាលអាវុសោ ពួកមហាជននោះ ប្រជុំគ្នាអំពីរឿងអ្វី ។ បុរសនោះឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ កាលដែលភ្លៀង កំពុងបង្អុរចុះ កាលដែលភ្លៀង កំពុងធ្វើសំឡេងឈូចរ កាលដែលផ្លេកបន្ទោរ កំពុងភ្លឺច្រវាត់ កាលដែលរន្ទះ កំពុងបាញ់ ក៏បាញ់ត្រូវអ្នកស្រែពីរនាក់ ជាបងប្អូន និងគោទាំង ៤ ស្លាប់ទៅ ពួកមហាជននោះប្រជុំគ្នា ព្រោះហេតុនេះឯង បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គទ្រង់គង់នៅក្នុងទីណា ។ តថាគតឆ្លើយថា ម្នាលអាវុសោ តថាគតនៅក្នុងពេងលានស្រូវនេះ ។ បុរសនោះ ក្រាបបង្គំទូលសួរថា ចុះព្រះអង្គបានទ្រង់ទតឃើញឬទេ ។ តថាគតឆ្លើយថា ម្នាលអាវុសោ តថាគតមិនបានឃើញទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គបានឮសូរសំឡេងទេ ។ ម្នាលអាវុសោ តថាគតមិនបានឮសូរសំឡេងទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គផ្ទំលក់ឬអ្វី ។ ម្នាលអាវុសោ តថាគតមិនបានលក់ទេ ។

កឹ បន ភន្តេ សញ្ញី អហោសីតិ ។ ឯវមាវុសោតិ ។ សោ ត្វំ ភន្តេ សញ្ញី សមានោ ជាគរោ ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ វិជ្ជុតាសុ និច្ឆរន្តីសុ អសនិយា ផលន្តិយា នេវ អទ្ទស ន បន សទ្ទំ អស្សោសីតិ ។ ឯវមាវុសោតិ ។ អថខោ បុក្កុស តស្ស បុរិសស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សន្តេន វត ភោ បព្វជិតា វិហារេន វិហរន្តិ យត្រ ហិ នាម សញ្ញី សមានោ ជាគរោ ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ វិជ្ជុតាសុ និច្ឆរន្តីសុ អសនិយា ផលន្តិយា នេវ ទក្ខិស្សតិ[១] ន បន សទ្ទំ សុណិស្សតីតិ[២] ។ មយិ ឧឡារំ បសាទំ បវេទេត្វា[៣] បទក្ខិណំ កត្វា បក្កាមីតិ ។ ឯវំ វុត្តេ បុក្កុសោ មល្លបុត្តោ ភគវន្តំ ឯតទវោច ឯសាហំ ភន្តេ យោ[៤] អាឡារេ កាលាមេ បសាទោ

១ ឱ. ទក្ខិតិ ។ ម. ទក្ខតិ ។ ២ ឱ. ម. សោស្សតីតិ ។ ៣ ឱ. ម. បវេទេត្វា មំ អភិវាទេត្វា ។ ៤ ឱ. ម. យោ មេ ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គមានសញ្ញាដែរឬ ។ ម្នាលអាវុសោ តថាគត មានសញ្ញាដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គមានសញ្ញានៅភ្ញាក់រលឹក កាលដែលភ្លៀង កំពុងបង្អុរចុះ កាលដែលភ្លៀងកំពុងធ្វើសំឡេងឈូឆរ កាលដែលផ្ទេកបន្ទោរកំពុងភ្លឺប្រវាត់ កាលដែលរន្ទះកំពុងបាញ់ ទ្រង់មិនបានឃើញ ទាំងមិនបានឮសូរសំឡេងទេឬ ។ អើអាវុសោ ។ ម្នាលបុក្កុសៈ គ្រានោះ បុរសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ហេតុនេះ ជាអស្ចារ្យពេកណាស់ ឱហ្ន៎ ហេតុនេះចម្លែកពេកណាស់ ឱហ្ន៎ ពួកបព្វជិតតែងនៅដោយវិហារធម៌ ដ៏ស្ងប់រម្ងាប់មែន ព្រោះថា បុគ្គលដែលមានសញ្ញានៅភ្ញាក់រលឹក កាលដែលភ្លៀងកំពុងបង្អុរចុះ កាលដែលភ្លៀង កំពុងធ្វើសំឡេងឈូឆរ កាលដែលផ្ទេកបន្ទោរកំពុងភ្លឺប្រវាត់ កាលដែលរន្ទះកំពុងបាញ់ ឥតបានឃើញ ទាំងមិនបានឮសូរសោះ ។ បុរសនោះ ក៏កើតសេចក្តីជ្រះថ្លា ដោយក្រៃលែងចំពោះតថាគត ហើយធ្វើប្រទក្សិណ ដើរចេញទៅ ។ លុះព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ បុក្កុសមល្លបុត្ត ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីជ្រះថ្លាណារបស់ខ្ញុំព្រះអង្គ ដែលកើតឡើងក្នុងអាឡារតាបសកាលាមគោត្ត ខ្ញុំព្រះអង្គ

២៨១



តំ មហាវាតេ វា ឱផុធាមិ សីឃសោតាយ វា នទិយា បវាហេមិ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ អថខោ បុក្កុសោ មល្លបុត្តោ អញ្ញតរំ បុរិសំ អាមន្តេសិ ឥង្ឃ មេ ត្វំ ភណេ សិង្គីវណ្ណំ យុគមដ្ឋំ ធារណីយំ អាហរាតិ ។ ឯវំ ភន្តេតិ ខោ សោ បុរិសោ បុក្កុសស្ស មល្លបុត្តស្ស បដិស្សុត្វា តំ សិង្គីវណ្ណំ យុគមដ្ឋំ ធារណីយំ អាហរិ[១] ។

១ ម. អាហរសិ ។

នេះពោយចោលនូវសេចក្តីជ្រះថ្លានោះ ក្នុងទីមានខ្យល់ច្រើនផង បណ្តែតចោលក្នុងស្ទឹង ដែលមានខ្សែទឹក ហូររហ័សផង បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលផ្ងារឡើងនូវរបស់ដែលគេផ្កាប់ក្តី បើកឡើងនូវរបស់ដែលគេគ្របទុកក្តី ចង្អុលប្រាប់ផ្លូវដល់បុរសដែលវង្វេងផ្លូវក្តី ទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថាអ្នកមានចក្ខុនឹងបានឃើញរូបក្តី យ៉ាងណាមិញ ធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសដោយអនេកបរិយាយ ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ ចាប់ដើមអំពីថ្ងៃនេះតទៅ សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិត ។ គ្រានោះ បុក្កុសមល្លបុត្ត ហៅបុរសម្នាក់ថា ម្នាលនាយ ចូរអ្នកទៅយកសំពត់ ដែលមានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសិង្គី ដែលខ្ញុំគួរប្រើប្រាស់ (ម្តង ៗ) មកដោយឆាប់ ។ បុរសនោះ ទទួលបន្ទូលបុក្កុសមល្លបុត្តថា ព្រះករុណាម្ចាស់ ហើយក៏ទៅយកសំពត់ ដែលមានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសិង្គី ដែលគួរប្រើប្រាស់ (ម្តង ៗ) នោះ ។

អថខោ បុក្កុសោ មល្លបុត្តោ តំ សិង្គីវណ្ណំ យុគមដ្ឋំ ធារណីយំ ភគវតោ ឧបនាមេសិ ឥទំ ភន្តេ សិង្គីវណ្ណំ យុគមដ្ឋំ ធារណីយំ តំ មេ ភន្តេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ តេនហិ បុក្កុស ឯកេន មំ អច្ឆាទេហិ ឯកេន អានន្ទន្តិ ។ ឯវំ ភន្តេតិ ខោ បុក្កុសោ មល្លបុត្តោ ភគវតោ បដិស្សុត្វា ឯកេន ភគវន្តំ អច្ឆាទេសិ ឯកេន អាយស្មន្តំ អានន្ទំ ។ អថខោ ភគវា បុក្កុសំ មល្លបុត្តំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ បុក្កុសោ មល្លបុត្តោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

ទើបបុក្កុសមល្លបុត្ត បង្អោននូវសំពត់ ដែលមានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសិង្គី ដែលគួរប្រើប្រាស់ (ម្តង ៗ) នោះ ចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សំពត់ដែលមានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសិង្គីនេះ ជាសំពត់ដែលខ្ញុំព្រះអង្គប្រើប្រាស់ (ម្តង ៗ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទទួលនូវសំពត់នោះ ដោយអាស្រ័យនូវសេចក្តីអនុគ្រោះ ដល់ខ្ញុំព្រះអង្គចុះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលបុក្កុសៈ បើដូច្នោះ អ្នកចូរឲ្យសំពត់ ១ មកតថាគត ឲ្យសំពត់ ១ ទៅអានន្ទចុះ ។ បុក្កុសមល្លបុត្ត ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ថ្វាយសំពត់ ១ ទៅព្រះមានព្រះភាគ ប្រគេនសំពត់ ១ ទៅព្រះអានន្ទមានអាយុ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ញុំាងបុក្កុសមល្លបុត្ត ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាកយ ដោយធម្មីកថា ។ គ្រានោះ បុក្កុសមល្លបុត្ត កាលដែលព្រះមានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចេញទៅ ។

មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ អច្ឆរិយព្ភុតកថា

[១២២] អថខោ អាយស្មា អានន្ទោ អចិរបក្កន្តេ បុក្កុសេ មល្លបុត្តេ តំ សិង្គីវណ្ណំ យុគមដ្ឋំ ធារណីយំ ភគវតោ កាយំ ឧបនាមេសិ ។ តំ ភគវតោ កាយំ ឧបនាមិតំ ហតច្ឆិកំ[១] វិយ ខាយតិ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ បរិសុទ្ធោ ភន្តេ តថាគតស្ស ឆវិវណ្ណោ បរិយោទាតោ ឥទំ ភន្តេ សិង្គីវណ្ណំ យុគមដ្ឋំ ធារណីយំ ភគវតោ កាយំ ឧបនាមិតំ ហតច្ឆិកំ វិយ ខាយតីតិ ។ ឯវមេតំ អានន្ទ ទ្វីសុ ខោ អានន្ទ[២] កាលេសុ អតិវិយ តថាគតស្ស កាយោ[៣] បរិសុទ្ធោ ហោតិ ឆវិវណ្ណោ បរិយោទាតោ កតមេសុ ទ្វីសុ យញ្ច អានន្ទ រត្តឹ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ យញ្ច រត្តឹ អនុបាទិសេសាយ

---

១ ឱ. វិតច្ឆិកំ ។ ម. ហតច្ឆិកំ ។ ២ ម. អានន្ទាតិ ន ទិស្សតិ ។ ៣ ឱ. កាយោតិ ន ទិស្សតិ ។

[១២២] លុះបុក្កុសមល្លបុត្ត ចេញទៅមិនទាន់យូរប៉ុន្មាន ព្រះអានន្ទមានអាយុ ក៏យកសំពត់ដែលមានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសិង្គី ដែលគួរប្រើប្រាស់ (ម្តង ៗ) នោះ ទៅបំពាក់ព្រះកាយនៃព្រះមានព្រះភាគ ។ ឯសំពត់ដែលព្រះអានន្ទ យកទៅបំពាក់ព្រះកាយនៃព្រះមានព្រះភាគនោះ (ក៏អាប់សម្បុរ) ប្រាកដដូចជារងើកភ្លើង ដែលប្រាសចាកអណ្តាតភ្លើង ។ គ្រានោះ ព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ជាអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះឆវិវណ្ណរបស់ព្រះតថាគតស្អាតបរិសុទ្ធ ផូរផង់ដល់ម៉្លោះ បពិត្រព្រះអង្គដ៏ចម្រើន សំពត់ដែលមានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសិង្គី ដែលគួរប្រើប្រាស់ (ម្តង ៗ) នេះ ដែលខ្ញុំព្រះអង្គ យកទៅបំពាក់ព្រះកាយនៃព្រះមានព្រះភាគ (ក៏អាប់សម្បុរ) ប្រាកដដូចជារងើកភ្លើង ដែលប្រាសចាកអណ្តាតភ្លើង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ហេតុនេះយ៉ាងនេះឯង ម្នាលអានន្ទ កាយតថាគតស្អាតឆវិវណ្ណក៏បរិសុទ្ធ ផូរផង់ក្រៃពេក ក្នុងកាលទាំងពីរ កាលទាំងពីរ តើដូចម្តេច ម្នាលអានន្ទ កាលតថាគតបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោ-ធិញ្ញាណ ក្នុងរាត្រីណា ១ កាលតថាគតបរិនិព្វានដោយអនុបាទិសេស-

និព្វានធាតុយា បរិនិព្វាយតិ ឥមេសុ ខោ អានន្ទ ទ្វីសុ កាលេសុ អតិវិយ តថាគតស្ស កាយោ បរិសុទ្ធោ ហោតិ ឆវិវណ្ណោ បរិយោទាតោ អជ្ជ ខោ បនានន្ទ រត្តិយា បច្ឆិមេ យាមេ កុសិនារាយំ ឧបវត្តនេ មល្លានំ សាលវនេ អន្តរេ[១] យមកសាលានំ តថាគតស្ស បរិ-និព្វានំ ភវិស្សតិ អាយាមានន្ទ យេន កកុធនទី តេ-នុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

[១២៣] សិង្គីវណ្ណំ យុគមដ្ឋំ
បុក្កុសោ អភិហារយិ
តេន អច្ឆាទិតោ សត្ថា
សោមវណ្ណោ[២] អសោភថាតិ ។

[១២៤] អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន កកុធនទី តេនុបសង្កមិ ឧបសង្កមិត្វា កកុធនទឹ អជ្ជោគាហេត្វា នហាត្វា ច បិវិត្វា ច បច្ចុត្តរិត្វា យេន អម្ពវនំ តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. ម. អន្តរេន ។ ២ ឱ. ម. ហេមវណ្ណោ ។

និព្វានធាតុក្នុងរាត្រីណា ១ ម្នាលអានន្ទ កាយតថាគតស្អាត ឆវិវណ្ណ ក៏បរិសុទ្ធ ផូរផង់ក្រៃពេក ក្នុងកាលទាំងពីរនេះឯង ម្នាលអានន្ទ ក្នុងយាមជាទីបំផុតនៃរាត្រីនេះឯង បរិនិព្វានរបស់តថាគតនឹងមាន ក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូ ក្នុងសាលវ័នរបស់ពួកមល្លក្សត្រិយ៍ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ម្នាលអានន្ទ មក យើងនឹងទៅកាន់ស្ទឹងកកុធៈ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១២៣] បុក្កុសមល្លបុត្ត ថ្វាយនូវសំពត់មានសាច់ម៉ដ្ឋ ១ គូ
មានសម្បុរដូចមាសសិង្គី (ចំពោះព្រះសាស្តា) ព្រះសាស្តា
ដែលព្រះអានន្ទនោះ ថ្វាយឲ្យទ្រង់សាដកហើយ ក៏មាន
សម្បុរ ដូចព្រះចន្ទល្អរុងរឿង ។

[១២៤] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់ស្ទឹងកកុធៈ ព្រមទាំងភិក្ខុសង្ឃជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ស្តេចចុះកាន់ស្ទឹងកកុធៈ ស្រង់ផង[១] សោយផង ហើយស្តេចត្រឡប់ឡើងវិញ ក៏ចូលទៅរកអម្ពវ័ន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់

---

១ អដ្ឋកថាថា កាលព្រះមានព្រះភាគកំពុងស្រង់ ហ្វូងត្រីនិងអណ្តើកក្នុងស្ទឹងនោះក្តី ដងព្រៃនៅក្បែរច្រាំងទាំងពីរក្តី ក៏មានសម្បុរហាក់ដូចជាមាសទាំងអស់ ។

អាយស្មន្តំ ចុន្ទកំ អាមន្តេសិ ឥង្ឃ មេ ត្វំ ចុន្ទក ចតុគ្គុណំ សង្ឃាដឹ បញ្ញបេហិ កិលន្តោស្មិ ចុន្ទក និបជ្ជិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា ចុន្ទកោ ភគវតោ បដិស្សុត្វា ចតុគ្គុណំ សង្ឃាដឹ បញ្ញបេសិ ។ អថខោ ភគវា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេន បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា ។ អាយស្មា បន ចុន្ទកោ តត្ថេវ ភគវតោ បុរតោ និសីទិ ។

[១២៤] គន្ត្វាន ពុទ្ធោ នទិកំ(១) កកុធំ
អច្ឆោទកំ សាតោទកំ វិប្បសន្នំ(២)
ឱគាហិ សត្ថា អកិលន្តរូបោ
តថាគតោ អប្បដិមោ ច លោកេ ។
ន្ហាត្វា ច បិវិត្វា ចុទតារិ សត្ថា(៣)
បុរក្ខតោ ភិក្ខុគណស្ស មជ្ឈេ
សត្ថា(៤) បវត្តា ភគវា ឥធ ធម្មេ
ឧបាគមិ អម្ពវនំ មហេសី ។

---

១ ឱ. ម. នទិយំ ។ ២ ឱ. អច្ឆោទិសាតោទិកវិប្បសន្នំ ។ ៣ ឱ. នហាត្វា បិត្វា ច ឧទការិ សត្ថា ។ ម. ន្ហាត្វា ច បិវិត្វា ចុន្ទកេន សត្ថា ។ ៤ ម. វត្តា ។

ហៅព្រះចុន្ទកៈមានអាយុមកថា ម្នាលចុន្ទកៈ ចូរអ្នកក្រាលសង្ឃាដី មានជាន់ ៤ ឲ្យតថាគតដោយឆាប់ ម្នាលចុន្ទកៈ តថាគតល្ហិតល្ហៃណាស់ តថាគតនឹងសិង ។ ព្រះចុន្ទកៈមានអាយុ ទទួលព្រះបន្ទូល ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ក្រាលសង្ឃាដី មានជាន់ ៤ ថ្វាយ ។ ទើបព្រះមានព្រះភាគ ទ្រង់សម្រេចសីហសេយ្យា ផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទផ្ទេងតម្រួតលើព្រះបាទស្តាំ ទ្រង់មានព្រះសតិនិងសម្បជញ្ញៈ ធ្វើទុកក្នុងព្រះទ័យនូវឧដ្ឋានសញ្ញា (សេចក្តីសម្គាល់ថានឹងក្រោកឡើងវិញ) ។ ឯព្រះចុន្ទកៈមានអាយុ ក៏អង្គុយចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងទីនោះឯង ។

[១២៥] ព្រះពុទ្ធ ទ្រង់ស្តេចទៅកាន់ស្ទឹងកកុធៈ ដែលមាន
ទឹកថ្លា មានទឹកមានរសជាតិ មានទឹកស្អាត ព្រះតថាគតជា
សាស្តា ឥតមានបុគ្គលប្រៀបផ្ទឹមក្នុងលោក ទ្រង់មិនលំបាក
ព្រះកាយ ស្តេចចុះ (កាន់ស្ទឹង) ។ ព្រះសាស្តាទ្រង់ស្រង់
ផង ទ្រង់សោយផង នូវទឹកនោះ ហើយគង់ក្នុងទីកណ្តាល
នៃពួកភិក្ខុ ដែលគាល់ព្រះមានព្រះភាគ ជាសាស្តា ជា
មហេសី (អ្នកស្វែងរកគុណធំ) ព្រះអង្គញុំាងធម៌ឲ្យប្រព្រឹត្ត
ទៅក្នុងសាសនានេះ ទ្រង់ស្តេចចូលទៅកាន់អម្ពវ័ន ។

អាមន្តយី ចុន្ទកំ ឯាម ភិក្ខុំ
ចតុគ្គុណំ សន្ថរិ មេ[១] និបជ្ជិ
សោ ចោទិតោ[២] ភាវិតត្តេន ចុន្ទោ
ចតុគ្គុណំ សន្ថរិ ខិប្បមេវ
និបជ្ជិ សត្ថា អកិលន្តរូបោ[៣]
ចុន្ទោបិ តត្ថ បមុខេ[៤] និសីទីតិ ។

[១២៦] អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ សិយា ខោ[៥] បនានន្ទ ចុន្ទស្ស កម្មារបុត្តស្ស កោចិ វិប្បដិសារំ ឧប្បាទេយ្យ[៦] តស្ស តេ អាវុសោ ចុន្ទ អលាភា តស្ស តេ ទុល្លទ្ធំ យស្ស តេ តថាគតោ បច្ឆិមំ បិណ្ឌបាតំ បរិភុញ្ជិត្វា[៧] បរិនិព្វុតោតិ ចុន្ទស្ស ខោ អានន្ទ[៨] កម្មារបុត្តស្ស ឯវំ វិប្បដិសារោ បដិវិនេតព្វោ តស្ស តេ អាវុសោ ចុន្ទ លាភា[៩] តស្ស តេ សុលទ្ធំ យស្ស តេ តថាគតោ បច្ឆិមំ បិណ្ឌបាតំ បរិ-

---

១ ឱ. បត្ថរមេ ។ ម. សន្ថរមេ ។ ២ ឱ. មោទិតោ ។ ៣ ឱ. សុកិលន្តរូបោ ។ ៤ ម. សមុខេ ។ ៥ ម. យោ ខោ ។ ៦ ឱ. ឧបទហេយ្យ ។ ៧ ឱ. ភុញ្ជិត្វា ។ ៨ ឱ. ចុន្ទស្ស អានន្ទ ។ ៩ ឱ. អាវុសោ លាភា ។

ទ្រង់ត្រាស់ហៅចុន្ទកភិក្ខុមកថា អ្នកចូរក្រាលសង្ឃាដី មានជាន់ ៤ ឲ្យតថាគតដោយឆាប់ តថាគតនឹងសិង ព្រះចុន្ទកភិក្ខុនោះ កាលដែលព្រះសាស្ដា មានព្រះអង្គចម្រើនហើយ ទ្រង់ត្រាស់បង្គាប់ហើយ ក៏ក្រាលសង្ឃាដី មានជាន់ ៤ ថ្វាយដោយប្រញាប់ ព្រះសាស្ដាមិនលំបាកព្រះកាយ ទ្រង់ផ្ទំហើយ ឯព្រះចុន្ទកភិក្ខុ ក៏អង្គុយគាល់ចំពោះព្រះភក្ត្រក្នុងទីនោះ ។

[១២៦] គ្រានោះ ព្រះមានព្រះភាគ បានត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ បើមានបុគ្គលណាមួយ ញុំាងសេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ឲ្យកើតឡើង ដល់ចុន្ទកម្មារបុត្តថា ម្នាលអាវុសោចុន្ទ អ្នកពេញហៅជាមនុស្ស ឥតលាភ អត្តភាពជាមនុស្ស ក៏អ្នកបានដោយអាក្រក់ ព្រោះព្រះតថាគត សោយបច្ឆិមបិណ្ឌបាតរបស់អ្នកហើយទ្រង់បរិនិព្វាន ម្នាលអានន្ទ អ្នកគប្បីបន្ទោបង់សេចក្ដីក្ដៅក្រហាយស្ដាយក្រោយ របស់ចុន្ទកម្មារបុត្តយ៉ាងនេះថា ម្នាលអាវុសោចុន្ទ អ្នកពេញហៅជាមនុស្សមានលាភ អត្តភាព ជាមនុស្ស អ្នកបានដោយប្រពៃហើយ ព្រោះថាព្រះតថាគត ទ្រង់សោយបច្ឆិមបិណ្ឌបាត របស់អ្នក

២៨៧



ភុញ្ជិត្វា បរិនិព្វុតោ សម្មុខា មេតំ អាវុសោ ចុន្ទ ភគវ-
តោ សុតំ សម្មុខា បដិគ្គហិតំ ទ្វេមេ បិណ្ឌបាតា
សមសមផលា សមសមវិបាកា អតិវិយ អញ្ញេហិ
បិណ្ឌបាតេហិ មហប្ផលតរា ច មហានិសំសតរា ច ។
កតមេ ទ្វេ ។ យញ្ច បិណ្ឌបាតំ បរិភុញ្ជិត្វា តថាគតោ
អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ យញ្ច បិណ្ឌបាតំ
បរិភុញ្ជិត្វា តថាគតោ អនុបាទិសេសាយ និព្វានធាតុ-
យា បរិនិព្វាយតិ ឥមេ ទ្វេ បិណ្ឌបាតា សមសមផលា
សមសមវិបាកា អតិវិយ អញ្ញេហិ បិណ្ឌបាតេហិ ម-
ហប្ផលតរា ច មហានិសំសតរា ច អាយុសំវត្តនិកំ
អាយស្មតា ចុន្ទេន កម្មារបុត្តេន កម្មំ ឧបចិតំ វណ្ណ-
សំវត្តនិកំ អាយស្មតា ចុន្ទេន កម្មារបុត្តេន កម្មំ
ឧបចិតំ សុខសំវត្តនិកំ អាយស្មតា ។ បេ ។ យស-
សំវត្តនិកំ ។ បេ ។ សគ្គសំវត្តនិកំ ។ បេ ។ អធិប-
តេយ្យសំវត្តនិកំ អាយស្មតា ចុន្ទេន កម្មារបុត្តេន

ហើយទ្រង់បរិនិព្វាន ម្នាលអានន្ទ ពាក្យនេះ យើងបានស្តាប់ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដូច្នេះថា ចង្ហាន់បិណ្ឌបាតទាំងពីរនេះ មានផលស្មើ ៗ គ្នា មានវិបាកស្មើ ៗ គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ ។ ចង្ហាន់បិណ្ឌបាតទាំងពីរ តើដូចម្តេច ។ គឺព្រះតថាគត ទ្រង់សោយចង្ហាន់បិណ្ឌបាតណាហើយ ទ្រង់បានត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ ១ ព្រះតថាគត ទ្រង់សោយចង្ហាន់បិណ្ឌបាតណាហើយ ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ១ ចង្ហាន់បិណ្ឌបាតទាំងពីរនេះឯង មានផលស្មើ ៗ គ្នា មានវិបាកស្មើ ៗ គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ បុញ្ញកម្មដែលញ៉ាំងអាយុឲ្យប្រព្រឹត្តទៅ ចុន្ទកម្មារបុត្តមានអាយុ ក៏បានសន្សំហើយ បុញ្ញកម្មដែលញ៉ាំងសម្បុរ ឲ្យប្រព្រឹត្តទៅ ចុន្ទកម្មារបុត្តមានអាយុ ក៏បានសន្សំហើយ បុញ្ញកម្មដែលញ៉ាំងសេចក្តីសុខឲ្យប្រព្រឹត្តទៅ ។ បេ ។ ញ៉ាំងយសឲ្យប្រព្រឹត្តទៅ ។ បេ ។ ញ៉ាំងឋានសួគ៌ឲ្យប្រព្រឹត្តទៅ ។ បេ ។ ញ៉ាំងភាវៈជាធំ ឲ្យប្រព្រឹត្តទៅ ចុន្ទកម្មារបុត្ត មានអាយុ ក៏បាន

កម្មំ ឧបចិតន្តិ ចុន្ទស្ស អានន្ទ កម្មារបុត្តស្ស ឯវំ វិប្បដិសារោ បដិវិនេតព្វោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

[១២៧] ទទតោ បុញ្ញំ បវឌ្ឍតិ

សំយមតោ វេរំ ន ចីយតិ[១]

កុសលោ ច ជហាតិ បាបកំ

រាគទោសមោហក្ខយា និព្វុតោតិ ។

ពុទ្ធភាណវារំ[២] ចតុត្ថំ ។

[១២៨] អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន ហិរញ្ញវតិយា នទិ-យា បារិមន្តីរំ[៣] យេន កុសិនារាឧបវត្តនំ មល្លានំ សាលវនំ តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ

---

១ ចីយតិតិបិ បាឋោ អដ្ឋកថាយម្បិ ឯវមេវ ។ ២ ឱ. អាឡារវេទល្លភាណវារំ និដ្ឋិតំ ចតុត្ថំ ។ ម. ភាណវារំ ចតុត្ថំ ។ ៣ ឱ. បារិមតីរំ ។ ម. បារិមំ តីរំ ។

សន្សំហើយ ម្នាលអានន្ទ អ្នកគប្បីបន្ទោបង់សេចក្តីក្តៅក្រហាយ ស្តាយក្រោយរបស់ចុន្ទកម្មារបុត្ត យ៉ាងនេះឯង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ ទ្រង់បន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា

[១២៧] បុណ្យ រមែងចម្រើនដល់អ្នកឲ្យទាន វេរាមិនចម្រើន
ដល់បុគ្គលអ្នកសង្រួម បុគ្គលអ្នកឈ្លាស (បរិបូណ៌ដោយ
ញាណ) រមែងលះបង់ នូវអំពើលាមកបាន បុគ្គលនោះ
ក៏បរិនិព្វាន ព្រោះអស់រាគៈ ទោសៈ មោហៈ ។

ចប់ ពុទ្ធភាណវារៈទី ៤ ។

[១២៨] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី នឹងចូលទៅកាន់សាលវ័ន របស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ

ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ហិរញ្ញវតិយា នទិយា បារិមន្តីរំ យេន កុសិនារាឧបវត្តនំ មល្លានំ សាលវនំ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ អន្តរេន យមកសាលានំ ឧត្តរសីសកំ មញ្ចកំ បញ្ញបេហិ កិលន្តោស្មិ អានន្ទ និបជ្ជិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា អន្តរេន យមកសាលានំ ឧត្តរសីសកំ មញ្ចកំ បញ្ញបេសិ ។ អថខោ ភគវា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេន បាទំ អច្ចាធាយ សតោ សម្បជានោ ។

[១២៩] តេន ខោ បន សមយេន យមកសាលា សព្វផាលិផុល្លា ហោន្តិ អកាលបុប្ផេហិ តេ តថាគតស្ស សរីរំ ឱកិរន្តិ អជ្ឈោកិរន្តិ អភិប្បកិរន្តិ តថាគតស្ស បូជាយ ។ ទិព្វានិបិ មន្ទារវបុប្ផានិ អន្តលិក្ខា បបតន្តិ តានិ តថាគតស្ស សរីរំ ឱកិរន្តិ អជ្ឈោកិរន្តិ អភិប្បកិរន្តិ តថាគតស្ស បូជាយ ។ ទិព្វានិបិ ចន្ទនចុណ្ណានិ អន្តលិក្ខា សម្បតន្តិ

ទ្រង់ស្តេចទៅកាន់ត្រើយខាងនាយ នៃស្ទឹងហិរញ្ញវតី នឹងចូលទៅកាន់សាលវ័ន របស់ពួកមល្លក្សត្រ ដែលជាទីចូលទៅ ក្នុងក្រុងកុសិនារា ព្រមទាំងភិក្ខុសង្ឃជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នករៀបចំគ្រែ ឲ្យមានក្បាលដំណេកបែរទៅទិសខាងជើង ក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូ ឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសិង ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយរៀបចំគ្រែ ឲ្យមានក្បាលដំណេក បែរទៅទិសខាងជើង ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូថ្វាយ ។ គ្រានោះ ព្រះមានព្រះភាគ មានព្រះសតិសម្បជញ្ញៈ ទ្រង់សម្រេចសីហសេយ្យា ផ្ទៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេង តម្រួតលើព្រះបាទស្តាំ ។

[១២៩] សម័យនោះឯង សាលព្រឹក្សទាំងគូ ក៏មានផ្ការីកស្គុះស្គាយទាំងអស់ (តាំងពីគល់ដល់ចុង) ដោយអកាលបុប្ផា (ផ្កាពុំដូកាល) សាលព្រឹក្សទាំងគូនោះ ក៏រោយរាយ បាចសាច (នូវផ្កា) លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត សូម្បីមន្ទារវបុស្ស (ផ្កាមន្ទារវៈ) ជាទិព្វ ក៏ធ្លាក់ចុះមកអំពីអាកាស ផ្កាទាំងនោះ ក៏រោយរាយ បាចសាច លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងលម្អិតខ្លឹមចន្ទន៍ជាទិព្វ ក៏ធ្លាក់ចុះមក

តានិ តថាគតស្ស សរីរំ ឱកិរន្តិ អជ្ឈោកិរន្តិ អភិប្បកិរន្តិ តថាគតស្ស បូជាយ ។ ទិព្វានិបិ តុរិយានិ អន្តលិក្ខេ វជ្ជន្តិ តថាគតស្ស បូជាយ ។ ទិព្វានិបិ សង្គីតានិ អន្តលិក្ខេ វត្តន្តិ តថាគតស្ស បូជាយ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ សព្វផាលិផុល្លា ខោ អានន្ទ យមកសាលា អកាលបុប្ផេហិ[១] តថាគតស្ស សរីរំ ឱកិរន្តិ អជ្ឈោកិរន្តិ អភិប្បកិរន្តិ តថាគតស្ស បូជាយ ទិព្វានិបិ មន្ទារវបុប្ផានិ អន្តលិក្ខា បបតន្តិ តានិ តថាគតស្ស សរីរំ ឱកិរន្តិ អជ្ឈោកិរន្តិ អភិប្បកិរន្តិ តថាគតស្ស បូជាយ ទិព្វានិបិ ចន្ទនចុណ្ណានិ អន្តលិក្ខា បបតន្តិ តានិ តថាគតស្ស សរីរំ ឱកិរន្តិ អជ្ឈោកិរន្តិ អភិប្បកិរន្តិ តថាគតស្ស បូជាយ ទិព្វានិបិ តុរិយានិ អន្តលិក្ខេ វជ្ជន្តិ តថាគតស្ស បូជាយ ទិព្វានិបិ សង្គីតានិ អន្តលិក្ខេ វត្តន្តិ តថាគតស្ស បូជាយ ន ខោ អានន្ទ ឯត្តាវតាវ តថាគតោ សក្កតោ វា ហោតិ គរុកតោ វា មានិតោ វា បូជិតោ

១ ម. អកាលបុប្ផេហិ តេ ។

អំពីអាកាស លម្អិតទាំងនោះ ក៏រោយរាយ បាចសាច លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងតូរ្យតន្ត្រីជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ។ ទាំងចម្រៀងជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ សាលព្រឹក្សទាំងគូ មានផ្ការីកស្គុះស្គាយទាំងអស់ (តាំងអំពីគល់ដរាបដល់ចុង) ដោយអកាលបុប្ផា រោយរាយ បាចសាច លើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងផ្កាមន្ទារវៈជាទិព្វ ធ្លាក់ចុះអំពីអាកាស ផ្កាទាំងនោះ រោយរាយ បាចសាចលើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងលម្អិតខ្លឹមចន្ទន៍ជាទិព្វ ធ្លាក់ចុះអំពីអាកាស លម្អិតទាំងនោះ រោយរាយ បាចសាច លើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងតូរ្យតន្ត្រីជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាតថាគត ទាំងចម្រៀងជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាតថាគត ម្នាលអានន្ទ ព្រះតថាគត មិនបានឈ្មោះថា បរិស័ទធ្វើសក្ការៈក្តី គោរពក្តី រាប់អានក្តី បូជាក្តី និងកោត

វា អបចិតោ វា យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ការោតិ គរុការោតិ មានេតិ បូជេតិ[១] បរមាយ បូជាយ តស្មាតិហានន្ទ ធម្មានុធម្មប្បដិបន្នា វិហរិស្សាម សាមីចិប្បដិបន្នា អនុធម្មចារិនោតិ ឯវញ្ហិ វោ អានន្ទ សិក្ខិតព្វន្តិ ។

[១៣០] តេន ខោ បន សមយេន អាយស្មា ឧបវាណោ ភគវតោ បុរតោ ឋិតោ ហោតិ ភគវន្តំ វីជមានោ ។ អថខោ ភគវា អាយស្មន្តំ ឧបវាណំ អបសាទេតិ[២] អបេហិ ភិក្ខុ មា មេ បុរតោ អដ្ឋាសីតិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ អយំ ខោ អាយស្មា ឧបវាណោ ទីឃរត្តំ ភគវតោ ឧបដ្ឋាកោ សន្តិកាវចរោ សមីបចារី អថ ច បន ភគវា បច្ឆិមេ កាលេ អាយស្មន្តំ ឧបវាណំ អបសា-

១ ម. បូជេតិ អបចិយតិ ។ ២ ម. អបសារេតិ ។

ក្រែងក្តី ដោយហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអានន្ទ បុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ម្នាលអានន្ទ ព្រោះហេតុនោះ បរិស័ទក្នុងសាសនានេះ គប្បីសិក្សាថា យើងទាំងឡាយ នឹងប្រតិបត្តិនូវធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

[១៣០] សម័យនោះឯង ឧបវាណភិក្ខុមានអាយុ ឋិតនៅចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ កំពុងបក់ថ្វាយ ព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់បណ្តេញឧបវាណៈមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំឋិតនៅខាងមុខ តថាគតឡើយ ។ គ្រានោះ ព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះឧបវាណៈមានអាយុនេះ ជាឧបដ្ឋាកធ្លាប់នៅឋិត ជើរជិតព្រះមានព្រះភាគ ជាយូរហើយ ទើបតែក្នុងបច្ឆិមកាល (នេះ) ព្រះមានព្រះភាគ ទ្រង់បណ្តេញ

ទេតិ អបេហិ ភិក្ខុ មា មេ បុរតោ អដ្ឋាសីតិ កោ នុ ខោ ហេតុ កោ បច្ចយោ យំ ភគវា អាយស្មន្តំ ឧបវាណំ អបសាទេតិ អបេហិ ភិក្ខុ មា មេ បុរតោ អដ្ឋាសីតិ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ អាយស្មា ឧបវាណោ ទីឃរត្តំ ភគវតោ ឧបដ្ឋាកោ សន្តិកាវចរោ សមីបចារី អថ ច បន ភគវា បច្ឆិមេ កាលេ អាយស្មន្តំ ឧបវាណំ អបសាទេតិ អបេហិ ភិក្ខុ មា មេ បុរតោ អដ្ឋាសីតិ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យំ ភគវា អាយស្មន្តំ ឧបវាណំ អបសាទេតិ អបេហិ ភិក្ខុ មា មេ បុរតោ អដ្ឋាសីតិ ។ យេភុយ្យេន អានន្ទ ទសសុ លោកធាតូសុ ទេវតា សន្និបតិតា តថាគតំ ទស្ស-នាយ យាវតា អានន្ទ កុសិនារាឧបវត្តនំ មល្លានំ សាលវនំ សមន្តតោ ទ្វាទស យោជនានិ នត្ថិ សោ បទេសោ វាលគ្គកោដិនិតុទ្ទនមតោ(១) មហេ-សក្ខាហិ ទេវតាហិ អប្ផុដោ ទេវតា អានន្ទ ឧជ្ឈាយន្តិ

---

១ ឱ. ម. វាលគ្គកោដិនិតុទ្ទនមត្តោបិ ។

ឧបវាណៈមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំឋិតនៅខាងមុខតថាគតឡើយ ដូច្នេះ មានហេតុដូចម្ដេច មានបច្ច័យដូចម្ដេច បានជាព្រះមានព្រះភាគ ទ្រង់បណ្ដេញឧបវាណៈមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំឋិតនៅ ខាងមុខតថាគតឡើយ ។ ទើបព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះឧបវាណៈមានអាយុនេះ ជាឧបដ្ឋាកនៅជិត ដើរជិតព្រះមានព្រះភាគជាយូរហើយ ទើបតែក្នុងបច្ឆិមកាល (នេះ) ព្រះមានព្រះភាគ ទ្រង់បណ្ដេញឧបវាណៈមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំឋិតនៅ ខាងមុខតថាគតឡើយ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដូចម្ដេច មានបច្ច័យដូចម្ដេច បានជាព្រះមានព្រះភាគ ទ្រង់បណ្ដេញឧបវាណៈមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំឋិតនៅ ខាងមុខតថាគតឡើយ ដូច្នេះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ទេវតាក្នុងលោកធាតុទាំង ១០ ប្រជុំគ្នា ដើម្បីមើលតថាគតដោយច្រើន ម្នាលអានន្ទ សាលវ័នរបស់ពួកមល្លក្សត្រិយ៍ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា មានចំនួន ១២ យោជន៍ដោយជុំវិញ មានកំណត់ត្រឹមណា ប្រទេសនោះសូម្បីគ្រាន់តែល្មមចាក់ដោយចុងបំផុតនៃសក់ ដែលទេវតាមានស័ក្តិធំ មិនបានពាល់ត្រូវ មិនមានឡើយ ម្នាលអានន្ទ ពួកទេវតាពោលទោសថា

២៩៣



ទូរា វតម្ហា អាគតា តថាគតំ ទស្សនាយ កទាចិ ករហចិ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ អជ្ជេវ រត្តិយា បច្ឆិមយាមេ តថាគតស្ស បរិនិព្វានំ ភវិស្សតិ អយញ្ច មហេសក្ខោ ភិក្ខុ ភគវតោ បុរតោ ឋិតោ ឱវារេន្តោ ន មយំ លភាម បច្ឆិមេ កាលេ តថាគតំ ទស្សនាយាតិ[1] ។ កថំភូតា បន ភន្តេ ភគវា ទេវតា មនសិករោន្តីតិ ។ សន្តានន្ទ ទេវតា អាកាសេ បថវីសញ្ញិនិយោ កេសេ បកិរិយ កន្ទន្តិ ពាហា បគ្គយ្ហ កន្ទន្តិ ឆិន្នបាតំ វិយ បបតន្តិ[2] អាវដ្ដន្តិ វិវដ្ដន្តិ អតិខិប្បំ ភគវា បរិនិព្វាយិស្សតិ អតិខិប្បំ សុគតោ បរិនិព្វាយិស្សតិ អតិខិប្បំ ចក្ខុមា លោកេ អន្តរធាយិស្សតីតិ សន្តានន្ទ ទេវតា បថវិយា បថវីសញ្ញិនិយោ កេសេ បកិរិយ កន្ទន្តិ ពាហា បគ្គយ្ហ កន្ទន្តិ ឆិន្នបាតំ វិយ បបតន្តិ អាវដ្ដន្តិ វិវដ្ដន្តិ អតិខិប្បំ ភគវា បរិនិព្វាយិស្សតិ អតិខិប្បំ សុគតោ បរិនិព្វាយិស្សតិ អតិខិប្បំ ចក្ខុមា លោកេ

១ ឱ. ឥតោ បរំ ទេវតា អានន្ទ ឧជ្ឈាយន្តីតិ បាឋា ទិស្សន្តិ ។ ២ ឱ. ឆិន្នបបាតំ បបតន្តិ ។ ម. ឆិន្នបាតំ បបតន្តិ ។

ពួកយើងមកអំពីចម្ងាយ ដើម្បីឃើញព្រះតថាគត ៗ ជាព្រះអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោក មានម្តង ៗ ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះឯង បរិនិព្វានរបស់ព្រះតថាគតនឹងមាន ក៏ភិក្ខុមានស័ក្តិធំនេះ មកឈរបាំងនៅចំព្រះភក្ត្រនៃព្រះមានព្រះភាគ ពួកយើងមិនបានឃើញព្រះតថាគត ក្នុងបច្ឆិមកាលឡើយ ។ ព្រះអានន្ទ ក្រាបបង្គំទូលសួរថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ចុះពួកទេវតា ធ្វើទុកក្នុងចិត្តដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មានពួកទេវតា (ខ្លះ) សម្គាល់ផែនដីក្នុងអាកាស (និម្មិតផែនដីក្នុងអាកាស) រំសាយកេសា កន្ទក់កន្ទេញ ផ្គងនូវកំភួនដៃឡើង កន្ទក់កន្ទេញ ផ្តួលខ្លួនបម្រះនឿលទៅមក បីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ នឹងបរិនិព្វានឆាប់ម្ល៉េះ ព្រះសុគតនឹងបរិនិព្វានឆាប់ម្ល៉េះ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក នឹងសូន្យបាត់ទៅឆាប់ម្ល៉េះ ម្នាលអានន្ទ មានពួកទេវតា (ខ្លះ) សម្គាល់ផែនដីក្នុងផែនដី (និម្មិតផែនដីប្រក្រតីឲ្យជាផែនដីទិព្វ) រំសាយកេសា កន្ទក់កន្ទេញផ្គងកំភួនដៃឡើង កន្ទក់កន្ទេញ ផ្តួលខ្លួនបម្រះនឿលទៅមក បីដូចមានជើងដាច់ហើយថា ព្រះមានព្រះភាគ នឹងបរិនិព្វាន ឆាប់ពេកណាស់ ព្រះសុគត នឹងបរិនិព្វាន ឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក

អន្តរធាយិស្សតីតិ យា បន តា ទេវតា វីតរាគា តា សតា សម្បជានា អធិវាសេន្តិ អនិច្ចា សង្ខារា តំ កុតេត្ថ លព្ភាតិ ។

[១៣១] បុព្វេ ភន្តេ ទិសាសុ វស្សំ វុត្ថា ភិក្ខូ អាគច្ឆន្តិ តថាគតំ ទស្សនាយ តេ មយំ លភាម មនោភាវនីយេ ភិក្ខូ ទស្សនាយ លភាម បយិរុបាសនាយ ភគវតោ បន មយំ ភន្តេ អច្ចយេន ន លភិស្សាម មនោភាវនីយេ ភិក្ខូ ទស្សនាយ ន លភិស្សាម បយិរុបាសនាយាតិ ។ ចត្តារិមានិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយានិ សំវេជនីយានិ ឋានានិ ។ កតមានិ ចត្តារិ ។ ឥធ តថាគតោ ជាតោតិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ

នឹងសូន្យបាត់ទៅឆាប់ពេកណាស់ ឯពួកទេវតាណា ដែលមិនមានរាគៈ ពួកទេវតានោះ មានសតិនិងសម្បជញ្ញៈ អត់សង្កត់សេចក្តីសោកបាន ដោយគិតថា សង្ខារទាំងឡាយ មិនទៀង ព្រោះហេតុនោះ បុគ្គល គប្បីបាននូវសេចក្តីទៀងទាត់ (ក្នុងខន្ធប្បវត្តិ) នេះ អំពីណា ។

[១៣១] ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើម ពួកភិក្ខុនៅចាំវស្សា ក្នុងទិសទាំងឡាយ រួចហើយតែងមក ដើម្បីគាល់ព្រះតថាគត យើងខ្ញុំព្រះអង្គ តែងបានជួបនឹងពួកភិក្ខុអ្នកចម្រើន ដោយចិត្ត ធ្លាប់បានចូលទៅអង្គុយជិតគ្នា បពិត្រព្រះអង្គដ៏ចម្រើន លុះ អំណើះតតនឹងព្រះមានព្រះភាគទៅ យើងខ្ញុំព្រះអង្គ នឹងលែងបានជួប លែងបានចូលទៅអង្គុយជិតពួកភិក្ខុ អ្នកចម្រើនដោយចិត្តហើយ ។ ព្រះ អង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សំវេជនីយដ្ឋាន (ទីដែលគួរកើតសង្វេគ) ដែលគួរឃើញ របស់កុលបុត្ត អ្នកមានសទ្ធានេះ ៤ កន្លែង ។ សំវេជ-នីយដ្ឋាន ៤ កន្លែង តើដូចម្តេច ។ ម្នាលអានន្ទ សំវេជនីយដ្ឋានដែល គួរឃើញ របស់កុលបុត្ត អ្នកមានសទ្ធា ដោយរលឹកឃើញថា ព្រះតថាគត

ឥធ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ ឥធ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតន្តិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ ឥធ តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វុតោតិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ ឥមានិ ខោ អានន្ទ ចត្តារិ សទ្ធស្ស កុលបុត្តស្ស ទស្សនីយានិ សំវេជនីយានិ ឋានានិ អាគមិស្សន្តិ ខោ អានន្ទ សទ្ធា ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ ឥធ តថាគតោ ជាតោតិបិ ឥធ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិបិ ឥធ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតន្តិបិ ឥធ តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វុតោតិបិ យេ ហិ កេចិ អានន្ទ ចេតិយចារិកំ អាហិណ្ឌន្តា បសន្នចិត្តា កាលំ ករិស្សន្តិ សព្វេ តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សន្តីតិ ។

ប្រសូត ក្នុងទីនេះដូច្នេះ ១ ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរឃើញ របស់កុលបុត្ត អ្នកមានសទ្ធា ដោយរឭកឃើញថា ព្រះតថាគតត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងទីដូច្នេះ ១ ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរឃើញ របស់កុលបុត្ត អ្នកមានសទ្ធា ដោយរឭកឃើញថា ព្រះតថាគត បានសម្តែងនូវអនុត្តរធម្មចក្ក ក្នុងទីនេះដូច្នេះ ១ ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរឃើញ របស់កុលបុត្ត អ្នកមានសទ្ធា ដោយរឭកឃើញថា ព្រះតថាគតបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងទីនេះដូច្នេះ ១ ម្នាលអានន្ទ នេះឯង សំវេជនីយដ្ឋាន ដែលគួរឃើញ ៤ កន្លែង របស់កុលបុត្ត អ្នកមានសទ្ធា ម្នាលអានន្ទ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អ្នកមានសទ្ធា នឹងមក ដោយរឭកឃើញថា ព្រះតថាគត ប្រសូតក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតត្រាស់ដឹង នូវអនុត្តរ-សម្មាសម្ពោធិញ្ញាណក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគត សម្តែងនូវអនុត្តរធម្ម-ចក្កក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វាន-ធាតុក្នុងទីនេះ ដូច្នេះក្តី ម្នាលអានន្ទ ពួកជនណាមួយ នឹងបានដើរមក កាន់ទីចារិកនៃចេតិយ ក៏មានចិត្តជ្រះថ្លា បើប្រសិនជាធ្វើមរណកាលទៅ ពួកជនទាំងអស់នោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ នឹងចូលទៅកាន់លោក គឺមនុស្សសុគតិ និងឋានសួគ៌ ។

[១៣២] កថំ មយំ ភន្តេ មាតុគ្គាមេ បដិបជ្ជាមាតិ ។ អទស្សនំ អានន្ទាតិ ។ ទស្សនេ ភគវា សតិ កថំ បដិបជ្ជិតព្វន្តិ ។ អនាលាបោ អានន្ទាតិ ។ អាលបន្តេ[១] ភន្តេ កថំ បដិបជ្ជិតព្វន្តិ ។ សតិ អានន្ទ ឧបដ្ឋាបេតព្វាតិ ។

[១៣៣] កថំ មយំ ភន្តេ តថាគតស្ស សរីរេ បដិបជ្ជាមាតិ ។ អព្យាវដា[២] តុម្ហេ អានន្ទ ហោថ តថាគតស្ស សរីរំ បូជាយ ឥង្ឃ តុម្ហេ អានន្ទ សទត្ថេ[៣] ឃដថ សទត្ថេ អនុយុញ្ជថ សទត្ថេ អប្បមត្តា អាតាបិនោ បហិតត្តា វិហរថ សន្តានន្ទ ខត្តិយបណ្ឌិតាបិ ព្រាហ្មណបណ្ឌិតាបិ គហបតិបណ្ឌិតាបិ តថាគតេ អភិប្បសន្នា តេ តថាគតស្ស សរីរបូជំ ករិស្សន្តីតិ ។ កថំ បន ភន្តេ តថាគតស្ស សរីរេ បដិបជ្ជិតព្វន្តិ ។

១ ឱ. ម. អាលបន្តេន បន ។ ២ ឱ. អព្យាវដា ។ ៣ ម. សរត្ថេ ។

[១៣២] ព្រះអានន្ទ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គទាំងឡាយ ត្រូវប្រតិបត្តិក្នុងមាតុគ្រាមដូចម្តេច ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ត្រូវកុំមើល ។ បពិត្រព្រះមានព្រះភាគ កាលបើមើលហើយ គប្បីប្រតិបត្តិដូចម្តេច ។ ម្នាលអានន្ទ ត្រូវកុំនិយាយរក ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើនិយាយរកហើយ គប្បីប្រតិបត្តិ ដូចម្តេចទៀត ។ ម្នាលអានន្ទ គប្បីតាំងសតិឲ្យមាំ ។

[១៣៣] បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គទាំងឡាយ ត្រូវប្រតិបត្តិ ក្នុងសរីរៈព្រះតថាគត ដូចម្តេច ។ ម្នាលអានន្ទ អ្នកទាំងឡាយកុំខ្វល់ខ្វាយ ដើម្បីបូជាសរីរៈតថាគតឡើយ ម្នាលអានន្ទ អ្នកទាំងឡាយចូរខំព្យាយាម ក្នុងប្រយោជន៍របស់ខ្លួនចុះ[១] ចូរខ្មីឃ្មាត សង្វាតក្នុងប្រយោជន៍របស់ខ្លួនចុះ កុំប្រមាទក្នុងប្រយោជន៍របស់ខ្លួន ចូរមានព្យាយាមមានចិត្តបញ្ជូនទៅ (កាន់ព្រះនិព្វាន) ចុះ ម្នាលអានន្ទ គង់តែមានខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតីបណ្ឌិតក្តី ជ្រះថ្លាក្នុងតថាគត គេនឹងធ្វើការបូជាសរីរៈតថាគត មិនខាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះជនទាំងឡាយនោះ គប្បីប្រតិបត្តិក្នុងសរីរៈ ព្រះតថាគត ដូចម្តេច ។

១ អដ្ឋកថា ថា សំដៅយកអរហត្តផល ។

មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ ចក្កវត្តិសរីរបដិបជ្ជនកថា

យថា ខោ អានន្ទ រញ្ញោ ចក្កវត្តិស្ស សរីរេ បដិ-
បជ្ជន្តិ ឯវំ តថាគតស្ស សរីរេ បដិបជ្ជិតព្វន្តិ ។ កថំ
បន ភន្តេ រញ្ញោ ចក្កវត្តិស្ស សរីរេ បដិបជ្ជន្តីតិ ។
រញ្ញោ អានន្ទ ចក្កវត្តិស្ស សរីរំ អហតេន វត្ថេន វេឋេន្តិ
អហតេន វត្ថេន វេឋេត្វា វិហតេន កប្បាសេន វេឋេន្តិ
វិហតេន កប្បាសេន វេឋេត្វា អហតេន វត្ថេន វេឋេន្តិ
ឯតេន ឧចាយេន បញ្ចហិ យុកសតេហិ រញ្ញោ ចក្ក-
វត្តិស្ស សរីរេ វេឋេត្វា អយសាយ តេលទោណិយា
បក្ខិបិត្វា អញ្ញិស្សា អយសាយ ទោណិយា បដិក្កុជ្ជិត្វា
សព្វកន្ធានំ ចិតកំ ករិត្វា រញ្ញោ ចក្កវត្តិស្ស សរីរេ
ឈាបេន្តិ ចាតុម្មហាបថេ រញ្ញោ ចក្កវត្តិស្ស ថូបំ ករោន្តិ
ឯវំ ខោ អានន្ទ រញ្ញោ ចក្កវត្តិស្ស សរីរំ បដិបជ្ជន្តិ យថា
ខោ អានន្ទ រញ្ញោ ចក្កវត្តិស្ស សរីរេ បដិបជ្ជន្តិ

ម្នាលអានន្ទ ជនទាំងឡាយ តែងប្រតិបត្តិក្នុងសរីរៈព្រះចក្រពត្តិរាជ យ៉ាងណាមិញ ជនទាំងនោះ គប្បីប្រតិបត្តិក្នុងសរីរៈតថាគត យ៉ាងនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះជនទាំងនោះ ប្រតិបត្តិក្នុងសរីរៈព្រះចក្រពត្តិរាជ ដូចម្តេច ។ ម្នាលអានន្ទ ជនទាំងឡាយ រុំសរីរៈព្រះចក្រពត្តិរាជ ដោយសំពត់ថ្មី លុះរុំដោយសំពត់ថ្មីរួចហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡីរួចហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) រុំសរីរៈនៃចក្រពត្តិរាជ ដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយតម្កល់ក្នុងមឈូសមាស[១] ដែលដាក់ប្រេង ហើយគ្របដោយមឈូសមាសដទៃ[២] រួចធ្វើជើងថ្ករ ហើយថ្វាយព្រះភ្លើង ចំពោះសរីរៈព្រះចក្រពត្តិរាជ ដោយគ្រឿងក្រអូបគ្រប់យ៉ាង ហើយគេធ្វើស្តូបនៃព្រះចក្រពត្តិរាជក្នុងផ្លូវធំបែកជា ៤ ម្នាលអានន្ទ ជនទាំងឡាយ ប្រតិបត្តិក្នុងសរីរៈព្រះរាជាចក្រពត្តិ យ៉ាងនេះឯង ម្នាលអានន្ទ ជនទាំងឡាយ ប្រតិបត្តិក្នុងសរីរៈព្រះចក្រពត្តិរាជ

---

១ ពាក្យថា មឈូស ប្រែចេញពីបាលីថា ទោណិ ដែលធ្លាប់ប្រែថា ស្នូក តែដែលប្រែថា មឈូស ដូច្នេះ តាមលំនាំសេចក្តីជាខ្មែរ ។ ពាក្យថា មាស ប្រែចេញពីបាលីថា អយសៈ ដែលក្នុងទីឯទៀត តែងប្រែថា ដែក តែក្នុងទីនេះ អដ្ឋកថាប្រាប់ឲ្យប្រែថា មាស ។ ២ គ្របមឈូស ឬគ្របភ្ជាស ។

ឯវំ តថាគតស្ស សរីរេ បដិបជ្ជិតព្វំ ចាតុម្មហាបថេ តថាគតស្ស ថូបោ កាតព្វោ តត្ថ យេ តេ មាលំ វា គន្ធំ វា ចុណ្ណកំ វា អារោបេស្សន្តិ វា អភិវាទេស្សន្តិ វា ចិត្តំ វា បសាទេស្សន្តិ តេសន្តំ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។

[១៣៤] ចត្តារោមេ អានន្ទ ថូបារហា ។ កតមេ ចត្តារោ ។ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ថូបារហោ បច្ចេកសម្ពុទ្ធោ ថូបារហោ តថាគតស្ស សាវកោ[១] ថូបារហោ រាជា ចក្កវត្តិ ថូបារហោ ។ កិញ្ចានន្ទ[២] អត្ថវសំ បដិច្ច តថាគតោ អរហំ សម្មាសម្ពុទ្ធោ ថូបារហោ ។ អយំ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ថូបោតិ អានន្ទ ពហូ ជនា ចិត្តំ បសាទេន្តិ[៣] តេ តត្ថ ចិត្តំ បសាទេត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ឥទំ ខោ

១ ឱ. តថាគតស្សាវកោ ។ ២ ឱ. កតមញ្ចានន្ទ ។ ៣ ឱ. ពហុជនោ ចិត្តំ បសាទេតិ ។

យ៉ាងណាមិញ ជនទាំងនោះ គប្បីប្រតិបត្តិក្នុងសរីរៈតថាគត គប្បីធ្វើស្តូបរបស់តថាគត ក្នុងផ្លូវធំបែកជា ៤ យ៉ាងនោះចុះ ពួកជនណានឹងលើកឡើងនូវកម្រងផ្កាក្តី គ្រឿងក្រអូបក្តី គ្រឿងលម្អិតក្តី ឬនឹងថ្វាយបង្គំ ឬធ្វើចិត្តឲ្យជ្រះថ្លា ក្នុងស្តូបនោះ អំពើនោះ របស់ជនទាំងនោះ នឹងនាំមកនូវប្រយោជន៍ និងសេចក្តីសុខអស់កាលយូរ ។

[១៣៤] ម្នាលអានន្ទ ថូបារហបុគ្គល (បុគ្គលដែលគួរដល់ស្តូប) នេះ មាន ៤ ពួក ។ ថូបារហបុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ជាថូបារហបុគ្គល ១ ព្រះបច្ចេកពុទ្ធ ជាថូបារហបុគ្គល ១ សាវ័ករបស់ព្រះតថាគត ជាថូបារហបុគ្គល ១ ព្រះចក្រពត្តិរាជ ជាថូបារហបុគ្គល ១ ។ ម្នាលអានន្ទ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបរបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លា ក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ[១] បានសួគ៌

១ អដ្ឋកថា សង្គ្រោះយកទាំងមនុស្សសុគតិចូលផង ។

មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ ចតុត្ថូបារហកថា

អានន្ទ អត្ថវសំ បដិច្ច តថាគតោ អរហំ សម្មាសម្ពុទ្ធោ ថូចារហោ ។ កិញ្ចានន្ទ អត្ថវសំ បដិច្ច បច្ចេកសម្ពុទ្ធោ ថូចារហោ ។ អយំ តស្ស បច្ចេកពុទ្ធស្ស ថូចោតិ អានន្ទ ពហូ ជនា ចិត្តំ បសាទេន្តិ តេ តត្ថ ចិត្តំ បសាទេត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ឥទំ ខោ អានន្ទ អត្ថវសំ បដិច្ច បច្ចេកសម្ពុទ្ធោ ថូចារហោ ។ កិញ្ចានន្ទ អត្ថវសំ ប-ដិច្ច តថាគតស្ស សាវកោ ថូចារហោ ។ អយំ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សាវកថូ-ចោតិ អានន្ទ ពហូ ជនា ចិត្តំ បសាទេន្តិ តេ តត្ថ ចិត្តំ បសាទេត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ឥទំ ខោ អានន្ទ អត្ថវសំ បដិច្ច តថាគតស្ស សាវកោ ថូចារហោ ។

ម្នាលអានន្ទ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលអានន្ទ ព្រះបច្ចេកសម្ពុទ្ធ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបរបស់ព្រះបច្ចេកពុទ្ធអង្គនោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លាក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ ព្រះបច្ចេក-សម្ពុទ្ធ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលអានន្ទ សាវ័ករបស់ព្រះតថាគត ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបនៃសាវ័ក របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លា ក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ សាវ័ករបស់ព្រះតថាគត ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

តិញ្ញានន្ទ អត្ថវសំ បដិច្ច រាជា ចក្កវត្តិ ថូបារហោ ។ អយំ តស្ស ធម្មិកស្ស ធម្មរញ្ញោ ថូបោតិ អានន្ទ ពហូ ជនា ចិត្តំ បសាទេន្តិ តេ តត្ថ ចិត្តំ បសាទេត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ឥទំ ខោ អានន្ទ អត្ថវសំ បដិច្ច រាជា ចក្កវត្តិ ថូបារហោ ឥមេ ខោ អានន្ទ ចត្តារោ ថូបារ-ហាតិ ។

[១៣៥] អថខោ អាយស្មា អានន្ទោ វិហារំ បវិសិ-ត្វា កបិសីសំ អាលម្ពិត្វា រោទមានោ អដ្ឋាសិ អហញ្ច វតម្ហិ សេក្ខោ សករណីយោ សត្ថុ ច មេ បរិនិព្វានំ ភវិស្សតិ យោ មម(១) អនុកម្បកោតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ កហំ នុ ខោ ភិក្ខវេ អានន្ទោ-តិ ។ ឯសោ ភន្តេ អាយស្មា អានន្ទោ វិហារំ បវិសិត្វា កបិសីសំ អាលម្ពិត្វា រោទមានោ ឋិតោ អហញ្ច វតម្ហិ

១ ឱ. មមំ ។

ម្នាលអានន្ទ ព្រះចក្រពត្តិរាជ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបរបស់ព្រះធម្មរាជ ដែលទ្រង់ធម៌នោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លា ក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ ព្រះចក្រពត្តិរាជ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលអានន្ទ ថូបារហបុគ្គលមាន ៤ ពួក នេះឯង ។

[១៣៥] គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅកាន់វិហារ ក៏តោងនូវឈើមានសណ្ឋានដូចក្បាលស្វា (ត្រដោកទ្វារ) ឈរយំរៀបរាប់ថា ឱអាត្មាអញ ជាសេក្ខបុគ្គល មានកិច្ចគួរធ្វើតទៅទៀតនៅឡើយ ក៏ព្រះសាស្តារបស់អាត្មា ដែលជាអ្នកអនុគ្រោះ ដល់អាត្មាអញ នឹងទ្រង់បរិនិព្វាន ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អានន្ទទៅណា ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអានន្ទមានអាយុ ចូលទៅកាន់រោងសម្រាប់សម្រាកកាយ តោងត្រដោកទ្វារ ឈរយំរៀបរាប់ឯណោះថា ឱអាត្មាអញ

សេក្ខោ សករណីយោ សត្ថុ ច មេ បរិនិព្វានំ ភវិស្សតិ យោ មម អនុកម្បកោតិ ។ អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន អានន្ទំ អាមន្តេហិ សត្ថា តំ អាវុសោ អានន្ទ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច សត្ថា តំ អាវុសោ អានន្ទ អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ អាយស្មា អានន្ទោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច អលំ អានន្ទ មា សោចិ មា បរិទេវិ ននុ ឯវំ[១] អានន្ទ មយា បដិកច្ចេវ អក្ខាតំ សព្វេហេវ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ តំ កុតេត្ថ[២] លព្ភា យន្តំ

១ ឱ. ឯតំ ។ ២ ឱ. ម. កុតេត្ថ អានន្ទ ។

នៅជាសេក្ខបុគ្គល មានកិច្ចគួរធ្វើតទៅទៀតនៅឡើយ ព្រះសាស្ដារបស់អាត្មា ដែលជាអ្នកអនុគ្រោះ ដល់អាត្មាអញ នឹងទ្រង់បរិនិព្វាន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ហៅភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ អ្នកចូរទៅហៅអានន្ទ តាមពាក្យតថាគតថា ម្នាលអាវុសោអានន្ទ ព្រះសាស្ដាទ្រង់ត្រាស់ឲ្យហៅអ្នក ។ ភិក្ខុនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយទៅនឹងព្រះអានន្ទមានអាយុ ដូច្នេះថា ម្នាលអាវុសោអានន្ទ ព្រះសាស្ដាទ្រង់ត្រាស់ឲ្យហៅអ្នក ។ ព្រះអានន្ទមានអាយុ ទទួលពាក្យរបស់ភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ នូវព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ណ្ហើយ អ្នកកុំសោយសោក កុំខ្សឹកខ្សួលឡើយ ម្នាលអានន្ទ តថាគតបានប្រាប់អ្នកជាមុនហើយ យ៉ាងនេះថា សេចក្ដីព្រាត់ប្រាស វិនាសប្រែប្រួល ចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងអស់ តែងមានជាធម្មតា ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្ដីមិនព្រាត់ប្រាសនោះ ក្នុង (ខន្ធប្បវត្តិ) នេះមកអំពីណា ធម្មជាតណាដែលកើតហើយ

ជាតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតិ ទីឃរត្តំ ខោ តេ អានន្ទ តថាគតោ បច្ចុបដ្ឋិតោ មេត្តេន កាយកម្មេន ហិតេន សុខេន អទ្វយេន អប្បមាណេន មេត្តេន វចីកម្មេន ហិតេន សុខេន អទ្វយេន អប្បមាណេន មេត្តេន មនោកម្មេន ហិតេន សុខេន អទ្វយេន អប្បមាណេន កតបុញ្ញោ-សិ ត្វំ អានន្ទ បធានមនុយុញ្ជ ខិប្បំ ហោហិសិ អនាសវោតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ យេបិ តេ ភិក្ខវេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេសម្បិ ភគវន្តានំ ឯតបរមាយេវ ឧបដ្ឋាកា អហេសុំ សេយ្យថាបិ មយ្ហំ អានន្ទោ

ដែលមានហើយ ដែលបច្ច័យតាក់តែងហើយ មានសេចក្តីទ្រោមទ្រុឌទៅជាធម្មតា ធម្មជាតនោះ បុគ្គលនឹងពោលឃាត់ថា កុំទ្រោមទ្រុឌទៅដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះ មិនមានឡើយ ម្នាលអានន្ទ ខ្លួនអ្នកបានបម្រើតថាគត មកជាយូរអង្វែងហើយ ដោយកាយកម្មប្រកបដោយមេត្តា នាំមកនូវប្រយោជន៍និងសេចក្តីសុខ មិនមានចំណែកពីរ[១] ជាកម្មប្រមាណមិនបាន ដោយវចីកម្មប្រកបដោយមេត្តា នាំមកនូវប្រយោជន៍និងសេចក្តីសុខ មិនមានចំណែកពីរ ជាកម្មប្រមាណមិនបាន ដោយមនោកម្មប្រកបដោយមេត្តា នាំមកនូវប្រយោជន៍និងសេចក្តីសុខ មិនមានចំណែកពីរ ជាកម្មប្រមាណមិនបាន ម្នាលអានន្ទ ខ្លួនអ្នកជាបុគ្គលបានធ្វើបុណ្យទុកហើយ ចូរប្រកបព្យាយាមឲ្យរឿយ ៗ ចុះ នឹងបានជាបុគ្គលមិនមានអាសវៈ ដោយឆាប់ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលមានក្នុងអតីតកាល ពួកភិក្ខុជាឧបដ្ឋាករបស់ព្រះមានព្រះភាគទាំងនោះ មានកំណត់ដូច្នេះឯង ដូចអានន្ទរបស់តថាគតដែរ

---

១ អដ្ឋកថា ថា បុគ្គលពួកមួយ ធ្វើការបម្រើតែក្នុងទីចំពោះមុខ មិនបានធ្វើក្នុងទីកំបាំងមុខ បុគ្គលពួកមួយទៀត ធ្វើការបម្រើតែក្នុងទីកំបាំងមុខ មិនបានធ្វើក្នុងទីចំពោះមុខ ឯកាយកម្មរបស់ព្រះអានន្ទមិនដូច្នោះទេ ទើបឈ្មោះថា មិនមានចំណែកពីរ ។

យេបិ តេ ភិក្ខវេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេសម្បិ ភគវន្តានំ ឯតបរមាយេវ ឧបដ្ឋាកា ភវិស្សន្តិ សេយ្យថាបិ មយ្ហំ អានន្ទោ បណ្ឌិតោ[១] ភិក្ខវេ អានន្ទោ ជានាតិ អយំ កាលោ តថាគតំ ទស្សនាយ ឧបសង្កមិតុំ អយំ កាលោ ភិក្ខូនំ[២] អយំ កាលោ ភិក្ខុនីនំ អយំ កាលោ ឧបាសកានំ អយំ កាលោ ឧបាសិកានំ អយំ កាលោ រញ្ញោ រាជមហាមត្តានំ អយំ កាលោ តិត្ថិយានំ អយំ កាលោ តិត្ថិយសាវកានន្តិ[៣] ។

[១៣៦] ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ ។ កតមេ ចត្តារោ ។ សចេ ភិក្ខវេ ភិក្ខុ-បរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេន សា អត្តមនា ហោតិ តត្រចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ

១ ឱ. បណ្ឌិតោ ខោ ។ ២ ឱ. ម. ឧបសង្កមិតុំ ភិក្ខូនំ ។ ៣ ឱ. ម. រាជមហាមត្តានំ តិត្ថិយានំ តិត្ថិយសាវកានន្តិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ នឹងមានមក ក្នុងអនាគតកាល ពួកភិក្ខុជាឧបដ្ឋាករបស់ព្រះមានព្រះភាគទាំងនោះ មានកំណត់ដូច្នេះឯង ដូចអានន្ទរបស់តថាគតដែរ ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិតតែងដឹងដូច្នេះថា កាលនេះ ជាកាលគួរនឹងចូលទៅគាល់ព្រះតថាគត កាលនេះ ជាកាលគួររបស់ពួកភិក្ខុ កាលនេះ ជាកាលគួររបស់ពួកភិក្ខុនី កាលនេះ ជាកាលគួររបស់ពួកឧបាសក កាលនេះ ជាកាលគួររបស់ពួកឧបាសិកា កាលនេះ ជាកាលគួររបស់ព្រះរាជានិងរាជមហាមាត្យ កាលនេះ ជាកាលគួររបស់ពួកតិរ្ថិយ កាលនេះ ជាកាលគួររបស់ពួកតិត្ថិយសាវ័ក ។

[១៣៦] ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភុតធម៌ (ធម៌ជាអស្ចារ្យចម្លែក) ទាំងឡាយ ៤ យ៉ាងនេះ មាននៅក្នុងអានន្ទ ។ ធម៌ទាំង ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើបរិស័ទចូលទៅ ដើម្បីជួបនឹងអានន្ទ ភិក្ខុបរិស័ទនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុបរិស័ទនោះ ក៏មានសេចក្តីត្រេកអរ ដោយភាសិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិស័ទ មិនទាន់ឆ្អែតនៅឡើយ ក៏

ភិក្ខុបរិសា ហោតិ អថ[១] អានន្ទោ តុណ្ហី ហោតិ សចេ ភិក្ខវេ ភិក្ខុនីបរិសា អានន្ទំ ទស្សនាយ ឧប-សង្កមតិ ទស្សនេន សា អត្តមនា ហោតិ តត្រ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ភិក្ខុនីបរិសា ហោតិ អថ[២] អានន្ទោ តុណ្ហី ហោតិ សចេ ភិក្ខវេ ឧបាសកបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេន សា អត្តមនា ហោតិ តត្រ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ឧបាសកបរិសា ហោតិ អថ[៣] អានន្ទោ តុណ្ហី ហោតិ សចេ ភិក្ខវេ ឧបាសិកាបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេន សា អត្តមនា ហោតិ តត្រ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេ-នបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ឧបា-សិកាបរិសា ហោតិ អថ[៤] អានន្ទោ តុណ្ហី ហោតិ ឥមេ ខោ ភិក្ខវេ ចត្តារោ អច្ឆរិយា អព្ភុតធម្មា អានន្ទេ ។

---

១-២-៣-៤ ម. អថខោ ។

ស្រាប់តែអានន្ទស្ងៀមទៅ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនីបរិស័ទ ចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុនីបរិស័ទនោះ រមែងមានសេចក្តីត្រេកអរដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុនីបរិស័ទនោះក៏មានសេចក្តីត្រេកអរដោយភាសិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀមទៅ ម្នាលភិក្ខុទាំងឡាយ បើឧបាសកបរិស័ទ ចូលទៅដើម្បីជួបនឹងអានន្ទ ឧបាសកបរិស័ទនោះរមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសកបរិស័ទនោះ ក៏មានសេចក្តីត្រេកអរដោយភាសិត ម្នាលភិក្ខុទាំងឡាយ ឧបាសកបរិស័ទ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀមទៅ ម្នាលភិក្ខុទាំងឡាយ បើឧបាសិកាបរិស័ទ ចូលទៅដើម្បីជួបនឹងអានន្ទ ឧបាសិកាបរិស័ទនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសិកាបរិស័ទនោះ ក៏មានសេចក្តីត្រេកអរដោយភាសិត ម្នាលភិក្ខុទាំងឡាយ ឧបាសិកាបរិស័ទមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀមទៅ ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភុតធម៌ទាំងឡាយ ៤ យ៉ាងនេះឯង មាននៅក្នុងអានន្ទ ។

ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា រញ្ញោ ចក្កវត្តិម្ហិ[១] សចេ ភិក្ខវេ ខត្តិយបរិសា រាជានំ ចក្កវត្តឹ ទស្សនាយ ឧបសង្កមិ ទស្សនេន សា អត្តមនា ហោតិ តត្រ ចេ រាជា ចក្កវត្តិ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ខត្តិយបរិសា ហោតិ អថ រាជា ចក្កវត្តិ តុណ្ហី ហោតិ ។ សចេ ភិក្ខវេ ព្រាហ្មណបរិសា ។ គហបតិបរិសា ។ សមណបរិសា រាជានំ ចក្កវត្តឹ ទស្សនាយ ឧបសង្កមតិ ទស្សនេន សា អត្តមនា ហោតិ តត្រ ចេ រាជា ចក្កវត្តិ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ សមណបរិសា ហោតិ អថ រាជា ចក្កវត្តិ តុណ្ហី ហោតីតិ ឯវមេវ ខោ ភិក្ខវេ ចត្តារោ[២] អច្ឆរិយា អព្ភុតធម្មា អានន្ទេ សចេ ភិក្ខវេ ភិក្ខុបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេន សា អត្តមនា ហោតិ តត្រ ចេ អានន្ទោ ធម្មំ ភាសតិ

---

១ ម. ចក្កវត្តិម្ហិ ។ កតមេ ចត្តារោ ។ ២ ម. ចត្តារោមេ ។

ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភុតធម៌ទាំងឡាយ ៤ យ៉ាងនេះ មាននៅក្នុងព្រះចក្រពត្តិរាជ ម្នាលភិក្ខុទាំងឡាយ បើខត្តិយបរិស័ទ ចូលទៅដើម្បីគាល់ព្រះចក្រពត្តិរាជ ខត្តិយបរិស័ទនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើព្រះចក្រពត្តិរាជ មានព្រះបន្ទូលក្នុងទីនោះ ខត្តិយបរិស័ទនោះ ក៏មានសេចក្តីត្រេកអរដោយភាសិត ម្នាលភិក្ខុទាំងឡាយ ខត្តិយ-បរិស័ទ មិនទាន់ឆ្អែតនៅឡើយ ស្រាប់តែព្រះចក្រពត្តិរាជស្ងៀមទៅ ។ ម្នាលភិក្ខុទាំងឡាយ បើព្រាហ្មណបរិស័ទ ។ គហបតិបរិស័ទ ។ សមណ-បរិស័ទ ចូលទៅដើម្បីគាល់ព្រះចក្រពត្តិរាជ សមណបរិស័ទនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានគាល់ បើព្រះចក្រពត្តិរាជ មានព្រះបន្ទូលក្នុងទីនោះ សមណបរិស័ទនោះ មានសេចក្តីត្រេកអរ ដោយភាសិត ម្នាលភិក្ខុទាំងឡាយ សមណបរិស័ទ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែព្រះចក្រពត្តិរាជស្ងៀមទៅ ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភុត-ធម៌ទាំងឡាយ ៤ យ៉ាងនេះ មាននៅក្នុងអានន្ទដូច្នោះឯង ម្នាលភិក្ខុទាំង-ឡាយ បើភិក្ខុបរិស័ទ ចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុបរិស័ទនោះរមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ

ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ភិក្ខុបរិសា ហោតិ អថ អានន្ទោ តុណ្ហី ហោតិ សចេ ភិក្ខវេ ភិក្ខុនីបរិសា ។ ឧបាសកបរិសា ។ ឧបាសិ-កាបរិសា អានន្ទំ ទស្សនាយ ឧបសង្កមតិ ទស្សនេន សា អត្តមនា ហោតិ តត្រ ចេ អានន្ទោ ធម្មំ ភាសតិ ភាសិតេនបិ សា អត្តមនា ហោតិ អតិត្តា វ ភិក្ខវេ ឧបាសិកាបរិសា ហោតិ អថ អានន្ទោ តុណ្ហី ហោតិ ឥមេ ខោ ភិក្ខវេ ចត្តារោ អច្ឆរិយា អព្ភុតធម្មា អានន្ទេតិ ។

[១៣៧] ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯ-តទវោច មា ភន្តេ ភគវា ឥមស្មឹ ខុទ្ទកនគរកេ[១] ឧជ្ជង្គលនគរកេ សាខានគរកេ បរិនិព្វាយិ សន្តិ ភន្តេ អញ្ញានិ មហានគរានិ សេយ្យថីទំ ចម្បា រាជគហំ សាវត្ថី សាកេតំ កោសម្ពី ពារាណសី ឯត្ថ ភគវា បរិនិព្វាយតុ ឯត្ថ ពហូ ខត្តិយមហាសាលា ព្រាហ្មណ-

១ ឱ. ខុទ្ទនគរកេ ។

ភិក្ខុបរិស័ទនោះ ក៏មានសេចក្តីត្រេកអរដោយភាសិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិស័ទ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀមទៅ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនីបរិស័ទ ។ ឧបាសកបរិស័ទ ។ ឧបាសិកា-បរិស័ទ ចូលទៅដើម្បីជួបនឹងអានន្ទ ឧបាសិកាបរិស័ទនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ ក្នុងទីនោះ ឧបាសិកាបរិស័ទនោះ ក៏មានសេចក្តីត្រេកអរ ដោយភាសិត ម្នាលភិក្ខុទាំងឡាយ ឧបាសិកាបរិស័ទ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀមទៅ ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភុតធម៌ ៤ យ៉ាងនេះឯង មាននៅក្នុងអានន្ទ ។

[១៣៧] លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ កុំបរិនិព្វាន (ក្នុងនគរកុសិនារា) ជានគរតូច ជានគរទួល ជាសាខានគរនេះឡើយ បពិត្រព្រះអង្គដ៏ចម្រើន មានមហា-នគរដទៃគឺ នគរចម្បា រាជគ្រឹះ សាវត្ថី សាកេត កោសម្ពី ពារាណសី សូមព្រះមានព្រះភាគ បរិនិព្វានក្នុងនគរទាំងនុ៎ះ ខត្តិយមហាសាល[១]

១ ក្សត្រិយ៍ដែលមានទ្រព្យកប់ទុកចំនួន ១ រយកោដិ ឬ ១ ពាន់កោដិឡើងទៅ វេលាថ្ងៃចំណាយកហាបណៈចំនួន ១ រទេះ វេលាល្ងាចមានកហាបណៈចំនួន ២ រទេះ ចូលមកវិញ ហៅថា ខត្តិយមហាសាល ។

៣០៧



មហាសាលា គហបតិមហាសាលា តថាគតេ អភិប្ប-
សន្នា តេ តថាគតស្ស សរីរបូជំ ការិស្សន្តីតិ ។
មា ហេវំ អានន្ទ អវច មា ហេវំ អានន្ទ អវច
ខុទ្ទកនគរកំ ឧជ្ជង្គលនគរកំ សាខានគរកន្តិ
ភូតបុព្វំ អានន្ទ រាជា មហាសុទស្សនោ នាម
អហោសិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ
វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតា
រញ្ញោ អានន្ទ មហាសុទស្សនស្ស អយំ កុសិនា-
រា កុសាវតី នាម រាជធានី អហោសិ បុរត្ថិមេ-
ន ច បច្ឆិមេន ច ទ្វាទសយោជនានិ អាយាមេន
ឧត្តរេន ច ទក្ខិណេន ច សត្តយោជនានិ វិត្ថារេន

ព្រាហ្មណមហាសាល[១] គហបតីមហាសាល[២]ជាច្រើន ក្នុងនគរទាំងនោះ មានសេចក្តីជ្រះថ្លាក្នុងព្រះតថាគត គេនឹងធ្វើការបូជា ព្រះសរីរៈព្រះតថាគត ។ ម្នាលអានន្ទ អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលអានន្ទ អ្នកកុំនិយាយថា នគរកុសិនារានេះ ជានគរតូច ជានគរទួល ជាសាខានគរយ៉ាងនេះឡើយ ម្នាលអានន្ទ កាលពីដើមមានព្រះចក្រពត្តិរាជ ព្រះនាមមហាសុទស្សនៈ ជាធម្មរាជ ទ្រង់ធម៌ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត មានជនបទមាំមួន ប្រកបដោយរតនៈទាំង ៧ ប្រការ ម្នាលអានន្ទ ទីក្រុងកុសិនារានេះ ជារាជធានីឈ្មោះកុសាវតី របស់ព្រះមហាសុទស្សនរាជ មានបណ្តោយ ១២ យោជន៍ អំពីទិសខាងកើតទៅទិសខាងលិច មានទទឹង ៧ យោជន៍ អំពីទិសខាងជើង ទៅទិសខាងត្បូង

---

១ ព្រាហ្មណ៍ដែលមានទ្រព្យកប់ទុកចំនួន ៨០ កោដិឡើងទៅ វេលាថ្ងៃចំណាយកហាបណៈចំនួន ១ កុម្ភៈ វេលាល្ងាចមានកហាបណៈចំនួន ១ រទេះចូលមកវិញ ហៅថា ព្រាហ្មណមហាសាល ។ ២ គហបតីដែលមានទ្រព្យកប់ទុកចំនួន ៤០ កោដិឡើងទៅ វេលាថ្ងៃចំណាយកហាបណៈចំនួន ៥ អម្ពណៈ វេលាល្ងាចមានកហាបណៈ ១ កុម្ភៈចូលមកវិញ ហៅថាគហបតីមហាសាល ។ សម្តែងរឿងរង្វាល់ថា ៤ ក្តាប់ ត្រូវជា ១ កុឌវៈ ៤ កុឌវៈ ត្រូវជា ១ បត្ថៈ ៤ បត្ថៈ ត្រូវជា ១ អាឡ្ហកៈ ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ ៤ ទោណៈ ត្រូវជា ១ មាតិកា ៤ មាតិកា ត្រូវជា ១ ខារិ (អម្រែក) ២០ ខារិ ត្រូវជា ១ សកដៈ គឺ ១ រទេះ ។ មួយទៀតថា ១ ទូកដៃ ហៅថា ១ កុឌវៈ ៤ កុឌវៈ ត្រូវជា ១ បត្ថៈ ៤ បត្ថៈ ត្រូវជា ១ អាឡ្ហកៈ ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ ១១ ទោណៈត្រូវជា ១១ អម្ពណៈ ១០ អម្ពណៈ ត្រូវជា ១ កុម្ភៈ គឺជាឈ្មោះរង្វាល់ក្អម ។

កុសាវតី អានន្ទ រាជធានី ឥទ្ធា ចេវ អហោសិ[១] ផីតា ច ពហុជនា ច អាកិណ្ណមនុស្សា ច សុភិក្ខា ច សេយ្យថាបិ អានន្ទ ទេវានំ អាលកមន្ទា នាម រាជធានី ឥទ្ធា ចេវ អហោសិ ផីតា ច ពហុជនា ច អាកិណ្ណយក្ខា ច សុភិក្ខា ច ឯវមេវ ខោ អានន្ទ កុសាវតី រាជធានី ឥទ្ធា ចេវ អហោសិ ផីតា ច ពហុជនា ច អាកិណ្ណមនុស្សា ច សុភិក្ខា ច កុសាវតី អានន្ទ រាជធានី ទសហិ សទ្ទេហិ អវិវិត្តា អហោសិ ទិវា ចេវ រត្តិញ្ច សេយ្យថីទំ ហត្ថិសទ្ទេន អស្សសទ្ទេន រថសទ្ទេន ភេរិសទ្ទេន មុទិង្គសទ្ទេន វីណាសទ្ទេន គីតសទ្ទេន សម្មសទ្ទេន តាលសទ្ទេន អស្នាថ[២] បិវថ ខាទថាតិ ទសមេន សទ្ទេន គច្ឆ ត្វំ អានន្ទ កុសិនារាយំ បវិសិត្វា កោសិនារកានំ មល្លានំ អារោចេហិ អជ្ជ ខោ វាសិដ្ឋា[៣] រត្តិយា បច្ឆិមេ យាមេ តថាគតស្ស បរិនិព្វានំ ភវិស្សតិ អភិក្កមថ វាសិដ្ឋា អភិក្កមថ វាសិដ្ឋា មា បច្ឆា វិប្បដិសារិនោ អហុវត្ថ

---

១ ម. ហោតិ ។ ឱ. អហោសីតិ ន ទិស្សតិ ។ ២ ឱ. ម. អស្នាថ ។ ៣ ឱ. វាសេដ្ឋា ។

ម្នាលអានន្ទ កុសាវតីរាជធានី ជាក្រុងស្តុកស្តម្ភ សម្បូណ៌ពោរពាស (ដោយទំនិញ) មានជនច្រើន មានមនុស្សដេរដាស ទាំងបរិបូណ៌ដោយភិក្ខាហារ ម្នាលអានន្ទ រាជធានីឈ្មោះ អាឡកមន្ទា របស់ពួកទេវតាជារាជ-ធានីស្តុកស្តម្ភ សម្បូណ៌ពោរពាស មានជនច្រើន មានយក្ខដេរដាស ទាំងបរិបូណ៌ដោយភិក្ខាហារ យ៉ាងណាមិញ ម្នាលអានន្ទ កុសាវតីរាជធានីក៏ជាក្រុងស្តុកស្តម្ភ សម្បូណ៌ពោរពាស (ដោយទំនិញ) មានជនច្រើន មានមនុស្សដេរដាស ទាំងបរិបូណ៌ដោយភិក្ខាហារ យ៉ាងនោះដែរ ម្នាលអានន្ទ កុសាវតីរាជធានី មិនដែលស្ងាត់ ដោយសូរសំឡេង ១០ យ៉ាង ទាំងថ្ងៃ ទាំងយប់ គឺសូរសំឡេងដំរី សូរសំឡេងសេះ សូរសំឡេងរថ សូរសំឡេងស្គរ សូរសំឡេងសំភោរ សូរសំឡេងពិណ សូរសំឡេងចម្រៀង សូរសំឡេងរគាំង សូរសំឡេងរនាត និងសូរសំឡេងជាគម្រប់ ១០ ថា អ្នកទាំងឡាយ ចូរស៊ី ចូរផឹក ចូរទំពា ម្នាលអានន្ទ អ្នកចូរទៅក្នុងក្រុងកុសិនារា ហើយថ្វាយដំណឹងដល់ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិ-នារាថា បពិត្រវាសិដ្ឋគោត្រទាំងឡាយ ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះតថាគតនឹងបរិនិព្វាន បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូមអ្នកទាំងឡាយអញ្ជើញទៅ បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូមអ្នកទាំងឡាយអញ្ជើញទៅ កុំឲ្យមានសេចក្តីក្តៅក្រហាយ ស្តាយក្នុងកាលជាខាងក្រោយ ថា

អម្ហាកញ្ច នោ គាមក្ខេត្តេ តថាគតស្ស បរិនិព្វានំ អហោសិ ន មយំ លភិម្ហា បច្ឆិមេ កាលេ តថា-គតំ ទស្សនាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា និវាសេត្វា បត្តចីវរំ អាទាយ អត្តុតិយោ[១] កុសិនារំ បាវិសិ ។ តេន ខោ បន សមយេន កោសិនារកា មល្លា សន្ធា-គារេ សន្និបតិតា ហោន្តិ កេនចិទេវ ករណីយេន ។ អថខោ អាយស្មា អានន្ទោ យេន កោសិនារកានំ មល្លានំ សន្ធាគារំ តេនុបសង្កមិ ឧបសង្កមិត្វា កោសិនារកានំ មល្លានំ អារោចេសិ អជ្ជ ខោ វា-សិដ្ឋា រត្តិយា បច្ឆិមេ យាមេ តថាគតស្ស បរិនិព្វានំ ភវិស្សតិ អភិក្កមថ វាសិដ្ឋា អភិក្កមថ វាសិដ្ឋា មា បច្ឆា វិប្បដិសារិនោ អហុវត្ថ អម្ហាកញ្ច នោ គាមក្ខេត្តេ តថាគតស្ស បរិនិព្វានំ អហោសិ ន មយំ

១ ឱ. ម. អត្តទុតិយោ ។

ព្រះតថាគតទ្រង់បរិនិព្វានក្នុងគាមក្ខេត្ត របស់យើងទាំងឡាយហើយ យើងទាំងឡាយ មិនបានឃើញព្រះតថាគត ក្នុងកាលជាទីបំផុតដូច្នេះឡើយ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូល នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ មិនមានកិក្ខុជាគម្រប់ពីរ ចូលទៅក្នុងក្រុងកុសិនារា ។ សម័យនោះឯង ពួកមល្លក្សត្រដែលនៅក្នុងក្រុងកុសិនារា កំពុងប្រជុំគ្នាក្នុងសណ្ឋាគារដ្ឋាន (សាលាសម្រាប់បង្រៀនវិជ្ជាក្នុងរាជត្រកូល) ដោយកិច្ចនីមួយ ។ ។ ព្រះអានន្ទមានអាយុ ក៏ចូលទៅកាន់សណ្ឋាគារដ្ឋាន របស់ពួកមល្លក្សត្រដែលនៅក្នុងក្រុងកុសិនារានោះ លុះចូលទៅដល់ហើយ ក៏ថ្វាយដំណឹងដល់ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារាថា បពិត្រវាសិដ្ឋគោត្រទាំងឡាយ ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះតថាគតនឹងបរិនិព្វាន បពិត្រវាសិដ្ឋ-គោត្រទាំងឡាយ សូមអ្នកទាំងឡាយអញ្ជើញទៅ បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូមអ្នកទាំងឡាយអញ្ជើញទៅ កុំឲ្យមានសេចក្ដីក្ដៅក្រ-ហាយ ស្ដាយក្នុងកាលជាខាងក្រោយថា ព្រះតថាគតទ្រង់បរិនិព្វានក្នុងគាមក្ខេត្ត របស់យើងទាំងឡាយហើយ យើងទាំងឡាយមិនបានឃើញ

លភិម្ហា បច្ឆិមេ កាលេ តថាគតស្ស ទស្សនាយាតិ ។ ឥទមាយស្មតោ អានន្ទស្ស សុត្វា មល្លា ច មល្លបុត្តា ច មល្លសុណិសា ច មល្លបជាបតិយោ ច អឃាវិនោ ទុម្មនា ចេតោទុក្ខសមប្បិតា អប្បេកច្ចេ កេសេ បកិរិយ កន្ទន្តិ ពាហា បគ្គយ្ហ កន្ទន្តិ ឆិន្នធាតំ វិយ បបតន្តិ[១] អាវដ្ដន្តិ[២] អតិខិប្បំ ភគវា បរិនិព្វាយិស្សតិ អតិខិប្បំ សុគតោ បរិនិព្វាយិស្សតិ អតិខិប្បំ ចក្ខុមា លោកេ អន្តរធាយិស្សតីតិ ។ អថខោ មល្លា ច មល្លបុត្តា ច មល្លសុណិសា ច មល្លបជាបតិយោ ច អឃាវិនោ ទុម្មនា ចេតោទុក្ខសមប្បិតា យេន ឧបវត្តនំ មល្លានំ សាលវនំ យេនាយស្មា អានន្ទោ តេនុបសង្កមឹសុ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ សចេ ខោ អហំ កោសិនារកេ មល្លេ ឯកមេកំ ភគវន្តំ វន្ទាបេស្សាមិ អវន្ទិតោ ច ភគវា កោសិនារកេហិ មល្លេហិ ភវិស្សតិ អថាយំ រត្តិ វិភាយិស្សតិ យន្នូនាហំ កោសិនារកេ

១ ឱ. ឆិន្នបបាតិ បបតន្តិ ។ ម. ឆិន្នបាតំ បបតន្តិ ។ ២ ឱ. ម. អាវដ្ដន្តិ វិវដ្ដន្តិ ។

ព្រះតថាគត ក្នុងកាលជាបំផុតដូច្នេះឡើយ ។ ពួកមល្លក្សត្រ និងពួកបុត្រ របស់មល្លក្សត្រ និងសុណិសារបស់មល្លក្សត្រ និងភរិយារបស់មល្លក្សត្រ លុះឮពាក្យនេះ របស់ព្រះអានន្ទមានអាយុហើយ ក៏កើតទុក្ខតូចព្រះទ័យ ពោរពេញដោយសេចក្តីទុក្ខក្នុងព្រះទ័យ ខ្លះក៏រំសាយកេសាកន្ទក់កន្ទេញ ផ្គងកំភួនដៃកន្ទក់កន្ទេញ ផ្តួលខ្លួនចុះបម្រះននៀលទៅមកដូចជាមានជើង ដាច់ហើយថា ព្រះមានព្រះភាគនឹងបរិនិព្វាន ឆាប់ពេកណាស់ ព្រះសុគតនឹងបរិនិព្វាន ឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក នឹងបាត់ទៅឆាប់ពេកណាស់ ។ លំដាប់នោះ ពួកមល្លក្សត្រ និងពួកបុត្ត របស់មល្លក្សត្រ និងសុណិសា របស់មល្លក្សត្រ និងភរិយារបស់មល្លក្សត្រ កើតទុក្ខតូចព្រះទ័យ ពោរពេញដោយសេចក្តីទុក្ខក្នុងព្រះទ័យ ក៏នាំគ្នាចូលទៅរកព្រះអានន្ទមានអាយុ ក្នុងសាលវ័ន របស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុង ។ ទើបព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា បើអាត្មាអញនឹងឲ្យពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារា ថ្វាយបង្គំព្រះមានព្រះភាគម្នាក់ម្តង ៗ ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារា នឹងថ្វាយបង្គំព្រះមានព្រះភាគ មិនទាន់ហើយស្រេច រាត្រីនេះ ក៏នឹងភ្លឺឡើង មិនខាន បើដូច្នេះគួរតែអាត្មាអញ ដាក់ឲ្យពួកមល្លក្សត្រ ដែលនៅក្នុងក្រុង

មល្លេ កុលបរិវត្តសោ កុលបរិវត្តសោ ឋបេត្វា ភគវន្តំ វន្ទាបេយ្យំ ឥត្ថន្នាមោ ភន្តេ មល្លោ សបុត្តោ សភរិយោ សបរិសោ សាមច្ចោ ភគវតោ បាទេ សិរសា វន្ទតីតិ ។ អថខោ អាយស្មា អានន្ទោ កោសិនារកេ មល្លេ កុលបរិវត្តសោ កុលបរិវត្តសោ ឋបេត្វា ភគវន្តំ វន្ទាបេសិ ឥត្ថន្នាមោ ភន្តេ មល្លោ សបុត្តោ សភរិយោ សបរិសោ សាមច្ចោ ភគវតោ បាទេ សិរសា វន្ទតីតិ ។ អថខោ អាយស្មា អានន្ទោ ឯតេន ឧបាយេន បឋមេនេវ យាមេន កោសិនារកេ មល្លេ ភគវន្តំ វន្ទាបេសិ ។

[១៣៨] តេន ខោ បន សមយេន សុភទ្ទោ នាម បរិព្វាជកោ កុសិនារាយំ បដិវសតិ ។ អស្សោសិ ខោ សុភទ្ទោ បរិព្វាជកោ អជ្ជេវ រត្តិយា[១] បច្ឆិមេ យាមេ សមណស្ស គោតមស្ស បរិនិព្វានំ ភវិស្សតីតិ ។ អថខោ

១ ឱ. អជ្ជេវ កិរ រត្តិយា ។ ម. អជ្ជ កិរ រត្តិយា ។

កុសិនារា ថ្វាយបង្គំព្រះមានព្រះភាគ តាមវង្សនៃត្រកូល ៗ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន មល្លក្សត្រឈ្មោះនេះ ព្រមទាំងបុត្រភរិយា បរិស័ទនិងអមាត្យ សូមបង្អោនសិរ្សៈ ថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ក៏ដាក់ឲ្យពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ថ្វាយបង្គំព្រះមានព្រះភាគ តាមវង្សនៃត្រកូល ៗ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន មល្លក្សត្រឈ្មោះនេះ ព្រមទាំងបុត្រភរិយា បរិស័ទនិងអាមាត្យ សូមបង្អោនសិរ្សៈ ថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ ។ ទើបព្រះអានន្ទមានអាយុ ឲ្យពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ថ្វាយបង្គំព្រះមានព្រះភាគ ក្នុងបឋមយាមតាមទំនងនេះ ។

[១៣៨] សម័យនោះឯង មានបរិព្វាជកឈ្មោះសុភទ្ទ នៅក្នុងក្រុងកុសិនារា ។ សុភទ្ទបរិព្វាជក បានឮដំណឹងថា ព្រះសមណគោ-តម នឹងបរិនិព្វានក្នុងបច្ឆិមយាម នៃរាត្រីថ្ងៃនេះ ។ គ្រានោះ សុភទ្ទ-

សុភទ្ទស្ស បរិព្វាជកស្ស ឯតទហោសិ សុតំ ខោ បន មេតំ បរិព្វាជកានំ វុឌ្ឍានំ មហល្លកានំ អាចរិយចាចរិយានំ ភាសមានានំ កទាចិ ករហចិ តថាគតា លោកេ ឧប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា អជ្ជេវ[១] រត្តិយា បច្ឆិមេ យាមេ សមណស្ស គោតមស្ស បរិនិព្វានំ ភវិស្សតិ អត្ថិ ច មេ អយំ កង្ខាធម្មោ ឧប្បន្នោ ឯវម្បសន្នោ អហំ សមណេ គោតមេ បហោតិ មេ សមណោ គោតមោ តថា ធម្មំ ទេសេតុំ យថា អហំ ឥមំ កង្ខាធម្មំ បជហេយ្យន្តិ ។ អថខោ សុភទ្ទោ បរិព្វាជកោ យេន ឧបវត្តនំ មល្លានំ សាលវនំ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច សុតំ មេតំ ភោ អានន្ទ

១ ឱ. សម្មាសម្ពុទ្ធាតិ អជ្ជ ច ។

បរិព្វាជក មានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យនេះ អាត្មាអញ បានឮមក អំពីពួកបរិព្វាជក ជាមនុស្សចាស់ទុំ ជាអាចារ្យត ៗ គ្នាមក តែងនិយាយថា ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយ ដងមួយកាល ក៏ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតម នឹង បរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះ កើតឡើងដល់អាត្មាអញ ទាំងអាត្មាក៏មានសេចក្តីជ្រះថ្លា ក្នុងព្រះសមណគោតមដែរ អាត្មាអញគួរ លះបង់ នូវសេចក្តីសង្ស័យនេះបានយ៉ាងណា ព្រះសមណគោតម អាច នឹងសម្តែងធម៌ដល់អាត្មាយ៉ាងនោះបាន ។ គ្រានោះ សុភទ្ទបរិព្វាជក ក៏ ចូលទៅរកព្រះអានន្ទមានអាយុ ក្នុងសាលវ័នរបស់ពួកមល្លក្សត្រ ដែល ជាទីចូលទៅក្នុងក្រុង លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះអានន្ទ មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ពាក្យនេះ ខ្ញុំបានឮមក

បរិព្វាជកានំ វុឌ្ឍានំ មហល្លកានំ អាចរិយចាចរិយានំ ភាសមានានំ កទាចិ ករហចិ តថាគតា លោកេ ឧប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា អជ្ជេវ រត្តិយា បច្ឆិមេ យាមេ សមណស្ស គោតមស្ស បរិនិព្វានំ ភវិស្សតិ អត្ថិ ច មេ អយំ កង្ខាធម្មោ ឧប្បន្នោ ឯវំបសន្នោ អហំ សមណេ គោតមេ បហោតិ មេ សមណោ គោតមោ តថា ធម្មំ ទេសេតុំ យថា អហំ ឥមំ កង្ខាធម្មំ បជហេយ្យំ សាធាហំ[១] ភោ អានន្ទ លភេយ្យំ សមណំ គោតមំ ទស្សនាយាតិ ឯវំ វុត្តេ អាយស្មា អានន្ទោ សុភទ្ទំ បរិព្វាជកំ ឯតទវោច អលំ អាវុសោ សុភទ្ទ មា តថាគតំ វិហេឋេសិ កិលន្តោ ភគវាតិ ។ ទុតិយម្បិ ខោ សុភទ្ទោ បរិព្វាជកោ ។ បេ ។ តតិយម្បិ ខោ សុភទ្ទោ បរិព្វាជកោ អាយស្មន្តំ អានន្ទំ ឯតទវោច សុតំ មេតំ ភោ អានន្ទ បរិព្វាជកានំ វុឌ្ឍានំ មហល្លកានំ អាចរិយចាចរិយានំ ភាសមានានំ កទាចិ ករហចិ តថាគតា លោកេ ឧប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា

---

១ ឱ. ស្វាហំ ។

អំពីពួកបរិព្វាជកជាមនុស្សចាស់ទុំ ជាអាចារ្យត ៗ គ្នាមក តែងនិយាយថា ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយ-ដងមួយកាល ក៏ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតម នឹងបរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះ កើតឡើងដល់ខ្ញុំ ខ្ញុំក៏មានសេចក្តីជ្រះថ្លា ក្នុងព្រះសមណគោតមដែរ ខ្ញុំគួរលះបង់នូវសេចក្តីសង្ស័យនេះបានយ៉ាងណា ព្រះសមណគោតម អាចនឹងសម្តែងធម៌ដល់ខ្ញុំយ៉ាងនោះបាន បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំសូមឲ្យបានគាល់ព្រះសមណគោតមផង ។ លុះសុភទ្ទបរិព្វាជក និយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏បានពោលទៅនឹងសុភទ្ទបរិព្វាជកដូច្នេះថា ម្នាលអាវុសោសុភទ្ទ កុំឡើយ អ្នកកុំបៀតបៀនព្រះតថាគត ព្រះមានព្រះភាគទ្រង់លំបាកព្រះអង្គណាស់ ។ សុភទ្ទបរិព្វាជក បាននិយាយជាគម្រប់ពីរដងផង ។ បេ ។ សុភទ្ទបរិព្វាជក បាននិយាយនឹងព្រះអានន្ទមានអាយុ ជាគម្រប់បីដងផង ដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ពាក្យនេះខ្ញុំបានឮមកអំពីពួកបរិព្វាជកជាមនុស្សចាស់ទុំ ជាអាចារ្យត ៗ គ្នាមក តែងនិយាយថា ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយដងមួយកាល

អជ្ជេវ រត្តិយា បច្ឆិមេ យាមេ សមណស្ស គោតមស្ស បរិនិព្វានំ ភវិស្សតិ អត្ថិ ច មេ អយំ កង្ខាធម្មោ ឧប្បន្នោ ឯវម្បសន្នោ អហំ សមណេ គោតមេ បហោតិ មេ សមណោ គោតមោ តថា ធម្មំ ទេសេតុំ យថា អហំ ឥមំ កង្ខាធម្មំ បជហេយ្យំ សាធាហំ ភោ អានន្ទ លភេយ្យំ សមណំ គោតមំ ទស្សនាយាតិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ សុភទ្ទំ បរិព្វាជកំ ឯតទវោច អលំ អាវុសោ សុភទ្ទ មា តថាគតំ វិហេឋេសិ កិលន្តោ ភគវាតិ ។ អស្សោសិ ខោ ភគវា អាយស្មតោ អានន្ទស្ស សុភទ្ទេន បរិព្វាជកេន សទ្ធឹ ឥមំ កថាសល្លាបំ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ អលំ អានន្ទ មា សុភទ្ទំ វារេសិ លភតុ[១] អានន្ទ សុភទ្ទោ តថាគតំ ទស្សនាយ យំកិញ្ចិ មំ សុភទ្ទោ បុច្ឆិស្សតិ សព្វន្តំ អញ្ញាបេក្ខោវ មំ[២] បុច្ឆិស្សតិ នោ វិហេសាបេក្ខោ យញ្ចស្សាហំ បុដ្ឋោ ព្យាករិស្សាមិ តំ ខិប្បមេវ អាជានិស្សតីតិ ។

១ ឱ. ម. លភតំ ។ ២ ឱ. ម. មន្តិ បទំ នត្ថិ ។

ក៏ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតមនឹងបរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះ កើតឡើងដល់ខ្ញុំ ខ្ញុំក៏មានសេចក្តីជ្រះថ្លា ក្នុងព្រះសមណគោតម ខ្ញុំគួរលះបង់នូវសេចក្តីសង្ស័យនេះបាន យ៉ាងណា ព្រះសមណគោតម អាចនឹងសម្តែងធម៌ ដល់ខ្ញុំយ៉ាងនេះបាន បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំសូមឲ្យបានគាល់ចំពោះព្រះសមណគោតមផង ។ ព្រះអានន្ទមានអាយុ បានពោលទៅនឹងសុភទ្ទបរិព្វាជក ជាគម្រប់បីដងទៀត ដូច្នេះថា ម្នាលអាវុសោសុភទ្ទ កុំឡើយ អ្នកកុំបៀតបៀនព្រះតថាគត ព្រះមានព្រះភាគ ទ្រង់លំបាកព្រះអង្គណាស់ ។ ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់ កថាសល្លាបៈនេះ របស់ព្រះអានន្ទមានអាយុ ជាមួយនឹងសុភទ្ទបរិព្វាជក ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅ ព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ កុំឡើយ អ្នកកុំឃាត់សុភទ្ទ ម្នាលអានន្ទ សុភទ្ទចូរបានឃើញតថាគតចុះ សុភទ្ទនឹងសួរ នូវសេចក្តីណាមួយ នឹងតថាគត គាត់ចង់ដឹងនូវសេចក្តីនោះមែន ទើបគាត់មកសួរតថាគត មិនមែនគាត់សួរចង់បៀតបៀនទេ បើសុភទ្ទនេះសួរហើយ តថាគតសម្តែងធម៌ណា គាត់នឹងបានដឹងធម៌នោះឆាប់ភ្លាម ។

អថខោ អាយស្មា អានន្ទោ សុភទ្ទំ បរិព្វាជកំ ឯតទវោច គច្ឆាវុសោ សុភទ្ទ ករោតិ តេ ភគវា ឱកាសន្តិ ។ អថខោ សុភទ្ទោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុភទ្ទោ បរិព្វាជកោ ភគវន្តំ ឯតទវោច យេមេ ភោ គោតម សមណព្រាហ្មណា សង្ឃិនោ គណិនោ គណាចរិយា ញាតា យសស្សិនោ តិត្ថករា សាធុសម្មតា[១] ពហុជនស្ស សេយ្យថីទំ បូរណោ កស្សបោ មក្ខលិ គោសាលោ អជិតោ កេសកម្ពលោ[២] បកុធោ កច្ចាយនោ សញ្ជយោ វេលដ្ឋបុត្តោ[៣] និគណ្ឋោ នាដបុត្តោ សព្វេ តេ សកាយ បដិញ្ញាយ អព្ភញ្ញឹសុ[៤]

---

១ ឱ. សាធុសម្មតា ច ។ ២ ឱ. កេសកម្ពលី ។ ៣ ឱ. ម. ពេលដ្ឋិបុត្តោ ។ ម. ពេលដ្ឋបុត្តោ ។ ៤ ឱ. អព្ភញ្ញំសុ ។

ទើបព្រះអានន្ទមានអាយុ ពោលនឹងសុភទ្ទបរិព្វាជក ដូច្នេះថា ម្នាលអាវុសោសុភទ្ទ ព្រះមានព្រះភាគ ទ្រង់បើកឱកាសដល់អ្នកហើយ អ្នកចូរទៅចុះ ។ គ្រានោះ សុភទ្ទបរិព្វាជក ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះសុភទ្ទបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សមណព្រាហ្មណ៍ណា ជាពួកគណៈ ជាគណាចារ្យ ល្បីល្បាញ មានយស អ្នកធ្វើលទ្ធិដូចកំពង់ ដែលជនច្រើនគ្នាគេសន្មតថា ល្អ ដូចយ៉ាងគ្រូឈ្មោះ បូរណកស្សប មក្ខលិគោសាល អជិតកេសកម្ពល បកុធកច្ចាយនៈ សញ្ជយវេលដ្ឋបុត្ត និគណ្ឋនាដបុត្ត ពួកជនទាំងនោះ សុទ្ធតែត្រាស់ដឹង ដូចជាពាក្យប្ដេជ្ញា របស់ខ្លួនមែន

សព្វេ បន[១] ន អព្ភញ្ញឹសុ ឧទាហុ ឯកច្ចេ អព្ភញ្ញឹសុ ឯកច្ចេ ន អព្ភញ្ញឹសូតិ ។ អលំ សុភទ្ទ តិដ្ឋតេតំ សព្វេ តេ សកាយ បដិញ្ញាយ អព្ភញ្ញឹសុ សព្វេ បន ន អព្ភញ្ញឹសុ ឧទាហុ ឯកច្ចេ អព្ភញ្ញឹសុ ឯកច្ចេ ន អព្ភញ្ញឹសូតិ ធម្មន្តេ សុភទ្ទ ទេសិស្សាមិ តំ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ សុភទ្ទោ បរិព្វាជកោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច យស្មឹ ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ន ឧបលព្ភតិ សមណោបិ តត្ថ ន ឧបលព្ភតិ ទុតិយោបិ តត្ថ សមណោ ន ឧបលព្ភតិ តតិយោបិ តត្ថ សមណោ ន ឧបលព្ភតិ ចតុត្ថោបិ តត្ថ សមណោ ន ឧបលព្ភតិ យស្មិញ្ច ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ឧបលព្ភតិ សមណោបិ តត្ថ ឧបលព្ភតិ ទុតិយោបិ តត្ថ សមណោ ឧបលព្ភតិ តតិយោបិ តត្ថ សមណោ ឧបលព្ភតិ ចតុត្ថោបិ តត្ថ សមណោ ឧបលព្ភតិ ឥមស្មឹ ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ឧបលព្ភតិ ឥធេវ សុភទ្ទ

១ ឱ. ម. វ ។

ឬសុទ្ធតែមិនបានត្រាស់ដឹងទេ ឬក៏ត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសុភទ្ទ ណ្ហើយចុះ ពាក្យដែលអ្នកនិយាយថា ពួកជនទាំងនោះ សុទ្ធតែត្រាស់ដឹងដូចជាពាក្យប្តេជ្ញារបស់ខ្លួនមែន ឬសុទ្ធតែមិនបានត្រាស់ដឹងទេ ឬក៏ត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ ដូច្នេះនេះចូរលើកទុកសិនចុះ ម្នាលសុភទ្ទ តថាគតនឹងសម្តែងធម៌ដល់អ្នក អ្នកចូរស្តាប់ធម៌នោះ ចូរតាំងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ សុភទ្ទបរិព្វាជក ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលសុភទ្ទ អរិយមគ្គ មានអង្គ ៨ មិនមានក្នុងធម្មវិន័យណា សមណៈ[១]ទី ១ ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈទី ២ ក្តី[២] មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៣ ក្តី[៣] មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក្តី[៤] ក៏មិនមានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ លុះតែអរិយមគ្គប្រកបដោយអង្គ ៨ មានក្នុងធម្មវិន័យណា សមណៈ (ទី ១) ក្តី ទើបមានក្នុងធម្មវិន័យនោះ សមណៈទី ២ ក្តី មានក្នុងធម្មវិន័យនោះ សមណៈទី ៣ ក្តី មានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក្តី ក៏មានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិន័យនេះឯង ម្នាលសុភទ្ទ

១ សំដៅយកសោតាបន្នសមណៈ ។ ២ សកទាគាមិសមណៈ ។ ៣ អនាគាមិសមណៈ ។ ៤ អរហន្តសមណៈ ។

សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេភិ អញ្ញេហិ ឥមេ ច សុភទ្ទ ភិក្ខូ សម្មា វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ អស្សាតិ[១] ។

[១៣៩] ឯកូនតឹស[២] វយសា សុភទ្ទ
យំ បព្វជឹ កឹកុសលានុឯសី
វស្សានិ បញ្ញាសសមាធិកានិ
យតោ អហំ បព្វជិតោ សុភទ្ទ
ញាយស្ស ធម្មស្ស បទេសវត្តិ
ឥតោ ពហិទ្ធា សមណោបិ នត្ថិ ។

ទុតិយោបិ សមណោ នត្ថិ តតិយោបិ សមណោ នត្ថិ ចតុត្ថោបិ សមណោ នត្ថិ សុញ្ញា បរប្បវាទា សមណេភិ អញ្ញេហិ ឥមេ ច សុភទ្ទ ភិក្ខូ សម្មា វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ អស្សាតិ ។

---

១ ឱ. អស្ស ។ ២ ឯកូនត្តឹសាតិ បកតិបាឋោ ឯវមិធ ឆន្ទានុរក្ខនត្ថំ លិខិតោ ។ ឱ. ម. ឯកូនតឹសោ ។

សមណៈ (ទី ១) ក៏មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ក៏មានតែក្នុងសាសនានេះ សម-ណៈទី ៤ ក៏មានតែក្នុងសាសនានេះ បរប្បវាទ (វាទៈនៃគ្រូដទៃ) អំពី-សម្នាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ (នេះ) ម្នាលសុភទ្ទ មួយទៀត ភិក្ខុទាំងនេះ គប្បីនៅដោយប្រពៃ លោកនឹងមិនបានសូន្យចាកពួកអរហន្តឡើយ ។

[១៣៩] ម្នាលសុភទ្ទ កាលតថាគតមានវ័យ ២៩ ឆ្នាំ បានបួសហើយ ជាអ្នកស្វែងរកនូវកុសល (សព្វញ្ញុតញ្ញាណ) ម្នាលសុភទ្ទ កាលណាបើតថាគត បួសបានជាង ៥០ ឆ្នាំហើយ ញុំាងប្រទេស គឺវិបស្សនាមគ្គ ឲ្យប្រព្រឹត្តទៅជាប្រក្រតី ដើម្បីធម៌ដែលគួរត្រាស់ដឹងគឺអរិយមគ្គ ព្រោះហេតុនោះ សមណៈ (ទី ១) ខាងក្រៅអំពីសាសនានៃតថាគតនេះ មិនមានឡើយ ។

សមណៈទី ២ ក្តី មិនមាន សមណៈទី ៣ ក្តី មិនមាន សមណៈទី ៤ ក្តី ក៏មិនមានដែរ បរប្បវាទអំពីសម្នាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ (នេះ) ម្នាលសុភទ្ទ មួយទៀត ភិក្ខុទាំងនេះ គប្បីនៅដោយប្រពៃ លោកនឹងមិនបានសូន្យចាកពួកអរហន្តឡើយ ។

[១៤០] ឯវំ វុត្តេ សុភទ្ទោ បរិព្វាជកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យ-ថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកា-សិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាមហំ[១] ភន្តេ ភគ-វតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ យោ ខោ សុភទ្ទ អញ្ញតិត្ថិយបុព្វោ ឥមស្មឹ ធម្មវិ-នយេ អាកង្ខតិ បព្វជ្ជំ អាកង្ខតិ ឧបសម្បទំ សោ ចត្តារោ មាសេ បរិវសតិ ចតុន្នំ មាសានំ អច្ចយេន

១ ឱ. ម. លភេយ្យាហំ ។

[១៤០] លុះព្រះមានព្រះភាគ មានព្រះពុទ្ធតម្រាស់ យ៉ាងនេះហើយ សុភទ្ទបរិព្វាជក ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គល ផ្ងារឡើងនូវរបស់ដែលគេផ្កាប់ចុះក្តី បើកនូវរបស់ដែលគេគ្របក្តី ចង្អុលប្រាប់ផ្លូវដល់បុរស ដែលវង្វេងផ្លូវក្តី ទ្រោលប្រទីបបំភ្លឺ ក្នុងទីងងឹតដោយគិតថា អ្នកមានចក្ខុ នឹងបានឃើញរូបក្តី យ៉ាងណាមិញ ធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសដោយអនេកបរិយាយ ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសុភទ្ទ បុគ្គលណាធ្លាប់ជាអន្យតិរ្ថិយ ហើយប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ បុគ្គលនោះរមែងនៅបរិវាសអស់កំណត់ ៤ ខែសិន លុះកន្លង ៤ ខែហើយ

អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុ-ភាវាយ អបិច មេត្ថ បុគ្គលវេមត្តតា វិទិតាតិ ។ សចេ ភន្តេ អញ្ញតិត្ថិយបុព្វា ឥមស្មឹ ធម្មវិនយេ អាកង្ខន្តា បព្វជ្ជំ អាកង្ខន្តា ឧបសម្បទំ ចត្តារោ មាសេ បរិវសន្តិ ចតុន្នំ មាសានំ អច្ចយេន អា-រទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភាវា-យ អហំ ចត្តារិ វស្សានិ បរិវសិស្សាមិ ចតុន្នំ វស្សានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តុ ឧ-បសម្បាទេន្តុ ភិក្ខុភាវាយាតិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ តេនហានន្ទ សុភទ្ទំ បរិព្វាជកំ បព្វាជេថាតិ[១] ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថ-ខោ សុភទ្ទោ បរិព្វាជកោ អាយស្មន្តំ អានន្ទំ ឯ-តទវោច លាភា តេ[២] អាវុសោ អានន្ទ សុលទ្ធំ តេ[៣] អាវុសោ អានន្ទ យេ ឯត្ថ សត្ថារា[៤] សម្មុខា អន្តេវាសិកាភិសេកេន អភិសិត្តាតិ ។

---

១ ឱ. សុភទ្ទំ បព្វាជេថាតិ ។ ម. សុភទ្ទំ បព្វាជេហីតិ ។ ២-៣ ឱ. ម. វោ ។ ៤ ម. សត្ថុ ។

ទើបពួកភិក្ខុជាអារទ្ធចិត្ត (អ្នកមានចិត្តត្រេកអរ) ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីភិក្ខុភាវៈបាន តែថា សភាវៈនៃបុគ្គលដែលផ្សេងគ្នា តថាគតដឹងច្បាស់ហើយ ក្នុងរឿងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកបុគ្គលធ្លាប់ជាអន្យតិរ្ថិយហើយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទា ក្នុងធម្មវិន័យនេះ រមែងនៅបរិវាស អស់កំណត់ ៤ ខែ លុះកន្លង ៤ ខែហើយ ទើបពួកភិក្ខុជាអារទ្ធចិត្ត ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីភិក្ខុភាវៈបាន ខ្ញុំព្រះអង្គនឹងនៅបរិវាស អស់កំណត់ ៤ ឆ្នាំ លុះកន្លង ៤ ឆ្នាំហើយ សូមពួកភិក្ខុជាអារទ្ធចិត្ត ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីភិក្ខុភាវៈចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកបំបួសសុភទ្ទបរិព្វាជកផងចុះ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបសុភទ្ទបរិព្វាជក ពោលនឹងព្រះអានន្ទមានអាយុដូច្នេះថា នែអាវុសោអានន្ទ លោកម្ចាស់ពេញហៅជាមានលាភ នែអាវុសោអានន្ទ អត្តភាពជាមនុស្ស លោកម្ចាស់ក៏បានដោយល្អហើយ ព្រោះថា ព្រះសាស្តាបានអភិសេកលោកម្ចាស់ ដោយការអភិសេកជាអន្តេវាសិក ក្នុងទីចំពោះព្រះភក្ត្រ ក្នុងសាសនានេះ ។

អលត្ថ ខោ សុភទ្ទោ បរិព្វាជកោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា សុភទ្ទោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ បនាយស្មា សុភទ្ទោ អរហតំ អហោសិ ។ សោ[១] ភគវតោ បច្ឆិមោ សក្ខិសាវកោ អហោសីតិ ។

ពុទ្ធភាណវារំ បញ្ចមំ សមត្តំ[២] ។

[១៤១] អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ សិយា ខោ បនានន្ទ តុម្ហាកំ ឯវមស្ស

១ អដ្ឋកថាយំ សោ ចាតិ ទិស្សតិ ។ ២ ឱ. ហិរញ្ញវត្តិយភាណវារំ និដ្ឋិតំ បញ្ចមំ ។ ម. ភាណវារំ បញ្ចមំ ។

សុភទ្ទបរិព្វាជក បានបព្វជ្ជា បានឧបសម្បទាក្នុងសម្នាក់ នៃព្រះមានព្រះភាគស្រេចហើយ ។ ឯសុភទ្ទមានអាយុ លុះបានឧបសម្បទារួចភ្លាម ក៏ចេញទៅតែម្នាក់ឯង មិនប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ពួកកុលបុត្ត ដែលចេញចាកផ្ទះមកកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយបានដល់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ដោយមិនយូរប៉ុន្មាន ក៏សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ក៏ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចារ្យ ក៏បានអប់រំហើយ សោឡសកិច្ច ក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីកិច្ចនេះ មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ សុភទ្ទភិក្ខុមានអាយុ ក៏ជាអរហន្តមួយអង្គដែរ ។ សុភទ្ទភិក្ខុនោះ ជាបច្ឆិមសក្ខិ-ស្សាវ័ក[១] របស់ព្រះមានព្រះភាគ ។

ចប់ ពុទ្ធភាណវារៈទី ៥ ។

[១៤១] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះ

១ អដ្ឋកថា ថា កាលព្រះមានព្រះភាគគង់នៅ ជនដែលបានបួសជាសាមណេរហើយ លុះអំណើះតមក ទើបបានឧបសម្បទា បានរៀនកម្មដ្ឋាន បានសម្រេចព្រះអរហត្តក្តី កាលព្រះមានព្រះភាគគង់នៅ ជនដែលបានឧបសម្បទាហើយ លុះអំណើះតមក ទើបរៀនកម្មដ្ឋាន បានសម្រេចព្រះអរហត្តក្តី កាលព្រះមានព្រះភាគគង់នៅ ជនដែលបានរៀនកម្មដ្ឋានហើយ លុះអំ-ណើះតមក ទើបបានសម្រេចព្រះអរហត្តក្តី ជនទាំងនោះ ហៅថា បច្ឆិមសក្ខិស្សាវ័កទាំងអស់ ។ ឯសុភទ្ទភិក្ខុនេះ កាលព្រះមានព្រះភាគគង់នៅ បានបួសផង បានឧបសម្បទាផង បានរៀនកម្មដ្ឋានផង បានសម្រេចព្រះអរហត្តផង តែក្នុងថ្ងៃមួយ (ក៏ហៅថា) បច្ឆិមសក្ខិស្សាវ័កដែរ ។

៣២១

អតីតសត្ថុកំ បាវចនំ នត្ថិ នោ សត្ថាតិ ន ខោ បនេតំ អានន្ទ ឯវំ ទដ្ឋព្វំ យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា យថា ខោ បនានន្ទ ឯតរហិ ភិក្ខូ អញ្ញមញ្ញំ អាវុសោវាទេន សមុទាចរន្តិ ន តេ មមច្ចយេន ឯវំ សមុទាចរិតព្វំ ថេរតរេន អានន្ទ ភិក្ខុនា នវកតរោ ភិក្ខុ នាមេន វា គោត្តេន វា អាវុសោវាទេន វា សមុទាចរិតព្វោ នវកតរេន ភិក្ខុនា ថេរតរោ ភិក្ខុ ភន្តេតិ វា អាយស្មាតិ វា សមុទាចរិតព្វោ អាកង្ខមានោ អានន្ទ សង្ឃោ មមច្ចយេន ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ សមូហនតុ[១] ឆន្នស្ស អានន្ទ ភិក្ខុនោ មមច្ចយេន ព្រហ្មទណ្ឌោ ទាតព្វោតិ ។ កតមោ បន ភន្តេ ព្រហ្មទណ្ឌោតិ ។ ឆន្នោ អានន្ទ ភិក្ខុ យំ ឥច្ឆេយ្យ តំ វទេយ្យ សោ ភិក្ខូហិ នេវ វត្តព្វោ ន ឱវទិតព្វោ ន អនុសាសិតព្វោតិ ។

១ ឱ. សមូហន្តិ ។

ថា ពាក្យប្រដៅ ដែលមានគ្រូប្រព្រឹត្តកន្លងទៅហើយ គ្រូរបស់យើង ឈ្មោះថា មិនមានឡើយ ម្នាលអានន្ទ សេចក្តីនេះ អ្នកកុំចូលចិត្តយ៉ាង នេះឡើយ ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែង ហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះឥតអំពីតថាគត ទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ម្នាលអានន្ទ ក៏ក្នុង កាលសព្វថ្ងៃនេះ ពួកភិក្ខុហៅគ្នានិងគ្នាដោយពាក្យថា អាវុសោ អំណើះ ឥតពីតថាគតទៅ អ្នកទាំងឡាយ កុំហៅយ៉ាងនេះទៀតឡើយ ម្នាល អានន្ទ ភិក្ខុចាស់ជាង ត្រូវហៅភិក្ខុខ្ចីជាង ដោយនាមក៏បាន ដោយគោត្រ ក៏បាន ដោយពាក្យថា អាវុសោ ក៏បាន ចំណែកភិក្ខុខ្ចីជាង ត្រូវហៅភិក្ខុ ចាស់ជាងថា ភន្តេ ក៏បាន ថា អាយស្មា ក៏បាន ម្នាលអានន្ទ លុះអំណើះ ឥតនឹងតថាគតទៅ បើសង្ឃមានប្រាថ្នានឹងដកសិក្ខាបទ ចូរដកសិក្ខាបទ ដែលតូចនិងតូច ដោយលំដាប់ចុះ ម្នាលអានន្ទ អំណើះឥតពីតថាគត ទៅ សង្ឃត្រូវដាក់ព្រហ្មទណ្ឌ ដល់ឆន្នភិក្ខុផងចុះ ។ ព្រះអានន្ទក្រាបបង្គំ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រហ្មទណ្ឌ តើដូចម្តេច ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ឆន្នភិក្ខុ ចង់ពោលនូវពាក្យណា ពោល នូវពាក្យនោះចុះ ប៉ុន្តែពួកភិក្ខុ មិនត្រូវនិយាយ មិនត្រូវទូន្មាន មិនត្រូវ ប្រដៅ ឆន្នភិក្ខុនោះឡើយ ។

[១៤២] អថខោ[១] ភគវា ភិក្ខូ អាមន្តេសិ សិយា ខោ បន ភិក្ខវេ ឯកភិក្ខុស្សបិ កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វា បុច្ឆថ ភិក្ខវេ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ សម្មុខីភូតោ នោ សត្ថា អហោសិ ន មយំ សិក្ខិម្ហា ភគវន្តំ សម្មុខា បដិ-បុច្ឆិតុន្តិ ។ ឯវំ វុត្តេ តេ ភិក្ខូ តុណ្ហី អហេសុំ ។ ទុតិ-យម្បិ ខោ ភគវា ។ បេ ។ តតិយម្បិ ខោ ភគវា ភិក្ខូ អាមន្តេសិ សិយា ខោ បន ភិក្ខវេ ឯកភិក្ខុស្សបិ កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វា បុច្ឆថ ភិក្ខវេ មា បច្ឆា វិប្បដិសា-រិនោ អហុវត្ថ សម្មុខីភូតោ នោ សត្ថា អហោសិ ន មយំ សិក្ខិម្ហា ភគវន្តំ សម្មុខា បដិបុច្ឆិតុន្តិ ។

---

១ ឱ. អថ ។

[១៤២] លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំង-ឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា គប្បីមានសូម្បីដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសាកសួរ (តថាគតចុះ) កុំឲ្យអ្នកទាំងឡាយ មានសេចក្តីក្តៅក្រហាយ ស្តាយក្នុងកាលជាខាងក្រោយថា ព្រះសាស្តាមាននៅ ចំពោះមុខនៃយើងរាល់គ្នា ៗ មិនបានជាយកចិត្តទុកដាក់ ដើម្បីសាកសួរ ព្រះមានព្រះភាគ ក្នុងទីចំពោះព្រះភក្ត្រសោះ ។ កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ភិក្ខុទាំងនោះ ក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ជាគម្រប់ពីរដង ។ បេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ជាគម្រប់បីដងថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា គប្បីមាន សូម្បីដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសាកសួរ (តថាគតចុះ) កុំឲ្យអ្នកទាំងឡាយ មានសេចក្តីក្តៅក្រហាយ ស្តាយក្នុងកាលជាខាងក្រោយថា ព្រះសាស្តាមាននៅចំពោះមុខនៃយើងរាល់គ្នា ៗ មិនបានជាយកចិត្តទុកដាក់ ដើម្បីសាកសួរព្រះមានព្រះភាគ ក្នុងទីចំពោះព្រះភក្ត្រសោះ ។

តតិយម្បិ ខោ តេ ភិក្ខូ តុណ្ហី អហេសុំ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ សិយា ខោ បន ភិក្ខវេ សត្ថុគារវេនបិ ន បុច្ឆេយ្យាថ សហាយកោបិ ភិក្ខវេ សហាយកស្ស អារោចេតូតិ ។ ឯវំ វុត្តេ តេ ភិក្ខូ តុណ្ហី អហេសុំ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ ឯវំ បសន្នោ អហំ ភន្តេ ឥមស្មឹ ភិក្ខុសង្ឃេ នត្ថិ ឥមស្មឹ ភិក្ខុសង្ឃេ ឯកភិក្ខុស្សាបិ[១] កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វាតិ ។ បសាទា ខោ ត្វំ អានន្ទ វទេសិ ញាណមេវ ហេត្ថ អានន្ទ តថាគតស្ស នត្ថិ ឥមស្មឹ ភិក្ខុសង្ឃេ[២] ឯកភិក្ខុស្សាបិ កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វា ឥមេសំ ហិ អានន្ទ បញ្ចន្នំ ភិក្ខុសតានំ

១ ឱ. នត្ថិ ឯកភិក្ខុស្សបិ ។ ម. នត្ថិ ឯកភិក្ខុស្សាបិ ។ ២ ឱ. ភិក្ខុសង្ឃេ នត្ថិ ។

ភិក្ខុទាំងនោះ ក៏នៅតែស្ងៀម ជាគម្រប់បីដង ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើមានសេចក្តីសង្ស័យ អ្នកទាំងឡាយ មិនហ៊ានសាកសួរ (តថាគត) ព្រោះសេចក្តីគោរព ក្នុងសាស្តា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសំឡាញ់ ចូរប្រាប់ដល់ភិក្ខុជាសំឡាញ់ផងចុះ ។ លុះព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ភិក្ខុទាំងនោះ ក៏នៅស្ងៀម ។ គ្រានោះ ព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ជាអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លាយ៉ាងនេះ ក្នុងភិក្ខុសង្ឃនេះ ព្រោះថា សេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា មិនមានដល់ភិក្ខុ សូម្បីមួយរូប ក្នុងភិក្ខុសង្ឃនេះឡើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកនិយាយដោយសេចក្តីជ្រះថ្លា ម្នាលអានន្ទ ញាណតថាគត ក៏ដឹងពិតក្នុងសេចក្តីនេះថា សេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា មិនមានដល់ភិក្ខុ សូម្បីមួយរូប ក្នុងភិក្ខុសង្ឃនេះឡើយ ម្នាលអានន្ទ ព្រោះថា បណ្តាភិក្ខុទាំង ៥០០ រូបនេះ

យោ បច្ឆិមកោ ភិក្ខុ សោ សោតាបន្នោ អវិនិបាត-
ធម្មោ និយតោ សម្ពោធិបរាយនោតិ ។

[១៤៣] អថខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ។ អយំ តថាគតស្ស បច្ឆិមា វាចា ។

[១៤៤] អថខោ ភគវា បឋមជ្ឈានំ សមាបជ្ជិ បឋមជ្ឈានា វុដ្ឋហិត្វា ទុតិយជ្ឈានំ សមាបជ្ជិ ទុតិ-
យជ្ឈានា វុដ្ឋហិត្វា តតិយជ្ឈានំ សមាបជ្ជិ តតិយជ្ឈានា វុដ្ឋហិត្វា ចតុត្ថជ្ឈានំ សមាបជ្ជិ ចតុត្ថជ្ឈានា វុដ្ឋហិត្វា អាកាសានញ្ចាយតនំ សមាបជ្ជិ អាកាសានញ្ចាយត-
នសមាបត្តិយា វុដ្ឋហិត្វា វិញ្ញាណញ្ចាយតនំ សមាបជ្ជិ វិញ្ញាណញ្ចាយតនសមាបត្តិយា វុដ្ឋហិត្វា អាកិញ្ច-
ញ្ញាយតនំ សមាបជ្ជិ អាកិញ្ចញ្ញាយតនសមាបត្តិ-
យា វុដ្ឋហិត្វា នេវសញ្ញានាសញ្ញាយតនំ សមាបជ្ជិ

ភិក្ខុណា ដែលមានគុណធម៌យ៉ាងទាបបំផុត ភិក្ខុនោះ គង់ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជានិយតបុគ្គល មានការត្រាស់ដឹង ប្រព្រឹត្តទៅក្នុងខាងមុខ ។

[១៤៣] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយ ឲ្យបានដឹង សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។ នេះជាបច្ឆិមវាចា របស់ព្រះតថាគត ។

[១៤៤] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចូលកាន់បឋមជ្ឈាន ចេញអំពីបឋមជ្ឈាន ហើយចូលកាន់ទុតិយជ្ឈាន ចេញអំពីទុតិយជ្ឈាន ហើយចូលកាន់តតិយជ្ឈាន ចេញអំពីតតិយជ្ឈាន ហើយចូលកាន់ចតុត្ថជ្ឈាន ចេញអំពីចតុត្ថជ្ឈាន ហើយចូលកាន់អាកាសានញ្ចាយតនសមាបត្តិ ចេញអំពីអាកាសានញ្ចាយតនសមាបត្តិហើយ ចូលកាន់វិញ្ញាណញ្ចាយតនសមាបត្តិ ចេញអំពីវិញ្ញាណញ្ចាយតនសមាបត្តិ ហើយចូលកាន់អាកិញ្ចញ្ញាយតនសមាបត្តិ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ចេញអំពី

នេវសញ្ញានាសញ្ញាយតនសមាបត្តិយា វុដ្ឋហិត្វា សញ្ញា-វេទយិតនិរោធំ សមាបជ្ជិ ។ អថខោ អាយស្មា អានន្ទោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច បរិនិព្វុតោ ភន្តេ អនុរុទ្ធ ភគវាតិ ។ នាវុសោ អានន្ទ ភគវា បរិនិព្វុតោ សញ្ញាវេទយិតនិរោធំ សមាបន្នោតិ ។ អថខោ ភគវា សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហិត្វា នេវសញ្ញា-នាសញ្ញាយតនំ សមាបជ្ជិ នេវសញ្ញានាសញ្ញាយតន-សមាបត្តិយា វុដ្ឋហិត្វា អាកិញ្ចញ្ញាយតនំ សមាបជ្ជិ អាកិញ្ចញ្ញាយតនសមាបត្តិយា វុដ្ឋហិត្វា វិញ្ញាណញ្ចា-យតនំ សមាបជ្ជិ វិញ្ញាណញ្ចាយតនសមាបត្តិយា វុដ្ឋ-ហិត្វា អាកាសានញ្ចាយតនំ សមាបជ្ជិ អាកាសា-នញ្ចាយតនសមាបត្តិយា វុដ្ឋហិត្វា ចតុត្ថំ ឈានំ សមាបជ្ជិ ចតុត្ថា ឈានា វុដ្ឋហិត្វា តតិយំ ឈានំ សមាបជ្ជិ តតិយា ឈានា វុដ្ឋហិត្វា ទុតិយំ ឈានំ សមាបជ្ជិ ទុតិយា ឈានា វុដ្ឋហិត្វា បឋមំ ឈានំ

នេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ចូលកាន់សញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានិងវេទនា) ។ គ្រានោះ ព្រះអានន្ទមានអាយុ ពោលទៅនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ព្រះមានព្រះភាគ បរិនិព្វានហើយឬ ។ ព្រះអនុរុទ្ធតបថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគ មិនទាន់បរិនិព្វានទេ ព្រះអង្គទ្រង់ចូលកាន់សញ្ញាវេទ-យិតនិរោធ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសញ្ញា-វេទយិតនិរោធសមាបត្តិហើយ ថយមកចូលកាន់នេវសញ្ញានាសញ្ញាយត-នសមាបត្តិវិញ ចេញអំពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ថយមកចូលកាន់អាកិញ្ចញ្ញាយតនសមាបត្តិវិញ ចេញអំពីអាកិញ្ចញ្ញាយតន-សមាបត្តិហើយ ថយមកចូលកាន់វិញ្ញាណញ្ចាយតនសមាបត្តិវិញ ចេញអំពីវិញ្ញាណញ្ចាយតនសមាបត្តិហើយ ថយមកចូលកាន់អាកាសានញ្ចា-យតនសមាបត្តិវិញ ចេញអំពីអាកាសានញ្ចាយតនសមាបត្តិហើយ ថយមកចូលកាន់ចតុត្ថជ្ឈានវិញ ចេញអំពីចតុត្ថជ្ឈានហើយ ថយមកចូលកាន់តតិយជ្ឈានវិញ ចេញអំពីតតិយជ្ឈានហើយ ថយមកចូលកាន់ទុតិ-យជ្ឈានវិញ ចេញអំពីទុតិយជ្ឈានហើយ ថយមកចូលកាន់បឋមជ្ឈានវិញ

សមាបជ្ជិ បឋមា ឈានា វុដ្ឋហិត្វា ទុតិយំ ឈានំ សមាបជ្ជិ ទុតិយា ឈានា វុដ្ឋហិត្វា តតិយំ ឈានំ សមាបជ្ជិ តតិយា ឈានា វុដ្ឋហិត្វា ចតុត្ថំ ឈានំ សមាបជ្ជិ ។ ចតុត្ថា ឈានា វុដ្ឋហិត្វា សមនន្តរា ភគវា បរិនិព្វាយិ ។

[១៤៥] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា មហាភូមិចាលោ អហោសិ ភឹសនកោ លោមហំសោ ទេវទុន្ទុភិយោ[១] ច ផលឹសុ ។

[១៤៦] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា ព្រហ្មា សហម្បតិ ឥមំ គាថំ អភាសិ

សព្វេ វ និក្ខិបិស្សន្តិ
ភូតា លោកេ សមុស្សយំ
យត្ថ ឯតាទិសោ សត្ថា
លោកេ អប្បដិបុគ្គលោ
តថាគតោ ពលប្បត្តោ
សម្ពុទ្ធោ បរិនិព្វុតោតិ ។

១ ឱ. ទេវទុន្ទុភិយោ ។ ម. ទេវទុទ្រភិយោ ។

ចេញអំពីបឋមជ្ឈានហើយ ក៏ចូលកាន់ទុតិយជ្ឈានទៀត ចេញអំពីទុតិយជ្ឈានហើយ ក៏ចូលកាន់តតិយជ្ឈានទៀត ចេញអំពីតតិយជ្ឈានហើយ ក៏ចូលកាន់ចតុត្ថជ្ឈានទៀត ។ លុះព្រះមានព្រះភាគ ទ្រង់ចេញចាកចតុត្ថជ្ឈានហើយ ក៏ទ្រង់បរិនិព្វានក្នុងចន្លោះនោះ[១] ។

[១៨៥] កាលព្រះមានព្រះភាគ បរិនិព្វានហើយ ការកក្រើកនៃផែនដីធំ គួរស្ញើម គួរព្រឺរោម ក៏កើតមាន ទាំងស្គរ[២] ក៏លាន់ឮគគ្រឹកគគ្រេង ព្រមនឹងការបរិនិព្វាន ។

[១៨៦] កាលព្រះមានព្រះភាគ បរិនិព្វានហើយ សហម្បតិព្រហ្ម ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា

ព្រះសាស្តា ដែលឥតបុគ្គលប្រៀបស្មើ ប្រាកដដូច្នេះ ព្រះតថាគតជាសម្ពុទ្ធបរិបូណ៌ហើយដោយកម្លាំង ទ្រង់បរិនិព្វានហើយ ក្នុងលោកណា ពួកសត្វទាំងអស់ មុខជានឹងដាក់ចុះនូវរាងកាយ ក្នុងលោក (នោះ) មិនខានឡើយ ។

---

១ អដ្ឋកថា ថាទ្រង់ចេញចាកចតុត្ថជ្ឈានហើយ ពិចារណាអង្គឈាន ហើយទ្រង់បរិនិព្វានដោយភវង្គចិត្ត ជាអព្យាកតទុក្ខសច្ច ។ ២ ថា ស្គរនៃទេវតាក៏បាន ។

[១៤៧] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា សក្កោ ទេវានមិន្ទោ ឥមំ គាថំ អភាសិ

អនិច្ចា វត សង្ខារា
ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ
តេសំ វូបសមោ សុខោតិ ។

[១៤៨] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា អាយស្មា អនុរុទ្ធោ ឥមា គាថា អភាសិ

នាហុ អស្សាសបស្សាសោ
ឋិតចិត្តស្ស តាទិនោ
អនេជោ សន្តិមារព្ភ
យំ កាលមករី មុនិ ។
អសល្លីនេន ចិត្តេន
វេទនំ អជ្ឈវាសយិ
បជ្ជោតស្សេវ និព្វានំ
វិមោក្ខោ ចេតសោ អហូតិ ។

[១៨៧] កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះឥន្ទ្រជាធំជាងទេវតា ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា

សង្ខារទាំងឡាយ មិនទៀងហ្ន៎ មានកិរិយាកើតឡើងនិងការ
សូន្យទៅជាធម្មតា លុះកើតឡើងហើយក៏រលត់ទៅវិញ កិរិ-
យារម្ងាប់នូវសង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្តីសុខ ។

[១៨៨] កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអនុរុទ្ធមានអាយុ ក៏ពោលនូវគាថាទាំងនេះ ព្រមនឹងការបរិនិព្វានថា

ព្រះមុនីនាថអង្គណា ដែលមិនមានតណ្ហា ទ្រង់ប្រារព្ធនូវ
អនុបាទិសេសនិព្វានហើយ ទ្រង់ធ្វើមរណកាល អស្សាស-
បស្សាសៈ នៃព្រះមុនីនាថ ជាតាទិបុគ្គល ដែលមានព្រះ
ទ័យខ្ជាប់ខ្ជួននោះ មិនមានហើយ ។ ព្រះមុនីនាថ ទ្រង់អត់
សង្កត់វេទនាបានដោយចិត្តមិនរួញរា សេចក្តីរលត់នៃចិត្តក៏
កើតមាន បីដូចជាការរលត់នៃប្រទីប ។

[១៤៩] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា អាយស្មា អានន្ទោ ឥមំ គាថំ អភាសិ

តទាសិ យំ ភឹសនកំ
តទាសិ លោមហំសនំ
សព្វាការវរូបេតេ
សម្ពុទ្ធេ បរិនិព្វុតេតិ ។

[១៥០] បរិនិព្វុតេ ភគវតិ យេ តេត្ថ[១] ភិក្ខូ អវីតរាគា អប្បេកច្ចេ ពាហា បគ្គយ្ហ កន្ទន្តិ ឆិន្នបាតំ វិយ បបតន្តិ អាវដ្ដន្តិ វិវដ្ដន្តិ អតិខិប្បំ ភគវា បរិនិព្វុតោ អតិខិប្បំ សុគតោ បរិនិព្វុតោ អតិខិប្បំ ចក្ខុមា លោកេ អន្តរហិតោតិ ។ យេ បន តេ ភិក្ខូ វីតរាគា តេ សតា សម្បជានា អធិវាសេន្តិ អនិច្ចា វត សង្ខារា[២] តំ កុតេត្ថ លព្ភាតិ ។

[១៥១] អថខោ អាយស្មា អនុរុទ្ធោ ភិក្ខូ អាមន្តេសិ អលំ អាវុសោ មា សោចិត្ថ មា បរិទេវិត្ថ

---

១ ឱ. តត្ថ យេ តេ ។ ម. យេ តេ តត្ថ ។ ២ ឱ. ម. អនិច្ចា សង្ខារា ។

[១៨៩] កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអានន្ទមានអាយុ ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា

កាលដែលព្រះសម្ពុទ្ធ ប្រកបដោយហេតុ ប្រសើរទាំងពួង
ទ្រង់បរិនិព្វានហើយ សេចក្តីញាប់ញ័រក្តី សេចក្តីព្រឺរោម
ក្តី ក៏កើតមានប្រាកដ ។

[១៩០] កាលព្រះមានព្រះភាគ បរិនិព្វានហើយ ភិក្ខុទាំងឡាយណា ដែលមិនទាន់ប្រាសចាករាគៈ មាននៅក្នុងទីនុ៎ះ ភិក្ខុទាំងនោះ ពួកខ្លះក៏ផ្គងឡើង នូវកំភួនដៃហើយកន្ទក់កន្ទេញ ផ្តួលខ្លួនបម្រះននៀលទៅមកហាក់ដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសុគត ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ប្រញាប់បាត់ទៅពេកណាស់ ។ ឯពួកភិក្ខុណា ដែលប្រាសចាករាគៈហើយ ភិក្ខុទាំងនោះ មានសតិនិងសម្បជញ្ញៈ អត់សង្កត់ដោយគិតថា សង្ខារទាំងឡាយមិនទៀងពិត ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ ក្នុង (ខន្ធប្បវត្តិ) នេះ អំពីណា ។

[១៩១] លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ប្រាប់ពួកភិក្ខុថាម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នកទាំងឡាយ កុំសោយសោក កុំខ្សឹក

៣២៩



ននុ ឯតំ អាវុសោ ភគវតា បដិកច្ចេវ អក្ខាតំ សព្វេហេវ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ តំ កុតេត្ថ អាវុសោ លព្ភា យន្តំ ជាតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតិ ទេវតា អាវុសោ ឧជ្ឈាយន្តីតិ ។ កថំភូតា បន ភន្តេ អនុរុទ្ធ ទេវតា មនសិករោន្តីតិ ។ សន្តាវុសោ អានន្ទ ទេវតា អាកាសេ បថវីសញ្ញិនិយោ កេសេ បកិរិយ កន្ទន្តិ ពាហា បគ្គយ្ហ កន្ទន្តិ ឆិន្នបាតំ វិយ បបតន្តិ អាវដ្ដន្តិ វិវដ្ដន្តិ អតិខិប្បំ ភគវា បរិនិព្វុតោ

*ខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ សេចក្តីនេះ ព្រះមានព្រះភាគ ទ្រង់បានសម្តែងមកពីមុនហើយថា សេចក្តីព្រាត់ប្រាស វិនាសប្រែប្រួល ចាកសត្វនិងសង្ខារ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងអស់ តែង មានជាធម្មតា ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាន នូវសេចក្តីមិនព្រាត់ប្រាសនោះ ក្នុង (ខន្ធប្បវត្តិ) នេះ អំពីណា ធម្មជាតណា ដែលកើតហើយ ដែលមានហើយ ដែលបច្ច័យតាក់តែងហើយ មាន សេចក្តីទ្រុឌទ្រោមជាធម្មតា ធម្មជាតនោះឯង បុគ្គលនឹងពោលឃាត់ថា កុំទ្រុឌទ្រោមដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះ មិនមានឡើយ ម្នាល អាវុសោទាំងឡាយ ទេវតាទាំងឡាយ នឹងពោលទោស[១] មិនខាន ។ ព្រះ អានន្ទសួរថា បពិត្រអនុរុទ្ធដ៏ចម្រើន ចុះពួកទេវតាធ្វើទុកក្នុងចិត្តដូចម្តេច ។ ព្រះអនុរុទ្ធមានថេរវាចាថា ម្នាលអាវុសោអានន្ទ មានពួកទេវតា (ខ្លះ) ដែលសម្គាល់ នូវនិម្មិត គឺផែនដី ក្នុងអាកាស រំសាយសក់កន្ទក់កន្ទេញផ្គង ឡើងនូវកំភួនដៃកន្ទក់កន្ទេញ ផ្ដួលខ្លួនចុះបម្រះនទៀលទៅមក បីដូចជាមាន ជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់ប្រញាប់បរិនិព្វានពេកណាស់*

---

១ អដ្ឋកថា ថា ពួកទេវតាពោលទោសថា លោកម្ចាស់ទាំងឡាយ មិនអាចអត់សង្កត់ សេចក្តីសោកចំពោះខ្លួនឯងទៅហើយ ដូចម្តេចនឹងឲ្យជនដ៏សេស ដកដង្ហើមស្រួលបាន ។

អតិទិព្វំ សុគតោ បរិនិព្វុតោ អតិទិព្វំ ចក្ខុមា លោ-
កេ អន្តរហិតោតិ សន្តាវុសោ អានន្ទ ទេវតា បឋវិយា
បឋវីសញ្ញិនិយោ កេសេ បកិរិយ កន្ទន្តិ ។ បេ ។
អន្តរហិតោតិ ។ យា បន ទេវតា វីតរាគា តា សតា
សម្បជានា អធិវាសេន្តិ អនិច្ចា សង្ខារា តំ កុតេត្ថ
លព្ភាតិ ។ អថខោ អាយស្មា ច អនុរុទ្ធោ អាយស្មា
ច អានន្ទោ តំ រត្តាវសេសំ ធម្មិយា កថាយ វីតិនា-
មេសុំ ។ អថខោ អាយស្មា អនុរុទ្ធោ អាយស្មន្តំ អា-
នន្ទំ អាមន្តេសិ គច្ឆ អាវុសោ អានន្ទ កុសិនារំ បវិ-
សិត្វា កោសិនារកានំ មល្លានំ អារោចេហិ បរិនិព្វុតោ
វាសិដ្ឋា ភគវា យស្សទានិ កាលំ មញ្ញថាតិ ។ ឯវំ
ភន្តេតិ ខោ អាយស្មា អានន្ទោ អាយស្មតោ អនុ-
រុទ្ធស្ស បដិស្សុត្វា បុព្វណ្ហសមយំ និវាសេត្វា បត្ត-
ចីវរំ អាទាយ អទុតិយោ[១] កុសិនារំ បាវិសិ ។

១ ឱ. ម. អត្តទុតិយោ ។

ព្រះសុគត ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់ប្រញាប់បាត់បង់ពេកណាស់ ម្នាលអាវុសោអានន្ទ មានពួកទេវតា (ខ្លះ) ដែលសម្គាល់ នូវនិម្មិត គឺផែនដី លើផែនដី រំសាយសក់កន្ទក់កន្ទេញ ។ បេ ។ បាត់ទៅ ។ ពួកទេវតាណា ដែលប្រាសចាករាគៈ ទេវតាទាំងនោះ មានសតិសម្បជញ្ញៈ អត់សង្កត់ដោយគិតថា សង្ខារទាំងឡាយមិនទៀង ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ ក្នុង (ខន្ធប្បវត្តិ) នេះ អំពីណា ។ គ្រានោះ ព្រះអនុរុទ្ធមានអាយុ និងព្រះអានន្ទមានអាយុ ធ្វើធម្មីកថា អស់រាត្រី ដែលនៅសល់នោះ ។ ទើបព្រះអនុរុទ្ធមានអាយុ ពោលនឹងព្រះអានន្ទមានអាយុថា ម្នាលអាវុសោអានន្ទ អ្នកចូរចូលទៅកាន់ក្រុងកុសិនារា ហើយថ្វាយដំណឹងដល់ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារាថា បពិត្រវាសិដ្ឋគោត្រទាំងឡាយ ព្រះមានព្រះភាគ បរិនិព្វានហើយ ឥឡូវអ្នកទាំងឡាយ ចូរសម្គាល់នូវកាលគួរចុះ ។ ព្រះអានន្ទមានអាយុ ទទួលវាចានៃព្រះអនុរុទ្ធមានអាយុថា អើលោកម្ចាស់ ហើយក៏ស្លៀកស្បង់កាន់យកបាត្រនិងចីវរក្នុងបុព្វណ្ហសម័យ មិនមានភិក្ខុជាគម្រប់ពីរឡើយ ចូលទៅកាន់ក្រុងកុសិនារា ។

[១៩២] តេន ខោ បន សមយេន កោសិ-
នារកា មល្លា សណ្ឋាគារេ សន្និបតិតា ហោន្តិ
តេន[១] ករណីយេន ។ អថខោ អាយស្មា អា-
នន្ទោ យេន កោសិនារកានំ មល្លានំ សណ្ឋាគារំ
តេនុបសង្កមិ ឧបសង្កមិត្វា កោសិនារកានំ មល្លានំ
អារោចេសិ បរិនិព្វុតោ វាសិដ្ឋា ភគវា យស្សទានិ
កាលំ មញ្ញថាតិ ។ ឥទមាយស្មតោ អានន្ទស្ស
សុត្វា មល្លា ច មល្លបុត្តា ច មល្លសុណិសា
ច មល្លបជាបតិយោ ច អឃាវិនោ ទុម្មនា ចេ-
តោទុក្ខសមប្បិតា អប្បេកច្ចេ កេសេ បកិរិយ
កន្ទន្តិ ពាហា បគ្គយ្ហ កន្ទន្តិ ឆិន្នបាតំ វិយ បប-
តន្តិ អាវដ្ដន្តិ វិវដ្ដន្តិ អតិខិប្បំ ភគវា បរិនិព្វុតោ
អតិខិប្បំ សុគតោ បរិនិព្វុតោ អតិខិប្បំ ចក្ខុមា
លោកេ អន្តរហិតោតិ ។ អថខោ កោសិនារកា
មល្លា បុរិសេ អាណាបេសុំ តេនហិ ភណេ

១ ឱ. ម. តេនេវ ។

[១៥២] ក្នុងសម័យនោះឯង ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា កំពុងប្រជុំគ្នា ក្នុងសណ្ឋាគារដ្ឋាន ដោយកិច្ចនីមួយ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅកាន់សណ្ឋាគារដ្ឋាន របស់ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារានោះ លុះចូលទៅដល់ហើយ ថ្វាយដំណឹងដល់ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារាថា បពិត្រវាសិដ្ឋទាំងឡាយ ព្រះមានព្រះភាគបរិនិព្វានហើយ ឥឡូវនេះ សូមទ្រង់ទាំងឡាយ សម្គាល់នូវកាលគួរចុះ ។ ពួកមល្ល-ក្សត្រិយ៍ ពួកបុត្ររបស់មល្លក្សត្រិយ៍ ព្រះសុណិសារបស់មល្លក្សត្រិយ៍ និងភរិយា របស់មល្លក្សត្រិយ៍ ឮពាក្យនេះ របស់ព្រះអានន្ទមានអាយុហើយ ក៏កើតទុក្ខតូចព្រះទ័យ ឆ្អែតដោយសេចក្តីទុក្ខក្នុងចិត្ត ខ្លះរំសាយសក់កន្ទក់កន្ទេញ ផ្គងកំភួនដៃកន្ទក់កន្ទេញ ផ្តួលខ្លួនចុះបម្រះននៀលទៅមកបីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសុគត ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក បាត់បង់ទៅឆាប់ពេកណាស់ ។ គ្រានោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា បង្គាប់ពួករាជបុរសថា ម្នាលនាយ បើដូច្នោះ ចូរអ្នកទាំងឡាយ

កុសិនារាយំ គន្ធមាលញ្ច សព្វញ្ច តាឡាវចរំ សន្និបាតេថាតិ ។ អថខោ កោសិនារកា មល្លា គន្ធមាលញ្ច សព្វញ្ច តាឡាវចរំ បញ្ច ទុស្សយុគសតានិ អាទាយ យេន ឧបវត្តនំ មល្លានំ សាលវនំ យេន ភគវតោ សរីរំ តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតោ សរីរំ នច្ចេហិ គីតេហិ វាទិតេហិ មាលេហិ គន្ធេហិ សក្ករោន្តា គរុករោន្តា មានេន្តា បូជេន្តា ចេលវិតានានិ ករោន្តា មណ្ឌលមាឡានិ[១] បដិយាទេន្តា ឯវំ តំ ទិវសំ[២] វីតិនាមេសុំ ។ អថខោ កោសិនារកានំ មល្លានំ ឯតទហោសិ អតិវិកាលោ ខោ អជ្ជ ភគវតោ សរីរំ ឈាបេតុំ ស្វេទានិ មយំ ភគវតោ សរីរំ ឈាបេស្សាមាតិ ។ អថខោ កោសិនារកា មល្លា ភគវតោ សរីរំ នច្ចេហិ គីតេហិ វាទិតេហិ មាលេហិ គន្ធេហិ សក្ករោន្តា គរុករោន្តា មានេន្តា បូជេន្តា ចេលវិតានានិ ករោន្តា មណ្ឌលមាឡានិ បដិយាទេន្តា ទុតិយម្បិ ទិវសំ វីតិនាមេសុំ

១ ម. មណ្ឌលមាលេ ។ ២ ឯកទិវសំ ។

ប្រមូលគ្រឿងក្រអូប និងកម្រងផ្កា និងគ្រឿងតូរ្យតន្ត្រីទាំងអស់ ដែលមានក្នុងក្រុងកុសិនារា ។ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា នាំយកគ្រឿងក្រអូបនិងកម្រងផ្កា និងគ្រឿងតូរ្យតន្ត្រីនិងសំពត់ ៥០០ គូ ចូលទៅគាល់ព្រះសរីរៈ នៃព្រះមានព្រះភាគ ក្នុងសាលវ័ន របស់ពួកមល្លក្សត្រិយ៍ ដែលជាទីចូលទៅក្នុងក្រុង លុះចូលទៅដល់ហើយ ក៏ធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈ នៃព្រះមានព្រះភាគដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ហើយធ្វើពិតានសំពត់ តាក់តែងរោងបារាំយ៉ាងនេះ ពេញអស់ ១ ថ្ងៃនោះ ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា មានសេចក្តីត្រិះរិះដូច្នេះថា កាលនេះជ្រុលវេលាហើយ នឹងថ្វាយព្រះភ្លើងព្រះសរីរៈ នៃព្រះមានព្រះភាគ ក្នុងថ្ងៃនេះ មិនទាន់ទេ ចាំថ្ងៃស្អែក សឹមយើងនឹងថ្វាយព្រះភ្លើងព្រះសរីរៈ នៃព្រះមានព្រះភាគ ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា នាំគ្នាធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈ នៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ហើយធ្វើពិតានសំពត់ តាក់-តែងរោងបារាំទាំងឡាយ ហើយញុំាងថ្ងៃជាគម្រប់ ២ ឲ្យកន្លងទៅទៀត

តតិយម្បិ ទិវសំ វីតិនាមេសុំ ចតុត្ថម្បិ ទិវសំ វីតិនា-
មេសុំ បញ្ចមម្បិ ទិវសំ វីតិនាមេសុំ ឆដ្ឋម្បិ ទិវសំ
វីតិនាមេសុំ ។ អថខោ សត្តមម្បិ ទិវសំ កោសិនា-
រកានំ មល្លានំ ឯតទហោសិ មយំ ភគវតោ សរីរំ
នច្ចេហិ គីតេហិ វាទិតេហិ មាលេហិ គន្ធេហិ សក្ក-
រោន្តា គរុករោន្តា មានេន្តា បូជេន្តា ទក្ខិណេន ទក្ខិ-
ណំ នគរស្ស ហរិត្វា ពាហិរេន ពាហិរំ ទក្ខិណតោ
នគរស្ស ភគវតោ សរីរំ ឈាបេស្សាមាតិ ។

[១៨៣] តេន ខោ បន សមយេន អដ្ឋ មល្លា
បាមោក្ខា សីសន្ហាតា អហតានិ វត្ថានិ និវត្ថា មយំ
ភគវតោ សរីរំ ឧច្ចារេស្សាមាតិ ន សក្កោន្តិ ឧច្ចារេតុំ ។
អថខោ កោសិនារកា មល្លា អាយស្មន្តំ អនុរុទ្ធំ ឯត-
ទវោចុំ កោ នុ ខោ ភន្តេ អនុរុទ្ធ ហេតុ កោ បច្ចយោ
យេនិមេ អដ្ឋ មល្លា បាមោក្ខា សីសន្ហាតា អហ-
តានិ វត្ថានិ និវត្ថា មយំ ភគវតោ សរីរំ ឧច្ចារេស្សាមាតិ
ន សក្កោន្តិ ឧច្ចារេតុន្តិ ។ អញ្ញថា ខោ វាសិដ្ឋា តុម្ហាកំ
អធិប្បាយោ អញ្ញថា ទេវតានំ អធិប្បាយោតិ ។ កថំ

ញុំាងថ្ងៃជាគម្រប់ ៣ ឲ្យកន្លងទៅទៀត ញុំាងថ្ងៃជាគម្រប់ ៤ ឲ្យកន្លងទៅទៀត ញុំាងថ្ងៃជាគម្រប់ ៥ ឲ្យកន្លងទៅទៀត ញុំាងថ្ងៃជាគម្រប់ ៦ ឲ្យកន្លងទៅទៀត លុះថ្ងៃជាគម្រប់ ៧ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងរាល់គ្នានឹងធ្វើសក្ការៈគោរព រាប់អានបូជាព្រះសរីរៈនៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ ហើយហែទៅតាមទិសខាងត្បូងក្រៅក្រុង ហើយថ្វាយព្រះភ្លើងព្រះសរីរៈ នៃព្រះមានព្រះភាគ អំពីខាងត្បូងនៃក្រុង ។

[១៥៣] ក្នុងសម័យនោះឯង មល្លក្សត្រិយ៍ ៨ អង្គ ដែលជាប្រធានជម្រះសីសៈហើយ ទ្រង់សំពត់ថ្មី គិតគ្នាថា យើងនឹងលើកព្រះសរីរៈ នៃព្រះមានព្រះភាគដូច្នេះ តែមិនអាចនឹងលើករួចបាន ។ ទើបពួកមល្លក្សត្រិយ៍អ្នកក្រុងកុសិនារា ពោលនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេច បានជាមល្លក្សត្រិយ៍ជាប្រធានទាំង ៨ អង្គនេះ ជម្រះសីសៈហើយ ទ្រង់សំពត់ថ្មី គិតគ្នាថា យើងនឹងលើកព្រះសរីរៈ នៃព្រះមានព្រះភាគដូច្នេះ តែមិនអាចនឹងលើករួចបាន ។ ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋៈទាំងឡាយ បំណងរបស់ទ្រង់ទាំងឡាយផ្សេង បំណងរបស់ពួកទេវតាផ្សេង ។ ពួកមល្លក្សត្រិយ៍

បន ភន្តេ ទេវតានំ អធិប្បាយោតិ ។ តុម្ហាកំ ខោ វាសិដ្ឋា អធិប្បាយោ ឥមំ ភគវតោ សរីរំ នច្ចេហិ គីតេហិ វាទិតេហិ មាលេហិ គន្ធេហិ សក្ករោន្តា គរុករោន្តា មានេន្តា បូជេន្តា ទក្ខិណេន ទក្ខិណំ នគរស្ស ហរិត្វា ពាហិរេន ពាហិរំ ទក្ខិណតោ នគរស្ស ភគវតោ សរីរំ ឈាបេស្សាមាតិ ទេវតានំ ខោ វាសិដ្ឋា អធិប្បាយោ ឥមំ ភគវតោ សរីរំ ទិព្វេហិ នច្ចេហិ គីតេហិ វាទិតេហិ មាលេហិ គន្ធេហិ សក្ករោន្តា គរុករោន្តា មានេន្តា បូជេន្តា ឧត្តរេន ឧត្តរំ នគរស្ស ហរិត្វា ឧត្តរេន ទ្វារេន នគរំ បវិសិត្វា[១] មជ្ឈេន មជ្ឈំ នគរស្ស ហរិត្វា បុរត្ថិមេន ទ្វារេន និក្ខមិត្វា បុរត្ថិមតោ នគរស្ស មកុដពន្ធនំ នាម មល្លានំ ចេតិយំ ឯត្ថ ភគវតោ សរីរំ ឈាបេស្សាមាតិ ។ យថា ភន្តេ ទេវតានំ អធិប្បាយោ តថា ហោតូតិ ។

---

១ ឱ. ម. បវេសេត្វា ។

សួរទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះបំណងរបស់ពួកទេវតា តើដូចម្តេច ។ ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋៈទាំងឡាយ បំណងរបស់ទ្រង់ទាំងឡាយថា យើងរាល់គ្នានឹងធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈ នៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ ហើយហែទៅតាមទិសខាងត្បូងក្រៅក្រុង ហើយថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ អំពីខាងត្បូងនៃក្រុង បពិត្រវាសិដ្ឋៈទាំងឡាយ ឯបំណងរបស់ពួកទេវតាថា យើងរាល់គ្នានឹងធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈ នៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ ដែលជាទិព្វ ហើយហែទៅខាងជើងតាមទិសខាងជើងនៃក្រុង ហើយចូលទៅកាន់ក្រុងតាមទ្វារខាងជើង ហើយហែទៅត្រង់កណ្តាលតាមទីកណ្តាលនៃក្រុង ហើយចេញទៅតាមទ្វារខាងកើត ហើយថ្វាយព្រះភ្លើងព្រះសរីរៈ នៃព្រះមានព្រះភាគ ក្នុងមកុដពន្ធនចេតិយ[១] របស់មល្លក្សត្រិយ៍ ខាងកើតនៃក្រុង ។ ពួកមល្លក្សត្រិយ៍ ទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន បំណងរបស់ពួកទេវតាយ៉ាងណា ការថ្វាយព្រះភ្លើងព្រះសរីរៈ នៃព្រះមានព្រះភាគ ក៏សូមឲ្យសម្រេចយ៉ាងនោះចុះ ។

---

១ អដ្ឋកថាថា សាលាជាមង្គល សម្រាប់តែងព្រះអង្គរបស់ពួកមល្លរាជហៅថា មកុដពន្ធនៈ ហៅថា ចេតិយ ព្រោះគេធ្វើវិចិត្ររចនាក្បូរក្បាច់វិសេសណាស់ ។

តេន ខោ បន សមយេន កោសិនារា យាវ សន្ធិ-
សមលសង្កដិរា[១] ជណ្ណុមត្តេន ឱធិនា មន្ទារវបុប្ផេហិ
សណ្ឋិតា[២] ហោតិ ។ អថខោ ទេវា ច កោសិនា-
រកា ច មល្លា ភគវតោ សរីរំ ទិព្វេហិ ច មានុស-
កេហិ[៣] នច្ចេហិ គីតេហិ វាទិតេហិ មាលេហិ
គន្ធេហិ សក្ករោន្តា គរុករោន្តា មានេន្តា បូជេន្តា
ឧត្តរេន ឧត្តរំ នគរស្ស ហរិត្វា ឧត្តរេន ទ្វារេន នគរំ
បវិសិត្វា មជ្ឈេន មជ្ឈំ នគរស្ស ហរិត្វា បុរត្ថិមេន
ទ្វារេន និក្ខមិត្វា បុរត្ថិមតោ នគរស្ស មកុដ-
ពន្ធនំ នាម មល្លានំ ចេតិយំ ឯត្ថ ភគវតោ
សរីរំ និក្ខិបឹសុ ។ អថខោ កោសិនារកា មល្លា
អាយស្មន្តំ អានន្ទំ ឯតទវោចុំ កថំ មយំ ភន្តេ
អានន្ទ តថាគតស្ស សរីរេ បដិបជ្ជាមាតិ ។ យថា
ខោ វាសិដ្ឋា រញ្ញោ ចក្កវត្តិស្ស សរីរេ បដិបជ្ជន្តិ
ឯវំ តថាគតស្ស សរីរេ បដិបជ្ជិតព្វន្តិ ។ កថំ
បន ភន្តេ អានន្ទ រញ្ញោ ចក្កវត្តិស្ស សរីរេ បដិបជ្ជន្តីតិ ។

១ ឱ. សន្ធិសមលសំកដីរា ។ ២ ឱ. ម. សណ្ឋតា ។ ៣ ឱ. ម. មានុសកេហិ ច ។

សម័យនោះឯង ក្រុងកុសិនារា ពាសពេញដោយផ្កាមន្ទារវៈ ដោយគំនរប្រមាណត្រឹមជង្គង់ រហូតដល់ទីជាចន្លោះនៃផ្ទះ និង-ទសម្រាប់បង្ហូរទូវគូថ និងកន្លែងសម្រាប់ចោលនូវសំរាម ។ គ្រានោះ ពួកទេវតានិងពួកមល្ល-ក្សត្រិយ៍ អ្នកក្រុងកុសិនារា នាំគ្នាធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈនៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ ជារបស់ទិព្វខ្លះ របស់មនុស្សខ្លះ ហើយហែទៅខាងជើងតាមទិសខាងជើងនៃក្រុង ហើយចូលទៅកាន់ក្រុង តាមទ្វារខាងជើង ហើយហែទៅត្រង់កណ្តាល តាមទីកណ្តាលនៃក្រុង ហើយចេញទៅតាមទ្វារខាងកើត ហើយថ្វាយព្រះភ្លើងព្រះសរីរៈ នៃព្រះមានព្រះភាគ ក្នុងមកុដពន្ធនចេតិយ របស់ពួកមល្លក្សត្រិយ៍ ខាងកើតនៃក្រុង ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា ពោលនឹងព្រះអានន្ទមានអាយុ ដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងទាំងឡាយ នឹងប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះតថាគតដូចម្តេច ។ ព្រះអានន្ទតបថា បពិត្រវាសិដ្ឋៈទាំងឡាយ ពួកឥស្សរជន ប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រពត្តិរាជយ៉ាងណា ពួកមហាបពិត្រគប្បីប្រតិបត្តិ ក្នុងព្រះសរីរៈនៃព្រះតថាគតយ៉ាងនោះចុះ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈ នៃព្រះចក្រពត្តិរាជដូចម្តេច ។

រញ្ញោ វាសិដ្ឋា ចក្កវត្តិស្ស សរីរំ អហតេន វត្ថេន វេឋេន្តិ អហតេន វត្ថេន វេឋេត្វា វិហតេន កប្បាសេន វេឋេន្តិ វិហតេន កប្បាសេន វេឋេត្វា អហតេន វត្ថេន វេឋេន្តិ ឯតេន ឧបាយេន បញ្ចហិ យុគសតេហិ រញ្ញោ ចក្កវត្តិស្ស សរីរំ វេឋេត្វា អយសាយ តេលទោណិយា បក្ខិបិត្វា អញ្ញិស្សា អយសាយ ទោណិយា បដិក្កុជ្ជិត្វា សព្វគន្ធានំ ចិតកំ ករិត្វា រញ្ញោ ចក្កវត្តិស្ស សរីរំ ឈាបេន្តិ ចាតុម្មហាបថេ រញ្ញោ ចក្កវត្តិស្ស ថូបំ ករោន្តិ ឯវំ ខោ វាសិដ្ឋា រញ្ញោ ចក្កវត្តិស្ស សរីរេ បដិបជ្ជន្តិ យថា ខោ វាសិដ្ឋា រញ្ញោ ចក្កវត្តិស្ស សរីរេ បដិបជ្ជន្តិ ឯវំ តថាគតស្ស សរីរេ បដិបជ្ជិតព្វំ ចាតុម្មហាបថេ តថាគតស្ស ថូបោ ការេតព្វោ[១] តត្ថ យេ មាលំ វា គន្ធំ វា ចុណ្ណកំ វា អារោបេស្សន្តិ វា អភិវាទេស្សន្តិ វា ចិត្តំ វា បសាទេស្សន្តិ តេសន្តំ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ អថខោ

១ ឱ. ម. កាតព្វោ ។

បពិត្រវាសិដ្ឋៈទាំងឡាយ ពួកឥស្សរជន រុំសរីរៈនៃព្រះចក្រពត្តិរាជ ដោយសំពត់ថ្មី លុះរុំដោយសំពត់ថ្មីរួចហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡីហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) រុំសរីរៈនៃព្រះចក្រពត្តិរាជដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយតម្កល់ក្នុងព្រះមឈូសមាសដែលដាក់ប្រេង ហើយគ្របដោយមឈូសមាសដទៃ ហើយធ្វើជើងថ្ករ ទើបថ្វាយព្រះភ្លើងនូវសរីរៈ នៃព្រះចក្រពត្តិរាជ ដោយគ្រឿងក្រអូបគ្រប់យ៉ាង ហើយគេធ្វើព្រះស្តូបនៃព្រះចក្រពត្តិរាជក្នុងផ្លូវធំ បែកជា ៤ បពិត្រវាសិដ្ឋៈទាំងឡាយ ពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រពត្តិរាជ យ៉ាងនេះឯង បពិត្រវាសិដ្ឋៈទាំងឡាយ ពួកឥស្សរជន ប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រពត្តិរាជ យ៉ាងណាមិញ ពួកមហាបពិត្រគប្បីប្រតិបត្តិ ក្នុងព្រះសរីរៈនៃព្រះតថាគត គប្បីធ្វើព្រះស្តូបរបស់ព្រះតថាគត ក្នុងផ្លូវបែកជា ៤ យ៉ាងនោះចុះ ពួកជនណានឹងលើកឡើងនូវផ្កាកម្រងក្តី គ្រឿងក្រអូបក្តី គ្រឿងលម្អិតក្តី ឬនឹងថ្វាយបង្គំ ឬធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះស្តូបនោះ អំពើនោះនឹងនាំមកនូវប្រយោជន៍និងសេចក្តីសុខដល់ជនទាំងនោះ អស់កាលយូរអង្វែង ។ គ្រានោះ

កោសិការកា មល្លា បុរិសេ អាណាបេសុំ តេនហិ ភណេ មល្លានំ វិហតកប្បាសំ[១] សន្និចាតេថាតិ ។ អថខោ កោសិការកា មល្លា ភគវតោ សរីរំ អហតេន វត្ថេន វេឋេសុំ អហតេន វត្ថេន វេឋេត្វា វិហតេន កប្បាសេន វេឋេសុំ វិហតេន កប្បាសេន វេឋេត្វា អហតេន វត្ថេន វេឋេសុំ ឯតេន ឧបាយេន បញ្ចហិ យុគសតេហិ ភគវតោ សរីរំ វេឋេត្វា អយសាយ តេលទោណិយា បក្ខិបិត្វា អញ្ញិស្សា អយសាយ ទោណិយា បដិក្កុជ្ជិត្វា សព្វគន្ធានំ ចិតកំ ករិត្វា ភគវតោ សរីរំ ចិតកំ អារោបេសុំ ។

[១៩៤] តេន ខោ បន សមយេន អាយស្មា មហាកស្សបោ បាវាយ កុសិនារំ អទ្ធានមគ្គប្បដិបន្នោ ហោតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ អថខោ អាយស្មា មហាកស្សបោ

១ ឱ. ម. វិហតំ កប្បាសំ ។

ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា បង្គាប់រាជបុរសថា ម្នាលនាយ បើដូច្នោះ ចូរអ្នកទាំងឡាយ ប្រមូលសំឡីរបស់ពួកមល្លជនមក ។ លំដាប់នោះ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា នាំគ្នារុំព្រះសរីរៈនៃព្រះមានព្រះភាគ ដោយសំពត់ថ្មី លុះរុំដោយសំពត់ថ្មីរួចហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡីហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) រុំព្រះសរីរៈនៃព្រះមានព្រះភាគ ដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយតម្កល់ក្នុងព្រះមឈូសមាស ដែលដាក់ប្រេង ហើយគ្របដោយមឈូសមាសដទៃ ហើយធ្វើជើងថ្ករ ទើបថ្វាយព្រះភ្លើង នូវព្រះសរីរៈនៃព្រះមានព្រះភាគ ដោយគ្រឿងក្រអូបគ្រប់យ៉ាង ។

[១៥៤] សម័យនោះឯង ព្រះមហាកស្សបៈមានអាយុ និមន្តតាមផ្លូវឆ្ងាយ មកអំពីក្រុងបាវា ទៅកាន់ក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឃជាច្រើន ប្រមាណ ៥០០ រូប ។ លំដាប់នោះ ព្រះមហាកស្សបៈមានអាយុ

មគ្គា ឱក្កម្ម អញ្ញតរស្មិំ[១] រុក្ខមូលេ និសីទិ ។ តេន ខោ បន សមយេន អញ្ញតរោ អាជីវកោ កុសិនារាយំ មន្ទារវបុប្ផំ គហេត្វា ចារំ អទ្ធានមគ្គប្បដិបន្នោ ហោតិ ។ អទ្ទសា ខោ អាយស្មា មហាកស្សបោ តំ[២] អាជីវកំ ទូរតោ វ អាគច្ឆន្តំ ទិស្វា តំ អាជីវកំ ឯតទវោច អបាវុសោ[៣] អម្ហាកំ សត្ថារំ ជានាសីតិ ។ អាមាវុសោ ជានាមិ អជ្ជ សត្តាហំ បរិនិព្វុតោ សមណោ គោតមោ តតោ មេ ឥទំ មន្ទារវបុប្ផំ គហិតន្តិ ។ តត្ថ យេ តេ ភិក្ខូ អវីតរាគា អប្បេកច្ចេ ពាហា បគ្គយ្ហ កន្ទន្តិ ឆិន្នបាតំ វិយ បបតន្តិ អាវដ្ដន្តិ វិវដ្ដន្តិ អតិខិប្បំ ភគវា បរិនិព្វុតោ អតិខិប្បំ សុគតោ បរិនិព្វុតោ អតិខិប្បំ ចក្ខុមា លោកេ អន្តរហិតោតិ ។ យេ បន តេ ភិក្ខូ វីតរាគា តេ សតា សម្បជានា អធិវាសេន្តិ អនិច្ចា សង្ខារា តំ កុតេត្ថ លព្ភាតិ ។

---

១ ឱ. ម. អញ្ញតរស្មឹ ។ ២ ឱ. តន្តិ បទំ នត្ថិ ។ ៣ ម. អាវុសោ ។

ចៀសអំពីផ្លូវ ទៅគង់ក្រោមម្លប់ឈើ ១ ។ ក៏សម័យនោះឯង មានអាជីវកម្នាក់ កាន់ផ្កាមន្ទារវៈអំពីក្រុងកុសិនារា ដើរតាមផ្លូវឆ្ងាយ ទៅកាន់ក្រុងបាវា ។ ព្រះមហាកស្សបៈមានអាយុ បានឃើញអាជីវកនោះ ដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលទៅនឹងអាជីវកនោះ ដូច្នេះថា ម្នាលអាវុសោ អ្នកបានដឹងដំណឹង ព្រះសាស្តារបស់យើងខ្លះដែរ ។ អាជីវកតបថា អើអាវុសោ ខ្ញុំដឹងដែរ ព្រះសមណគោតម បរិនិព្វានទៅ ៧ ថ្ងៃគម្រប់នឹងថ្ងៃនេះហើយ ផ្កាមន្ទារវៈនេះ ខ្ញុំយកមកអំពីទីបរិនិព្វាន របស់ព្រះសមណគោតមនោះ ។ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណា ដែលមិនទាន់ប្រាសចាករាគៈ ពួកភិក្ខុទាំងនោះ ខ្លះក៏ផ្គងកំភួនដៃ កន្ទក់កន្ទេញដួលបម្រះននៀលទៅមក បីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសុគត ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់បាត់ទៅឆាប់ពេកណាស់ ។ ឯពួកភិក្ខុណា ដែលប្រាសចាករាគៈហើយ ពួកភិក្ខុនោះ ក៏មានសតិសម្បជញ្ញៈ អត់សង្កត់ថា សង្ខារទាំងឡាយមិនទៀង ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ ក្នុងខន្ធប្បវត្តិនេះ មកអំពីណា ។

[១៨៨] តេន ខោ បន សមយេន សុភទ្ទោ នាម វុឌ្ឍបព្វជិតោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ អថខោ សុភទ្ទោ វុឌ្ឍបព្វជិតោ តេ ភិក្ខូ ឯតទវោច អលំ អាវុសោ មា សោចិត្ថ មា បរិទេវិត្ថ សុមុត្តា មយំ តេន មហាសមណេន ឧបទ្ទុតា ច ហោម ឥទំ តេ[១] កប្បតិ ឥទំ តេ[២] ន កប្បតីតិ ឥទានិ បន មយំ យំ ឥច្ឆិស្សាម តំ ករិស្សាម យំ ន ឥច្ឆិស្សាម តំ ន ករិស្សាមាតិ ។ អថខោ មហាកស្សបោ[៣] ភិក្ខូ អាមន្តេសិ អលំ អាវុសោ មា សោចិត្ថ មា បរិទេវិត្ថ ននុ ឯវំ[៤] អាវុសោ ភគវតា បដិកច្ចេវ អក្ខាតំ សព្វេហេវ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ តំ កុតេត្ថ អាវុសោ លព្ភា យន្តំ ជាតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតីតិ ។

១-២ វោតិបិ ទិស្សតិ ។ ៣ ឱ. ម. អាយស្មា មហាកស្សបោ ។ ៤ ឱ. ម. ឯតំ ។

[១៩៥] សម័យនោះឯង ភិក្ខុបួសចាស់ឈ្មោះសុភទ្ទ អង្គុយក្នុងកណ្តាលបរិស័ទនោះ ។ លំដាប់នោះ ភិក្ខុបួសចាស់ឈ្មោះសុភទ្ទ ពោលទៅនឹងពួកភិក្ខុទាំងនោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នកទាំងឡាយ កុំសោកសៅ កុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ ព្រោះថា ពួកយើង មហាសមណៈនោះ តែងបៀតបៀនថា អំពើនេះ គួរដល់អ្នក អំពើនេះ មិនគួរដល់អ្នក ក៏ឥឡូវនេះ ពួកយើងនឹងប្រាថ្នាធ្វើនូវអំពើណា នឹងធ្វើអំពើនោះបាន មិនប្រាថ្នាធ្វើនូវអំពើណា នឹងមិនធ្វើអំពើនោះបាន ។ គ្រានោះ ព្រះមហាកស្សបៈ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នកពល់គ្នា កុំសោកសៅ កុំខ្សឹកខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ ពាក្យនេះ ព្រះមានព្រះភាគបានសម្តែងជាមុនហើយថា សេចក្តីព្រាត់ប្រាសវិនាសប្រែប្រួលចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីមិនព្រាត់ប្រាសនោះ ក្នុងខន្ធប្បវត្តិនេះ មកអំពីណា ធម្មជាតណា ដែលកើតហើយ មានហើយ ដែលបច្ច័យតាក់តែងហើយ សឹងមានសេចក្តីទ្រុឌទ្រោមទៅជាធម្មតា ធម្មជាតនោះ បុគ្គលនឹងពោលឃាត់ថា កុំទ្រុឌទ្រោមដូច្នេះ (ដោយហេតុណា) ហេតុនេះ មិនមានឡើយ ។

[១៩៦] តេន ខោ បន សមយេន ចត្តារោ មល្លបាមោក្ខា សីសន្ហាតា អហតានិ វត្ថានិ និវត្ថា មយំ ភគវតោ ចិតកំ អាឡិម្បេស្សាមាតិ ន សក្កោន្តិ អាឡិម្បេតុំ ។ អថខោ កោសិនារកា មល្លា អាយស្មន្តំ អនុរុទ្ធំ ឯតទវោចុំ កោ នុ ខោ ភន្តេ អនុរុទ្ធ ហេតុ កោ បច្ចយោ យេនិមេ ចត្តារោ មល្លបាមោក្ខា សីសន្ហាតា អហតានិ វត្ថានិ និវត្ថា មយំ ភគវតោ ចិតកំ អាឡិម្បេស្សាមាតិ ន សក្កោន្តិ អាឡិម្បេតុន្តិ ។ អញ្ញថា ខោ វាសិដ្ឋា ទេវតានំ អធិប្បាយោតិ ។ កថំ បន ភន្តេ ទេវតានំ អធិប្បាយោតិ ។ ទេវតានំ ខោ វាសិដ្ឋា អធិប្បាយោ អយំ អាយស្មា មហាកស្សបោ បាវាយ កុសិនារំ អទ្ធានមគ្គប្បដិបន្នោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ន តាវ ភគវតោ ចិតកោ បជ្ជលិស្សតិ យាវាយស្មា មហាកស្សបោ ភគវតោ បាទេ សិរសា វន្ទិស្សតីតិ ។ យថា ភន្តេ ទេវតានំ អធិប្បាយោ

[១៩៦] សម័យនោះឯង ពួកមល្លក្សត្រ ៤ អង្គ ដែលជាប្រធាន ទ្រង់ជម្រះសីសៈ ហើយទ្រង់សំពត់ថ្មីគិតគ្នាថា យើងនឹងឈួលនូវជើងថ្ករ នៃព្រះមានព្រះភាគ ដូច្នេះ តែមិនអាចនឹងឈួលឲ្យឆេះបាន ។ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា បានពោលទៅនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេច បានជាពួកមល្លក្សត្រិយ៍ ជាប្រធានទាំង ៤ អង្គនេះ ជម្រះសីសៈ ហើយទ្រង់សំពត់ថ្មីគិតគ្នាថា យើងនឹងឈួលជើងថ្ករ នៃព្រះមានព្រះភាគ ដូច្នេះ តែមិនអាចនឹងឈួលឲ្យឆេះបាន ។ ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋៈទាំងឡាយ បំណងរបស់ពួកទេវតាផ្សេងគ្នា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះបំណងរបស់ពួកទេវតាដូចម្តេច ។ បពិត្រវាសិដ្ឋៈទាំងឡាយ បំណងរបស់ពួកទេវតាថា ព្រះមហាកស្សបៈមានអាយុនេះ កំពុងនិមន្តតាមផ្លូវឆ្ងាយ ចេញអំពីក្រុងបាវា មកកាន់ក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឃជាច្រើន ប្រមាណ ៥០០ រូប ព្រះមហាកស្សបៈមានអាយុ មិនទាន់បានថ្វាយបង្គំនូវព្រះបាទា នៃព្រះមានព្រះភាគ ដោយដៃរបស់ខ្លួនដរាបណា ជើងថ្ករព្រះមានព្រះភាគ ក៏មិនទាន់ឆេះដរាបនោះ ។ ពួកមល្លក្សត្រិយ៍ តបថា បពិត្រលោកម្ចាស់ដ៏ចម្រើន បំណងរបស់ពួកទេវតា យ៉ាងណា

៣៤១



តថា ហោតូតិ ។ អថខោ អាយស្មា មហាកស្សបោ យេន កុសិនារាយំ[១] មកុដពន្ធនំ[២] មល្លានំ ចេតិយំ យេន ភគវតោ ចិតកោ តេនុបសង្កមិ ឧបសង្កមិត្វា ឯកំសំ ចីវរំ កត្វា អញ្ជលឹ បណាមេត្វា តិក្ខត្តុំ ចិតកំ បទក្ខិណំ កត្វា បាទតោ វិវរិត្វា ភគវតោ បាទេ សិរសា វន្ទិ ។ តានិបិ ខោ បញ្ច ភិក្ខុសតានិ ឯកំសំ ចីវរំ កត្វា អញ្ជលឹ បណាមេត្វា តិក្ខត្តុំ បទក្ខិណំ កត្វា ភគវតោ បាទេ សិរសា វន្ទឹសុ ។ វន្ទិតេ[៣] បនាយស្មតា មហាកស្សបេន តេហិ ច បញ្ចហិ ភិក្ខុសតេហិ

១ ឱ. ម. កុសិនារា ។ ២ ម. មកុដពន្ធនំ នាម ។ ៣ ឱ. ម. វន្ទិតេ ច ។

ការថ្វាយព្រះភ្លើងនូវព្រះសរីរៈ នៃព្រះមានព្រះភាគ ក៏សូមឲ្យសម្រេចយ៉ាង នោះចុះ ។ គ្រានោះ ព្រះមហាកស្សបៈមានអាយុ ចូលទៅកាន់ជើងថ្ករ នៃព្រះមានព្រះភាគ ក្នុងមកុដពន្ធនចេតិយ របស់ពួកមល្លក្សត្រ ទៀបក្រុង កុសិនារានោះ លុះចូលទៅដល់ហើយ ក៏ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យ អញ្ជលី ធ្វើប្រទក្សិណជើងថ្ករ ៣ ជុំហើយ បើកអំពីខាងព្រះបាទ[១] ថ្វាយ បង្គំព្រះបាទា នៃព្រះមានព្រះភាគ ដោយសិរ្សៈ ។ ឯពួកភិក្ខុទាំង ៥០០ រូបនោះ ក៏ធ្វើចីវរឆៀងស្មាម្ខាងហើយ ប្រណម្យអញ្ជលី ធ្វើប្រទក្សិណ ៣ ជុំហើយ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្សៈ ។ កាល ដែលព្រះមហាកស្សបៈមានអាយុ និងពួកភិក្ខុទាំង ៥០០ រូបនោះ ថ្វាយបង្គំ

---

១ អដ្ឋកថាថា ព្រះមហាកស្សបៈចូលចតុត្ថជ្ឈាន ចេញចាកចតុត្ថជ្ឈានហើយអធិដ្ឋានថា សូមឲ្យព្រះបាទទាំងគូ ទម្លាយសំពត់ទាំង ៥០០ គូ ព្រមទាំងសំឡីនិងព្រះមឈូសមាស និងជើងថ្ករធ្វើដោយខ្លឹមចន្ទន៍ហើយលៀនចេញមកប្រតិស្ឋានលើក្បាលរបស់ខ្ញុំ ។ គ្រានោះ ព្រះបាទទាំងគូក៏ទម្លាយសំពត់ទាំង ៥០០ គូជាដើម លៀនចេញមក ដំណាលគ្នានឹងការអធិដ្ឋានចិត្តរបស់ព្រះមហាកស្សបៈ ប្រៀបដូចព្រះចន្ទពេញវង់ ចេញមកអំពីចន្លោះពពក ។ ព្រះមហាកស្សបៈក៏លាដៃឡើង ចាប់ព្រះបាទាលើកដាក់លើសិរ្សៈរបស់លោក ។

សយមេវ ភគវតោ ចិតកោ បជ្ជលិ ។ ឈាយមានស្ស ខោ[១] បន ភគវតោ សរីរស្ស យំ អហោសិ ឆវីតិ វា ចម្មន្តិ វា មំសន្តិ វា ន្ហារូតិ វា លសិកាតិ វា តស្ស នេវ ឆារិកា បញ្ញាយិត្ថ ន មសិ សរីរានេវ អវសិស្សឹសុ ។ សេយ្យថាបិ នាម សប្បិស្ស វា តេលស្ស វា ឈាយ-មានស្ស នេវ ឆារិកា បញ្ញាយតិ ន មសិ ឯវមេវ ភគវតោ សរីរស្ស ឈាយមានស្ស យំ អហោសិ ឆវីតិ វា ចម្មន្តិ វា មំសន្តិ វា ន្ហារូតិ វា លសិកាតិ វា តស្ស នេវ ឆារិកា បញ្ញាយិត្ថ ន មសិ សរីរានេវ អវសិស្សឹសុ ។ តេសញ្ច បញ្ចន្នំ ទុស្សយុគសតានំ ទ្វេវ ទុស្សានិ ឌយ្ហឹសុ យញ្ច សព្វអព្ភន្តរិមំ យញ្ច ពាហិរំ ។ ឌឌ្ឍេ ខោ បន ភគវតោ សរីរេ អន្តលិក្ខា ឧទកធារា ចាតុ-ភវិត្វា ភគវតោ ចិតកំ និព្វាបេសិ ។ ឧទកំ សាល-តោបិ អព្ភុន្នមិត្វា ភគវតោ ចិតកំ និព្វាបេសិ ។ កោសិនារកា[២] មល្លា សព្វគន្ធោទកេន ភគវតោ ចិតកំ និព្វាបេសុំ ។ អថខោ កោសិនារកា មល្លា

១ ឱ. ខោសទ្ទោ នត្ថិ ។ ២ ឱ. ម. កោសិនារកាបិ ។

ព្រះបាទា នៃព្រះមានព្រះភាគរួចហើយ ជើងថ្ករព្រះមានព្រះភាគ ក៏ឆេះឯង[១] ។ ព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែលភ្លើងឆេះហើយ អាការៈណា ទោះព្រះឆវិក្តី ព្រះចម្មៈក្តី ព្រះមំសៈក្តី ព្រះន្ហារូក្តី ព្រះលសិកាក្តី អាការៈនោះ ក៏ឆេះអស់ មិនមានផេះ និងកំញ៉មធ្យូងឡើយ សល់នៅតែព្រះសរីរធាតុសុទ្ធ[២] ។ សប្បិ ឬប្រេង ដែលភ្លើងឆេះ ក៏មិនមានផេះកំញមយ៉ាងណាមិញ ព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែលភ្លើងឆេះហើយ អាការៈណា ទោះព្រះឆវិក្តី ព្រះចម្មៈក្តី ព្រះមំសៈក្តី ព្រះន្ហារូក្តី ព្រះលសិកាក្តី អាការៈនោះ ក៏ឆេះអស់ មិនមានផេះនិងកំញ៉មឡើយ សល់នៅតែព្រះសរីរធាតុសុទ្ធ ក៏យ៉ាងនោះដែរ ។ បណ្តាសំពត់ទាំង ៥០០ គូនោះ សំពត់ពីរ គឺសំពត់ជាន់ក្នុងបំផុត ១ សំពត់ជាន់ក្រៅបំផុត ១ ក៏ឆេះអស់ ។ លុះសរីរៈព្រះមានព្រះភាគ ដែលត្រូវភ្លើងឆេះហើយ ធារទឹកក៏បង្អុរអំពីអាកាស រំលត់ជើងថ្ករ នៃព្រះមានព្រះភាគ ។ ទាំងមានទឹកខ្ពុរចេញ អំពីដើមសាលព្រឹក្ស រំលត់ជើងថ្ករ នៃព្រះមានព្រះភាគ ។ ទើបពួកមល្លក្សត្រ អ្នកក្រុងកុសិនារារំលត់ជើងថ្ករ នៃព្រះមានព្រះភាគ ដោយទឹកក្រអូបទាំងពួង ។ គ្រានោះ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា

---

១ អដ្ឋកថា ថា ជើងថ្ករនោះឆេះឡើងដោយអានុភាពនៃទេវតា ។ ២ អដ្ឋកថាថា នៅសល់តែព្រះអដ្ឋិធាតុ ប្រៀបដូចផ្កាម្លិះក្រពុំខ្លះ ដូចកែវមុក្តាដ៏ស្អាតខ្លះ ដូចកម្ទេចមាសខ្លះ ។

ភគវតោ សរីរានិ សត្តាហំ សណ្ឋាគារេ សត្តិបញ្ជរំ កត្វា[១] ធនុបាការំ បរិក្ខិបិត្វា នច្ចេហិ គីតេហិ វាទិតេហិ មាលេហិ គន្ធេហិ សក្ការឹសុ គរុការឹសុ មានេសុំ បូជេសុំ ។

[១៩៧] អស្សោសិ ខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ ភគវា កិរ កុសិនារាយំ បរិនិព្វុតោតិ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ កោសិនារកានំ មល្លានំ ទូតំ បាហេសិ ភគវាបិ ខត្តិយោ អហំបិ ខត្តិយោ អហំបិ អរហាមិ ភគវតោ សរីរានំ ភាគំ អហំបិ ភគវតោ សរីរានំ ថូបញ្ច មហញ្ច ករិស្សាមីតិ ។ អស្សោសុំ ខោ វេសាលិកា លិច្ឆវី ភគវា កិរ កុសិនារាយំ បរិនិព្វុតោតិ ។ អថខោ វេសាលិកា លិច្ឆវី កោសិនារកានំ មល្លានំ ទូតំ បាហេសុំ ភគវាបិ ខត្តិយោ មយម្បិ ខត្តិយា មយម្បិ

---

១ ឱ. ម. ករិត្វា ។

ក៏ធ្វើនូវការបញ្ជរលំពែង[១] រួចព័ទ្ធដោយកំពែងធ្នូ[២] ហើយធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះសរីរធាតុ របស់ព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ អស់ ៧ ថ្ងៃ ក្នុងសណ្ឋាគារដ្ឋាន ។

[១៥៧] ព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត បញ្ជូនរាជទូត ទៅកាន់សម្នាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកនៃព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសារីរធាតុ នៃព្រះមានព្រះភាគ ។ ពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលី ទ្រង់បានឮថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលី បញ្ជូនរាជទូតទៅកាន់សម្នាក់ នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើង

---

១ អដ្ឋកថា ថា ញ៉ាំងបុរសអ្នកកាន់លំពែងឲ្យឈរព័ទ្ធជុំវិញព្រះសរីរធាតុ ។ ២ ញ៉ាំងពួកដំរី ពួកសេះ ពួករថ ពួកយោធា ឲ្យឈរព័ទ្ធជុំវិញព្រះសរីរធាតុ ធ្នូក៏ច្រុះព័ទ្ធជុំវិញខាងក្រៅបង្អស់ ។

អរហាម ភគវតោ សរីរានំ ភាគំ មយម្បិ ភគវតោ សរីរានំ ថូបញ្ច មហញ្ច ករិស្សាមាតិ ។ អស្សោសុំ ខោ កាបិលវត្ថវា សក្យា ភគវា កិរ កុសិនារាយំ បរិនិព្វុតោតិ ។ អថខោ កាបិលវត្ថវា សក្យា កោសិនារកានំ មល្លានំ ទូតំ បាហេសុំ ភគវា អម្ហាកំ ញាតិសេដ្ឋោ មយម្បិ អរហាម ភគវតោ សរីរានំ ភាគំ មយម្បិ ភគវតោ សរីរានំ ថូបញ្ច មហញ្ច ករិស្សាមាតិ ។ អស្សោសុំ ខោ អល្លកប្បកា ថូលយោ[១] ភគវា កិរ កុសិនារាយំ បរិនិព្វុតោតិ ។ អថខោ អល្លកប្បកា ថូលយោ[២] កោសិនារកានំ មល្លានំ ទូតំ បាហេសុំ ភគវាបិ ខត្តិយោ មយម្បិ ខត្តិយា មយម្បិ អរហាម ភគវតោ សរីរានំ ភាគំ មយម្បិ ភគវតោ សរីរានំ ថូបញ្ច មហញ្ច ករិស្សាមាតិ ។ អស្សោសុំ ខោ រាមគាមកា កោឡិយា ភគវា កិរ កុសិនារាយំ បរិនិព្វុតោតិ ។ អថខោ រាមគាមកា កោឡិយា

១-២ ឱ. ម. ពុលយោ ។

គួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។ ពួកក្សត្រសក្យៈ អ្នកក្រុងកបិលវត្ថុ ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រសក្យៈ អ្នកក្រុងកបិលវត្ថុ បញ្ជូនរាជទូតទៅកាន់សម្នាក់ នៃពួកមល្លក្សត្រ អ្នកក្រុងកុ-សិនារាថា ព្រះមានព្រះភាគ ជាញាតិផ្ទាល់របស់យើង យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ។ ពួកក្សត្រថូលិ អ្នកក្រុងអល្លកប្បៈ ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រថូលិ អ្នកក្រុងអល្ល-កប្បៈ បញ្ជូនរាជទូតទៅកាន់សម្នាក់ នៃពួកមល្លក្សត្រ អ្នកនៅក្នុងក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។ ពួកក្សត្រកោ-ឡិយៈ អ្នកក្រុងរាមគ្រាម ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិ-និព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រកោឡិយៈ អ្នករាមគ្រាម

កោសិនារកានំ មល្លានំ ទូតំ បាហេសុំ ភគវាបិ ខត្តិយោ មយម្បិ ខត្តិយា មយម្បិ អរហាម ភគវតោ សរីរានំ ភាគំ មយម្បិ ភគវតោ សរីរានំ ថូបញ្ច មហញ្ច ករិស្សាមាតិ ។ អស្សោសិ ខោ វេដ្ឋទីបកោ ព្រាហ្មណោ ភគវា កិរ កុសិនារាយំ បរិនិព្វុតោតិ ។ អថខោ វេដ្ឋទីបកោ ព្រាហ្មណោ កោសិនារកានំ មល្លានំ ទូតំ បាហេសិ ភគវាបិ ខត្តិយោ អហម្បិ ព្រាហ្មណោ អហម្បិ អរហាមិ ភគវតោ សរីរានំ ភាគំ អហម្បិ ភគវតោ សរីរានំ ថូបញ្ច មហញ្ច ករិស្សាមីតិ ។ អស្សោសុំ ខោ បាវេយ្យកា មល្លា ភគវា កិរ កុសិនារាយំ បរិនិព្វុតោតិ ។ អថខោ បាវេយ្យកា មល្លា កោសិនារកានំ មល្លានំ ទូតំ បាហេសុំ ភគវាបិ ខត្តិយោ មយម្បិ ខត្តិយា មយម្បិ អរហាម ភគវតោ សរីរានំ ភាគំ មយម្បិ ភគវតោ សរីរានំ ថូបញ្ច មហញ្ច ករិស្សាមាតិ ។ ឯវំ វុត្តេ កោសិនារកា មល្លា តេ សង្ឃេ គណេ ឯតទវោចុំ ភគវា

បញ្ជូនរាជទូតទៅកាន់សម្នាក់ នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ។ ព្រាហ្មណ៍ដែលនៅក្នុងដែនវេដ្ឋទីបៈ បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបព្រាហ្មណ៍ដែលនៅក្នុងដែនវេដ្ឋទីបៈ បញ្ជូនទូតទៅកាន់សម្នាក់ នៃពួកមល្លក្សត្រអ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាព្រាហ្មណ៍ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ។ ពួកមល្លក្សត្រអ្នកក្រុងបាវា ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកមល្លក្សត្រអ្នកក្រុងបាវា បញ្ជូនរាជទូតទៅកាន់សម្នាក់ នៃពួកមល្លក្សត្រអ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ។ លុះពួកក្សត្រនិងព្រាហ្មណ៍ទាំងនោះ ពោលពាក្យយ៉ាងនេះហើយ ពួកមល្លក្សត្រអ្នកក្រុងកុសិនារា បានពោលទៅនឹងពួកគណៈទូតទាំងនោះ ដូច្នេះថា

អម្ហាកំ កាមក្ខេត្តេ បរិនិព្ពុតោ ន មយំ ឧស្សហាម ភគវតោ សរីរានំ ភាគន្តិ ។

[១៩៨] ឯវំ វុត្តេ ទោណោ ព្រាហ្មណោ តេ សង្ឃេ គណេ ឯតទវោច

សុណន្តុ ភោន្តោ មម ឯកវាក្យំ
អម្ហាក ពុទ្ធោ អហុ ខន្តិវាទោ
ន ហិ សាធុយំ ឧត្តមបុគ្គលស្ស
សរីរភាគេ[១] សិយ សម្បហារោ[២] ។
សព្វេវ ភោន្តោ សហិតា សមគ្គា
សម្មោទមានា ករោមដ្ឋ ភាគេ
វិត្ថារិកា ហោន្តុ ទិសាសុ ថូបា
ពហូ ជនា ចក្ខុមតោ បសន្នាតិ[៣] ។

---

១ ឱ. សរីរភង្គេ ។ ២ ម. សិយា សំបហារោ ។ ៣ ឱ. ពហុជ្ជនោ ចក្ខុមតោ បសន្នោតិ ។

ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងគាមក្ខេត្តរបស់យើង យើងនឹងមិនឲ្យនូវចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគឡើយ ។

[១៥៨] កាលបើពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះហើយ ទើបទោណព្រាហ្មណ៍ និយាយទៅនឹងពួកគណៈទូត ទាំងនោះដូច្នេះថា

លោកទាំងឡាយដ៏ចម្រើន សូមស្តាប់ពាក្យរបស់ខ្ញុំមួយម៉ាត់សិន ព្រះពុទ្ធជាម្ចាស់នៃយើង ព្រះអង្គជាខន្តិវាទ (អ្នកពោលសរសើរគុណនៃខន្តី) មែនពិត ការប្រហារគ្នា (ច្បាំងគ្នា) ព្រោះតែចំណែកនៃព្រះសរីរធាតុ របស់ឧត្តមបុគ្គលនេះ មិនប្រពៃឡើយ ។ បពិត្រលោកទាំងឡាយដ៏ចម្រើន យើងទាំងអស់គ្នា (គួរតែ) ស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែកព្រះសរីរធាតុឲ្យជា ៨ ចំណែក ព្រះស្តូបទាំង-ឡាយ សូមផ្សាយទៅក្នុងទិសទាំងឡាយចុះ ពួកជនច្រើនគង់ជ្រះថ្លាចំពោះព្រះសម្ពុទ្ធមានចក្ខុ មិនលែង ។

[១៥៩] តេនហិ ព្រាហ្មណ ត្វញ្ញេវ[១] ភគវតោ សរីរានិ អដ្ឋធា សមំ សុវិភត្តំ វិភជាហីតិ ។ ឯវំ ភោតិ ឯវំ ភោតិ ខោ ទោណោ ព្រាហ្មណោ តេសំ សង្ឃានំ គណានំ បដិស្សុណិត្វា[២] ភគវតោ សរីរានិ អដ្ឋធា សមំ សុវិភត្តំ វិភជិត្វា តេ សង្ឃេ គណេ ឯតទវោច ឥមំ មេ ភោន្តោ តុម្ពំ ទេន្តុ[៣] អហំបិ តុម្ពស្ស ថូបញ្ច មហញ្ច ករិស្សាមីតិ ។ អទំសុ ខោ តេ ទោណស្ស ព្រាហ្មណស្ស តុម្ពំ ។

[១៦០] អស្សោសុំ ខោ បិប្ផលិវនិយា មោរិយា ភគវា កិរ កុសិនារាយំ បរិនិព្វុតោតិ ។ អថខោ បិប្ផលិវនិយា មោរិយា កោសិនារកានំ មល្លានំ ទូតំ បាហេសុំ ភគវាបិ ខត្តិយោ មយម្បិ ខត្តិយា មយម្បិ អរហាម ភគវតោ សរីរានំ ភាគំ មយម្បិ ភគវតោ សរីរានំ ថូបញ្ច មហញ្ច ករិស្សាមាតិ ។

---

១ ឱ. ត្វំ យេវ ។ ម. ត្វញ្ញេវ ។ ២ បដិស្សុត្វាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៣ ឱ. ទទន្តុ ។

[១៥៩] ពួកក្សត្រនិងព្រាហ្មណ៍ទាំងនោះ ទទួលពាក្យថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរចែកព្រះសរីរធាតុនៃព្រះមានព្រះភាគ ឲ្យជា ៨ ចំណែកស្មើគ្នាចុះ ។ ទោណព្រាហ្មណ៍ ក៏ទទួលពាក្យរបស់ពួកគណៈទូតទាំងនោះ ដោយពាក្យថា អើអ្នកដ៏ចម្រើន អើអ្នកដ៏ចម្រើន ហើយក៏ចែកព្រះសរីរធាតុនៃព្រះមានព្រះភាគ ឲ្យជា ៨ ចំណែកស្មើភាគគ្នា ហើយនិយាយនឹងពួកគណៈទូតទាំងនោះ ដូច្នេះថា លោកទាំងឡាយដ៏ចម្រើន សូមលោកទាំងឡាយដ៏ចម្រើន ឲ្យតុម្ព[១]នេះ ដល់ខ្ញុំចុះ ខ្ញុំនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះតុម្ព ។ ពួកក្សត្រនិងព្រាហ្មណ៍ទាំងនោះ ក៏បានឲ្យតុម្ព ដល់ទោណព្រាហ្មណ៍ ។

[១៦០] ឯពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ក៏បញ្ជូនរាជទូតទៅកាន់សម្នាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។

---

១ ជាឈ្មោះរង្វាល់ម្យ៉ាងនៅប្រទេសឥណ្ឌាក្នុងកាលនោះ ។

ឯត្ថ ភគវតោ សរីរានំ ភាគោ វិភត្តានិ ភគវតោ សរីរានិ ឥតោ អង្គារំ ហរថាតិ ។ តេ តតោ អង្គារំ អាហរឹសុ ។

[១៦១] អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ រាជគហេ ភគវតោ សរីរានំ ថូបញ្ច មហញ្ច អកាសិ ។ វេសាលិកាបិ លិច្ឆវី វេសាលិយំ ភគវតោ សរីរានំ ថូបញ្ច មហញ្ច អកំសុ ។ កាបិលវត្ថវាបិ សក្យា កបិលវត្ថុស្មឹ ភគវតោ សរីរានំ ថូបញ្ច មហញ្ច អកំសុ ។ អល្លកប្បកាបិ ថូលយោ អល្លកប្បេ ភគវតោ សរីរានំ ថូបញ្ច មហញ្ច អកំសុ ។ រាមគ្គាមកាបិ កោឡិយា រាមគ្គាមេ ភគវតោ សរីរានំ ថូបញ្ច មហញ្ច អកំសុ ។ វេដ្ឋទីបកោបិ ព្រាហ្មណោ វេដ្ឋទីបេ ភគវតោ សរីរានំ ថូបញ្ច មហញ្ច អកាសិ ។

ពួកមល្លក្សត្រតបថា ចំណែកព្រះសរីរធាតុរបស់ព្រះមានព្រះភាគ មិនមានទេ ព្រះសរីរធាតុទាំងឡាយ របស់ព្រះមានព្រះភាគ យើងចែកគ្នាអស់ហើយ ចូរអ្នកទាំងឡាយ នាំយកព្រះអង្គារ (ធ្យូង) អំពីកន្លែងដែលថ្វាយព្រះភ្លើងនេះទៅចុះ ។ ពួកក្សត្រមោរិយៈទាំងនោះ ក៏នាំយកព្រះអង្គារអំពីកន្លែង ដែលថ្វាយព្រះភ្លើងនោះទៅ ។

[១៦១] គ្រានោះ ព្រះបាទមាគធអជាតសត្តុវេទេហិបុត្ត ទ្រង់បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងក្រុងរាជគ្រឹះ ។ ឯពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលី ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងក្រុងវេសាលី ។ ពួកក្សត្រអ្នកក្រុងកបិលវត្ថុ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងក្រុងកបិលវត្ថុ ។ ពួកក្សត្រថូលិ អ្នកក្រុងអល្លកប្បៈ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងក្រុងអល្លកប្បៈ ។ ពួកក្សត្រកោឡិយៈ អ្នករាមគ្រាម ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងរាមគ្រាម ។ ព្រាហ្មណ៍អ្នកវេដ្ឋទីបៈ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងដែនវេដ្ឋទីបៈ ។

ចាវេយ្យកាបិ មល្លា ចាវាយំ ភគវតោ សរីរានំ ថូបញ្ច មហញ្ច អកំសុ ។ កោសិនារកាបិ មល្លា កុសិនារាយំ ភគវតោ សរីរានំ ថូបញ្ច មហញ្ច អកំសុ ។ ទោណោបិ ព្រាហ្មណោ តុម្ពស្ស ថូបញ្ច មហញ្ច អកាសិ ។ បិប្ផលិវនិយាបិ មោរិយា បិប្ផ-លិវនេ អង្គារានំ ថូបញ្ច មហញ្ច អកំសុ ។ ឥតិ អដ្ឋ សរីរត្ថូបា[១] នវមោ តុម្ពត្ថូបោ ទសមោ អង្គា-រត្ថូបោ ឯវមេតំ ភូតបុព្វន្តិ ។

[១៦២] អដ្ឋទោណំ ចក្ខុមតោ សរីរំ
សត្តទោណំ ជម្ពុទីបេ មហេន្តិ
ឯកញ្ច ទោណំ បុរិសវរុត្តមស្ស
រាមគ្គាមេ នាគរាជា មហេន្តិ[២] ។
ឯកា ហិ[៣] ទាឋា តិទិវេហិ បូជិតា
ឯកា បន គន្ធារបុរេ មហិយ្យតិ

១ ឱ. អដ្ឋស្ស សរីរថូបា ។ ម. សរីរថូបា ។ ២ ម. មហេតិ ។ ៣ ឱ. ឯកាបិ ។

ពួកមល្លក្សត្រអ្នកក្រុងបាវា ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងក្រុងបាវា ។ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងក្រុងកុសិនារា ។ ទោណព្រាហ្មណ៍ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះតុម្ព ។ ពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះអង្គារ ក្នុងក្រុងបិប្ផលិវ័ន ។ រួមព្រះស្តូបតម្កល់ព្រះសរីរធាតុទាំងអស់មាន ៨ ជាគម្រប់ ៩ និងព្រះស្តូបដែលតម្កល់ព្រះតុម្ព ជាគម្រប់ ១០ និងព្រះស្តូបដែលតម្កល់ព្រះអង្គារ ឯធាតុនិធាន (ទីបញ្ចុះព្រះធាតុ) នេះ ធ្លាប់មានមកហើយយ៉ាងនេះ ។

[១៦២] ព្រះសរីរធាតុ របស់ព្រះសម្ពុទ្ធមានចក្ខុ មានចំនួន
៨ ទោណៈ[១] ព្រះសរីរធាតុ ៧ ទោណៈ ជនទាំងឡាយធ្វើ
សក្ការបូជាក្នុងជម្ពូទ្វីប ព្រះសរីរធាតុរបស់ព្រះសម្ពុទ្ធជាបុរស
ប្រសើរខ្ពង់ខ្ពស់ ១ ទោណៈទៀត ពួកនាគរាជធ្វើសក្ការបូជា
ក្នុងរាមគ្រាម ។ ព្រះទាឋា (ចង្កូម) ១ ពួកទេវតានាំយកទៅ
បូជា ព្រះទាឋា ១ ទៀត ពួកជនធ្វើសក្ការបូជាក្នុងគន្ធារបុរី

១ បួនក្ដាប់ ត្រូវជា ១ កុឌវៈ ៤ កុឌវៈ ត្រូវជា ១ បត្ថៈ (នាឡី) ៤ បត្ថៈ ត្រូវជា ១ អាឡ្ហកៈ ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ គឺទោណៈ ១ ត្រូវជា ១៦ នាឡិតូច ។

កាលិង្គរញ្ញោ វិជិតេ បុនេកំ
ឯកំ បុន នាគរាជា មហេន្តិ ។
តស្សេវ តេជេន អយំ វសុន្ធរា
អាយាគសេដ្ឋេហិ មហី អលង្កតា
ឯវំ ឥមំ ចក្ខុមតោ សរីរំ
សុសក្កតំ សក្កតសក្កតេហិ ។
ទេវិន្ទនាគិន្ទនរិន្ទបូជិតោ
មនុស្សិន្ទសេដ្ឋេហិ[១] តថេវ បូជិតោ
តំ តំ វន្ទថ បញ្ជលិកា ភវិត្វា
ពុទ្ធា[២] ហវេ កប្បសតេហិ ទុល្លភាតិ[៣] ។
ចត្តាឡីសសមា ទន្តា
កេសា លោមា ច សព្វសោ
ទេវា ហរឹសុ ឯកេកំ
ចក្កវាឡបរម្បរាតិ[៤] ។

មហាបរិនិព្វានសុត្តំ តតិយំ និដ្ឋិតំ[៥] ។

---

១ ឱ. មនុស្សសេដ្ឋេហិ ។ ២ ឱ. ម. ពុទ្ធោ ។ ៣ ឱ. ម. ទុល្លភោតិ ។ ៤ ឱ. អយំ គាថា ន ទិស្សតិ ។ ៥ ឱ. មហាបរិនិព្វានសុត្តន្តំ និដ្ឋិតំ ។

ព្រះទាឋា ១ ទៀត ពួកជនធ្វើសក្ការបូជា ក្នុងដែនរបស់ស្តេចកាលិង្គៈ ព្រះទាឋា ១ ទៀត ពួកនាគរាជនាំយកទៅធ្វើសក្ការបូជា ។ ហេតុតែតេជះ នៃព្រះសរីរធាតុរបស់ព្រះមានព្រះភាគនោះឯង មហាប្រឹថពីនេះ ក៏បានប្រដាប់ដោយគ្រឿងបូជាវិសេស ឯព្រះសរីរធាតុ របស់ព្រះសម្ពុទ្ធ មានចក្ខុនេះ គឺពួកសត្វ ដែលធ្លាប់ធ្វើនូវគ្រឿងសក្ការៈ ដ៏លើសលុបទាំង-ឡាយ បានធ្វើសក្ការៈ ដោយល្អហើយយ៉ាងនេះ ។ ស្តេចទេវ-តា ស្តេចនាគ និងស្តេចមនុស្ស បានបូជាហើយ ចំពោះព្រះសម្ពុទ្ធជាម្ចាស់ ទាំងពួកមនុស្សអ្នកប្រសើរ ក៏បានធ្វើបូជាព្រះអង្គហើយដូច្នោះដែរ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរផ្គងអញ្ជលីឡើង ថ្វាយបង្គំ ព្រះពុទ្ធជាម្ចាស់នោះចុះ ព្រោះថាព្រះពុទ្ធជាម្ចាស់ទាំងឡាយ ជាបុគ្គលរកបានក្រ ដោយរយនៃកប្បទាំងឡាយ ។ ព្រះទន្តទាំង ៤០ គត់ក្តី កេសាក្តី ព្រះលោមាក្តីទាំងអស់ ពួកទេវតាដែលនៅក្នុងចក្រវាឡត ៗ គ្នានាំយកទៅមួយ ៗ ម្នាក់ ។

ចប់ មហាបរិនិព្វានសូត្រទី ៣ ។

# សុត្តន្តបិដកេ ទីឃនិកាយស្ស

# តតិយោ ភាគោ

# **មហាវគ្គោ**

# មហាបទានសុត្តំ បឋមំ

*មាតិកា* *អង្កេ*

*មហាបទានសុត្តេ បឋមភាណវារំ សត្តសម្មាសម្ពុទ្ធប្បវត្តិ* ....................................... ៣

*ភគវតោ បុព្វេនិវាសានុស្សតិកថា* ....................... ១៥

*ពោធិសត្តស្ស ធម្មតាកថា* ................................. ២៣

*ទ្វត្តឹសមហាបុរិសលក្ខណកថា* ............................. ៣៣

*វិបស្សិប្បវត្តិកថា* .................................................. ៤១

*ទុតិយភាណវារំ វិបស្សិស្ស ឧយ្យានភូមិគមនំ* ................................. ៤៥

*បឋមទេវទូតទស្សនកថា* .................................... ៤៧

*ទុតិយទេវទូតទស្សនកថា* ................................... ៤៩

*ពន្ធុមបរិវិតក្កកថា* ................................................ ៥៣

*តតិយទេវទូតទស្សនកថា* .................................... ៥៥

# សុត្តន្តបិដក ទីឃនិកាយ

# តតិយភាគ

# មហាវគ្គ

# មហាបទានសូត្រទី ១

មាតិកា លេខទំព័រ


មហាបទានសូត្រ ភាណវារៈទី ១ ប្រវត្តិនៃព្រះសម្មាសម្ពុទ្ធ ៧ ព្រះអង្គ ................ ៣

ពោលអំពីបុព្វេនិវាសានុស្សតិរបស់ព្រះមានព្រះភាគ ...... ១៥

ពោលអំពីធម្មតារបស់ព្រះពោធិសត្វ .............................. ២៣

ពោលអំពីមហាបុរិសលក្ខណៈ ៣២ ប្រការ ................. ៣៣

ពោលអំពីប្រវត្តិរបស់ព្រះវិបស្សីកុមារ............................ ៤១

ភាណវារៈទី ២ ព្រះវិបស្សីកុមារស្តេចទៅកាន់ឧទ្យាន ................. ៤៥

ពោលអំពីការទតឃើញទេវទូតទី ១ ............................. ៤៧

ពោលអំពីការទតឃើញទេវទូតទី ២ ............................. ៤៩

ពោលអំពីព្រះតម្រិះរបស់ព្រះបាទពន្ធុមៈ ....................... ៥៣

ពោលអំពីការទតឃើញទេវទូតទី ៣ ............................. ៥៥

៣៥៣

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| មហាបទានសុត្តេ ទុតិយភាណវារំ ពន្ធុមបរិវិតក្កកថា............................................ | ៥៩ |
| បព្វជិតទស្សនកថា ............................................ | ៦១ |
| វិបស្សិស្ស បព្វជ្ជា............................................ | ៦៣ |
| វិបស្សិស្ស បរិវិតក្កោ ........................................ | ៦៥ |
| សមុទយវារប្បច្ចវេក្ខណា ................................... | ៦៧ |
| និរោធវារប្បច្ចវេក្ខណា ....................................... | ៧១ |
| បញ្ចុបាទានក្ខន្ធេសុ ឧទយព្វយានុ-<br>បស្សនា ..................................................... | ៧៥ |
| តតិយភាណវារំ វិបស្សិពុទ្ធបរិវិតក្កកថា ....................................... | ៧៧ |
| មហាព្រហ្មយាចនកថា....................................... | ៧៩ |
| លោកំ វោលោកនំ ............................................ | ៨១ |
| ព្រហ្មយាចនគាថា ............................................ | ៨៣ |
| ខណ្ឌាតិស្សវត្ថុ .................................................... | ៨៥ |
| ខណ្ឌាតិស្សវត្ថុ ធម្មចក្កុ ...................................... | ៨៧ |
| មហាជនកាយបរិវិតក្កកថា ................................ | ៨៩ |
| មហាជនកាយស្ស បព្វជ្ជូបសម្បទា .................. | ៩១ |

# សង្ខេបចង្អុលប្រាប់មាតិកា


| មាតិកា | លេខទំព័រ |
|---|---|
| មហាបទានសូត្រ ភាណវារៈទី ២ ពោលអំពីព្រះតម្រិះរបស់ព្រះបាទពន្ធុមៈ .......... | ៥៩ |
| ពោលអំពីការទតឃើញអ្នកបួស .................................. | ៦១ |
| ការទ្រង់ព្រះផ្នួសនៃព្រះវិបស្សីកុមារ .............................. | ៦៣ |
| ព្រះតម្រិះរបស់ព្រះវិបស្សីពោធិសត្វ .............................. | ៦៥ |
| ការទ្រង់ពិចារណាសមុទយវារៈ .................................... | ៦៧ |
| ការទ្រង់ពិចារណានិរោធវារៈ ........................................ | ៧១ |
| ការទ្រង់ពិចារណាការកើតនិងការរលត់ក្នុងឧបា-ទានក្ខន្ធ ៥ .......................................................... | ៧៥ |
| ភាណវារៈទី ៣ ពោលអំពីការទ្រង់ព្រះតម្រិះរបស់ព្រះពុទ្ធវិបស្សី ...... | ៧៧ |
| ពោលអំពីការអារាធនានៃមហាព្រហ្ម ............................ | ៧៩ |
| ការទ្រង់ប្រមើលមើលនូវសត្វលោក .............................. | ៨១ |
| គាថាជាពាក្យអារាធនានៃព្រហ្ម .................................... | ៨៣ |
| រឿងព្រះខណ្ឌរាជកុមារនិងតិស្សកុមារ .......................... | ៨៥ |
| រឿងព្រះខណ្ឌរាជកុមារនិងតិស្សកុមារ ធម្មចក្ក ........... | ៨៧ |
| ពោលអំពីសេចក្តីត្រិះរិះរបស់ពួកមហាជន .................... | ៨៩ |
| បព្វជ្ជា ឧបសម្បទារបស់ពួកមហាជន .......................... | ៩១ |

# មាតិកាបត្តានិ

| មាតិកា | អង្កេ |
|---|---|
| មហាបទានសុត្តេ តតិយភាណវារំ ចតុរាសីតិបព្វជិតសហស្សានំ ធម្មចក្ក ............ | ៩៣ |
| វិបស្សិពុទ្ធបរិវិតក្កោ ............ | ៩៥ |
| សាវកានំ ចារិកចរណកថា ............ | ៩៧ |
| ទេវតានំ សទ្ធានុស្សាវនំ ............ | ១០១ |
| បាតិមោក្ខុទ្ទិសនំ ............ | ១០៣ |
| ទេវតាបដិនិវេទនកថា ............ | ១០៥ |
| ធម្មជាតុ សុប្បដិវិទ្ធា ............ | ១១៥ |

# មហានិទានសុត្តំ ទុតិយំ

| | |
|---|---|
| មហាបទានសុត្តេ ពុទ្ធភាណវារំ បដិច្ចសមុប្បាទកថា ............ | ១១៩ |
| អកុសលធម្មានំ ហេតុប្បច្ចយកថា ............ | ១២៥ |
| ឆន្ទរាគាទីនំ ហេតុប្បច្ចយកថា ............ | ១២៩ |
| វេទនាយ ហេតុប្បច្ចយកថា ............ | ១៣១ |
| ផស្សាទីនំ ហេតុប្បច្ចយកថា ............ | ១៣៣ |

# សង្ខឹកចង្អុលច្រាប់មាតិកា

មាតិកា លេខទំព័រ

មហាបទានសូត្រ ភាណវារៈទី ៣ ធម្មចក្ខុរបស់បព្វជិតទាំង ៨ ហ្មឺន ៤ ពាន់ ........ ៩៣
ព្រះតម្រិះរបស់ព្រះពុទ្ធវិបស្សី ........ ៩៥
ពោលអំពីការត្រាច់ទៅកាន់ចារិកនៃពួកសាវ័ក ........ ៩៧
ការបន្ទឹស្ទូរសព្ទនៃពួកទេវតា ........ ១០១
ការទ្រង់សម្តែងបាតិមោក្ខ ........ ១០៣
ពោលអំពីការក្រាបបង្គំទូលនៃទេវតា ........ ១០៥
ធម្មធាតុដែលតថាគតបានជ្រាបច្បាស់ហើយ ........ ១១៥

# មហានិទានសូត្រទី ២

មហានិទានសូត្រ ពុទ្ធភាណវារៈ ពោលអំពីបដិច្ចសមុប្បាទ ........ ១១៩
ពោលអំពីហេតុនិងបច្ច័យនៃអកុសលធម៌ទាំងឡាយ ........ ១២៥
ពោលអំពីហេតុនៃធម៌ទាំងឡាយមានឆន្ទរាគជាដើម ........ ១២៩
ពោលអំពីហេតុបច្ច័យនៃវេទនា ........ ១៣១
ពោលអំពីហេតុបច្ច័យនៃធម៌ទាំងឡាយមានផស្សៈជាដើម ........ ១៣៣

# មាតិកាបត្តានិ

មាតិកា អង្កេ

*មហានិទានសុត្តេ ពុទ្ធភាណវារំ អត្តប្បញ្ញត្តិកថា* ........................................ *១៣៥*

*អត្តប្បញ្ញត្តិកថា* ........................................ *១៣៩*

*អត្តសមនុបស្សនាកថា* ........................................ *១៤១*

*វេទនត្តាសមនុបស្សនាកថា* ........................................ *១៤៥*

*សត្តវិញ្ញាណដ្ឋិតិកថា* ........................................ *១៤៧*

*អដ្ឋវិមោក្ខកថា* ........................................ *១៥១*

*ឧភតោភាគវិមុត្តិ* ........................................ *១៥៣*

# មហាបរិនិព្វានសុត្តំ តតិយំ

*មហាបរិនិព្វានសុត្តេ វជ្ជិភាណវារំ និទានកថា* ........................................ *១៥៥*

*វជ្ជីនំ សត្តអបរិហានិយធម្មកថា* ........................................ *១៥៧*

*ភិក្ខុភាណវារំ ភិក្ខូនំ សន្និបាតាបនំ* ........................................ *១៦៣*

*ភិក្ខូនំ សត្តអបរិហានិយធម្មា* ........................................ *១៦៥*

*ភិក្ខូនំ ឆអបរិហានិយធម្មា* ........................................ *១៧៣*

*ពុទ្ធភាណវារំ ភគវតោ អម្ពដ្ឋិកាយ ឧបសង្កមនំ* ........................................ *១៧៥*

# សន្លឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


មហានិទានសូត្រ ពុទ្ធភាណវារៈ ពោលអំពីបញ្ញត្តិខ្លួន ........................................ ១៣៥

ពោលអំពីបញ្ញត្តិខ្លួន ........................................ ១៣៩

ពោលអំពីការពិចារណាខ្លួន ........................................ ១៤១

ពោលអំពីការមិនពិចារណានូវវេទនាថាជាខ្លួន .............. ១៤៥

ពោលអំពីវិញ្ញាណដ្ឋិតិទាំង ៧ ........................................ ១៤៧

ពោលអំពីវិមោក្ខទាំង ៨ ........................................ ១៥១

ឧភតោភាគវិមុត្តិ ........................................ ១៥៣


# មហាបរិនិព្វានសូត្រទី ៣


មហាបរិនិព្វានសូត្រ វជ្ជីភាណវារៈ និទានកថា ........................................ ១៥៥

ពោលអំពីអបរិហានិយធម៌ទាំង ៧ របស់ពួកវជ្ជីក្សត្រិយ៍.... ១៥៧

ភិក្ខុភាណវារៈ ការទ្រង់ឲ្យប្រជុំភិក្ខុទាំងឡាយ ........................................ ១៦៣

អបរិហានិយធម៌ទាំង ៧ របស់ពួកភិក្ខុ ........................................ ១៦៥

អបរិហានិយធម៌ទាំង ៦ របស់ពួកភិក្ខុ ........................................ ១៧៣

ពុទ្ធភាណវារៈ ព្រះមានព្រះភាគស្តេចទៅកាន់អម្ពលដ្ឋិកាឧទ្យាន .......... ១៧៥

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ ពុទ្ធគុណានុយោគកថា | ១៧៧ |
| សិក្ខាត្តយានិសំសកថា | ១៨១ |
| ភគវតោ អាវសថាគារូបសង្កមនំ | ១៨៣ |
| បញ្ចសីលវានិសំសកថា | ១៨៥ |
| បាដលិគ្គាមេ នគរមាបនកថា | ១៨៧ |
| សុនីធវស្សការវត្ថុ | ១៨៩ |
| អនុមោទនាគាថា | ១៩១ |
| ភគវតោ ឧទានំ | ១៩៣ |
| ចតុរារិយសច្ចទេសនា | ១៩៥ |
| សាវកានំ គតិបុច្ឆា | ១៩៧ |
| សាវកានំ គតិព្យាករណំ | ១៩៩ |
| ធម្មាទាសធម្មបរិយាយទេសនា | ២០១ |
| ចតុស្សតិប្បដ្ឋានទេសនា | ២០៣ |
| អម្ពបាលិគណិកាវត្ថុ | ២០៥ |
| លិច្ឆវិវត្ថុ | ២០៧ |

# សង្ខិកចង្អុលប្រាប់មាតិកា


| មាតិកា | លេខទំព័រ |
|---|---|
| មហាបរិនិព្វានសូត្រ ពុទ្ធភាណវារៈ ពោលអំពីការសាកសួរព្រះពុទ្ធគុណ.............. | ១៧៧ |
| ពោលអំពីអានិសង្សនៃត្រៃសិក្ខា.................................... | ១៨១ |
| ព្រះមានព្រះភាគ ស្តេចចូលទៅកាន់សម្នាក់................ | ១៨៣ |
| ពោលអំពីអានិសង្សនៃបុគ្គលមានសីលមាន ៥ ប្រការ.. | ១៨៥ |
| ពោលអំពីការសាងក្រុងក្នុងបាដលិគ្រាម....................... | ១៨៧ |
| រឿងសុនីធៈនិងវស្សការព្រាហ្មណ៍................................ | ១៨៩ |
| អនុមោទនាគាថា........................................................ | ១៩១ |
| ព្រះឧទានរបស់ព្រះមានព្រះភាគ.................................. | ១៩៣ |
| ការទ្រង់សម្តែងចតុរារិយសច្ច........................................ | ១៩៥ |
| ការក្រាបបង្គំទូលសួរគតិរបស់ពួកសាវ័ក....................... | ១៩៧ |
| ការទ្រង់ព្យាករណ៍គតិរបស់ពួកសាវ័ក........................... | ១៩៩ |
| ការទ្រង់សម្តែងធម្មបរិយាយឈ្មោះធម្មាទាសៈ............... | ២០១ |
| ការទ្រង់សម្តែងសតិប្បដ្ឋាន ៤...................................... | ២០៣ |
| រឿងស្រីផ្កាមាសឈ្មោះអម្ពបាលី.................................... | ២០៥ |
| រឿងស្តេចលិច្ឆវី.............................................................. | ២០៧ |

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| *មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ អម្ពបាលិកាយ បរិវេសនគមនំ* ........................ | ២០៩ |
| *ភគវតោ ខរាពាធុប្បត្តិ* ...................................... | ២១១ |
| *អានន្ទត្ថេរាវព្ភកថនំ* ............................................ | ២១៣ |
| *ភគវតោ ចាបាលចេតិយូបសង្កមនំ* .................... | ២១៥ |
| *ចតុរិទ្ធិបាទានុភាវកថា* ........................................ | ២១៧ |
| *ភគវតោ បរិនិព្វានយាចនកថា*........................... | ២១៩ |
| *អាយុសង្ខារឱស្សជ្ជនំ* ........................................... | ២២៥ |
| *ភូមិចាលហេតុកថា*............................................... | ២២៧ |
| *អដ្ឋបរិសាកថា*....................................................... | ២២៩ |
| *អដ្ឋាភិភាយតនកថា* .............................................. | ២៣១ |
| *អដ្ឋវិមោក្ខា មារវត្ថុ*.............................................. | ២៣៧ |
| *ចតុព្ពុទ្ធបរិសាកថា* ............................................... | ២៣៩ |
| *ឥទ្ធិបាទានុភាវកថា*.............................................. | ២៤៥ |

# សង្ខឹកចង្អុលប្រាប់មាតិកា


| មាតិកា | លេខទំព័រ |
|---|---|
| មហាបរិនិព្វានសូត្រ ពុទ្ធភាណវារៈ ការស្តេចទៅកាន់ទីអង្គាសរបស់នាងអម្ពបាលី ..... | ២០៩ |
| ព្រះមានព្រះភាគទ្រង់មានអាពាធដ៏ក្លៀវក្លា.................... | ២១១ |
| ទ្រង់មានព្រះពុទ្ធដីកាប្រារព្ធនឹងព្រះអានន្ទត្ថេរ .............. | ២១៣ |
| ព្រះមានព្រះភាគ ស្តេចចូលទៅកាន់បាវាលចេតិយ ...... | ២១៥ |
| ពោលអំពីអានុភាពនៃឥទ្ធិបាទទាំង ៤ .......................... | ២១៧ |
| ពោលអំពីការក្រាបទូលអារាធនាឲ្យព្រះមានព្រះភាគ បរិនិព្វាន ............................................................. | ២១៩ |
| ការទ្រង់ដាក់អាយុសង្ខារ ................................................ | ២២៥ |
| ពោលអំពីហេតុនៃការកក្រើកផែនដី.............................. | ២២៧ |
| ពោលអំពីបរិស័ទ ៨ ពួក .............................................. | ២២៩ |
| ពោលអំពីអភិភាយតនៈទាំង ៨ .................................... | ២៣១ |
| វិមោក្ខ ៨ រឿងក្រុងមារ................................................. | ២៣៧ |
| ពោលអំពីពុទ្ធបរិស័ទ ៤ ពួក ........................................ | ២៣៩ |
| ពោលអំពីអានុភាពរបស់ឥទ្ធិបាទ .................................. | ២៤៥ |

# មាតិកាបត្តាជិ


| មាតិកា | អង្គេ |
|---|---|
| មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ សំវេជនីយកថា | ២៥១ |
| ភិក្ខុសង្ឃសន្និបាតាបនំ | ២៥៣ |
| អភិញ្ញាទេសិតធម្មកថា | ២៥៥ |
| វេសាលិយា បច្ឆិមទស្សនំ | ២៥៧ |
| ចតុរារិយធម្មកថា | ២៥៩ |
| ចាតុម្មហាទេសកថា | ២៦១ |
| ចុន្ទកម្មារបុត្តវត្ថុ | ២៦៧ |
| លោហិតប្បក្ខន្ទិកាពាធោ | ២៧១ |
| អច្ឆរិយព្ភុតកថា | ២៧៣ |
| បុក្កុសស្ស ឧបាសកត្តទេសនា | ២៨១ |
| អច្ឆរិយព្ភុតកថា | ២៨៣ |
| កកុធនទីគមនកថា | ២៨៥ |
| មហាប្ផលតរទ្វិបិណ្ឌបាតកថា | ២៨៧ |
| តថាគតបូជាកថា | ២៨៩ |

# សន្ទឹកាចង្អុលប្រាប់មាតិកា


| មាតិកា | លេខទំព័រ |
| --- | --- |
| មហាបរិនិព្វានសូត្រ ពុទ្ធភាណវារៈ ពោលអំពីសំវេជនីយធម៌................................ | ២៥១ |
| ការទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ..................................... | ២៥៣ |
| ពោលអំពីអភិញ្ញាទេសិតធម៌ ............................... | ២៥៥ |
| ការទ្រង់ទតក្រុងវេសាលី ជាបច្ឆិមទស្សនៈ ......... | ២៥៧ |
| ពោលអំពីអរិយធម៌ ៤ ....................................... | ២៥៩ |
| ពោលអំពីមហាបទេសទាំង ៤ ........................... | ២៦១ |
| រឿងនាយចុន្ទកម្មារបុត្ត ....................................... | ២៦៧ |
| ព្រះលោហិតប្បក្ខន្ទិកាពាធ.................................. | ២៧១ |
| ពោលអំពីហេតុជាអស្ចារ្យចម្លែក.......................... | ២៧៣ |
| ការសម្តែងខ្លួនជាឧបាសក នៃបុក្កុសមល្លបុត្ត ..... | ២៨១ |
| ពោលអំពីហេតុជាអស្ចារ្យចម្លែក.......................... | ២៨៣ |
| ពោលអំពីពុទ្ធដំណើរទៅកាន់ស្ទឹងកកុធៈ............. | ២៨៥ |
| ពោលអំពីចង្ហាន់បិណ្ឌបាតទាំង ២ ដែលមានផល-ច្រើនជាង ..................................................... | ២៨៧ |
| ពោលអំពីការបូជាចំពោះតថាគត ....................... | ២៨៩ |

# មាតិកាបត្តានិ

| មាតិកា | អង្កេ |
|---|---|
| មហាបរិនិព្វានសុត្តេ ពុទ្ធភាណវារំ ឧបវាណវត្ថុ .................................................. | ២៩១ |
| ទេវតាកន្ទនកថា................................................ | ២៩៣ |
| ចតុសំវេជនីយដ្ឋានកថា .................................... | ២៩៥ |
| ចក្កវត្តិសរីរប្បដិបជ្ជនកថា.................................. | ២៩៧ |
| ចតុត្ថូបារហកថា................................................ | ២៩៩ |
| អានន្ទត្ថេរាមន្តាបនំ ........................................... | ៣០១ |
| អានន្ទេ ចតុរច្ឆរិយព្ភុតធម្មកថា ......................... | ៣០៣ |
| ចក្កវត្តិម្ហិ ចតុរច្ឆរិយព្ភុតធម្មកថា......................... | ៣០៥ |
| កុសាវតីរាជធានីកថា.......................................... | ៣០៧ |
| កោសិនារកមល្លារោចនកថា............................... | ៣០៩ |
| សុភទ្ទបរិព្វាជកវត្ថុ............................................. | ៣១១ |
| ឆតិត្ថករកថា ..................................................... | ៣១៥ |
| សុភទ្ទស្ស ធម្មទេសនា ...................................... | ៣១៧ |
| សុភទ្ទស្ស បព្វជ្ជូបសម្បទា ................................ | ៣១៩ |

# សង្ខេបកថាផ្ទុលប្រាប់មាតិកា

មាតិកា លេខទំព័រ

មហាបរិនិព្វានសូត្រ ពុទ្ធភាណវារៈ រឿងឧបវាណភិក្ខុ........................................ ២៩១
ពោលអំពីសេចក្តីកន្ទក់កន្ទេញរបស់ទេវតា.................... ២៩៣
ពោលអំពីសំវេជនីយដ្ឋាន ៤ កន្លែង ............................ ២៩៥
ពោលអំពីការប្រតិបត្តិក្នុងព្រះសរីរៈ របស់ព្រះ-
ចក្រពត្តិរាជ........................................................ ២៩៧
ពោលអំពីថូបារហបុគ្គល ៤ ពួក ................................ ២៩៩
ទ្រង់ឲ្យត្រាស់ហៅព្រះអានន្ទត្ថេរ .................................. ៣០១
ពោលអំពីអច្ឆរិយព្ភុតធម៌ ៤ យ៉ាង ក្នុងព្រះអានន្ទត្ថេរ ... ៣០៣
ពោលអំពីអច្ឆរិយព្ភុតធម៌ ៤ យ៉ាង ក្នុងព្រះចក្រពត្តិរាជ.. ៣០៥
ពោលអំពីរាជធានីឈ្មោះកុសាវតី................................. ៣០៧
ពោលអំពីការថ្វាយដំណឹង ដល់មល្លក្សត្រិយ៍ នៅ-
ក្រុងកុសិនារា ...................................................... ៣០៩
រឿងសុភទ្ទបរិព្វាជក..................................................... ៣១១
ពោលអំពីគ្រូអ្នកធ្វើលទ្ធិដូចជាកំពង់ទាំង ៦ នាក់ ........ ៣១៥
ការទ្រង់សម្តែងធម៌ ដល់សុភទ្ទបរិព្វាជក...................... ៣១៧
បព្វជ្ជានិងឧបសម្បទា របស់សុភទ្ទបរិព្វាជក ................ ៣១៩

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| មហាបរិនិព្វានសុត្តេ  បរិនិព្វានភាណវារំ  ភគវតោ  បច្ឆិមវាចា | ៣២១ |
| ភគវតោ  បរិនិព្វានំ | ៣២៥ |
| បរិនិព្វានារោចនា | ៣៣១ |
| អដ្ឋ  មល្លបាមោក្ខា | ៣៣៣ |
| តថាគតសរីរជ្ឈាបនំ | ៣៣៥ |
| មហាកស្សបត្ថេរវត្ថុ | ៣៣៧ |
| អជាតសត្តុរាជាទិវត្ថុ | ៣៤៣ |
| ភគវតោ  សរីរវិភាគោ | ៣៤៧ |
| ពុទ្ធសារីរិកគាថា | ៣៤៩ |

# សង្ខឹកាចង្អុលប្រាប់មាតិកា

| មាតិកា | លេខទំព័រ |
|---|---|


*មហាបរិនិព្វានសូត្រ បរិនិព្វានភាណវារៈ ព្រះបច្ឆិមវាចារបស់ព្រះមានព្រះភាគ ..... ៣២១*

*ការបរិនិព្វាននៃព្រះមានព្រះភាគ ................................. ៣២៥*

*ការថ្វាយដំណឹងបរិនិព្វាន ............................................ ៣៣១*

*មល្លក្សត្រិយ៍ជាប្រធាន ៨ អង្គ ..................................... ៣៣៣*

*ការថ្វាយព្រះភ្លើងព្រះសរីរៈ របស់ព្រះតថាគត ........... ៣៣៥*

*រឿងព្រះមហាកស្សបត្ថេរ .............................................. ៣៣៧*

*រឿងព្រះបាទអជាតសត្តុជាដើម .................................... ៣៤៣*

*ការចែកព្រះសរីរធាតុ របស់ព្រះមានព្រះភាគ ............. ៣៤៧*

*ពុទ្ធសារីរិកគាថា ........................................................... ៣៤៩*

